# ផលទាក់ទងនៃមូលធនមនុស្ស លើកំណើនសេដ្ឋកិច្ចនៅកម្ពុជា ក្នុងពេលអនាគត

## ធាតុនានានៃសំណើផែនទីយុទ្ធសាស្ត្រ (Roadmap)

UNDP
Cambodia







ឯកសារពិភាក្សាលេខ ៨

២០១១

**រូបថតក្របមុខ :**

រូបខាងឆ្វេងលើ : *© UNDP Cambodia/Arantxa Cedillo*

រូបខាងឆ្វេងក្រោម : *© UNDP Cambodia/Isabelle Lesser*

ខាងស្តាំ : *© UNDP Cambodia/Gregory Lavender*

រក្សាសិទ្ធិ ឆ្នាំ ២០១១ យូអិនឌីភីកម្ពុជា

ផលទាក់ទងនៃមូលធនមនុស្សលើកំណើនសេដ្ឋកិច្ចនៅកម្ពុជាក្នុងពេលអនាគតៈ ធាតុនានានៃសំណើផែនទីយុទ្ធសាស្ត្រ *(Roadmap)*

## សេចក្តីប្រកាសបដិសេធ

ការទទួលខុសត្រូវចំពោះមតិយោបល់ នៅក្នុងឯកសារនេះជាបន្ទុកផ្តាច់មុខរបស់អ្នកនិពន្ធ ។ឯកសារនេះមិនឆ្លុះបញ្ចាំងពីគំនិតរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ *(យូអិនឌីភី)* ឬស្ថាប័ននានា នៃអង្គការសហប្រជាជាតិឡើយ ។

# ផលទាក់ទងនៃមូលធនមនុស្ស លើកំណើនសេដ្ឋកិច្ចនៅកម្ពុជា ក្នុងពេលអនាគត ៖

## ធាតុនានានៃសំណើផែនទីយុទ្ធសាស្ត្រ (Roadmap)

ឯកសារពិភាក្សាលេខ ៨ ផ្តល់មូលនិធិដោយ យូអិនឌីភី (UNDP)
ក្នុងកិច្ចសហប្រតិបត្តិការជាមួយ
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

# មាតិកា

**អក្សរកាត់** ..... VI
**បុព្វកថា** ..... ១
**សេចក្តីថ្លែងអំណរគុណ** ..... ៣
**ខ្លឹមសារសង្ខេប** ..... ៥

**ជំពូក ១ : មូលធនមនុស្ស និងកំណើនសេដ្ឋកិច្ច** ..... ១៥
១.១. សេចក្តីផ្តើម ..... ១៥
១.២. មូលធនមនុស្ស និងសេដ្ឋកិច្ចពុទ្ធិ និងកំណើនសេដ្ឋកិច្ច : ឆ្ពោះទៅរបត់ថ្មី ..... ១៦
១.៣. សមាសធាតុនៃសេដ្ឋកិច្ចពុទ្ធិ ..... ២៣
១.៤. មូលធនមនុស្ស ពិពិធកម្មសេដ្ឋកិច្ច និងការស្តារសេដ្ឋកិច្ចនៅកម្ពុជា ..... ២៦
១.៥ ការរៀបចំជំពូកនៃរបាយការណ៍នេះ ..... ២៧

**ជំពូកទី ២: មូលធនមនុស្សនៅកម្ពុជាបច្ចុប្បន្ន** ..... ២៩
២.១ ប្រជាសាស្ត្រ ..... ៣០
២.២ អន្តោប្រវេសន៍ ..... ៣២
២.៣ អត្រាចូលសាលា អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា ..... ៣៤
២.៤ គុណភាព និងកម្រិតនៃការអប់រំ និងការបណ្តុះបណ្តាល ..... ៣៨
២.៥ និន្នាការការងារ ..... ៤០
២.៦ អសង្គតិភាព រវាងការអប់រំ និងការងារ ..... ៤៧
២.៧ សាកលវិទ្យាល័យ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ..... ៤៩
២.៨ ភាពខុសគ្នាថ្នាក់តំបន់ ..... ៥៣
២.៩ បញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងសម្រាប់អនាគត ..... ៥៤

**ជំពូកទី ៣ : ពិពិធកម្មឧស្សាហកម្ម និងឱនភាពនៃមូលធនមនុស្ស** ..... ៥៧
៣.១ លំនាំដើម ..... ៥៧
៣.២ ការដោះស្រាយភាពខ្វះចន្លោះនៃជំនាញ ..... ៥៨
៣.៣ ទិដ្ឋភាពរួមនៃកម្លាំងពលកម្មក្នុងប្រទេសកម្ពុជា ..... ៦១
៣.៤ អន្តរាគមន៍ថ្មីៗដើម្បីបំពេញការខ្វះចន្លោះនៃចំណេះដឹង និងជំនាញក្នុងចំណោមនិយោជិតនៅកម្ពុជា ..... ៧៥

**ជំពូក ៤ :មូលធនមនុស្សក្នុងរដ្ឋាភិបាល និងវិស័យមិនរកប្រាក់ចំណេញនៅកម្ពុជា** ..... ៧៩
៤.១ សេចក្តីផ្តើម ..... ៧៩
៤.២ សមត្ថភាពប្រកួតប្រជែង កំណើនសេដ្ឋកិច្ច និងស្ថានភាពអភិវឌ្ឍន៍ ..... ៨០
៤.៣ ប្រទេសនិងការបង្កើតសេដ្ឋកិច្ចពុទ្ធិ ..... ៨៣
៤.៤ តថភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍមូលធនមនុស្ស ..... ៨៥
៤.៥ តួនាទីនៃការអភិវឌ្ឍមនុស្សក្នុងការវិនិយោគមូលធនមនុស្សនៅកម្ពុជា ..... ៩១
៤.៦ មូលធនមនុស្ស និងការទំនាក់ទំនងរវាងសង្គមស៊ីវិល-រដ្ឋ ..... ៩៥
៤.៧ សេចក្តីសន្និដ្ឋាន ..... ៩៧

**ជំពូកទី៥ :ធាតុផ្សំនៃផែនទីយុទ្ធសាស្ត្រមួយស្តីពីមូលធនមនុស្សនៅកម្ពុជា** ..... ៩៩
៥.១ តើមានផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្សនៅកម្ពុជាដែរឬទេ? ..... ៩៩
៥.២ កិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាល (កម្មវិធីរដ្ឋាភិបាលដែលមានស្រាប់) ..... ១០១
៥.៣ គំនិតផ្តួចផ្តើមរបស់វិស័យឯកជន និងគំនិតផ្តួចផ្តើមរួមរវាងឯកជន និងរដ្ឋាភិបាល ..... ១០៧
៥.៤ កិច្ចផ្តួចផ្តើមរបស់ទីភ្នាក់ងារអន្តរជាតិ និងម្ចាស់ជំនួយ ..... ១១១

**ជំពូកទី៦ :ផែនទីយុទ្ធសាស្ត្រមូលធនមនុស្សសម្រាប់កម្ពុជា និងហេតុផលសុទិដ្ឋិនិយម** ..... ១១៧
៦.១ អន្តរាគមន៍រយៈពេលខ្លី ..... ១១៧
៦.២ អន្តរាគមន៍រយៈពេលខ្លីដល់រយៈពេលវែង ..... ១២៤
៦.៣. អន្តរាគមន៍រយៈពេលវែង ..... ១២៨
៦.៤ ផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្សនៅកម្ពុជា ..... ១៣៣

**ឯកសារពិគ្រោះយោបល់** ..... ១៣៩
**ឧបសម្ព័ន្ធ** ..... ១៤៩
ឧបសម្ព័ន្ធ ១ : យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា : បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ ..... ១៤៩
ឧបសម្ព័ន្ធ ២ : ប្រទេសកម្ពុជាក្នុងផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្ស និងអន្តរាគមន៍ដែលអាចធ្វើទៅបាន ..... ១៥៧
ឧបសម្ព័ន្ធស្ថិតិ ..... ១៨៣

# រូបភាព


រូប ១. ១ ការបែងចែកកម្លាំងពលកម្មក្នុងបណ្តាញផលិតកម្មសកល ........ ១៩
រូប ២.១ : អត្រាអ្នកតាមហួបកំណត់តាមឆ្នាំ ........ ៣១
រូប ២.២ : ពីរ៉ាមីតអាយុប្រជាជនកម្ពុជា ........ ៣១
រូប ២.៣ : ការព្យាករពីកំណើនកម្លាំងពលកម្មក្នុងប្រទេសកម្ពុជាពីឆ្នាំ២០០៧-២០១៦ (%) ........ ៣២
រូប ២.៤ : ភាគរយនៃការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនក្នុងអំឡុងពេលបីដង
គឺពីឆ្នាំ ១៩៨០-១៩៩៣ ........ ៣៣
រូប ២.៥ : អត្រាចុះឈ្មោះចូលរៀនពិតនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ
ក្នុងខេត្តនីមួយៗ ២០០៩ - ២០១០ ........ ៣៥
រូប ២.៦ : ស្ថានភាពការបោះបង់ការសិក្សារបស់យុវជន និងការអប់រំ ឆ្នាំ២០០៧ ........ ៣៦
រូប ២.៧ : ចំនួនសិស្សរៀនត្រួតថ្នាក់នៅគ្រប់កម្រិតនៅមធ្យមសិក្សា ........ ៣៦
រូប ២.៨ : ការបញ្ចប់ការអប់រំរបស់ប្រជាជនពេញវ័យ ២០០៤ - ២០០៧ ........ ៣៨
រូប ២.៩ : អត្រាចុះឈ្មោះចូលរៀនពិត (%) ........ ៣៩
រូប ២.១០ : សមាសធាតុកំណើនផលិតផលក្នុងស្រុកសរុបឆ្នាំ២០០១-២០០៨ ........ ៤០
រូប ២.១១ : អត្រាចូលរួមក្នុងកម្លាំងពលកម្ម សម្រាប់និយោជិតអាយុចាប់ពី ១៥ ឆ្នាំ (គិតជា%) ........ ៤០
រូប ២.១២ : សមាមាត្រនៃការងារដែលងាយបង្គគ្រោះថ្នាក់ក្នុងចំណោមការងារទាំងអស់ ........ ៤៥
រូប ២.១៣ : លទ្ធផលក្នុងនិយោជិតម្នាក់នៅតាមប្រទេសក្នុងតំបន់អាស៊ាន ឆ្នាំ២០០៨ ........ ៤៦
រូប ២.១៤ : ការអប់រំធ្វើឱ្យប្រាក់ចំណូលមានភាពខុសគ្នាបន្តិចបន្តួច
លើកលែងក្រុមអ្នកមានបំផុត ........ ៤៩
រូប ២.១៥ : ទីតាំងសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា ........ ៥០
រូប ២.១៦ : ផលចំណេញធៀបនឹងអាយុ និងការអប់រំក្នុងតំបន់អាស៊ីខាងកើត ឆ្នាំ២០០៤ ........ ៥៤
រូប ៣.១: វិធីសាស្ត្របណ្តុះបណ្តាលដែលត្រូវការជាចាំបាច់ក្នុងប្រទេសកម្ពុជា
ដើម្បីលើកកម្ពស់ ផលិតភាពរបស់និយោជិត ........ ៦០
រូប ៣.២ : អសង្គតិភាពនៃជំនាញ រវាងតម្រូវការរបស់និយោជក
និងការបណ្តុះបណ្តាលយោងតាមនិយោជក (ឆ្នាំ២០០៩) ........ ៦១
រូប ៣.៣ : ការបង្កើតការងារ នៅទូទាំងវិស័យ ឆ្នាំ២០០១-២០០៨ ........ ៦១
រូប ៣.៤ : ជំនាញដែលនិយោជិតកម្ពុជាភាគច្រើនខ្វះខាត ........ ៦៣
រូប ៣.៥ : កង្វះខាតជំនាញដ៏ចម្បងក្នុងវិស័យកាត់ដេរនៅកម្ពុជា ........ ៦៥
រូប ៣.៦ : ការខ្វះចន្លោះធំៗនៃជំនាញក្នុងវិស័យបដិសណ្ឋារកិច្ចនៅកម្ពុជា ........ ៦៩
រូប ៣.៧ : បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍នៅកម្ពុជា ធៀបនឹងប្រទេសផ្សេងៗ
នៅបណ្តាប្រទេសអាស៊ាន ........ ៧៤
រូប ៤.១ សកលវិទ្យាល័យដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងនានា ........ ៨៦
រូប ៤.២ វិសមភាពសេដ្ឋកិច្ចប្រទេសនៅតំបន់អាស៊ីដែលបានជ្រើសរើស ........ ៩២

# តារាង


តារាង ២.១ : អត្រាអន្តោប្រវេសន៍របស់ប្រជាជនទីក្រុង និងជនបទដោយបែងចែកតាមប្រភេទ ក្នុងចន្លោះអាយុ ៥ឆ្នាំ និងភេទ ឆ្នាំ២០០៤ ..... ៣៣

តារាង ២.២: អត្រាចុះឈ្មោះចូលរៀនពិត/អត្រាចូលសាលានៅបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ តាមតំបន់ និងភេទ គិតជាភាគរយ ឆ្នាំ២០០៧ ..... ៣៥

តារាង ២.៣ : កម្លាំងពលកម្ម និងអត្រាចូលរួមក្នុងកម្លាំងពលកម្ម (%) ..... ៤១

តារាង ២.៤: ការងារបែងចែកតាមកម្រិតនៃការបញ្ចប់ការអប់រំ និងតាមភេទ ..... ៤២

តារាង ២.៥: ការងារតាមវិស័យ អាយុ និងតាមភេទ ..... ៤៤

តារាង ២.៦: តម្រូវការការងារតាមរយៈគម្រោងវិនិយោគ គិតតាមវិស័យ ឆ្នាំ២០០៨ ..... ៤៥

តារាង ២.៧ : ផលិតភាពការងារ តាមឧស្សាហកម្ម (តម្លៃបន្ថែមសម្រាប់មនុស្សម្នាក់ ដែលមានការងារធ្វើ តម្លៃថេរនៅឆ្នាំ២០០០) ..... ៤៦

តារាង ២.៨: ស្ថានភាពការងាររបស់ប្រជាជន អាយុចាប់ពី ១០ឆ្នាំឡើងទៅ ឆ្នាំ២០០៤ និង២០០៧ (ភាគរយ) ..... ៤៧

តារាង ២.៩: ប្រាក់ចំណូលជាមធ្យមតាមកម្រិតអប់រំសម្រាប់យុវជន (ដុល្លារ/ខែ) ..... ៤៨

តារាង ២.១០: ការចុះឈ្មោះចូលរៀនសរុបតាមមុខវិជ្ជាសិក្សានៅគ្រឹះស្ថានអប់រំឧត្តមសិក្សា សាធារណៈ និងឯកជន ..... ៥១

តារាង ២.១១: តួលេខសិស្សចុះឈ្មោះចូលរៀននៅឧត្តមសិក្សា និងការអប់រំ និងបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ នៅកម្ពុជា ..... ៥២

តារាង ២.១២: អត្រាចុះឈ្មោះចូលរៀនសរុបនៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ធៀបនឹងប្រទេស ផ្សេងទៀតនៅតំបន់អាស៊ាន ..... ៥៣

តារាង ២.១៣: ហេតុផលមិនចូលសាលាក្នុងចំណោមកុមារ និងយុវជនអាយុពី ៥-១៧ឆ្នាំ ដែលមិនបានចូលសាលា គិតតាមភេទ ឆ្នាំ២០០៧ (%) ..... ៥៥

តារាង ៣.១ : ចំនួនប្រជាជនសរុបបម្រើការងារផ្ទាល់ក្នុងវិស័យទេសចរណ៍ ..... ៦៨

តារាង ៤.១ ប្រវត្តិនៃវិសាលភាពសេវាសាធារណៈ តាមប្រភេទ ក/ខ/ ..... ៨០

តារាង ៤.២ ចំណាយសាធារណៈគិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប និងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ..... ៨១

តារាង ៤.៣ ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍក្នុងប្រទេសដែលបានជ្រើសរើស ឆ្នាំ២០០០ និង ២០០៧ ..... ៨៤

តារាង ៤.៤ ការចំណាយសាធារណៈរបស់អប់រំលើការអប់រំឧត្តមសិក្សា គិតជា%នៃការចំណាយ ក្នុងវិស័យអប់រំ សាធារណៈសរុប ឆ្នាំ២០០០ និង ២០០៧ ..... ៨៤

តារាង ៤.៥ អត្រាប៉ាន់ស្មាននៃភាពក្រីក្រនៅកម្ពុជាតាមរយៈការគណនាតាមបណ្តាខេត្ត ពីទិន្នន័យគោលឃុំ ..... ៩៤

តារាង ៤.៦ ខ្សែបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិតាមតំបន់ (ឆ្នាំ ២០០៤ និង ២០០៧) (គិតជារៀលសម្រាប់មនុស្សម្នាក់ ក្នុងមួយថ្ងៃ) ..... ៩៥

តារាង ៥.១ អត្រាកំណើននៃឧស្សាហកម្មតាមវិស័យ កំពុងកែលម្អនូវអ្វីដែលមានបង្រៀន ក្នុងការអប់រំវិជ្ជាជីវៈនៅកម្ពុជា ..... ១០៥

# ប្រអប់


ប្រអប់ ២.១ : ការបញ្ឈប់ការបោះបង់ការសិក្សារតាមរយៈកម្មវិធីឧបត្ថម្ភប្រាក់ ..... ៣៧

ប្រអប់ ៣.១ : ការវិនិយោគបរទេសផ្ទាល់ និងភាពប្រែប្រួលខ្លាំងពាក់ព័ន្ធទៅនឹងការវិនិយោគនេះ ..... ៦៦

ប្រអប់ ៤.១ ការដោះស្រាយបញ្ហាលំបាក : ទស្សនាទាននៃគោលនយោបាយសាធារណៈ ..... ៩៦

ប្រអប់ ៥. ១ ការអប់រំ មូលធនមនុស្ស និងផលិតផលក្នុងស្រុកសរុប ..... ១០០

ប្រអប់ ៥. ២ អន្តរាគមន៍ដឹកនាំដោយរដ្ឋាភិបាលលើមូលធនមនុស្សនៅកូរ៉េ ..... ១០៣

ប្រអប់ ៥.៣ ឱកាសទទួលទូរសិក្សា ..... ១០៦

ប្រអប់ ៥.៤ ការលាតត្រដាងការរស់រៀនឡើងវិញនៃសេដ្ឋកិច្ចនៅអាស៊ី ..... ១០៨

ប្រអប់ ៦.១ ការអប់រំមានប្រាក់ឧបត្ថម្ភ (EMA) ..... ១២១

ប្រអប់ ៦.២ ប្រព័ន្ធសុវត្ថិភាពសង្គម និងការជួយដល់និកម្មជន ..... ១២២

ប្រអប់ ៦.៣ ដើម្បីលើកកម្ពស់មូលធនមនុស្សនៅកម្ពុជា យើងត្រូវការយុទ្ធសាស្ត្ររយៈពេលវែង ដែលមានធាតុផ្សំរយៈពេលខ្លី ..... ១២៧

ប្រអប់ ៦.៤ ដើម្បីលើកកម្ពស់មូលធនមនុស្សនៅកម្ពុជា យើងត្រូវការយុទ្ធសាស្ត្ររយៈពេលវែង ដែលមានធាតុផ្សំរយៈពេលខ្លី ..... ១៣២

# អក្សរកាត់

| | | |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ASEAN** | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CAS** | Country Assistance Strategy | យុទ្ធសាស្ត្រជំនួយប្រចាំប្រទេស |
| **CSES** | Cambodia Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច កម្ពុជា |
| **ESDP II** | Education Sector Development Programme | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ ដំណាក់កាលទី២ |
| **EU** | European Union | សហគមន៍អឺរ៉ុប |
| **FDI** | Foreign direct investment | វិនិយោគផ្ទាល់ពីបរទេស |
| **GDP** | Gross domestic product | ផលិតផលក្នុងស្រុកសរុប |
| **HEIs** | Higher education institutions | គ្រឹះស្ថានឧត្តមសិក្សា |
| **ICT** | Information and communications technology | បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ |
| **IFC** | International Financial Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| **ILO** | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| **MDGs** | Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MIME** | Ministry of Industry, Mines and Energy | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| **MoEYS** | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoLVT** | Ministry of Labour and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **MoP** | Ministry of Planning | ក្រសួងផែនការ |
| **NEA** | National Employment Agency | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| **NIS** | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| **NSDP** | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| **NTB** | National Training Board | ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល |
| **OECD** | Organisation for Economic Co-operation and Development | អង្គការសហការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |

| | | |
|---|---|---|
| **PNPM** | National Programme for Community Empowerment (Indonesia) | កម្មវិធីជាតិដើម្បីផ្តល់សិទ្ធិអំណាចដល់សហគមន៍( ឥណ្ឌូនេស៊ី) |
| **PPPs** | public-private partnerships | ភាពជាដៃគូរដ្ឋ-ឯកជន |
| **PTBs** | Provincial Training Boards | ក្រុមប្រឹក្សាខេត្តបណ្តុះបណ្តាល |
| **PTCs** | Provincial Training Centres | សាលាបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **SME** | Small- and medium-sized enterprises | សហគ្រាសខ្នាតតូច និងមធ្យម |
| **SNEC** | Supreme National Economic Council | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| **SWAp** | Sector-wide approach | វិធីសាស្ត្រឆ្លងវិស័យ |
| **TVET** | Technical and vocational education and training | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| **UNDAF** | United Nations Development Assistance Framework | ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ |
| **UOC** | Open University of Catalonia (Spain) | សាកលវិទ្យាល័យបើកទូលាយរបស់កាតាឡូនៀ |
| **USAID** | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| **WTO** | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |



© 2001, UNDP/Arantxa Cedillo

# បុព្វកថា

វិបត្តិសេដ្ឋកិច្ចសកលបានជំរុញឱ្យមនុស្សគ្រប់ៗរូបដកឃ្លាមកគិតយ៉ាងហោចណាស់ប្រទេសដែលមានសេដ្ឋកិច្ចពឹងអាស្រ័យខ្លាំងលើការនាំចេញផលិតផលទៅទីផ្សារអឺរ៉ុប និងអាមេរិក។ ការអំពាវនាវឱ្យមានពិពិធកម្មសេដ្ឋកិច្ច បានផ្តល់កាលានុវត្តភាពមួយសម្រាប់ឱ្យប្រទេសនានា ពិចារណាឡើងវិញអំពីគោលនយោបាយឧស្សាហកម្មូបនីយកម្ម និងពិនិត្យរកមធ្យោបាយរយៈពេលយូរ ដើម្បីធានានិរន្តរភាពនៃកំណើនសេដ្ឋកិច្ច។ ពិពិធកម្មសេដ្ឋកិច្ចដែលជោគជ័យ គឺទាមទារការប្តេជ្ញាចិត្ត និងការវិនិយោគទាំងលើមូលធនមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ។

“ពិពិធកម្មដែលទទួលបានជោគជ័យតំរូវអោយមានការតាំងចិត្ត និងការវិនិយោគទាំងមូលធនមនុស្ស និងហេដ្ឋារចនាសម្ពន្ធ័។”

សេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងល្បឿនមួយគួរឱ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង ក្នុងអំឡុងទសវត្សរ៍ ១៩៩០ ប៉ុន្តែ ការប្រមូលផ្តុំតិចតួចតែលើការនាំចេញ ធ្វើឱ្យប្រទេសកម្ពុជាត្រូវប្រឈមមុខនឹងភាពងាយរងគ្រោះដោយសារវិបត្តិពីខាងក្រៅដែរ។ ហេតុដូច្នេះ ប្រទេសនេះត្រូវយល់ឱ្យច្បាស់ថា កំណើនសេដ្ឋកិច្ចរឹងមាំក្នុងពេលអនាគត គឺសំខាន់ជាងកំណើនលឿន។

រាជរដ្ឋាភិបាលកម្ពុជាបានយកឱកាសនេះដើម្បីសម្លឹងមើលសេដ្ឋកិច្ចរបស់ប្រទេសជាតិឱ្យកាន់តែកៀកទៀត និងសម្លឹងមើលភាពងាយគ្រោះថ្នាក់នៃសេដ្ឋកិច្ចរបស់ខ្លួនផងដែរ ហើយត្រូវមានផែនការច្បាស់លាស់សម្រាប់អនាគតនៃ សេដ្ឋកិច្ចមួយដែលបានកែលម្អច្បាស់លាស់មានពិពិធភាព និងកាន់តែរឹងមាំថែមទៀត។

ក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទីបួន នាខែកុម្ភៈ ឆ្នាំ២០១១ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងអំពីតម្រូវការរបស់កម្ពុជាក្នុងការធ្វើទំនើបកម្ម សេដ្ឋកិច្ច ដោយលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដើម្បីធានាសម្រេចកំណើនប្រកបដោយចីរភាព ហើយត្រូវដឹកនាំសេដ្ឋកិច្ចឱ្យឈានដល់កម្រិតអភិវឌ្ឍន៍មួយកាន់តែខ្ពស់។ គោលនយោបាយអភិវឌ្ឍន៍ ឧស្សាហកម្ម បង្ហាញក្នុងវេទិកាលើកទីបួននេះ ត្រូវបានចងក្រងឡើងដើម្បីចាប់ច្បាមយកតម្លៃបន្ថែមឱ្យបានកាន់តែច្រើនក្នុងវិស័យស្នូល (កសិកម្ម កាត់ដេរ និងទេសចរណ៍) ធ្វើឱ្យប្រសើរឡើងនូវឧស្សាហកម្មទើបនឹងពន្លកឡើងថ្មីដែលមានសក្តានុពលភាពកំណើនខ្ពស់ (គ្រឿងសង្ហារឹម សិប្បកម្មកែច្នៃ សម្ភារៈសំណង់ ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ និងឧស្សាហកម្មនិស្សារណកម្ម) និងកំណត់រកឧត្តមភាពប្រៀបធៀបដែលមានអនាគតក្នុងការអភិវឌ្ឍផ្នែកទន់ ឧស្សាហកម្មគីមី ថាមពលកកើតឡើងវិញ និងឧស្សាហកម្មច្នៃប្រឌិត។

យុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មគ្រប់ជ្រុងជ្រោយ និងមានលក្ខណៈសម្របសម្រួលច្បាស់លាស់មួយសម្រាប់អនាគតកម្ពុជា ត្រូវដាក់បញ្ចូលយុទ្ធសាស្ត្រអភិវឌ្ឍន៍មូលធនមនុស្ស ដើម្បីរៀបចំត្រៀមកម្លាំងពលកម្មសម្រាប់ឱកាសដែលបានមកពីកំណើន។ ផែនទីយុទ្ធសាស្ត្រដែលលើកឡើងលម្អិតក្នុងរបាយការណ៍នេះបង្ហាញច្បាស់អំពីតម្រូវការធ្វើពិពិធកម្ម និងពង្រឹងឧស្សាហកម្ម ព្រមទាំងលើកឡើងអំពីជំហានដែលត្រូវប្រើដើម្បីធានាសម្រេចគោលដៅនៃយុទ្ធសាស្ត្រនេះ។

ក្នុងពេលបច្ចុប្បន្ន គឺមានគម្លាតមួយយ៉ាងធំរវាងតម្រូវការទីផ្សារ និងជំនាញដែលមានស្រាប់ ហើយគ្រឹះស្ថានអប់រំដែលមានស្រាប់ និងកម្មវិធីបណ្តុះបណ្តាល ជាញឹកញាប់មិនឆ្លើយតបតាមតម្រូវការទីផ្សារ និងតម្រូវការរបស់វិស័យឯកជនទេ។ ដំណើរការនៃការកសាងមូលធនមនុស្សប្រកបដោយគុណភាពខ្ពស់

គឺត្រូវការពេលវេលាយូរ ប៉ុន្តែ ដោយមានការប្រមូលផ្តុំកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធ និងចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់ និងពីក្រសួងរបស់រដ្ឋាភិបាល គឺអាចរៀបចំត្រៀមយុវជនបច្ចុប្បន្នសម្រាប់អនាគតបាន។

មានភូមិសាស្ត្រជាយុទ្ធសាស្ត្រនៅចំកណ្តាលបេះដូងនៃអាស៊ីអាគ្នេយ៍ កម្ពុជាមានកម្លាំងពលកម្មយុវជនហើយមានសក្តានុពលភាពខ្ពស់ក្នុងការដឹកនាំប្រទេសក្នុងអន្តរកាល កែប្រែពីប្រទេសអភិវឌ្ឍន៍តិចឱ្យក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យម។ តាមការរំពឹងមានមនុស្សប្រមាណ ៣០០០០០នាក់ ត្រូវចូលក្នុងកម្លាំងពលកម្មរៀងរាល់ឆ្នាំ ការអភិវឌ្ឍមូលធនមនុស្សនៅគ្រប់កម្រិតបង្ហាញអំពីការវិនិយោគយ៉ាងសំខាន់របស់ប្រទេសនៅពេលអនាគត។

មានវិធានការបន្ទាន់ដែលអាចចាត់ការបាន ប៉ុន្តែ របាយការណ៍បានគូសបញ្ជាក់ច្បាស់ហើយថាមានវិធានការរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងដែលអាចយកមកដាក់បញ្ចូលឱ្យស្របតាមមាតិកាការអភិវឌ្ឍមូលធនមនុស្ស ហើយអាចធ្វើការរួមគ្នាដើម្បីបង្កើតសេដ្ឋកិច្ចឱ្យសម្បូរបែប និងឱ្យរឹងមាំដើម្បីផ្តល់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជា។

ដើម្បីបញ្ជាក់ឱ្យច្បាស់ឡើងវិញអំពីសារៈសំខាន់នៃគោលនយោបាយអភិវឌ្ឍន៍មូលធនមនុស្សនៅកម្ពុជា ដូចដែលបានបញ្ជាក់នៅក្នុងសន្ទរកថារបស់សម្តេចអគ្គសេនាបតីតេជោ ក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទីបួន សម្តេចបានថ្លែងថា "រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើ...ព្រមទាំងការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការបណ្តុះបណ្តាលជំនាញនិងវិជ្ជាជីវៈដែលជាកត្តាយ៉ាងសំខាន់សម្រាប់សម្រេចសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។"

UNDP កំពុងបំពេញការងារដើម្បីជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានាក្នុងការត្រៀមរៀបចំការអភិវឌ្ឍមនុស្សរបស់កម្ពុជាក្នុងជំហានបន្ទាប់ទៀត និងត្រៀមធានាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនិងកំណើនសេដ្ឋកិច្ចដែលមានដាក់បញ្ចូលគ្រប់សមាសភាព។ ការងាររបស់ UNDP ក្នុងវិស័យអភិវឌ្ឍន៍មូលធនមនុស្សគឺមានទិសដៅឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជន និងគាំទ្រដល់រដ្ឋាភិបាលកម្ពុជា ព្រោះរដ្ឋាភិបាលព្យាយាមពង្រីកនិងលើកកម្ពស់មូលធនមនុស្សរបស់ប្រទេសដោយផ្តល់កាលានុវត្តភាព លើសពី៦៥ភាគរយសម្រាប់ប្រជាជន ថិតក្នុងក្រុមអាយុក្រោម ៣០ឆ្នាំ។ កំណត់ទិសដៅការងារតាមផ្លូវបែបនេះ និងការប្តេជ្ញាចិត្តដើម្បីឈានក្លាយជាប្រទេសមួយដែលមានប្រាក់ចំណូលមធ្យមនៅត្រឹមឆ្នាំ ២០២០ រាជរដ្ឋាភិបាលកម្ពុជាអាចកសាងអនាគតមួយដែលកាន់តែរឹងមាំមានសមធម៌ និងកាន់តែមានវិបុលភាពភ្លឺស្វាង សម្រាប់ប្រជាពលរដ្ឋទាំងអស់។

**យូអិនឌីភីកម្ពុជា**

**ខែសីហា ឆ្នាំ២០១១**

# សេចក្តីថ្លែងអំណរគុណ


ការសិក្សានេះបានធ្វើឡើងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា (UNDP) និងសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)។ ការស្រាវជ្រាវនេះដឹកនាំដោយបណ្ឌិត Satish Mishra មកពីក្រុមហ៊ុន Strategic Asia។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោក លោកស្រី ផ្សេងទៀតដែលបានចូលរួមចំណែកយ៉ាងធំធេង និងដ៏មានអត្ថន័យក្នុងការសិក្សាស្រាវជ្រាវនេះ។

អង្គការ UNDP សូមថ្លែងអំណរគុណចំពោះមន្ត្រីជាន់ខ្ពស់នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលបានផ្តល់ការណែនាំដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន រួមមាន ឯកឧត្តម រស់ សីលវ៉ា អគ្គលេខាធិការរង ឯកឧត្តម ទេព ភិយោរិទ្ធ ប្រធានផ្នែកគោលនយោបាយ និងវិភាគសេដ្ឋកិច្ច លោក ហៃ សុរុទ្ធា អ្នកស្រាវជ្រាវ។

សូមថ្លែងអំណរគុណយ៉ាងពិសេសចំពោះអង្គការពលកម្មអន្តរជាតិ (ILO) ដែលបានផ្តល់យោបល់យ៉ាងមានតម្លៃអំពីដំណើរការស្រាវជ្រាវ និងបានពិនិត្យកែលម្អសេចក្តីព្រាងនៃរបាយការណ៍ រួមមាន លោកស្រី Carmela Torres អ្នកឯកទេសជាន់ខ្ពស់ខាងជំនាញនិងការងារ បណ្ឌិត Sukti Dasgupta អ្នកឯកទេសជាន់ខ្ពស់ផ្នែកគោលនយោបាយការងារនិងទីផ្សារពលកម្ម លោក Tuomo Poutiainen ប្រធានទីប្រឹក្សាបច្ចេកទេសនៃកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ លោក ទុន សុភ័ណ មន្ត្រីសម្របសម្រួលថ្នាក់ជាតិនៃអង្គការ ILO ប្រចាំកម្ពុជា។

អង្គការ UNDP ក៏សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការផ្តល់យោបល់និងការប្រឹក្សាយ៉ាងមានតម្លៃ ដូចជា លោកស្រី Sandra D'Amico នាយិកាគ្រប់គ្រងនៃក្រុមហ៊ុន HR Inc។ លោកស្រី Yumiko Yamamoto អ្នកឯកទេសកម្មវិធីនៃមជ្ឈមណ្ឌលប្រចាំតំបន់អាស៊ីប៉ាស៊ីភិចរបស់អង្គការ UNDP លោក Radhika Lal អ្នកឯកទេសគោលនយោបាយនៃមជ្ឈមណ្ឌលគោលនយោបាយអន្តរជាតិរបស់អង្គការ UNDP ដើម្បីកំណើនគ្រប់សមាសភាព អ្នកស្រី Sun Lei អ្នកឯកទេសកម្មវិធីអប់រំនៃអង្គការ UNESCO លោក សុត និមល អ្នកជំនួយការបច្ចេកទេសផ្នែកអប់រំនៃអង្គការ UNESCO ។

ចំពោះការចូលរួមដោយផ្ទាល់ និងដោយប្រយោលក្នុងការសិក្សានេះ អង្គការ UNDP សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណ និងការដឹងគុណចំពោះមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងទីភ្នាក់ងារជាតិមុខរបរនិងការងារ។ ប្រសិនបើពុំមានការគាំទ្រ និងការចូលរួមពីសំណាក់មន្ត្រីទាំងនេះទេ ការស្រាវជ្រាវនេះក៏មិនអាចដំណើរការរហូតដល់ទីបញ្ចប់នេះបានដែរ។

ដំណើរការនៃការរៀបចំ និងការបញ្ចប់របាយការណ៍នេះ គឺធ្វើឡើងដោយគម្រោងផ្សារភ្ជាប់គោលនយោបាយនិងការអនុវត្ត (LPP) ដើម្បីពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (គោលដៅទី១) ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់លោកស្រី ឃន ឌីនវ៉ារី ប្រធានសម្របសម្រួលគោលនយោបាយ និងស្រាវជ្រាវ។ ការសិក្សាស្រាវជ្រាវនេះក៏មានការគាំទ្របន្ថែមពីសំណាក់បុគ្គលិកជាច្រើនទៀតរួមមាន លោក ប៉ែន រក្សា លោកស្រី ឆាយ ពិដោរ កញ្ញា អ៊ឹង សុមាល័យ កញ្ញា Priscila Scalco លោក លឹម សុវណ្ណារ៉ា កញ្ញា Flavia Di Marco កញ្ញា នង ឧត្តតារា លោក Tomas Flores លោកស្រី ប៉ក់ សុហៀង និង លោក Glenn Kendal ។



© 2001, UNDP/Arantxa Cedillo

# ខ្លឹមសារសង្ខេប

## ផលទាក់ទងនានានៃមូលធនមនុស្សលើកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលអនាគត៖ ធាតុនានានៃសំណើផែនទីយុទ្ធសាស្ត្រ

### *មូលធនមនុស្សកម្ពុជាក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលកន្លងទៅថ្មីៗនេះ*

១. កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការងើបឡើងវិញពីវិបត្តិសេដ្ឋកិច្ចខ្លាំងជាងពេលណាណាទាំងអស់របស់ខ្លួនក្នុងរយៈពេលពីរទសវត្សរ៍។ វិបត្តិនេះកាន់តែមានលក្ខណៈធ្ងន់ធ្ងរបន្ថែមទៀតដោយសារវាបានកើតឡើងដោយឥតបានរំពឹងទុក។ គេពិបាកគូសបញ្ជាក់ឱ្យបានច្បាស់អំពីផលប៉ះពាល់ទៅលើសង្គមដែលបណ្តាលមកពីវិបត្តិនេះ ដោយហេតុថាវាបានកើតឡើងក្រោយពីមានអត្រាកំណើនប្រាំបួនភាគរយក្នុងកំឡុងពេលរយៈពេលមួយទសវត្សមកនេះ ដែលអត្រានេះស្ថិតនៅក្នុងចំនោមអត្រាខ្ពស់បំផុតនៅលើពិភពលោក។

២. ការប៉ះទង្គិចមកលើផលិតផលក្រោយពីវិបត្តិសេដ្ឋកិច្ចពិភពលោកក្នុងពេលបច្ចុប្បន្ន បានបង្ហាញអោយឃើញនូវចំណុចខ្សោយសំខាន់ៗនានានៃរចនាសម្ព័ន្ធនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ កំណើនសេដ្ឋកិច្ចកម្ពុជាប្រមូលផ្តុំលើវិស័យមួយចំនួនតូចដែលពឹងផ្អែកលើវិនិយោគផ្ទាល់ពីបរទេស ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់ វិស័យទេសចរណ៍ និងវិស័យសំណង់។ ការប្រមូលផ្តុំនេះទៀតសោត ភាគច្រើនកើតមានតែនៅតាមតំបន់ទីក្រុងមួយចំនួនតូច ពិសេសនៅរាជធានីភ្នំពេញ។ វិស័យឯកជនក្នុងស្រុកនៅតែមានទម្រង់ជាសហគ្រាសគ្រួសារតូចៗនៅឡើយនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងពេលកន្លងទៅថ្មីៗនេះបានជម្រុញឱ្យមានការប្រែប្រួលរចនាសម្ព័ន្ធនៅក្នុងសមាសភាពនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។ ទោះជាយ៉ាងណាក្តី កម្ពុជានៅតែជាប្រទេសដែលមានខឿនសេដ្ឋកិច្ចខាងផ្អែកកសិកម្ម។ វិស័យកសិកម្មកម្ពុជា ជាការធ្វើកសិកម្មសម្រាប់ចិញ្ចឹមជីវិត ដែលស្រូវគឺជាដំណាំកសិកម្មចំបង។

៣. កំណើនសេដ្ឋកិច្ចឆាប់រហ័សដែលប្រមូលផ្តុំលើផ្នែក និងវិស័យមួយចំនួនតូចព្រមជាមួយការកើនឡើងយ៉ាងឆាប់រហ័សនៃទីផ្សារពលកម្មនៅតាមទីក្រុងដែលកើតឡើងទន្ទឹមនឹងកំណើនសេដ្ឋកិច្ចបានបង្ហាញអោយឃើញពីបញ្ហានៃរចនាសម្ព័ន្ធនៅក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងពេលដែលអត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សានៅកម្ពុជាបានកើនឡើងយ៉ាងខ្ពស់ចាប់ពីឆ្នាំ ១៩៩៧ មកគឺកើនឡើងពីកម្រិតជាង ៥០% ទៅជាង ៨០% នៃសិស្សគ្រប់អាយុចូលរៀនក្នុងរយៈពេលមួយទសវត្សក្រោយ ប៉ុន្តែ អត្រានេះបានធ្លាក់ចុះជាខ្លាំងក្នុងដំណាក់កាលក្រោយមកទៀតនៃវដ្តអប់រំ។ នៅក្នុងឆ្នាំមុនពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោក (២០០៧) កុមារកម្ពុជាត្រឹមតែ ២៤% ប៉ុណ្ណោះដែលបានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ ១៥,៦% បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ ហើយមានត្រឹមតែ ២,៧% ប៉ុណ្ណោះដែលបានបញ្ចប់កម្រិតឧត្តមសិក្សា។ នេះគឺជាបុព្វហេតុដែលគួរអោយព្រួយបារម្ភ។ អត្រាប្រៀបធៀបជាមួយប្រទេសជិតខាងនៅក្នុងសមាគមអាស៊ាន ដូចជាប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងប្រទេសថៃ ដែលពួកគេមានអត្រាខ្ពស់ជាងកម្ពុជា ទោះបីជាអត្រា

> *"ការប៉ះទង្គិចលើផលិតផលក្រោយពីវិបត្តិសេដ្ឋកិច្ចពិភពលោកក្នុងពេលបច្ចុប្បន្នបានបង្ហាញអោយឃើញនូវចំណុចខ្សោយសំខាន់ៗនានានៃរចនាសម្ព័ន្ធនៅក្នុងសេដ្ឋកិច្ចកម្ពុជា។"*

ចុះឈ្មោះចូលរៀនកម្រិតមធ្យមសិក្សា នៅក្នុងទសវត្ស ១៩៩៧-២០០៧ បានកើតឡើងពីរដងក្តី។ ជាពិសេសកម្ពុជាបានស្ថិតនៅក្រោយប្រទេសជិតខាងក្នុងកម្រិតសិក្សាថ្នាក់ឧត្តម។ នៅឆ្នាំ ២០០៧ អត្រាចុះឈ្មោះចូលរៀននៅក្នុងកម្រិតនេះមានត្រឹមតែ ៥% ប៉ុណ្ណោះ ធៀបនឹងអត្រា ១២% នៅប្រទេសឡាវ ១៧% នៅប្រទេសឥណ្ឌូនេស៊ី និង ២៨% នៅប្រទេសហ្វីលីពីន។

៤. កំណើនឆាប់រហ័សនៃផលិតផលក្នុងស្រុកសរុបក្នុងទសវត្សមុនពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលកន្លងទៅថ្មីៗនេះគួបផ្សំជាមួយរចនាសម្ព័ន្ធប្រជាសាស្ត្រក្នុងនោះប្រជាជនចំនួន ៦០% មានអាយុតិចជាង ២៤ ឆ្នាំ បានធ្វើចំណាកស្រុកក្នុងប្រទេសក្នុងកម្រិតខ្ពស់ និងជាអត្រាកម្លាំងពលកម្មខ្ពស់បំផុតដែលបានព្យាករណ៍នៅអាស៊ាន។ ប្រការនេះធ្វើឱ្យបញ្ហាអភិវឌ្ឍជំនាញកាន់តែមានលក្ខណៈស្មុគស្មាញបន្ថែមទៀត។ គេពិបាកកំណត់អត្តសញ្ញាណពលករ ចំណាកស្រុក និងពិបាកតម្រង់ទិសពួកគេទៅក្នុងកម្មវិធីក្នុងប្រព័ន្ធនៅថ្នាក់មធ្យមសិក្សាបឋមភូមិ។ បន្ថែមលើនេះ កម្លាំងពលកម្មដែលកើនឡើងយ៉ាងឆាប់រហ័សក៏ដាក់សម្ពាធមកលើហេដ្ឋារចនាសម្ព័ន្ធសាលារៀនក្នុងពេលដែលវានៅមានភាពទន់ខ្សោយនៅឡើយ។ នេះនៅមិនទាន់គិតដល់ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចនាពេលកន្លងទៅថ្មីៗនេះមកលើភាពក្រីក្រនៅឡើយទេខណៈដែលវិបត្តិនេះជម្រុញដល់ការគិតគូរអំពីផលសេដ្ឋកិច្ចចំពោះមុខតាមរយៈការបញ្ជូនកូនចៅឱ្យទៅធ្វើការជាជាងការទុកឱ្យពួកគេបញ្ចប់ការសិក្សាដើម្បីទទួលផលក្នុងរយៈពេលវែង។

៥. ភាពខុសគ្នាយ៉ាងច្រើននៅក្នុងតំបន់អំពីការចូលរៀន និងអំពីគុណភាពធ្វើឱ្យរូបភាពទូទៅនៃការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជាកាន់តែមានភាពស្មុគស្មាញ។ ខណៈពេលដែលការចុះឈ្មោះចូលរៀននៅបឋមសិក្សាមានកម្រិតប្រហាក់ប្រហែលគ្នានៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាការចុះឈ្មោះចូលរៀនមានភាពខុសគ្នាជាខ្លាំងរវាងតំបន់នានានៅកម្ពុជា។ សម្រាប់មធ្យមសិក្សាបឋមភូមិតែមួយផ្នែក ការចុះឈ្មោះចូលរៀនអាចប្រែប្រួលពីមានកម្រិតទាបនៅតំបន់នានាដូចជានៅរតនគិរី ទៅកាន់កម្រិតខ្ពស់បំផុតនៅភ្នំពេញ ដែលភាពខុសគ្នានោះមានកម្រិតមួយទល់នឹងដប់។ លើទិដ្ឋភាពសមធម៌ និងលទ្ធភាពនៃការទទួលបាននូវការអភិវឌ្ឍជំនាញសូម្បីតែក្នុងកម្រិតមូលដ្ឋាននេះក្តីក៏ហាក់ដូចជាមានសារៈសំខាន់ជាចំបងចំពោះការរៀបចំគោលនយោបាយក្នុងពេលអនាគតដែរ។

៦. លើផ្នែកនយោបាយវិញ រាជរដ្ឋាភិបាលកម្ពុជាបានឆ្លើយតបចំពោះបញ្ហាប្រឈមផ្នែកគោលនយោបាយទាំងនេះ តាមរយៈការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ពេញលេញគឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិដែលមិនត្រឹមតែផ្តោតការយកចិត្តទុកដាក់លើកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានផ្តោតការយកចិត្តទុកដាក់លើស្ថេរភាព និងសុខុមាលភាពសង្គម អភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយព្រមទាំងការធ្វើពិពិធកម្មសេដ្ឋកិច្ចផងដែរ។ យុទ្ធសាស្ត្រនេះផ្តល់លទ្ធភាពក្នុងការកសាងមូលដ្ឋានគ្រឹះសម្រាប់ការងើបឡើងវិញដោយចីរភាពក្នុងពេលអនាគត ពិសេសគឺ ដោយសារយុទ្ធសាស្ត្រនេះព្យាយាមធ្វើសមាហរណកម្មគោលនយោបាយសេដ្ឋកិច្ចជាមួយគោលនយោបាយអភិវឌ្ឍធនធានមនុស្ស។

៧. ទោះជាយ៉ាងណាក្តី នៅក្នុងបរិបទចំពោះមុខនៃវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលកន្លងទៅថ្មីៗនេះ ប្រទេសកម្ពុជានៅតែបន្តប្រឈមមុខជាមួយបញ្ហាប្រឈមផ្នែកគោលនយោបាយមួយចំនួនយ៉ាងសំខាន់។ ទីមួយ គឺការស្វែងរកវិធីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិលើផលិតផល និងពាណិជ្ជកម្មមកលើពលរដ្ឋ

ក្រីក្រ។ ទីពីរ គឺការដាក់ឱ្យកម្មករដែលត្រូវបានផ្អាក/បញ្ឈប់ការងារពីវិស័យសំខាន់ៗរបស់ខ្លួន ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់ ទេសចរណ៍ និងសំណង់ឱ្យមានការងារធ្វើជាថ្មីឡើងវិញ។ ទីបី គឺការជម្រុញឱ្យមានប្រភពថ្មីនៃកំណើនក្នុងពេលអនាគត ដូចជា ការព្យាយាមធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចកម្ពុជាកាត់បន្ថយផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចអន្តរជាតិនៅក្នុងសេដ្ឋកិច្ចពិភពលោក។ ទីបួន គឺធ្វើយ៉ាងណាឱ្យកំណើនក្នុងពេលអនាគតមានមូលដ្ឋានទូលំទូលាយដើម្បីឈានទៅកាត់បន្ថយវិសមភាពប្រាក់ចំណូលនៅតាមតំបន់ និងគ្រួសារ។

៨. បញ្ហាប្រឈមចំបងមួយចំពោះការរៀបចំគោលនយោបាយគឺការរិះរកវិធីផ្សារភ្ជាប់អាទិភាពរយៈពេលខ្លីនានានៃការបង្កើតការងារ និងការកាត់បន្ថយភាពក្រីក្រជាមួយនឹងកិច្ចប្រឹងប្រែងរយៈពេលវែងនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច តាមរយៈការកសាងមូលដ្ឋានរឹងមាំនៃមូលធនមនុស្ស និងការពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការប្រឈមមុខនឹងបញ្ហាប្រឈមក្នុងពេលអនាគតអំពីនិយ័តកម្មហិរញ្ញវត្ថុ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការប្រយុទ្ធនឹងវិសមភាពសេដ្ឋកិច្ច ទាំងនេះគឺជាបញ្ហាដែលប្រទេសស្ទើរតែទាំងអស់នៅក្នុងតំបន់អាស៊ានបូក កំពុងជួបប្រទះ។

> “...ផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្ស នឹងអនុញ្ញាតអោយប្រទេសកម្ពុជាដាក់បញ្ចូលវិធានការរយៈពេលខ្លី និងលើកកំពស់ការងារជាមួយអាទិភាពរយៈពេលវែងនៃពិពិធកម្មសេដ្ឋកិច្ច...។”

## *ពិពិធកម្មសេដ្ឋកិច្ចនិងផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្ស*

៩. បន្ថែមលើការរក្សាឱ្យបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច អភិក្រមរបស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍមូលធនមនុស្សនៅក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចនាពេលកន្លងទៅថ្មីៗនេះ គឺការស្តារឡើងវិញនូវលទ្ធភាពផ្តល់ការងារដល់កម្មករដែលត្រូវបានផ្អាក/បញ្ឈប់ ក៏ដូចជាត្រូវស្តារឡើងវិញនូវលំហូរវិនិយោគផ្ទាល់ពីបរទេសមកកាន់កម្ពុជាដែលបានរងផលប៉ះពាល់យ៉ាងដំណំក្នុងអំឡុងពេលមានការរឹតបន្តឹងឥណទានជាសាកល។ រាជរដ្ឋាភិបាលក៏បានចាត់វិធានការដើម្បីកែលំអព័ត៌មានទីផ្សារការងារ តាមរយៈការបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារជម្រុញការបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈទីភ្នាក់ងារជាតិហ្វឹកហ្វឺនបំប្រួញអសង្គតិភាពផ្នែកជំនាញរវាងការផ្គត់ផ្គង់និងតម្រូវការពលកម្ម តាមរយៈការពិគ្រោះយោបល់ និងការពិនិត្យមើលរួមគ្នាសារជាថ្មី ជាមួយវិស័យឯកជន ក៏ដូចជាចូលរួមក្នុងការស្វែងរកគោលនយោបាយពិពិធកម្មឧស្សាហកម្មសម្រាប់ពេលអនាគតដែលមានលក្ខណៈសមស្រប និងងាយអនុវត្តចំពោះទីផ្សារ។

១០. ទាំងនេះសុទ្ធតែជាគំនិតផ្តួចផ្តើមសំខាន់ៗ ទោះបីជាគំនិតផ្តួចផ្តើមទាំងនោះនៅខ្វះកម្លាំងអប្បបរមាចាំបាច់ដើម្បីធ្វើឱ្យមានភាពជឿនលឿននៅក្នុងទិដ្ឋភាពនៃឱកាសការងារក្តី។ ទោះជាយ៉ាងណាក៏ដោយគំនិតផ្តួចផ្តើមទាំងអស់ នោះឆ្លុះបញ្ចាំងអភិក្រមមួយផ្នែកអំពីអ្វីដែលជាបញ្ហាទូទៅនៃសេដ្ឋកិច្ចនោះគឺការបង្កើតមូលដ្ឋានមូលធនមនុស្សដែលស្របគ្នាជាមួយយុទ្ធសាស្ត្រពិពិធកម្មសេដ្ឋកិច្ចរបស់រដ្ឋាភិបាល និងស្របជាមួយអាទិភាពផ្នែកសុខុមាលភាពផងដែរ។ តាមពិតបញ្ហាដែលមានលក្ខណៈជារចនាសម្ព័ន្ធដែលប្រឈមមុខចំពោះវិស័យអប់រំ និងវិស័យអភិវឌ្ឍជំនាញសព្វថ្ងៃមួយផ្នែកគឺដោយសារការមិនអាចដោះស្រាយបញ្ហាទាំងនេះក្នុងបណ្តាឆ្នាំដែលមានកំណើន។ នៅពេលដែលប្រទេសកម្ពុជាបន្តទៅមុខឆ្ពោះទៅកាន់កំណើនសេដ្ឋកិច្ចដែលបានធ្វើពិពិធកម្ម ហើយមាននិរន្តរភាពក្នុងពេលអនាគត គឺជាពេលវេលាដែលត្រូវរៀបចំ និងអនុវត្តផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្សថ្មីមួយដែលមានលក្ខណៈពេញលេញ។

១១. ភាពបន្ទាន់នៃការបង្កើតផែនទីយុទ្ធសាស្ត្របែបនេះក៏មានប្រភពនៅក្នុងការត្រេះរិះពិចារណាអំពីយុទ្ធសាស្ត្រស្ដីពីពិពិធកម្មសេដ្ឋកិច្ចទាំងនេះផងដែរ។ កំណែទម្រង់នៃវិស័យអប់រំ និងជំនាញកំពុងត្រូវបានអនុវត្តដោយប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ភាគច្រើន ពិសេសនៅក្នុងទ្វីបអាស៊ីទន្ទឹមជាមួយជំនាញ និងបណ្ដាញផលិតផល បង្ហាញអំពីការកើនឡើងនូវការទទួលយកទស្សនៈដែលថាកំណើននិងផលិតភាពនាពេលអនាគតនឹងជម្រុញដោយ "ផលិតផលពុទ្ធិ" រាប់ទាំងសមត្ថភាពរបស់បណ្ដាប្រទេសនានាក្នុងការប្រណាំងប្រជែងជាមួយបច្ចេកវិទ្យាថ្មីៗផងដែរ។ មានតែអភិក្រមគ្រប់ជ្រុងជ្រោយចំពោះការអភិវឌ្ឍមូលធនមនុស្សក្នុងពេលអនាគត ដែលមានចែងនៅក្នុងផែនទីយុទ្ធសាស្ត្រស្ដីពីមូលធនមនុស្សប៉ុណ្ណោះដែលអនុញ្ញាតឱ្យប្រទេសកម្ពុជាដាក់បញ្ចូលវិធានការរយៈពេលខ្លីនៃការលើកកំពស់ការងារជាមួយអាទិភាពរយៈពេលវែងនៃពិពិធកម្មសេដ្ឋកិច្ច និងការកសាងសមត្ថភាពរបស់រដ្ឋក្នុងការនាំមកនូវកម្មវិធីពិពិធកម្មជាក់ស្ដែង។

១២. ការដាក់បញ្ចូលនូវលក្ខខណ្ឌទាំងអម្បាលមាណខាងលើអំពីការរៀបចំមូលដ្ឋានគ្រឹះនៃគោលនយោបាយជាតិដើម្បីទាញផលពីខឿនសេដ្ឋកិច្ចពុទ្ធិសាកល និងការប្រែក្លាយកត្តាទាំងនេះឱ្យទៅជាផែនទីយុទ្ធ-សាស្ត្រសម្រាប់អភិវឌ្ឍមូលធនមនុស្សមានន័យថា ត្រូវរក្សាគោលការណ៍ចំបងខាងក្រោមជាគោលការណ៍សំខាន់៖

- ធានាឱ្យមានការកំណត់គុណភាពអប្បបរមាអត្រាស្ដីពីលទ្ធភាពទទួលបាន និងអត្រាចូលរួមនៅក្នុងការអប់រំមូលដ្ឋាន និងការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិនៅថ្នាក់ជាតិដើម្បីធ្វើជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការហ្វឹកហាត់ការងារក្នុងពេលធ្វើការព្រមទាំងសម្រាប់គ្រឹះស្ថានឧត្ដមសិក្សាផងដែរ។ ប្រការនេះមានន័យថាជាការដោះស្រាយមូលហេតុដើមនៃការបោះបង់សាលា ភាពខុសគ្នានៅក្នុងតំបន់អំពីលទ្ធភាពចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងគុណភាពព្រមទាំងកម្មវិធីសិក្សាពាក់ព័ន្ធជាមួយនឹងការចូលទៅក្នុងពិភពការងារ។ នេះគឺជាបញ្ហាប្រឈមចំបងមួយចំពោះប្រព័ន្ធអប់រំកម្ពុជា ប៉ុន្តែត្រឹមប៉ុណ្ណេះនៅពុំទាន់គ្រប់គ្រាន់ក្នុងការធានាឱ្យគោល-នយោបាយពិពិធកម្មឧស្សាហកម្មទទួលជោគជ័យដោយមិនបានអនុវត្តគំរូសេដ្ឋកិច្ចពុទ្ធិក្នុងរយៈពេលវែងនៅឡើយទេ។
- អនុវត្តអភិក្រមចំពោះការអភិវឌ្ឍមូលធនមនុស្សរយៈពេលយូរបង្កើតឱ្យមានឱកាសក្នុងការរៀនសូត្រថ្មីនៅគ្រប់ផ្នែកនៃវដ្ដជីវិត។
- ការប៉ាន់ស្មានតម្រូវការមូលធនមនុស្សមិនត្រឹមតែសម្រាប់ធុរកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បណ្ដាញនៃការបង្កើតថ្មី និងសួនធុរកិច្ចព្រមទាំងការប៉ាន់ស្មានតម្រូវការស្ដីពីការកសាងសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាលផងដែរ។
- សមាហរណកម្មដោយប្រយ័ត្នប្រយែងតាមលំដាប់នៃគោលដៅអប់រំ និងគោលដៅបណ្ដុះបណ្ដាលរយៈពេលវែងព្រមទាំងមូលដ្ឋានគោលអំពីគុណភាព ជាមួយការអប់រំក្រៅប្រព័ន្ធរយៈពេលខ្លី និងការរៀបចំការងារសារជាថ្មីដោយមិនរំពឹងថាអសង្គតិភាពជំនាញរយៈពេលខ្លីអាចត្រូវដោះស្រាយតាមរយៈកម្មវិធីបណ្ដុះបណ្ដាលចំបងនោះទេ។

- ការធ្វើឱ្យមានតុល្យភាពចំពោះការចូលរួមចំណែកនៃការរីកចម្រើនជាខ្លាំងក្នុងការអប់រំមធ្យមសិក្សា និងឧត្តមសិក្សានិងតម្រូវការក្នុងការកសាងគ្រឹះស្ថានឯកទេសប្រសើរបំផុតដែលមានលទ្ធភាពធ្វើការស្រាវជ្រាវអន្តរជាតិ និងបច្ចេកវិទ្យាចំពោះសេដ្ឋកិច្ចពុទ្ធិ ។
- ការបង្កើតផែនការផ្តល់ហិរញ្ញប្បទានរយៈពេលវែងចំពោះចំណាយសាធារណៈលើមូលធនមនុស្សនៅក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចពុទ្ធិ ដោយគិតគូរអំពីលទ្ធភាពឱ្យមានការផ្តល់ហិរញ្ញប្បទានលើកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលរវាងផ្នែកសាធារណៈ និងឯកជនដែលគេឃើញមាននៅក្នុងសេដ្ឋកិច្ចនៃបណ្តាប្រទេសនៅអាស៊ីជាច្រើន ។
- ការអភិវឌ្ឍយន្តការនៃស្ថាប័នសម្រាប់សម្របសម្រួល និងសម្រាប់ការរៀបចំកម្មវិធីរួមគ្នានៃការកសាងផែនទីយុទ្ធសាស្រ្តអំពីមូលធនមនុស្ស ត្រូវបានគេពិចារណាលើសរសរស្តម្ភទាំងបួននៃសេដ្ឋកិច្ចពុទ្ធិទំនងជាអាចមានការចូលរួមពីទីភ្នាក់ងារមិនមែនរដ្ឋាភិបាល ដូចជា ទីភ្នាក់ងារជាតិស្តីពីចំណេះដឹង ឬគណៈកម្មការផលិតភាពជាដើម ។

## *ការកសាងមូលធនមនុស្សនិងសមត្ថភាពរបស់រដ្ឋ*

១៣. ដោយសារការបង្កើតការងាររយៈពេលខ្លី និងអាទិភាពកាត់បន្ថយភាពក្រីក្រគ្របដណ្តប់ភាគច្រើននៅក្នុងគោលនយោបាយអប់រំ និងបណ្តុះបណ្តាលក្រោយពីមានវិបត្តិសេដ្ឋកិច្ចពិភពលោកមកមានការយកចិត្តទុកដាក់តិចតួចចំពោះបញ្ហាអភិវឌ្ឍមូលធនមនុស្សនៅក្នុងរដ្ឋាភិបាលខ្លួនឯង ។

១៤. ទោះជាយ៉ាងណាក្តី កម្ពុជាបន្តពង្រឹងប្រព័ន្ធប្រជាធិបតេយ្យរបស់ខ្លួន លើកកំពស់សុខុមាលភាពសង្គម ដោះស្រាយបញ្ហាសាកលមួយចំនួនចាប់តាំងពីនិយ័តកម្មហិរញ្ញវត្ថុរហូតដល់ការប្រែប្រួលធាតុអាកាស ហើយបន្តបោះជំហានទៅមុខឆ្ពោះទៅកាន់សមាហរណកម្មសេដ្ឋកិច្ចជាមួយអាស៊ាន ទិដ្ឋភាពមូលធនមនុស្សរបស់រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធកាន់តែមានសារសំខាន់ខ្លាំងឡើង ។ ហេតុនេះកត្តាគន្លឹះគឺផែនទីយុទ្ធសាស្រ្តអំពីមូលធនមនុស្សត្រូវតែភ្ជាប់ជាមួយកម្មវិធីពិពិធកម្មសេដ្ឋកិច្ច ប៉ុន្តែក៏ត្រូវធ្វើយ៉ាងណាឱ្យរដ្ឋមានជំនាញត្រឹមត្រូវ ក្នុងបរិមាណគ្រប់ គ្រាន់ដើម្បីអនុវត្តកម្មវិធីទាំងនេះ ។

១៥. អនុសាសន៍សំខាន់មួយទៀតនៃរបាយការណ៍នេះ គឺថាការបង្កើនគុណភាពនៃកំណើនតាមរយៈការលើកកំពស់ឱ្យមានលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានឱកាសអភិវឌ្ឍការអប់រំ និងអភិវឌ្ឍជំនាញ គឺជាសមាសភាពមួយដ៏សំខាន់នៃផែនទីយុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍធនធានមនុស្សនៅពេលអនាគត ។ នៅក្នុងបរិបទនៃសេដ្ឋកិច្ចដែលបានធ្វើពិពិធកម្មដើម្បីបង្កលក្ខណៈឱ្យសេដ្ឋកិច្ចនេះស្រូបយកផលិតផលថ្មីៗ និងប្រភេទថ្មីៗនៃវិនិយោគផ្ទាល់ពីបរទេស ដែលមានទំនាក់ទំនងជាមួយចំណេះដឹងលទ្ធភាពទូលំទូលាយចំពោះការទទួលបាននូវនវានុវត្តភណ្ឌ និងទទួលបាននូវ ពុទ្ធិ គឺជាផ្នែកនៃដំណើរការនៃការបង្កើនកម្រិតផលិតភាព ។ ហេតុនេះ សមធម៌នឹងបន្តមិនត្រឹមតែមានភាពទាក់ទងផ្នែកសង្គមប៉ុណ្ណោះទេ ប៉ុន្តែក៏មានភាពពាក់ព័ន្ធជាមួយសេដ្ឋកិច្ច និងផលិតភាពផងដែរ ។

## *ការវិនិយោគលើមូលធនមនុស្សនៅកម្ពុជា*

១៦. របាយការណ៍នេះពិនិត្យមើលសារឡើងវិញនូវទិន្នន័យតាមវិស័យ និងពិនិត្យមើលភាពខ្វះចន្លោះជំនាញ និងអាទិភាពនានាផ្នែកមូលធនមនុស្សនៅក្នុងវិស័យឧស្សាហកម្មសំខាន់ៗ រួមមានវិស័យកាត់ដេរសម្លៀកបំពាក់វិស័យទេសចរណ៍ និងព័ត៌មានវិទ្យា។ ខណៈពេលដែលទិន្នន័យអំពីការងារ និងទិន្នន័យនៃភាពខ្វះចន្លោះជំនាញនៅមានតិចតួចនៅឡើយ ប្រការនេះពិតជាបង្ហាញអំពីភាពចាំបាច់ឱ្យមានវិធានការជាក់ស្តែងនៅលើផ្នែកមួយចំនួន។ សំណុំវិធានការមួយចំនួនមានបង្ហាញនៅក្នុងតារាងម៉ាទ្រីសគោលនយោបាយដែលភ្ជាប់ជាមួយអត្ថបទសង្ខេបនេះ។

១៧. ជាមួយគ្នានេះផងដែរទិន្នន័យបច្ចុប្បន្នមិនអនុញ្ញាតឱ្យយើងផ្តល់អនុសាសន៍លំអិតអំពីវិធីលើកកំពស់អសង្គតិភាពនៃជំនាញវិធីផ្តល់លាភចិត្តឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈចំពោះសភាពការណ៍នៃការចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា វិធីទាក់ទាញគ្រូដែលមានជំនាញសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលជាដើម។ ការបំពេញការខ្វះចន្លោះផ្នែកព័ត៌មានអំពីការងារ និងជំនាញគឺជាអាទិភាពចំពោះមុខ។

១៨. ជាមួយគ្នានេះក៏មានសារៈសំខាន់ផងដែរក្នុងការយល់ដឹងឱ្យបានពេញលេញអំពីកង្វល់ស្តីពី "កង្វះជំនាញផ្នែកទន់" ដែលនិយោជកកម្ពុជាតែងតែលើកឡើងជារឿយៗ។ ជាងនេះទៅទៀតនោះគំនិតផ្តួចផ្តើមទូលំទូលាយផ្នែកសេដ្ឋកិច្ចមួយចំនួនអាចដោះស្រាយបញ្ហានេះជាច្រើន ដូចជា ភាពទាន់ពេលវេលាភាពមានសុជីវធម៌ និងឥរិយាបថធ្វើការតាមរយៈបច្ចេកទេសទូរសិក្សានៅថ្នាក់ជាតិត្រូវបានប្រើនៅក្នុងយុទ្ធនាការអប់រំនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដូចជានៅប្រទេសម៉ិចស៊ិកូ ជាដើម។

១៩. ទិដ្ឋភាពសំខាន់បំផុតនៃគោលនយោបាយអនាគតអំពីការអភិវឌ្ឍមូលធនមនុស្សគឺការសម្របសម្រួលយន្តការនានាដើម្បីដាក់បញ្ចូលជាអាទិភាពរយៈពេលវែង និងខ្លី។ ក្នុងសភាពដែលការវិនិយោគលើមូលធនមនុស្សគឺជាសកម្មភាពអភិវឌ្ឍ រយៈពេលវែងការរួមវិភាគទានមួយនៃការរួមវិភាគទានសំខាន់ៗនៃផែនទីយុទ្ធសាស្ត្រ ស្តីពីមូលធនមនុស្សគឺដើម្បីបង្កើតក្របខណ្ឌមួយដែលមានរយៈពេលវែង និងមានលំដាប់លំដោយក្នុងនោះគេអាចដោះស្រាយបាននូវកង្វល់ ស្តីពីការឆ្លើយតបនឹងវិបត្តិ។ សំណើតារាងម៉ាទ្រីស ដែលភ្ជាប់ជាមួយនេះបានបង្ហាញពីការកសាងគោលនយោបាយបង្កើតបានជាមូលដ្ឋានគ្រឹះអំពីវិធីដែលគេអាចធ្វើកិច្ចនេះតទៅទៀត។

## *មូលធនមនុស្សនៅកម្ពុជា: មូលហេតុដើម្បីឱ្យមានសុទិដ្ឋិនិយម*

២០. ការកសាងផែនទីយុទ្ធសាស្ត្រ ស្តីពីមូលធនមនុស្សស្របជាមួយពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជាការកសាងសមត្ថភាពរបស់រដ្ឋ និងផែនការសុខុមាលភាពសង្គមតម្រូវឱ្យធ្វើការងារដោយប្រយ័ត្នប្រយែង។ ទោះជាយ៉ាងណាក្តីមានវិធីតែមួយគត់ក្នុងការបង្កាការកើនឡើងនូវឧបសគ្គសម្រាប់រចនាសម្ព័ន្ធក្នុងពេលអនាគត ដូចជា ឧបសគ្គទាំងឡាយដែលមាននៅក្នុងទសវត្ស ១៩៩៨-២០០៨។ ទោះជាយ៉ាងណាក្តីការសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចដ៏សម្បើមរបស់កម្ពុជាក្នុងរយៈពេលពីរទសវត្សកន្លងទៅប្រាកដណាស់ថាគេអាចសម្រេចកិច្ចការនេះបាន។

២១. កម្ពុជាមានលក្ខណៈសម្បត្តិដ៏ធំធេង ដែលថាទោះបីជាធ្លាប់មានប្រវត្តិកាលពីពេលកន្លងទៅថ្មីៗអំពីទំនាស់ការបាត់បង់មូលធនមនុស្សអស្ថេរភាពនយោបាយ និងទំនាស់សង្គមទាំងនេះជាព្រឹត្តិការណ៍ដែលអាចជម្រុញឱ្យប្រទេសដទៃទៀតចូលទៅក្នុងសភាពខ្វះចខ្វាំផ្នែកស្ថាប័ន និងការភាពហិនហោចផ្នែកសេដ្ឋកិច្ច ប៉ុន្តែ កម្ពុជាបានព្យាយាមពង្រឹងប្រព័ន្ធនយោបាយថ្មីមួយនៃលទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោតដែលបាននាំផ្លូវនៅក្នុងអំឡុងពេលមានកំណើន ហើយបានបង្កើនការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួនយ៉ាងឆាប់រហ័ស។

២២. ជាងនេះទៅទៀតកម្ពុជាមិនត្រឹមតែងើបឡើងវិញពីទំនាស់សង្គម និងពីការបាត់បង់មូលធនមនុស្សប៉ុណ្ណោះទេ កម្ពុជាបានធ្វើឱ្យមានការប្រែប្រួលក្នុងទ្រង់ទ្រាយធំនូវផ្នែកស្ថាប័នដោយបានកសាងប្រភពថ្មីៗទាំងស្រុងនៃកំណើន និងការងារដូចជាការធ្វើឱ្យមានកម្មករស្ត្រីដ៏ច្រើនសន្ធឹកសន្ធាប់ចូលរួមជាកម្លាំងពលកម្មដោយកម្ពុជាបានសម្រេចចិត្តបោះបង់ចោលនូវប្រព័ន្ធសេដ្ឋកិច្ចផែនការនៅថ្នាក់កណ្តាលទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបើកចំហររហូតដល់ការចូលជាសមាជិកអង្គការអន្តរជាតិ និងអង្គការអន្តរតំបន់ព្រមទាំងទីភ្នាក់ងារនានា (ដូចជា អាស៊ានជាដើម) ហើយបានផ្តួចផ្តើមជាប្រព័ន្ធផ្លូវការ និងមានការចាត់តាំងឱ្យមានការពិភាក្សាជាទៀងទាត់ជាមួយវិស័យឯកជន។ ជាមួយគ្នានេះផងដែរ កម្ពុជាត្រូវតស៊ូជាមួយផលវិបាកអវិជ្ជមានពីវិបត្តិសេដ្ឋកិច្ចដ៏ធំធេងចំនួនពីរ លើកដំបូងក្នុងទ្រង់ទ្រាយជាវិបត្តិសេដ្ឋកិច្ចនៅអាស៊ីដែលស្ថិតនៅក្បែរប្រទេសកម្ពុជា និងលើកទីពីរជាវិបត្តិដែលមានទ្រង់ទ្រាយសាកលមានប្រភពចេញមកពីវិបត្តិបំណុលអចលនទ្រព្យនៅសហរដ្ឋអាមេរិក។ ជាការឆ្លើយតបកម្ពុជាមិនត្រឹមតែមិនអនុវត្តលទ្ធិគាំពារនិយមប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើនការចូលរួមរបស់ខ្លួនជាមួយវិស័យឯកជន ហើយបានអញ្ជើញអង្គការផ្តល់ជំនួយឱ្យធ្វើការជាមួយវិស័យនេះលើផ្នែកស្មុគស្មាញជាច្រើននៃគោលនយោបាយ សេដ្ឋកិច្ច ចាប់ពីប្រសិទ្ធភាពជំនួយរហូតដល់ភាពប្រកួតប្រជែងអន្តរជាតិ បរិយាកាសវិនិយោគទីផ្សារការងារ និងតម្រូវការមូលធនមនុស្សផងដែរ។

២៣. ខណៈដែលកំណើននាពេលអនាគតមិនទំនងជាកើតឡើងដដែលនូវអ្វីដែលបានកើតឡើងពីអតីតកាលដោយសារមានការពិនិត្យយ៉ាងយកចិត្តទុកដាក់នៅក្នុងរបាយការណ៍របស់ធនាគារពិភពលោក អំពីស្ថានភាពកំណើនរបស់កម្ពុជា និងដែលមានបញ្ជាក់នៅក្នុងរបាយការណ៍នេះទស្សនៈវិស័យហាក់ដូចជាមិនអាក្រក់ដូចដែលអាចកើតមានតាមការរៀបរាប់នៃទិន្នន័យសេដ្ឋកិច្ចសាកលអង្កេតស្តីពីភាពប្រកួតប្រជែង ឬគុណភាពនៃវិនិយោគផ្ទាល់ពីបរទេស និងសភាពងាយរុះរើនៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់អន្តរជាតិនោះទេ។ កម្មវិធីពិពិធកម្មសេដ្ឋកិច្ចនៅក្នុងក្របខណ្ឌនៃផលិតភាពសេដ្ឋកិច្ចពុទ្ធិ គឺជាផ្នែកមួយនៃរបៀបវារៈគោលនយោបាយនេះ។ ការកសាងផែនទីយុទ្ធសាស្ត្រអំពីការអភិវឌ្ឍមូលធនមនុស្សចាប់ផ្តើមពីទស្សនៈរយៈពេលវែង និងការដាក់បញ្ចូលកង្វល់ស្តីពីទីផ្សារ ការងារ និងការខ្វះចន្លោះជំនាញរយៈពេលខ្លី គឺជាផ្នែកសំខាន់មួយទៀត។ វិធីមួយដើម្បីដោះស្រាយបញ្ហានេះគឺត្រូវផ្តល់ផែនទីយុទ្ធសាស្ត្រអំពីមូលធនមនុស្សពេញលេញមួយទៅឱ្យអ្នកតាក់តែងគោលនយោបាយនៅក្នុងកិច្ចប្រជុំលើកក្រោយនៃវេទិកាសេដ្ឋកិច្ចកម្ពុជាដោយប្រើបច្ចេកទេសវិភាគសាកល និងបទពិសោធន៍របស់កម្ពុជា។

"...ការរួមវិភាគទានមួយនៃការរួមវិភាគទានសំខាន់ៗនៃផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្ស គឺដើម្បីបង្កើតក្របខ័ណ្ឌមួយដែលមានរយៈពេលវែង និងមានលំដាប់លំដោយ...។"

## អនុសាសន៍ផ្នែកគោលនយោបាយ[១]

**អន្តរាគមន៍ចំពោះមុខ**

***ការឆ្លើយតបនឹងវិបត្តិ និងការងើបឡើងវិញ***

- ការកាត់បន្ថយភាពក្រីក្រ
- បង្កើនសំណាញ់សុវត្ថិភាពសង្គម និងធានាឱ្យសំណាញ់សុវត្ថិភាពមានការផ្តល់មូលនិធិឱ្យបានគ្រប់គ្រាន់
- ការដោះស្រាយចំណាកស្រុកក្នុងប្រទេស
- ការលើកកំពស់ការអភិវឌ្ឍផ្នែកឯកជននិងសហប្រតិបត្តិការ

***ការដោះស្រាយនិកម្មភាព***

- កំណត់មុខសញ្ញាទៅកាន់ពលរដ្ឋ និងសហគមន៍ក្រីក្រនៅជនបទដែលរងផលប៉ះពាល ធ្ងន់ធ្ងរបំផុត ពីវិបត្តិសេដ្ឋកិច្ច
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលប្រើប្រាស់អតិពលកម្ម និងលើកទឹកចិត្តឱ្យមានការ អភិវឌ្ឍក្នុងស្រុក
- លើកកំពស់ព័ត៌មានទីផ្សារការងារ

***ការបញ្ឈប់ការបោះបង់ការសិក្សា***

- បង្កើនឧបត្ថម្ភធន សម្រាប់បន្ត ការសិក្សា
- ពង្រឹងនិងពង្រីកកម្មវិធីអាហារូបករណ៍ សម្រាប់សិស្សក្រីក្រ (អាហារូបករណ៍មធ្យមសិក្សា បឋមភូមិ និងអនុវត្តសាកល្បងអាហារូបករណ៍កម្រិតបឋមសិក្សា)
- បង្កើនអាយុអប្បបរមាក្នុងការចាកចេញពីសាលារៀន

***កសាងប្រព័ន្ធដែលមានលទ្ធភាពទាញយកទិន្នន័យ និងព័ត៌មានស្តីពីស្ថិតិអប់រំ និងស្ថិតិឧស្សាហកម្ម***

- បង្កើតប្រព័ន្ធព័ត៌មានស្តីពីស្ថិតិអប់រំ និងស្ថិតិឧស្សាហកម្ម
- បង្កើតប្រព័ន្ធដែលមានលទ្ធភាពវិភាគ និងធ្វើប្រព្រឹត្តកម្មព័ត៌មានដែលបានប្រមូលមកពីកម្រងទិន្នន័យព័ត៌មានដើម្បីរៀបចំបង្កើតគោលនយោបាយសមស្រប

**អន្តរាគមន៍រយៈពេលខ្លី**

***ការបំពេញភាពខ្វះចន្លោះនៃជំនាញ***

- លើកកំពស់ការបណ្តុះបណ្តាលបែបសាមញ្ញដើម្បីបង្កើនជំនាញផ្នែកទន់ និងជំនាញផ្នែករឹង
- កំណត់អត្តសញ្ញាណ និងពង្រីកការបណ្តុះបណ្តាលចំពោះផ្នែកសំខាន់ៗដែលត្រូវការ បង្កើនការផ្តល់ជំនាញ
- ធានាឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ចំពោះកម្មវិធីបណ្តុះបណ្តាលថ្មីៗ និងកម្មវិធីកសាងជំនាញ

## អនុសាសន៍ផ្នែកគោលនយោបាយ (ត)

**អន្តរាគមន៍ពីរយៈពេលខ្លីដល់រយៈពេលវែង**

***លើកកំពស់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ***

- បង្កើនភាពងាយបត់បែន និងការរៀបចំការបណ្ដុះបណ្ដាលឱ្យទៅជាម៉ូឌុល
- បង្កើនប្រព័ន្ធធានារ៉ាប់រងគុណភាពនៅក្នុង ទូទៃ
- លើកកំពស់គុណភាពមណ្ឌលផ្ដល់សេវានិងបរិក្ខារ ទូទៃ
- ការបើកទ្វារចំហរវាង ទូទៃ និងការអប់រំកម្រិតឧត្ដមសិក្សា
- ការពង្រីកអ្នកផ្ដល់សេវាឯកជន និងអ្នកផ្ដល់សេវា ណអឿ ទូទៃ

**អន្តរាគមន៍រយៈពេលវែង**

***កែទម្រង់ការអប់រំកម្រិតឧត្ដមសិក្សា***

- រៀបចំចាត់តាំងសារជាថ្មីនូវការគ្រប់គ្រង អភិបាលកិច្ច និងការផ្ដល់ហិរញ្ញប្បទាននៃ គ្រឹះស្ថានឧត្ដមសិក្សា
- ការបង្កើន និងធ្វើឱ្យការផ្ដល់មូលនិធិ សម្រាប់ឧត្ដមសិក្សាមាននិរន្តរភាព

***កំណែទម្រង់រដ្ឋាភិបាល និងស្ថាប័ន***

- រដ្ឋាភិបាលផ្ដោតការយកចិត្តទុកដាក់លើការប្ដូរទៅកាន់ការចូលរួមដែលមានលក្ខណៈ សហប្រតិបត្តិការនៅក្នុងប្រព័ន្ធឧត្ដមសិក្សា
- ការបង្កើនហប្រតិបត្តិកររវាងរដ្ឋាភិបាលនិងផ្នែកឯកជន

***ការរៀនសូត្រពេញមួយជីវិត***

- ការបង្កើតចក្ខុវិស័យរៀនសូត្រពេញមួយជីវិតសម្រាប់កម្ពុជា
- ការបង្កើនការយកចិត្តទុកដាក់លើផលចំណេញរបស់បុគ្គលដែលបានទទួលពីការរៀនសូត្រ នៅក្នុងអាយុជីវិតរស់នៅរបស់ខ្លួន
- ការបង្កើនការសម្របសម្រួល និងការកាត់បន្ថយភាពមិនចុះសម្រុងអំពីស្ដង់ដារនៃ គុណវុឌ្ឍិនៃការសិក្សាអប់រំ

---

១ For more information on policy recommendations, see Annexes ។



© 2001, UNDP/Arantxa Cedillo

# ជំពូក ១ : មូលធនមនុស្ស និងកំណើនសេដ្ឋកិច្ច

## ១.១. សេចក្តីផ្តើម

"មានមន្ទិលបន្តិចថា វិបត្តិហិរញ្ញវត្ថុសកល បច្ចុប្បន្នបានបង្កគ្រោះថ្នាក់ខាងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ដល់ល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។"

មានមន្ទិលបន្តិចបន្តួចថា វិបត្តិហិរញ្ញវត្ថុសកលបច្ចុប្បន្នបានបង្កគ្រោះថ្នាក់ខាងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដល់ល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។ មូលហេតុគន្លឹះមួយចំពោះវិបត្តិនេះគឺសេដ្ឋកិច្ចកម្ពុជាក្នុងមួយទសវត្សរ៍កន្លងមកពឹងផ្អែកយ៉ាងខ្លាំងលើមុខព្រួញសេដ្ឋកិច្ចបី គឺ : ទេសចរណ៍ វាយនភណ្ឌ និងសំណង់។ មូលហេតុគន្លឹះមួយទៀតជាក់ស្តែងណាស់ព្រោះភាពធ្ងន់ធ្ងរ និងការកើតឡើងបន្ទាន់ពេកនៃវិបត្តិសេដ្ឋកិច្ចសកលបានប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចនៃប្រទេសមួយ ដូចជាកម្ពុជាដែលធ្លាប់ទទួលបានកំណើនប្រចាំឆ្នាំ ១០% ក្នុងកំឡុងដប់ឆ្នាំមុនមានវិបត្តិកើតឡើង។ ការធ្លាក់ចុះនៃកំណើនប្រចាំឆ្នាំ ពី ១០% មកត្រឹមកម្រិតមួយទាបបំផុត ជាបទពិសោធគួរឱ្យរន្ធត់មួយដែលធ្លាប់កើតឡើងនៅអតីតសហភាពសូវៀតក្នុងដើមទសវត្សរ៍ ១៩៩០ ឬប្រទេសឥណ្ឌូនេស៊ីក្នុងឆ្នាំ១៩៩៨/៩៩។ចំពោះករណីវិបត្តិនៅប្រទេសទាំងពីរនេះ នៅពេលចុងបញ្ចប់នៃវិបត្តិការស្តារសេដ្ឋកិច្ចឡើងវិញត្រូវចំណាយពេលវេលាយូរជាងការគិតខ្លាំងណាស់។ បញ្ហានេះក៏បង្ហាញឱ្យឃើញដែរអំពីភាពខ្វះខាតនៃសមត្ថភាពតាមស្ថាប័ន និងខ្វះអភិបាលកិច្ចដែលត្រូវកែតម្រូវជាចំខាត។

ដោយសារប្រវត្តិសាស្ត្រដ៏រំខានបំផុតរបស់កម្ពុជាបង្កឡើងដោយសាររបបខ្មែរក្រហមក្នុងពាក់កណ្តាលទសវត្សរ៍ ១៩៧០ វិបត្តិសេដ្ឋកិច្ចបច្ចុប្បន្នក៏ពុំបានកើតឡើងធ្ងន់ធ្ងរពេកទេ។ ក្នុងទសវត្សរ៍ចុងក្រោយ គឺមួយចតុភាគនៃសតវត្សរ៍ចុងក្រោយនេះ ស្ថានភាពនយោបាយបានវិលត្រលប់មករកភាពធម្មតាវិញ ហើយសេដ្ឋកិច្ចមានភាពជឿនលឿនដែលបន្ទាប់មកក៏មានភាពរីកវរចលាចលនៃអំពើហិង្សានយោបាយ និងសង្គម ហើយផលិតកម្មកសិកម្មទាបក៏នៅទ្រឹងទៀត។ ក្នុងទសវត្សរ៍ចុងក្រោយនេះ ឃើញមានកំណើនរហូតដល់ពីរខ្ទង់ដែលកើនពីកម្រិតមូលដ្ឋានទាប។ ផលចំណេញបានពីសន្តិភាពកើតឡើងម្តងក៏ជាចំណែកមួយនៃរឿងទាំងមូលអំពីកំណើននេះដែរ។ ការប្រឹងប្រែងយ៉ាងជាក់លាក់មួយដើម្បីប្តូរពីសេដ្ឋកិច្ចផែនការមកកាន់សេដ្ឋកិច្ចផ្សារសេរី និងប្តូរពីការតស៊ូជម្លោះនយោបាយយ៉ាងក្តៅគគុកមកកាន់ការបោះឆ្នោតប្រជាធិបតេយ្យ ក៏ជាចំណែកមួយនៃរូបភាពរួមរបស់ប្រទេសនេះផងដែរ។ សូចនាករសេដ្ឋកិច្ច ដូចជាអត្រាផលធៀបនៃការវិនិយោគបរទេសផ្ទាល់ជាមួយផលិតផលក្នុងស្រុកសរុប ឬធៀបនឹងអត្រាអ្នកមានការងារធ្វើក្នុងវិស័យឧស្សាហកម្មវាយនភ័ណ្ឌ ឬធៀបនឹងកំណើនពុះកញ្ជ្រោលនៃអចលនវត្ថុនៅភ្នំពេញបានលាក់បិទបាំងនូវចំណែកនៃរឿងគួរឱ្យចាប់អារម្មណ៍ជាច្រើនទៀតពាក់ព័ន្ធនឹងស្ថិរភាពសង្គម គំនិតនយោបាយ និងកំណែទម្រង់ស្ថាប័ន។ ចំណែកនៃរឿងនេះជាបេះដូងនៃកំណត់ហេតុកំណើនយ៉ាងអស្ចារ្យរបស់កម្ពុជា កាលពីទសវត្សរ៍១៩៩៨-២០០៨។

អ្នកតាក់តែងគោលនយោបាយកម្ពុជា ព្យាយាមយ៉ាងខ្លាំងក្លាក្នុងការកាច់ចង្កូតសេដ្ឋកិច្ច និងសង្គមឱ្យចេញផុតពីការធ្លាក់ចុះធ្ងន់ធ្ងរនៃសេដ្ឋកិច្ច និងពីវិបត្តិសង្គមម្តងទៀតកម្ពុជានៅតែប្រឈមនឹងកាលៈទេសៈអភិវឌ្ឍន៍ដែលមិនធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រ។ សេដ្ឋកិច្ចកម្ពុជាក្នុងពេលអនាគតត្រូវផ្តោតការយកចិត្តទុកដាក់លើការស្តារសេដ្ឋកិច្ចឡើងវិញ។ ទីមួយ ភាពធ្ងន់ធ្ងរនៃវិបត្តិសេដ្ឋកិច្ចសកលកើតឡើងនៅប្រទេសអភិវឌ្ឍន៍នៅអាមេរិកខាងជើង និងអឺរ៉ុប បានបង្កការផ្លាស់ប្តូរនៃកម្លាំងទាញរបស់សេដ្ឋកិច្ច ឆ្ពោះទៅរកសេដ្ឋកិច្ចធំៗរបស់អាស៊ី ជាពិសេសឥណ្ឌា និងចិន ហើយអាចមានឥណ្ឌូនេស៊ីផងដែរ។ ទីពីរ ការងើបឡើងវិញ

"...ទម្រង់នៃកំណើនកាលពីអតីតកាល ប្រហែលជាមិនអាចចាត់ទុកជាគោលការណ៍ល្អមួយសំរាប់ការស្តារសេដ្ឋកិច្ចក្នុងពេលអនាគតបានទេ។"

ចេញផុតពីវិបត្តិហិរញ្ញវត្ថុអាស៊ី ឆ្នាំ១៩៩៧-១៩៩៨ បាននាំឱ្យមានការផ្លាស់ប្តូរទម្រង់ពាណិជ្ជកម្មនៅតំបន់អាស៊ាន និងរវាងអាស៊ាន និងសេដ្ឋកិច្ចនៃប្រទេសជិតខាងអាស៊ីដែរ។ ការប្រែប្រួលនេះក៏ជំរុញឱ្យមានសមាហរណកម្ម ពាណិជ្ជកម្មក្នុងតំបន់យ៉ាងធំទូលាយជាងមុនដែរ ដោយមានពន្យល់យ៉ាងច្បាស់ក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគីជាច្រើនក្នុងតំបន់នេះដែរ។ ទីបី សកលភាវូបនីយកម្មបន្តកាត់បន្ថយចំណាយដឹកជញ្ជូន និងទូរគមនាគមន៍កែប្រែខ្សែចង្វាក់ផ្គត់ផ្គង់ និងបណ្តាញផ្គត់ផ្គង់ និងបន្តពង្រីកលំហូរហិរញ្ញវត្ថុ និងពលកម្មឆ្លងប្រទេសផងដែរ។

ផលវិបាកធំៗនៃការអភិវឌ្ឍក្នុងសេដ្ឋកិច្ចអន្តរជាតិ និងតំបន់នៅអាស៊ី គឺថា ពិភពលោកទាំងមូលមិនឈរទ្រឹងមួយកន្លែងទេ ហើយប្រទេសមួយ ឬតំបន់មួយពិតជាងើបចេញផុតពីវិបត្តិសេដ្ឋកិច្ច ឬវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរនោះបាន។ វិបត្តិជារយៈពេលនៃការកែប្រែសេដ្ឋកិច្ច និងនយោបាយឱ្យស្របជាមួយឧស្សាហកម្មដែលផ្លាស់ប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយទៀត ហើយវិនិយោគិនតែងផ្លាស់ប្តូរទៅរកកន្លែងដែលមានសុវត្ថិភាពបំផុត ហើយការចំណាយរបស់រដ្ឋាភិបាលផ្លាស់ប្តូរពីការវិនិយោគទៅរកសុខុមាលភាពសង្គម និងឧបត្ថម្ភធន។ ដូច្នេះ វិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរបានបង្កើតជាចម្ងល់មួយអំពីវិសាលភាពនៃការងើបឡើងវិញនៃសេដ្ឋកិច្ចបច្ចុប្បន្នយកទៅជំនួសកំណើន និងការប្រកួតប្រជែងនៃសេដ្ឋកិច្ចដែលធ្លាប់មាន កំណើនខ្ពស់កាលពីអតីតកាលបានកម្រិតណា ឬលើកជាចម្ងល់អំពីការងើបឡើងវិញនៃសេដ្ឋកិច្ចដែលអាចជំនួសអថេរនៃការប្រែប្រួលបច្ចេកវិទ្យា តម្លៃ និងពាណិជ្ជកម្មក្នុងទីផ្សារអន្តរជាតិដែរ។ និយាយឱ្យសាមញ្ញ និងងាយយល់ការងើបឡើងផុតពី ការប៉ះទង្គិចធ្ងន់ធ្ងរនៃឥទ្ធិពលនៃវិបត្តិនេះទម្រង់នៃកំណើនកាលពីអតីតកាល ប្រហែលជាមិនអាចចាត់ទុកជាគោលការណ៍ ល្អមួយសម្រាប់ការស្តារសេដ្ឋកិច្ចក្នុងពេលអនាគតបានទេ។

## ១.២. មូលធនមនុស្ស និងសេដ្ឋកិច្ចពុទ្ធិ និងកំណើនសេដ្ឋកិច្ច : ឆ្ពោះទៅរបត់ថ្មី

### *១.២.១ ការកើនឡើងនៃមូលធនមនុស្ស*

ជាការជាក់ច្បាស់ណាស់ថា ក្នុងបរិបទនៃកម្លាំងចលករនៃកំណើនសេដ្ឋកិច្ចសកល គឺថាសំណួរអំពីការបង្កើតមូលធនមនុស្សគឺកាន់តែមានសារៈសំខាន់ខ្លាំងឡើងថែមទៀត។ ជាកាពិតផ្សារសេរីទិសដៅនាំចេញ និងការកើនឡើងនៃកម្រិតអក្ខរកម្ម ត្រូវបានចាត់ទុកជាការពន្យល់ដ៏មានសារៈសំខាន់បំផុតអំពីអច្ឆរិយភាពនៃសេដ្ឋកិច្ចអាស៊ី។ ក្នុងន័យនេះមូលធនមនុស្សនិយាយទាំងអំពីជំនាញមូលដ្ឋាន និងអំពីវិស័យការងារ (សមាសធាតុនៃ "តម្លៃអាស៊ី") ជាលក្ខខណ្ឌពិសេសនៃគោលនយោបាយរបស់រដ្ឋាភិបាលក្នុងសេដ្ឋកិច្ចបែបថ្មីរបស់អាស៊ីខាងកើត។ បញ្ហានេះមិនមែនកើតឡើងដោយមិនមានគំនិតផ្ទុយគ្នានោះទេព្រោះមានការជជែកគ្នារកអំណះអំណាងអំពីប្រភព និងនិរន្តរភាពនៃកំណើនសេដ្ឋកិច្ចក្នុងអច្ឆរិយប្រទេសនៅអាស៊ីនេះផងដែរ។

ក្នុងន័យនេះ កត្តាអំណោយផលសម្រាប់កំណើនដែលជួយជំរុញដល់ការសម្រេចសមិទ្ធផលនៃកំណើននៅប្រទេសអាស៊ីខាងកើតនៅតែជាបញ្ហាមួយនៃជម្លោះដោយមានគំនិតជជែកផ្លាស់ប្តូរគ្នាច្រើនរវាងអ្នកដែលមើលឃើញកំណើនសេដ្ឋកិច្ចក្នុងតំបន់កំពុងដឹកនាំដោយកត្តាកំណើនតែមួយមុខ (ភាគច្រើនគឺមូលធន និងពលកម្ម) និងអ្នកដែលមើលឃើញផលិតភាពនៃកំណើន (មានមូលធនច្រើន និងពលកម្ម) ជាមួយនឹងអ្នកដែលមើលឃើញកត្តាផលិតកម្មរួមជាកត្តាសំខាន់ជាង ព្រោះល្បឿននៃការផ្លាស់ប្តូរកម្លាំងពលកម្មតាមវិស័យប្តូរពីកសិកម្មទៅឧស្សាហកម្ម និងការធ្លាក់ចុះសេវាកម្ម ហើយតម្លៃប្រាក់ឈ្នួលឡើងថ្លៃ។ លទ្ធផលនៃការកើនឡើងមូលធន គឺមិនធានានិរន្តរភាពក្នុងសេដ្ឋកិច្ចអាស៊ីទេព្រោះប្រាក់សន្សំក្នុងប្រទេស និងអត្រា

វិនិយោគកំពុងឡើងខ្ពស់ដល់ចំណុចកំពូល និងព្រោះការវិនិយោគបរទេសផ្ទាល់ប្រមូលផ្តុំនៅប្រទេសមួយចំនួន មិនទៅប្រមូលផ្តុំនៅប្រទេសផ្សេងៗទៀត។

ថ្វីបើមានការចាប់អារម្មណ៍ជាបន្តបន្ទាប់អំពីកំណើនសម្រាប់ពន្យល់ និងបង្ហាញនូវភាពខុសគ្នាអំពីទស្សនៈនៃសារៈសំខាន់របស់ផលិតភាព ដោយប្រើកត្តាគណនាកំណើនយកមកពន្យល់អំពីកំណើនសេដ្ឋកិច្ចខ្ពស់នៅអាស៊ីខាងកើតក៏ទស្សនៈទូលំទូលាយមួយយល់ថា ការវិនិយោគលើមូលធនមនុស្ស ជាពិសេសនៅដំណាក់កាលដំបូងនៃកំណើនជាកត្តាសំខាន់ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងក្នុងការទាក់ទាញវិនិយោគបរទេសផ្ទាល់ឱ្យចូលមកក្នុងតំបន់នេះច្រើនផងដែរ។[២] ការចាប់អារម្មណ៍ច្រើនលើបរិបទនៃសេដ្ឋកិច្ចរបស់អាស៊ីខាងកើតគឺមានការកើនឡើងយ៉ាងរហ័សនៃអត្រាសិស្សចុះឈ្មោះចូលរៀននៅបឋមសិក្សាកើនខ្ពស់ និងការកើនឡើងនៃអត្រាអក្ខរកម្មហើយការពិតមួយទៀតគឺថាអត្រាអក្ខរកម្មរវាងបុរស និងស្ត្រីមានភាពខុសគ្នាកាន់តែតិច។

លទ្ធផលរួម គឺជោគជ័យនៃការផ្ទេរកំលាំងពលកម្មយ៉ាងច្រើន ពីជនបទមកកាន់ឧស្សាហកម្មថ្មីត្រូវការពលកម្មខ្ពស់ ដូចជា កាត់ដេរ វាយនភ័ណ្ឌ ស្បែកជើង និងការតម្លើងគ្រឿងអេឡិចត្រូនិចនៅទីក្រុងនៃប្រទេសអាស៊ីខាងកើត។ ទិដ្ឋភាព រួមនេះ មានអត្រាស្មានផលចំណេញទទួលបានពីការអប់រំបឋមសិក្សាមកគាំទ្រ។ ការប៉ាន់ស្មានលើកដំបូងបង្ហាញថា ផលចំណេញទទួលបានពីការអប់រំបឋមសិក្សា គឺបានខ្ពស់ជាងផលចំណេញទទួលបានពីការវិនិយោគលើការអប់រំមធ្យមសិក្សា ឬឧត្តមសិក្សា។ ភស្តុតាងបញ្ជាក់ថាសេដ្ឋកិច្ចអាស៊ីខាងកើត គឺមិនត្រឹមតែផ្តោតតែលើការនាំចេញ និងការអភិវឌ្ឍមូលធនមនុស្សទេ ប៉ុន្តែក៏ផ្តោតលើការវិនិយោគសាធារណៈឱ្យបានគ្រប់គ្រាន់សម្រាប់ការអប់រំ និងបណ្តុះបណ្តាលឱ្យត្រឹមត្រូវដែរ។

វិបត្តិសេដ្ឋកិច្ចអាស៊ីបញ្ជាក់អំពីចំណុចផ្លាស់ប្តូរក្នុងគំនិតអភិវឌ្ឍន៍។ វិបត្តិនេះមិនត្រឹមតែបង្ហាញពីភាពគ្រោះថ្នាក់នៃសកលភាវូបនីយកម្មដែលមានជាប់ប្រទាក់ក្រឡាគ្នា ដូចជា ការកើនឡើងមូលធនយ៉ាងឆាប់ជំងឺឆ្លងក្នុងតំបន់ការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុ និងអតិផរណាប្រែប្រួលខ្លាំងគំរាមកំហែងបង្វែរថយក្រោយមករកចំណុចដើមវិញនៃកំណើនសេដ្ឋកិច្ច និងកំណើនប្រាក់ចំណូលប្រចាំឆ្នាំកាលពីច្រើនទសវត្សរ៍មុន។ វិបត្តិនេះបង្ហាញថាការស្តារសេដ្ឋកិច្ចអាចពាក់ព័ន្ធនឹងកំណែទម្រង់សេដ្ឋកិច្ចទូទាំងវិស័យ និងកំណែទម្រង់តាមស្ថាប័ន។ វិបត្តិសេដ្ឋកិច្ចសកល ឆ្នាំ២០០៨ បង្ហាញរឹតតែច្បាស់ថែមទៀតថា វិបត្តិហិរញ្ញវត្ថុ និងដំណើរថយក្រោយនៃសេដ្ឋកិច្ចមិនត្រឹមតែជាកត្តាបំរុងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលបានធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាជាកត្តាបំរុងរបស់ប្រទេសអភិវឌ្ឍន៍ឧស្សាហកម្មផងដែរ។

វិបត្តិសេដ្ឋកិច្ចសកលបច្ចុប្បន្ន បង្ហាញអំពីអ្វីដែលមនុស្សជាច្រើនសង្ស័យ ចាប់តាំងពីដំណាក់កាលដំបូលនៃសកលភាវូបនីយកម្មពីពាក់កណ្តាលទសវត្សរ៍១៩៩០: ការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងគំហុកព្រោះតម្លៃនៃការដឹកជញ្ជូន និងបច្ចេកវិទ្យា ទំនាក់ទំនង ការបង្កើតទីផ្សារមូលធនសកល ជាមួយនឹងវិនិយោគិនជាច្រើនដែលស្វែងរកឱកាសថ្មីសម្រាប់វិនិយោគ? និងការផ្លាស់ប្តូរខ្សែចង្វាក់ផ្គត់ផ្គង់ដែលបង្កើតឱ្យមានចលនានៃមូលធន? និងពលករជំនាញ ហើយបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះការកំណត់អំពីការរីកចម្រើនក្នុងវេទិកាប្រកួតប្រជែងអន្តរជាតិថ្មីៗជាច្រើន។

តាមការពិតនៅពេលប្រទេសដែលរងផលប៉ះពាល់នៃវិបត្តិនៅអាស៊ីខាងកើតព្យាយាមធ្វើឱ្យប្រសើរឡើងនូវអត្រាឯកទកម្មប្រវត្តិសាស្ត្រស្រដៀងគ្នានៃកំណើនសេដ្ឋកិច្ចគ្រប់គ្រងតម្លៃនៃវិបត្តិសេដ្ឋកិច្ច តាមរយៈ

២ សូមអាន World Bank-East Asian Economic Miracle, and ADB (1997), Resurgent Asia

គោលនយោបាយសុវត្ថិភាព សង្គម និងវិធានការកាត់បន្ថយភាពក្រីក្រ ធ្វើកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីទប់ស្កាត់ការធ្លាក់ចុះនៅពេលអនាគត និងរក្សាបាននូវភាពស្អាតស្អំនៃថវិការដ្ឋ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងបំណុល និងកំណែទម្រង់ប្រព័ន្ធថវិកាដោយពិចារណាលើកត្តាកំណត់លើសមត្ថ-ភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចពេលអនាគតដែលបានចាប់ផ្តើមផ្លាស់ប្តូរទម្រង់រួចហើយ។ គំនិតថ្មីៗអំពីកំណើនសេដ្ឋកិច្ចសកលមានបង្ហាញក្នុងអត្ថបទដកស្រង់ចេញពីឯកសាររបស់ក្រុមការងារ ស្តីពីការអប់រំឧត្តមសិក្សា និងសង្គមរបស់ UNESCO/World Bank (២000):

> សេដ្ឋកិច្ចពិភពលោកកំពុងមានការប្រែប្រួលព្រោះចំណេះដឹងជាអ្នកមកជំនួសមូលធនរូបវ័ន្តជាប្រភពនៃទ្រព្យបច្ចុប្បន្ន និងអនាគត។ បច្ចេកវិទ្យាបូករួមជាមួយបច្ចេកវិទ្យាព័ត៌មាន ជីវបច្ចេកវិទ្យា និងនវានុវត្តភណ្ឌផ្សេងៗទៀតជាអ្នកជំរុញឱ្យមានការប្រែប្រួលនូវវិធីជីវិត និងការងាររបស់យើងថែមទៀត។
>
> ពេលដែលចំណេះដឹងកាន់តែមានសារៈសំខាន់ការអប់រំឧត្តមសិក្សាក៏កាន់តែមានប្រយោជន៍។ ប្រទេសជាច្រើនត្រូវផ្តល់ការអប់រំដល់មនុស្សវ័យក្មេងឱ្យបានច្រើនឱ្យដល់កម្រិតស្តង់ដារមួយខ្ពស់ជាងនេះ មានន័យថា សញ្ញាបត្រជាគុណវុឌ្ឍិសិក្សាមូលដ្ឋានសម្រាប់ការងារជំនាញជាច្រើន។ គុណភាពចំណេះដឹងគឺកើតឡើងនៅតាមគ្រឹះស្ថានអប់រំឧត្តមសិក្សាហើយរូបវ័ន្តភាពនៃគុណភាពចំណេះដឹងមានក្នុងសេដ្ឋកិច្ចទូទៅ គឺកាន់តែមានសារៈប្រយោជន៍ថែមទៀតចំពោះ សមត្ថភាពប្រកួតប្រជែងរបស់ប្រទេស។[៣]

ប្រាំពីរឆ្នាំក្រោយមក ក្នុងពេលដែលសេដ្ឋកិច្ចរបស់ប្រទេសអាស៊ីខាងកើតកំពុងចាប់ផ្តើមស្តារសេដ្ឋកិច្ចឡើងវិញគេចចេញផុតពីវិបត្តិហិរញ្ញវត្ថុនាចុងទសវត្សរ៍ ១៩៩០ គំនិតអភិវឌ្ឍន៍ថ្មីៗបានចាប់ផ្តើមកើតមាននៅតាមស្ថាប័នអន្តរជាតិធំៗ និងពីអ្នកធ្វើគោលនយោបាយសំខាន់ៗនៅប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ ធនាគារពិភពលោក (២00៧) "ការកសាងសេដ្ឋកិច្ចពុទ្ធិ យុទ្ធសាស្ត្រឈានមុខសម្រាប់អភិវឌ្ឍន៍" ត្រូវបានបង្កើតឡើងដើម្បីបង្ហាញអំពីរបៀបដែលចំណេះដឹងជាអ្នកកែប្រែផ្លូវនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ ឧទាហរណ៍លើកឡើងញឹកញាប់អំពីប្រទេសកូរ៉េ និងប្រទេសហ្គាណាបង្ហាញអំពីភាពផ្សេងគ្នានៃកំណើនដ៏អស្ចារ្យ (ចាប់ផ្តើមពីប្រាក់ចំណូលជាមធ្យមរបស់មនុស្សម្នាក់ធៀបនឹងផលិតផលក្នុងស្រុកសរុប) ចន្លោះឆ្នាំ ១៩៦0 និងឆ្នាំ ២00៥ ដែលអាចធ្វើបានតាមរយៈការបង្កើន សេដ្ឋកិច្ចពុទ្ធិ។[៤]

---

៣ ធនគារពិភពលោក ២000 ទំព័រលេខ៩ របាយការណ៍បន្តខាងក្រោមៈករណីនេះត្រូវបានចោទជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ ចាប់តាំងពីឆ្នាំ ១៩៨0 រាជរដ្ឋាភិបាលនៃប្រទេសជាច្រើន និងអ្នកផ្តល់ជំនួយអន្តជាតិនានាបានផ្តល់អាទិភាពលំដាប់ទាបលើការអប់រំកម្រិតក្រោយឧត្តមសិក្សាធៀបនឹងកម្រិតអប់រំផ្សេងទៀត។ ការវិភាគសេដ្ឋកិច្ចដែលបានរួមចំនែកក្នុងទស្សនៈតូចចង្អៀត និងចាកគន្លងមួយបានពន្យល់ថា ការវិនិយោគសារធារណៈ លើមហាវិទ្យាល័យ និងសាកលវិទ្យាល័យទាំងនោះនាំមកនូវផលចំណេញតិចតួចស្តួចស្តើងធៀបនឹងផលចំណេញបានមកពីការវិនិយោកលើការអប់រំកម្រិតបឋមសិក្សា និងកម្រិតទុតិយភូមិ ព្រមទាំងពន្យល់ទៀតថាការអប់រំកម្រិតក្រោយឧត្តមសិក្សាបានពង្រីកវិសមភាពប្រាក់ចំណូល។ "ជាផទ្ធផលប្រពន្ធ័អប់រំក្នុងកម្រិតខ្ពស់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺកំពុងចោទជាបញ្ហាដ៏ធំ"។ ប្រពន្ធ័អប់រំក្រោយឧត្តមសិក្សានៃប្រទេសទាំងនោះកំពុងខ្វះខាតជំនួយថវិការយ៉ាងខ្លាំង ខណៈពេលដែលតំរូវការនៃការសិក្សាកំពុងកើនឡើងរឹតតែខ្លាំង គឺមានតំរូវការចំនួនប្រហែលជាងពាក់កណ្តាលនៃសិស្សកម្រិតក្រោយឧត្តមសិក្សាបច្ចុប្បន្ននៅក្នុងបណ្តាលប្រទេសកំពុងអភិវឌ្ឍ។ មហាវិទ្យាល័យភាគច្រើនឋិតនៅក្រោមស្តង់ដា និងការខ្វះការជំរុញការលើទឹកចិត្តនិងគ្មានលទ្ធភាពផ្តល់នូវអាហារូបករណ៍។ សិស្សជាច្រើនទទួលបានការបង្ហាត់បង្រៀននៅកម្រិតទន់ខ្សោយហើយកម្មវិធីសិក្សាកំពុងត្រូវបានអភិវឌ្ឍ ខណៈដែលបណ្តាប្រទេសអភិវឌ្ឍន៍បាននិងកំពុងបង្កើនការអភិវឌ្ឍគុណភាពប្រពន្ធ័អប់រំ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវតែខិតខំប្រឹងប្រែងរក្សាលំដាប់ថ្នាក់របស់ខ្លួនដោយមិនចាំបាច់គិតគូរដល់ការប្រជែងជាមួយប្រទេសអភិវឌ្ឍន៍ទាំងនោះផង។ (ibid, ទំព័រលេខ១0)

៤ អានរូប១ ក្នុង ឧបសម្ព័ន្ធនៃរបាយការណ៍នេះ

ចាប់ពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ នៅពេលទីផ្សារបូរបិយវត្ថុ និងទំនិញប្រើប្រាស់ប្រចាំថ្ងៃរបស់សកលលោកបានពង្រីកខ្លួនយ៉ាងស្រួចស្រាល ជាពេលវេលាមួយនៃការប្រែប្រួលរចនាសម្ព័ន្ធពាណិជ្ជកម្មអន្តរជាតិ។ ឋិតក្នុងចំណុចបេះដូងនៃការប្រែប្រួលរចនាសម្ព័ន្ធនេះ គឺពាណិជ្ជកម្មសកលនៃផលិតផលឧស្សាហកម្មតាមបច្ចេកទេសទំនើបមានការកើនឡើងយ៉ាងស្រួចស្រាលដែលភាគច្រើនជាពាណិជ្ជកម្មនៃសម្ភារប្រើប្រាស់ប្រចាំថ្ងៃថ្មីៗ[៥]។ ផលិតកម្មទាំងនេះជាអនុផលនៃនវានុវត្តភណ្ឌ បច្ចេកវិទ្យាថ្មីក្នុងសេដ្ឋកិច្ចសកល។ បំរែបំរួលនៃរចនាសម្ព័ន្ធពាណិជ្ជកម្ម និងផលិតកម្មនេះបានបង្ហាញជារូបរាងច្បាស់ក្នុងកំណើនទម្ងន់នៃវិស័យសេវាកម្មធំៗដល់កំណើនផលិតផលក្នុងស្រុកសរុប ជាពិសេសនៅប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ ការប្រែប្រួលនេះក៏អាចមើលឃើញ តាមរយៈកំណើននៃចំនួនប្រជាជនដែលមានការអប់រំកម្រិតឧត្តមសិក្សាកាន់តែច្រើននៅប្រទេសអភិវឌ្ឍន៍។ លទ្ធផលរួមគ្នាគឺថា នៅប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនកម្លាំងពលកម្មប្រមាណ ៧០ ភាគរយ គឺបម្រើការងារក្នុងវិស័យសេវាកម្ម។ ការប្រែប្រួលនៅតាមប្រទេសដែលគឺកើតឡើងមិនយូរប៉ុន្មាននៅប្រទេសឧស្សាហកម្មចម្បងនៃសេដ្ឋកិច្ចសកល។ ការស្រាវជ្រាវជាក់ស្តែងច្រើនបង្ហាញថា នៅពាក់កណ្តាលទសវត្សរ៍ ២០០០ ឥទ្ធិពលនៃការប្រែប្រួលរចនាសម្ព័ន្ធនេះប៉ះពាល់ដល់ការងារក្នុងវិស័យផលិតកម្មប្រើពុទ្ធិ គឺពិតជាកើតឡើងមែន។ ដូច្នេះ ក្នុងករណីសេដ្ឋកិច្ចសហរដ្ឋអាមេរិកចាប់ពីឆ្នាំ ១៩៩៥-២០០៥ ការងារក្នុងវិស័យផលិតកម្មដែលប្រើបច្ចេកវិទ្យាកម្រិតមធ្យមបានធ្លាក់ចុះ ១៥,៧ ភាគរយ ប៉ុន្តែកើនឡើង ២៧,២ ភាគរយ ក្នុងសេវាកម្មដែលប្រើពុទ្ធិជាមូលដ្ឋាន។ លទ្ធផលស្រដៀងគ្នាដែរ ក៏មានបង្ហាញនៅប្រទេសអ៊ឺរ៉ុប ១៥ ដែរ ដោយវិស័យផលិតកម្មបានធ្លាក់ចុះ ២,៤ ភាគរយ ហើយវិស័យសេវាកម្មដែលប្រើពុទ្ធិជាមូលដ្ឋានបានកើនឡើង ៣០ ភាគរយ។

ផលវិបាកដ៏សំខាន់មួយនៃបំរែបំរួលនៃការបែងចែកការងារកម្រិតអន្តរជាតិ គឺថា ប្រទេសកំពុងអភិវឌ្ឍន៍ ហើយទោះបីជាប្រទេសដែលមានប្រវត្តិជោគជ័យនៃកំណើនផលិតផលក្នុងស្រុកសរុបខ្ពស់ និងនៃការលើកកម្ពស់ការនាំចេញខ្ពស់ក៏ដោយក៏ត្រូវប្រឈមនឹងហានិភ័យដែលអាចជាប់អន្ទាក់ក្នុងវិស័យផលិតកម្មដែលមានខ្សែចង្វាក់ផលិតផលដែលមានតម្លៃ ទាបដដែលដែរ (រូប ១.១)។

*រូប ១. ១ ការបែងចែកការងារក្នុងបណ្តាញផលិតកម្មសកល*




*ប្រភព ៖ ធនាគាពិភពលោក ២០០៧ កសាងសេដ្ឋកិច្ចពុទ្ធិ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍទំព័រ១៩។*

---

៥ ធនាគារពិភពលោក ២០០៧ ទំព័រលេខ១១៣ តារាង១.២។

*"កត្តាផ្តើមរឿងក្នុងសេដ្ឋកិច្ចពុទ្ធិ គឺមិនមែននិយាយអំពីជំនាញមួយមុខ ឬអំពីប្រព័ន្ធវាគតភណ្ឌមួយមុខទេ ប៉ុន្តែក៏និយាយអំពីដំណើរការនៃការធ្វើសមាហរ័ណកម្មអន្តរជាតិ និងសកលភាវូបនីយកម្មដែរ ។"*

ស្ថានភាពនេះមានលក្ខណៈប្រទាំងប្រទិសគ្នា ដោយហេតុថាគឺបណ្តាប្រទេសអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ដែលមានប្រាក់កម្រៃការងារទាបប្រើបច្ចេកវិទ្យាផលិតកម្មទាប ជាប្រទេសដែលប្រឈមនឹងគ្រោះថ្នាក់នៃការជាប់អន្ទាក់ក្នុងការប្រើបច្ចេកវិទ្យាទាប/តម្លៃបន្ថែមទាប ។ វិនិយោគបរទេសផ្ទាល់ដែលនាំមកនូវកំណើន និងការវិនិយោគខ្ពស់ ហើយដែលបានទាក់ទាញជាលើកដំបូងដោយការផ្គត់ផ្គង់យ៉ាងច្រើនសន្ធឹកសន្ធាប់នៃកម្លាំងពលកម្មដែលមានតម្លៃទាប ក៏នៅតែអាចប្រឈមនឹងគ្រោះថ្នាក់នៃការជាប់អន្ទាក់ចូលក្នុងសកម្មភាពតម្លៃបន្ថែមទាបខណៈពេលដែលប្រាក់ចំណេញបានពីការស្រាវជ្រាវ និងអភិវឌ្ឍន៍រចនាបថផលិតផលការស្វែងរកទីផ្សារ និងអាជីវកម្មលើម៉ាកសញ្ញាក្រុមហ៊ុនត្រូវបានប្រមូលផលដោយពួកក្រុមហ៊ុននៃប្រទេសអភិវឌ្ឍន៍មានឯកទេសជំនាញខាងផលិតកម្មនៃផលិតផលប្រើពុទ្ធិទាំងនេះ ។

តាមការពិត ការរីករាលដាលនៃសេដ្ឋកិច្ចពុទ្ធិយ៉ាងលឿនមិនតែងតែនិទានរឿងដែលមានភាពជឿនរហូតនោះទេ ។ ប្រទេសកំពុងអភិវឌ្ឍន៍ពុំចាំបាច់ឆ្លងកាត់ដំណាក់កាលអភិវឌ្ឍន៍ដែលឈឺចាប់ និងដំណាក់កាលអភិវឌ្ឍន៍មូលធនកម្រិតខ្ពស់ដើម្បីផ្តល់ពិន្ទុឱ្យអត្រានៃកំណើនសេដ្ឋកិច្ចទេ ។ សេវាកម្ម និងសេដ្ឋកិច្ចពុទ្ធិដែលបានជំរុញឱ្យប្រទេសកំពុងអភិវឌ្ឍន៍លោតជំហានកង្កែបចូលក្នុងគន្លងផ្លូវអភិវឌ្ឍន៍ ដូចក្នុងករណីឧស្សាហកម្មបច្ចេកវិទ្យាព័ត៌មាននៅឥណ្ឌាដែរ ។ ការរីករាលដាលនៃសេដ្ឋកិច្ចពុទ្ធិនេះ ក៏បញ្ឆៀសនូវតម្រូវការឱ្យមានវិនិយោគធំៗផ្តោតលើមូលធនហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដោយប្រៀបធៀបនឹងផលិតកម្ម ឬវិស័យរ៉ែព្រោះការផ្ទេរទិន្នន័យព័ត៌មាន និងការផ្តល់សេវាហិរញ្ញវត្ថុ និងសេវាផ្សេងៗក្នុងតម្លៃមួយថោកជាងផលិតកម្ម និងពាណិជ្ជកម្មផលិតផលប្រើប្រាស់ប្រចាំថ្ងៃ ។

### ១.២.២. *សាកលភាវូបនីយកម្មសេដ្ឋកិច្ចពុទ្ធិ និងវិសាលភាពសម្រាប់គោលនយោបាយឧស្សាហកម្ម*

ទំនោរថ្មីអំពីសេដ្ឋកិច្ចពុទ្ធិថា ជាប្រភពនៃកំណើនសេដ្ឋកិច្ចដ៏សំខាន់បំផុតក្នុងពេលអនាគត គឺមិនមែននិយាយអំពីតម្រូវការវិនិយោគ និងពាណិជ្ជកម្មសម្រាប់ជំនាញថ្មីៗទាំងអស់ទេ ។ កត្តាផ្តើមរឿងក្នុងសេដ្ឋកិច្ចពុទ្ធិ គឺមិនមែននិយាយអំពីជំនាញមួយមុខ ឬអំពីប្រព័ន្ធវាគតភណ្ឌមួយមុខទេ ប៉ុន្តែក៏និយាយអំពីដំណើរការនៃការធ្វើសមាហរ័ណកម្មអន្តរជាតិ និងសកលភាវូបនីយកម្មដែរ ។ បញ្ហាកើតឡើងនៅចំកណ្តាលបេះដូងនៃគោលនយោបាយសម្រាប់ធ្វើវិស្វកម្មនៃកំណើនសេដ្ឋកិច្ចនៅប្រទេសមួយចំនួនក្នុងពេលអនាគត គឺថាសេដ្ឋកិច្ចសកលកំពុងបង្កើតវិបត្តិសេដ្ឋកិច្ចថ្មី និងប្រថុចប្រថុចដោយសារការប្រែប្រួលបន្ទាន់នៃទីផ្សារមូលធនអន្តរជាតិ ។

ដូច្នេះ នៅពេលប្រមូលបានទីផ្សារ និងបច្ចេកវិទ្យាថ្មី សេដ្ឋកិច្ចពុទ្ធិក៏បង្កើតឡើងនូវអស្ថិរភាព និងហានិភ័យបន្ថែមទៀត ។ អ្នកតាក់តែងគោលនយោបាយថ្នាក់ជាតិបានបង្កើតនូវសិប្បរចនានៃយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ចឡើងវិញ ។ យុទ្ធសាស្ត្រនេះត្រូវពិចារណាអំពីសារធាតុដើមនៃការប្រែប្រួលលឿននៃសេដ្ឋកិច្ចសកលផងដែរ ។ គោលនយោបាយសេដ្ឋកិច្ច គឺមិនមែននិយាយអំពីស្ថានភាពសេដ្ឋកិច្ចដ៏យ៉ាប់យឺនអំពីឱនភាពថវិកា ឬអំពីការកែលម្អអត្រាប្តូរប្រាក់មួយមុខទេ គោលនយោបាយនេះត្រូវនិយាយអំពីការធ្វើចំណោល? នៃផលប៉ះពាល់ដែលអាចកើតឡើងដោយសារការបង្កើតពាណិជ្ជកម្មថ្មី និងផលិតផលថ្មីដែលត្រូវចូលទៅក្នុងទីផ្សារអន្តរជាតិក្នុងអំលុងពេលស្តារសេដ្ឋកិច្ចឡើងវិញ ។

ក្នុងបរិបទនេះ ក៏មានសំណួរដ៏សំខាន់មួយ និងមានប្រតិមតិដែលរដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍កំពុងប្រឈម គឺវិសាលភាព និងការបង្កើតនៃគោលនយោបាយលើកកម្ពស់ឧស្សាហកម្ម/គោលនយោបាយ

ពិពិធកម្មឧស្សាហកម្មក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមរបស់ប្រទេស។ បញ្ហានេះជាប្រធានបទដ៏ពេញនិយមមួយនៅកម្ពុជាបច្ចុប្បន្ន។ បញ្ហានេះពេញនិយមព្រោះមួយចំណែកបញ្ហានេះផ្តោតការយកចិត្តទុកដាក់លើកំណើនសេដ្ឋកិច្ចក្នុងឧស្សាកម្មមួយចំនួនតូចបន្តពីអតីតកាល ដូចជា ឧស្សាហកម្មកាត់ដេរ ឬសំណង់ ហើយមួយចំណែកទៀតដោយសារការទទួលស្គាល់ការពិតនៃសារធាតុដើមនៃបញ្ហាវិនិយោគបរទេសផ្ទាល់ និងដោយសារការទទួលស្គាល់ការពិតថា គ្រប់ទម្រង់នៃការវិនិយោគបរទេសផ្ទាល់មិន "ដោះស្រាយ" បញ្ហាដោយស្មើភាពគ្នាទេ។ ឧទាហរណ៍ វិស័យកាត់ដេរមានលក្ខណៈសេរីបើកទូលាយជាងវិស័យគ្រឿងយន្ត។ កម្ពុជាកំពុងប្រឈមនឹងបញ្ហាធំៗជាច្រើនក្នុងការចងក្រងឧស្សាហកម្មឱ្យនៅរួមគ្នា និងក្នុងការវិនិយោគលើវិស័យឧស្សាហកម្មនេះ ដូចជា សហគ្រាសខ្នាតតូច ឬខ្នាតតូចល្អិតជាច្រើនកម្រិតបច្ចេកវិទ្យាទាប និងផលិតផលបន្ថែមតម្លៃសេដ្ឋកិច្ចទាបចំណងទាក់ទងនៃសេដ្ឋកិច្ចឆ្លងវិស័យមានតិចតួច? ភាពរីកវរនៃវិស័យឧស្សាហកម្ម និងភាពអត់ការងារធ្វើកាន់តែកើនឡើងអសង្គតិភាពនៃជំនាញជាមួយការងារ ។ល។ ពិពិធកម្មឧស្សាហកម្មជាយុទ្ធសាស្ត្រដ៏ប្រសើរមួយ ប៉ុន្តែវិធីអនុវត្តដើម្បីធានាឱ្យមានពិពិធកម្មនេះកំពុងថិតក្នុងការជជែកគ្នានៅឡើយ។

វិធីដ៏ច្បាស់លាស់បំផុតមួយក្នុងការធ្វើពិពិធកម្មនេះ គឺសំដៅបង្កើននានាភាពនៃផលិតផល និងឧស្សាហកម្មឱ្យថិតក្នុងប្រព័ន្ធមួយច្បាស់លាស់។ ការផលិតវាយនភណ្ឌដែលមានសិប្បរចនាល្អ និងច្រើនមុខការប្តូរទិសដៅផលិតពីការផលិតស្រូវទៅជាការកិនស្រូវ និងកែច្នៃស្រូវ ឬប្តូរពីការដាំដំណាំបរិភោគទៅជាដំណាំពាណិជ្ជកម្ម ពង្រីកទិសដៅ និងប្រភេទនៃទេសចរណ៍ឱ្យបានទូលំទូលាយ។ ការសន្និដ្ឋានរួមគឺថាការធ្វើពិពិធកម្មប្រភេទនេះ គឺស្របនឹងឧត្តមភាពប្រៀបធៀបរបស់កម្ពុជាយ៉ាងពិតប្រាកដ។ នេះមានន័យថាការធ្វើពិពិធកម្មនេះ គឺប្រើសក្តានុពលភាពរបស់កម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប? ដូចជា កម្លាំង ពលកម្មថោកសម្បូរបែប និងវ័យក្មេង ដីសម្បូរជីជាតិ រចនាសម្ព័ន្ធអភិបាលកិច្ចប្រកបដោយស្ថិរភាពដែលមានឆន្ទៈលើកកម្ពស់ការនាំចេញឱ្យបានកាន់តែច្រើន និងទាក់ទាញវិនិយោគបរទេសផ្ទាល់ឱ្យបានច្រើនដែរ។

គោលនយោបាយឧស្សាហកម្មនៅតែជាបញ្ហាចម្រុងចម្រាស់មួយយ៉ាងធំ ក្នុងគោលនយោបាយសេដ្ឋកិច្ច។ ភាពប្រតិមតិនេះ គឺមានចំណងទាក់ទងគ្នាជាមួយបញ្ហាធំៗ ដូចជាជាតួនាទីរបស់រដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ការជំទាស់ជាច្រើនចំពោះគោលនយោបាយឧស្សាហកម្មនេះ គឺទាក់ទងនឹងភាពគ្រោះថ្នាក់នៃការធ្វើវិភាជន៍ធនធានមិនគ្រប់គ្រាន់របស់ "អ្នកឈ្នះ" និងការទប់ស្កាត់មិនឱ្យផ្តល់ធនធានទៅឱ្យឧស្សាហកម្មទើបចាប់កំណើតដែលកើតឡើងដោយសារអំពើពុករលួយ និងការិយាធិបតេយ្យ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ទស្សនៈអំពីការគោរពតួនាទីរបស់រដ្ឋក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងតួនាទីដែលរដ្ឋអាចធ្វើបានក្នុងការធ្វើពិពិធកម្មឧស្សាហកម្មបានចាប់ផ្តើមកែប្រែហើយ។ ការដួលរលំគួរឱ្យភ្ញាក់ផ្អើលនៃធនាគារវិនិយោគល្បីៗ និងគ្រឹះស្ថានហិរញ្ញវត្ថុល្បីៗក្នុងប្រព័ន្ធនៃអំពីពុករលួយ និងភាពអសកម្មនៃការគ្រប់គ្រងរដ្ឋបាលសាធារណៈ បង្ហាញថាអំពើពុករលួយមិនត្រឹមតែថិតក្នុងបញ្ហានៃវិស័យសាធារណៈនៅប្រទេសកំពុងអភិវឌ្ឍន៍ទេ ប៉ុន្តែ ក៏ថិតក្នុងចំណោម???ក្នុងគ្រប់របបនយោបាយទាំងអស់នៅគ្រប់ទូរកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចទាំងអស់។[៦] វិបត្តិសេដ្ឋកិច្ចសកលបច្ចុប្បន្នបង្ហាញយ៉ាងច្បាស់អំពីកម្រិត ឬទំហំដែលរដ្ឋត្រូវចូលរួមអន្តរាគមន៍ដើម្បីផ្តល់មូលធនទៅឱ្យធនាគារឡើងវិញរៀបចំរចនាសម្ព័ន្ធ និងចេញបដ្ឋានគតិយុត្តដើម្បីគ្រប់គ្រងឧបករណ៍ហិរញ្ញវត្ថុឡើងវិញព្រមទាំងបន្ថយកម្រិតចំណាយលើការគ្រប់គ្រង និងបន្ថយលាភធនឱ្យកាន់តែតិច។

"...ការកើតមាននូវសេដ្ឋកិច្ចពុទ្ធិក្នុងឆាកសកលលោកបានទាញការចាប់អារម្មណ៍លើគោលនយោបាយឧស្សាហកម្ម។"

៦ Gan Mishra (២០០៩) អំពីការពិភាក្សាលម្អិតលើសេដ្ឋកិច្ចនយោបាយនៃអំពើពុករលួយ នៅអាស៊ី និងប៉ាស៊ីភិច។

ក្នុងករណីជាច្រើន ការកើតមាននូវសេដ្ឋកិច្ចពុទ្ធិក្នុងឆាកសកលលោក និងលទ្ធភាពនៃការលោតជំហានកង្កែបចូលក្នុងផ្លូវអភិវឌ្ឍន៍មួយដែលមានស្តង់ដារកំណត់ច្បាស់លាស់ គឺលោតពីកសិកម្មទៅឧស្សាហ-កម្មទៅសេវាកម្ម។ ម្យ៉ាងវិញទៀតភាពគ្រោះថ្នាក់នៃការជាប់អន្ទាក់ក្នុងផលិតកម្មកម្រិតទាបបានទាញការចាប់អារម្មណ៍លើគោលនយោបាយឧស្សាហកម្ម។ ឧទាហរណ៍ កូរ៉េ តៃវ៉ាន់ ម៉ាឡេស៊ី ចិន និងឥណ្ឌាទាំងអស់សុទ្ធតែបង្ហាញថា គោលនយោបាយឧស្សាហកម្មដ៏សកម្មមួយពិតជាអាចផលិតនូវភាគចំណេញទទួលបានពីការអភិវឌ្ឍនៅតំបន់អាស៊ីអាគ្នេយ៍ដោយខានមិនបាន។[៧]

តាមការពិត ការពិពណ៌នាបែបនេះមិនមែនមានន័យថា មានស្តង់ដារកំណត់មួយអំពីពិពិធកម្មឧស្សាហកម្មដែលកម្ពុជាអាចយកទៅអនុវត្តតាមបានទេ ប៉ុន្តែ ស្តង់ដារនេះបង្ហាញអំពីការប្រែប្រួលនៃគំនិតអភិវឌ្ឍន៍ដែលមានចំណងទាក់ទងជាមួយនឹងសម្ពាធនៃសកលភាវូបនីយកម្ម និងការកើតមាននូវសេដ្ឋកិច្ចពុទ្ធិដែលកំណត់អំពីរបៀបវារៈក្នុងគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា។ ការបង្ហាញមួយចំនួនអំពីទស្សនៈអន្តរជាតិ និងទម្លាប់អនុវត្តរបស់អាស៊ីអាគ្នេយ៍ដែលបានប្រែប្រួលត្រូវបានសន្និដ្ឋានដោយ Chimoli, Dosi and Stiglitz (២០០៩)។[៨]

> ប្រហែលជាមានភាពខុសគ្នាច្រើនជាងអតីតកាលប្រទេសនានាមានសមត្ថភាពខុសៗគ្នាក្នុងការស្រូបយកបច្ចេកវិទ្យាផលិកម្ម និងបង្កើតសិប្បរចនានៃផលិតផលនៅប្រទេស "ជួរមុខ"។ ក្រោមពហុទម្រង់នៃផលចំណេញក្នុងស្រុកដែលចេះតែកើនឡើងកម្រិតនៃការធ្វើសមាហរ័ណកម្មអន្តរជាតិត្រូវបានជំរុញដោយសកលភាវូបនីយកម្មប្រសិនបើមានអ្វីប្រែប្រួល។ ប្រសិនបើផលចំណេញទាំងអស់ត្រូវប្រមូលដោយខ្លួនឯងតាមប្រទេសនោះភាពខុសគ្នារវាងជាតិ និងអន្តរជាតិកាន់តែរីកធំទៅៗដោយជំរុញឱ្យមានស្វ័យប្រតិបត្តិ និងសកម្មភាពផលិតកម្មពិសេសទម្រង់នៃឯកទេសកម្ម និងសមត្ថភាពបច្ចេកវិទ្យា (ឬខ្វះសមត្ថភាព)។សកលភាវូបនីយកម្មដោយខ្លួនឯងដោយមិនមានទម្រង់អ្វីសម្រាប់អនុវត្តតាមកំណត់ដោយ*សមត្ថភាពបច្ចេកវិទ្យា និងប្រភពចំណូលខុសៗគ្នាទេ*។ ផ្ទុយទៅវិញសេដ្ឋកិច្ចឯករាជ្យជាងនេះប្រហែលជាត្រូវការវិធានការនៃការអនុវត្តគោលនយោបាយកាន់តែស្មុគស្មាញជាងនេះដោយប្រទេសទន់ខ្សោយ។ (មានបន្ថែមអក្សរទ្រេតទៀត)។

សេចក្តីសន្និដ្ឋានទាំងនេះ ពុំមែនជាចំណែកមួយនៃការបញ្ជ្រាបអភិក្រក្នុងគោលនយោបាយពាណិជ្ជកម្ម និងសមត្ថភាពប្រកួតប្រជែងរបស់គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិទេ ប៉ុន្តែសេចក្តីសន្និដ្ឋាននេះជាចំណែកមួយនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ថ្មីៗឆ្លងវិស័យ ហើយការសន្និដ្ឋាននេះកំពុងទាក់ទាញការចាប់អារម្មណ៍របស់អ្នកតាក់តែងគោលនយោបាយនៅប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីដែលកំពុងប្រឈមនឹងការដួលរលំនៃសេដ្ឋកិច្ចវិសមភាពរីកធំទៅៗ និងការប្រែប្រួលរចនាសម្ព័ន្ធសមាសភាពនៃលទ្ធផល។ លើសពីនេះទៀតជំនួយរបស់រដ្ឋផ្តល់ទៅឱ្យឧស្សាហកម្មក្មេងខ្ចី សមត្ថភាពកែច្នៃបច្ចេកវិទ្យាសម្រាប់ប្រើរយៈពេលយូរអង្វែង និងការរៀនសូត្របទពិសោធពីការវិនិយោគបរទេសផ្ទាល់ និងគ្រឿងម៉ាស៊ីននាំចូលជាផ្នែកដ៏សំខាន់មួយនៃជោគជ័យរបស់ប្រទេសកូរ៉េ តៃវ៉ាន់ និងខ្លាអាស៊ី។

៧ For a highly informed discussion of the industrial policy landscape in developing countries see Cimoli et al (2009)

៨ Mario Cimoli, Giovanni Dosi and Joseph Stiglitz (2009), "The future of industrial policies in the new millennium: towards a knowledge centred development agenda"។

ចំណុចទាក់ទាញនៃគោលនយោបាយឧស្សាហកម្មមួយដែលមានបំណងធ្វើពិពិធកម្មលើកកម្ពស់ផលិតភាពពលកម្ម និងបង្កើនប្រាក់ចំណូលសម្រាប់កម្ពុជាដែលមានឧស្សាហកម្មដឹកមុខដែលកំពុងប្រឈមនឹងការធ្លាក់ចុះនៃតម្លៃយ៉ាងលឿន គឺពិតជាមានប្រាកដមែន។ ក្នុងពេលមួយដែលទស្សនៈសេដ្ឋកិច្ចធម្មតាកំពុងស្វែងរកការកំណត់បញ្ញត្តិ និងប្រភេទថ្មីការស្រាវជ្រាវរកគោលនយោបាយឧស្សាហកម្មសមស្របមួយសម្រាប់កម្ពុជាត្រូវប្រើយុទ្ធសាស្ត្រមូលធនមនុស្សដែលត្រូវបានធ្វើសិប្បរចនាដើម្បីពង្រីកសមត្ថភាពស្រូបយកបច្ចេកវិទ្យាមកប្រើជាការបញ្ជាក់មួយយ៉ាងច្បាស់អំពីកម្លាំងចលករនៃគំនិតរបស់រដ្ឋាភិបាលនៅលើផ្លូវផ្សេងៗឈានទៅរកការស្តារសេដ្ឋកិច្ចឡើងវិញឱ្យមាននិរន្តរភាព។

### ១.២.៣. *ការអប់រំមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ច*

ចំណុចទាំងអស់ខាងលើបាននាំយើងត្រឡប់ទៅរកសំណួរអំពីទំនាក់ទំនងរវាងមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ច។ ដោយសារមានចំនួនឆ្នាំចូលសាលាជាមធ្យម ឬសូចនាករបែបនេះជារង្វាស់ចំណុចខាងលើបង្ហាញច្បាស់ថា មានអភិក្រមសាមញ្ញមួយសម្រាប់ដោះស្រាយបញ្ហានៃការភ្ជាប់ទំនាក់ទំនងរវាងមូលធនមនុស្សជាមួយកំណើនផលិតភាព និងជាមួយកំណើនផលិតផលក្នុងស្រុកសរុបព្រោះមានសារៈសំខាន់ដូចទឡ្ហីកម្មទូទៅមួយទាមទារឱ្យមានគោលនយោបាយផ្តល់ជំនួយ និងអាទិភាពចំណាយសាធារណៈសម្រាប់ការអប់រំ គឺទាន់មិនគ្រប់គ្រាន់សម្រាប់គោលបំណងនៃការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍នោះទេ។ ជាទូទៅបច្ចុប្បន្នក៏មានការទទួលស្គាល់ថា ការផ្តោតការយកចិត្តទុកដាក់លើការអប់រំមូលដ្ឋានដោយផ្តល់ផលចំណេញទទួលបានពីការវិនិយោគខ្ពស់បំផុតទៅឱ្យការអប់រំ គឺមានការអភិវឌ្ឍពាក់ព័ន្ធពុទ្ធិក្នុងសេដ្ឋកិច្ចសកល។ ដោយសារអត្រាផលចំណេញទទួលបានពីការអប់រំនៅកម្រិតផ្សេងៗមានសារៈសំខាន់សម្រាប់ការប្រៀបធៀបសេដ្ឋកិច្ចកម្រិតម៉ាក្រូ និងសម្រាប់ការបង្កើតបរិយាកាសសេដ្ឋកិច្ចរួម[៩] អត្រាផលចំណេញទទួលបានពីការវិនិយោគ និងកំណើននៃផលិតភាពរួម និងកំណើនសេដ្ឋកិច្ចរួមអាចផ្ទុះឡើងយ៉ាងលឿនដើម្បីតម្រឹមឱ្យស្របនឹងរបត់ថ្មីនៃការកសាងសេដ្ឋកិច្ចពុទ្ធិ។

## ១.៣. សមាសធាតុនៃផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្សក្នុងសម័យសេដ្ឋកិច្ចពុទ្ធិ

ផលវិបាកមួយនៃសេដ្ឋកិច្ចពុទ្ធិ គឺតម្រូវការឱ្យគិតឡើងវិញអំពីគោលការណ៍កំណត់ និងគោលការណ៍ណែនាំអំពីគោលនយោបាយអភិវឌ្ឍន៍មូលធនមនុស្សនៅថ្នាក់ជាតិ។ ទីមួយ ដោយសារការអប់រំឧត្តមសិក្សាកំពុងឋិតក្នុងកម្រិតកំពូលនៃក្រខ័ណ្ឌសេដ្ឋកិច្ចពុទ្ធិ ការអប់រំឧត្តមសិក្សាមានសមាសភាពដែលមានចំណងទាក់ទងគ្នាយ៉ាងច្រើន ដូចជា *ការអប់រំប្រព័ន្ធនវានុវត្តភណ្ឌ ហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន និងអភិបាលកិច្ច (ឬរបបស្ថាប័ន)*។ នេះមានន័យថា យុទ្ធសាស្ត្រអភិវឌ្ឍន៍មនុស្សត្រូវពង្រីកឱ្យគ្របដណ្តប់មិនត្រឹមតែលើការអប់រំ (ជាពិសេសអប់រំឧត្តមសិក្សា និងការបណ្តុះបណ្តាល) ទេ ប៉ុន្តែក៏ត្រូវគ្របដណ្តប់លើក្របខ័ណ្ឌស្ថាប័ន និងលាភការសម្រាប់លើកកម្ពស់បណ្តាញនវានុវត្តភណ្ឌ បច្ចេកវិទ្យាព័ត៌មាន និងរបបអភិបាលកិច្ច/គោល-នយោបាយ។ វាជាបណ្តាញនៃគ្រឹះស្ថាន និងលាភការរួមគ្នាដែលផ្តល់គន្លឹះសម្រាប់លើកកម្ពស់សមត្ថភាព

៩ សម្រាប់ការពិភាក្សាដេញដោយគ្នាអំពីបញ្ហានេះ រវាងប្រធានសេដ្ឋវិទូរបស់ធនាគារពិភពលោក Justin Lin និងសេដ្ឋវិទូរបស់ Cambridge Ha-Joon Chang អានទស្សនាវដ្តី Development Policy Review (2009), 27(5). "Should Industrial Policy in Developing Countries Conform to Comparative Advantage or Defy it? A Debate Between Justin Lin and Ha-Joon Chang ។

ជាតិប្រកួតប្រជែងស្រូបយកបច្ចេកវិទ្យា និងដំណើរការដែលកម្រមាន។ ផ្នែកមួយដ៏សំខាន់នៃផែនទីយុទ្ធសាស្ត្រមូលធនមនុស្ស គឺវាយតម្លៃតម្រូវការនៃការអប់រំ និងការបណ្តុះបណ្តាលមិនត្រឹមតែក្នុងវិស័យឧស្សាហកម្មទេ ប៉ុន្តែក៏ក្នុងបណ្តាញនវានុវត្តភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន និងអភិបាលកិច្ចដែរ។ ការយកចិត្តទុកដាក់ដោយខានមិនបានផ្តោតលើពាណិជ្ជកម្មទាក់ទងនឹងតម្រូវការនៃការបណ្តុះបណ្តាលអាចលើកកម្ពស់ឱកាសការងារក្នុងរយៈពេលខ្លី ប៉ុន្តែ ត្រូវមានប្រសិទ្ធភាពក្នុងការបង្កើនពិពិធកម្មសេដ្ឋកិច្ច និងសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចក្នុងឆាកអន្តរជាតិរបស់ប្រទេសទាំងមូលឱ្យបានច្រើនផងដែរ។

ទីពីរ ការបំពេញតម្រូវការមូលធនមនុស្សចែងក្នុងយុទ្ធសាស្ត្រតម្រង់ទិសទៅរកសេដ្ឋកិច្ចពុទ្ធិជាដំណើរការយូរអង្វែងមួយ។ អំឡុងពេលអភិវឌ្ឍរវាងកំណែទម្រង់ប្រព័ន្ធអប់រំ និងការបង្កើតកម្មវិធីបណ្តុះបណ្តាលដែលមានគុណភាពសម្រាប់បំពេញតម្រូវការធុរកិច្ចហើយរដ្ឋាភិបាលអាចចំណាយពេលមួយទសវត្សឬច្រើនជាង។ ការប៉ាន់ស្មាននៃអត្រាផលចំណេញទទួលបានពីការវិនិយោគសាធារណៈលើការអប់រំ និងបណ្តុះបណ្តាលក្នុងបរិបទបែបនេះ គឺពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានសត្យានុម័ត និងជម្រើសបត្យានុម័តអំពីសូចនាករវាស់អត្រាផលចំណេញនេះ។ ដោយបញ្ហានៃទិន្នន័យ និងលក្ខខណ្ឌលម្អិតអំពីគុណភាពអ្វីដែលប្រសើរបំផុតអាចធ្វើបាននៅគ្រប់កន្លែង គឺត្រូវផ្តោតការយកចិត្តទុកដាក់លើទិសដៅនៃបរិមាណ និងគុណភាពនៃសេវាអប់រំ និងការបណ្តុះបណ្តាលប្រសើរជាងផ្តោតការយកចិត្តទុកដាក់លើអភក្រមគិតអំពីផលចំណេញផលខាតសម្រាប់ការវិនិយោគលើការអប់រំ និងបណ្តុះបណ្តាល។

ទីបី ក្នុងបរិបទនៃការប្រែប្រួលជាបន្តបន្ទាប់នៃរចនាសម្ព័ន្ធគ្រប់គ្រងផលិតផលក្នុងស្រុកសរុបកម្មវិធីពិពិធកម្មឧស្សាហកម្មដែលមានផែនការច្បាស់លាស់របស់រដ្ឋាភិបាល ឬពេលវេលាដែលមានមិនដើរទាន់គ្នារវាងការអប់រំ និងការបណ្តុះបណ្តាល និងការធានាសម្រេចលើកកម្ពស់សមត្ថភាពមូលធនមនុស្សឱ្យដល់កម្រិតអតិបរមានោះអសង្គតិភាពនៃជំនាញនឹងក្លាយជាការពិតនៃជីវិតសេដ្ឋកិច្ចជាមិនខាន។ សំណួរគោល-នយោបាយមួយ គឺត្រូវសម្រេចចិត្តអំពីពេលណាដែលកម្រិតនៃអសង្គតិភាពកើនខ្ពស់ហួសកម្រិតដែលអាចទទួលយកបាន និងមានការប្រែប្រួលនៃគោលនយោបាយ។ តាមពិតបណ្តាញផលិតកម្មសកលលោកដែលមានការប្រែប្រួល និងចលានបំលាស់ទីនៃឧស្សាហកម្មផ្សេងៗគ្នាជាបញ្ហាគោលនយោបាយមួយដែលខុសពីការបែកផ្លូវផ្សេងៗគ្នារវាងចង្វាក់ផ្គត់ផ្គង់ និងចង្វាក់តម្រូវការសម្រាប់ពលកម្មប្រភេទណាមួយ។

ទីបួន ការកសាងសេដ្ឋកិចពុទ្ធិសម្រាប់អនាគតក៏ទាមទារឱ្យមានទស្សនវិស័យខុសគ្នាមួយអំពីការអប់រំ និងការបណ្តុះបណ្តាលជារួមដែរ។ ម្យ៉ាងការកសាងសេដ្ឋកិច្ចពុទ្ធិទាមទារឱ្យមានអភិក្រមសម្រាប់ការបណ្តុះបណ្តាលពេញមួយជីវិតព្រោះនិយោជិតត្រូវទទួលការបណ្តុះបណ្តាលឡើងវិញដើម្បីដើរឱ្យទាន់ការប្រែប្រួលបច្ចេកវិទ្យា និងដំណើរការផលិតកម្មទាំងនៅលើសកលលោក និងនៅតាមប្រទេស។ ដោយសារហេតុផលថាមួយចំណែកធំនៃការលើកកម្ពស់នវានុវត្តភាព និងការប្រកួតរបស់ជាតិ គឺអាស្រ័យលើការប្រើប្រាស់គ្រឿងម៉ាស៊ីន និងបណ្តាញគ្រប់គ្រងការនាំចូលពីប្រទេសផ្សេង ដូច្នេះ ការបណ្តុះបណ្តាលក្នុងប្រព័ន្ធត្រូវតែបំពេញបន្ថែមដោយការធ្វើផងរៀនផងព្រោះសិប្បរចនាភាពជឿនលឿន និងស្មុគស្មាញនៃគ្រឿងម៉ាស៊ីន និងសេវាប្រើប្រាស់ថ្មីៗសុទ្ធតែនាំចូលពីប្រទេសផ្សេងៗ។ កំណើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន គឺជំរុញឱ្យមានចម្ងល់អំពីទម្រង់នៃការបណ្តុះបណ្តាល និងការអប់រំរៀបចំតាមកម្មវិធីទូរសិក្សា និងកម្មវិធីបណ្តុះបណ្តាលបង្កើនសមត្ថភាព។

ទីប្រាំ អភិក្រមនៃការអភិវឌ្ឍមូលធនមនុស្សពេញមួយជីវិត គឺនិយាយអំពីការសន្យាផ្តល់ហិរញ្ញវត្ថុរយៈពេលយូរសម្រាប់កម្មវិធីបណ្តុះបណ្តាល និងអប់រំទាំងនេះ។ ក្នុងបរិបទនៃសេដ្ឋកិច្ចដែលមានកំណើនលឿន អភិក្រមនេះមិនមានការលំបាកអ្វីទេ ព្រោះសូម្បីចំណែកថវិកាចំណាយសាធារណៈក្នុងរយៈពេលណាមួយច្រើននិយាយអំពីកំណើននៃការចំណាយលើការអប់រំ និងបណ្តុះបណ្តាល។ ហិរញ្ញប្បទានសម្រាប់សកម្មភាពទាំងនេះត្រូវការពារឱ្យបានក្នុងអំលុងពេលមានវិបត្តិ និងពេលធ្លាក់ចុះនៃសេដ្ឋកិច្ចព្រោះហិរញ្ញប្បទាននេះអាចយកទៅប្រើក្រោមគោលនយោបាយនៃការបែងចែកធនធាន និងទម្រង់ផ្សេងៗនៃហិរញ្ញវត្ថុលើសផែនការក្នុងអំលុងពេលមានកំណើនខ្ពស់ និងជាហិរញ្ញប្បទានសម្រាប់ពេលកំណើនធ្លាក់ចុះ។

ទីប្រាំមួយ ជោគជ័យនៃការពង្រីកពុទ្ធិមួយចំណែកធំក្នុងរយៈពេលជាង ១៥ ឆ្នាំកន្លងមក គឺការពង្រីក និងលើកកម្ពស់បណ្តាញពុទ្ធិឱ្យបានកាន់តែធំទៀត។ ពុទ្ធិពីអតីតកាលបានអនុញ្ញាតឱ្យមានប្រជាជន និងស្ថាប័នចូលរួមកាន់តែច្រើនដែលមិនធ្លាប់មានពីមុនមកក្នុងគ្រប់ដំណើរជីវិតដើម្បីរួមចំណែកដល់ការបង្កើនសន្តិធិនៃពុទ្ធិសកល។ ភាពអាថិកំបាំងនៃបដិវត្តន៍ពុទ្ធិមិនមែនជាការកសាងអ្នកមានជំនាញជាន់ខ្ពស់មួយចំនួនតូច និងស្ថានប័នជំនាញស្រាវជ្រាវ និងនវានុវត្តភណ្ឌបន្តិចបន្តួចនោះទេ។ សេដ្ឋកិច្ចពុទ្ធិនេះជាសមត្ថភាពលើកកម្ពស់ការចូលរួមរបស់មហាជនក្នុងការចែករំលែកពុទ្ធិ និងដោះស្រាយបញ្ហា។ ការចូលរួមរបស់មហាជននេះជាកម្លាំងចលករនៃសេដ្ឋកិច្ចសកលបច្ចុប្បន្ន។ ដោយបានឃើញក្នុងបរិបទនេះគោលនយោបាយលើកកម្ពស់ពុទ្ធិជាតិ និងអភិវឌ្ឍមូលធនមនុស្សក៏ត្រូវការបង្កើតតុល្យភាពមួយរវាងការបង្កើតគ្រឹះស្ថានជំនាញឯកទេសកម្រិតជំនាញខ្ពស់ និងការពង្រីកបណ្តាញពុទ្ធិមួយដែលធ្លាប់មានឈ្មោះមិនសូវទាក់ទាញមួយគឺ "មហាជនកម្ម"។ តុល្យភាពរវាងជម្រៅ និងទំហំនៃបណ្តាញ និងគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជាការរួមចំណែកមួយនៃការកសាងសេដ្ឋកិច្ច ពុទ្ធិ និងមមែនជាចម្ងល់អំពី "សមធម៌" ឬចលនាសង្គម និងភាពយុត្តិធម៌សង្គមទេ។

លើកយកលក្ខខណ្ឌនៃតម្រូវការចាំបាច់ខាងលើមកបង្កើតគោលនយោបាយជាតិមួយក្នុងការប្រើប្រាស់សេដ្ឋកិច្ច ពុទ្ធិសកលដាក់បញ្ចូលក្នុងផែនទីយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍មូលធនមនុស្ស គឺចង់និយាយអំពីការថែរក្សាគោលការណ៍សំខាន់ៗខាង ក្រោមជាចំណុចស្នូល :

- ធានាឱ្យមានស្តង់ដារគុណភាពជាតិអប្បបរមាអត្រាចូលរៀន និងអត្រាការចូលរួមក្នុងការអប់រំមូលដ្ឋាន និងមធ្យមសិក្សាដើម្បីផ្តល់មូលដ្ឋានគ្រឹះដ៏ត្រឹមត្រូវមួយសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបំប៉នជំនាញ បន្ថែមនៅកន្លែងការងារ និងនៅតាមគ្រឹះស្ថានអប់រំឧត្តមសិក្សា។
- អនុម័តអភិក្រមសម្រាប់អភិវឌ្ឍមូលធនមនុស្សពេញមួយជីវិត។
- វាយតម្លៃតម្រូវការមូលធនមនុស្សមិនត្រឹមតែសម្រាប់វិស័យអាជីវកម្មទេ ប៉ុន្តែសម្រាប់វិស័យស្រាវជ្រាវ និងអភិវឌ្ឍន៍បណ្តាញនវានុវត្តភណ្ឌស្នូលអាជីវកម្ម និងសម្រាប់តម្រូវការនៃការកសាងសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាលផងដែរ។
- សមាហរ័ណកម្មយ៉ាងប្រុងប្រយ័ត្ន និងការកំណត់ចំណុចដៅនៃការអប់រំ និងការបណ្តុះបណ្តាលរយៈពេលយូរសូចនាករគុណភាពរយៈពេលខ្លី ការកែទម្រង់ការអប់រំក្រៅប្រព័ន្ធ និងការងារដោយមិនចាំបាច់រងចាំឱ្យ កម្មវិធីបញ្ច្រាបការអប់រំក្នុងប្រព័ន្ធ ដោះស្រាយបញ្ហាអសង្គតិភាពជំនាញក្នុងរយៈពេលខ្លីនោះទេ។

"...សេដ្ឋកិច្ចពុទ្ធិនេះ ជាសមត្ថភាពលើកកម្ពស់ការចូលរួមរបស់មហាជនក្នុងការចែករំលែកពុទ្ធិ និងដោះស្រាយបញ្ហា។"

*"...ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី២ បានបញ្ជាក់ពីសមាសធាតុចាំបាច់ជាច្រើនសម្រាប់កសាងផែនទីយុទ្ធសាស្ត្រ ។"*

- កំណត់តុល្យភាពរវាងវិភាគទាននៃការពង្រីកការអប់រំមធ្យមសិក្សា និងឧត្តមសិក្សា ចំពោះសេដ្ឋកិច្ចពុទ្ធិ និងតម្រូវការនៃការកសាងគ្រឹះស្ថានជំនាញឯកទេសកម្រិតខ្ពស់ដែលមានសមត្ថភាពប្រើប្រាស់ការស្រាវជ្រាវ និងបច្ចេកទេសអន្តរជាតិ ។
- បង្កើតផែនការហិរញ្ញវត្ថុរយៈពេលវែងសម្រាប់ចំណាយសាធារណៈ លើមូលធនមនុស្សក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច ពុទ្ធិដោយគិតគូរពិចារណាអំពីលទ្ធភាពហិរញ្ញប្បទានរួមគ្នារវាងសាធារណៈ និងឯកជនសម្រាប់កម្មវិធីអប់រំនិងបណ្តុះបណ្តាល
- យន្តការស្ថាប័នមួយសម្រាប់សម្របសម្រួល និងបង្កើតផែនទីយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍមូលធនមនុស្សដោយយកចតុស្តម្ភនៃសេដ្ឋកិច្ចពុទ្ធិមកពិចារណាដាក់បញ្ចូលផងដែរ ។

## ១.៤. មូលធនមនុស្ស ពិពិធកម្មសេដ្ឋកិច្ច និងការស្តារសេដ្ឋកិច្ចនៅកម្ពុជា

វិបត្តិសេដ្ឋកិច្ចសកលដែលមានសភាពធ្ងន់ធ្ងរមិននឹកស្មានដល់ និងផលប៉ះពាល់យ៉ាងធំធេងនៃវិបត្តិនេះលើសេដ្ឋកិច្ចដែលកើតចេញពីអស្ថិរភាពនយោបាយ និងជម្លោះសង្គមបីទសវត្សរ៍របស់កម្ពុជាបានជំរុញឱ្យមានការវិភាគយ៉ាងច្រើនគួរឱ្យកត់សម្គាល់ឯកសារបច្ចេកទេសយ៉ាងច្រើន ឯកសារគោលនយោបាយ និងការធ្វើចំណោលសេដ្ឋកិច្ចក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ។ ថ្វីបើមានឯកសារយ៉ាងសម្បូរបែបនេះក៏ដោយក៏កម្ពុជាពុំទាន់មានផែនទីយុទ្ធសាស្ត្រអំពីការអភិវឌ្ឍមូលធនមនុស្សឱ្យច្បាស់លាស់មួយនៅឡើយទេ ដែលផែនទីយុទ្ធសាស្ត្រនោះត្រូវតែមានវិសាលភាពគ្របដណ្តប់លើចំណែកដ៏សំខាន់មួយចំនួននៃរបៀបវារៈសេដ្ឋកិច្ចពុទ្ធិដូចបានបង្ហាញខាងលើដែរ ។

ការសិក្សាវិភាគបញ្ហាកំណើនធ្វើឡើងដោយធនាគារពិភពលោកផ្តោតការយកចិត្តទុកដាក់លើអភិក្រមអប់រំ និងបណ្តុះបណ្តាលពេញមួយជីវិត និងលើសារៈសំខាន់នៃការបន្តធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងអាស៊ាន និងក្នុងអង្គការចាត់តាំងពាណិជ្ជកម្មសេដ្ឋកិច្ច និងវិនិយោគនានា ។ ការសិក្សាជាច្រើនរបស់អង្គការពលកម្មអន្តរជាតិ (ILO) និងរបាយការណ៍របស់ធនាគារពិភពលោកអំពីជំនាញបានផ្តោតការយកចិត្តទុកដាក់លើការងាររបស់យុវជន និងតម្រូវការនៃការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមឧស្សាហកម្ម និងមានការស្រាវជ្រាវជាច្រើនបានផ្តោតការយកចិត្តទុកដាក់លើបញ្ហានៃបរិយាកាស វិនិយោគ និងគោលបំណងរបស់កម្ពុជាក្នុងចំណាត់ថ្នាក់នៃសមត្ថភាពប្រកួតប្រជែងអន្តរជាតិ ។ ប៉ុន្តែ ការសិក្សាទាំងនេះ គឺល្អមួយចំណែកតូចប៉ុណ្ណោះសម្រាប់ឆ្លើយតបនឹងបញ្ហាធំៗនៃការធ្វើពិពិធកម្មឧស្សាហកម្មក្នុងរយៈពេលខ្លី ។

បន្ថែមលើការរក្សាស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ច អភិក្រមអំពីការអភិវឌ្ឍមូលធនមនុស្សរបស់រដ្ឋាភិបាលក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចបច្ចុប្បន្ន គឺបង្កើតឡើងក្នុងគោលបំណងស្តារលទ្ធភាពការងាររបស់កម្មករដែលបានបង់ការងារ និងក្នុងគោលបំណងស្តារលំហូរនៃការវិនិយោគបរទេសផ្ទាល់សម្រាប់កម្ពុជា ។ អភិក្រមនេះក៏មានទិសដៅលើកកម្ពស់ព័ត៌មានអំពីទីផ្សារ ការងារតាមរយៈការបង្កើតឡើងនូវទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) លើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈគណៈកម្មការជាតិបណ្តុះបណ្តាលបិទគម្លាតនៃអសង្គតិភាពជំនាញរវាងការពលករផ្គត់ផ្គង់ជំនាញ និងតម្រូវការជំនាញតាមរយៈការពិគ្រោះយោបល់ដែលមានការរចនាសម្ព័ន្ធច្បាស់លាស់ និងតាមរយៈការពិនិត្យវិភាគរួមគ្នាជាមួយវិស័យឯកជន និងអនុញ្ញាតឱ្យវិស័យឯកជនចូលរួមក្នុងការស្រាវជ្រាវរកគោលនយោបាយទីផ្សារមួយសមស្របសម្រាប់ជាជំនួយដល់គោលនយោបាយពិពិធកម្មឧស្សាហកម្មក្នុងពេលអនាគត ។

ក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចរយៈពេលខ្លីនេះ គឺមានគំនិតផ្ដួចផ្ដើមសកម្មភាពសំខាន់ៗទាំងអស់។ ប្រសិនបើគំនិតផ្ដួចផ្ដើមទាំងនេះ *គឺគ្រាន់តែបន្ធូរបន្ថយវិបត្តិសេដ្ឋកិច្ចបណ្ដោះអាសន្ន ឬគ្រាន់តែកាត់បន្ថយភាពអត់ការងារធ្វើមួយចំណែកដែលបង្កើតឡើងដោយព័ត៌មានទីផ្សារការងារដ៏ខ្សត់ខ្សោយមែននោះផែនទីយុទ្ធសាស្ត្រអំពីមូលធនមនុស្សជាតម្រូវការចាំបាច់។*

*ជាក់ស្ដែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី២ បានបញ្ជាក់ពីសមាសធាតុចាំបាច់ជាច្រើនសម្រាប់កសាងផែនទីយុទ្ធសាស្ត្រស្ដីការអភិវឌ្ឍមនុស្សក្នុងគោលបំណងដឹកនាំកម្ពុជាឱ្យចូលទៅកាន់សេដ្ឋកិច្ចពុទ្ធិសកល* និងតំបន់។ យុទ្ធសាស្ត្រនេះបានបញ្ជាក់យ៉ាងត្រឹមត្រូវនូវគោល-នយោបាយសម្រាប់ការរីកចម្រើននៃឧស្សាហកម្មភាពមានការងារធ្វើ និងសុវត្ថភាពសង្គម ក៏ដូចជាទិដ្ឋភាពចំបងៗនៃអភិបាលកិច្ច និងកំណែទម្រង់រដ្ឋបាលសាធារណៈដែរ។ ប្រសិនបើបណ្ដាញនៃការច្នៃប្រឌិត និងគោលនយោបាយស្រាវជ្រាវ និងអភិវឌ្ឍត្រូវបានបញ្ចូលនេះយើងនឹងមាននូវសមាសធាតុទូលទូលាយសម្រាប់យុទ្ធសាស្ត្រមូលធនមនុស្សសមរម្យក្នុងការកសាងគ្រឹះនៃសេដ្ឋកិច្ចពុទ្ធិ។

ក្នុងបរិបទនៃការមានវិបត្តិសេដ្ឋកិច្ច ការអន្ទងឱ្យអ្នកតាក់តែងគោលនយោបាយផ្ដោតការយកចិត្តទុកដាក់ទៅលើអ្វីដែលចាំបាច់សម្រាប់យកកម្មវិធីវិនិយោគលើមូលធនមនុស្សរយៈវែងជាការលំបាកណាស់ព្រោះកម្មវិធីនៃការវិនិយោគលើមូលធនមនុស្សគឺត្រូវការរយៈពេលយូរណាស់។ ប៉ុន្តែអាទិភាពក្នុងបរិបទកម្ពុជាសម្រាប់ការអភិវឌ្ឍមូលធនមនុស្សក៏មានសារប្រយោជន៍សម្រាប់រយៈពេលខ្លីដែរ។

ទីមួយ កម្ពុជាបន្តប្រឈមនឹងភាពខ្វះខាតជំនាញយ៉ាងខ្លាំងដែលបន្ថែមឡើងដោយការបំផ្លិចបំផ្លាញកម្លាំងពលកម្មជំនាញនៅទីក្រុងក្នុងរបបខ្មែរក្រហម។ ទីពីរ ស្ទើរគ្រប់សេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍទាំងអស់ ជាពិសេសនៅអាស៊ីបានឆ្លងកាត់នូវកំណែទម្រង់ធំៗជាច្រើននៃមូលដ្ឋានគ្រឹះមូលធនមនុស្ស ប្រព័ន្ធបណ្ដុះបណ្ដាល និងអប់រំនៅដែលភាគច្រើននៅទសវត្សរ៍ចុងក្រោយនេះ។ ទីបី ពិពិធកម្មឧស្សាហកម្មក្នុងផលិតផលសកលថ្មីមិនអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាពបានទេ ប្រសិនបើមិនអភិវឌ្ឍន៍ធនធាននៃមូលធនមនុស្សរបស់កម្ពុជាឱ្យលឿនទេ។ ទីបួន កិច្ចព្រមព្រៀងសេដ្ឋកិច្ចជាច្រើនចុះហត្ថលេខាជាមួយអាស៊ាន និងរវាងអាស៊ានជាមួយប្រទេសដទៃទៀតនៅអាស៊ីប៉ាស៊ីភិច (ក៏ដូចជាអឺរ៉ុប) កំពុងជួយកែប្រែមូលដ្ឋាននៃពាណិជ្ជកម្ម និងវិនិយោគដែលអាចទាក់ទាញសេដ្ឋកិច្ចបែបឧស្សាហកម្មដែលកាន់តែមានពិពិធកម្មថ្មី និងច្រើនជាងមុនឱ្យចូលរួមផងដែរ។ ដោយសារស្ថានភាពបែបនេះ ការឆ្លើយតបនឹងវិបត្តិរយៈពេលខ្លី និងរយៈពេលវែង គឺមិនអាចដាក់ឱ្យនៅដាច់ពីគ្នាទេ។

## ១.៥. ការរៀបចំជំពូកនៃរបាយការណ៍នេះ

គោលបំណងសំខាន់មួយនៃរបាយការណ៍ស្ដីពីមូលធនមនុស្សរបស់កម្ពុជា សំដៅផ្ដល់ចំណេះដឹង និងកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ផែនទីយុទ្ធសាស្ត្រស្ដីពីមូលធនមនុស្សសម្រាប់ពេលអនាគត។ ជំពូក២ បង្ហាញទិដ្ឋភាពរួមនៃស្ថានភាពមូលធនមនុស្សនៅកម្ពុជាបច្ចុប្បន្ន។ ជំពូក៣ ផ្ដោតការយកចិត្តទុកដាក់លើការបណ្ដុះបណ្ដាលតាមវិស័យ និងបញ្ហាជំនាញ។ ជំពូក៤ ពិនិត្យមើលលើកត្តាសំខាន់នៃមូលធនមនុស្សនៅក្នុងវិស័យក្រៅធុរកិច្ច។ ជំពូក៥ បង្ហាញអំពីយុទ្ធសាស្ត្រមូលធនមនុស្សដែលអាចអនុវត្តបានសម្រាប់កម្ពុជា។ ជំពូក ៦ ធ្វើការសន្និដ្ឋាន និងគូសបង្ហាញពីគោលនយោបាយគន្លឹះៗ និងផ្ដល់អនុសាសន៍គោលនយោបាយជំហ៊ានដំបូង។

# ជំពូកទី ២: មូលធនមនុស្សនៅកម្ពុជាបច្ចុប្បន្ន

ជំពូកនេះព្យាយាមវិភាគយ៉ាងយកចិត្តទុកដាក់អំពីកម្រិតអំពីគុណភាព និងផលប៉ះពាល់នៃមូលធនមនុស្សនៅកម្ពុជាបច្ចុប្បន្ន។ ជំពូកនេះក៏សិក្សាវិភាគអំពីចរិតលក្ខណៈ និងលក្ខណៈពិសេស១ៗនៃការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជាផងដែលក្នុងគោលបំណងកំណត់ដំណាក់កាលនៃការវិភាគ និងវាយតម្លៃអំពីមូលធនមនុស្សដែលត្រូវសរសេរក្នុងជំពូកបន្តបន្ទាប់ទៀត។ ជំពូកនេះ ក៏សិក្សាវិភាគអំពីកត្តានានា ដូចជាប្រជាសាស្ត្រ អន្តោប្រវេសន៍អត្រាសិស្សចូលសាលា គុណភាព និងកម្រិតនៃការបណ្តុះបណ្តាលវិភាគអំពីនិន្នាការការងារ អសង្គតិភាពរវាងការអប់រំ និងតម្រូវការកម្លាំងពលកម្មភាពប្រែប្រួលខុស១ៗគ្នាតាមតំបន់គោលនយោបាយរបស់រដ្ឋាភិបាល និងបញ្ហាដែលកម្ពុជាកំពុងប្រឈម។

ដើម្បីកំណត់អំពីសន្និធិនៃមូលធនមនុស្សរបស់ប្រទេសមួយ ពុំមែនជាការសាមញ្ញដូចការក្រឡេកមើលចំនួនមនុស្សក្នុងសាលា ឬចំនួនមនុស្សបានបញ្ចប់ការសិក្សាទេ។ ដោយសារការពន្យល់នេះបង្ហាញគ្រាន់តែឱ្យឃើញរូបភាពមួយចំណែក ដូច្នេះនៅមានការខ្វះចន្លោះច្រើនណាស់។ ឧទាហរណ៍ ប្រសិនបើមនុស្សចំនួន x បានបញ្ចប់ការសិក្សា តើមនុស្សប៉ុន្មាននាក់ មិនបានបញ្ចប់ការសិក្សា? តើនិស្សិតបញ្ចប់ការសិក្សាទាំងនោះយកចំណេះទទួលបានពីការអប់រំទៅប្រើដើម្បីធ្វើអ្វីខ្លះ? តើការអប់រំដែលពួកគេទទួលបានមានប្រយោជន៍ឬទេ? តើពួកគេនឹងបន្តការសិក្សាតទៅទៀតដែរឬទេ? ហើយចុងបញ្ចប់ តើការអប់រំនេះនឹងមានឥទ្ធិពលលើវិថីអាជីពរបស់ពួកគេ និងលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសយ៉ាងដូម្តេច?

សំណួរទាំងអស់ខាងលើបង្ហាញឱ្យឃើញអំពីតម្រូវការសិក្សាវិភាគអំពីគំនិតដែលផ្លាស់ប្តូរ និងជូនកាលត្រួតពិនិត្យមើលគំនិតផ្ទុយគ្នា និងគំនិតប្រែប្រួលមុននឹងបង្ហាញរូបភាពពិតទាំងស្រុងមួយ។ សូចនាករដែលនិយមប្រើប្រាស់សម្រាប់អ្នកវាយតម្លៃច្រើនយកចំនួនឆ្នាំគិតជាមធ្យមនៃការអប់រំរបស់ប្រជាជនទូទៅ។ ទោះជាយ៉ាងណាការប្រើសូចនាករនេះបង្កើតឱ្យមានក្តីបារម្ភធំៗជាច្រើន។ ឧទារហណ៍ ភាពខុសគ្នានៃគុណភាពអប់រំរវាងប្រទេស និងប្រទេសរវាងតំបន់ និងតំបន់ ឬរវាងសាលា និងសាលាក្នុងប្រទេសមួយនេះមានន័យថា រយៈពេលមួយឆ្នាំនៃការចូលរៀននៅសាលាសម្រាប់សិស្សម្នាក់ មិនមែនមានន័យថា មានកម្រិតអប់រំដូចគ្នាជាមួយសិស្សម្នាក់ទៀតទេ។ ការសន្និដ្ឋានគឺថា ចំនួនឆ្នាំទាំងអស់នៃការអប់រំអាចចាត់ទុកថាដូចគ្នា ប៉ុន្តែប្រភេទ និងចំនួននៃផលចំណេញទទួលបានពីការចូលរៀននៅសាលាបឋមសិក្សារយៈពេលមួយឆ្នាំធៀបនឹងរយៈពេលមួយឆ្នាំចូលរៀនក្នុងកម្មវិធីសិក្សាសម្រាប់ថ្នាក់បណ្ឌិត គឺមានភាពខុសគ្នាខ្លាំង។ ដូច្នេះ ចំនួនឆ្នាំសិក្សានេះមិនបានដោះស្រាយបញ្ហាដែលថា ការអប់រំដែលផ្តល់ឱ្យសិស្សឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សិស្ស ឬតម្រូវការសេដ្ឋកិច្ចឬយ៉ាងណានោះទេ។ ចំនួនឆ្នាំសិក្សានេះមិនមានបង្ហាញអំពីផលប៉ះពាល់នៃការប្រែប្រួលធៀបនឹងកម្រិតអប់រំក្នុងប្រទេសនោះទេ។ ចំនួនឆ្នាំសិក្សានេះ ក៏មិនដោះស្រាយបញ្ហារយៈពេលចូលរៀនក្នុងសាលាពិតប្រាកដដែរ ឧទារហណ៍ ការបាត់បង់ពេលវេលានៃការសិក្សាដោយសារការរៀនត្រួតថ្នាក់។ រហូតមកដល់ពេលនេះ មិនទាន់មានការវាយតម្លៃអំពីការអប់រំបន្ត ឬការអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សពេញវ័យដែលកំពុងឋិតក្នុងកម្លាំងពលកម្មទេ។ ការវាយតម្លៃបែបនេះក៏មិនសិក្សាវិភាគអំពីកម្រិតអប់រំខ្ពស់របស់យុវវ័យជាងកម្រិតអប់រំរបស់មនុស្សពេញវ័យក្នុងកម្រិតមួយដែលអាចមានឥទ្ធិពលប៉ះពាល់ដល់កម្រិតមូលធនមនុស្សក្នុងចំណោមប្រជាជនទូទៅ។ ការវាយតម្លៃបែបនេះក៏មិនដោះស្រាយបញ្ហាវិសមភាព អប់រំដែរ ឧទារហណ៍ប្រជាជនមួយភាគតូចមានការអប់រំខ្ពស់ហើយប្រជាជនមួយក្រុមទៀតជា

*"... ដើម្បីកំណត់អំពីសន្និធិនៃមូលធនមនុស្សរបស់ប្រទេសមួយ ពុំមែនជាការសាមញ្ញដូចការក្រឡេកមើលចំនួនមនុស្សក្នុងសាលា ឬ ចំនួនមនុស្សបានបញ្ចប់ការសិក្សាទេ។"*

អនក្ខរជន។ ការវាយតម្លៃនេះ ក៏មិនសិក្សាវិភាគអំពីលាភការដែលមានការប្រែប្រួលសម្រាប់ការចូលរៀននៅសាលា និងអំពីផលប៉ះពាល់ទៅលើកម្រិតអប់រំទាំងមូលដែរ។

ហេតុនេះហើយបានជាការសិក្សានេះយើងពិនិត្យមើលសូចនាករជាច្រើនដែលមានផលប៉ះពាល់ដល់កម្រិតមូលធនមនុស្សទាំងក្នុងរយៈពេលខ្លី និងទាំងរយៈពេលវែង។ ផ្នែកនេះមានបំណងដូចតទៅ។ ផ្នែកប្រជាសាស្ត្របង្ហាញអំពីសម្ពាធនៃបំរែបំរួលប្រជាជនកម្ពុជាសង្កត់ទៅលើតម្រូវការរបស់ប្រព័ន្ធអប់រំ និងទៅលើកំណើនកម្លាំងពលកម្មដែលត្រូវទទួលការបណ្តុះបណ្តាលជាចាំបាច់។ ផ្នែកអន្តោប្រវេសន៍បង្ហាញអំពីចលនាបំលាស់ទីរបស់ប្រជាជនដែលធ្វើឱ្យមានការប្រែប្រួលនៃតម្រូវការសម្រាប់ការអប់រំដែលត្រូវដោះស្រាយក្នុងពេលអនាគត។ ផ្នែកអំពីអត្រាចូលរៀន អត្រារៀនត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា វិភាគអំពីកម្រិតអប់រំដែលយុវជនកម្ពុជាកំពុងទទួលបានក្នុងពេលបច្ចុប្បន្ន។ ផ្នែកអំពីគុណភាព និងកម្រិតអប់រំ បង្ហាញអំពីសន្និធិនៃមូលធនមនុស្សរួមទាក់ទិននឹងចំនួនឆ្នាំនៃការអប់រំនៅកម្ពុជា និងអំពីអត្ថប្រយោជន៍នៃសន្និធិរបស់មូលធនមនុស្ស។ ផ្នែកអំពីនិន្នាការការងារបង្ហាញអំពីទីកន្លែងដែលមានកំណើនតម្រូវការនៃការអប់រំ និងកន្លែងដែលមានការប្រែប្រួលសេដ្ឋកិច្ចកម្ពុជាឆ្លុះបញ្ចាំងពីការប្រែប្រួលនៃប្រព័ន្ធអប់រំ និងដាក់សម្ពាធលើសេដ្ឋកិច្ចក្នុងពេលអនាគត។ ផ្នែកអំពីអសង្គតិភាពរវាងការអប់រំ និងការងារបង្ហាញអំពីប្រព័ន្ធអប់រំដែលពុំមានផ្តល់ការបណ្តុះបណ្តាលសមរម្យដល់និស្សិតរបស់ខ្លួនសម្រាប់បំពេញការងារ។ ផ្នែកសាកលវិទ្យាល័យ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្យាយាមបង្ហាញទស្សនៈរួមអំពីអ្វីដែលជាភាពពិតនៃវិស័យទាំងអស់នេះនៅកម្ពុជាសព្វថ្ងៃ។ ផ្នែកភាពខុសគ្នាក្នុងតំបន់បង្ហាញអំពីលំដាប់ថ្នាក់របស់ប្រទេសកម្ពុជាធៀបនឹងប្រទេសផ្សេងទៀតនៅអាស៊ី និងអាស៊ាន តើខុសគ្នាយ៉ាងដូចម្តេច។ ផ្នែកចុងក្រោយ និយាយអំពីបញ្ហាប្រឈមពណិនាអំពីតំបន់នានាដែលកំពុងមានបញ្ហារាំងការសម្រេចបង្កើតសន្និធិមូលធនមនុស្សនៅកម្ពុជា។

## ២.១ ប្រជាសាស្ត្រ

ប្រវត្តិសាស្ត្រក្នុងរយៈកាល ៤ ទសវត្សរ៍ចុងក្រោយនេះមានឥទ្ធិពលមកលើប្រជាសាស្ត្ររបស់កម្ពុជាយ៉ាងខ្លាំង។ សង្គ្រាមស៊ីវិល និងរបបខ្មែរក្រហមបានសម្លាប់មនុស្សរាប់លាននាក់ ហើយជះឥទ្ធិពលប៉ះពាល់ដល់ការអង្កេតប្រជាសាស្ត្ររបស់ប្រទេសយ៉ាងខ្លាំង។ ដោយរបបខ្មែរក្រហមបានបញ្ចប់ និងការត្រលប់មកវិញនូវសន្តិភាពប្រកបដោយស្ថិរភាពជាងមុន ក្នុងទសវត្សរ៍១៩៩០ កម្ពុជាបានឆ្លងកាត់បទពិសោធនៃការផ្ទុះកំណើតទារកក្នុងទសវត្សរ៍ ១៩៨០ និង១៩៩០។ ដំណាក់កាលទាំងពីរនេះបានផ្តល់កំណើនអ្វីដែលត្រូវបានចាត់ទុកថាជា "កំណើនយុវជន" ក្នុងរចនាសម្ព័ន្ធប្រជាជនរបស់កម្ពុជា។ ដោយសារយុវជនទាំងនេះបានពេញវ័យ និងបានក្លាយជាកម្លាំងពលកម្មរួមបញ្ចូលទាំងការធ្លាក់ចុះអត្រាកំណើតចាប់ពីឆ្នាំ ២០០០ កម្ពុជាកំពុងជួបប្រទះការធ្លាក់ចុះនៃអត្រាអ្នកតាមហួប។ ក្នុងរយៈពេលតែពីរឆ្នាំ ចាប់ពី ២០០៥ ដល់ ២០០៧ អត្រានេះបានធ្លាក់ចុះ ៥ ភាគរយ ហើយក្នុងឆ្នាំ ២០០៥ អត្រានេះបានធ្លាក់ចុះ ៤ ភាគរយពីកម្រិតក្នុងឆ្នាំ ២០០០ (រូប២.១)។

*រូប ២.១ : អត្រាអ្នកតាមហូបកំណត់តាមឆ្នាំ*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០០៩។ ការរក្សានិរន្តរភាពកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សក្នុងបរិស្ថានប្រកបដោយ ភាពប្រឈម : អនុស្សារណៈយោគយល់សេដ្ឋកិច្ចប្រទេសកម្ពុជា។ អង្គភាពកាត់បន្ថយភាពក្រីក្រ និងវិស័យគ្រប់គ្រងសេដ្ឋកិច្ចប្រចាំតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ទំព័រទី ២៩។*

កំណើនយុវជនដូចបានលើកឡើងកំពុងដឹកនាំឆ្ពោះទៅរកការពង្រីកកម្លាំងពលកម្មកម្ពុជាយ៉ាងខ្លាំង។ ពីរ៉ាមីតអាយុប្រជាជនពី ឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៨ បង្ហាញថា យុវជនទាំងនេះកាន់តែមានអាយុច្រើន និងក្លាយជាកម្លាំងពលកម្ម (រូប ២.២) ហើយតួលេខនេះ រំពឹងថានឹងកើតមានបន្តទៀតព្រមទាំងបង្កើតឱ្យមានកំណើនយុវជនដំណាក់កាលទីពីរនៅទសវត្សរ៍ខាងមុខ។

*រូប ២.២ : ពីរ៉ាមីតអាយុប្រជាជនកម្ពុជា*




*ប្រភព : ក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ទំព័រទី ៦។*

ភាពជំពាក់ជំពិននៃបញ្ហានេះលើប្រព័ន្ធអប់រំមានកម្រិតខ្លាំងក្លា។ កំណើនយុវជនដ៏ច្រើនបែបនេះអាចបង្កឱ្យមានបញ្ហាគ្មានការអភិវឌ្ឍ និងការគ្មានការងារធ្វើកាន់តែខ្លាំង ប្រសិនបើពុំមានការអនុវត្តគោលនយោបាយត្រឹមត្រូវ។ ក្នុងឆ្នាំ ២០០៨ ប្រជាជនចំនួនជិត ៦០ ភាគរយ នៃចំនួនប្រជាជនសរុបមានអាយុក្រោម ២៤ឆ្នាំ។ កម្រិតនេះធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយមានប្រជាជនជាយុវជនច្រើនបំផុត

ក្នុងចំណោមប្រទេសផ្សេងទៀតនៅក្នុងសមាគមអាស៊ាន និងជាប្រទេសដែលទទួលបានការព្យាករថានឹងមានកំណើនកម្លាំងពលកម្មខ្ពស់បំផុតទីពីរ បន្ទាប់ពីប្រទេសឡាវ (មាន ២៥ ភាគរយ) គិតចាប់ពី ឆ្នាំ២០០៧ ដល់ ឆ្នាំ២០១៥ ក្នុងកំណើន ២២ ភាគរយ (រូប២.៣)។

*រូប ២.៣ : ការព្យាករពីកំណើនកម្លាំងពលកម្មក្នុងប្រទេសកម្ពុជាពីឆ្នាំ២០០៧-២០១៥ (%)*




*ប្រភព : ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃរាជរដ្ឋាភិបាលគោលនយោបាយទេសន្តរប្រវេសន៍ការងារកម្ពុជា ទំព័រទី៦។*

ដើម្បីបន្តឱ្យមានកំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់ដែលសេដ្ឋកិច្ចរបស់កម្ពុជា បានឆ្លងកាត់អស់រយៈកាល១០ឆ្នាំ កន្លងទៅនេះរដ្ឋាភិបាលធានាបង្កើតកម្លាំងពលកម្មប្រកបដោយការអប់រំល្អ និងមានជំនាញ។ ការពង្រីកកម្លាំងពលកម្មប្រកបដោយជំនាញ និងមានសមត្ថភាពអាចទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញឱ្យមានកំណើនបន្ថែមទៀត។ ប្រសិនបើទីផ្សារការងារពោរពេញដោយនិយោជិតគ្មានជំនាញសេដ្ឋកិច្ចមិនអាចទាញយកផលចំណេញពីអត្ថប្រយោជន៍ទាំងនេះបានទេ។ លើសពីនេះទៅទៀត ប្រសិនបើប្រជាជនជាច្រើនចូលរួមក្នុងកម្លាំងពលកម្ម ដោយគ្មានជំនាញ និងគ្មានការបណ្តុះបណ្តាលគ្រប់គ្រាន់ពួកគេមិនអាចរក្សាការងារបានទេ។ កត្តានេះបង្កើតឱ្យមានចំនួននិយោជិតក្រីក្រ និងគ្មានជំនាញជាច្រើន ហើយបន្តពឹងអាស្រ័យលើរដ្ឋាភិបាលពេញមួយជីវិត (ធនាគារពិភពលោក ២០១០)។ ជាការពិតណាស់ការសន្យានេះពិតជាពិបាកសម្រេចបានណាស់ដោយសារធនធានហិរញ្ញវត្ថុនៅមានកម្រិត។ រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតផែនការអប់រំទូលំទូលាយមួយដោយពិចារណាលើកត្តាអភិវឌ្ឍន៍ផ្សេងៗ ដែលអាចជួយពួកគេឱ្យជៀសផុតពីអន្ទាក់នៃភាពក្រីក្រដែលអាចជំរុញអនុវត្តផែនការអប់រំដែលមានប្រសិទ្ធភាពជាបន្ទាន់។

## ២.២ អន្តោប្រវេសន៍

ទោះជាប្រជាជនកម្ពុជាមួយភាគធំនៅតែរស់នៅជនបទ ហើយប្រជាជនកម្ពុជាជាច្រើនមិនបានចាកចេញពីភូមិ ឋានរបស់ខ្លួនក្តីក៏ក្នុងរយៈពេល ១ ទសវត្សរ៍ចុងក្រោយនេះប្រទេសកម្ពុជាបានជួបប្រទះនូវកំណើននៃចំនួនប្រជាជនជាច្រើនដែលធ្វើអន្តោប្រវេសន៍ក្នុងប្រទេសផងដែរ (រូប២.៤)។

*រូប ២.៤ : ភាគរយនៃការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនក្នុងអំឡុងពេលបីដង គឺពីឆ្នាំ ១៩៨០-១៩៩៣ ឆ្នាំ១៩៩១-១៩៩៥ និងឆ្នាំ១៩៩៩-២០០៣*




*ប្រភព : E. Morris ឆ្នាំ២០០៧ ។ ការលើកកម្ពស់ការងារក្នុងប្រទេសកម្ពុជា : ការវិភាគ និងជម្រើសអង្គការ ឡូ ទំព័រទី ៧៧ ។*

យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ ជនអន្តោប្រវេសន៍មាន ៤,៥ លាននាក់ ពោលគឺកើនឡើងពី ៣,៦ លាននាក់ ក្នុងការអង្កេត ឆ្នាំ១៩៩៨ ហើយ ៩៦ ភាគរយ ជាការធ្វើអន្តោប្រវេសន៍ក្នុងប្រទេស (ដកស្រង់ចេញពីឯកសាររបស់អង្គការ ILO ឆ្នាំ២០០៧ ដែលមានចំណងជើងថា ការលើកកម្ពស់ការងារនៅកម្ពុជា) ។

តួលេខនេះ បង្ហាញឱ្យឃើញថា តើការធ្វើអន្តោប្រវេសន៍របស់យុវជនមានកម្រិតខ្ពស់ប៉ុណ្ណា ជាពិសេសយុវជនទាំងពីរភេទក្នុងអាយុចន្លោះ ២០ឆ្នាំ។ ក្នុង ឆ្នាំ២០០៤ យុវជនអាយុពី ២០ ទៅ ២៤ឆ្នាំ ចំនួន ១៧,២ ភាគរយ បានធ្វើអន្តោប្រវេសន៍ (ប្រុស ១៩,៥ ភាគរយ ស្រី ១៥ ភាគរយ) ចំណែកឯ ១៧,៨ ភាគរយទៀត មានអាយុចាប់ពី ២៥ ដល់ ២៩ឆ្នាំ (ប្រុស ២២,៩ភាគរយ ស្រី ១៣ ភាគរយ)។ ទោះជាយ៉ាងណាយុវជនមានភាពចល័តទីជាងមនុស្សចាស់ជំនាន់មុនដែលអាចនៅតែមានន័យថា ចំនួនយុវជនធ្វើអន្តោប្រវេសន៍នាពេលអនាគតនឹងកើនកាន់តែខ្ពស់ (តារាង ២.១) ។

*តារាង ២.១ : អត្រាអន្តោប្រវេសន៍របស់ប្រជាជនទីក្រុង និងជនបទដោយបែងចែកតាមប្រភេទក្នុងចន្លោះអាយុ ៥ឆ្នាំ និងភេទ ឆ្នាំ២០០៤*

| អាយុ | កម្ពុជា | | | ទីក្រុង | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| ក្រុម | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| 15-19 | 8.2 | 7.2 | 9.2 | 17.3 | 14.7 | 19.7 | 6.5 | 5.8 | 7.1 |
| 20-24 | 17.2 | 19.5 | 15.0 | 28.2 | 27.9 | 28.5 | 14.8 | 17.8 | 12.1 |
| 25-29 | 17.8 | 22.9 | 13.0 | 31.6 | 36.4 | 27.3 | 15.1 | 20.4 | 10.2 |
| 30-34 | 11.7 | 14.2 | 9.5 | 22.4 | 25.3 | 19.6 | 9.6 | 12.0 | 7.5 |
| 35-39 | 8.9 | 10.9 | 7.1 | 16.9 | 20.0 | 14.1 | 7.4 | 9.1 | 5.9 |
| អាយុទាំងអស់ | 8.3 | 9.1 | 7.6 | 16.4 | 16.6 | 16.2 | 6.9 | 7.8 | 6.0 |

*ប្រភព : E. Morris ឆ្នាំ២០០៧ ។ ការលើកកម្ពស់ការងារក្នុងប្រទេសកម្ពុជា : ការវិភាគ និងជម្រើស ។ អង្គការ ILO ទំព័រទី ៨០ ។*

*"ការចូលសិក្សាក្នុងសាលាបឋមសិក្សានាពេលបច្ចុប្បន្ននៅកម្ពុជាបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈកាល ២ ទសវត្សរ៍ចុងក្រោយនេះ ហើយបច្ចុប្បន្នអត្រានេះមានកម្រិតខ្ពស់ ប៉ុន្តែធ្លាក់ចុះទៅវិញបន្ទាប់ពីបានបញ្ចប់បឋមសិក្សា ។"*

ស្ថិតក្នុងលក្ខខណ្ឌកំណើនកម្រិតនៃការធ្វើអន្តោប្រវេសន៍ទាំងនេះ ការយល់ដឹងឱ្យបានប្រសើរជាងមុនអំពីផលប៉ះពាល់ ដែលចលនានេះបង្កឡើងលើការអភិវឌ្ឍជំនាញ និងការងារកំពុងមានសារៈសំខាន់ជាខ្លាំង ។ នៅពេលមានអន្តោប្រវេសន៍ពីតំបន់ជនបទទៅកាន់ទីក្រុង ឬការធ្វើអន្តោប្រវេសន៍តាមរដូវកាល ពោលគឺជាការធ្វើអន្តោប្រវេសន៍ដើម្បីស្វែងរកការងារធ្វើ ប៉ុន្តែ ស្ថិតក្នុងលក្ខខណកម្រិតការអប់រំទាបនៅទូទាំងប្រទេសកម្ពុជា (ពិសេសតំបន់ជនបទមានច្រើនជាង) ការធ្វើអន្តោប្រវេសន៍ទាំងនេះកំពុងឈានទៅរកការបង្កើនចំនួនកម្មករអន្តោប្រវេសន៍ដែលទទួលបានកម្រៃទាប និងគ្មានជំនាញជាច្រើនដែលការធ្វើអន្តោប្រវេសន៍ (ជាញឹកញាប់ទៅទីក្រុង) ដើម្បីស្វែងរកការងារធ្វើ ។ ការបរាជ័យក្នុងការប្រើប្រាស់ជនអន្តោប្រវេសន៍ទាំងនេះក្នុងការងារផលិតកម្មជាការខាតបង់មួយយ៉ាងធំធេងណាស់ហើយអាចបង្កើតឱ្យមានភាពចលាចលសង្គមបង្កឡើងដោយកម្មករជាច្រើនដែលមិនសប្បាយចិត្ត ។ ដូច្នេះ ការធ្វើអន្តោប្រវេសន៍ និងការបន្លាស់លំនៅនេះជាតម្រូវការប្រកបដោយថាមពលសម្រាប់បង្កើនសមត្ថភាពអនុវត្តជំនាញ ហើយការផ្តោតការយកចិត្តទុកដាក់ចំពោះអនាគតមិនមែនត្រូវការត្រឹមតែជំនាញផ្នែករឹងប៉ុណ្ណោះទេ ថែមទាំងត្រូវការជំនាញផ្នែកទន់ថែមទៀតផងដែលជំនាញផ្នែករឹង និងជំនាញផ្នែកទន់នេះអាចយកមកប្រើប្រាស់ក្នុងឧស្សាហកម្ម ឬវិស័យផ្សេងៗទៅតាមតម្រូវការនៃការប្រែប្រួលកម្លាំងពលកម្ម ។

## ២.៣ អត្រាចូលសាលា អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា

ការចូលសិក្សាក្នុងសាលាបឋមសិក្សានាពេលបច្ចុប្បន្ននៅកម្ពុជាបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈកាល ២ទសវត្សរ៍ចុងក្រោយនេះ ហើយបច្ចុប្បន្នអត្រានេះមានកម្រិតខ្ពស់ ប៉ុន្តែធ្លាក់ចុះទៅវិញបន្ទាប់ពីបានបញ្ចប់បឋមសិក្សា ។ តួលេខពីឆ្នាំ ២០០៩-២០០១០ បង្ហាញថា ការចុះឈ្មោះចូលរៀននៅបឋមសិក្សាទូទាំងប្រទេសមានជាង ៩០ភាគរយ ហើយបើទោះបីជាចំនួនសិស្សចុះឈ្មោះចូលរៀនមានភាពប្រែប្រួលពីតំបន់មួយទៅតំបន់មួយក្តីក៏ការចុះឈ្មោះចូលរៀនទាំងអស់មានចំនួនលើស ៨០ភាគរយ ហើយភាគច្រើនលើសពី ៩០ភាគរយ ។ ទោះបីជាយ៉ាណា នៅពេលសិស្សបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ (ពីថ្នាក់ទី ៧-៩) ការចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំង ។ នៅទូទាំងប្រទេសតួលេខសិស្សបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ មានចំនួនលើពី ៣០ ភាគរយបន្តិច ដោយនៅទីក្រុងភ្នំពេញឋិតនៅលំដាប់ខ្ពស់ក្នុងតារាង ហើយមានអត្រាចុះឈ្មោះចូលរៀន ៥៥ ភាគរយ ហើយនៅតំបន់ផ្សេងទៀតមានចំនួន ១០ភាគរយ (រូប ២.៥) ។

*រូប ២.៥ : អត្រាចុះឈ្មោះចូលរៀនពិតនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិក្នុងខេត្តនីមួយៗ សម្រាប់ឆ្នាំសិក្សា ២០០៩-២០១០*




*ប្រភព : ក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ទំព័រទី ១៧។*

និន្នាការនេះបន្តកើតមានពាសពេញឋានានុក្រមអប់រំ។ ដូចក្នុងតារាង ២.២ បង្ហាញថា អត្រាចុះឈ្មោះចូលរៀនសម្រាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ មានកម្រិតតិចតួច គឺ ១៣ភាគរយ។ ក្នុងចំណោមយុវជនដែលមានអាយុ ១៥ឆ្នាំ ១ ភាគ ៤ ក្នុងចំណោមយុវជនទាំងនោះបោះបង់ការសិក្សា ហើយក្នុងចំណោមយុវជនអាយុ១៩ឆ្នាំ យុវជនចំនួន ២ ភាគ៣ ក្នុងចំណោមយុវជនទាំងនោះបានឈប់រៀន។ លើសពីនេះទៀតប្រជាជនកម្ពុជាភាគច្រើនបានចូលសិក្សាបានរយៈពេលត្រឹមតែពី ៥ ទៅ ៧ឆ្នាំ ប៉ុន្តែសម្រាប់រយៈពេល ១១ឆ្នាំ ចំនួនសិស្សចុះឈ្មោះចូលរៀនបានធ្លាក់ចុះយ៉ាងខ្លាំង (រូប ២.៦)។

*តារាង ២.២: អត្រាចុះឈ្មោះចូលរៀនពិត/អត្រាចូលសាលានៅបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ តាមតំបន់ និងភេទ គិតជាភាគរយ ឆ្នាំ២០០៧*

| ប្រទេសកម្ពុជា | ស្រី | ប្រុស | សរុប |
|---|---|---|---|
| អត្រាចុះឈ្មោះចូលរៀនពិត/អត្រាចូលសាលានៅបឋមសិក្សា តាមតំបន់ និងភេទ ឆ្នាំ២០០៧ គិតជាភាគរយ | ៨២ | ៨១ | ៨២ |
| អត្រាចុះឈ្មោះចូលរៀនពិត/អត្រាចូលសាលានៅមធ្យមសិក្សា បឋមភូមិ តាមតំបន់ និងភេទ ឆ្នាំ២០០៧ គិតជាភាគរយ | ៣០ | ២៧ | ២៩ |
| អត្រាចុះឈ្មោះចូលរៀនពិត/អត្រាចូលសាលានៅមធ្យមសិក្សា ទុតិយភូមិ តាមតំបន់ និងភេទ ឆ្នាំ២០០៧ គិតជាភាគរយ | ១៣ | ១៤ | ១៣ |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៩។ ក្រសួងផែនការនៃប្រទេសកម្ពុជា ទំព័រទី ១២។*

*"...សិស្សបោះបង់ការសិក្សា ខកខានក្នុងការទទួលបានការអប់រំមូលដ្ឋាន ដែលការសិក្សានាពេលអនាគតត្រូវការការអភិវឌ្ឍ ។"*

*រូប ២.៦ : ស្ថានភាពការបោះបង់ការសិក្សារបស់យុវជន និងការអប់រំ ឆ្នាំ២០០៧*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០ ។ ការផ្ដល់ជំនាញសម្រាប់សមធម៌ និងកំណើនសេដ្ឋកិច្ច : ការរៀបចំយុវជន កម្ពុជាសម្រាប់ទីផ្សារការងារ ។ នាយកដ្ឋានអភិវឌ្ឍន៍មនុស្សប្រចាំតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ទំព័រទី ៤២ ។*

ក្រៅពីអត្រាអប់រំទាប និងអត្រាបោះបង់ការសិក្សាខ្ពស់ គួរផ្ដោតការយកចិត្តទុកដាក់លើអត្រារៀនត្រួតថ្នាក់នៅក្នុងប្រទេស ។ តួលេខចំនួនសិស្សត្រួតថ្នាក់ពីថ្នាក់ទី ១ ដល់ទី ៦ បង្ហាញក្នុងរូប ២.៧ ។ ទោះបីជាតួលេខទាំងនេះមិនមានកម្រិតខ្ពស់ក្ដី ក៏តួលេខទាំងនេះគួរទទួលបានការកត់សម្គាល់ផងដែរ ។ អ្វីដែលកាន់តែមានក្ដីបារម្ភនោះ គឺថាអត្រាទាំងនេះពិតជាបាន និងកំពុងកើនឡើងក្នុងរយៈពេលជាង១ទសវត្សរ៍ចុងក្រោយនេះ ពោលគឺជានិន្នាការការដ៏គ្រោះថ្នាក់មួយសម្រាប់អនាគត ។ ទោះបីជាអត្រាត្រួតថ្នាក់នេះ បណ្ដាលមកពីកត្តាផ្សេងៗក្ដី (សេចក្ដីពិភាក្សាបន្ថែមមានក្នុងផ្នែកបញ្ហាប្រឈម) ក៏អត្រានេះជាក្លាយវិស័យដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលដើម្បីប្រយុទ្ធប្រឆាំងដោះស្រាយឱ្យបាន ប្រសិនបើរដ្ឋាភិបាលចង់លើកកម្ពស់កម្រិតការអប់រំរបស់ពលរដ្ឋឱ្យបានខ្ពស់ ។

*រូប ២.៧ : ចំនួនសិស្សរៀនត្រួតថ្នាក់នៅគ្រប់កម្រិតនៅមធ្យមសិក្សា*




*ប្រភព : ស្ថិតិរបស់អង្គការយូណេស្កូ ។*

ដូច្នេះ ទោះបីជាមានភាពរីចម្រើនខ្លាំងក្ដី ក៏អត្រាចូលសាលាក្នុងប្រទេសកម្ពុជានៅថ្នាក់ក្រោយបឋមសិក្សា មានកម្រិតខ្សោយខ្លាំងណាស់ ។ ចាំបាច់ត្រូវកត់សម្គាល់ថា ហេតុអ្វីបានជាកើតមានករណីនេះ បើទោះបីជាកម្ពុជាបានផ្ដោតការយកចិត្តទុកដាក់ចំពោះការអប់រំកាលពីអតីតកាល និងបើទោះបីជាមាន

កំណើនខ្ពស់ខ្លាំងដែលជាក្តីសង្ឃឹមរបស់ប្រទេសក្នុងការបង្កើនកម្រិតអប់រំនេះ។ ជាការពិត កំណើននេះជាកត្តាមួយក្នុងចំណោមកត្តានានាជាច្រើនដែលរួមចំណែកដល់ការបង្កឱ្យមានការខ្វះខាតការអប់រំលើថ្នាក់បឋមសិក្សាសម្រាប់កម្លាំងពលកម្មជាច្រើន។ អត្រាកំណើនសេដ្ឋកិច្ចខ្ពស់ភ្លាមៗ មានន័យថាឱកាសការងារមានច្រើនហើយគួបផ្សំជាមួយនឹងប្រជាជនជាយុវវ័យដែលច្រើនធ្វើការបំលាស់លំនៅអាចឱ្យពួកគេបំលាស់ទីទៅកាន់តំបន់ទីក្រុងដែលសម្បូរការងារធ្វើច្រើន។ នេះមានន័យថា កត្តាលើកទឹកចិត្តឱ្យបន្តការសិក្សាមានតិចតួចដោយសារតែពួកគេអាចទទួលបានការងារធ្វើដោយមិនចាំបាច់មានការអប់រំខ្ពស់។ ការចូលរួមចំណែកដល់កត្តានេះ ជាការពិត គឺថាដោយសារកត្តារួមផ្សំដូចជារោងចក្រ និងឧស្សាហកម្មដែលបានកំពុងផ្តល់ការងារជាច្រើនមិនបានទាមទារឱ្យមានការសិក្សាខ្ពស់ទេ។ ជាថ្មីម្តងទៀត កំណើនសេដ្ឋកិច្ចបានដាក់កម្រិតកំណត់ដល់កត្តាលើកទឹកចិត្តឱ្យបន្តការសិក្សាទៅវិញ។ ជាចុងក្រោយ ដោយសារតែចក្ខុវិស័យអប់រំរយៈពេលខ្លីរបស់រដ្ឋាភិបាលមានកិច្ចប្រឹងប្រែងមួយចំនួនប៉ុណ្ណោះត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់និន្នាការនេះ ហើយគោល-នយោបាយអប់រំបានផ្តោតការយកចិត្តទុកដាក់ជាខ្លាំងលើក្តីបារម្ភរយៈពេលខ្លីនៃការបង្កើនការអប់រំ កម្រិតបឋមសិក្សា ដែលកំពុងកើនឡើង។ ដូច្នេះ បច្ចុប្បន្នរដ្ឋាភិបាលត្រូវប្រឈមនឹងអត្រាបោះបង់ការសិក្សាខ្ពស់ ហើយមិនអាចបញ្ឈប់បានទេ បើទោះបីជាការអប់រំបឋមសិក្សាមានកម្រិតខ្ពស់យ៉ាងណាក៏ដោយ។ ទាំងនេះបង្កើតឱ្យមានស្ថានភាពមួយដែលធ្វើឱ្យសិស្សបោះបង់ការសិក្សាខកខានក្នុងការទទួលបានការអប់រំមូលដ្ឋានដែលការសិក្សានាពេលអនាគតត្រូវការការអភិវឌ្ឍ ហើយបង្កការរារាំងដល់សិស្សបោះបង់ការសិក្សាទាំងនោះមិនឱ្យលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេព្រមទាំងមិនបានរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងមិនបានទទួលផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចដែលកាន់តែធំជាងមុន។

*“រូបភាពដ៏ធំនៃកម្រិតអប់រំនៅកម្ពុជាកំពុងមានភាពប្រសើរឡើងសម្រាប់មនុស្សជំនាន់ថ្មី។”*

### *ប្រអប់ ២.១ : ការបញ្ឈប់សិស្សបោះបង់ការសិក្សារតាមរយៈកម្មវិធីឧបត្ថម្ភប្រាក់*

និរន្តរភាពនៃការសិក្សា ជាបញ្ហាមួយដែលទទួលបានការយកចិត្តទុកជាខ្លាំង ដោយចាត់ទុកថាលទ្ធភាពរបស់ប្រទេសមួយដើម្បីទាក់ទាញ និងបន្តទទួលបានសិស្សជាក្តីបារម្ភដ៏ចំបង មួយសម្រាប់ភាពរឹងមាំនៃប្រព័ន្ធអប់រំរបស់ប្រទេសមួយ។ ក្នុងប្រទេសឥណ្ឌូនេស៊ី អនិរន្តរភាពនៃការសិក្សាត្រូវបានដោះស្រាយមួយផ្នែកដោយគម្រោងមួយ ហៅថាកម្មវិធីជាតិសម្រាប់ការផ្តល់អំណាចដល់សហគមន៍ (PNPM)។ កម្មវិធីនេះ ជាគំនិតផ្តួចផ្តើមដ៏ចម្បងមួយដែលកំពុងក្តោបក្តាប់ដំណាក់កាលកណ្តាលក្នុងគោលនយោបាយ និងអនុវត្តការកាត់បន្ថយភាពក្រីក្រនៅប្រទេសឥណ្ឌូនេស៊ី។ គំនិតផ្តួចផ្តើមនេះ បានស្រូបយកម្ចាស់ជំនួយជាច្រើនរួចមកហើយព្រមទាំងទទួលបានការយកចិត្តទុកដាក់ និងការផ្តល់មូលនិធិរបស់រដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។

ឧទាហរណ៍ កម្មវិធី PNPM Mandiri ធ្វើការលើការអប់រំមូលដ្ឋានដោយផ្តល់ជំនួយជាកញ្ចប់ដល់សាលាចំនួន ៤.000 នៅទូទាំងប្រទេសដើម្បីលើកកម្ពស់គុណភាពនៃដំណើរការរៀន និងបង្រៀនដោយប្រើប្រាស់អភិក្រមគ្រប់គ្រងតាមសាលា។ គោលបំណងរបស់កម្មវិធីនេះ រួមមាន លើកកម្ពស់ការចុះឈ្មោះចូលរៀនរបស់សិស្សក្រីក្រ លើកកម្ពស់ និរន្តរភាព និងលទ្ធផលនៃការសិក្សាសម្រាប់ការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ និងគាំទ្រដល់ការគ្រប់គ្រងសាលាតាមគោលការណ៍វិមជ្ឈការ និងការចូលរួមរបស់សហគមន៍។

នៅដំណាក់កាលដំបូងកម្មវិធីឧបត្ថម្ភប្រាក់ដោយភ្ជាប់លក្ខខណ្ឌ ជាកម្មវិធីលើកកម្ពស់និរន្តរភាពនៃការសិក្សា និងការចូលសាលាមានប្រជាប្រិយភាពក្នុងប្រទេសជាច្រើននៅអាមេរិកឡាទីនក្នុងអំឡុងទសវត្សរ៍១៩៩0 ព្រមទាំងបានចាប់ផ្តើមរីករាលដាលដល់ប្រទេសនៅអាស៊ី ដូចជាឥណ្ឌូនេស៊ី និងហ្វីលីពីន។ កម្មវិធីទាំងនេះជាការឧបត្ថម្ភប្រាក់ដល់គ្រួសារក្រីក្រដោយមានលក្ខខណ្ឌឱ្យបញ្ជូនកូនទៅសាលា និងពិនិត្យសុខភាពនៅមណ្ឌលសុខភាពជាទៀងទាត់។

យុទ្ធសាស្ត្រសម្រាប់ការឧបត្ថម្ភប្រាក់ដល់គ្រួសារក្រីក្រ គឺមិនមែនជាយុទ្ធសាស្ត្រថ្មីទេ ហើយត្រូវបានប្រើប្រាស់ជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ តាមរយៈការភ្ជាប់ការឧបត្ថម្ភប្រាក់ ឧទាហរណ៍ជាមួយនឹងអត្រាចូលសាលារៀនការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្សត្រូវបានសម្រេចឡើងដែលអាចជួយឱ្យមានការកាត់បន្ថយភាពក្រីក្ររយៈពេលខ្លី និងរយៈពេលវែង។ ទោះបីជាយ៉ាងណាក៏មានការទាមទារឱ្យយកចិត្តទុកដាក់ជា ពិសេសលើបញ្ហាជាច្រើនដែលស្ថិតក្នុងគម្រោងឧបត្ថម្ភប្រាក់ផងដែរ។ បញ្ហាទាំងនេះរួមមាន បញ្ហាកំណត់គោលដៅគឺសម្រាប់ការជ្រើសរើស "អ្នកដែលសាកសមនឹងទទួលផល" តម្រូវការនីតិវិធីរដ្ឋបាលប្រកបដោយប្រសិទ្ធភាព ការវាយតម្លៃពិតប្រាកដចំពោះសមត្ថភាពស្ថាប័នសមត្ថភាព និងការរៀបចំខ្លួនក្នុងការដាក់ចេញនូវយន្តការបែបនេះ (ទីភ្នាក់ងារពិនិត្យតាមដានវាយតម្លៃ និងគណនេយ្យភាពមានសមត្ថភាពខ្លាំង) ព្រមទាំងកង្វល់ទាក់ទិននឹងនិរន្តរភាពសារពើពន្ធរយៈពេលវែង។ ដូច្នេះទោះបីជាការយកចិត្តទុកដាក់ទាំងនេះជាឧបករណ៍ដ៏មានប្រយោជន៍ក្នុងការជួយឱ្យអត្រាបោះ បង់ការសិក្សាធ្លាក់ចុះ និងបង្កើនសេវាសង្គមក្តីក៏រដ្ឋាភិបាលត្រូវតែប្រុងប្រយ័ត្នក្នុងការអនុវត្ត និងរៀនសូត្របទពិសោធន៍របស់ប្រទេសផ្សេងៗ ដូចជាប្រទេសតណ្ហនេស៊ីជាដើម។

* ការផ្សព្វផ្សាយកម្មវិធីទាំងនេះនៅអាស៊ី កំពុងបង្កឱ្យមានផលវិបាកមួយចំនួនក្នុងចំណោមផ្នែកសង្គមស៊ីវិលធំៗ។ ផលវិបាកមួយនៃជម្លោះសាមញ្ញដែលប្រើប្រាស់ប្រឆាំងទៅនឹង CCTs គឺ ១) ប្រជាជនមិនចង់បានការផ្តល់ជាសាច់ប្រាក់ដល់ ពួកគេនោះទេ ប៉ុន្តែត្រូវការការងារដ៏សមរម្យ ២) លក្ខខណ្ឌមិនអនុវត្តបាននៅពេលសេវាផ្តល់ការអប់រំ និងសេវាសុខភាព ខ្វះគុណភាព ឬបរិមាណ ឬខ្វះទាំងគុណភាព និងបរិមាណ។

## ២.៤ គុណភាព និងកម្រិតនៃការអប់រំ និងការបណ្តុះបណ្តាល

រូបភាពដ៏ធំនៃកម្រិតអប់រំនៅកម្ពុជាកំពុងមានភាពប្រសើរឡើងសម្រាប់មនុស្សជំនាន់ថ្មី បើទោះបីជាមានការខ្វះខាតការអប់រំជាខ្លាំងសម្រាប់មនុស្សជំនាន់មុនបន្តលាបពណ៌អាក្រក់លើរូបភាពនៃកម្រិតអប់រំរួមបច្ចុប្បន្នក៏ដោយ។ ទំនោរនេះជាការកើនឡើងនៃការអប់រំ បើទោះបីជាការអង្កេត CSES ឆ្នាំ២០០៧ បានបង្ហាញថា កំណើនគិតជាភាគរយនៃប្រជាជនពេញវ័យ (អាយុពី ១៨ឆ្នាំឡើង) ដែលមិនបានចូលសាលាទាល់តែសោះមានចំនួនលើសពី ឆ្នាំ២០០៤ ហើយអត្រាចូលសាលារបស់មនុស្សពេញវ័យទាំងអស់សម្រាប់ការបញ្ចប់ការអប់រំពីកម្រិតបឋមដល់ឧត្តមសិក្សាធ្លាក់ចុះក្តី (រូប ២.៨)។

*រូប ២.៨ : ការបញ្ចប់ការអប់រំរបស់ប្រជាជនពេញវ័យ (អាយុចាប់ពី ១៨ឆ្នាំ) ឆ្នាំ២០០៤-២០០៧*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០c។ ទំព័រទី ៤៣។*

ទោះជាមាននិន្នាការនេះក្តី ក៏និន្នាការរយៈពេលមួយទសវត្សរ៍ចុងក្រោយ ឬរយៈពេលលើសពីនេះ បានបង្កើនកម្រិតអប់រំដែលប្រជាជនបានទទួល។ អ្វីដែលគួរកត់សម្គាល់នោះគឺជាកំណើនជាលំដាប់នៃអត្រាចុះឈ្មោះចូលរៀនក្នុង រយៈពេលមួយទសវត្សរ៍ចុងក្រោយនេះដែលបង្ហាញឱ្យឃើញថា យ៉ាងហោចណាស់យុវជនអាចទទួលបានការអប់រំត្រឹមកម្រិតមួយចំនួន។ ក្នុងការអប់រំបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ការចុះឈ្មោះចូលរៀន បន្តកើនឡើងចាប់ពី ឆ្នាំ១៩៩៧ រហូតដល់ ឆ្នាំ២០០៧។ ទិន្នន័យការអប់រំឧត្តមសិក្សាមុនឆ្នាំ២០០៧មិនមាននោះទេ (មើលរូបទី២.៩) ។ការបង្កើតមូលដ្ឋានការអប់រំគឺជាគន្លឹះមួយសម្រាប់ការលើកម្ពស់ជំនាញកម្លាំងពលកម្មទៅថ្ងៃមុខ ដូច្នេះហើយនិន្នាការទាំងនេះនឹងកើតមាននៅថ្ងៃអនាគត។

*រូប ២.៩ : អត្រាចុះឈ្មោះចូលរៀនពិត (%)*




*ប្រភព: ធនាគារពិភពលោក ឆ្នាំ២០០៩ ។ ការរក្សានិរន្តរភាពកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សក្នុងបរិស្ថានប្រកបដោយភាពប្រឈម : អនុស្សារណៈយោគយល់សេដ្ឋកិច្ចប្រទេសកម្ពុជា។ អង្គភាពកាត់បន្ថយភាពក្រីក្រ និងវិស័យគ្រប់គ្រងសេដ្ឋកិច្ចប្រចាំតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ទំព័រទី ៣៨។*

លើសពីនេះទៀតប្រការដ៏មានសារៈសំខាន់នោះគឺថា កំណើនការអប់រំទាំងនេះហាក់ដូចជាមានឥទ្ធិពលជាវិជ្ជមានចំពោះផលិតភាព។ កំណើនផលិតភាពនេះ អាចចូលចំណែកមួយយ៉ាងច្រើនដល់កំណើនផលិតផលក្នុងស្រុកសរុបចាប់ពី ឆ្នាំ២០០១ ដល់ ឆ្នាំ២០០៨។ ក្នុងរយៈពេល ៧ឆ្នាំចុងក្រោយនេះផលិតផលក្នុងស្រុកសរុប (GDP) ជាក់ស្តែងសម្រាប់មនុស្សម្នាក់បានកើនឡើង ៥៩ភាគរយ ហើយ ៩៨ភាគរយ នៃ GDP នេះបានមកពីកំណើនផលិតភាព។ ស្របពេលដែលកំណើនផលិតភាពប្រហែលជាងពាក់កណ្តាលទទួលបានពីបំលាស់ទីរបស់កម្មករទៅក្នុងវិស័យដែលកាន់តែមានផលិតភាពច្រើនជាងមុន ហើយកំណើនពាក់កណ្តាលទៀតទទួលបានពីកំណើនផលិតភាពក្នុងវិស័យផ្ទាល់ទាំងនោះ (មើលរូបទី ២.១០)។ ការអប់រំអាចដើរតួនាទីដ៏ចម្បងក្នុងកំណើនផលិភាពនេះ ហើយកិច្ចប្រឹងប្រែងនានាគួរផ្តោតការយកចិត្តទុកដាក់លើការ អប់រំនេះនៅថ្ងៃអនាគត។

*"... កម្លាំងពលកម្មក្នុងប្រទេស បានឆ្លងកាត់ការប្រែប្រួលយ៉ាងខ្លាំង ក្នុងទសវត្សរ៍ចុងក្រោយនេះ ។"*

*រូប ២.១០ : សមាសធាតុកំណើនផលិតផលក្នុងស្រុកសរុបឆ្នាំ២០០១-២០០៨*

| | % |
|---|---|
| កំណើន ផ.ស.ស ក្នុងមនុស្សម្នាក់ | 58.9 |
| ការរួមចំណែកក្នុងការបង្កើតការងារ | -6.3 |
| ការរួមចំណែកក្នុងកំណើនពលកម្ម | 8.3 |
| វិភាគទាននៃកំណើនផលិតកម្ម | 98.0 |
| | |
| កំណើនទិន្នផលផលិតកម្មសម្រាប់កម្មករមួយនាក់ | 54.3 |
| វិភាគទាននៃបំលាស់ប្តូរការងារ | 47.4 |
| វិភាគទាននៃកំណើនផលិតកម្ម | 52.6 |

*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០ ។ ការផ្តល់ជំនាញសម្រាប់សមភាព និងកំណើន : ការរៀបចំយុវជនកម្ពុជាសម្រាប់ទីផ្សារការងារ ។ នាយកដ្ឋានអភិវឌ្ឍន៍មនុស្សប្រចាំតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ទំព័រទី ៣៧ ។*

## ២.៥ និន្នាការការងារ

ដើម្បីស្វែងយល់ឱ្យកាន់តែប្រសើរថែមទៀតអំពីឥទ្ធិពលនៃការអភិវឌ្ឍមូលធនមនុស្សមកលើកំណើនសេដ្ឋកិច្ចកម្ពុជា ប្រការចាំបាច់ត្រូវសម្លឹងមើលនិន្នាការការងារ និងឥទ្ធិពលនៃកម្រិតអប់រំកាន់តែខ្ពស់ដែលកើតមានលើលទ្ធភាពមានការងារធ្វើរបស់កម្លាំងពលកម្ម ។

ទីមួយ សំខាន់ត្រូវកត់សម្គាល់ថា កម្លាំងពលកម្មក្នុងប្រទេស បានឆ្លងកាត់ការប្រែប្រួលយ៉ាងខ្លាំងក្នុងទសវត្សរ៍ចុងក្រោយនេះ ។ ឧទាហរណ៍ អត្រាផលធៀបរវាងការងាររបស់កម្លាំងពលកម្មជាមួយនឹងប្រជាជនសរុបមានការប្រែប្រួលយ៉ាងច្រើន ។ ក្នុងឆ្នាំ១៩៩៨ ការចូលរួមក្នុងកម្លាំងពលកម្មសរុបមាន ៧៧ ភាគរយ ក្នុងនោះប្រុសមាន ៨១,២ ភាគរយ ហើយស្រីមាន ៧៣.៥ភាគរយ ។ ត្រឹម ឆ្នាំ២០០៨ ភាគរយនៃការចូលរួមក្នុងកម្លាំងពលកម្មមានការប្រែប្រួលដោយកើនដល់ ៧៨,៣ ភាគរយ ក្នុងនោះប្រុសមាន ៨០,៨ ភាគរយ និងស្រីមាន ៧៦ ភាគរយ ។ ដោយសារតែអត្រាចូលរួមកម្លាំងពលកម្មរបស់បុរសច្រើនមានការធ្លាក់ចុះនៅពេលយុវជនបន្តការសិក្សា ឬសិក្សារយៈពេលយូរ ។ ប្រការគួរឱ្យចាប់អារម្មណ៍គឺថា ភាគរយនៃបុរសដែលបម្រើការងារបានធ្លាក់ចុះមកត្រឹមតែ ០,៤ ភាគរយ ប៉ុណ្ណោះក្នុងរយៈពេល ១០ឆ្នាំនេះ ។ ម្យ៉ាងវិញទៀតកំណើន ០៣ ភាគរយនៃនិយោជិតជាស្ត្រីបានមកពីកត្តាផ្សេងៗ ដូចជាកំណើនឱកាសការងារសម្រាប់ស្ត្រីកំណើនការទទួលនិយោជិតជាស្ត្រីក្នុងសង្គម ឬកំណើនឆន្ទៈរបស់ក្រុមហ៊ុនក្នុងការជួលនិយោជិតជាស្ត្រីឱ្យចូលបម្រើការងារ ។ ទោះបីជាយ៉ាងណាការងារភាគច្រើន ជាការងារស្ថិតក្នុងវិស័យកាត់ដេរ (ជំពូក ៣) ដូច្នេះកំណើននេះមិនអាចបញ្ជាក់ថាស្ត្រីបានទទួលការអប់រំកម្រិតខ្ពស់នោះទេ (រូប ២.១១ និងតារាង ២.៣) ។

*រូប ២.១១ : អត្រាចូលរួមក្នុងកម្លាំងពលកម្ម សម្រាប់និយោជិតអាយុចាប់ពី ១៥ ឆ្នាំ (គិតជា%)*




*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។និន្នាការការងារ និងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ១៩ ។*

**តារាង ២.៣ : កម្លាំងពលកម្ម និងអត្រាចូលរួមក្នុងកម្លាំងពលកម្ម ( % )**

| ក្រុមអាយុ | 1998 | 2000 | 2001 | 2008 |
|---|---|---|---|---|
| **ទាំងពីរភេទ** | **5,038,382** | **5,278,956** | **6,007,406** | **6,955,640** |
| 15-24 | 1,268,671 | 1,649,728 | 2,085,526 | 1,796,785 |
| 25-34 | 1,489,631 | 1,220,233 | 1,291,148 | 1,759,531 |
| 35-44 | 1,080,119 | 1,128,499 | 1,196,778 | 1,476,944 |
| 45-54 | 651,613 | 782,125 | 851,614 | 1,048,172 |
| 55-64 | 364,127 | 371,270 | 422,115 | 562,728 |
| 65+ | 184,221 | 127,101 | 160,225 | 311,480 |
| **ប្រុស** | **2,443,580** | **2,529,755** | **2,878,362** | **3,396,449** |
| 15-24 | 572,862 | 751,707 | 983,914 | 858,191 |
| 25-34 | 769,547 | 602,908 | 647,397 | 897,833 |
| 35-44 | 516,781 | 551,771 | 565,881 | 740,697 |
| 45-54 | 301,151 | 350,470 | 371,657 | 483,132 |
| 55-64 | 180,297 | 195,479 | 210,971 | 259,140 |
| 65+ | 102,942 | 77,420 | 98,542 | 157,456 |
| **ស្រី** | **2,594,802** | **2,749,201** | **3,129,044** | **3,559,191** |
| 15-24 | 695,809 | 898,021 | 1,101,612 | 938,594 |
| 25-34 | 720,084 | 617,325 | 643,751 | 861,698 |
| 35-44 | 563,338 | 576,728 | 630,897 | 736,247 |
| 45-54 | 350,462 | 431,655 | 479,957 | 565,040 |
| 55-64 | 183,830 | 175,791 | 211,144 | 303,588 |
| 65+ | 81,279 | 49,681 | 61,683 | 154,024 |
| **Labour force to population (%)** | | | | |
| **ទាំងពីរភេទ** | **77.0** | **78.4** | **83.3** | **78.3** |
| 15-24 | 60.7 | 67.7 | 76.7 | 60.1 |
| 25-34 | 89.1 | 90.5 | 93.6 | 91.3 |
| 35-44 | 90.5 | 92.9 | 94.5 | 93.3 |
| 45-54 | 89.5 | 90.6 | 93.1 | 91.6 |
| 55-64 | 78.8 | 77.3 | 80.6 | 84.1 |
| 65+ | 46.6 | 32.6 | 39.0 | 54.5 |
| **ប្រុស** | **81.2** | **80.8** | **85.1** | **80.8** |
| 15-24 | 56.3 | 63.3 | 73.6 | 57.1 |
| 25-34 | 96.5 | 96.9 | 97.3 | 95.4 |
| 35-44 | 98.4 | 97.8 | 98.8 | 98.4 |
| 45-54 | 97.9 | 96.6 | 98.0 | 97.6 |
| 55-64 | 91.6 | 86.7 | 88.7 | 92.9 |
| 65+ | 62.6 | 46.0 | 52.1 | 68.4 |
| **ស្រី** | **73.5** | **76.3** | **81.6** | **76.0** |
| 15-24 | 64.9 | 71.8 | 79.7 | 63.2 |
| 25-34 | 82.4 | 85.0 | 90.2 | 87.4 |
| 35-44 | 84.3 | 88.7 | 91.0 | 88.7 |
| 45-54 | 83.3 | 86.3 | 89.6 | 87.0 |
| 55-64 | 69.3 | 68.9 | 73.9 | 77.9 |
| 65+ | 35.2 | 22.4 | 27.8 | 45.2 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។និន្នាការការងារនិងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ៦៧ ។*

*"...ផលិតភាពពលកម្មបានកើនឡើងស្ទើរគ្រប់ឧស្សាហកម្មទាំងអស់ក្នុងទសវត្សរ៍ចុងក្រោយនេះ ។"*

និន្នាការសំខាន់ទី២ គឺកំណើនកម្រិតអប់រំក្នុងកម្លាំងពលកម្ម ។ ដោយសារការបង្កើនការវិនិយោគរបស់រដ្ឋាភិបាលលើការអប់រំបឋមសិក្សាទើបមានលទ្ធផលរំពឹងទុកបែបនេះ ។ ភាគរយប្រជាជនទាំងពីរភេទអាយុលើសពី ១៥ឆ្នាំ ដែលចូលរួមក្នុងកម្លាំងពលកម្ម និងជាអនក្ខរជនបានធ្លាក់ចុះមកត្រឹម ៨,៦ភាគរយ ពោលគឺចុះពី ៣២,៩ភាគរយ ក្នុងឆ្នាំ ១៩៩៨ មកនៅត្រឹម ២៤,៣ភាគរយ ។ ការធ្លាក់ចុះនៃចំនួនស្ត្រីមានច្រើនជាង គឺធ្លាក់ចុះពី ៤៣,៧ភាគរយ មកនៅត្រឹម ៣០,៩ភាគរយ ក្នុងរយៈពេលដូចគ្នា ។ តួលេខរួមនៃនិយោជិតដែលបានរៀនចប់បឋមសិក្សាបានកើនឡើងពី ១៧,២ ភាគរយ ដល់ ២៣ភាគរយ (ហើយក្នុងចំណោមនិយោជិតមានអាយុចាប់ពី ១៥ ដល់ ២៤ឆ្នាំ តួលេខនេះ បានកើនពី ២០ភាគរយ ដល់ ៣១,៨ភាគរយ) ។

ជាថ្មីម្តងទៀតនិន្នាការនេះឆ្លុះបញ្ចាំងឱ្យឃើញអំពីការតាំងចិត្ត ដើម្បីបង្កើនការអប់រំបឋមសិក្សាក្នុងចំណោមប្រជាជនទាំងអស់ ។ ទោះជាយ៉ាងណាបញ្ហាប្រឈមដែលប្រជាជនត្រូវប្រឈមដោះស្រាយក្នុងការធានាសម្រេចកម្រិតអប់រំឱ្យបានខ្ពស់ជាងបឋមសិក្សា ក៏បានស្តែងឱ្យឃើញច្បាស់ថា ចាប់ពី ឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៨ ភាគរយនៃប្រជាជនដែលបានបញ្ចប់ការអប់រំមធ្យមសិក្សា បានធ្លាក់ចុះពី ២,៤ភាគរយ មកនៅត្រឹម ១,៩ភាគរយ (ទោះជាអត្រាបញ្ចប់ការអប់រំមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៧,២ភាគរយ ដល់ ១៣,៧ភាគរយ (តារាង ២.៤) ។

*តារាង ២.៤: ការងារបែងចែកតាមកម្រិតនៃការបញ្ចប់ការអប់រំ និងតាមភេទ*

| | 1998 | | | 2008 | | |
|---|---|---|---|---|---|---|
| | 15+ | 15-24 | 25+ | 15+ | 15-24 | 25+ |
| **ទាំពីរភេទ** | **4,773,488** | **1,114,189** | **3,659,299** | **6,841,272** | **1,736,962** | **5,104,310** |
| អនក្ខរជន | 1,572,554 | 327,833 | 1,244,721 | 1,662,308 | 306,298 | 1,356,010 |
| មិនបានរៀនចប់ថ្នាក់ | 51,946 | 6,973 | 44,973 | 133,984 | 28,869 | 105,115 |
| មិនបានរៀនចប់បឋមសិក្សា | 1,842,486 | 478,600 | 1,363,886 | 2,359,867 | 577,267 | 1,782,600 |
| រៀនចប់បឋមសិក្សា | 820,636 | 223,286 | 597,350 | 1,570,424 | 552,197 | 1,018,227 |
| មធ្យមសិក្សាបឋមភូមិ | 344,767 | 59,327 | 285,440 | 936,296 | 242,463 | 693,833 |
| មធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រទុតិយភូមិ | 115,337 | 15,949 | 99,388 | 99,822 | 18,190 | 81,632 |
| រៀនហួសកម្រិតមធ្យមសិក្សា | 19,239 | 1,470 | 17,769 | 74,000 | 11,127 | 62,873 |
| ផ្សេងៗ | 3,236 | 205 | 3,031 | 4,162 | 450 | 3,712 |
| មិនព័តិមាន | 3,287 | 546 | 2,741 | 409 | 101 | 308 |
| **ប្រុស** | **2,330,301** | **502,134** | **1,828,167** | **3,345,926** | **828,975** | **2,516,951** |
| អនក្ខរជន | 506,046 | 121,841 | 384,205 | 580,503 | 129,799 | 450,704 |
| មិនបានរៀនចប់ថ្នាក់ | 29,352 | 3,491 | 25,861 | 60,585 | 14,125 | 46,460 |
| មិនបានរៀនចប់បឋមសិក្សា | 920,636 | 211,624 | 709,012 | 1,098,498 | 271,227 | 827,271 |
| រៀនចប់បឋមសិក្សា | 533,801 | 117,681 | 416,120 | 881,102 | 264,014 | 617,088 |
| មធ្យមសិក្សាបឋមភូមិ | 234,948 | 35,642 | 199,306 | 600,436 | 134,125 | 466,311 |
| មធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រទុតិយភូមិ | 85,611 | 10,332 | 75,279 | 67,691 | 9,433 | 58,258 |
| រៀនហួសកម្រិតមធ្យមសិក្សា | 15,117 | 1,015 | 14,102 | 53,856 | 5,877 | 47,979 |
| ផ្សេងៗ | 2,653 | 171 | 2,482 | 2,986 | 304 | 2,682 |
| មិនព័តិមាន | 2,137 | 337 | 1,800 | 269 | 71 | 198 |
| **ស្រី** | **2,443,187** | **612,055** | **1,831,132** | **3,495,346** | **907,987** | **2,587,359** |
| អនក្ខរជន | 1,066,508 | 205,992 | 860,516 | 1,081,805 | 176,499 | 905,306 |

*តារាង ២.៤: ការងារបែងចែកតាមកម្រិតនៃការបញ្ចប់ការអប់រំ និងតាមភេទ(ត)*

| | 1998 | | | 2008 | | |
|---|---|---|---|---|---|---|
| | 15+ | 15-24 | 25+ | 15+ | 15-24 | 25+ |
| | Percentage | | | | | |
| មិនបានរៀនចប់ថ្នាក់ | 22,594 | 3,482 | 19,112 | 73,399 | 14,744 | 58,655 |
| មិនបានរៀនចប់បឋមសិក្សា | 921,850 | 266,976 | 654,874 | 1,261,369 | 306,040 | 955,329 |
| រៀនចប់បឋមសិក្សា | 286,835 | 105,605 | 181,230 | 689,322 | 288,183 | 401,139 |
| មធ្យមសិក្សាបឋមភូមិ | 109,819 | 23,685 | 86,134 | 335,860 | 108,338 | 227,522 |
| មធ្យមសិក្សាទុតិយភូមិ/ សញ្ញាបត្រទុតិយភូមិ | 29,726 | 5,617 | 24,109 | 32,131 | 8,757 | 23,374 |
| រៀនហួសកម្រិតមធ្យមសិក្សា | 4,122 | 455 | 3,667 | 20,144 | 5,250 | 14,894 |
| ផ្សេងៗ | 583 | 34 | 549 | 1,176 | 146 | 1,030 |
| មិនព័ត៌មាន | 1,150 | 209 | 941 | 140 | 30 | 110 |
| **ទាំពីរភេទ** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** |
| អនក្ខរជន | 32.9 | 29.4 | 34.0 | 24.3 | 17.6 | 26.6 |
| មិនបានរៀនចប់ថ្នាក់ | 1.1 | 0.6 | 1.2 | 2.0 | 1.7 | 2.1 |
| មិនបានរៀនចប់បឋមសិក្សា | 38.6 | 43.0 | 37.3 | 34.5 | 33.2 | 34.9 |
| រៀនចប់បឋមសិក្សា | 17.2 | 20.0 | 16.3 | 23.0 | 31.8 | 19.9 |
| មធ្យមសិក្សាបឋមភូមិ | 7.2 | 5.3 | 7.8 | 13.7 | 14.0 | 13.6 |
| មធ្យមសិក្សាទុតិយភូមិ/ សញ្ញាបត្រទុតិយភូមិ | 2.4 | 1.4 | 2.7 | 1.5 | 1.0 | 1.6 |
| រៀនហួសកម្រិតមធ្យមសិក្សា | 0.4 | 0.1 | 0.5 | 1.1 | 0.6 | 1.2 |
| ផ្សេងៗ | 0.1 | 0.0 | 0.1 | 0.1 | 0.0 | 0.1 |
| មិនព័ត៌មាន | 0.1 | 0.0 | 0.1 | 0.0 | 0.0 | 0.0 |
| **ប្រុស** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** |
| អនក្ខរជន | 21.7 | 24.3 | 21.0 | 17.3 | 15.7 | 17.9 |
| មិនបានរៀនចប់ថ្នាក់ | 1.3 | 0.7 | 1.4 | 1.8 | 1.7 | 1.8 |
| មិនបានរៀនចប់បឋមសិក្សា | 39.5 | 42.1 | 38.8 | 32.8 | 32.7 | 32.9 |
| រៀនចប់បឋមសិក្សា | 22.9 | 23.4 | 22.8 | 26.3 | 31.8 | 24.5 |
| មធ្យមសិក្សាបឋមភូមិ | 10.1 | 7.1 | 10.9 | 17.9 | 16.2 | 18.5 |
| មធ្យមសិក្សាទុតិយភូមិ/ សញ្ញាបត្រទុតិយភូមិ | 3.7 | 2.1 | 4.1 | 2.0 | 1.1 | 2.3 |
| រៀនហួសកម្រិតមធ្យមសិក្សា | 0.6 | 0.2 | 0.8 | 1.6 | 0.7 | 1.9 |
| ផ្សេងៗ | 0.1 | 0.0 | 0.1 | 0.1 | 0.0 | 0.1 |
| មិនព័ត៌មាន | 0.1 | 0.1 | 0.1 | 0.0 | 0.0 | 0.0 |
| **ស្រី** | **100.0** | **100.0** | **100.0** | **100.0** | **100.0** | **100.0** |
| អនក្ខរជន | 43.7 | 33.7 | 47.0 | 30.9 | 19.4 | 35.0 |
| មិនបានរៀនចប់ថ្នាក់ | 0.9 | 0.6 | 1.0 | 2.1 | 1.6 | 2.3 |
| មិនបានរៀនចប់បឋមសិក្សា | 37.7 | 43.6 | 35.8 | 36.1 | 33.7 | 36.9 |
| រៀនចប់បឋមសិក្សា | 11.7 | 17.3 | 9.9 | 19.7 | 31.7 | 15.5 |
| មធ្យមសិក្សាបឋមភូមិ | 4.5 | 3.9 | 4.7 | 9.6 | 11.9 | 8.8 |
| មធ្យមសិក្សាទុតិយភូមិ/ សញ្ញាបត្រទុតិយភូមិ | 1.2 | 0.9 | 1.3 | 0.9 | 1.0 | 0.9 |
| រៀនហួសកម្រិតមធ្យមសិក្សា | 0.2 | 0.1 | 0.2 | 0.6 | 0.6 | 0.6 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| មិនព័ត៌មាន | 0.0 | 0.0 | 0.1 | 0.0 | 0.0 | 0.0 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។ទិន្នាការការងារនិងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ៦៧ ។*

ដោយបានដឹងថា កម្រិតអប់រំបានកើនឡើង តើមាននរណាម្នាក់អាចមើលឃើញឥទ្ធិពលដ៏គួរឱ្យកត់សម្គាល់នៃកំណើនកម្រិតអប់រំមានលើសមាសធាតុប្រមូលផ្តុំនៃសេដ្ឋកិច្ច? ដោយមានកត្តាជាច្រើននាំឱ្យមានការប្រែប្រួលសមាសធាតុប្រមូលផ្តុំនៃសេដ្ឋកិច្ចរបស់ប្រទេសមួយក៏មានការប្រែប្រួលគួរឱ្យកត់សម្គាល់ជាច្រើនកើតឡើងដែរ។ ទី១ ទាក់ទងនឹងការផ្លាស់ប្តូរសមត្ថភាពជំនាញ ក៏ការមានការប្រែប្រួលការងារតាមវិស័យផងដែរ។ សមាមាត្រប្រជាជនតាមវិស័យចម្បងទីមួយ (កសិកម្ម នេសាទ និង និស្សារណកម្ម) បានធ្លាក់ចុះក្នុងទសវត្សរ៍ចុងក្រោយនេះ ខណៈពេលដែលសមាមាត្រវិស័យចម្បងទីពីរ (ផលិតកម្ម) និង វិស័យទីបី (សេវា និងការលក់ដូរ) បានកើនឡើង។ ក្នុងឆ្នាំ១៩៩៨ ការងារក្នុងវិស័យ ទីមួយមាន ៧៧ ភាគរយ ទីពីរ មាន ៤,២ ភាគរយ និងទីបីមាន ១៨,៣ ភាគរយ សម្រាប់ទាំងប្រុស និងស្រីដែលមានអាយុចាប់ពី ១៥ឆ្នាំឡើង ហើយក្នុង ឆ្នាំ២០០៨ តួលេខនេះ មាន ៧២ ភាគរយ ៨,៦ភាគរយ និង ១៩,៣ភាគរយ (តារាង ២.៥)។ នេះមានន័យថា ប្រភពការងារកំពុងធ្វើពិពិធកម្មយ៉ាងឃឹត ហើយនិយោជិតកំពុងអភិវឌ្ឍជំនាញរបស់ខ្លួនលើសពីកម្រិតជំនាញមូលដ្ឋានដែលត្រូវការសម្រាប់វិស័យទីមួយទៅទៀត។

*តារាង ២.៥: ការងារតាមវិស័យ អាយុ និងតាមភេទ*

| | 1998 | | | 2008 | | |
|---|---|---|---|---|---|---|
| | 15+ | 15-24 | 25+ | 15+ | 15-24 | 25+ |
| **ទាំពីរភេទ** | **4,773,488** | **1,114,189** | **3,659,299** | **6,841,272** | **1,736,962** | **5,104,310** |
| វិស័យទី ១ | 77.0 | 79.1 | 76.4 | 72.1 | 68.6 | 73.3 |
| វិស័យទី ២ | 4.2 | 6.5 | 3.5 | 8.6 | 15.5 | 6.2 |
| វិស័យទី ៣ | 18.3 | 13.7 | 19.7 | 19.3 | 15.9 | 20.5 |
| គ្មានរបាយការណ៍ | 0.4 | 0.7 | 0.4 | 0.0 | 0.0 | 0.0 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| **ប្រុស** | **2,330,301** | **502,134** | **1,828,167** | **3,345,926** | **828,975** | **2,516,951** |
| វិស័យទី ១ | 71.1 | 75.7 | 69.8 | 69.2 | 70.6 | 68.7 |
| វិស័យទី ២ | 5.0 | 6.2 | 4.7 | 8.1 | 11.9 | 6.9 |
| វិស័យទី ៣ | 23.4 | 17.2 | 25.1 | 22.7 | 17.5 | 24.4 |
| គ្មានរបាយការណ៍ | 0.5 | 0.8 | 0.4 | 0.0 | 0.0 | 0.0 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |
| **ស្រី** | **2,443,187** | **612,055** | **1,831,132** | **3,495,346** | **907,987** | **2,587,359** |
| វិស័យទី ១ | 82.7 | 81.9 | 82.9 | 75.0 | 66.9 | 77.8 |
| វិស័យទី ២ | 3.5 | 6.8 | 2.4 | 9.0 | 18.7 | 5.6 |
| វិស័យទី ៣ | 13.5 | 10.8 | 14.3 | 16.0 | 14.4 | 16.6 |
| គ្មានរបាយការណ៍ | 0.4 | 0.5 | 0.4 | 0.0 | 0.0 | 0.0 |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៩។ ក្រសួងផែនការនៃប្រទេសកម្ពុជា។ និន្នាការការងារ និងសង្គមក្នុងប្រទេសកម្ពុជា ឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ២៣។*

ទីពីរ ការប្រែប្រួលនេះក៏ឃើញមានការបែកខ្ញែកនៃការវិនិយោគចាប់ពី ឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៨ ផងដែរ។ នៅ ឆ្នាំ២០០៦ កសិកម្មមានគម្រោង ២០ ស្មើនឹង ៣៥,៧ភាគរយ នៃតម្រូវការងារ ហើយក្នុងឆ្នាំ២០០៨វិស័យនេះមានគម្រោងតែ ៥ ស្មើនឹង ២,៨ភាគរយនៃតម្រូវការការងារ។ផ្ទុយមកវិញ ឧស្សាហកម្មមានគម្រោង ៦១ ស្មើនឹង ៥៧,១ ភាគរយ ហើយសេវាកម្មមាន ១៧គម្រោង ស្មើនឹង ៧,២ភាគរយ ក្នុងឆ្នាំ២០០៦ ហើយក្នុងឆ្នាំ២០០៨ ឧស្សាហកម្មមាន ៦៦គម្រោង ស្មើនឹង ៥៧,៤ភាគរយ ហើយសេវាកម្មមាន ២៧គម្រោង ស្មើនឹង ៣៩,៨ភាគរយ (តារាង ២.៦)។

*តារាង ២.៦: តម្រូវការការងារតាមរយៈគម្រោងវិនិយោគ គិតតាមវិស័យ ឆ្នាំ២០០៨*

| វិស័យ | ពលកម្ម | % | ចំនួនគំរោង |
|---|---|---|---|
| **2008** | | | |
| កសិកម្ម | 4,729 | 2.8 | 5 |
| ឧស្សាហកម្ម | 98,583 | 57.4 | 66 |
| សេវាកម្ម | 68,398 | 39.8 | 27 |
| សរុប | 171,710 | 100.0 | 98 |
| **2007** | | | |
| កសិកម្ម | 2,198 | 3.7 | 3 |
| ស្សាហកម្ម | 52,761 | 89.0 | 36 |
| សេវាកម្ម | 4,355 | 7.3 | 8 |
| សរុប | 59,314 | 100.0 | 47 |
| **2006** | | | |
| កសិកម្ម | 68,367 | 35.7 | 20 |
| ស្សាហកម្ម | 109,344 | 57.1 | 61 |
| សេវាកម្ម | 13,851 | 7.2 | 17 |
| សរុប | 191,562 | 100.0 | 98 |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។និន្នាការការងារនិងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការផលិតពលកម្មអន្តរជាតិ ទំព័រទី ៣០ ។*

ទីបី ឃើញមានការធ្លាក់ចុះនៃប្រភេទការងារដែលងាយគ្រោះថ្នាក់ ។ ការងារដែលងាយបង្កគ្រោះថ្នាក់អាចឱ្យនិយមន័យថា ជាអ្នកបម្រើការក្នុងគ្រួសារគ្មានប្រាក់ឈ្នួល និងអ្នករកស៊ីខ្លួនឯង ។ បើទោះបីជាសមាមាត្រនេះនៅតែមានកម្រិតខ្ពស់ខ្លាំងក៏ដោយ ហើយបើទោះជាតួលេខសរុបបានកើនឡើងពីឆ្នាំ១៩៩៨ ក៏ដោយក៏នៅត្រឹម ឆ្នាំ២០០៨ តួលេខសមាមាត្រនេះបានធ្លាក់ចុះពី ៨៦,៨ភាគរយ មកនៅត្រឹម ៨២,៥ ភាគរយ (ហើយតួលេខនៃចំនួនស្ត្រីបានធ្លាក់ចុះខ្លាំង គឺធ្លាក់ចុះពី ៩៣,១ភាគរយ មកនៅត្រឹម ៨៥,៩ ភាគរយ) (រូប ២.១២) ។

*រូប ២.១២ : សមាមាត្រនៃការងារដែលងាយបង្កគ្រោះថ្នាក់ក្នុងចំណោមការងារទាំងអស់*




*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។និន្នាការការងារនិងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ២៥ ។*

ទីបួន ឃើញមានការកើនឡើងនៃ ផលិតភាពពលកម្មស្ទើរគ្រប់ឧស្សាហកម្មទាំងអស់ ក្នុងទសវត្សរ៍ចុងក្រោយនេះ ។ ដូចបានកំណត់និយមន័យតាមតម្លៃបន្ថែមសម្រាប់មនុស្សម្នាក់ដែលមានការងារធ្វើកំណើន

ផលិតភាពពលកម្មនេះធ្វើឱ្យមានការភ្ញាក់ផ្អើលសម្បើមណាស់ គឺក្នុងវិស័យរុករករ៉ែ និងរ៉ែត្បូងដោយមានកំណើនប្រចាំឆ្នាំ ១៩.៤ភាគរយ (យោងតាមតម្លៃប្តូរប្រាក់រៀល) វិស័យបន្ទាប់ គឺហិរញ្ញវត្ថុ និងសេវាកម្មផ្សេងទៀតដែលមានកំណើន ៨.៦ភាគរយ ហើយវិស័យដឹកជញ្ជូន និងទូរគមនាគមន៍មានកំណើន ៥.៨ ភាគរយ ។ វិស័យតែមួយគត់ដែលផលិតភាពបានធ្លាក់ចុះ គឺ អគ្គិសនី ឧស្ម័ន និងទឹកដោយកំណើនប្រចាំឆ្នាំជាមធ្យមមានចំនួន -៣.៩ភាគរយ (តារាង ២.៧) ។ ទោះជាយ៉ាងណា ប្រការសំខាន់ដែលត្រូវកត់សម្គាល់គឺថា ទោះជាមានកំណើនផលិតភាពនេះក៏ដោយក៏កម្រិតលទ្ធផលរួមរបស់និយោជិតមានកម្រិតទាបដែរ បើធៀបនឹងប្រទេសផ្សេងៗទៀតនៅតំបន់អាស៊ាន (រូប ២.១៣) ។ ប្រសិនបើកម្ពុជានៅតែចង់ប្រកួតប្រជែងជាមួយប្រទេសផ្សេងទៀតនៅតំបន់អាស៊ាន ជាពិសេសបន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចសកលលោក កម្ពុជាត្រូវតែបន្តលើកកម្ពស់ផលិតភាពនិយោជិតរបស់ខ្លួនបន្តទៀត ។

*តារាង ២.៧ : ផលិតភាពការងារ តាមឧស្សាហកម្ម (តម្លៃបន្ថែមសម្រាប់មនុស្សម្នាក់ ដែលមានការងារធ្វើតម្លៃទឹកប្រាក់នៅឆ្នាំ២000)*

| វិស័យ | 1998 | | 2008 | | កំណើនមធ្យមប្រចាំឆ្នាំ (%) | |
|---|---|---|---|---|---|---|
| | (ពាន់ រៀល) | ដុល្លា | (ពាន់ រៀល) | ដុល្លា | រៀល | ដុល្លា |
| **សរុប** | **2,380** | **631** | **4190** | **1030** | **5.7%** | **4.9%** |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1,294 | 343 | 1,537 | 378 | 1.7% | 1.0% |
| វិស័យរ៉ែ និងរ៉ែមាស | 3,637 | 964 | 25,341 | 6,229 | 19.4% | 18.7% |
| ផលិតកម្ម | 9,735 | 2,580 | 13,339 | 3,279 | 3.1% | 2.4% |
| អគ្គិសនី ហ្គាស និងទឹក | 15,849 | 4,200 | 10,695 | 2,629 | -3.9% | -4.7% |
| សំណង់ | 9,337 | 2,474 | 13,553 | 3,332 | 3.7% | 3.0% |
| ពាណិជ្ជកម្ម | 4,156 | 1,101 | 4,598 | 1,130 | 1.0% | 0.3% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 24,378 | 6,460 | 22,068 | 5,425 | -1.0% | -1.7% |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | 6,042 | 1,601 | 10,824 | 2,661 | 5.8% | 5.1% |
| ហិរញ្ញវត្ថុ និងសេវកម្ម | 4,292 | 1,137 | 10,096 | 2,482 | 8.6% | 7.8% |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។ទិន្នាការការងារនិងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ៣១ ។*

*រូប ២.១៣ : លទ្ធផលក្នុងនិយោជិតម្នាក់នៅតាមប្រទេសក្នុងតំបន់អាស៊ាន ឆ្នាំ២០០៨ (តម្លៃទឹកប្រាក់ដុល្លារអាមេរិកនៅឆ្នាំ២០០៩)*




*ប្រភព : វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩ ។ក្រសួងផែនការនៃប្រទេសកម្ពុជា ។ទិន្នាការការងារនិងសង្គមក្នុងប្រទេសកម្ពុជាឆ្នាំ២០១០ អង្គការពលកម្មអន្តរជាតិ ទំព័រទី ៣១ ។*

## ២.៦ អសមត្ថភាព រវាងការអប់រំ និងការងារ

ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពសំខាន់បំផុតនៃការអប់រំគឺថា ការអប់រំបង្កើតកម្លាំងពលកម្មដែលមានជំនាញ និងអាចបង្កើតផលចំណេញបានពីការអប់រំសម្រាប់កម្លាំងពលកម្មវិញ ហើយសម្រាប់សេដ្ឋកិច្ចរួមនៅពេលកម្លាំងពលកម្មចាប់ផ្តើមចូលបម្រើការងារ។ ដូច្នេះ ប្រព័ន្ធអប់រំត្រូវតែសម្របសម្រួលទៅតាមតម្រូវការ និងតាមភាពចាំបាច់របស់សេដ្ឋកិច្ច ហើយត្រូវធ្វើការដើម្បីឈានទៅបំពាក់បំប៉នសិស្សឱ្យត្រៀមខ្លួនជាស្រេចសម្រាប់ជីវិតសេដ្ឋកិច្ច។ បញ្ហាមួយចំណោមបញ្ហាចម្បងៗក្នុងប្រទេសកម្ពុជាគឺថាពុំឃើញមានផលចំណេញទទួលបានពីការអប់រំ និង/ឬពីការបណ្តុះបណ្តាលសម្រាប់ប្រជាជន ទូទៅពាក់ព័ន្ធនឹងការងារ និងការអភិវឌ្ឍន៍ការងារ។ ក្នុងប្រទេសកម្ពុជាអត្រាគ្មានការងារធ្វើដែលបានចុះក្នុងបញ្ជី ពិតជាមានកម្រិតទាបខ្លាំង (ក្នុងឆ្នាំ២០០៧ មាន០,៩ភាគរយ ប្រសិនបើយោងតាមនិយមន័យច្បាស់លាស់ មួយដែលមានន័យថាជាណិកម្មជន និងអ្នកកំពុងស្វែងរកការងារធ្វើយ៉ាងសកម្ម និងមាន ៣,៨២ ភាគរយ យោងតាមនិយមន័យមិនតឹងរ៉ឹងមួយដែលមានន័យថា ជានិកម្មជន និងអ្នកដែលអាចធ្វើការងារបាន ប៉ុន្តែមិនសកម្មក្នុងការស្វែងរកការងារធ្វើ) (ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិឆ្នាំ២០០៩)។ ទោះជាយ៉ាងណាអត្រាគ្មានការងារធ្វើទាបនេះកើតមានឡើង ដោយសារមនុស្សជាច្រើននាក់ ត្រូវបង្ខំចិត្តស្វែងរកប្រភេទការងារធ្វើប្រសើរជាងការគ្មានប្រាក់ចំណូលដោយសារតែការខ្វះខាតគម្រោងជំនួយសម្រាប់អ្នកអត់ការងារធ្វើផងដែរ។ បើទោះបីជាយ៉ាងនេះក្តី បញ្ហានៅតែកើតមានព្រោះជាញឹកញាប់ គុណភាព និងប្រាក់បៀវត្សរ៍ការងារមានកម្រិតទាប ឬដោយសារគុណវុឌ្ឍិសិក្សារបស់បុគ្គលម្នាក់ៗមិនគ្រប់គ្រាន់។ ដោយសារហេតុ ឬផលនៃបញ្ហាកើតឡើងដោយសារកម្រិតអប់រំទាប គឺដូចជារឿងមេមាន់ និងពងមាន់យ៉ាងដូច្នោះដែរ។ កត្តាដ៏សំខាន់គឺថាផលចំណេញទាបទទួលបានពីការអប់រំជាឧបសគ្គមួយក្នុងការផ្តល់លាភការឱ្យសិស្សបន្តការសិក្សាឱ្យខ្ពស់ជាងមម្រិតអប់រំមូលដ្ឋាន។

> *"ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពសំខាន់បំផុតនៃការអប់រំគឺថា ការអប់រំបង្កើតកម្លាំងពលកម្មដែលមានជំនាញ និងអាចបង្កើតផលចំណេញបានពីការអប់រំសម្រាប់កម្លាំងពលកម្មវិញ។"*

ធម្មជាតិនៃសេដ្ឋកិច្ចរបស់កម្ពុជា មិនបានជួយសម្រួលដល់និន្នាការនេះទេ។ សមាមាត្រនៃកម្លាំងពលកម្មដ៏ធំកំពុងបម្រើការងារក្នុងសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធជាស្វ័យអាជីវករ ឬបម្រើការក្នុងគ្រួសារមិនទទួលបានប្រាក់ឈ្នួល (តារាង ២.៨)។

*តារាង ២.៨: ស្ថានភាពការងាររបស់ប្រជាជន អាយុចាប់ពី ១០ឆ្នាំ ឆ្នាំ២០០៤និង២០០៧ (ភាគរយ)*

| | ២០០៤ | | | ២០០៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| និយោជិត | ២០ | ២៣,៣ | ១៦,៦ | ២៣,៣ | ២៦,៩ | ១៩,៥ |
| និយោជក | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,០៣ |
| អ្នករកស៊ីខ្លួនឯង | ៣៤,៤ | ៣៩,៧ | ២៨,៨ | ៣៥,៨ | ៤៣,១ | ២៨,២ |
| អ្នកបម្រើការក្នុងគ្រួសារគ្មានប្រាក់ឈ្នួល | ៤៣,៣ | ៣៤,៨ | ៥២ | ៤០,៧ | ២៩,៨ | ៥២,៣ |

*ប្រភព: ឧត្តមក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចឆ្នាំ២០០៩។ទីផ្សារការងារនិងការងារសម្រាប់យុវជន។ឧត្តមក្រុមប្រឹក្សាជាតិ: ស្ថិតក្រោមការណែនាំពីអង្គការ UNDP/IFA ទំព័រទី ១២។*

ថ្វីបើមានកំណើនមែនវិស័យការងារក្នុងប្រព័ន្ធនៅតែតូចចង្អៀតណាស់ព្រោះវិស័យនេះអាចស្រូបយកនិយោជិតបានតែ ២៣,៣ភាគរយ នៃកម្លាំងពលកម្មរួម។ កត្តារារាំងមួយទៀត គឺការខ្វះប្រព័ន្ធដំឡើង

ប្រាក់កម្រៃមធ្យមផ្អែកតាមកំណើននៃកម្រិតឆ្នាំសិក្សា។ ការពិតដែលត្រូវពិចារណាគឺថា ប្រាក់ចំណូលជាមធ្យមនៅកម្ពុជានៅតិចតួចណាស់ ដូច្នេះ ការដំឡើងប្រាក់កម្រៃប្រចាំខែសម្រាប់ចំនួនឆ្នាំបន្ថែមនៃការបន្តការសិក្សាផ្តល់នូវលាភចិត្តតិចតួចណាស់សម្រាប់បន្តការអប់រំ។ ក្នុងឆ្នាំ២០០៧ ប្រាក់កម្រៃមធ្យមសម្រាប់មនុស្សម្នាក់ដែលបានរៀនចប់បឋមសិក្សា គឺបានតែ ៥៨,១៤ ដុល្លារក្នុងមួយខែ ហើយប្រាក់កម្រៃមធ្យមសម្រាប់មនុស្សម្នាក់ដែលបានរៀនចប់មធ្យមសិក្សាមបឋមភូមិ គឺបានត្រឹមតែ ៦១,៣៥ ដុល្លារ ក្នុងមួយខែ។ សម្រាប់ការសិក្សាបន្ថែមបន្ត៣ឆ្នាំទៀតមនុស្សម្នាក់មានសង្ឃឹមទទួលបានកំណើនប្រាក់កម្រៃ ត្រឹមតែ ៣,២១ដុល្លារប៉ុណ្ណោះក្នុងមួយខែ។ ភាពខុសគ្នារវាងការអប់រំមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ មានកម្រិតកាន់តែទាបទៅទៀត ពោលគឺអាចកើនប្រាក់កម្រៃបានត្រឹមតែ ០,៨២ ដុល្លារប៉ុណ្ណោះដែលធ្វើឱ្យប្រាក់កម្រៃក្នុងមួយខែ កើនដល់ ៦២,១៧ដុល្លារប៉ុណ្ណោះសម្រាប់ការសិក្សាបន្តបន្ថែម ៣ឆ្នាំទៀត។ កំណើននៃប្រាក់កម្រៃសម្រាប់អ្នកដែលមាន វិញ្ញាបនបត្រ ឬសញ្ញាបត្រនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ/បច្ចេកទេស ឬកម្រិតសាកលវិទ្យាល័យគឺមានច្រើន ប៉ុន្តែកម្រិតកំណើននោះមិនមានលាភចិត្តដើម្បីឱ្យមនុស្សបន្តការសិក្សាដល់កម្រិតនោះទេ (តារាង ២.៩)។

*តារាង ២.៩: ប្រាក់ចំណូលជាមធ្យមតាមកម្រិតអប់រំសម្រាប់យុវជន (ដុល្លារ/ខែ)*

| កម្រិតអប់រំ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| គ្មាន | - | - | ៣៧,៥ |
| បឋមសិក្សា | ៥៦,២៣ | ៥៩,៨២ | ៥៨,១៤ |
| មធ្យមសិក្សាមបឋមភូមិ | ៦១,៧០ | ៦១,០៣ | ៦១,៣៥ |
| មធ្យមសិក្សាមបឋមទុតិយភូមិ | ៥៩,១៩ | ៦៥,៧៩ | ៦២,១៧ |
| សាលាបច្ចេកទេស/វិជ្ជាជីវៈ | ១៤៩,៧១ | ៧៥,៦០ | ៩៥,០២ |
| មហាវិទ្យាល័យ | ១៣៩,៥៣ | ១០៣,០២ | ១១៥,៥៥ |
| បរិញ្ញាបត្រ | ១៥០,៧៨ | ១២៩,២៩ | ១៤១,៧៤ |

*ប្រភព : ការអង្កេតសង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០៧។*

ដូចមានបង្ហាញក្នុងរូប២.១៤ ការបង្កើនចំនួនឆ្នាំនៃការបន្តការសិក្សាហាក់ដូចជាមិនមានឥទ្ធិពលខ្លាំងទៅលើប្រាក់ចំណូលទេ នៅពេលរៀបចំតួលេខតាមលំដាប់ក្រុមដែលមានទ្រព្យសម្បត្តិ ពោលគឺមានតួលេខខុសគ្នាខ្លាំងសម្រាប់បុគ្គលដែលមានទ្រព្យសម្បត្តិបំផុត ១០ ភាគរយ នៅកម្ពុជា។ រហូតដល់ ៧៥ភាគរយ ហើយក្នុងករណីខ្លះរហូតដល់ពី ៧៥-៩០ ភាគរយ កំណើនប្រាក់កម្រៃគិតតាមម៉ោង មិនកើនឡើងខ្លាំងទេ។ ប្រការសំខាន់ផងដែរគឺថា បើទោះបីជាប្រាក់ឈ្នួលបានស្ទុះងើបជាលំដាប់ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះដោយសារកំណើនសេដ្ឋកិច្ចគួរឱ្យចាប់អារម្មណ៍របស់ប្រទេសក៏ដោយក៏កំណើននេះពុំមានរបាយស្មើគ្នាដែរ។ ប្រាក់ចំណូលរបស់ប្រជាជនក្នុងក្រុមអ្នកមានលំដាប់កំពូល ១០ភាគរយ ទាក់ទងនឹងរបាយទ្រព្យសម្បត្តិបានកើនឡើង ៩០ភាគរយ ខណៈពេលដែលប្រាក់ចំណូលរបស់ប្រជាជនជាអ្នកក្របំផុត ១០ ភាគរយ បានងើបឡើងត្រឹមតែ ៤០ភាគរយប៉ុណ្ណោះ (World Bank ២០០៩)។

*រូប ២.១៤ : ការអប់រំធ្វើឱ្យប្រាក់ចំណូលមានភាពខុសគ្នាបន្តិចបន្តួច លើកលែងក្រុមអ្នកមានបំផុត*




*ប្រភព: ធនាគារពិភពលោកឆ្នាំ២០០៩ ។ ទំព័រទី ៣១ ។*

## ២.៧ សាកលវិទ្យាល័យ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

និយាយរួមទាំងការអប់រំនៅសាកលវិទ្យាល័យ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ស្ថានភាពនៃប្រព័ន្ធអប់រំឧត្តមសិក្សានៅកម្ពុជាមានការគ្រប់គ្រងតាមយន្តការខុសៗគ្នា មានគុណភាពខ្សោយ និងមានអត្រាចុះឈ្មោះចូលរៀនទាប ។ កត្តាទាំងបីនេះកំពុងរារាំងយ៉ាងខ្លាំងដល់ការអភិវឌ្ឍការអប់រំឧត្តមសិក្សា និងរារាំងដល់ការជំរុញឱ្យមូលធនមនុស្សក្នុងប្រទេសកាន់តែមានសមត្ថភាពទាបថែមទៀត ហើយកត្តាទាំងបីនេះ គួរជាចំណុចយកចិត្តទុកដាក់សម្រាប់ការចាប់ផ្តើម ធ្វើកំណែទម្រង់វិស័យអប់រំនេះ ។

ជាដំបូង យើងអាចក្រឡេកមើលស្ថានភាពនៃប្រព័ន្ធសាកលវិទ្យាល័យនៅកម្ពុជា ។ ជាសរុបមានក្រសួង និងទីភ្នាក់ងារទាំងអស់ចំនួន ១១ ដែលផ្តល់សេវាអប់រំឧត្តមសិក្សា និងមានសិទ្ធិប្រើប្រាស់ថវិកាសាធារណៈសម្រាប់វិស័យអប់រំរបស់កម្ពុជា ។ ក្រសួងពីរក្នុងចំណោមក្រសួងសំខាន់បំផុតទទួលខុសត្រូវលើការអប់រំឧត្តមសិក្សា គឺក្រសួងអប់រំ យុវជន និងកីឡា (អយក) និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយបើទោះជាច្បាប់ស្តីពីការអប់រំរបស់កម្ពុជាចែងថា ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកការអប់រំចំណេះទូទៅ អប់រំឧត្តមសិក្សា និងអប់រំវិជ្ជាជីវៈក៏ដោយក៏ច្បាប់នេះមិនផ្តល់ការពន្យល់ អំពីតួនាទីរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ ។ ការមិនមានសេចក្តីពន្យល់នេះបានបង្កឱ្យមានការប្រទាញប្រទង់ការងារគ្នាយ៉ាងខ្លាំង ហើយបង្កការលំបាកខ្លាំងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរឱ្យបានខ្លាំងក្លា ។ ដូច្នេះជាការងាយយល់ណាស់បញ្ហានេះបង្កការលំបាកដល់រដ្ឋាភិបាលក្នុងការសម្របសម្រួលប្រព័ន្ធអប់រំឧត្តមសិក្សា ។ ការលំបាកទាំងនេះមានពន្យល់លម្អិតក្នុងជំពូក៤ ។

ប្រការគួរឱ្យកត់សម្គាល់នោះគឺថា គ្រឹះស្ថានអប់រំឧត្តមសិក្សាភាគច្រើនស្ថិតក្នុងទីក្រុងភ្នំពេញ ប៉ុន្តែក៏មានឃើញ ចំនួនគ្រឹះស្ថានរីកដុះដាលច្រើននៅតាមខេត្តដែរភាគច្រើនជាគ្រឹះស្ថានឯកជន (រូប ២.១៥) ។

> *“...គ្រឹះស្ថានអប់រំឧត្តមសិក្សាភាគច្រើនស្ថិតក្នុងទីក្រុងភ្នំពេញ ប៉ុន្តែក៏មានឃើញ ចំនួនគ្រឹះស្ថានរីកដុះដាលច្រើននៅតាមខេត្តដែរភាគច្រើនជាគ្រឹះស្ថានឯកជន”*

*រូប ២.១៥ : ទីតាំងសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា*




*ប្រភព : ក្រសួងអប់រំ យុវជន និងកីឡា ។*

ទាក់ទងទៅនឹងវិស័យនៃមុខវិជ្ជាសិក្សាដែលពេញនិយមសម្រាប់និស្សិតសាកលវិទ្យានៅកម្ពុជា វិស័យពេញនិយមរួមបំផុត គឺភាសាបរទេស (ជាមធ្យមមាន១៤,៥ភាគរយ ចាប់ពីឆ្នាំ២០០៦-២០០៩) មុខវិជ្ជាគ្រប់គ្រង (១៣,១ភាគរយ) គណនេយ្យ (១០,៤ភាគរយ) និងវិទ្យាសាស្រ្តកុំព្យូទ័រ (៧,៩ភាគរយ) (តារាង ២.១០) ។ ទោះជាបីយ៉ាងណាប្រការគួរឱ្យកត់សម្គាល់គឺថា ក្នុងករណីជាច្រើននិស្សិតដែលបានចប់ពីសាកលវិទ្យាល័យទទួលបានសញ្ញាបត្រផ្នែកគ្រប់គ្រងគណនេយ្យ និងរដ្ឋបាលធុរកិច្ចឃើញខ្វះជំនាញសំខាន់ៗ និងបទពិសោធជាក់ស្តែងសម្រាប់យកទៅបម្រើការងារក្នុងវិស័យដែលត្រូវស្របនឹងជំនាញ និងគុណវុឌ្ឍិសិក្សារបស់និស្សិត ។ បញ្ហានេះបង្ហាញឱ្យឃើញបញ្ហាបច្ចេកទេសយ៉ាងធំធេងដែលសាកល វិទ្យាល័យកំពុងប្រឈមយ៉ាងខ្លាំង គឺការបង្កើតគ្រឹះស្ថានសិក្សាដែលធ្វើឱ្យការអប់រំកាន់តែមានតម្លៃ ហើយបំពេញតម្រូវការនៃទីផ្សារ ។ ក្នុងតារាង ២.១០ បង្ហាញថាអត្រាសិស្សចុះឈ្មោះចូលរៀនសរុបមានកម្រិតទាបណាស់ ។ បញ្ហាតម្រូវការទាំងនេះនឹងត្រូវបានលើកឡើងនៅផ្នែកខាងក្រោយនៃជំពូកនេះ ។ បញ្ហាទាំងនេះ គឺនិយាយអំពីការជម្នះលើបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាទាំងនេះ និងអំពីការធានាថា និស្សិតកំពុងទទួលការសិក្សាក្នុងប្រព័ន្ធអប់រំនេះនឹងមានសារប្រយោជន៍សម្រាប់លើកកម្ពស់កម្រិតនៃមូលធនមនុស្សនៅកម្ពុជា ។

*តារាង ២.១០: ការចុះឈ្មោះចូលរៀនសរុបតាមមុខវិជ្ជាសិក្សានៅគ្រឹះស្ថានអប់រំឧត្តមសិក្សាសាធារណៈ និងឯកជន*

| មុខវិជ្ជាសិក្សា | ២០០៦-២០០៧ | % | ២០០៧-២០០៨ | % | ២០០៦-២០០៩ | % | រយៈពេល ៣ឆ្នាំ ជាមធ្យម (%) (២០០៧-២០០៩) |
|---|---|---|---|---|---|---|---|
| គណិតវិទ្យា គីមីវិទ្យា រូបវិទ្យា ជីវវិទ្យា | ១.៦១៩ | ១៨% | ២.៥៦២ | ២.៣% | ៣.០៧៣ | ២,២% | ២,១% |
| ឆ្នាំសិក្សាមូលដ្ឋាន | ២.០៣៨ | ២,២% | ៤.៧០៧ | ៤,៣% | ៤,៥៦១ | ៣,៣% | ៣,៣% |
| វិទ្យាសាស្ត្រកុំព្យូទ័រ | ៨.១៤៩ | ៨,៨% | ៨.៧៦៩ | ៨,០% | ៩.៥២៣ | ៦,៩% | ៧.៩% |
| សង្គមវិទ្យា មនុស្ស សាស្ត្រ និងសិល្បៈ | ៥.១៧២ | ៥.៦% | ៦.៩៦៨ | ៦,៣% | ៨.៦៨៥ | ៦,៣% | ៦,១% |
| ទេសចរណ៍ | ៣.៣៦១ | ៣.៦% | ៣.១៩០ | ២.៩% | ២.៩៩៩ | ២,២% | ២,៩% |
| ភាសាបរទេស | ១៥.២០០ | ១៦,៥% | ១៥.៧៩៧ | ១៤,៣% | ១៧,៣៧០ | ១២,៧% | ១៤,៥% |
| ច្បាប់ | ៤.៥៥៤ | ៤,៩% | ៥.៧១៨ | ៥,២% | ៧,៤៨៤ | ៥,៥% | ៥,២% |
| វិទ្យាសាស្ត្រសុខាភិបាល | ៥.៣៤១ | ៥,៨% | ៥.៤១១ | ៤,៩% | ៧.៨១៧ | ៥,៧% | ៥,៥% |
| កសិកម្ម និងអភិវឌ្ឍន៍ជនបទ | ៣.៧៤៥ | ៤,១% | ៣.៧១៣ | ៣,៤% | ៥.២៨៨ | ៣,៩% | ៣,៨% |
| វិស្វកម្ម និងមេកានិក | ២.៨៧០ | ៣.១% | ៣.៣៤៩ | ៣,០% | ៤.៧១៩ | ៣,៤% | ៣,២% |
| សរុប (១) | ៥២.១០៩ | ៥៦% | ៦០.១៨៤ | ៥៥% | ៧១.៥១៩ | ៥២% | ៥៤% |
| **ការគ្រប់គ្រងអាជីវកម្ម** | | | | | | | |
| - អាជីវកម្ម | ៧.២៦៥ | ៧,៩% | ៧.៦៦៩ | ៧,០% | ១០.៨៤៦ | ៧,៩% | ៧,៦% |
| - ទីផ្សារ | ៨៤២ | ០,៩% | ១.៣២៩ | ១,២% | ១.៦១០ | ១,២% | ១,១% |
| - ការគ្រប់គ្រង | ១៣.៤៤៥ | ១៤,៦% | ១៣.៦៥៧ | ១២,៤% | ១៦,៧៦៨ | ១២,២% | ១៣,១% |
| - ធនាគារ និងហិរញ្ញវត្ថុ | ១.១២២ | ១,២% | ១.៥៧៥ | ១,៤% | ៣.៥៤១ | ២,៦% | ១,៧% |
| - សេដ្ឋកិច្ច | ៥.៦៥៣ | ៦.១% | ៦.២៦២ | ៥.៧% | ៨.៧២៩ | ៦,៤% | ៦,១% |
| - គណនេយ្យ | ៨.១៦៣ | ៨,៨% | ១២.១៦១ | ១១,០% | ១៥.៤៨២ | ១១,៣% | ១០,៤% |
| - ហិរញ្ញវត្ថុ | ៣.៧៤១ | ៤,១% | ៧.២៥៣ | ៦,៦% | ៨.៧៥៨ | ៦,៤% | ៥.៧% |
| សរុប (២) | ៤០.២៣១ | ៤៤% | ៤៩.៩០៦ | ៤៥% | ៦៥.៧៣៤ | ៤៨% | ៤៦% |
| សរុបរួម (១)+(២) | ៩២.៣៤០ | ១០០% | ១១០.០៩០ | ១០០% | ១៣៧.២៥៣ | ១០០% | ១០០% |

*ប្រភព : នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៩ និងការគណនារបស់អ្នកនិពន្ធ ។*

និយាយអំពីការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈវិញ យើងឃើញថាបញ្ហាសម្របសម្រួលបញ្ហាគុណភាព និងបញ្ហាការចូលរួម គឺកើតមានដូចគ្នានឹងឧត្តមសិក្សាដែរ ។ បច្ចុប្បន្ន ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់គ្រងដោយក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល ។ ក្រុមប្រឹក្សានេះទទួលខុសត្រូវដោយផ្ទាល់លើការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទទួលខុសត្រូវបង្វែរទិសនៃការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនេះឱ្យ

ទៅជាប្រព័ន្ធមួយឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច។ និយាយអំពីការផ្ដោតការយកចិត្តទុកដាក់របស់ការអប់រំ និងការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ កាលពីមុនអគ្គនាយកដ្ឋានផ្ដោតការយកចិត្តទុកដាក់លើអភិក្រមតម្រូវតាមសមត្ថភាព ដោយផ្ដោតលើការបណ្ដុះបណ្ដាលជំនាញក្នុងគោលបំណងធានាថា បំពាក់ចំណេះដឹង ជំនាញ និងឥរិយាបថដែលបុគ្គលម្នាក់ត្រូវយកទៅប្រើក្នុងការបំពេញការងារ។

ទោះជាមានការយកចិត្តទុកដាក់ និងការសម្របសម្រួលរបស់វិស័យដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាជាតិបណ្ដុះបណ្ដាលក្ដី ក៏វិស័យអប់រំនេះនៅតែប្រឈមនឹងបញ្ហាជាច្រើន ដូចជាការសម្របសម្រួលមូលនិធិ និងការសម្របសម្រួលគ្រឹះស្ថានផ្ដល់សេវាអប់រំ។ ក្នុងចំណោមគ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ៣១៦ នៅកម្ពុជា ក្នុងឆ្នាំសិក្សា២០០៨-២០០៩ មានគ្រឹះស្ថានសាធារណៈចំនួន ៣៨ គ្រប់គ្រងដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានគ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈចំនួន ២១ គ្រប់គ្រងដោយក្រសួងផ្សេងទៀតមានគ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈចំនួន ១៨១ គ្រប់គ្រងដោយឯកជន និងមានគ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈចំនួន ៧៦ គ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ តាមប្រវត្តិសាស្ត្រការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈក៏បានទទួលមូលនិធិពីប្រភពជាច្រើនដែរ ហើយមូលនិធិបានកើនឡើង ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ផ្ដល់ដោយទីភ្នាក់ងារម្ចាស់ជំនួយអន្តរជាតិ ប៉ុន្តែការសម្របសម្រួលជំនួយ រវាងម្ចាស់អំណោយដើម្បីធ្វើឱ្យដំណើរការនេះមានភាពល្អប្រសើរឡើងមានតិចតួចណាស់ ឬពុំមានសោះ (សេចក្ដីលម្អិតក្នុងជំពូក៥)។

ដូចឃើញក្នុងតារាង ២.១១ ការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ នៅកម្ពុជាក៏ប្រឈមនឹងបញ្ហាប្រហាក់ប្រហែលគ្នានឹងការអប់រំនៅសាកលវិទ្យាល័យដែរ ដូចជាអត្រាចុះឈ្មោះចូលរៀនទាប។ ទោះបីជាចំនួនអ្នកចុះឈ្មោះចូលរៀនបានកើនឡើងក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះក៏ដោយ ចំនួននេះនៅមានកម្រិតទាបខ្លាំងបើធៀបនឹងប្រជាជនកម្ពុជាជាង ១៤លាននាក់ ហើយប្រសិនបើមានកំណែទម្រង់ប្រព័ន្ធអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាពចំនួនសិស្សចូលរៀនក្នុងប្រព័ន្ធនេះនឹងកើនឡើងជាក់ជាមិនខានឡើយ។

*តារាង ២.១១: តួលេខសិស្សចុះឈ្មោះចូលរៀននៅឧត្តមសិក្សា និងការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ នៅកម្ពុជា*

| កម្រិតបណ្ដុះបណ្ដាល | ២០០៤-២០០៥ | ២០០៥-២០០៦ | ២០០៦-២០០៧ | ២០០៧-២០០៨ | ២០០៨-២០០៩ | ២០០៩-២០១០ |
|---|---|---|---|---|---|---|
| បរិញ្ញាបត្រ (៤ឆ្នាំ) | ១.០៤១ | ១.១២៦ | ១.១៥៨ | ១.៤០៨ | ១.៣៣០ | ១.៩៨១ |
| បរិញ្ញាបត្ររង (២ឆ្នាំ) | ១.២៣៧ | ២.២០១ | ២.១៧២ | ៣.១៥១ | ២.៩៥៩ | ៣.៣០៨ |
| វិញ្ញាបនបត្របណ្ដុះបណ្ដាល វិជ្ជាជីវៈ ១, ២ និង៣ឆ្នាំ (ថ្នាក់ទី ១០-១២) | ៥៩៤ | ៥០៣ | ១.៥៦២ | ១.៥២៤ | ១.២១៤ | ៧៤៦ |
| វិញ្ញាបនបត្របណ្ដុះបណ្ដាលវិជ្ជាជីវៈ (តិចជាង ១ឆ្នាំ/ក្រៅផ្លូវការ) | ១០.៦៩២ | ១៧.៧២២ | ៦៤.៩៧០ | ៦៧.១៧៨ | ១១៧.២៤០ | ៦៦.៦៩៥ |
| ការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានឯកជន និងអង្គការមិនមែនរដ្ឋាភិបាល | ១៤.៣៣០ | ២៦.៤៣៤ | ១៨.៥០៥ | ៤០.៣៨៧ | ៤៥.៨៨៧ | ៤៧.៤៤៧ |

*ប្រភព : ទិន្នន័យពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជិវៈ។*

## ២.៨ ភាពខុសគ្នាថ្នាក់តំបន់

ប្រការសំខាន់គឺត្រូវមើលកម្ពុជាដោយធៀបនឹងប្រទេសផ្សេងទៀតក្នុងតំបន់ ជាពិសេស ប្រទេសដែលមានសារៈតារនៃកំណើនសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា និងមើលក្នុងវិស័យជាច្រើន ដូចជា ទេសចរណ៍ និងកាត់ដេរកំពុងមានប្រកួតប្រជែងគ្នាដើម្បីទាក់ទាញវិនិយោគិន។ ដោយសារតែកត្តានេះកម្ពុជាត្រូវធានាថា ខ្លួននឹងរីកចម្រើនដោយមិនត្រូវដើរក្រោយប្រទេសជិតខាង ហើយមិនឱ្យបាត់បង់ឱកាសទទួលបានកំណើនសេដ្ឋកិច្ចនៅពេលអនាគតទេ។

*"...កម្ពុជាត្រូវធានាថា ខ្លួននឹងរីកចម្រើនដោយមិនត្រូវដើរក្រោយប្រទេសជិតខាង ហើយមិនឱ្យបាត់បង់ឱកាសទទួលបានកំណើនសេដ្ឋកិច្ចនៅពេលអនាគតទេ។"*

ធៀបនឹងប្រទេសអាស៊ានកម្ពុជាស្ថិតនៅបាតតារាង។ ប្រសិនបើប្រៀបធៀបអត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាកម្ពុជាកំពុងដំណើរការយ៉ាងល្អប្រសើរណាស់។ ប៉ុន្តែប្រសិនបើប្រៀបធៀបអត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សា និងឧត្តមសិក្សាកម្ពុជាស្ថិតនៅលេខក្រោយគេក្នុងកម្រិតអប់រំទាំងពីរ។ អត្រាចុះឈ្មោះចូលរៀនសរុបនៅមធ្យមសិក្សាកម្ពុជានៅពីក្រោយប្រទេសឡាវ ៤ ពិន្ទុ ប៉ុន្តែនៅក្រោយប្រទេសព្រុយណេ ៥៧ពិន្ទុ និងក្រោយប្រទេស ហ្វីលីពីន និងថៃ ៤៣ពិន្ទុ។ ប្រទេសទាំងបីនេះជាប់ចំណាត់ថ្នាក់លេខ ១ លេខ ២ និងលេខ ៣។ នៅថ្នាក់ឧត្តមសិក្សាវិញកម្ពុជាកាន់តែទទួលបានចំណាត់ថ្នាក់អន់បំផុត (តារាង ២.១២)។

*តារាង ២.១២: អត្រាចុះឈ្មោះចូលរៀនសរុបនៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ធៀបនឹងប្រទេសផ្សេងទៀតនៅតំបន់អាស៊ាន*

| | បឋមសិក្សា | | មធ្យមសិក្សា | | ឧត្តមសិក្សា | |
|---|---|---|---|---|---|---|
| ប្រទេស | ២០០០ | ២០០៧ | ២០០០ | ២០០៧ | ២០០០ | ២០០៧ |
| កម្ពុជា | ១០២ | ១១៩ | ១៨ | ៤០ | ២ | ៥ |
| ឥណ្ឌូនេស៊ី | ១០៩ | ១១៧ | ៥៥ | ៧៣ | ១៤ | ១៧ |
| ហ្វីលីពីន | ១១២ | ១០៩ | ៧៧ | ៨៣ | ៣០ | ២៨ |
| ម៉ាឡេស៊ី | ៩៧ | ៩៨ | ៦៥ | ៦៩ | ២៦ | ៣០ |
| សិង្ហបុរី | N/A | N/A | N/A | N/A | N/A | N/A |
| ភូមា | N/A | N/A | N/A | N/A | N/A | N/A |
| ព្រុយណេ | ១១១ | ១០៦ | ៨៥ | ៩៧ | ១៣ | ១៥ |
| ថៃ | ១០៦ | ១០៤ | ៦៧ | ៨៣ | ៣៥ | ៤៨ |
| ឡាវ | ១០៩ | ១១៨ | ៣៥ | ៤៤ | ៣ | ១២ |
| វៀតណាម | ១០៦ | N/A | ៦៥ | N/A | ៩ | N/A |

*ប្រភព: វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ។*

ផលចំណេញទទួលបានពីការអប់រំនៅកម្ពុជា គឺនៅមានកម្រិតទាបជាងប្រទេសផ្សេងទៀតនៅតំបន់អាស៊ាន។ និយាយអំពីផលចំណេញទទួលបានពីការអប់រំបឋមសិក្សា កម្ពុជាមានកម្រិតប្រហាក់ប្រហែលនឹងប្រទេសហ្វីលីពីន ប៉ុន្តែ ចាញ់ប្រទេសឥណ្ឌូនេស៊ី និងថៃ។ ប្រការសំខាន់នោះគឺថា ក្នុងប្រទេសបីផ្សេងទៀត ប្រទេសនីមួយៗបន្តពង្រីកការសិក្សាឱ្យបានកម្រិតខ្ពស់ថែមទៀត។ នេះមានន័យថា ប្រទេសទាំងបីនេះរំពឹងទទួលផលចំណេញបានពីការអប់រំខ្ពស់ជាងមុន ចំណែកកម្ពុជាប្រជាជនមួយភាគធំមិនបន្តការសិក្សាឱ្យខ្ពស់

*"... ការលំបាកផ្នែកតម្រូវការ ដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរលើការអភិវឌ្ឍមូលធនមនុស្ស និងវិស័យអប់រំ ។"*

ថែមទៀតទេ។ ផលចំណេញទទួលបានពីការអប់រំមធ្យមសិក្សាមានកម្រិតប្រហាក់ប្រហែលនឹងប្រទេសហ្វីលីពីន ប៉ុន្តែខុសគ្នាឆ្ងាយពីប្រទេសឥណ្ឌូនេស៊ី និងថៃ។ ដោយឡែកប្រសិនបើពិនិត្យមើលការអប់រំឧត្តមសិក្សាវិញ រូបភាពនេះកាន់តែបារម្ភថែមទៀត គឺកម្ពុជាឋិតនៅក្រោយឆ្ងាយពីប្រទេសបីផ្សេងទៀតណាស់ (រូប ២.១៦) ។ ដូច្នេះ ប្រទេសផ្សេងទៀតហាក់ដូចជាទទួលបានជោគជ័យជាងក្នុងការបំពេញតាមតម្រូវការទីផ្សារការងារដែលអាចលើកទឹកចិត្តដល់បុគ្គលម្នាក់ៗឱ្យបន្តការសិក្សាឱ្យបានច្រើនទៀត ប៉ុន្តែ កម្ពុជាមិនមានការលើកទឹកចិត្តនេះទេ។ ការមិនលើកទឹកចិត្តនេះនឹងបង្កើតឱ្យមានផលប៉ះពាល់អាក្រក់ដល់សិស្សជាច្រើននាក់ដែលជ្រើសរើសការបន្តការសិក្សាសម្រាប់អនាគតបង្កផលអាក្រក់ប៉ះពាល់កម្រិតជំនាញ និងផលិតភាពរបស់កម្លាំងពលកម្ម និងបង្កផលអាក្រក់ប៉ះពាល់ដល់កម្រិតនៃកំណើនសម្រាប់ប្រទេសទាំងមូល ។

*រូប ២.១៦ : ផលចំណេញធៀបនឹងអាយុ និងការអប់រំក្នុងតំបន់អាស៊ីខាងកើត ឆ្នាំ២០០៤*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០ ។ ទំព័រទី ៤៥ ។*

## ២.៩ បញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងសម្រាប់អនាគត

ការពិតនៃប្រព័ន្ធអប់រំកម្ពុជា និងផ្សារពលកម្ម/ផ្សារការងារ បង្កការលំបាកយ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រព័ន្ធអប់រំកម្ពុជា ហើយក៏បង្កការលំបាកដល់កម្រិតមូលធនមនុស្សនៅកម្ពុជាដែរ។ ថ្វីបើមានបញ្ហាប្រឈម និងការលំបាកមួយចំនួនបានលើកឡើងដូចខាងលើក៏ដោយ ប៉ុន្តែនៅផ្នែកនេះមានលើកឡើងយ៉ាងលម្អិត និងពិស្តារថែមទៀតដែរ។

បញ្ហាចម្បងៗដែលប្រព័ន្ធអប់រំរបស់ប្រទេសនេះកំពុងប្រឈម គឺអាចបែងចែងជាពីរផ្នែក ទីមួយតម្រូវការ (ប្រជាជនកម្ពុជាគ្មានឆន្ទៈ ឬគ្មានលទ្ធភាពទៅសាលារៀន) ហើយទីពីរ គឺបញ្ហាផ្គត់ផ្គង់ (បញ្ហាគ្មានលទ្ធភាព ឬគ្មានប្រសិទ្ធផលដែលកើតឡើងដោយសារការបែងចែកធនធានរបស់រដ្ឋាភិបាល និងរបស់ប្រព័ន្ធអប់រំសម្រាប់អប់រំ)។ ការលំបាករបស់ផ្នែកផ្គត់ផ្គង់មានពិណ៌នាលម្អិតក្នុងជំពូក៤។ ក្នុងផ្នែកនេះយើងផ្តោតការយកចិត្តទុកដាក់លើតែការលំបាកផ្នែកតម្រូវការប៉ុណ្ណោះ។

ការលំបាកផ្នែកតម្រូវការ ដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរលើការអភិវឌ្ឍមូលធនមនុស្ស និងវិស័យអប់រំ។ ក្ដីកង្វល់ជាច្រើនរបស់ប្រជាជនកម្ពុជាត្រូវបានសង្ខេបក្នុងតារាង ២.១៣ និយាយអំពីមូលហេតុក្មេងៗ និងយុវជនក្នុងក្រុមអាយុពី ៥ ដល់ ២៤ឆ្នាំ ដែលមិនចូលសាលា។ មូលហេតុចម្បងៗរៀបតាមលំដាប់ចាប់ពីលើកំពូលតារាងរួមមាន "មិនចង់ទៅសាលា" (២៣ភាគរយ) "ត្រូវជួយធ្វើការងារផ្ទះ" (១៦ភាគរយ) និង "ត្រូវជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ" (១៥ភាគរយ)។ តាមការរំពឹងមូលហេតុទាំងនេះបង្ហាញអំពីការលំបាករបស់ផ្នែកតម្រូវការ។

*តារាង ២.១៣: ហេតុផលមិនចូលសាលាក្នុងចំណោមកុមារ និងយុវជនអាយុពី ៥-១៧ឆ្នាំ ដែលមិនបានចូលសាលា គិតតាមភេទ ឆ្នាំ២០០៧ (%)*

| | ស្រី | ប្រុស | សរុប |
|---|---|---|---|
| មិនចង់ទៅសាលា | ២១ | ២៦ | ២៣ |
| រៀនមិនពូកែ | ៦ | ៨ | ៧ |
| គ្មានសាលាសមរម្យ/សាលានៅឆ្ងាយពេក | ៩ | ៧ | ៨ |
| គ្មានគ្រូបង្រៀន /ការផ្គត់ផ្គង់ | ១ | ១ | ១ |
| ចំណាយច្រើនលើការរៀន/គ្មានប្រាក់ | ០ | ០ | ០ |
| ត្រូវជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ | ១៦ | ១៥ | ១៥ |
| ត្រូវជួយធ្វើការងារផ្ទះ | ១៨ | ១៣ | ១៦ |
| ដោយសារពិការភាព | ៦ | ៣ | ៥ |
| ផ្សេងទៀត | ២៥ | ២៧ | ២៦ |
| សរុប | ១០០ | ១០០ | ១០០ |

*ប្រភព : វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៩។ ក្រសួងផែនការនៃប្រទេសកម្ពុជា ទំព័រទី១៤។*

ចម្លើយបិតក្នុងលំដាប់ខ្ពស់បំផុត "មិនចង់ទៅសាលា" មួយផ្នែកអាចកើតឡើងដោយសារការមានការងារធ្វើ និងអត្រាផលចំណេញទទួលបានពីការអប់រំដែលមានសម្រាប់អ្នកបញ្ចប់ការសិក្សាកម្រិតខ្ពស់។ ផលចំណេញនេះត្រូវបានពណ៌នា ខាងលើថា អត្រាប្រាក់ឈ្នួលមិនកើនឡើងខ្លាំងទេ ទោះបីជាមានការអប់រំខ្ពស់ជាងនេះក៏ដោយ ហើយការពិតគឺថា ផលចំណេញទទួលបានពីការអប់រំមិនមានច្រើនប្រសិនបើប្រៀបធៀបជាមួយប្រទេសផ្សេងទៀតក្នុងតំបន់។ នេះជាកត្តាដែលបុគ្គលម្នាក់ៗត្រូវពិចារណាអំពីភាពរឹងមាំផ្នែកសេដ្ឋកិច្ចនៃការបន្តការសិក្សាឱ្យបានខ្ពស់ថែមទៀត។

បញ្ហាដូចបានប្រមូលផ្តុំនេះ ជាតថភាពមួយចំនួននៃកម្លាំងពលកម្មនៅកម្ពុជា។ ទីមួយ ការងារផ្លូវការនៅកម្ពុជាមានកម្រិតទាបខ្លាំង គឺក្នុងចំណោមបុគ្គល ៥នាក់ ដែលមានការងារធ្វើមានបុគ្គលតែម្នាក់គត់ដែលទទួលបានប្រាក់កម្រៃ។ ហើយការងារទាំងនេះមិនបានផ្ដល់ប្រាក់កម្រៃគ្រប់គ្រាន់ទេ ពោលគឺ ២៧ភាគរយនៃអ្នកមានកម្រិតវិជ្ជាជីវៈ អាជីព ១ ភាគ ៤ នៃអ្នកច្បាប់ មន្ត្រី អ្នកគ្រប់គ្រង និងមន្ត្រីរាជការស៊ីវិលមួយចំនួនធំមានការងារលើសពីមួយកន្លែង (អង្គការ ILO : ការលើកកម្ពស់ការងារ)។ ប្រជាជនកម្ពុជាជាច្រើនរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯង ឬធ្វើការងារឱ្យគ្រួសារ (រូប ២.១៥)។ មានន័យថា ពួកគេមិន

ចាប់អារម្មណ៍នឹងការចាប់យក "ជំនាញឱ្យបានខ្ពស់" ដើម្បីអភិវឌ្ឍអាជីពឱ្យចម្រើនទៅមុខទេ។ នេះក៏មានន័យដែរថា (ក្នុងករណីបម្រើការងារឱ្យគ្រួសារ) ជាញឹកញាប់អ្នករកស៊ីខ្លួនឯងមិនមែនជាអ្នកមានជំនាញខ្លាំងសម្រាប់ការងារនោះទេ ប៉ុន្តែ ជាអ្នកប្រកបអាជីវកម្មខ្លួនឯងដែលមានការងារធ្វើ ហើយជាថ្មីម្តងទៀតបានកាត់បន្ថយលាភចិត្តក្នុងការបន្តការបណ្តុះបណ្តាល និងការអប់រំបន្ថែមទៀត។ កម្មករអន្តោប្រវេសន៍ និងកម្មករតាមរដូវកាលក៏មានការលាភចិត្តតិចតួចក្នុងការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល ឬបន្តការអប់រំដែរ ព្រោះការងារមិនឋិតថេរ។ លាភចិត្តក៏មានតិចតួចផងដែរដោយសារតែផលចំណេញរំពឹងទទួលបានពីការអប់រំមានតិចតួច។ ឧទាហរណ៍ ក្នុងឧស្សាហកម្មកាត់ដេរជាវិស័យមួយផ្តល់ ការងារដ៏ច្រើនសន្ធឹកសន្ធាប់សម្រាប់ស្ត្រីកម្ពុជាលាភចិត្តឱ្យបន្តការបណ្តុះបណ្តាលមានកម្រិតតិចតួច ព្រោះឱកាសសម្រាប់ការអភិវឌ្ឍអាជីពឱ្យរីកចម្រើនទៅមុខ ឬការឡើងតំណែងខ្ពស់ជាងនេះតំណែងជាអ្នកគ្រប់គ្រងមានតិចតួច ឬមិនមានសោះ។ ជាចុងក្រោយលាភចិត្តធ្លាក់ចុះ ដោយសារតែកម្រិតមូលដ្ឋានដែលចាប់ផ្តើមពីការបណ្តុះបណ្តាលទាបពេក។ នៅពេលបុគ្គលម្នាក់បានបោះបង់ការសិក្សានៅកម្រិតអប់រំទាបពេកបុគ្គលនោះមិនចេះអាន និងមិនចេះសរសេរ ឬមិនមានជំនាញមូលដ្ឋានដែលចាំបាច់សម្រាប់យកទៅប្រើក្នុងការចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលឱ្យបានជោគជ័យនោះទេ។

ទាក់ទងនឹងចម្លើយថា "ត្រូវជួយធ្វើការងារផ្ទះ" និង "ត្រូវជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ" បង្ហាញឱ្យឃើញពីបញ្ហាក្រីក្រដែលកាត់បន្ថយការចូលរួមក្នុងកម្មវិធីអប់រំ។ ជាញឹកញាប់គ្រួសារជាច្រើនក្រីក្រខ្លាំងដែលមិនអាចបញ្ជូនកូនទៅសាលាបាន ឬកុមារត្រូវនៅផ្ទះ និងធ្វើការងារផ្ទះ ឬមើលប្អូនៗ ខណៈពេលឪពុកម្តាយចេញទៅធ្វើការ។ ដូចគ្នានេះដែរនៅពេលដែលកុមារលូតលាស់ធំបន្តិចពួកគេត្រូវបោះបង់ការសិក្សាដើម្បីជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ។ ដូច្នេះ តម្លៃឱកាសត្រូវបាត់បង់ដើម្បីបន្តការសិក្សាឱ្យបានខ្ពស់មានទំហំធំពេក ហើយផលចំណេញផ្តល់មកវិញមិនច្រើនគ្រប់គ្រាន់ដើម្បីទូទាត់ចំពោះការវិនិយោគលើការសិក្សានោះទេ។ រដ្ឋាភិបាលត្រូវរិះរកមធ្យោបាយដើម្បីជម្នះបញ្ហាក្រីក្រទាំងនេះព្រមទាំងបញ្ចុះបញ្ចូលប្រជាជនកម្ពុជាថា ការបញ្ជូនកូនទៅសាលា និងការឱ្យកូនបន្តការសិក្សា គឺជាការសម្រេចចិត្តដ៏ឆ្លាតវៃក្នុងន័យសេដ្ឋកិច្ច (ប្រអប់ ២.១ ខាងលើស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ការអប់រំ)។

បញ្ហាប្រឈមទាំងនេះ ជាឧបសគ្គដ៏ធំដែលរារាំងផ្លូវឆ្ពោះទៅទទួលបានកម្រិតអប់រំខ្ពស់ជាងនេះនៅកម្ពុជា។ បញ្ហាប្រឈមកើតចេញពីកត្តាផ្គត់ផ្គង់ និងកត្តាតម្រូវការត្រូវតែទទួលបានដំណោះស្រាយមុននឹងកម្ពុជាអាចបង្កើនសន្និធិនៃមូលធនមនុស្សរបស់ខ្លួនឱ្យបានច្រើន។

# ជំពូកទី ៣ : ពិពិធកម្មឧស្សាហកម្ម និងឱនភាព នៃមូលធនមនុស្ស

"ចំណេះដឹងភាគច្រើនត្រូវតែរៀនពីសាលា គឺអ្នកមានវិជ្ជាជីវៈអាជីព ហើយអ្នកគ្មានវិជ្ជាជីវៈអាជីព ពុំអាចបំពេញតាមតម្រូវការរបស់ឧស្សាហកម្ម និងទីកន្លែងការងារទេ។"

## ៣.១ សេចក្តីផ្តើម

អ្នកធ្វើការភាគច្រើនស្ទើរតែនៅគ្រប់កម្រិតទាំងអស់ខ្វះចំណេះដឹង និងជំនាញសមស្របសម្រាប់ប្រើក្នុងការបំពេញការងារឱ្យមានប្រសិទ្ធភាពក្នុងបរិយាកាសមួយដែលមានការប្រែប្រួលឆាប់រហ័សស្មុគស្មាញ និងផ្លាស់ប្តូរលឿន។ ចំណេះដឹងភាគច្រើនត្រូវតែរៀនពីសាលា គឺអ្នកមានវិជ្ជាជីវៈអាជីព ហើយអ្នកគ្មានវិជ្ជាជីវៈអាជីពពុំអាចបំពេញតាមតម្រូវការរបស់ឧស្សាហកម្ម និងទីកន្លែងការងារទេ។ ដូច្នេះ ការឆ្លើយតបទៅនឹងឱនភាពនៃធនធានមនុស្សនៅកម្ពុជាជាកត្តាចាំបាច់ណាស់។ ចាំបាច់ត្រូវតែសម្លឹងមើលហេតុផលនៃការបង្កើតឱ្យមានឱនភាពនេះដើម្បីបង្កើតយុទ្ធសាស្ត្រមួយដែលល្អអាចជំនះរាល់បញ្ហាឱនភាពនៃមូលធនមនុស្សនេះ។

ជំពូកនេះ ពិនិត្យអំពីទស្សនាទាននៃឱនភាពនៃមូលធនមនុស្សក្នុងបរិបទម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា ដោយពិនិត្យមើលឡើងវិញលើពិពិធកម្មឧស្សាហកម្ម និងដោយវាយតម្លៃតាមវិស័យអំពីឱនភាពនៃមូលធនមនុស្ស និងភាពខ្វះចន្លោះនៃចំណេះដឹងក្នុងឧស្សាហកម្មចម្បងៗរបស់កម្ពុជា។

### ៣.១.១ ឱនភាពនៃមូលធនមនុស្ស

ធនធានបឋម ឬពលកម្មទទួលប្រាក់ឈ្នួលទាប និងគ្មានជំនាញ គឺមិនគ្រប់គ្រាន់សម្រាប់កម្ពុជាទៀតទេ ជាពិសេសសម្រាប់ទស្សនៈវិស័យយូរអង្វែងនៅពេលដែលតម្រូវការនៃសមត្ថភាពស្ថាប័ន និងឧស្សាហកម្មក្នុងស្រុកជាកត្តាចាំបាច់។ នៅកម្ពុជា ក៏ដូចប្រទេសផ្សេងដែរការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពប្រកួតប្រជែងមានន័យថាជាការស្វែងរកកត្តាកំណត់នៃភាពប្រកួតប្រជែងជាសកលដើម្បីដោះស្រាយបញ្ហានៃពាក្យមួយនិយាយថាកម្ពុជាកំពុងប្រឈមនឹងឱនភាពនៃមូលធនមនុស្ស។

បច្ចុប្បន្នមានជំនឿយ៉ាងមុតមាំមួយថា កម្ពុជាពឹងអាស្រ័យការអភិវឌ្ឍរបស់ខ្លួនលើវិស័យដែលកំពុងដំណើរល្អមួយចំនួន ដូចជាកាត់ដេរ សំណង់ និងទេសចរណ៍ ហើយវិស័យទាំងនេះមិនមាននិរន្តរភាពតទៅទៀតទេ ហើយប្រទេសនេះត្រូវការពង្រីកប្រភពនៃកំណើនសេដ្ឋកិច្ចរបស់ខ្លួនថែមទៀត តាមរយៈការបង្កើនសមត្ថភាពប្រកួតប្រជែង និងពិពិធកម្មនៃផលិតផលថ្មី និងទីផ្សារថ្មីឱ្យបានច្រើន។ ការកែប្រែកត្តាកំណត់នៃភាពប្រកួតប្រជែងជាសកលកំពុងកំណត់អនាគតនៃគោលគំនិតដែលមានផលវិបាកយ៉ាងខ្លាំងលើនយោបាយកម្ពុជា។ ការប្រែប្រួលទាំងនេះត្រូវតែមានការយល់ដឹងឱ្យស្របជាមួយនឹងតម្រូវការជំនាញថ្មីដែលចេះតែកើនឡើងឥតឈប់សម្រាប់យកទៅប្រើក្នុងការគ្រប់គ្រងការប្រែប្រួលនៃបច្ចេកទេស ហើយកំណែទម្រង់ចម្បងគឺត្រូវការកំណែទម្រង់នៃរចនាសម្ព័ន្ធអប់រំ និងការបណ្តុះបណ្តាលជាចាំបាច់។

ដោយសារច្បាប់ការងារមិនទាន់ជាបញ្ហាសម្រាប់ក្រុមហ៊ុន ប៉ុន្តែជំនាញជាក្តីបារម្ភធំបំផុតមួយ។ យោងតាមរបាយការណ៍របស់ IFC/World Bank ឆ្នាំ២០០៩ ថ្វីបើមានការពិតមួយបញ្ជាក់ថា ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះកម្រិតអប់រំមានការកើនឡើងជាទូទៅក៏ដោយក៏កម្រិតអប់រំនៅតែទាបដដែល ហើយ

*"និយោជកក្នុងក្រុមហ៊ុនសំលៀកបំពាក់ដេរ និងក្រុមហ៊ុនបដិសណ្ឋារកិច្ច នៅគ្រប់កម្រិតនៃគុណវុឌ្ឍិសិក្សា ទាំងអស់ជំនាញផ្នែកទន់ដ៏ល្អ គឺពិបាកស្វែងរកជាងជំនាញបច្ចេកទេស ។"*

តម្រូវការជំនាញនៅតែបន្តកើនឡើងដដែល ។ អភិក្រមរយៈពេលខ្លីរបស់ក្រុមហ៊ុននៅកម្ពុជា គឺត្រូវឆ្លើយតបជាបន្ទាន់ដោយបង្កើនការផ្តល់ការបណ្តុះបណ្តាលដល់និយោជិត ប៉ុន្តែប្រសិទ្ធភាពនៃអភិក្រមនេះ មិនទាន់ច្បាស់នៅឡើយទេ ។ ព្រោះអភិក្រមនេះផ្តល់ការបណ្តុះបណ្តាលផ្ទៃក្នុង ហើយគុណភាពប្រហែលជាមានកម្រិតទាប និងមិនអាចបំពេញតាមតម្រូវការទីផ្សារ គឺផ្តល់ការបណ្តុះបណ្តាលដែលពាក់ព័ន្ធ និងត្រូវការដល់និយោជិតនៃវិស័យឯកជនប៉ុណ្ណោះ (IFC/World Bank ២០០៩) ។

លើសពីនេះទៀត ការផ្គត់ផ្គង់កម្លាំងពលកម្មនៅតែមានបរិមាណច្រើនលើសលុប ហើយប្រាក់ឈ្នួលនៅតែមានកម្រិតទាបដែលបង្កើតឱ្យមានសនិទានភាពទីផ្សារពលកម្ម ។ សនិទានភាពនេះ ជាកត្តាកំណត់ជាច្រើនអំពីប្រទេសដែលមានប្រាក់ចំណូលទាប ទោះបីជាកម្លាំងពលកម្មគឺជាទ្រព្យសកម្មដ៏សំខាន់មួយប៉ុន្តែវាពុំមែនជាកំហិតចម្បងនៃកំណើនសេដ្ឋកិច្ចទេ ។ យោងតាមរបាយការណ៍របស់ World Bank and IFC បានឱ្យដឹងថា ឱនភាពនៃមូលធនមនុស្សក្នុងពេលបច្ចុប្បន្នកំពុងដាក់សម្ពាធកាន់តែខ្លាំង រួមមាន :

១. **កម្រិតជំនាញនៅខ្សោយ ហើយភាពទន់ខ្សោយនៃការសម្របសម្រួលឱ្យតាមតម្រូវការថ្មីនៃវិស័យឯកជន**ព្រមទាំងទីផ្សារដែលត្រូវការជំនាញត្រូវបរាជ័យច្រើន ។

២. **ទម្លាប់ផ្តល់ប្រាក់ឈ្នួល** មិនគ្រប់គ្រាន់សម្រាប់ការគាំទ្រដល់ដល់ការលើកកម្ពស់ផលិតភាព ។

៣. ក្នុងវិស័យកាត់ដេរ **ទំនាក់ទំនងឧស្សាហកម្មខ្សោយ** បានធ្វើឱ្យខូចប្រយោជន៍យ៉ាងខ្លាំងដល់ផលិតភាព និងសីលធម៌ ។

## ៣.២ ការដោះស្រាយភាពខ្វះចន្លោះនៃជំនាញ

ជំនាញជាកត្តាកំណត់ដ៏មានសារៈសំខាន់ចំពោះលទ្ធផលសេដ្ឋកិច្ច ដោយសារថាជំនាញទាំងនេះបង្កើនផលិតភាពរបស់បុគ្គលម្នាក់ៗ ។ ជាពិសេស វាពិតជាមានសារៈសំខាន់ណាស់ក្នុងការលើកឡើងពីភាពខ្វះចន្លោះនៃជំនាញផ្នែកទន់នៅកម្ពុជា ដូចជា ការតាំងចិត្តការប្រាស្រ័យទាក់ទង ភាពច្នៃប្រឌិត ការធ្វើសេចក្តីសម្រេចការដោះស្រាយបញ្ហាស្វ័យលើកទឹកចិត្ត និងការធ្វើការងារជាក្រុម ។ ធនាគារពិភពលោកបានឱ្យនិយមន័យនៃ*ជំនាញផ្នែកទន់*ជា (១) ជំនាញត្រិះរិះពិចារណារួមទាំងការគិតនិងការច្នៃប្រឌិតនិង (២)[10] អាកប្បកិរិយាដែលរួមទាំងសេចក្តីព្យាយាមការរក្សាវិន័យខ្លួនឯង និងការធ្វើការងារជាក្រុម ។ ឯកសារថ្មីៗជាច្រើនស្តីពីមូលធនមនុស្សសង្កត់ធ្ងន់ពីសារៈសំខាន់នៃជំនាញបែបនេះ ទាំងក្នុងដំណើរការអភិវឌ្ឍន៍មូលធនមនុស្ស និងកត្តាកំណត់លទ្ធផលសិក្សា និងលទ្ធផលការងារ ។ ជំនាញមួយចំនួនក្នុងចំណោម*ជំនាញផ្នែកទន់* (ឧទាហរណ៍ : ការមកធ្វើការទៀងទាត់ ឬការធ្វើការងារជាក្រុម) អាចរៀនសូត្រនៅពេលធ្វើការ ។ ប៉ុន្តែ ជំនាញផ្សេងទៀតត្រូវតែរៀននៅតាមគ្រឹះស្ថាន ដូចជា សាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាល ។ និយោជកចាត់ទុកជំនាញផ្នែកទន់នៅកម្ពុជា ជាជំនាញសំខាន់បំផុតដែលនិយោជិតខ្វះខាតយ៉ាងខ្លាំង (អង្កេតនិយោជក) ជាពិសេសក្នុង ចំណោមយុវជនក្រៅសាលាហើយនិយោជក ៨៩ភាគរយ បានឆ្លើយថា មានការលំបាកក្នុងការធ្វើការជាមួយយុវជនក្រៅសាលាដោយសារតែបញ្ហាអាកប្បកិរិយា ។

លើសនេះទៀត *ជំនាញផ្នែកទន់*ត្រូវបានបំពេញបន្ថែមដោយជំនាញផ្នែករឹង និងសមត្ថភាពបច្ចេកទេសដែលនិយាយសំដៅដល់កិច្ចការ ឬសកម្មភាពណាមួយពិតប្រាកដ ។ ឧទាហរណ៍នៃជំនាញផ្នែករឹង និងជំនាញ

១០ របាយការណ៍អភិវឌ្ឍន៍ពិភពលោក ធនាគារពិភពលោក ឆ្នាំ២០០៦

បច្ចេកទេស រួមមាន ការប្រើម៉ាស៊ីន និងការចេះប្រើកុំព្យូទ័រ។ ការខ្វះខាតជំនាញផ្នែកទន់ ជាបញ្ហាប្រឈមមួយដ៏ចម្បង ប៉ុន្តែជំនាញបច្ចេកទេសខ្សោយដែលមិនស៊ីគ្នាជាមួយនឹងតម្រូវការរបស់និយោជក ក៏បង្ហាញឱ្យឃើញពីឧបសគ្គមួយចំពោះកំណើនផលិតភាពនេះដែរ។

សម្រាប់និយោជកក្នុងក្រុមហ៊ុនសំណង់ កាត់ដេរ និងក្រុមហ៊ុនបដិសណ្ឋារកិច្ច នៅគ្រប់កម្រិតនៃគុណវុឌ្ឍិសិក្សាទាំងអស់ជំនាញផ្នែកទន់ដ៏ល្អ គឺពិបាកស្វែងរកជាងជំនាញបច្ចេកទេស។ សម្រាប់និយោជិតគ្មានជំនាញ និយោជក ៥២ ភាគរយ ចាត់ទុកឥរិយាបថការងារជាការខ្វះជំនាញដ៏ចម្បងបំផុតបន្ទាប់មកគឺភាសាបរទេស ហើយជំនាញបច្ចេកទេសស្ថិតនៅលំដាប់ទីបី (World Bank, ២០១០)។

និយមន័យនិយោជិតគ្មានជំនាញពាក់កណ្តាលជំនាញ និងនិយោជិតជំនាញអាចសរសេរសង្ខេបដូចខាងក្រោម ៖

**និយោជិតគ្មានជំនាញ ៖** ជានិយោជិតដែលធ្វើកិច្ចការសាមញ្ញដោយទាមទារឱ្យមានបទពិសោធតិចតួចដោយគ្មានការពិចារណាលើលក្ខណៈសម្បត្តិ ឬបទពិសោធបើទោះជាការយល់ដឹងបីបរិស្ថានការងារមានភាពចាំបាច់ក្តី។

**និយោជិតពាក់កណ្តាលជំនាញ ៖** ជានិយោជិតដែលធ្វើការងារទូទៅតាមទម្លាប់ដែលបានកំណត់មិនទាមទារលក្ខណៈសម្បត្តិការងារខ្ពស់ ប៉ុន្តែទាមទារឱ្យមានការទទួលខុសត្រូវសមស្របចំពោះការងារដែលបានប្រគល់ឱ្យ ឬមិនមានការធ្វើសេចក្តីសម្រេចចិត្តលើការងារសំខាន់ៗទេ។ ដូច្នេះ និយោជិតប្រភេទនេះទទួលខុសត្រូវលើវិសាលភាពការងារមានកម្រិត។

**និយោជិតជំនាញ ៖** ជានិយោជិតដែលមានសមត្ថភាពធ្វើការប្រកបដោយប្រសិទ្ធភាពធ្វើការដោយមានម្ចាស់ការ និងអនុវត្តកាតព្វកិច្ចប្រកបដោយការទទួលខុសត្រូវ។ និយោជិតប្រភេទនេះ ត្រូវមានចំណេះដឹងផ្នែកពាណិជ្ជកម្ម សិប្បកម្ម ឬឧស្សាហកម្មនៅពេលដែលក្រុមហ៊ុនជ្រើសរើសឱ្យមកបម្រើការងារ។

> “កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធមិនដោះស្រាយតម្រូវការទីផ្សារការងារគ្រប់ពេលទេ។”

## ៣.២.១ ការបណ្តុះបណ្តាលសម្រាប់ការងារ

### ៣.២.១.១ ការបណ្តុះបណ្តាលវិជ្ជាជីវៈ

ដោយបានដាក់បញ្ចូលក្នុង ផ.យ.អ.ជ ២០០៦-២០១០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ពីឆ្នាំ២០០៦-២០១០ អនុម័តដោយក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល។ យុទ្ធសាស្ត្រនេះ មានទិសដៅយុទ្ធសាស្ត្រ៤ គឺ (១) បង្កើតការងារ (២) ធានាឱ្យមានលក្ខខណ្ឌការងារប្រសើរជាងមុន (៣) លើកកម្ពស់ការអនុវត្តច្បាប់ស្តីពីសុវត្ថិភាពសង្គម (៤) អភិវឌ្ឍការកសាងសមត្ថភាពចំពោះជំនាញបច្ចេកទេស និងវិជ្ជាជីវៈ។

គ្រឹះស្ថានសាធារណៈភាគច្រើនផ្តល់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់គ្រងប្រព័ន្ធផ្លូវការ និងផ្តល់ឱកាសដល់សិស្សដែលបានបញ្ចប់ការអប់រំចំណេះទូទៅ ៣ឆ្នាំ នៅមធ្យមសិក្សាទុតិយភូមិឱ្យចូលរៀនក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលរយៈពេល ២ឆ្នាំ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាមួយ រៀន ៤ឆ្នាំ ដើម្បីទទួលបានបរិញ្ញាបត្រ ឬដើម្បីទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកបច្ចេកវិទ្យា និង/ឬ ធុរកិច្ច។ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ចំនួននិស្សិតដែលបានបញ្ចប់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានកើនឡើងពី ៨៨.៣៦៧ នាក់ ក្នុងឆ្នាំ២០០៧ ដល់១១៣.៦៤៨ នាក់ក្នុងឆ្នាំ ២០០៨[១១] ។

### ៣.២.១.២ ការបណ្តុះបណ្តាលក្នុងប្រព័ន្ធ

ក្រុមហ៊ុនមួយចំនួនពី ៤០ ទៅ ៦០ ភាគរយក្នុងចំនួនសរុប ពឹងផ្អែលើការបំពាក់បំប៉នការបណ្តុះបណ្តាលបន្ថែមនៅពេលបម្រើការងារ និងការបណ្តុះបណ្តាលផ្តល់ពីខាងក្រៅ ។ ក្រុមហ៊ុនមួយចំនួន ជាពិសេសក្នុងវិស័យបដិសណ្ឋារកិច្ចដែលភាគច្រើនត្រូវទាក់ទងជាមួយភ្ញៀវបរទេសជាចាំបាច់ និងជាបន្តបន្ទាប់ត្រូវបង្កើតអង្គភាពបណ្តុះបណ្តាលផ្ទៃក្នុងដើម្បីបង្កើន និងលើកកម្ពស់កម្រិតនៃសេវារបស់ខ្លួនឱ្យប្រសើរថែមទៀត ។

ការបណ្តុះបណ្តាលជាច្រើនដែលនិយោជកផ្តល់ឱ្យនិយោជិតឆ្លុះបញ្ចាំងឱ្យឃើញអំពីតម្រូវការដើម្បីបំពេញការខ្វះចន្លោះនៃជំនាញមូលដ្ឋានរបស់និយោជិតជាច្រើន ។ លើសពីនេះទៀត អត្រាផ្លាស់ប្តូរនិយោជិតខ្ពស់ប៉ះពាល់ដល់ការលើកទឹកចិត្តរបស់ក្រុមហ៊ុនក្នុងការវិនិយោគលើនិយោជិតដែរ ។ ក្នុងឆ្នាំ២០០៧ និយោជិត ១៧ភាគរយក្នុងវិស័យទាំងអស់ គឺជានិយោជិតថ្មី និង ១១ភាគរយ បានលាឈប់ពីក្រុមហ៊ុននៅចុងឆ្នាំ (World Bank, ២០០៨) ។ អត្រាផ្លាស់ប្តូរការងាររបស់និយោជិតខ្ពស់អាចប៉ះពាល់ដល់ការលើកទឹកចិត្តរបស់ក្រុមហ៊ុនក្នុងការវិនិយោគលើការបណ្តុះបណ្តាលកម្លាំងពលកម្មរបស់ខ្លួន និងការគាំទ្រដល់តម្រូវការដើម្បីលើកកម្ពស់គុណភាពនៃបណ្តុះបណ្តាលក្នុងប្រព័ន្ធអប់រំចំណេះទូទៅ ។

*រូប ៣.១: វិធីសាស្ត្របណ្តុះបណ្តាលដែលត្រូវការជាចាំបាច់ក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ផលិតភាពរបស់និយោជិត*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០ ។ ការផ្តល់ជំនាញសម្រាប់សមធម៌ និងកំណើនសេដ្ឋកិច្ច : ការរៀបចំយុវជនកម្ពុជាសម្រាប់ទីផ្សារការងារ ។ នាយកដ្ឋានអភិវឌ្ឍន៍មនុស្សប្រចាំតំបនអាស៊ីខាងកើត និងប៉ាស៊ីហ្វិក ទំព័រទី ៦៤ ។*

## ៣.២.២ ការខ្វះចន្លោះនៃជំនាញ

កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធមិនដោះស្រាយតម្រូវការទីផ្សារការងារគ្រប់ពេលទេ ។ កម្លាំងពលកម្មរបស់កម្ពុជាត្រូវមានជំនាញដែលតម្រឹមទៅតាមការកែប្រែមុខមាត់ថ្មីនៃសេដ្ឋកិច្ច

១១ ការងារ និងនិន្នាការសង្គមក្នុងប្រទេសកម្ពុជា : អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០១០ ។

និងដែលអាចគាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសជាបន្តទៀត ។ និយោជក៥៤ភាគរយដែលបានចូលរួមក្នុងការអង្កេតអះអាងថាពិតជាកើតមាន អសង្គតិភាពរវាងជំនាញផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ និងលក្ខខណ្ឌតម្រូវរបស់ក្រុមហ៊ុន (២០០៩) ។

*រូប ៣.២ : អសង្គតិភាពនៃជំនាញ រវាងតម្រូវការរបស់និយោជក និងការបណ្តុះបណ្តាលយោងតាមនិយោជក (ឆ្នាំ២០០៩)*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០c ។ ទំព័រទី ៩៦ ។*

## ៣.៣ ទិដ្ឋភាពរួមនៃកម្លាំងពលកម្មក្នុងប្រទេសកម្ពុជា

ក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងមកនេះ កម្ពុជាបានរក្សាកំណើនសេដ្ឋកិច្ចឱ្យមាននិរន្តរភាពដោយបង្វែរទិសពីវិស័យកសិកម្មឈានទៅរកវិស័យឧស្សាហកម្មវិញ ។ ទោះជាយ៉ាងណា ការផ្លាស់ប្តូរនេះមិនបានពិចារណាអំពីជំនាញផ្នែកទន់ដែលវិស័យការងារផ្សេងៗត្រូវការទេ ។ ជំនាញផ្នែកទន់នេះទាមទារឱ្យមានទាំងការអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេសដោយផ្តោតការយកចិត្តទុកដាក់លើគ្រប់កម្រិតសិក្សា ប៉ុន្តែ ជាពិសេសក្នុងការរក្សាកុមារឱ្យបន្តការសិក្សានៅសាលាឱ្យបានយូរ និងលើកកម្ពស់ឱកាសការងារ និងផលិតភាពរបស់កម្លាំងពលកម្មភាគច្រើនតាមរយៈការបង្កើនកម្រិតជំនាញឱ្យបានខ្ពស់ថែមទៀត ។

### ៣.៣.១ កំណើនសេដ្ឋកិច្ចរបស់ប្រទេស និងតម្រូវការកម្លាំងពលកម្ម

ដោយរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្លាំងក្នុងរយៈពេល ១០ឆ្នាំ កន្លងមកនេះ កម្ពុជាពិតបានឆ្លងកាត់កំណើននៃសម្ពាធក្នុងការបង្កើតការងារ និងការបន្តពង្រីកសេដ្ឋកិច្ចរបស់ប្រទេសឱ្យបានឆាប់រហ័សថែមទៀត ។

*រូប ៣.៣ : ការបង្កើតការងារ[១២] នៅទូទាំងវិស័យ ឆ្នាំ២០០១-២០០៨*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០c ។ ទំព័រទី ៣៥ ។*

"បញ្ហាមូលធនមនុស្សរបស់កម្ពុជាផ្តោតការយកចិត្តទុកដាក់លើជំនាញទាក់ទងនឹងការងាររបស់កម្លាំងពលកម្មដែលជាញឹកញាប់មិនបានឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់និយោជកទេ ។"

១២ វិស័យរ៉ែ និងសេវាសាធារណៈ គឺជាប្រភពនៃការបង្កើតការងារធ្វើធំបំផុតទីបី ប៉ុន្តែមិនត្រូវបានលើកយកមកនិយាយក្នុងការសិក្សារបស់ធនាគារពិភពលោក នេះនោះទេ ហើយក៏មិនមាននៅក្នុងក្រាហ្វិកផងដែរ ។

ដូចបានបង្ហាញក្នុងតារាងខាងលើកម្ពុជាដែលកាលពី ១០ឆ្នាំមុន ជាប្រទេសមានសេដ្ឋកិច្ចពឹងអាស្រ័យលើស្ទ័យ មុខរបរ កសិករ និងសេដ្ឋកិច្ចកសិកម្ម។ ទើបតែពេលថ្មីៗនេះ កម្ពុជាបានចាប់ផ្តើមធ្វើពិពិធកម្មសេដ្ឋកិច្ច និងការងាររបស់ខ្លួនក្រៅពីវិស័យកសិកម្ម។ នេះជាលទ្ធផលនៃកើ្តដំណើលប្រវត្តិសាស្ត្រដ៏លំបាក ដែលមិនអាចជៀសផុតគួបផ្សំនឹងលក្ខខណ្ឌនៃរចនាសម្ព័ន្ធជាច្រើនដែលមានឥទ្ធិពលប៉ះពាល់ដល់ប្រទេស ប្រែប្រួលតាមសន្តិភាព និងស្ថិរភាពនយោបាយ រួមជាមួយកត្តាជំរុញមួយធ្វើឱ្យប្រទេសធ្វើដំណើរឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ និងមួយផ្នែកដោយសារការចូលរួមជាមួយអង្គការពាណិជ្ជកម្មពិភពលោក។ បញ្ហាប្រឈមថ្មីៗ គឺផ្តោតការយកចិត្តទុកដាក់លើរបៀបដែលកម្ពុជាអាចបញ្ចូលខ្លួនក្នុងពាណិជ្ជកម្មអន្តរជាតិប្រកបដោយប្រសិទ្ធភាព និងលើរបៀបដែលកម្ពុជាអាចប្រើប្រាស់ក្របខ័ណ្ឌពាណិជ្ជកម្មធ្វើជាឱកាសមួយសម្រាប់ធ្វើពិពិធកម្មសេដ្ឋកិច្ច។ កត្តារួមផ្សំទាំងអស់នេះក៏បានបង្កើតលក្ខខណ្ឌចាំបាច់ដែលបានជួយបង្កើនផលិតកម្មក្នុងវិស័យផ្សេងៗនៅកម្ពុជាដែរ។ ការពង្រីកសេដ្ឋកិច្ចនេះអាចមើលឃើញច្បាស់ក្នុងវិស័យសេវាកម្ម ដូចជាទេសចរណ៍ កាត់ដេរ និងកំណើន អចលនទ្រព្យ។ ដោយសារលទ្ធផលនៃកការពង្រីកវិនិយោគបរទេសផ្ទាល់ មានរោងចក្រកាន់តែច្រើនបានបង្កើតឡើងពង្រីកវិស័យសំណង់ ប៉ុន្តែ បានបង្កើតលក្ខខណ្ឌឱ្យមានកំណើននៃវិសមភាពក្នុងសង្គមដែលជាលទ្ធផលបានធ្វើឱ្យកម្លាំងពលកម្មដែលពុំមានជំនាញមានកាន់តែច្រើន។

### ៣.៣.២ តើអសង្គតិភាពបច្ចុប្បន្នរវាងជំនាញដែលមាន និងការខ្វះចន្លោះនៃជំនាញដែលប្រទេសត្រូវការមានអ្វីខ្លះ?

បញ្ហាមូលធនមនុស្សរបស់កម្ពុជាផ្តោតការយកចិត្តទុកដាក់លើជំនាញទាក់ទងនឹងការងាររបស់កម្លាំងពលកម្មដែលជាញឹកញាប់មិនបានឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់និយោជកទេ ជាពិសេសក្នុងវិស័យកើតថ្មីៗ។ ជាមួយនឹងយុវជនគ្មានជំនាញមានកម្រិតខ្ពស់ក្នុងកម្លាំងពលកម្ម និងការខ្វះជំនាញផ្នែកទន់របស់យុវជន និយោជកភាគច្រើនបានបង្ហាញឱ្យដឹងពីការលំបាកក្នុងការធ្វើការជាមួយយុវជនក្រៅសាលា ដោយសារយុវជនទាំងនោះប្រកាន់ឥរិយាបថមិនល្អនៅកន្លែងធ្វើការ។ យោងតាមការអង្កេតនិយោជក (CAMFEBA, ២០០៨)។

បច្ចេកវិទ្យាផលិតកម្ម និងព័ត៌មានវិទ្យានៅតែសម្របទៅតាមកម្លាំងពលកម្មដែលខ្សោយជំនាញ ហើយបច្ចេកវិទ្យាផលិតកម្ម ក៏នៅតែសម្របតាមទីផ្សារការងារដែរ។ ក្នុងនោះអ្នកចូលរួមមានត្រឹមតែ ៧ ភាគរយប៉ុណ្ណោះ បានរៀនចប់មធ្យមសិក្សា។ បញ្ហានេះកំពុងកើតឡើងស្របនឹងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការពង្រីកវិស័យកាត់ដេរ ផលិតកម្ម សេវាកម្ម សំណង់ និងទេសចរណ៍ផង។

*រូប ៣.៤ :ជំនាញដែលនិយោជិតកម្ពុជាភាគច្រើនខ្វះខាត*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០c ។ ទំព័រទី ៥៤ ។*

វិស័យលូតលាស់ខ្ពស់បំផុតបីនៅកម្ពុជា (កាត់ដេរ បដិសណ្ឋារកិច្ច និងសំណង់) ក៏មានរបាយការណ៍ថា និស្សិតទើបរៀនចប់ថ្មីៗមានខ្វះចន្លោះនូវជំនាញច្រើនណាស់ ។ ក្នុងវិស័យទាំងបីនេះ និយោជក ២០ភាគរយ ប៉ុណ្ណោះអះអាងថា អ្នកបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលជំនាញចាំបាច់សម្រាប់យកមកធ្វើការ ។ ប៉ុន្តែ ភាពខុសគ្នាជាច្រើនតាមវិស័យនីមួយៗបង្ហាញអំពីភាពធ្ងន់ធ្ងរនៃការខ្វះចន្លោះនៃជំនាញ ។ វិស័យកាត់ដេរ និងសំណង់ត្រូវការនិយោជិតដែលមានជំនាញទាប និងគ្មានជំនាញសោះទើបវិស័យទាំងពីនេះមានភាពងាយស្រួលសម្រាប់ប្រជាជនជនបទចូលមកបម្រើការងារ និងទាមទារលក្ខណៈសម្បត្តិតិចតួចពីនិយោជិតដែលបានបោះបង់ការសិក្សាចេញពីប្រព័ន្ធអប់រំ ។

## ៣.៣.២.១ ឱនភាពនៃមូលធនមនុស្សក្នុងវិស័យកាត់ដេរ

កម្ពុជាពឹងអាស្រ័យលើវិស័យកាត់ដេរខ្លាំងណាស់ព្រោះវិស័យនេះរួមចំណែកដល់ផលិតផលក្នុងស្រុកសរុបប្រហែល ១៦ ភាគរយ ។ វិស័យនេះទទួលបានកំណើនមិនគួរឱ្យជឿ គឺ ២៨ ភាគរយក្នុងមួយឆ្នាំ ហើយការនាំចេញសំលៀកបំពាក់កើនឡើងពីតួលេខប្រហែលសូន្យក្នុង ឆ្នាំ១៩៩៤ ដល់ចំនួន ២,៨ ពាន់លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៧ (World Bank ២០០៩) គឺរួមចំណែក៧៥ភាគរយនៃការនាំចេញសរុបក្នុងឆ្នាំ២០០២ និង ៦៥ ភាគរយនៃការនាំចេញសរុបក្នុងឆ្នាំ២០០៨ ។

ការផ្ទុះកំណើននៃវិស័យកាត់ដេរក៏បានឈានទៅពង្រីកការងារផងដែរ គឺក្នុងឆ្នាំ២០០៥-២០០៦ បានបង្កើតការងាររហូតដល់ ៣០.០០០កន្លែង ហើយនៅឆ្នាំ២០០៨ បង្កើតបានការងារសរុប ៣៥០.០០០ កន្លែង ។ ក្នុងវិស័យនេះ និយោជិតពី៨០-៨៥% ជាស្ត្រីដែលភាគច្រើនជាជនចំណាកស្រុកមកពីខេត្តផ្សេងៗ ហើយនិយោជិតភាគច្រើនជាអ្នករកប្រាក់ចំណូលសម្រាប់គ្រួសារ ។ ជាមធ្យមពួកគេមានបទពិសោធបានធ្វើការក្នុងវិស័យនេះពី២-៣ឆ្នាំ និយោជិតភាគច្រើនបានបញ្ចប់ការសិក្សានៅត្រឹមកម្រិតបឋមសិក្សាប៉ុណ្ណោះ ។ ពួកគេធ្វើការពី ៤៨-៦០ម៉ោងក្នុងមួយសប្តាហ៍ ហើយក្នុងមួយខែពួកគេទទួលបានប្រាក់ចំណូលពី ៧០ ទៅ ១០០ដុល្លារអាមេរិក ។

*“... កំណើនផលិតភាពមានន័យថា ជាការលើកកម្ពស់ជំនាញ និងការបណ្តុះបណ្តាល ។”*

ការពឹងអាស្រ័យយ៉ាងខ្លាំងលើវិស័យនេះ អាចវិភាគឃើញយ៉ាងច្បាស់ដោយប្រើការពិតថា វិស័យនេះតែមួយមុខ រួមចំណែកប្រហែល៥០ភាគរយនៃទិន្នផលឧស្សាហកម្មសរុប និង៦៩ភាគរយនៃការផលិតសរុបក្នុងប្រទេសនៅឆ្នាំ២០០៥។ ដោយសារខ្វះសមត្ថភាពប្រកួតប្រជែងក្នុងការនាំចេញនៃវិស័យកាត់ដេរនេះ ការពឹងអាស្រ័យដ៏គ្រោះថ្នាក់នេះធ្វើឱ្យកម្ពុជាងាយរងគ្រោះដោយសារការប្រកួតប្រជែងពីប្រទេសផ្សេងៗ និងការរីកវិវររបស់អន្តរជាតិ។ ការខ្វះខាតសមត្ថភាពប្រកួតប្រជែងបណ្តាលមកពីស្ថាពភាពលំបាកផ្សេងៗនៃកត្តាដែលពាក់ព័ន្ធនឹងវិស័យនេះមាន ដូចជាផលិតភាពទាប ការផ្គត់ផ្គង់មិនគួរឱ្យទុកចិត្ត និងតម្លៃអគ្គិសនីខ្ពស់។ ឧទាហរណ៍ វៀតណាមអាចយកប្រៀបលើកម្ពុជាយ៉ាងងាយស្រួលព្រោះវៀតណាមមានតម្លៃអគ្គិសនីថោកជាង ហើយការចំណាយលើការផលិតសរុបទាបជាងការផលិតនៅកម្ពុជាប្រហែល ២០ភាគរយ។

ផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចអន្តរជាតិនៅកម្ពុជា មានសភាពធ្ងន់ធ្ងរខ្លាំងដែលធ្វើឱ្យការនាំចេញធ្លាក់ចុះជាង ៥០ភាគរយ គឺធ្លាក់ចុះពី ២៥០លានដុល្លារអាមេរិក មកនៅត្រឹម ១០០លានដុល្លារអាមេរិក នៅខែមករា ឆ្នាំ២០០៩។ លើសពីនេះទៀតរោងចក្រជាច្រើននៅកម្ពុជា គឺមានបរទេសជាម្ចាស់ ហើយដោយសារវិបត្តិហិរញ្ញវត្ថុប៉ះពាល់ដល់ទីផ្សារបរទេស ការវិនិយោគបរទេសផ្ទាល់បានធ្លាក់ចុះ ១៥ភាគរយ។ ការធ្លាក់ចុះទាំងអស់នេះធ្វើឱ្យនិយោជិតទទួលបានម៉ោងធ្វើការតិចដោយក្នុងមួយខែបានបាត់បង់ប្រាក់ឈ្នួលពី ៤-៥លានដុល្លារ។ ពីឆ្នាំ ២០០៨-២០០៩ កម្លាំងពលកម្ម ១៨ភាគរយនៃកម្លាំងពលកម្មសរុបក្នុងវិស័យនេះត្រូវបានបញ្ឈប់ ឬសម្រាកដោយសារតែវិបត្តិសេដ្ឋកិច្ច។

និយាយអំពីការខ្វះចន្លោះនៃជំនាញរបស់និយោជិតក្នុងឧស្សាហកម្មកាត់ដេរ ក្រុមហ៊ុនមិនចាត់ទុកការខ្វះខាតនេះជាបញ្ហាធ្ងន់ធ្ងរទេ ព្រោះការបណ្តុះបណ្តាលនិយោជិតឱ្យចេះប្រើប្រាស់ម៉ាស៊ីនដាក់លាក់ជាការងាយស្រួល។ ប៉ុន្តែវិស័យនេះប្រឈមបញ្ហាខ្វះនិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ហើយវិស័យនេះនឹងត្រូវការបុគ្គលិកផ្នែកលក់ដែលមានគុណវុឌ្ឍិសិក្សា។ ដូចគ្នាដែរ និយោជិតអាជីពនៅខ្វះជំនាញភាសាជាពិសេសអង់គ្លេស និងចិន ខ្វះជំនាញភាសានេះជាឧបសគ្គដ៏ធំមួយរារាំងដល់ការលើកកម្ពស់វិស័យនេះមានភាពល្អប្រសើរ។ ជំនាញភាសានេះមានសារៈសំខាន់សម្រាប់ជួយបង្កើតទំនាក់ទំនងរវាងនិយោជិត អ្នកទិញ និងម្ចាស់ក្រុមហ៊ុន។

លើសពីនេះទៀតជំនាញច្នៃប្រឌិតក៏មានសារៈសំខាន់ក្នុងវិស័យកាត់ដេរដែរ ប៉ុន្តែការអង្កេតបង្ហាញថាជំនាញច្នៃប្រឌិតនេះមានការខ្វះខាតខ្លាំងបំផុត។ ជំនាញច្នៃប្រឌិតគឺពិបាករកបំផុតក្នុងចំណោមនិយោជិតភាគច្រើន និងពិបាករកក្នុងគ្រប់កម្រិតនៃជំនាញទាំងអស់។ ប៉ុន្តែការពិបាករឃើញនេះកើតមានជាពិសេសក្នុងចំណោមនិយោជិតគ្មានជំនាញ (៦៧ ភាគរយ) ហើយក៏មានការពិបាករកផងដែរក្នុងចំណោមនិយោជិតពាក់កណ្តាលជំនាញ (៥៣ភាគរយ) និងនិយោជិតជំនាញ (៤០ភាគរយ)។

ការលំបាកធំៗក្នុងការរកជំនាញ គឺភាពទន់ខ្សោយនៃជំនាញការធ្វើសេចក្តីសម្រេចចិត្តក្នុងចំណោមនិយោជិតពាក់កណ្តាលជំនាញ និងជំនាញ។ សម្រាប់តំណែងដែលត្រូវការជំនាញនិយោជក ៩៣ភាគរយតម្រូវឱ្យមានសញ្ញាបត្រសាកលវិទ្យាល័យ ប៉ុន្តែ និយោជក ៧ភាគរយ យល់ឃើញថា មានវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈជាការគ្រប់គ្រាន់ហើយ។និយោជិតគ្មានជំនាញក្នុងវិស័យកាត់ដេរមានជំនាញបច្ចេកទេសខ្សោយខ្លាំងណាស់។ មាននិយោជក ១ ភាគ ៤ បានត្អូញត្អែរអំពីការខ្វះខាតជំនាញបច្ចេកទេស ក្នុងចំណោមនិយោជិតគ្មានជំនាញ ជាពិសេសជំនាញដេរភ្ជាប់លេវ និងជំនាញមេកានិច។ និយោជក ១ ភាគ ៥ បាន

អះអាងថា ខ្សោយខាងជំនាញផ្នែកទន់ ជាកំហិតមួយក្នុងចំណោមនិយោជិតគ្មានជំនាញ ដូចជា ស្មារតីធ្វើការងារជាក្រុម មានឆន្ទៈ ចេះដោះស្រាយបញ្ហា និងការតាំងចិត្តចំពោះការងារ ។

*រូប ៣.៥ : ការខ្វះខាតជំនាញចម្បងៗក្នុងវិស័យកាត់ដេរនៅកម្ពុជា*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០c ។ ទំព័រទី ៥៩ ។*

ដូច្នេះ សមត្ថភាពប្រកួតប្រជែងពីរយៈពេលខ្លី ដល់រយៈពេលវែងក្នុងវិស័យកាត់ដេរសកលរបស់កម្ពុជានៅតែជាបញ្ហាដ៏ធំសម្រាប់ប្រទេសជាបញ្ហាដែលបានលើកឡើងក្នុងរបាយការណ៍[១៣]របស់អង្គការ USAID ។ របាយការណ៍បង្ហាញថា ក្នុងមុខតំណែងជាអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ និងមុខតំណែងជាន់ខ្ពស់ក្នុងទីផ្សារការងារក្នុងវិស័យកាត់ដេរនេះ គឺជនបរទេសមាន ប្រៀបគ្របដណ្តប់ខ្លាំង។ បរទេសគឺមានតែ ២ភាគរយនៃកម្លាំង

១៣ ការវាស់វែងភាពប្រកួតប្រជែង និងផលិតភាពពលកម្មក្នុងឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៥ អង្គការ USAID និងមជ្ឈមណ្ឌលផលិតភាពឧស្សាហកម្មកាត់ដេរប្រទេសកម្ពុជា (របាការណ៍ចុងក្រោយ) ឆ្នាំ២០០៩ អង្គការ USAID.

ពលកម្មសរុបក្នុងវិស័យកាត់ដេរ ប៉ុន្តែពួកគេបានស្រូបយក ១០ភាគរយ នៃប្រាក់បៀវត្សសរុប។ ឱកាសបណ្តុះបណ្តាលសម្រាប់ជនជាតិកម្ពុជាសម្រាប់កាន់មុខតំណែងជាអ្នកគ្រប់គ្រងត្រូវបានផ្តល់ជាគំនិតសម្រាប់ពិចារណា ហើយត្រូវបានបំពេញបន្ថែមដោយការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស។ ដូច្នេះ និយោជិតអាចទទួលបានឱកាស និងការលើកទឹកចិត្តឱ្យបញ្ចេញសមត្ថភាព និងបន្តអនុវត្តសកម្មភាពបន្ថែមតម្លៃដែលអាចបង្កើនប្រាក់ចំណូលរួមរបស់ក្រុមហ៊ុន និងបង្កើតផលិតភាពផងដែរ។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក (ឆ្នាំ២០១០) កំណើនផលិតភាពមានន័យថាជាការលើកកម្ពស់ជំនាញ និងការបណ្តុះបណ្តាល។ ការនាំចេញសំលៀកបំពាក់ដែលមានសមិទ្ធផលខ្ពស់ គឺផ្តត់ផ្គង់បន្ថែមឱ្យបានច្រើន ប៉ុន្តែក្នុងតម្លៃទាបដែលមិននិរន្តរភាពព្រោះការនាំចេញសំលៀកបំពាក់ មិនអាចប្រកួតប្រជែងបានដោយសារប្រាក់ឈ្នួល។ ដូច្នេះជាការចំបាច់ត្រូវលើកកម្ពស់ជំនាញ និងមូលធនមនុស្សក្នុងវិស័យនេះឱ្យបានប្រសើរថែមទៀត។

### *ប្រអប់ ៣.១ : ការវិនិយោគបរទេសផ្ទាល់ និងភាពប្រែប្រួលខ្លាំងពាក់ព័ន្ធទៅនឹងការវិនិយោគនេះ*

មានហេតុផលមួយចំនួនថាតើហេតុអ្វីបានជាភាពប្រែប្រួលឆាប់រហ័សនៃលំហូរវិនិយោគបរទេសផ្ទាល់ (FDI) អាចធ្វើឱ្យកំណើនសេដ្ឋកិច្ច មានភាពអវិជ្ជមាន។

១. ហេតុផលទី១ គឺថា ភាពប្រែប្រួលឆាប់រហ័យក្នុងការវិនិយោគបរទេសផ្ទាល់មានឥទ្ធិពលជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច។ ប្រសិនបើលំហូរនៃការវិនិយោគបរទេសផ្ទាល់មានភាពមិនច្បាស់លាស់នោះការចំណាយ (និងផលចំណេញ) នៃការវិនិយោគក៏មិនច្បាស់លាស់ដែរ ព្រោះការវិនិយោគបរទេសផ្ទាល់អាចផ្តល់កម្លាំងចលករដល់ការវិនិយោគក្នុងស្រុក និងនវានុវត្តភាព។ ដូច្នេះ ករណីនេះគឺថា ភាពប្រែប្រួលឆាប់រហ័សក្នុងលំហូរនៃការវិនិយោគបរទេសផ្ទាល់ធ្វើឱ្យអន្តរាយដល់ការវិនិយោគក្នុងស្រុកដោយសារផលអាក្រក់ប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចក្នុងស្រុក។

២. ហេតុផលទី ២ គឺថា ការប្រែប្រួលឆាប់រហ័សក្នុងលំហូរនៃការវិនិយោគបរទេសផ្ទាល់បង្កអស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ។ នៅប្រទេសណាដែលការវិនិយោគបរទេសផ្ទាល់មានការប្រែប្រួលខ្លាំង ប្រទេសនោះអាចប្រឈមនឹងអស្ថិរភាព (នយោបាយ និងសេដ្ឋកិច្ច)។ មានភស្តុតាងមួយបញ្ជាក់ថា កំណើនមានភាពយឺតយ៉ាវនៅប្រទេដែលប្រឈមនឹងភាពមិនច្បាស់លាស់ខ្លាំងនៃសេដ្ឋកិច្ច ដូចជាកម្ពុជា ហើយនិន្នាការនេះអាចបង្កភាពងាយរងគ្រោះដោយវិបត្តិហិរញ្ញវត្ថុដល់ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន។

ក្នុងករណីផលិតផលជាសំលៀកបំពាក់ និងផលិតផលផ្សេងទៀតសម្រាប់នាំចេញការវិនិយោគបរទេសផ្ទាល់អាចផ្តល់ជាស្ពានមួយសម្រាប់និយោជិតឱ្យចាកចេញពីតំបន់ជនបទ និងចេញពីសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ដូច្នេះ លំហូរចូលនៃការវិនិយោគបរទេសផ្ទាល់មានឥទ្ធិពលវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច ហើយការប្រែប្រួលឆាប់រហ័សនៃការវិនិយោគបរទេសផ្ទាល់មានផលប៉ះពាល់អវិជ្ជាមានមកលើសេដ្ឋកិច្ចរបស់ប្រទេសមួយ ហើយគ្មានភស្តុតាងបង្ហាញថា ប្រសិទ្ធភាពនៃការវិនិយោគបរទេសផ្ទាល់ក្នុងប្រទេសមួយ (រួមណែកដល់កំណើន) ត្រូវបានកំណត់ដោយកម្រិតនៃមូលធមនុស្សក្នុងប្រទេសនោះទេ។

ដូច្នេះ វាមិនមែនថាភាពប្រែប្រួលឆាប់រហ័សនៃការវិនិយោគបរទេសផ្ទាល់នោះទេដែលពន្យារកំណើននៃសេដ្ឋកិច្ចធ្លាក់ចុះ ប៉ុន្តែថា ភាពប្រែប្រួលឆាប់រហ័សបែបនេះចាប់យកឥទ្ធិពលនៃការពន្យារកំណើនរបស់

---

១៤ លោក Robert Lensink និងលោក Oliver Morrissey សាកលវិទ្យាល័យ Nottingham ឯកសារស្រាវជ្រាវពិភាក្សាស្តីពីការវិនិយោគផ្ទាល់ពីបរទេស : លំហូរភាពប្រែប្រួលខ្លាំង និងកំណើនសេដ្ឋកិច្ចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឆ្នាំ២០០១។

អថេរដែលមិនអាចអង្កេតបាន។ ភាពអាចកើតមានមួយគឺថា ប្រទេសដែលមានកម្រិតនៃភាពមិនប្រាកដប្រជាខ្ពស់ផ្នែកសេដ្ឋកិច្ចនឹងមានទំនោរទៅរកអត្រាកំណើនសេដ្ឋកិច្ចទាបជាងមុន និង/ឬមានភាពប្រែប្រួលខ្លាំង ហើយក៏អាចធ្វើឱ្យចំណាប់អារម្មណ៍របស់វិនិយោគិន ធ្លាក់ចុះទាបជាងមុនផងដែរ។ កត្តានេះមានភាពស្របគ្នាជាមួយនឹងភស្តុតាងនៃទំនាក់ទំនងរវាងការវិនិយោគបរទេសផ្ទាល់ និងភាពប្រែប្រួលឆាប់រហ័សនៃការវិនិយោគបរទេសផ្ទាល់។ ការបកស្រាយមួយក្នុងចំណោមលទ្ធផលរកឃើញទាំងនេះគឺថា ប្រភេទនៃការវិនិយោគបរទេសផ្ទាល់មួយចំនួនទទួលរងឥទ្ធិពលតិចតួចពីអស្ថិរភាពសេដ្ឋកិច្ច (ឬអស្ថិរភាពនយោបាយ) ជាងប្រភេទនៃការវិនិយោគបរទេសផ្ទាល់ផ្សេងទៀត។ តាមការពិត គឺថាសមាធាតុនៃការវិនិយោគបរទេសផ្ទាល់ដែលមានភាពប្រែប្រួលខ្លាំង ហើយជាការពិតគឺថាសមាធាតុទាំងនេះឆ្លើយតបនឹង (និងអាចមានឥទ្ធិពលលើ) ភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច។ នេះជាវិស័យមួយដែលនឹងត្រូវការ ការវិភាគ ក្នុងការងារនាពេលអនាគត។

### ៣.៣.២.២ ឱនភាពនៃមូលធនមនុស្សក្នុងវិស័យបដិសណ្ឋារកិច្ច និងទេសចរណ៍

ក្នុងទសវត្សរ៍កន្លងមកទេសចរណ៍ និងឧស្សាហកម្មបានរីកលូតលាស់ក្លាយជាស្ដម្ភមួយក្នុងចំណោមស្ដម្ភចម្បងៗនៃកំណើនសេដ្ឋកិច្ចក្នុងប្រទេសគ្រាន់តែវិស័យទេសចរណ៍បានកើនដល់កម្រិតខ្ពស់បំផុត គឺមានទេសចរណ៍ប្រហែល ២,១៦ លាននាក់ បានមកទស្សនាកម្ពុជាក្នុង ឆ្នាំ២០០៩។ ប្រសិនបើប្រៀបធៀបនឹងចំនួនភ្ញៀវទេសចរណ៍ត្រឹម ២០.០០០ នាក់ក្នុង ឆ្នាំ១៩៩២ (UNDP Asia Pacific, Ministry of Tourism)។ កំណើនក្នុងឧស្សាហកម្មទេសចរណ៍ជាលទ្ធផលនៃការសម្រេចបានសន្តិភាព និងស្ថិរភាពចាប់ពីចុងទសវត្សរ៍ ១៩៩០ ចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរណ៍ទៅនឹងប្រាសាទអង្គរវត្តដែលបានក្លាយជាបេតិកភ័ណ្ឌពិភពលោកក្នុងឆ្នាំ១៩៩២ កំណើននៃការធ្វើដំណើរអន្តរជាតិ និងក្នុងស្រុក និងគោលនយោបាយរបស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍវិស័យទេសចរណ៍ (ឧ. គោលនយោបាយបើកចំហរជើងមេឃ ការទទួលបានទិដ្ឋការនៅពេលមកដល់ ។ល។)។

ដោយសារហេតុផលខាងលើចំនួនសណ្ឋាគារ និងផ្ទះសំណាក់មានការកើនឡើងយ៉ាងលឿន។ កំណើននៃសេវាកម្មសណ្ឋាគារយ៉ាងឆាប់រហ័សនេះ បានទាញឱ្យមានកំណើននៃចំនួនមនុស្សបម្រើការងារក្នុងវិស័យបដិសណ្ឋារកិច្ច ហើយតម្រូវឱ្យបង្កើនចំនួននៃកម្លាំងពលកម្មក្នុងឧស្សាហកម្មនៃសេវានេះបន្ថែមទៀត។ សណ្ឋាគារបាន និងកំពុងរីកដុះដាល ហើយភ្នាក់ងារទេសចរណ៍ និងក្រុមហ៊ុនបម្រើសេវាធ្វើដំណើរកំសាន្តក៏រីកដុះដាលដែរ មគ្គុទេសទេសចរណ៍ជំនាញដែលមានអាជ្ញាប័ណ្ណ ព្រលានយន្តហោះ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងផ្លូវដែកក៏មានការកើនឡើងដែរ។ ថ្វីបើមានអត្រាកំណើនខ្ពស់យ៉ាងនេះមែនជាមធ្យមក្នុងមួយឆ្នាំសណ្ឋាគារ និងភោជនីយដ្ឋាន មានកំណើនជាមធ្យម ១៥ភាគរយ ក៏វិស័យនេះនៅតែមាន ភាពងាយគ្រោះថ្នាក់ខ្លាំងដោយសារវិបត្តិអន្តរជាតិដែរដូចដែលវិស័យនេះធ្លាប់បានឆ្លងកាត់ការធ្លាក់ចុះក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុអាស៊ី (ឆ្នាំ១៩៩៧-១៩៩៨) ការរីករាលដាលជំងឺសារ (ឆ្នាំ២០០៣) និង វិបត្តិហិរញ្ញវត្ថុសកល (ឆ្នាំ២០០៨-២០០៩)។ ទេសចរណ៍បានឆ្លងកាត់បទពិសោធនៃការធ្លាក់ចុះនូវចំនួនទេសចរណ៍ប្រហែល ២.៣ភាគរយ ចាប់ពីឆ្នាំ ២០០៧-២០០៨។ យោងតាមក្រសួងទេសចរណ៍ដោយសារវិបត្តិសេដ្ឋកិច្ច វិស័យទេសចរណ៍នៅកម្ពុជាបានធ្លាក់ចុះ ១០,៧ ភាគរយ ក្នុងត្រីមាសទីមួយឆ្នាំ២០០៩ ធៀបទៅនឹងឆ្នាំមុន។ ទោះជាយ៉ាងណានៅត្រីមាសទីពីរ វិស័យនេះបានងើបឡើងវិញជាថ្មីក្នុងអត្រា ៤,៦៦ភាគរយ ធៀបនឹងរយៈដូចគ្នាក្នុងឆ្នាំកន្លងមក។

ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ មានភ្ញៀវទេសចរណ៍ក្នុងតំបន់មកពីប្រទេសមានប្រាក់ចំណូលមធ្យម និងប្រាក់ចំណូលទាប (វៀតណាម និងចិន) បានមកទស្សនាកម្ពុជាច្រើនជាងមុន។ ដោយសារការធ្លាក់ចុះនៃអត្រាស្នាក់នៅក្នុងសណ្ឋាគារ សណ្ឋាគារទំនើបៗជាច្រើនបានបិទទ្វារបណ្តោះអាសន្នក្នុងរយៈពេលមានវិបត្តិនេះ ហើយបុគ្គលិកសណ្ឋាគារបានឈប់សម្រាកពីការងារបណ្តោះអាសន្ន ឬត្រូវបានបញ្ឈប់ពីការងារ។

| *តារាង ៣.១ : ចំនួនប្រជាជនសរុបបម្រើការងារផ្ទាល់ក្នុងវិស័យទេសចរណ៍* | | |
|---|---|---|
| វិស័យ | ចំនួនការងារផ្ទាល់ | % |
| ការស្នាក់អាស្រ័យ | ១១,១១៧ | ២៩ |
| អាហារ និងភេសជ្ជៈ | ៨,២៨៧ | ១៥ |
| ការដើរទិញទំនិញ | ៤,២១២ | ៨ |
| ការដឹកជញ្ជូន | ១០,៤១៧ | ១៩ |
| មគ្គុទេសក៍ទេសចរ | ២,២៣៥ | ៤ |
| បុគ្គលិកព្រលានយន្តហោះ | ៥,២៧៤ | ១០ |
| ក្រុមហ៊ុនទេសចរណ៍ | ២,៦៦០ | ៥ |
| មន្ត្រីរាជការស៊ីវិលបម្រើការទាក់ទងនឹងទេសចរណ៍ | ៤,៧៦៣ | ៩ |
| ផ្សេងៗ | ១,០០០ | ២ |
| សរុប | ៥៤,៩៦៥ | ១០០ |

*ប្រភព : Naron, C.H ឆ្នាំ២០០៩។ សេដ្ឋកិច្ចកម្ពុជា : ការរៀបចំផែនការឆ្ពោះទៅរកអនាគតដ៏ប្រសើរ។ ការអង្កេតវឌ្ឍនភាពបញ្ហា និងចក្ខុវិស័យ ធនាគារអភិវឌ្ឍន៍អាស៊ី ទំព័រ ២៨៨។*

វិស័យទេសចរណ៍ផ្តល់កំណើនសេដ្ឋកិច្ចជាង ១៣ ភាគរយ នៃផលិតផលក្នុងស្រុកសរុបដោយ ៤ ភាគរយបានមកពីសេវាសណ្ឋាគារ និងភោជនីយដ្ឋាន។ ប៉ុន្តែសកម្មភាពរបស់ទេសចរច្រើនប្រមូលផ្តុំនៅតំបន់ជុំវិញប្រាសាទ ហេតុដូច្នេះទេសចរណ៍មិនបានរួមចំណែកដល់សេដ្ឋកិច្ចឱ្យបានធំជាងនេះនោះទេ។ ទេសចរភាគច្រើនទៅទស្សនាក្នុងតំបន់នានាក្នុងខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តកោះកុងដែលសម្បូរទៅដោយសណ្ឋាគារ។

តាមធម្មតាកញ្ចប់នៃជំនាញសម្រាប់អ្នកប្រតិបត្តិក្នុងវិស័យនេះ គឺទូលំទូលាយណាស់។ ជំនាញទាំងនេះគឺអាស្រ័យលើមុខនាទីបម្រើការងារ ប៉ុន្តែជាទូទៅជំនាញមូលដ្ឋានដែលត្រូវការចាំបាច់រួមមានបុគ្គលិកលក្ខណៈរួសរាយរាក់ទាក់ជំនាញប្រាស្រ័យទាក់ទងជំនាញកុំព្យូទ័រ អាកប្បកិរិយាល្អ អត់ធ្មត់ បុគ្គលិកលក្ខណៈចូលចុះក្នុងសង្គម ចំណេះដឹងទូទៅ រួមទាំងមានព័ត៌មាន និងចំណេះដឹងគ្រប់គ្រាន់អំពីការងារ ដើម្បីឆ្លើយតបទៅនឹងការរំពឹងចង់បានរបស់អតិថិជនជំនាញរៀបចំបន្ទប់សណ្ឋាគារ និងសមត្ថភាពចាត់ចែងការងារទាន់ពេលវេលា និងឆ្លើយតបតាមតម្រូវការអាជីវកម្មទេសចរណ៍។

ភាសាក្នុងវិស័យបដិសណ្ឋារកិច្ចជាជំនាញសំខាន់បំផុត គឺកំពុងប្រឈមនឹងការខ្វះចន្លោះយ៉ាងធំដោយនិយោជកតែ ១២ភាគរយ (CSES ២០០៨ និង NIS ២០០៨) បានអះអាងថា មាននិស្សិតបញ្ចប់ការសិក្សាដែលមានសមត្ថភាព ភាសា និងបច្ចេកទេសចាំបាច់សម្រាប់អនុវត្តការងារ។ ក្នុងវិស័យនេះជាធម្មតាភាសា

បរទេសមានតម្រូវការខ្លាំងណាស់ សូម្បីតែសម្រាប់និយោជិតគ្មានជំនាញដើម្បីបម្រើភ្ញៀវទេសចរ ផ្តល់សេវាដល់អតិថិជនប្រកបដោយគុណភាព និងរក្សាភាពប្រកួតប្រជែងក្នុងវិស័យដ៏សកម្មនេះ។ ដើម្បីបំពេញបន្ថែមលើឱនភាពនេះការស្វែងរកមនុស្សដែលមានជំនាញខ្លាំងទាក់ទងនឹងការធ្វើសេចក្តីសម្រេចចិត្ត និងការដោះស្រាយបញ្ហានៅតែពិបាក បើទោះបីជាការពិតបង្ហាញថា មុខនាទីទាំងនេះត្រូវការជាចាំបាច់សម្រាប់តំណែងគ្រប់គ្រងនៅគ្រប់កម្រិតក្នុងវិស័យនេះក៏ដោយ។ និយោជកមិនពេញចិត្តនឹងការខ្វះជំនាញផ្នែកទន់នៅគ្រប់កម្រិតទាំងអស់។ សម្រាប់ជំនាញបច្ចេកទេស គឺពិបាករកនិយោជិតដែលមានជំនាញខាងថែរក្សាសណ្ឋាគារ និងជំនាញរៀបចំបន្ទប់។ ការខ្វះជំនាញឥរិយាបថ ស្មារតីធ្វើការជាក្រុម និងស្វ័យសម្រេច ក៏ចាត់ទុកជាការលំបាកមួយដែរ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ក្នុងវិស័យ**បដិសណ្ឋារកិច្ច**នេះទៀត គឺថាលក្ខខណ្ឌតម្រូវអំពីការអប់រំក្នុងប្រព័ន្ធហាក់ដូចជាមិនសូវតឹងរឹងដូចវិស័យផ្សេងទៀតទេ។ ឧទាហរណ៍សម្រាប់មុខងារអាជីព និងមុខងារគ្រប់គ្រង (និយោជិតជំនាញ) និយោជកតែ ៤៤ ភាគរយប៉ុណ្ណោះ ទាមទារឱ្យមានសញ្ញាបត្រសាកលវិទ្យាល័យ និយោជក ៣៩ភាគរយទាមទារឱ្យមានការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់គ្រាន់ ហើយ១៧ភាគរយទៀត យ៉ាងហោចក៏ត្រូវការសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែរ។

*"... ការពង្រីកជំនាញការងារដោយមិនគិតអំពីកម្រិតការងារអ្វីដែលបុគ្គលម្នាក់កំពុងធ្វើនោះទេ គឺអាចលើកកម្ពស់ជម្រើសអាជីពបាន។"*

*រូប ៣.៦ : ការខ្វះចន្លោះធំៗនៃជំនាញក្នុងវិស័យបដិសណ្ឋារកិច្ចនៅកម្ពុជា*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០១០c ។ ទំព័រទី ៥៨។*

តម្រូវការជំនាញភាសាសម្រាប់និយោជិតគ្មានជំនាញពាក់កណ្តាលជំនាញ និងនិយោជិតជំនាញទាំងអស់ហាក់ដូចជាមិនទាក់ទងគ្នាទាំងស្រុងទេ ជាពិសេសសម្រាប់និយោជិតគ្មានជំនាញ និងនិយោជិតពាក់កណ្តាលជំនាញ។ ប៉ុន្តែការពង្រីកជំនាញការងារដោយមិនគិតអំពីកម្រិតការងារអ្វីដែលបុគ្គលម្នាក់កំពុងធ្វើនោះទេ គឺអាចលើកកម្ពស់ជម្រើសអាជីពបាន។ ឧទាហរណ៍ ការរៀនភាសាបរទេសលើកកម្ពស់ជំនាញការងាររួមរបស់បុគ្គលម្នាក់ និងធ្វើឱ្យនិយោជិតគ្មានជំនាញកាន់តែមានតម្លៃជាងមុន គឺតម្លៃជានិយោជិតម្នាក់។ ការរៀនភាសាបរទេសក៏ពង្រីកឱកាសសម្រាប់ជម្រើសនៃអាជីពការងារសម្រាប់អនាគតដែរ ហើយក៏អាចក្លាយជាសូចនាករដ៏សំខាន់មួយសម្រាប់ជម្រើសអាជីពការងារដ៏មានសក្តានុពលភាព និងអាចមានលទ្ធភាពសម្រេចលើវិថីអាជីពផ្សេងៗទៀតបានដែរ។

ការខ្វះសមត្ថភាព កើតមានឡើងជាខ្លាំងពាសពេញបំនែងនានានៃជំនាញនៅក្នុងសង្គមដែលទាមទារឱ្យមានជំនាញផ្សេងៗ។ បញ្ហានេះគួបផ្សំជាមួយការពិតថា ការបំពេញការងារហាក់ដូចជាមានការលំបាកក្នុងវិស័យបដិសណ្ឋារកិច្ច ជាពិសេស សម្រាប់មុខតំណែង ដូចជាមេចុងភៅ អ្នកទទួលភ្ញៀវ និងប្រធានគ្រប់គ្រងអាហារ និងភេសជ្ជៈ និងប្រធានគ្រប់គ្រងបារ។ ការបណ្តុះបណ្តាលក៏ហាក់ដូចជាមានបញ្ហាប្រឈមដ៏លំបាកមួយដែលត្រូវដោះស្រាយជាចាំបាច់ ព្រោះវិស័យ ទេសចរណ៍ បន្តដើរតួរនាទីដ៏សំខាន់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចរបស់កម្ពុជា និងគាំទ្រដល់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ។ អត្រាផ្លាស់ប្តូរកន្លែងការងាររបស់បុគ្គលិកក្នុងវិស័យទេសចរណ៍មានអត្រាខ្ពស់។

### ៣.៣.២.៣ ឱនភាពនៃមូលធនមនុស្សក្នុងវិស័យសំណង់

វិស័យសំណង់ ជាវិស័យមួយក្នុងចំណោមវិស័យដ៏មានសារៈសំខាន់បំផុតសម្រាប់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាកន្លងមក។ ក្នុងឆ្នាំ២០០៩ សំណង់មាន៧ភាគរយនៃផលិតផលក្នុងស្រុកសរុប ហើយការផ្តោតការយកចិត្តទុកដាក់ភាគច្រើនជាការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធក្នុងអំឡុងពេល ១៥ឆ្នាំ កន្លងមកនេះដែលបានចូលរួមចំណែកដល់កំណើនសកម្មភាពសំណង់។ អត្រាកំណើនប្រចាំឆ្នាំនៃវិស័យសំណង់មានជាមធ្យម ១៣ភាគរយ រវាងពីឆ្នាំ១៩៩៤ ដល់ ២០០៧ ដោយសារវិស័យសំណង់បានស្ទុះងើបឡើងចន្លោះពីឆ្នាំ ២០០២ និង ឆ្នាំ២០០៦ ដែលអត្រាកំណើននៃវិស័យសំណង់មានកម្រិតជិត ២០ភាគរយ។ ការស្ទុះ ងើបឡើងនៃវិស័យសំណង់នេះត្រូវបានជំរុញយ៉ាងពិសេសដោយសារគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងលំនៅឋានក្នុងទីក្រុង។

វិបត្តិសេដ្ឋកិច្ចសកលបានប៉ះពាល់ដល់វិស័យសំណង់នៅកម្ពុជានៅពាក់កណ្តាល ឆ្នាំ២០០៨ គឺប៉ះពាល់ដល់ការងារក្នុងវិស័យនេះប្រហែល ៥ភាគរយ។ វិបត្តិហិរញ្ញវត្ថុក៏កាត់បន្ថយតម្រូវការនៃអចលនទ្រព្យ ព្រោះការផ្គត់ផ្គង់អចលនទ្រព្យមានច្រើនធ្វើឱ្យតម្លៃនៃអចលនទ្រព្យធ្លាក់ចុះ។ គម្រោងសំណង់ប្រហែល ៣០ភាគរយ ត្រូវបានលុបចោល ឬកាត់បន្ថយ។ ក្នុងរយៈពេល ១១ខែដំបូងនៃឆ្នាំ២០០៨ កម្ពុជាមានគម្រោងសំណង់សរុប ១.៨៦៩គម្រោង ពោលគឺ ធ្លាក់ចុះពី ១.៩៤២ គម្រោងដែលមានក្នុង ឆ្នាំ២០០៧។ ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់បានឱ្យដឹងថាការធ្លាក់ចុះនៃគម្រោងសំណង់ភាគច្រើនជាគម្រោងទទួលមូលនិធិតាមរយៈការវិនិយោគបរទេសផ្ទាល់ ហើយដោយសារពិភពលោកប្រឈមនឹងការលំបាកក្នុងឆ្នាំ ២០១០ ការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យធ្វើឱ្យវិស័យសំណង់នៅនឹងថ្កល់។

ការខ្វះចន្លោះនៃមូលធនមនុស្សក្នុងវិស័យនេះ គឺងាយមើលឃើញណាស់ដោយនិយោជក ២០ភាគរយ ចាត់ទុកថា និស្សិតបញ្ចប់ការសិក្សាមានជំនាញគ្រប់គ្រាន់បំពេញតាមតម្រូវការ និងនៅមានការខ្វះខាតស្ថាបត្យករ និងវិស្វករ។ យោងតាមការអង្កេតនិយោជក និយោជក ៥៣ភាគរយ អះអាងថាមានការលំបាកបំផុតក្នុងការស្វែងរកមនុស្សមកបំពេញតួនាទីជាវិស្វករ ហើយនិយោជក ៤៧ភាគរយ ឆ្លើយថាពិបាកស្វែងរកអ្នកមានសមត្ថភាពសមស្របនឹងតំណែងជាស្ថាបត្យករណាស់។ ជាញឹកញាប់ក្រុមហ៊ុនត្រូវបង្ខំចិត្តជួលស្ថាបត្យករ និងវិស្វករបរទេសឱ្យមកគ្រប់គ្រងគម្រោង និងកាន់តួនាទីសំខាន់ៗ។ ភាពខុសគ្នារវាងសមត្ថភាពរបស់ស្ថាបត្យករ និងវិស្វករខ្មែរ និងបរទេស គឺនៅត្រង់សមត្ថភាពប្រើបច្ចេកវិទ្យាក្នុងការបំពេញការងារតាមការចង់បានរបស់និយោជក។ ប៉ុន្តែនៅពេលនិយោជកសង្កត់ធ្ងន់លើសារៈសំខាន់នៃជំនាញផ្នែកទន់ដែលផ្ទុយពីជំនាញបច្ចេកទេសនោះ ឧបសគ្គមួយក្នុងចំណោមឧបសគ្គដ៏ចម្បងកើតឡើងចេញពីការបន្ស៊ីខុសនៃបច្ចេកវិទ្យា។ ជំនាញផ្នែករឹង និងជំនាញផ្នែកទន់ ទំនងជាលក្ខណៈពិសេសទូទៅមួយនៃទីផ្សារការងាររបស់កម្ពុជាដែលជះឥទ្ធិពលដល់និយោជិតជំនាញមួយចំនួន និងនិយោជិតគ្មានជំនាញជាច្រើន។

ការបំពេញការងារជាច្រើនហាក់ដូចជាពិបាកក្នុងវិស័យសំណង់ ជាពិសេសការជួលនិយោជិកពាក់កណ្ដាលជំនាញឬគ្មានជំនាញដូចជា ជាងឈើ ជាងទឹក ជាងដែក និងជាងអគ្គិសនី។ ជំនាញភាគច្រើនដែលតម្រូវឱ្យកម្មករសំណង់ដែលមានជំនាញទាបមានដូចជា រៀនអានប្រភេទសញ្ញាមូលដ្ឋានឱ្យយល់ន័យត្រឹមត្រូវ ស្គាល់លេខ និងយល់រង្វាស់មាន ជំនាញទំនាក់ទំនង សង្គម និងការប្រាស្រ័យទាក់ទង អាកប្បកិរិយាក្នុងការគ្រប់គ្រង និងដោះស្រាយជម្លោះ។ ជំនាញទាំងអស់នេះ គឺការបូកផ្សំគ្នាទាំងជំនាញផ្នែកទន់ និងជំនាញផ្នែករឹងដែលក្រុមហ៊ុនព្យាយាមដោះស្រាយជាចាំបាច់។

### ៣.៣.២.៤ ឱនភាពនៃមូលធនមនុស្សក្នុងវិស័យកសិកម្ម

យោងតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ ឆ្នាំ២០១៥ ប្រការគួរកត់សម្គាល់គឺថា តម្រូវការផលិតផលកសិកម្មរបស់កម្ពុជានៅលើទីផ្សារអន្តរជាតិនៅតែខ្លាំងដដែល។ សំអាងលើនិន្នាការសេដ្ឋកិច្ចបច្ចុប្បន្នកំណើនម្ហូបអាហារភេសជ្ជៈ និងថ្នាំជក់ក៏រំពឹងថានៅមានកំណើនខ្លាំងដដែល គឺកើនប្រហែល ១៤ភាគរយ ថ្វីបើមានការពិតបញ្ជាក់ថាការវិនិយោគលើកសិអាជីវកម្មមានកម្រិតតិចតួចក៏ដោយ។ ទស្សនវិស័យនេះ មានមូលដ្ឋានដ៏ល្អមួយសម្រាប់អភិវឌ្ឍឧស្សាហកម្ម។ វិស័យនេះត្រូវការធនធានបន្ថែម និងយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់កសាងសមត្ថភាពផលិតកម្មក្នុងស្រុក និងសមត្ថភាពប្រកួតប្រជែង។ ដូចនេះ កិច្ចប្រឹងប្រែងទាំងនេះគប្បីផ្ដោតការយកចិត្តទុកដាក់លើការធ្វើពិពិធកម្មមូលដ្ឋានគ្រឹះនៃឧស្សាហកម្ម និងផ្ដោតលើការធ្វើទំនើបកម្មលើវិស័យនេះផងដែរ។ យ៉ាងណាមិញការចំណាយខ្ពស់លើការធ្វើយន្តកម្មបានបន្ទុចបង្អាក់ដល់ការចាប់ផ្ដើមអនុវត្តការធ្វើកសិកម្មបែបទំនើប។

ជាប្រវត្តិសាស្ត្រ កសិកម្មជា (និងនៅតែជា) វិស័យមួយនៃវិស័យដ៏សំខាន់បំផុតសម្រាប់កម្ពុជា។ វិស័យកសិកម្មមាន ២៩ភាគរយ នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០០៧ (ធ្លាក់ចុះពី៤៣,៧ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ១៩៩៨)[១៥]។ ដោយសារកម្ពុជាជាប្រទេសជនបទ កសិកម្មបានផ្គត់ផ្គង់ប្រជាជនជិត ៥៩ ភាគរយនៃប្រជាជនសរុប (World Bank ២០០៩)។ ការធ្វើកសិកម្មសម្រាប់ចិញ្ចឹមជីវិតមាន ៩០ភាគរយ ហើយ ១០ភាគរយទៀត ជាការធ្វើកសិកម្មជាលក្ខណៈអាជីវកម្ម។ ដោយសាររបរកសិកម្ម

១៥ Hang Chuon Naron, Cambodian Economy: carting the course of a brighter future, 2009 ។

*"ជាប្រវត្តិសាស្ត្រ កសិកម្មនៅតែជា ជាវិស័យមួយ នៃ វិស័យដែលសំខាន់ បំផុតសំរាប់កម្ពុជា។"*

សម្រាប់ចិញ្ចឹមជីវិតតែងប្រើកម្លាំងពលកម្មក្នុងគ្រួសារមិនចំណាយលើប្រាក់ឈ្នួល ទើបអាជីវកម្មកសិកម្មត្រូវជួលកម្មករចំណាកស្រុកឱ្យធ្វើការតាមរដូវកាល។

ការខ្វះខាតយន្តកម្មក្នុងវិស័យកសិកម្ម បានកើតមានពាសពេញផ្ទៃប្រទេស។ កម្ពុជាអាចដាំដំណាំក្នុងតម្លៃទាប ព្រោះតម្លៃនៃកម្លាំងពលកម្មថោក និងចំណាយតិចតួចលើធាតុបញ្ចូល។ ដោយសារប្រព័ន្ធផ្គត់ផ្គង់ដែលអាចបង្កើតចំណងទាក់ទងឱ្យកសិករមានឱកាសរកធាតុបញ្ចូលសម្រាប់ប្រើ ដូចជា ជី និងទីផ្សារ មានការអភិវឌ្ឍយឺតទើបការអភិវឌ្ឍវិស័យនេះមានបញ្ហានៃការខ្វះសមត្ថភាពដោយសារខ្វះមូលធនការងារ។

និយាយអំពីមូលធនមនុស្សក្នុងវិស័យកសិកម្ម ចំណុចខ្លាំងមួយសម្រាប់ការបង្កើនសមត្ថភាពឧស្សាហកម្មនេះឱ្យកាន់តែប្រសើរឡើង គឺភាពសម្បូរកម្លាំងពលកម្មក្នុងតម្លៃទាបនៅទីជនបទ និងភាពសម្បូរបែបនៃស្ថានប្រព័ន្ធសម្រាប់កសិកម្មដែលផ្តល់ដីជាច្រើនប្រភេទ (ទោះបីជាដីនៅកន្លែងជាច្រើនមានជីជាតិខ្សោយក៏ដោយ)។ ប៉ុន្តែការធ្វើកសិកម្មទំនើបប្រឈមនឹងបញ្ហាជាច្រើនក្នុងការផ្ទេរបច្ចេកវិទ្យារបៀបរកបច្ចេកវិទ្យាមកប្រើ និងជំនាញរបស់កសិករ និងរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម។ ប៉ុន្តែការអភិវឌ្ឍវិស័យនេះឱ្យប្រសើរអាចបន្ថែមតម្លៃសេដ្ឋកិច្ចដល់កសិកម្មផលចម្បងដែលអាចបើកផ្លូវឱ្យកសិកចាកចេញពីកសិកម្មបែបចិញ្ចឹមជីវិតប្រចាំថ្ងៃ និងលើកទឹកចិត្តឱ្យកសិករចូលរួមក្នុងទីផ្សារកិសកម្ម ពោលគឺ ជាវិស័យមួយដែលកសិករមិនដែលធ្លាប់ចូលរួមពេញលេញពីមុនមកទេ។

### ៣.៣.២.៥ ឱនភាពនៃមូលធនមនុស្សក្នុងវិស័យរ៉ែ[១៦]

ក្នុងតំណាក់កាលបច្ចុប្បន្ននេះ វិស័យរ៉ែរបស់កម្ពុជាមានប្រតិបត្តិការរ៉ែឧស្សាហកម្មដែលជាទូទៅបំពេញតម្រូវការទីផ្សារក្នុងស្រុក មានរ៉ែលោហៈគ្មានតម្លៃ និងមានតម្លៃភាគច្រើនស្ថិតក្នុងតំណាក់កាលរុករកនៅឡើយ។ នៅកម្ពុជាមានប្រតិបត្តិការរុករករ៉ែមាសលក្ខណៈជំនាញផ្ទាល់ខ្លួន និងខ្នាតតូច។ ពេលបច្ចុប្បន្ននេះការរុករករ៉ែនេះបានផ្តល់កំណើនសេដ្ឋកិច្ចប្រហែល ៤ភាគរយនៃផលិតផលក្នុងស្រុកសរុប។

ធនធានរ៉ែរបស់កម្ពុជាភាគច្រើន នៅពុំទាន់បានរុករកនៅឡើយ ទោះបីជាមានការរុករកឃើញរ៉ែសំខាន់ៗមួយចំនួនក្តី ដែលរ៉ែទាំងនោះរួមមាន រ៉ែបុកស៊ីត ទង់ដែង រ៉ែមាស រ៉ែដែក ត្បូងថ្ម ពេជ្រ ត្បូង និងរ៉ែដែកខ្មៅ។ បច្ចុប្បន្នរ៉ែដែលបានធ្វើនិស្សារណកម្ម រួមមាន ពេជ្យ ត្បូង និងរ៉ែមាស (ភាគច្រើនប្រតិបត្តិការខ្នាតតូច) ថ្មកែវ ថ្មក្រានីត ខ្សាច់ ថ្មកំបោរ និងអំបិល។ ផលិតកម្មរ៉ែនៅកម្ពុជា មានការកើនឡើងជាលំដាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហេតុដូចនេះអាជ្ញាប័ណ្ណរុករករ៉ែមួយចំនួនត្រូវបានផ្តល់ឱ្យក្រុមហ៊ុនបរទេស និងក្នុងស្រុក។ ទោះបីជាការរុករករ៉ែបានធ្លាក់ចុះហក្នុងអំឡុង ពេលមានវិបត្តិហិរញ្ញវត្ថុក៏ដោយក៏ក្នុងពេលថ្មីៗនេះ កំណើននៃតម្លៃរ៉ែកើនឡើងជាលំដាប់ដែរ (ឧ. តម្លៃមាសបច្ចុប្បន្នកើនឡើងដល់កម្រិតខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រ) ជំរុញឱ្យមានចំណាប់អារម្មណ៍ក្នុងការរុករក និងអភិវឌ្ឍធនធានរ៉ែនៅកម្ពុជា។

ដើម្បីអភិវឌ្ឍន៍វិស័យរ៉ែនិងប្រេងកាតឱ្យបានជោគជ័យ កម្ពុជាចាំបាច់ត្រូវបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងលើវិស័យនេះឱ្យមានប្រសិទ្ធភាព។ ការអភិវឌ្ឍសមត្ថភាពនេះ គឺនិយាយអំពីការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពក្នុងវិស័យសាធារណៈបង្កើនកម្រិតជំនាញដែលត្រូវការចាំបាច់សម្រាប់គ្រប់គ្រង និង

---

១៦ ផ្នែកនេះនៅមានកម្រិតដោយសារតែកង្វះខាតទិន្នន័យ និងព័ត៌មាន។

ធ្វើកិច្ចសន្យាលើការរុករករ៉ែប្រេងកាត និងរ៉ែផ្សេងៗទៀត។ ដូច្នេះ ការអភិវឌ្ឍសមត្ថភាពគួរផ្តោតការយកចិត្តទុកដាក់លើសមត្ថភាពបុគ្គល និងសមត្ថភាព បច្ចេកទេសរបស់មនុស្ស និងស្ថាប័ន។ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានចុះកិច្ចសន្យាលើអនុស្សរណៈយោគយល់គ្នាមួយកាលពី ខែមករា ឆ្នាំ២០១១ ដែលផ្តោតការយកចិត្តទុកដាក់លើការពង្រឹងគោល-នយោបាយបទដ្ឋានគតិយុត្តិ និងសមត្ថភាពរបស់នាយកដ្ឋានគតិយុត្តិផ្នែករ៉ែរបស់កម្ពុជា។ UNDP កំពុងធ្វើការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ដទៃទៀតដើម្បីបង្កើនជំនាញ និងសមត្ថភាពបុគ្គលិករបស់អាជ្ញាធរជាតិប្រេងកាតកម្ពុជា។ ជាពិសេសសម្រាប់ឧស្សាហកម្មប្រេងកាតកម្ពុជាបានបង្ហាញចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍឧស្សាហកម្មនេះក្នុងស្រុក។ ប៉ុន្តែ ប្រទេសនេះបានទទួលស្គាល់ថា ឧស្សាហកម្មប្រេងកាតត្រូវការដើមទុនច្រើន និងត្រូវការកម្លាំងពលកម្មតិចតួច។ ការពិតគឺខុសពីកម្លាំងពលកម្មក្នុងដំណាក់កាលដំបូងដែលត្រូវការសម្រាប់ការសាងសង់រោងចក្រ កម្លាំងពលកម្មសម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្មនេះ ជាទូទៅចាំបាច់ត្រូវមានឯកទេស និងជំនាញខ្ពស់។ កត្តានេះ ជាញឹកញាប់ត្រូវជួលជនជាតិបរទេសពីក្រុមហ៊ុនពាក់ព័ន្ធឧស្សាហកម្មនិស្សារណកម្ម[១៧]ឱ្យចូលមកក្នុងប្រទេសផ្ទាល់ដើម្បីបំពេញការងារក្នុងតំណែងខ្ពស់មួយចំនួន ហើយបញ្ហានេះក៏តំណាងឱ្យវិស័យមួយផ្សេងទៀតដែលកម្រិតនៃការអប់រំខ្ពស់ជាងនេះនឹងផ្តល់ផលចំណេញត្រលប់មកវិញសម្រាប់សេដ្ឋកិច្ចកម្ពុជាផងដែរ។

ការខ្វះខាតនៃកម្លាំងពលកម្ម និងខ្វះជំនាញឯកទេសក្នុងអាជ្ញាធររ៉ែ និងប្រេងកាតជាបញ្ហាប្រឈមគន្លឹះ។ គ្រឹះស្ថានអប់រំកម្ពុជាដែលបានបណ្តុះបណ្តាលអ្នកបច្ចេកទេសផ្នែកភូគព្ភសាស្ត្រ និងរ៉ែព្រមទាំងកំពុងបណ្តុះបណ្តាលវិស្វករបានផ្អាក់ដំណើរការក្នុងទសវត្សរ៍១៩៩០។ ការផ្អាកការបណ្តុះបណ្តាលនេះបានបណ្តាលឱ្យធនធានមនុស្ស ដូចជា ភូគព្ភវិទូត្រូវបាននាំយកមកផ្ទាល់ពីប្រទេសផ្សេងៗ ដោយចំណាយលើប្រាក់បៀវត្សរ៍ខ្ពស់សម្រាប់អ្នកទាំងនោះ។ ដើម្បីតបនឹងតម្រូវការដ៏ចាំបាច់នេះ UNDP កំពុងធ្វើការជាដៃគូជាមួយវិទ្យាស្ថានបច្ចេកវិទ្យានៃកម្ពុជាដើម្បីបើកដំណើរការសាលាភូគព្ភសាស្ត្រ និងវិស្វកម្មកម្ពុជាឡើងវិញ។ នាយកដ្ឋានធនធានភូមិសាស្ត្រ និងវិស្វកម្មភូមិសាស្ត្រ បច្ចេកទេសថ្មី អាចបើកដំណើរការនៅ ចុងឆ្នាំ២០១១ ហើយនិស្សិតបញ្ចប់ការសិក្សាផ្នែកនេះនឹងមានជាលើកទីមួយនៅ ឆ្នាំ២០១៥។

### ៣.៣.២.៦ ឱនភាពនៃមូលធនមនុស្សក្នុងវិស័យពត៌មានវិទ្យា

បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍នៅកម្ពុជាបាននិងកំពុងរីកដុះដាលយ៉ាងឆាប់រហ័ស និងត្រូវបានព្យាករថាកំពុងបង្កើតប្រាក់ចំណូលបានលើសពី ៤២៩ លានដុល្លាសហរដ្ឋអាមេរិចក្នុងមួយឆ្នាំ។ យ៉ាងណាក៏ដោយបញ្ហាប្រឈមសម្រាប់ការលូតលាស់ក្នុងវិស័យនេះ រួមមានប្រព័ន្ធអ៊ិនធឺណែតមានតម្លៃខ្ពស់ មនុស្សដែលមានគុណវុឌ្ឍិសិក្សាក្នុងវិស័យនេះមានតិចតួច ដែលរារាំងកម្ពុជាក្នុងការចូលរួមប្រកួតប្រជែងលើទីផ្សារអន្តរជាតិ។ បញ្ហាប្រឈមទាំងនេះ មើលឃើញយ៉ាងជាក់ច្បាស់ ជាពិសេសនៅពេលប្រៀបធៀបជាមួយប្រទេសផ្សេងទៀត ដូចជា ឥណ្ឌា ដែលជាប្រទេសបានវិនិយោគយ៉ាងសម្បើមលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍នេះ។ បច្ចុប្បន្នវិស័យនេះកំពុងចូលរួមចំណែកយ៉ាងខ្លាំងដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសនេះតាមរយៈការនាំចេញ។

---

១៧ ការរក្សានិរន្តរភាពកំណើនសេដ្ឋកិច្ចឆាប់រហ័សក្នុងបរិស្ថានប្រកួតប្រជែង របាយការណ៍ចុងក្រោយរបស់ធនាគារពិភពលោក ឆ្នាំ២០០៩។

សង្គ្រាមស៊ីវិល បានរារាំងវិស័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍យ៉ាងខ្លាំងនៅកម្ពុជា។ ឧទាហរណ៍ កម្ពុជាទទួលបានអត្រាទាបបំផុតផ្នែកទូរស័ព្ទខ្សែកាបក្រោមដីលាតសន្ធឹងនៅទូទាំងប្រទេសក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ាន។

*រូប ៣.៧ : បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍នៅកម្ពុជា ធៀបនឹងប្រទេសផ្សេងៗ នៅអាស៊ាន (ទូរស័ព្ទអចល័តខ្សែកាបក្រោមដី)*




*ប្រភព : ITU (ឆ្នាំ២០០៨)។*

ការវាយតម្លៃសមស្របចំពោះផលប៉ះពាល់នៃវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍នៅកម្ពុជា មិនមែនជារឿងងាយស្រួលទេ ដោយសារការខ្វះខាតទិន្នន័យក្នុងវិស័យនេះ។ ទោះជាយ៉ាងនេះក៏ដោយ និន្នាការទូទៅបង្ហាញថា គ្រួសារជាច្រើននៅប្រទេសកំពុងអភិវឌ្ឍ ដូចជាកម្ពុជាខ្វះលទ្ធភាពទទួលបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ រួមទាំងកុំព្យូទ័រ និងអ៊ិនធឺណែត។ សូចនាករជាប្រពៃណី ដូចជា អតិថជនប្រើប្រាស់បណ្តាញទូរស័ព្ទអចល័ត និងទូរស័ព្ទចល័តនៅពុំទាន់សមល្មមក្នុងការកំណត់ឱ្យបាននូវវិសាលភាពនៃគម្លាតជាមួយនឹងអ្នកប្រើប្រាស់ប្រព័ន្ធឌីជីថលនោះទេ ប៉ុន្តែនេះនៅតែអាចបង្ហាញអំពីតម្រូវការដើម្បីកំណត់សហគមន៍ និងសាធារណៈជនក្នុងការទទួលបានបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ក្រៅពីវិធីសាស្ត្រប្រពៃណីនោះទេ។ ការលើកឡើងទាំងអស់នេះរួមបញ្ចូលទាំងការប្រើប្រាស់សូចនាករទូលំទូលាយជាងនេះ ដើម្បីវាស់វែងលទ្ធភាពទទួលបានបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍របស់សហគមន៍រួមទាំងការតាមដានទៅលើកម្រិតគិតជាភាគរយនៃការទទួលបានបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍តាមសហគមន៍ក្នុងភូមិ និងទីក្រុងដែលតភ្ជាប់ប្រព័ន្ធទូរស័ព្ទអចល័ត និងទូរស័ព្ទចល័តសាធារណៈ និងសហគមន៍ដែលមានលទ្ធភាពប្រើប្រាស់មជ្ឈមណ្ឌលអ៊ិនធឺណែតសាធារណៈ ទោះបីជាការទទួលបាននេះចាប់ផ្តើមពីមធ្យោបាយជាមូលដ្ឋានដំបូងបំផុតក្តី។

កត្តាមួយចំនួន បានបង្កការរារាំងដល់សមត្ថភាពប្រកួតប្រជែងលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដែលក្នុងចំណោមកត្តាទាំងនោះមានការចំណាយលើអ៊ីធើណិតមានកម្រិតខ្ពស់ (ជាតម្លៃខ្ពស់បំផុតទីពីរក្នុងចំណោមប្រទេសនៅអាស៊ាន ដោយមានតម្លៃ ៤០០ដុល្លាអាមេរិកក្នុង ១ MB bandwidth)

ហើយបុគ្គលិកផ្នែកបច្ចេកវិទ្យាពតិមាន និងទូរគមនាគមន៍ដែលមានគុណវុឌ្ឍិសិក្សាគ្រប់គ្រាន់នៅកម្ពុជាមានតិចតួច។ កត្តាទាំងអស់នេះបានរារាំងដល់សមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យនេះ។ យោងតាមវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (២០០៩)[១៨] និយោជកប្រឈមនឹងការខ្វះកម្លាំងពលកម្ម និងអត្រាផ្លាស់ប្តូរការងាររបស់និយោជិតខ្ពស់។ ទោះបីជាយ៉ាងណានិយោជិតដែលមានបទពិសោធការងារ ២ឬ៣ឆ្នាំ ទទួលបានប្រាក់បៀវត្សរ៍ទាបរហូតដល់៦០០ដុល្លារ ក្នុង១ខែ ដែលបង្ហាញពីតម្រូវការខ្ពស់ចំពោះនិយោជិតដែលមានជំនាញក្នុងវិស័យនេះ ខណៈពេលប្រាក់ឈ្នួលមានចំនួនប្រហាក់ប្រហែលគ្នាទៅនឹងនិយោជិតជំនាញក្នុងប្រទេសវៀតណាម ហើយកម្ពុជាមានកម្រិតទាបជាងខ្លាំង បើធៀបនឹងប្រទេសវៀតណាម។ មានការលើកឡើងថារាជរដ្ឋាភិបាលគួរពិចារណាបង្កើតគម្រោងទទួលស្គាល់ស្តង់ដារមួយសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងរួមបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាដើម្បីធ្វើឱ្យមានជំនាញកាន់តែប្រសើរ និងបង្កើនចំនួនអ្នកមានវិជ្ជាជីវៈដែលមានសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន និងទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព។

តាមរយៈផែនកាយុទ្ធអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) រាជរដ្ឋាភិបាលកម្ពុជា បង្ហាញឱ្យឃើញពីការតាំងចិត្តយ៉ាងមុតមាំរបស់ប្រទេសក្នុងការស្វែងរកព្រំដែនសេដ្ឋកិច្ចថ្មី និងថែរក្សាវិស័យដែលមានស្រាប់ និងវិស័យដែលកំពុងស្ទុះងើបឡើង ដូចជា វិស័យបច្ចេកវិទ្យាពតិមាន និងទូរគមនាគមន៍ រួមទាំងទូរសព្ទ ទូរគមនាគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ។ ជាពិសេស ជាមួយនឹងការកើនឡើងនៃការប្រកួតប្រជែងដែលភាគច្រើននាំមុខដោយក្រុមហ៊ុនប្រតិបត្តិការឯកជន កម្ពុជាបានបោះជំហានទៅមុខដ៏គួរឱ្យកត់សម្គាល់ក្នុងការប្រើប្រាស់ទូរសព្ទចល័ត។ ការប្រើប្រាស់វិច្ចេកវិទ្យាកុំព្យូទ័រក៏បាន និងកំពុងរីកដុះដាលលឿនព្រមគ្នាផងដែរ ស្របពេលដែលអ្នកជំនាញក្នុងចំណោមយុវជនក៏កំពុងកើនឡើងច្រើនដែរ។

"ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) រាជរដ្ឋាភិបាលកម្ពុជា បង្ហាញឱ្យឃើញពីការតាំងចិត្តយ៉ាងមុតមាំរបស់ប្រទេសក្នុងការស្វែងរកព្រំដែនសេដ្ឋកិច្ចថ្មី។"

រដ្ឋាភិបាលលើកឡើងក្នុងផែនការអភិវឌ្ឍន៍ជាតិថា ខ្លួនមានបំណងបន្តពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាព តាមរយៈការលើកកម្ពស់ការគ្រប់គ្រងបុគ្គលិក និងការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល។ រាជរដ្ឋាភិបាលក៏មានគោលបំណងបង្កើតបរិស្ថានអំណោយផលដើម្បីទាក់ទាញវិនិយោគិនឯកជនទាំងក្នុងស្រុក និងបរទេសដើម្បីធានាឱ្យការផ្ទេរចំណេះធ្វើ និងបច្ចេកទេសទៅដល់គ្រប់ផ្នែកទាំងអស់របស់សង្គមដែលមានចាប់ពីវិស័យកសិកម្មរហូតដល់ឧស្សាហកម្ម និងសេវាកម្ម។

## ៣.៤ អន្តរាគមន៍ថ្មីៗដើម្បីបំពេញការខ្វះចន្លោះនៃចំណេះដឹង និងជំនាញក្នុងចំណោមនិយោជិតនៅកម្ពុជា

ក្នុងបរិបទមួយដែលមានយុវជនជាច្រើននាក់ចូលក្នុងទីផ្សារការងារមានជំនាញផ្នែករឹង និងជំនាញផ្នែកទន់តិចតួច តើមានជម្រើសគោលនយោបាយល្អបំផុតសម្រាប់ប្រទេសដែលមានការអភិវឌ្ឍដូចប្រទេសកម្ពុជានេះដែរឬទេ?

១៨ វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) ការសិក្សាអំពីភាពប្រកួតប្រជែងកម្ពុជា ឆ្នាំ២០០៩។

*"វិញ្ញាបនបត្រ ការទទួលស្គាល់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុត្រូវបានស្នើឡើង ដើម្បីលើកកម្ពស់កម្មវិធីបណ្តុះបណ្តាលដែលពាក់ព័ន្ធ និងលើកកម្ពស់គុណភាពនៃកម្មវិធីបណ្តុះបណ្តាលក្រៅប្រព័ន្ធ ។"*

ឧបសគ្គធំៗ ចំពោះការអភិវឌ្ឍជំនាញនៅកម្ពុជាដែលត្រូវជម្នះដោះស្រាយរួមមាន (១) អត្រាបោះបង់ការសិក្សា (២) គុណភាពអប់រំខ្សោយនិង (៣) តម្រូវការបណ្តុះបណ្តាលសម្រាប់យុវវ័យក្រៅសាលាដែលមានឱកាសតិចតួចក្នុងការចូលរួមក្នុងការអប់រំក្នុងប្រព័ន្ធ ។ ជាពិសេស ការធ្វើអន្តរាគមន៍ចុងក្រោយអាចមានផលប៉ះពាល់ខ្លាំងលើកម្លាំងពលកម្មនាពេលបច្ចុប្បន្នរបស់កម្ពុជា ។ វិញ្ញាបនបត្រ ការទទួលស្គាល់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុត្រូវបានស្នើឡើងដើម្បីលើកកម្ពស់កម្មវិធីបណ្តុះបណ្តាលដែលពាក់ព័ន្ធ និងលើកកម្ពស់គុណភាពនៃកម្មវិធីបណ្តុះបណ្តាលក្រៅប្រព័ន្ធ ។ អនុសាសន៍គោលនយោបាយរយៈពេលខ្លីចំនួនបីត្រូវបានព្រាងឡើងសម្រាប់កម្ពុជាដើម្បីបំពេញបន្ថែមខ្វះចន្លោះនៃចំណេះដឹង និងការងារដែលមានលើកឡើងក្នុងជំពូក៦ ។

### ៣.៤.១ ពិពិធកម្មឧស្សាហកម្ម និងការខ្វះចន្លោះនៃជំនាញនៅកម្ពុជា

សមាសភាពនាពេលបច្ចុប្បន្ននៃសេដ្ឋកិច្ចកម្ពុជា បង្ហាញថាវិស័យដែលបានកំពុងរួមចំណែកយ៉ាងខ្លាំងដល់ផលិតផលក្នុងស្រុកសរុបបាន និងកំពុងផ្លាស់ប្តូរយ៉ាងខ្លាំង ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០៩ ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីការផ្លាស់ប្តូរពីកសិកម្មទៅរកឧស្សាហកម្ម ។ ការបែងចែកការងារឆ្លុះបង្ហាញឱ្យឃើញអំពីការផ្លាស់ប្តូរទាំងនេះ ។ វិស័យឧស្សាហកម្ម (ភាគច្រើនជាវិស័យកាត់ដេរ) វិស័យសេវាកម្ម (ទេសចរណ៍ជាវិស័យដ៏ចម្បង) និងវិស័យកសិកម្ម (ពឹងអាស្រ័យខ្លាំងលើការធ្វើស្រូវ) ជាវិស័យឈានមុខនៃសេដ្ឋកិច្ចកម្ពុជា និងជាមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សកាលពីអតីតកាល ។ ទោះបីជាយ៉ាងណាភាពរីកចម្រើនក្នុងវិស័យទាំងនេះមិនអាចផ្គត់ផ្គង់ការងារ និងបង្កើនប្រាក់ចំណូលឱ្យបានគ្រប់គ្រាន់ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍជាតិបានទេ ។ ក្នុងបរិបទនៃការអភិវឌ្ឍឧស្សាហកម្មមិនត្រូវគិតគូរពិចារណាត្រឹមតែអំពីកម្លាំងពលកម្មទាបបែបប្រពៃណី និងវិស័យផលិតផលមានតម្លៃទាបនោះទេ ។

ដូច្នេះ ពិពិធកម្មសេដ្ឋកិច្ចទាមទារឱ្យមានការបង្កើនជំនាញរបស់និយោជិតដែលមានជំនាញទាបស្វែងរកឱកាសពង្រីកសេដ្ឋកិច្ចឱ្យស្របតាមខ្សែចង្វាក់តម្លៃកំណត់រក និងបង្កបរិយាកាសអំណោយផលសម្រាប់ឧស្សាកម្មថ្មី ។ ការងើបឡើងនៃវិស័យឧស្សាហកម្មរ៉ែ ឧស្ម័ន និងប្រេងកាត និងកសិកម្មបង្ហាញឱ្យឃើញអំពីឱកាសសម្រាប់ប្រទេសកម្ពុជា ។ ទស្សនៈជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក៏បានលើកឡើងក្នុងយុទ្ធសាស្ត្រពិពិធកម្មរបស់រដ្ឋាភិបាលផងដែរ ។ ការសម្រេចបានទស្សនៈនេះ ពិតជាមានឧសបគ្គប៉ុន្តែការទាញយកប្រយោជន៍ពីសេដ្ឋកិច្ចសកលលោក និងពីសេដ្ឋកិច្ចតំបន់អាចធ្វើឱ្យកម្ពុជាបង្កើតសេដ្ឋកិច្ចទីផ្សារមួយថ្មី ហើយពិតជាអាចកាត់បន្ថយភាពក្រីក្រ និងបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាមិនខានឡើយ ។

ទោះជាយ៉ាងណា ក្នុងការដោះស្រាយកាខ្វះខាតជំនាញប្រការសំខាន់ត្រូវបង្កើត និងបង្កើនយន្តការសម្របសម្រួលរវាងអ្នកដែលនឹងក្លាយជានិយោជក និងអ្នកផ្តល់ការអប់រំ និងការបណ្តុះបណ្តាលតាមរយៈការបង្កើនបរិមាណសេវាផ្តល់ការបណ្តុះបណ្តលសាធារណៈ និងការលើកទឹកចិត្តឱ្យមានការសិក្សានៅកន្លែងធ្វើការងារដែរ ។ ការយកចិត្តទុកដាក់នេះគួរផ្តោតលើការលើកកម្ពស់លទ្ធភាពទទួលបានការអភិវឌ្ឍជំនាញ

ប្រកបដោយគុណភាពនៅក្រៅតំបន់ទីប្រជុំជនដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ ដោយបង្កើតប្រព័ន្ធសម្រាប់ការទទួលស្គាល់តម្លៃការសិក្សាកន្លងមក និងកំណត់គោលដៅបណ្តុះបណ្តាលសហគ្រិនភាពដើម្បីលើកកម្ពស់សហគ្រាស និងអាចបង្កបរិយាកាសចុះបញ្ជីសហគ្រាសខ្នាតតូចជាផ្លូវការឱ្យបានច្រើនដែរ។

## ៣.៤.២ អន្តរាគមន៍ចំគោលដៅ

ការលើកកម្ពស់ជំនាញត្រូវការអភិក្រមមុខពីរ សម្រាប់ដោះស្រាយតម្រូវការភ្លាមៗរបស់វិស័យឯកជន។ ឧបសគ្គចម្បងមួយដែលក្រុមហ៊ុនជាច្រើនប្រឈមទាក់ទងនឹងការបណ្តុះបណ្តាលជំនាញមូលដ្ឋាន គឺរួមមានឥរិយាបថចំពោះការងារ។ ដូច្នេះការបណ្តុះបណ្តាលជំនាញមូលដ្ឋានចាំបាច់ត្រូវតែទទួលបានការពង្រឹង និងពង្រីកនៅទូទាំងប្រទេស។ ក្រុមហ៊ុនក៏ប្រឈមនឹងការលំបាកក្នុងការស្វែងរកមនុស្សដែលមានជំនាញឯកទេសផងដែរ។ ដូច្នេះ គួរមានការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាពយន្តការចែកចាយស្របពេលដែលមានការបង្កើនលទ្ធភាពចូលរួមក្នុងមណ្ឌលបណ្តុះបណ្តាល ដោយសហការជាមួយសមាគមអាជីវកម្ម និងសាកលវិទ្យាល័យនានា និងដោយបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលដែលគ្រប់គ្រងដោយសម្ព័ន្ធនៃក្រុមហ៊ុនឯកជន។

វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមានទំហំធំធេងកំពុងគ្របដណ្តប់លើសេដ្ឋកិច្ចកម្ពុជា។ ជារឿយៗវិស័យនេះត្រូវបានគិតថាពិបាកអភិវឌ្ឍឱ្យទៅជាឧស្សាហកម្មណាស់។ សហគ្រាសខ្នាតតូច និងមធ្យមទាំងនេះមានប្រភពផលិតកម្មចម្បងៗសម្រាប់កម្ពុជា ប៉ុន្តែ សេដ្ឋកិច្ចផ្នែកនេះត្រូវការបច្ចេកវិទ្យាទាន់សម័យ និងជំនួយយ៉ាងច្រើនសម្រាប់កែលម្អ និងត្រៀមខ្លួនចូលប្រកួតប្រជែងក្នុងតំបន់ និងលើពិភពលោក។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ និងវត្តមានឥណទាន តាមរយៈធនាគារពាណិជ្ជអាចបង្កើតឱកាសឱ្យមានសហគ្រាសខ្នាតតូច និងមធ្យម បើកចំហរទីផ្សារ និងលូតលាស់កាន់តែលឿន ដូចជាសហគ្រាសអាហារ ភេសជ្ជៈ ថ្នាំជក់ សម្ភារៈសំណង់ ។ល។

ការខ្វះការការពារពីសង្គម គឺជាទិដ្ឋភាពដ៏សំខាន់បំផុតមួយរបស់និយោជិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូច្នេះការបង្កើតប្រព័ន្ធបង្កើនការការពារសុវត្ថិភាពសង្គមសម្រាប់និយោជិតទាំងបុរសនិងស្ត្រីធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធក៏មានសារៈសំខាន់ផងដែរ។

ក្នុងយុទ្ធសាស្ត្រពិពិធកម្មឧស្សាហកម្មរបស់រាជរដ្ឋាភិបាលសម្រាប់ធានាកំណើននៃវិស័យដ៏មានសក្តានុពលនៅកម្ពុជាមានកំណត់អំពីកាលានុវត្តភាពជាច្រើន រួមមាន (១) វិស័យកសិកម្ម (ដី កម្លាំងពលកម្ម) (២) វិស័យកាត់ដេរ សំលៀកបំពាក់ ស្បែកជើង និងគ្រឿងតុបតែង (ឱកាសពាណិជ្ជកម្ម កម្លាំងពលកម្ម) (៣) វិស័យទេសចរណ៍ (ភាពអំណោយផល)។ សម្រាប់ការអភិវឌ្ឍឧស្សាហកម្មថ្មីទាំងនេះ កម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់លើឧត្តមភាពប្រកួតប្រជែងតាមវិស័យ និងតាមរយៈការយល់ដឹង និងការចាប់យកតម្លៃបន្ថែមក្នុងឧស្សាហកម្មដែលមានស្រាប់ដែលអាចឱ្យកម្ពុជាប្រកួតប្រជែងបានយ៉ាងប្រសើរក្នុងទីផ្សារអន្តរជាតិ។ ទោះបីជាយ៉ាងណាតាមវិធីណាក៏ដោយដែលកម្ពុជាសម្រេចយកមកប្រើប្រាស់ការអភិវឌ្ឍជំនាញរបស់និយោជិតនៅតែជាលក្ខខណ្ឌតម្រូវសម្រាប់ភាពជោគជ័យក្នុងការអភិវឌ្ឍរបស់កម្ពុជាដែរ។

"...គួរមានការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាពយន្តការចែកចាយស្របពេលដែលមានការបង្កើនលទ្ធភាពចូលរួមក្នុងមណ្ឌលបណ្តុះបណ្តាល។"

# ជំពូកទី ៤ : មូលធនមនុស្សក្នុងរដ្ឋាភិបាល និង វិស័យមិនរកប្រាក់ចំណេញនៅកម្ពុជា

## ៤.១ សេចក្តីផ្តើម

ការពិភាក្សាកន្លងមកអំពីមូលធនមនុស្ស សមត្ថភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើការខ្វះចន្លោះនៃជំនាញ និងតម្រូវការនៃការបណ្តុះបណ្តាល និងអប់រំដែលពាក់ព័ន្ធនឹងការខ្វះចន្លោះនៃជំនាញរបស់និយោជិតក្នុងវិស័យឯកជន។ ការពិក្សានេះគឺអាចយល់បានដោយសារមានភាពធ្ងន់ធ្ងរនៃការធ្លាក់ចុះនៃសេដ្ឋកិច្ច និងតម្រូវការនៃការបង្កើតការងារថ្មីតាមរយៈការស្តារសេដ្ឋកិច្ចឱ្យមានភាពប្រសើរឡើងវិញ។ លើសពីនេះទៀតការពិភាក្សានេះមានបំណងស៊ីជំរៅលើសារៈតារនៃបញ្ហាមូលធនមនុស្សក្នុងប្រទេសទាំងមូល ដូចជា បញ្ហាទាក់ទងនឹងរដ្ឋាភិបាល និងទីភ្នាក់ងារមិនស្វែងរកប្រាក់ចំណេញ ដូចជា សមាគមវិជ្ជាជីវៈ អង្គការសង្គមស៊ីវិល និងស្ថាប័នអនុវត្តច្បាប់ឯករាជ្យ។ ទោះបីយ៉ាងណាការកាត់បន្ថយឱនភាពនៃមូលធនមនុស្សនៅកម្ពុជាដើម្បីស្តារសេដ្ឋកិច្ចមានភាពប្រសើរឡើងវិញប្រកបដោយនិរន្តរភាព និងមានភាពរឹងមាំជាភារកិច្ចមួយដែលទាមទារឱ្យមានអភិក្រមគ្រប់ជ្រុងជ្រោយមួយក្នុងការអភិវឌ្ឍមូលធនមនុស្សនៅទូទាំងអាជីវកម្មឯកជន រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។

ការកាត់បន្ថយការខ្វះចន្លោះនៃមូលធនមនុស្ស អាចជាការងារមួយដ៏លំបាកសម្រាប់ប្រទេសកម្ពុជាដែលស្ថិតនៅពាក់កណ្តាលផ្លូវនៃកំណើនដ៏យឺតយ៉ាវ។ ទោះបីយ៉ាងណា ដូចបានលើកឡើងក្នុងជំពូក ១ ពិពិធកម្មសេដ្ឋកិច្ចកម្ពុជាបែបនេះ មានទំនាកក់ទំនងយ៉ាងរឹងមាំជាមួយនឹងផលិតផលនៃពុទ្ធិសកល និងបច្ចេកវិទ្យាសម្រាប់អនាគតទាមទារលើសពីការខ្វះខាតជំនាញជាក់ស្តែងក្នុងវិស័យឯកជន រហូតដល់ពិនិត្យវិភាគលើតម្រូវការមូលធនមនុស្ស និងការអនុវត្តការងារក្នុងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ។ ដូច្នេះការកំណត់ពីការខ្វះខាតជំនាញ និងវិស័យដែលមិនស៊ីសង្វាក់គ្នារវាងការផ្គត់ផ្គង់ និងតម្រូវការពលកម្មជំនាញត្រូវដើរឱ្យស្របគ្នានឹងអនុសាសន៍គោលនយោបាយសមស្របស្តីពីកំណែទម្រង់ការអប់រំ និងកម្មវិធីបណ្តុះបណ្តាលការសម្របសម្រួលដ៏ប្រសើរនៅគ្រប់ស្ថាប័នរដ្ឋាភិបាល និងហិរញ្ញប្បទានច្បាស់លាស់សម្រាប់ការអប់រំ និងសកម្មភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការសម្រេចភារកិច្ចនេះចាំបាច់ត្រូវពិនិត្យ និងវិភាគលើសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការបង្កើត និងពង្រឹងគំនិតផ្តួចផ្តើមទាំងនេះឱ្យបានរឹងមាំថែមទៀត។ មានការលើកឡើងនូវសំណួរថា តើកត្តាដែលធ្វើឱ្យមានការខ្វះខាតជំនាញក្នុងអាជីវកម្មឯកជន (ដោយសង្កត់ទៅលើបញ្ហាគុណភាពអប់រំប្រាក់ឈ្នួលមិនគ្រប់គ្រាន់ ប្រាក់លើកទឹកចិត្តតិចតួចក្នុងការលើកកម្ពស់ជំនាញដែលមានស្រាប់) កើតមានក្នុងស្ថាប័នសាធារណៈ។

បញ្ហាមួយទៀត គឺផ្អែកលើភាពសមស្របនៃនយោបាយ និងរដ្ឋបាល : កំណែទម្រង់សេវាសាធារណៈជាដំណើរការមួយដែលត្រូវចំណាយថវិកាច្រើន និងលំបាកទាមទារឱ្យមានឆន្ទៈនយោបាយខ្ពស់ (តារាង ៤.១)។ កំណែទម្រង់នេះមានការលំបាកក្នុងការសម្រេចលទ្ធផលណាស់នៅពេលសេដ្ឋកិច្ចកំពុងធ្លាក់ចុះ គឺមិនធ្វើកំណែទម្រង់ឱ្យចំពេលសេដ្ឋកិច្ច និងចំណូលកំពុងមានកំណើនខ្ពស់។ ដូច្នេះ ក្នុងអំឡុងពេលសេដ្ឋកិច្ចមានកំណើនទាបការផ្តោតការយកចិត្តទុកដាក់លើការស្តារស្ថានភាពសេដ្ឋកិច្ចឱ្យមានភាពប្រសើរឡើងវិញ

> "...ការកំណត់ពីការខ្វះខាតជំនាញ និងវិស័យដែលមិនស៊ីសង្វាក់គ្នារវាងការផ្គត់ផ្គង់ និងតម្រូវការពលកម្មជំនាញត្រូវដើរឱ្យស្របគ្នានឹងអនុសាសន៍គោលនយោបាយ។"

ស្របពេលដែលមានការពិចារណាលើបញ្ហាអភិបាលកិច្ចក្នុងពេលដែល សេដ្ឋកិច្ចមិនសូវមានភាពស្មុគស្មាញ គឺជារឿងសមហេតុផលណាស់ ។

ជាការពិត មានហេតុផលត្រឹមត្រូវមួយចំនួនដែលបង្ហាញឱ្យឃើញថា ហេតុអ្វីបានជាផែនទីយុទ្ធសាស្ត្រមូលធនមនុស្សក្នុងការលើកកម្ពស់ការប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចត្រូវមានបញ្ចូលនូវតម្រូវការមូលធនមនុស្សនៃវិស័យសំខាន់ៗ ក្រៅពីវិស័យអាជីវកម្មឯកជន និងគួរផ្សារភ្ជាប់ជាមួយកំណែទម្រង់ និងជាមួយការបង្កើនសមត្ថភាពក្នុងវិស័យសាធារណៈដែលសម្រេចឱ្យមានគោលនយោបាយ ។ ជំពូកនេះ នឹងពិនិត្យលើការពិចារណាមួយចំនួនក្នុងចំណោមការពិចារណាទាំងអស់នេះ ។

*តារាង ៤.១ ប្រវត្តិនៃវិសាលភាពសេវាសាធារណៈ តាមប្រភព* [ក/ខ/]

| | ច្បាប់ថវិកា | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
|---|---|---|
| ១៩៩៤ | ១៤៨.៣៥៣ | មិនមាន |
| ១៩៩៥ | ១៤៣.៨៥៥ | មិនមាន |
| ១៩៩៦ | ១៤៧.០៨៦ | មិនមាន |
| ១៩៩៧ | ១៥៣.៣៧២ | មិនមាន |
| ១៩៩៨ | ១៥៦.៧៣១ | ១៦១.៤៦៦ |
| ១៩៩៩ | ១៥៥.២៣៣ | ១៦២.៧៧២ |
| ២០០០ | ១៦៥.៥៣៩ | ១៦២.៩៥១ |
| ២០០១ | ១៦៤.៣៩៧ | ១៦២.៩៦៩ |
| ២០០២ | ១៦៤.២១៩ | ១៦៥.៣៦៩ |
| ២០០៣ | ១៦៧.៧៧៨ | ១៦៦.៣៨១ |
| ២០០៤ | មិនមាន | ១៦៥.៩៥៣ |
| ២០០៥ | មិនមាន | ១៦៤.៥៩៥ |
| ២០០៦ | មិនមាន | ១៦៣.៤៦៩ |

*កំណត់សម្គាល់ : ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល*

*ក/ តួលេខឆ្នាំ២០០៤-២០០៦ ផ្អែកលើការព្យាករណ៍របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។*

*ខ/ ទិន្នន័យច្បាប់ថវិកា រួមមានអ្នកទទួលបានការតែងតាំងផ្អែកនយោបាយ និងបុគ្គលិកក្របខ័ណ្ឌ និងបុគ្គលិកបណ្តែតខណៈពេលដែលទិន្នន័យរបស់ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលមិនមាន ។*

*ប្រភព : Taliercio,R.R មិនដឹងឆ្នាំ ។ ចាប់ពីរដ្ឋាភិបាលទាំងមូលដល់វិធីសាស្ត្រកំណែទម្រង់ទាំងមូល?: កំណែទម្រង់សេវាសាធារណៈរបស់កម្ពុជា ។*

## ៤.២ សមត្ថភាពប្រកួតប្រជែង កំណើនសេដ្ឋកិច្ច និងស្ថានភាពអតិចឡូន៍

ការស្រាវជ្រាវថ្មីៗ និងបទពិសោធក្នុងការអភិវឌ្ឍបានលើកឡើងនូវហេតុផលមួយចំនួនក្នុងការដាក់បញ្ចូលឱនភាពនៃមូលធនមនុស្ស និងតម្រូវការមូលធនមនុស្សរបស់ប្រទេសនេះ ក្នុងការកំណត់ផែនទីយុទ្ធសាស្ត្រនៃមូលធនមនុស្សសម្រាប់ជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនាពេលអនាគត ។

ហេតុផលមួយសំខាន់បំផុត គឺអាចប្រហែលជាទំហំ និងភាពស្មុគស្មាញនៃស្ថានភាពអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យទំនើបបច្ចុប្បន្ន។ ទោះបីជាមានការព្យាយាមជាច្រើនក្នុងការធ្វើឱ្យប្រទេសមិនមានភាពរីកចម្រើនដែលមានការបែងចែងមនោគមវិជ្ជាផ្សេងគ្នាតាមក្រុមក្នុងអំឡុងទសវត្សរ៍ ១៩៨០ ក៏ដោយក៏មានការព្យាយាមប្រឹងប្រែងច្រើននៅគ្រប់ប្រទេសកាន់លទ្ធិប្រជាធិបតេយ្យបានកាត់បន្ថយអត្រាចំណាយសាធារណៈយ៉ាងច្រើនសន្ធឹកសន្ធាប់ធៀបនឹងផលិតផលក្នុងស្រុកសរុប។ នេះគឺជាការវាស់ស្ទង់ជាទូទៅមួយនៃទំហំស្ថានភាពសេដ្ឋកិច្ចប្រទេស (តារាង ៤.២)។

*តារាង ៤.២ ចំណាយសាធារណៈគិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប និងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស*

| | ចំណាយសាធារណៈ (%នៃផលិផក្នុងស្រុកសរុប) | | |
|---|---|---|---|
| ប្រទេស | ឆ្នាំដែលមានកម្រិតចំណាយខ្ពស់បំផុត | ២០០២ | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស |
| ន័រវែស | ៥២,០ (១៩៩២) | ៤២,៣ | ០,៩៤២ |
| ស៊ុយអែត | ៦៧,៥ (១៩៩៣) | ៥២,៦ | ០,៩៤១ |
| កាណាដា | ៤៩,៩ (១៩៩២) | ៣៨,២ | ០,៩៤០ |
| បែលហ្ស៊ិក | ៥៧,១ (១៩៨៥) | ៤៦,២ | ០,៩៣៩ |
| អូស្ត្រាលី | ៣៧,៧ (១៩៨៥) | ៣២,៥ | ០,៩៣៩ |
| សហរដ្ឋអាមេរិក | ៣៤,៨ (១៩៩២) | ៣០,៩ | ០,៩៣៩ |
| អាយស្លែន | ៤០,៥ (១៩៩២) | ៤០,៣ | ០,៩៣៦ |
| ហូឡង់ | ៥៣,៣ (១៩៨៧) | ៤១,៨ | ០,៩៣៥ |
| ជប៉ុន | - | ៣៧,៩ | ០,៩៣៣ |
| ហ្វាំងឡង់ | ៥៩,១ (១៩៩៣) | ៤៥,២ | ០,៩៣០ |
| បារាំង | ៥១,៨ (១៩៩៣) | ៤៩,០ | ០,៩២៨ |
| ចក្រភពអង់គ្លេស | ៤៣,២ (១៩៩៣) | ៣៩,១ | ០,៩២៨ |
| ដាណឺម៉ាក | ៥៨,០ (១៩៩៦) | ៥០,១ | ០,៩២៦ |
| អូទ្រីស | ៥៣,៣ (១៩៩៣) | ៤៨,៨ | ០,៩២៦ |
| លុចហ្សំបួ | ៤៤,០ (១៩៩២) | ៤០,៥ | ០,៩២៥ |
| អាល្លឺម៉ង់ | ៤៧,៣ (១៩៩៦) | ៤៦,៣ | ០,៩២៥ |
| អៀរឡង់ | ៥០,៧ (១៩៨៥) | ៣១,៨ | ០,៩២៥ |
| ញូវហ្ស៊ីលែន | ៥១,៨ (១៩៨៦) | ៣៩,០ | ០,៩១៧ |
| អ៊ីតាលី | ៥៥,៤ (១៩៩៣) | ៤៥,៥ | ០,៩១៣ |
| អេស្ប៉ាញ | ៤៧,២ (១៩៩៣) | ៣៨,៨ | ០,៩១៣ |

*ប្រភព : Tanzi, V. ឆ្នាំ២០០៥។ មុខងារសេដ្ឋកិច្ចរបស់ប្រទេសក្នុងសតវត្សរ៍ទី២១។ ទំព័រទី៦២៣។*

ទំហំស្ថានភាពសេដ្ឋកិច្ចប្រទេសមានកម្រិតទាបនៅតាមបណ្តាប្រទេសនៅអាស៊ីជាច្រើន មួយផ្នែកដោយសារចំណូលទាបធៀបនឹងអត្រានៃផលិតផលក្នុងស្រុកសរុប ហើយដោយសារប្រទេសទាំងនោះបាន

ចំណាយតិចលើសុខាភិបាល អប់រំ ស្រាវជ្រាវ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងប្រយោជន៍សាធារណៈ។ ទំហំស្ថានភាពសេដ្ឋកិច្ចប្រទេសបានធ្លាក់ចុះដោយសារថា រដ្ឋាភិបាលនៃប្រទេសជាច្រើនទើបតែបានក្លាយជារដ្ឋាភិបាលប្រជាធិបតេយ្យក្នុងតំបន់ប៉ុណ្ណោះ។ ឥទ្ធិពលទូទៅនៃការមកដល់នៃរបបប្រជាធិបតេយ្យ និងសេរីភាពសារព័ត៌មាន គឺការបង្កើនតម្រូវការសេវាសាធារណៈកាន់តែខ្ពស់។ ប្រទេស កាន់លទ្ធិប្រជាធិបតេយ្យមិនមែនជាប្រទេសតូចតាចទេ ហើយជាទូទៅប្រទេសទាំងនោះរំពឹងថាទំហំស្ថានភាពសេដ្ឋកិច្ចប្រទេសរបស់ខ្លួននឹងកើនឡើងជាលំដាប់ព្រោះមានប្រព័ន្ធសុខុមាលភាពសង្គម និងបំពេញតម្រូវការហេដ្ឋារចនាសម្ព័ន្ធបានយ៉ាងត្រឹមត្រូវ។

ភាពស្មុគស្មាញរបស់រដ្ឋកាន់តែច្រើន បង្កជាបាតុភូតមួយផ្សេងទៀតដល់រដ្ឋាភិបាលទំនើប។ តួនាទីបុរាណក្នុងការរក្សាសណ្តាប់ធ្នាប់ និងផ្តល់ក្របខ័ណ្ឌគតិយុត្តិដើម្បីពង្រឹងការអនុវត្តសិទ្ធិកម្មសិទ្ធិ និងការដោះស្រាយជម្លោះបានផ្តល់ឱ្យមានវិធីក្នុងការអនុវត្តការងារដែលច្របូកច្របល់ជាច្រើនក្នុងចំណោមបញ្ហាផ្សេងៗ ដូចជាការផ្តល់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការធានាឱ្យមានរូបវ័ន្តភាពនៃសេវាសាធារណៈ និងលទ្ធភាពទទួលសេវាសាធារណៈគន្លឹះៗ ដូចជា សុខាភិបាល និងអប់រំ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចឱ្យមានស្ថិរភាព ការគ្រប់គ្រង និងការពារបរិស្ថាន និងការជួយអភិវឌ្ឍន៍ប្រជាករក្នុងពេលចូលរួមក្នុងកិច្ចការចរចា និងទំនាក់ទំនងអន្តរជាតិ។ ការងារទាំងនេះ គឺជាការទទួលខុសត្រូវដ៏ធ្ងន់ធ្ងររបស់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលកំពុងឋិតក្នុងស្ថានភាពបន្តស្វែងយល់អំពីអភិបាលកិច្ចប្រជាធិបតេយ្យក្នុងប្រព័ន្ធសាធារណៈ។

ការកើនឡើងនូវរដ្ឋាភិបាលទំនើបមិនមែនឈប់ត្រឹមហ្នឹងទេ។ ការលើកកម្ពស់ការធានាគុណភាព និងការឃ្លាំមើលទាមទារការចូលរួមពីក្រុមអ្នកប្រើប្រាស់សេវា និងសមាគមពាក់ព័ន្ធជាដាច់ខាត។ ស្ថាប័នអនុវត្តច្បាប់ចាំបាច់ត្រូវត្រួតពិនិត្យ និងគ្រប់គ្រងដំណើរការពាណិជ្ជកម្មដោយឯករាជ្យ។ សមាគមវិជ្ជាជីវៈត្រូវផ្តល់ស្តង់ដារសេវាអប្បបរមា។ អង្គការជួយខ្លួនឯងរបស់ប្រជាជនជាប្រភពព័ត៌មានមូលដ្ឋានដ៏សំខាន់មួយ និងជាប្រភពនៃការជួយខ្លួនឯងក្នុងពេលមានគ្រោះធម្មជាតិ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្តល់យន្តការក្នុងការពន្យល់ពីជម្រើសគោលនយោបាយដល់សាធារណៈទូទៅ និងរៀបចំឱ្យសាធារណៈចូលរួមក្នុងការកែប្រែគោលនយោបាយ។ រដ្ឋាភិបាលប្រជាធិបតេយ្យទំនើបជាការសិក្សាមួយរួម ចំណែកដល់ការទាក់ទាញសាធារណៈ និងក្នុងការការដោះស្រាយជម្លោះដោយសន្តិវិធី។

កាលពីពីរទសវត្សរ៍ចុងក្រោយនេះ មិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេព្រោះក្នុងអំឡុងពេលមានវឌ្ឍនភាពនៃសកលភាវូបនីយកម្មពាណិជ្ជកម្មអន្តរជាតិ និងសមាហរ័ណកម្មមូលធនរដ្ឋាភិបាលប្រទេសជឿនលឿន និងរដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនគឺជាជំពាក់ជំពិននឹងរឿងធ្វើទំនើបកម្មរដ្ឋាភិបាល។ ការខំប្រឹងប្រែងសំខាន់ៗមួយចំនួនដើម្បីធ្វើទំនើបកម្មនេះ រួមមានការតម្រែតម្រង់យន្តការសម្របសម្រួលផ្ទៃក្នុងរបស់រដ្ឋាភិបាល យន្តការហិរញ្ញប្បទាន ការបង្កើតក្រុមការងារ និងអង្គភាពយុទ្ធសាស្ត្រ និងការបង្កើតយន្តការពិគ្រោះយោបល់សាធារណៈ ដូចជា ឯកសារគោលជំហររបស់រដ្ឋាភិបាលដែលមានការចូលរួមជាសាធារណៈ និងមានបញ្ចូលទស្សនៈរបស់អ្នកជំនាញ។ ការអភិវឌ្ឍទាំងអស់របស់រដ្ឋាភិបាលទំនើប និងបែបផែនអភិបាលកិច្ចរបស់រដ្ឋាភិបាលទំនើប បង្ហាញថារដ្ឋមិនមែនត្រឹមតែជាស្ថាប័នដោះស្រាយជម្លោះផ្លូវច្បាប់ ឬជានគរបាលចាំដោះស្រាយបញ្ហានៅពេលអ្វីៗគ្រប់យ៉ាងធ្ងន់ធ្ងរនោះទេ។ រដ្ឋត្រូវតែជាទីភ្នាក់ងារដើម្បីការផ្លាស់ប្តូរ និងជាមធ្យោបាយក្នុងការធ្វើចំណោលអំពីផលប៉ះពាល់ និងគ្រោះថ្នាក់ និងកាត់បន្ថយផលប៉ះពាល់ និងគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងពេលអនាគត។

ដូច្នេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍មូលធនមនុស្សដែលភ្លេចគិតអំពីភាគីពាក់ព័ន្ធដ៏មានឥទ្ធិពលយ៉ាងធំបំផុត នៅក្នុងប្រព័ន្ធរដ្ឋាភិបាលជាយុទ្ធសាស្ត្រដែលនៅមានកម្រិត និងមិនមានលក្ខណៈពេញលេញសម្រាប់អនុវត្ត។ លើសពីនេះទៀតយុទ្ធសាស្ត្រនេះមិនជំរុញឱ្យមានការប្រកួតប្រជែងជាអន្តរជាតិ ឬមិនជំរុញឱ្យមានកំណើនខ្លាំងគ្រប់គ្រាន់ ដោយសារហេតុផលសាមញ្ញគឺថា សូចនាចករទាំងអស់សម្រាប់វាស់លទ្ធផល គឺទាមទារសកម្មភាព និងវិធានការធំៗរបស់រដ្ឋ។

សកម្មភាពទាំងអស់នេះទាមទារឱ្យមានការអភិវឌ្ឍមូលធនមនុស្សក្នុងរដ្ឋ មិនឱ្យតិចជាងនៅក្នុងវិស័យឯកជនទេ។ អភិបាលកិច្ចអសន្សាណ្ឌ ការគ្រប់គ្រងប្រើលទ្ធផលជាសំអាង ការពិគ្រោះយោបល់សាធារណៈការឆ្លើយតបនិងការគ្រប់គ្រងទស្សនៈសាធារណៈ ក្រុមការងារ និងអង្គភាពរេខាគណិតក៏ការពិនិត្យវិភាគឯករាជ្យ និងសនវកម្មលើការគ្រប់គ្រងសមិទ្ធផលការបានជាជំនាញ និងជាព័តិមានចាំបាច់របស់រដ្ឋាភិបាលទំនើប។ ផែនទីយុទ្ធសាស្ត្រនៃមូលធនមនុស្សនៅមានកន្លែងមិនទាន់ពេញលេញច្រើនបំផុត ហើយមិនអាចជួយដោះស្រាយបញ្ហាគោលនយោបាយបន្ទាន់បានបន្តិចសោះ ប្រសិនបើភ្លេចគិតអំពីការថ្លឹងថ្លែងសមីការនៃឱនភាពមូលធនមនុស្សរវាងសមត្ថភាពបច្ចេកទេស និងការសម្របសម្រួល។

ដោយសារហេតុផលទាំងនេះ សារៈសំខាន់របស់ស្ថាប័ន និងរបស់អភិបាលកិច្ចកំពុងទទួលបានការចាប់អារម្មណ៍យ៉ាងច្រើនឡើងក្នុងឯកសារស្រាវជ្រាវអំពីការអភិវឌ្ឍថ្មីៗ។ យុទ្ធសាស្ត្រចុតកោណពិតជាមានភាពត្រឹមត្រូវ ព្រោះយុទ្ធសាស្ត្រនេះបានចាត់ទុកអភិបាលកិច្ចជាកត្តាស្នូលក្នុងការលើកកម្ពស់កំណើនប្រកបដោយសមធម៌ និងនិរន្តរភាព។ បញ្ហានេះកាន់តែវែងឆ្ងាយជាងបញ្ហានៃអសង្គតិភាពជំនាញក្នុងវិស័យឯកជនទៅទៀត។ បញ្ហានេះវិវត្តទៅជាបញ្ហាស្នូលនៃបញ្ហាធំថា តើអនុសាសន៍គោលនយោបាយក្នុងវិស័យអ្វីមួយត្រូវស្ថាប័នណា ឬបុគ្គលណាជាអ្នកដោះស្រាយ តើត្រូវផ្តល់ហិរញ្ញប្បទានដោយរបៀបណា និងសម្រាប់រយៈពេលប៉ុន្មាន ហើយតើស្ថាប័ន និងបុគ្គលនោះត្រូវធានាអនុវត្តមុខនាទីឱ្យស្របតាមបរិបទគោលនយោបាយអន្តរជាតិ និងគោលនយោបាយក្នុងប្រទេសដោយរបៀបណា និងនៅពេលណា។

## ៤.៣ ប្រទេស និងការបង្កើតសេដ្ឋកិច្ចពុទ្ធិ

សេចក្តីសន្និដ្ឋានដ៏សំខាន់ អំពីបទពិសោធអន្តរជាតិក្នុងការផ្តល់មូលដ្ឋានសមស្របឱ្យកើតមាននូវសេដ្ឋកិច្ចពុទ្ធិ គឺថាដោយសារការអប់រំឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាសមាសធាតុដ៏សំខាន់នៃការបង្កើតសិប្បរចនាទូទៅសម្រាប់សេដ្ឋកិច្ចពុទ្ធិទាំងការអប់រំឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈគឺមានភាពចាំបាច់ដោយខានមិនបាន ប៉ុន្តែលក្ខខណ្ឌទាំងនេះមិនទាន់គ្រប់គ្រាន់សម្រាប់ផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចពុទ្ធិឱ្យបានជោគជ័យទេ។ ហេដ្ឋារចនាសម្ព័ន្ធព័តិមានបណ្តាញនវានុវត្តន៍ និងក្របខ័ណ្ឌស្ថាប័នសម្រាប់ធានាប្រសិទ្ធភាពអភិបាលកិច្ច (ឧទាហរណ៍ការការពារ IPRs) មានសារៈសំខាន់សម្រាប់អនាគត។

ដូចមានបង្ហាញក្នុងតារាងខាងក្រោម (តារាង ៤.៣ និងតារាង ៤.៤) ថ្វីបើកម្ពុជាមានប្រវត្តិកំណើនសេដកិច្ចក្នុងមួយទសវត្សរ៍ក៏ដោយក៏កម្ពុជានៅតែឋិតនៅក្រោមកម្រិតមធ្យមនៃហេដ្ឋារចនាសម្ព័ន្ធព័តិមានស្រាវជ្រាវនិងអភិវឌ្ឍន៍ និងសមត្ថភាពប្រកួតប្រជែងផលិតផល ហើយកម្ពុជាក៏កំពុងឋិតក្នុងការអភិវឌ្ឍមនុស្សដែលទាក់ទិននឹងការគ្របដណ្តប់សេវាសាធារណៈក្នុងវិស័យអប់រំ និងសុខាភិបាល។ ចំណុចនេះមិនមែនចង់មានន័យថាសមិទ្ធផលរបស់កម្ពុជាទាក់ទងនឹងសូចនាករជាច្រើន (ជាពិសេសសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស)

*"...តម្រូវការមូលធនមនុស្សទូទៅកំណត់ក្នុងយុទ្ធសាស្ត្រពិពិធកម្មឧស្សាហកម្ម ការវាយតម្លៃជំនាញបន្ទាប់បន្សំរបស់រដ្ឋាភិបាល ។"*

មិនមានអ្វីគួរឱ្យចាប់អារម្មណ៍នោះទេ[១៩] គឺមិនមែនយ៉ាងដូច្នេះទេ ។ ប៉ុន្តែដោយសារមូលដ្ឋានគ្រឹះនៃមូលធនមនុស្សនៅទាប និងដោយសារការបាត់បង់មូលធនមនុស្សក្រោមសម្ពាធភ្លោះគឺ ជម្លោះនយោបាយ និងអចលនានៃសេដ្ឋកិច្ចរយៈពេលយូរក្នុងអំលុងមុនទសវត្សរ៍ ១៩៩០ ទើបកម្ពុជានៅតែបន្តប្រឈមនឹងការបំពេញឱនភាពនៃមូលធនមនុស្ស និងការខ្វះការអភិវឌ្ឍមនុស្ស ។

*តារាង ៤.៣ ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍក្នុងប្រទេសដែលបានជ្រើសរើស ឆ្នាំ២០០០ និង ២០០៧*

| | 000 PPP$ | | As percentage (%) of GDP | | Per capita (PPPS) | | GERD performed by higher education sector (%) | |
|---|---|---|---|---|---|---|---|---|
| ប្រទេស | 2000 | 2007 | 2000 | 2007 | 2000 | 2007 | 2000 | 2007 |
| ប៊ូគីណាហ្វាសូ | 19,659 | 18,392 | 0.19% | 0.11% | 1.6 | 1.2 | — | — |
| កម្ពុជា | 6,838 | — | 0.05% | — | 0.5 | — | 11.8% | — |
| កាណាដា | 16,687,599 | 23,970,003 | 1.91% | 2.03% | 543.8 | 729.1 | 28.1% | 36.0% |
| ហ្វាំងឡង់ | 4,439,726 | 6,320,699 | 3.34% | 3.47% | 857.8 | 1,197.8 | 17.8% | 18.7% |
| បារាំង | 32,920,326 | 43,359,554 | 2.15% | 2.10% | 556.2 | 703.3 | 18.8% | 19.2% |
| ហុងគ្រី | 21,111 | 27,805 | 0.22% | 0.18% | 4.5 | 6.2 | 28.6% | 26.8% |
| អាឡឺម៉ង់ | 52,283,497 | 69,334,450 | 2.45% | 2.54% | 635.2 | 839.4 | 16.1% | 16.3% |
| ក្រិច | 1,269,719 | 1,845,571 | 0.51% | 0.50% | 115.3 | 165.6 | 44.9% | 50.4% |

*ប្រភព : Altbach,P.G. et al. ឆ្នាំ២០០៩ ។ និន្នាការក្នុងការអប់រំកម្រិតឧត្តមសិក្សាជាសកល : ដំណើរផ្លាស់ប្តូរការអប់រំ ។ របាយការណ៍រៀបចំសម្រាប់អង្គការ UNESCO ឆ្នាំ២០០៩ សន្និសីទពិភពលោកស្តីពីការអប់រំកម្រិតឧត្តមសិក្សា ។*

*តារាង ៤.៤ ការចំណាយសាធារណៈរបស់អប់រំលើការអប់រំឧត្តមសិក្សា គិតជា% នៃការចំណាយក្នុងវិស័យអប់រំសាធារណៈសរុប ឆ្នាំ២០០០ និង ២០០៧*

| ប្រទេស | 2000 | 2007 |
|---|---|---|
| ប៊ូគីណាហ្វាសូ | — | 11.1 |
| កម្ពុជា | 5.0 | 3.4 |
| កាណាដា | 35.7 | — |
| ហ្វាំងឡង់ | 34.0 | 31.7 |
| បារាំង | 17.6 | 21.4 |
| ហុងគ្រី | — | — |
| អាឡឺម៉ង់ | 24.2 | 25.2 |
| ក្រិច | 24.0 | 36.1 |

*ប្រភព : Altbach,P.G. et al. ឆ្នាំ២០០៩ ។ និន្នាការក្នុងការអប់រំកម្រិតឧត្តមសិក្សាជាសកល : ការតាមដានការផ្លាស់ប្តូរការអប់រំ ។ របាយការណ៍រៀបចំសម្រាប់អង្គការ UNESCO ឆ្នាំ២០០៩ សន្និសីទពិភពលោកស្តីពីការអប់រំកម្រិតឧត្តមសិក្សា ។ អង្គការ UNESCO ។*

ដោយឈរលើចំណាត់ថ្នាក់នៃបច្ចេកវិទ្យា ដូចជា ព័ត៌មាន ឬជីវបច្ចេកវិទ្យា ឬយកតាមនិយមន័យតាមវិស័យ ដូចជា វិស័យអសន្យាណូ ឬវិស័យរ៉ែ ឬយកតាមប្រភេទជំនាញ ដូចជា សេវាហិរញ្ញវត្ថុ ឬឧស្សាហកម្មបដិសណ្ឋារកិច្ច យុទ្ធសាស្ត្រ ពិពិធកម្មឧស្សាហកម្មនឹងទម្លាក់តម្រូវការបន្ថែមទៅលើសមត្ថភាពរបស់រដ្ឋាភិបាលបច្ចុប្បន្នឱ្យរៀបចំសម្របសម្រួល និងផ្តល់ហិរញ្ញវត្ថុសម្រាប់ការវិនិយោគលើមូលធនមនុស្សដែលពាក់ព័ន្ធនឹងពិពិធកម្មនេះ ។ យុទ្ធសាស្ត្រនេះទាមទារឱ្យមានសមត្ថភាពថ្មីច្រើនក្នុងការព្យាករណ៍អំពីនិន្នាការឧស្សាហកម្មផលប៉ះពាល់បណ្តាលមកពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងយន្តការលើក

១៩ យោងតាមរបាយការណ៍អភិវឌ្ឍន៍ប្រទេសកម្ពុជាឆ្នាំ២០១០ : ប្រទេសកម្ពុជា មានភាពរីកចម្រើនយ៉ាងធំធេងក្នុងភាពប្រក្រតីភាវូបនីយកម្មនៃការរស់នៅកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍តំបន់ និងអន្តរជាតិ ។

កម្ពស់ការវិនិយោគរបស់ឯកជនដែលមានប្រសិទ្ធភាពបំផុតក្នុងគម្រោងសាធារណៈ និងជំនាញកំណត់តម្លៃជំនាញចរចាជំនាញគ្រប់គ្រងហានិភ័យ និងជំនាញធ្វើផែនការគម្រោងយ៉ាងច្រើនសន្ទឹកសន្ធាប់ក្នុងរយៈពេលមួយយ៉ាងយូរ។

ដូច្នេះ តម្រូវការមូលធនមនុស្សទូទៅកំណត់ក្នុងយុទ្ធសាស្ត្រពិពិធកម្មឧស្សាហកម្មមិនត្រឹមតែទាមទារឱ្យកំណត់អំពីជំនាញដែលត្រូវការនៅតាមកម្រិតឧស្សាហកម្ម ឬក្នុងតំបន់ភូមិសាស្ត្រណាមួយទេ ប៉ុន្តែទាមទារឱ្យមានការវាយតម្លៃជំនាញបន្ទាប់បន្សំរបស់រដ្ឋាភិបាលក្នុងការតាក់តែងផែនការផ្តល់ហិរញ្ញវត្ថុ ប្រតិបត្តិការងារ និងវាយតម្លៃអំពីការផ្លាស់ប្តូរកែប្រែគោលនយោបាយបែបនេះផងដែរ។ ការផ្លាស់ប្តូរកែប្រែនេះមិនមែនត្រឹមតែជាបញ្ហាអំពីការកំណត់រកឱនភាពនៃជំនាញ និងតម្រូវការការបណ្តុះបណ្តាលនៅតាមកម្រិតផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលនីមួយៗ ឬនៅតាមស្ថាប័ន ឬទីភ្នាក់ងារណាមួយប៉ុណ្ណោះទេ។ គម្លាតនៃបច្ចេកវិទ្យា និងគម្លាតទាក់ទងនឹងការដំណើរការក្នុងទម្រង់ទូរអភិបាលកិច្ចក្នុងដំណើរការកំណត់ថវិកាក្នុងបច្ចេកទេសវាយតម្លៃ និងនីតិវិធីចរចាក៏មានសារៈសំខាន់ផងដែរ។ បូកបន្ថែមជាមួយនឹងគម្លាតនៃសមត្ថភាពតាមក្រសួង ដូចជា ផ្តល់គ្រូបង្រៀនបន្ថែមដើម្បីបង្កើនអត្រាសិស្សចូលរៀននៅមធ្យមសិក្សាឱ្យបានច្រើន និងដើម្បីកំណត់ស្តង់ដារអប្បបរមាសម្របសម្រួលឱ្យជិតស្និទ្ធជាងមុនជាមួយស្ថាប័នពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបំប៉នជំនាញ (ឧទាហរណ៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងបរិបទប្រទេសកម្ពុជា) និងការតាក់តែងវិធីបណ្តុះបណ្តាលថ្មីដោយមានការចូលរួមរបស់ភាគីពាក់ព័ន្ធ និងដោយប្រើលទ្ធផលអង្កេតឧស្សាហកម្ម។

ប្រធានបទនិយាយអំពីឱនភាពនៃមូលធនមនុស្សរបស់រដ្ឋក្នុងបរិបទនៃការធ្វើពិពិធកម្មឧស្សាហកម្ម និងក្នុងបរិបទនៃការកសាងមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចពុទ្ធិក្នុងពេលអនាគត គឺមានសារៈសំខាន់គ្រប់គ្រាន់ល្មមសម្រាប់បង្ហាញអំពីខ្លឹមសារដោយឡែក និងខ្លឹមសារលម្អិតអំពីបញ្ហានេះ។ គោលបំណងនៅត្រង់ចំណុចនេះគឺសំដៅគូសបញ្ជាក់អំពីសារៈសំខាន់នៃចម្ងល់នេះ និងសំដៅផ្តោតការយកចិត្តទុកដាក់លើគ្រោះថ្នាក់នៃការប្រើប្រាស់វិធីវាយតម្លៃអំពីតម្រូវការមូលធនមនុស្សមួយចំណែករយៈពេលខ្លីនៅកម្ពុជាព្រោះកម្ពុជាត្រូវការតាក់តែងយុទ្ធសាស្ត្រមួយដែលអាចអនុវត្តបានសម្រាប់ធានាកំណើនសេដ្ឋកិច្ចក្នុងពេលអនាគត។

## ៤.៤ តថភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍមូលធនមនុស្ស

នៅកម្ពុជានៅក្នុងរដ្ឋាភិបាលឃើញមានបញ្ហានៃឱនភាពនៃមូលធនមនុស្សជាច្រើន ហើយបញ្ហាឱនភាពនេះមានផលប៉ះពាល់ដល់ការអភិវឌ្ឍមូលធនមនុស្សក្នុងសង្គមជារួម។ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃការអភិវឌ្ឍមូលធនមនុស្សក្នុងប្រទេសក្នុងពេលតែមួយរដ្ឋាភិបាលត្រូវកែប្រែរចនាសម្ព័ន្ធ និងប្រព័ន្ធផ្ទៃក្នុងរបស់រដ្ឋាភិបាលដែលមានកាតព្វកិច្ចទទួលខុសត្រូវអនុវត្តកម្មវិធីកំណែទម្រង់។ ដើម្បីកំណត់អំពីវិធីដែលរដ្ឋាភិបាលត្រូវប្រើដើម្បីបំពេញតម្រូវការមូលធនមនុស្សក្នុងជួររដ្ឋាភិបាលប្រការសំខាន់បំផុត គត្រូវក្រឡេកមើលស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមដែលកំពុងកើតមាន។

*“វិស័យឯកជន ត្រូវតែចូលរួមពាក់ព័ន្ធឱ្យកាន់តែជ្រៅថែមទៀត ក្នុងវិស័យអប់រំ ប្រសិនបើវិស័យឯកជនចង់មើលឃើញជំនាញ និងការបណ្តុះបណ្តាល មានការលើកកម្ពស់ឱ្យបានល្អប្រសើរតាមអ្វីដែលវិស័យឯកជនកំពុងស្វែងរក។”*

## ៤.៤.១ បញ្ហាប្រឈមនៅតាមស្ថាប័ន និងការលើកកម្ពស់ការសហការ

ជាដំបូង ការផ្តល់សេវាអប់រំ ជួបប្រទះបញ្ហាប្រឈមជាច្រើន៖ ការលំបាកខាងផ្នែកផ្គត់ផ្គង់ (ការលំបាកខាងផ្នែកតម្រូវការមានពិភាក្សាក្នុងជំពូកទី២)។ ការលំបាកខាងផ្នែកផ្គត់ផ្គង់ រួមមាន បញ្ហាសម្របសម្រួលរបស់ក្រសួងពាក់ព័ន្ធនឹងវិស័យអប់រំ គុណភាពនៃធនធានអប់រំ (គ្រូបង្រៀន លទ្ធភាពទទួលបានការអប់រំនៅតំបន់ផ្សេងៗ និងការផ្តល់ការអប់រំ) និងគុណភាពអប់រំ។ កត្តាទាំងនេះបង្កើតឱ្យមានជម្រើសនៃប្រព័ន្ធអប់រំមួយផ្សេងទៀតដល់ប្រជាជនកម្ពុជា ហើយដែលប្រព័ន្ធបែបនេះហុចផលឱ្យមានឱនភាពនៃមូលធនមនុស្សក្នុងរដ្ឋាភិបាលខ្លួនឯង។

ដើម្បីសិក្សាវិភាគឱ្យបានស៊ីជម្រៅអំពីការលំបាកខាងផ្នែកផ្គត់ផ្គង់ដំបូងបំផុតត្រូវពិនិត្យមើលធនធានសិន។ នៅកម្ពុជាការលំបាកធំៗជាច្រើនកើតឡើងនៅតាមស្ថាប័នបង្កឡើងដោយសារភាពអសកម្មនៃការសម្របសម្រួលការងារក្នុងចំណោមក្រសួងនានារបស់រដ្ឋាភិបាល ហើយភាពអសកម្មទាំងនេះជាការបារម្ភយ៉ាងធំមួយសម្រាប់ការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ។ ឧទាហរណ៍ ការប្រកួតប្រជែងរវាងក្រសួងខុសគ្នាដែលគ្រប់គ្រងប្រព័ន្ធអប់រំផ្សេងគ្នា គឺក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងទាំងពីរប្រជែងគ្នាដណ្តើមការគ្រប់គ្រងការផ្តល់ការអប់រំ និងការបណ្តុះបណ្តាល។ បន្ថែមពីលើសឧទាហរណ៍នេះទៀតមានក្រសួងផ្សេងទៀត គ្រប់គ្រងសាកលវិទ្យាល័យផ្សេងៗគ្នានៅកម្ពុជា។ ដូចបង្ហាញក្នុងរូប ៤.១ ក្នុងចំណោមសាកលវិទ្យាល័យរដ្ឋ និងឯកជនចំនួន ៨៨ ក្នុងប្រទេសមានក្រសួងផ្សេងៗគ្នាចំនួន ១១ ដែលគ្រប់គ្រងយ៉ាងតិចសាកលវិទ្យាល័យមួយ។ ចំពោះក្រសួងអប់រំ យុវជន និងកីឡាផ្ទាល់ ក៏មានក្តីកង្វល់មួយចំនួនអំពីសមត្ថភាពរបស់ខ្លួនក្នុងការទទួលយកចាត់ចែងដំណើរការប្រើប្រាស់ និងផ្សព្វផ្សាយអំពីមូលនិធិសកលសម្រាប់ប្រព័ន្ធអប់រំអំពីសមត្ថភាពបង្កើតគោលនយោបាយសមស្រប និងឆ្លើយតបទៅនឹងតម្រូវការក្នុងការធ្វើកំណែទម្រង់អប់រំ និងសមត្ថភាពអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រទាំងនេះផងដែរ (Chhinh និង Dy ២០០៩)។

*រូប ៤.១ មហាវិទ្យាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងនានា*




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានឧត្តមសិក្សា ឆ្នាំ២០០៩។*

ក្នុងបរិបទខ្លះចាំបាច់ត្រូវផ្លាស់ប្តូរផ្នត់គំនិតខ្លះក្នុងប្រព័ន្ធរដ្ឋាភិបាល។ ដោយសារការប្រឹងប្រែងដើម្បីលើកកម្ពស់ការអប់រំ ជាពិសេសអប់រំមូលដ្ឋានមានការចាប់អារម្មណ៍ដោយមិនអាចប្រកែកបាន ដូច្នេះក្នុងរដ្ឋាភិបាលចាំបាច់ត្រូវមានឥរិយាបថសហប្រតិបត្តិការឱ្យប្រសើរជាងមុនដើម្បីកែទម្រង់ប្រព័ន្ធអប់រំ និងកែប្រែស្ថាននៃការអនុវត្តការងារក្នុងក្រសួង។ ការប្រកួតប្រជែងក្នុងរដ្ឋាភិបាលបច្ចុប្បន្នកំពុងបង្អាក់ការធានាប្រើប្រាស់សក្តានុពលភាពនៃមូលធនមនុស្សរបស់កម្ពុជាឱ្យបានពេញលេញ។ បន្ថែមពីលើសនេះទៀត ប្រសិនបើពុំមានគំនិតផ្តួចផ្តើមសកម្មភាពផ្តើមចេញពីថ្នាក់លើមកថ្នាក់ក្រោមអំពីការផ្លាស់ប្តូរទេ ការផ្លាស់ប្តូរផ្តើមចេញពីថ្នាក់ក្រោមដែលថាមានភាពចាំបាច់នោះ ដូចជាការបណ្តុះបណ្តាលគ្រូ និងការកាត់បន្ថយអំពីពុករលួយ (ពិភាក្សាខាងក្រោម) ក៏មិនដែលមានឱកាសកើតឡើងដែរ។

ចំណែកដ៏សំខាន់នៃការផ្លាស់ប្តូរឥរិយាបថនេះនឹងជួយជំរុញឱ្យមានកំណើនថវិកាក្នុងវិស័យអប់រំផងដែរ។ ដូចមាន ពន្យល់នៅខាងក្រោយការផ្លាស់ប្តូរនេះជាកត្តាមិនអំណោយផលមួយយ៉ាងធំ ចំពោះកំណែទម្រង់អប់រំ ហើយផែនការនានានឹងមិនអាចយកទៅអនុវត្តឱ្យបានទូលំទូលាយ និងសមស្របឡើយប្រសិនបើមិនមានថវិកាគ្រប់គ្រាន់។

រដ្ឋាភិបាលត្រូវធ្វើការវាយតម្លៃឥរិយាបថ និងការយល់ឃើញរបស់ខ្លួនទាក់ទងនឹងតួនាទីរបស់វិស័យឯកជនក្នុងការផ្តល់ការអប់រំសាជាថ្មីម្តងទៀត។ វិស័យឯកជនត្រូវតែចូលរួមពាក់ព័ន្ធឱ្យកាន់តែជ្រៅថែមទៀតក្នុងវិស័យអប់រំ ប្រសិនបើវិស័យឯកជនចង់មើលឃើញជំនាញ និងការបណ្តុះបណ្តាលមានការលើកកម្ពស់ឱ្យបានល្អប្រសើរតាមអ្វីដែលវិស័យឯកជនកំពុងស្វែងរក។ ប៉ុន្តែរដ្ឋាភិបាលត្រូវតែទទួលស្គាល់ថា ការចូលរួមរបស់វិស័យឯកជនបែបនេះ គឺមិនអាចកើតឡើងបានទេ ឬអាចកើតឡើងបានដែរ ប៉ុន្តែកើតឡើងក្នុងស្ថានភាពដាច់ដោយឡែកពីគ្នាខ្លាំង គឺស្ថានភាពមួយដែលអាចមានប្រសិទ្ធភាព ឬអាចវាស់វែងបានប្រសិនបើរដ្ឋាភិបាលប្រើអំណាចឱ្យខ្លាំងក្នុងការចាត់ចែង ផ្តួចផ្តើមសកម្មភាព និងដឹកនាំរាល់កិច្ចប្រឹងប្រែងទាំងអស់នេះទេ។ ប្រសិនបើពុំមានឥរិយាបថសហប្រតិបត្តិការ និងសម្របសម្រួលឱ្យបានប្រសើរជាងមុនទេ រដ្ឋាភិបាលមិនអាចប្រើសក្តានុពលភាពពេញលេញកើតចេញពីការវិនិយោគវិស័យឯកជនលើប្រព័ន្ធអប់រំទេ។

បញ្ហាសម្របសម្រួល និងឥរិយាបថក៏មានសារៈសំខាន់ណាស់ដែរ ព្រោះបញ្ហាទាំងនេះអាចបង្កបញ្ហាបន្ថែមទៀតដល់វិស័យអប់រំ។ ប្រសិនបើពុំមានការដឹកនាំ និងការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពទេ ក៏ពុំមានបទដ្ឋានគតិយុត្តិច្រើនសម្រាប់ដាក់ធាតុបញ្ចូលក្នុងប្រព័ន្ធអប់រំទេ ដូចជាគ្រូបង្រៀនជាដើម។ កម្ពុជាត្រូវឆ្លងកាត់ការលំបាកដោយសារការខ្វះគ្រូបង្រៀន ហើយក្នុងឆ្នាំ២០០៧ គ្រូបង្រៀនម្នាក់ៗទទួលខុសត្រូវបង្រៀនសិស្សបឋមសិក្សាចំនួន៥១នាក់ និងសិស្សមធ្យមសិក្សាចំនួន២៩នាក់ (World Bank ២០១០)។ ជាញឹកញាប់គ្រូបង្រៀនមិនទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ដែលកត្តានេះរារាំងដល់ដំណើរការរៀនសូត្រ។ ការខ្វះបទដ្ឋានគតិយុត្តិក៏ជំរុញឱ្យធនធានអប់រំមានគុណភាពទាបដែរ។ ឧទាហរណ៍អំពីទីតាំងអគារសិក្សា – នៅភ្នំពេញ និងទីប្រជុំជនមានសាលាដែលអាចដាក់សិស្សឱ្យចូលរៀនបាន ចំណែកនៅតំបន់ផ្សេងទៀត ឬតំបន់ជនបទជាច្រើនកន្លែងអគារសាលាអាចថិតនៅឆ្ងាយពីសហគមន៍ខ្លាំង។ ប្រសិនបើមានការណីបែបនេះមែនគ្រួសារប្រហែលជាអាចសម្រេចចិត្តថា ការឱ្យកូនចូលរៀននៅសាលាដែលនៅឆ្ងាយពីភូមិ គឺមិនសន្សំសំចៃទេ។ ការលំបាកផ្សេងទៀតទាក់ទងនឹងធនធានរួមមានការផ្គត់ផ្គង់សម្រាប់ការអប់រំ។ កង្វះខាតបរិក្ខារអប់រំមូលដ្ឋាន មិនថាតែអគារសាលា ឬបរិក្ខារអប់រំ ដូចជាសៀវភៅអាន ក្រដាស ខ្មៅដៃ សុទ្ធតែរារាំងដល់ការបង្រៀនសិស្សឱ្យមានប្រសិទ្ធភាព។ ការលំបាកនៃការខ្វះធនធាន និងការខ្វះបទដ្ឋានគតិយុត្តិ

*“...ការខ្វះការសម្របសម្រួលនេះ គឺធ្វើឱ្យស្តង់ដារ និងគុណវុឌ្ឍិអប់រំមិនមានភាពសមស្របជាមួយគ្នា។”*

បង្កើតឱ្យមានបញ្ហាពាក់ព័ន្ធនឹងគុណភាពអប់រំពិតប្រាកដ។ ដោយសារប្រាក់បៀវត្សមិនគ្រប់គ្រាន់គ្រូបង្រៀនត្រូវយកថ្លៃសិក្សាក្រៅផ្លូវការពីសិស្សដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គុណភាពអប់រំ។ សិស្សអាចចំណាយប្រាក់ដើម្បីទទួលបានពិន្ទុល្អផងដែរ ការយកថ្លៃសិក្សាក្រៅផ្លូវការ ជាមធ្យោបាយមួយផ្សេងទៀត

សម្រាប់គ្រូបង្រៀនដើម្បីរកប្រាក់ចំណូលបន្ថែមយកទៅបំពេញប្រាក់ចំណូលតិចតួចដែលខ្វះខាត។ ការយកថ្លៃសិក្សា ក្រៅផ្លូវការបង្កើតបរិយាកាសខ្វះគណនេយ្យភាពក្នុងសាលា គឺកាន់តែបង្កការលំបាកក្នុងការកសាងប្រព័ន្ធសាលារៀនមួយដោយប្រើសមត្ថភាពជាមូលដ្ឋានក្នុងការដឹកនាំសាលា (ទាន ២០០៦)។ លើសនេះទៀត ក៏នៅខ្វះប្រព័ន្ធគ្រប់គ្រងគុណភាពនៅតាមគ្រឹះស្ថានអប់រំ និងមានភាពស្របគ្នានឹងស្តង់ដារអន្តរជាតិតិចតួចនេះមានន័យថា ការចូលរួមក្នុងគ្រឹះស្ថានអប់រំមិនធានាឱ្យមានគុណភាពអប់រំបានទេ។

មានការបារម្ភធ្ងន់ធ្ងរកើតចេញការពិតមួយ គឺថាការខ្វះការសម្របសម្រួលនេះ គឺធ្វើឱ្យស្តង់ដារ និងគុណវុឌ្ឍិអប់រំមិនមានភាពសមស្របជាមួយគ្នា។ ការខ្វះការសម្របសម្រួលនេះចែកចេញជាពីរផ្នែកគឺ ៖ ទីមួយ ការខ្វះប្រព័ន្ធទទួលស្គាល់ គុណវុឌ្ឍិសិក្សាមានន័យថា ពុំមានប្រព័ន្ធផ្ទៀងផ្ទាត់សមមូលជំនាញដែលសិស្សបានរៀន គឺសិស្សដែលបានរៀនចប់ថ្នាក់ទាប ឬសិស្សដែលបានទទួលការអប់រំក្រៅប្រព័ន្ធ និងសិស្សធ្វើការផងរៀនផង។ ទីពីរ ការខ្វះការសម្របសម្រួលឱ្យមានស្តង់ដារ មានន័យថា ចំពោះការអប់រំមធ្យមសិក្សា ឬឧត្តមសិក្សា សិស្សម្នាក់ៗទទួលបានកម្រិតជំនាញខុសៗគ្នាយ៉ាងខ្លាំងពីតំបន់មួយទៅតំបន់មួយ ឬពីសាលាមួយទៅសាលាមួយ។ ការខ្វះខាតនេះបង្កការស្មុគស្មាញដល់ការអប់រំបន្ត និងបង្កការលំបាកដល់និយោជកក្នុងការជួលបុគ្គលិកឱ្យធ្វើការដែលមានកម្រិតអប់រំពិតប្រាកដមួយ គឺត្រូវមានជំនាញពិតប្រាកដ (អានជំពូក ៣ និយាយអំពីជំនាញនៅតាមវិស័យផ្សេងៗ)។ មានចំណុចក៏គួរចាប់អារម្មណ៍មួយផងដែរថា ប្រព័ន្ធកំណត់គុណវុឌ្ឍិសិក្សាត្រូវពឹងលើប្រព័ន្ធអប់រំមួយដែលខ្លាំង និងពុំមានអំពើពុករលួយ។ ការដាក់ឱ្យមានគុណវុឌ្ឍិសិក្សានេះអាចមិនមានប្រយោជន៍ ប្រសិនបើមនុស្សនៅតែអាចទិញសញ្ញាបត្រ ឬវិញ្ញាបនបត្រយកទៅប្រើបានដូចអ្វីដែលកំពុងកើតមានបច្ចុប្បន្ន។ នេះមានន័យថា ត្រូវមានស្ថាប័នកំពូលមួយកំណត់អំពីគុណវុឌ្ឍិសិក្សាដូចជាគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំសម្រាប់សាកលវិទ្យាល័យ និងសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ តាមការពិត ប្រសិនបើពុំមានប្រព័ន្ធអប់រំមួយខ្លាំងដែលមាន សមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀន និងបណ្តុះបណ្តាលសិស្សឱ្យមានគុណភាពទេប្រព័ន្ធទទួលស្គាល់គុណវុឌ្ឍិសិក្សាអាចអត់មានន័យអ្វីទាំងអស់ ហើយស្តង់ការគុណវុឌ្ឍិគឺនៅតែជាចំណែកមួយដ៏សំខាន់ក្នុងការជំរុញប្រព័ន្ធអប់រំឱ្យដំណើរការទៅមុខ។

ការលំបាកតាមស្ថាប័ន បង្កការលំបាកដល់ការបង្កើតឱ្យមានប្រព័ន្ធអប់រំមួយពេលលេញសម្រាប់ពេលខាងមុខ។ តាមការពិត ឧបសគ្គរាំងដ៏លំបាកធ្ងន់ធ្ងរកែលម្អស្ថានភាពនេះឱ្យល្អប្រសើរណាស់។ ការបារម្ភមួយដ៏ធំបំផុត គឺការខ្វះថវិកាដែលធ្វើឱ្យមន្ត្រីរាជការ និងគ្រូបង្រៀនត្រូវទទួលបានប្រាក់ខែទាប។ ការខ្វះថវិកានេះបង្កើតឱ្យមានអសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់កែលម្អស្ថានភាព និងដោះស្រាយការលំបាកក្នុងការអនុវត្តការកែប្រែប្រព័ន្ធអប់រំនេះឱ្យល្អប្រសើរ។

ការខ្វះខាតប្រាក់បៀវត្សសមរម្យបង្កផលវិបាកជាច្រើន - ដូចបានពិភាក្សាខាងលើសម្រាប់គ្រូបង្រៀនវិញប្រាក់បៀវត្សមិនបានលើកទឹកចិត្តដល់បុគ្គលម្នាក់ឱ្យធ្វើជាគ្រូបង្រៀន និងមិនផ្តល់ការអប់រំប្រកបដោយគុណភាព និងអាចបង្កឱ្យមានអំពើពុករលួយក្នុងប្រព័ន្ធអប់រំនេះផងដែរ។ សម្រាប់មន្ត្រីរាជការ ការខ្វះខាត

ប្រាក់បៀវត្សរ៍សមរម្យអាចធ្វើឱ្យមានបញ្ហា ដូចគ្នាដែរគឺ អ្នកដែលមានជំនាញមិនចូលបម្រើការងារជាមន្ត្រីរាជការដោយសារមិនទទួលបានប្រាក់បៀវត្សរ៍បានសមស្របតាមសមត្ថភាព ហើយបុគ្គលិកពុំមានការលើកទឹកចិត្តឱ្យខិតខំធ្វើការងារ និង/ឬបង្កើនជំនាញ ដូច្នេះអំពើពុករលួយអាចបន្តជាបញ្ហាដ៏ក្តៅគគុកដដែល។

ការខ្វះខាតថវិកាមានន័យថា រដ្ឋាភិបាលតូវប្រឈមនឹងបញ្ហាក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់លើកកម្ពស់ស្ថានភាពនៃធនធានដែលមានស្រាប់ ដូចជាបង្កើតជំនាញថ្មីផ្តល់ឧបករណ៍អប់រំ ឬការផ្តល់ហិរញ្ញវត្ថុលើកទឹកចិត្តសម្រាប់គ្រួសារក្រីក្រដើម្បីបញ្ជូនកូនទៅសាលារៀន។ ជាការពិតណាស់ ការខ្វះថវិកាក៏បង្កការលំបាកដល់ការអនុវត្ត និងការធានាឱ្យមានការកែប្រែជានិរន្តរ៍ដែរ ព្រោះការកែប្រែប្រព័ន្ធអប់រំនេះតែងទាមទារមូលធនច្រើនសន្ធឹកសន្ធាប់ដើម្បីដំណើរការការកែប្រែនេះ ហើយធានាឱ្យច្បាស់ថា បានអនុវត្តការកែប្រែទាំងនេះឱ្យបានពេញលេញ និងត្រឹមត្រូវ។ ដោយសារការលំបាកខ្វះខាតធនធានទាំងនេះរដ្ឋាភិបាលប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ។ នៅពេលអនុវត្តផែនទីយុទ្ធសាស្ត្រនៃការអភិវឌ្ឍមូលធនមនុស្សរដ្ឋាភិបាលត្រូវទទួលស្គាល់ការលំបាកទាំងនេះដើម្បីកុំឱ្យផ្តោតការយកចិត្តទុកដាក់លើតែវិស័យមួយព្រោះវិស័យទាំងអស់សុទ្ធតែសំខាន់ស្មើៗគ្នា។

## *៤.៤.២ ការបង្កើតឃ្លាំងព័ត៌មានមួយឱ្យខ្លាំងជាងមុន*

ក្នុងការវិភាគអំពីកំណើទម្រង់ និងការអនុវត្តកំណែទម្រង់ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើប្រព័ន្ធព័ត៌មានពេញលេញ និងបច្ចុប្បន្នភាព គឺមានសារៈសំខាន់ដើម្បីធានាថា មានការផ្លាស់ប្តូរត្រឹមត្រូវ និងមានការអនុវត្តលើការផ្លាស់ប្តូរឱ្យត្រឹមត្រូវ។ កាលពីអតីតកាលដូចបច្ចុប្បន្នដែរមានក្តីបារម្ភគន្លឹះមួយគឺថាមិនមានព័ត៌មានគ្រប់គ្រាន់សម្រាប់ព្យាករណ៍អំពីបញ្ហា និងការប្រឈម និងដោះស្រាយបញ្ហា និងការប្រឈមដែលអាចកើតឡើងក្នុងពេលអនាគតឱ្យបានពេញលេញទេ ឬបញ្ហា និងការប្រឈមដែលកំពុងកើតឡើងក្នុងពេលបច្ចុប្បន្នបានទេ។ ការខ្វះព័ត៌មានបានបង្ហាញខ្លះក្នុងរបាយការណ៍នេះ ព្រោះមានការខ្វះចន្លោះយ៉ាងច្រើនក្នុងទិន្នន័យដែលប្រមូលបានបង្ហាញព័ត៌មានបន្តិចបន្តួចក្នុងឃ្លាំងទិន្នន័យ។ ការបង្កើតឃ្លាំងព័ត៌ពេលលេញ និងខ្លាំងមួយជាសមាសធាតុគន្លឹះមួយសម្រាប់កំណែទម្រង់វិស័យអប់រំ។

បញ្ហាដំបូងដែលត្រូវដោះស្រាយក្នុងផ្នែកនេះ គឺការប្រមូលព័ត៌មាន។ រដ្ឋាភិបាលនឹងត្រូវកំណត់ពីសូចនាករសំខាន់ៗដោយសហការជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុង និងក្រៅប្រព័ន្ធអប់រំដើម្បីកំណត់ថា តើការវាយតម្លៃការអភិវឌ្ឍការអប់រំ និងកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាល និងកំណែទម្រង់មានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពរបៀបណា។ ការដោះស្រាយបញ្ហានេះនឹងត្រូវមានការចូលរួមសម្របសម្រួលក្នុងចំណោមភាគីសំខាន់ៗខុសៗគ្នា ជាពិសេសការចូលរួមពីរដ្ឋាភិបាល និងវិស័យឯកជនដើម្បីកំណត់អំពីគម្លាតនៃជំនាញ និងតម្រូវការការបណ្តុះបណ្តាល។ សូចនាករទាំងនេះនឹងត្រូវប្រមូលឱ្យបានទៀងទាត់ និងតាមវិធីសាស្ត្រដើម្បីបង្កើតទិន្នន័យមូលដ្ឋានពេញលេញមួយដែលទាមទារឱ្យមានចំណេះដឹង និងការវិភាគ។ ការប្រមូលព័ត៌មាននេះនឹងត្រូវធ្វើឡើងគ្រប់ផ្នែកទាំងអស់នៃវិស័យអប់រំ មានន័យថា ត្រូវធានាឱ្យមានកិច្ចសហការ និងការសម្របសម្រួលយ៉ាងខ្លាំងក្លារវាងក្រសួងទទួលខុសត្រូវគ្រប់គ្រងលើបណ្ណាសាកលវិទ្យាល័យ និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានា។ ហើយក៏មានន័យថា ចាំបាច់ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការប្រមូលព័ត៌មានពីវិស័យឯកជនទាំងព័ត៌មានស្តីពីជំនាញដែលមិនបានផ្តល់ឱ្យសិស្ស និងស្តីពីសកម្មភាពការងាររបស់វិស័យឯកជនឆ្ពោះទៅការមានលទ្ធភាព

*"ពេលអនាគតកម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពទាំងក្នុងវិស័យឧស្សាហកម្មសេដ្ឋកិច្ចធំៗ និងវិស័យសាធារណៈ។"*

ដោះស្រាយភាពខ្វះចន្លោះនៃជំនាញទាំងនេះ។ វិស័យឯកជនក៏ត្រូវចូលរួមប្រមូលព័ត៌មានទីផ្សារដែលជាគន្លឹះក្នុងការតាមដានលើការផ្លាស់ប្តូរ និងកំណើនផងដែរ។ ជាចុងក្រោយប្រការសំខាន់នោះគឺថាព័ត៌មានដែលសប្រមូលពីក្រុមការងារផ្ទាល់ក្នុងការកំណត់អំពីការជំរុញលើកទឹកចិត្ត និងគំនិតរបស់កម្មករ និងហេតុផលអ្វីដែលកម្មករមិនបញ្ចប់ការសិក្សា ឬបន្តការសិក្សា ហើយចុងក្រោយមានសារៈសំខាន់បំផុតគឺថាអ្វីដែលត្រូវធ្វើដើម្បីលើកទឹកចិត្តដល់ពួកគេឱ្យទទួលបានការអប់រំ និងការបណ្តុះបណ្តាលឱ្យមានកម្រិតកាន់ខ្ពស់។

ទោះបីយ៉ាងណាការប្រមូលផ្តុំទិន្នន័យជាការពិត គឺជាជំហានទីមួយដែលត្រូវអនុវត្តផែនទីយុទ្ធសាស្រ្តមូលធនមនុស្ស។ ការវិភាគទិន្នន័យនេះ គឺដើម្បីតាមដានការផ្លាស់ប្តូរ និងបង្កើតឱ្យមានការផ្លាស់ប្តូរសមស្របក្នុងប្រព័ន្ធអប់រំដែលជាធាតុផ្សំដ៏ចាំបាច់ក្នុងការបង្កើតប្រព័ន្ធអប់រំដែលអាចសម្របទៅតាមតម្រូវការ។ឥឡូវនេះលក្ខណៈពិសេសមួយក្នុងចំណោមលក្ខណៈពិសេសដែលគួរឱ្យកត់សម្គាល់នៃប្រព័ន្ធអប់រំ គឺថា អាកប្បកិរិយារបស់និយោជិត បង្ហាញថា សូម្បីទទួលបានការអប់រំឧត្តមសិក្សាក៏ដោយក៏មិនមានការរកឃើញថា និយោជិតមានកម្រិតជំនាញជាក់លាក់នោះទេ (ជំពូក ៣)។ ដូច្នេះ ប្រព័ន្ធអប់រំចាំបាច់ត្រូវតែកែសម្រួលឱ្យបានសមស្របដើម្បីដោះស្រាយបញ្ហានេះឱ្យបាន។ បន្ទាប់ពីបានប្រមូលទិន្នន័យអប់រំ និងទិន្នន័យទីផ្សារសំខាន់ៗរួចហើយរដ្ឋាភិបាលចាំបាច់ត្រូវធ្វើការវិភាគ និងវាយតម្លៃទិន្នន័យឱ្យបានត្រឹមត្រូវដើម្បីបង្កើត ឬធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ។

ពាក់ព័ន្ធនឹងការបង្កើត ឬធ្វើកំណែទម្រង់ប្រព័ន្ធអប់រំនេះមានបញ្ហាប្រឈមចំនួនពីរ។ ទីមួយ គឺដូចលើកឡើងក្នុងជំពូកនេះរដ្ឋាភិបាលត្រូវមានក្រុមការងារដែលមានសមត្ថភាពខ្ពស់ក្នុងការអនុវត្តការវិភាគនេះប្រកបដោយប្រសិទ្ធភាពដែល ជាការបន្ថែមគំនិតថា រដ្ឋាភិបាលត្រូវផ្តោតការយលចិត្តទុកដាក់ទាំងកត្តាខាងក្នុង និងក្រៅនៅពេលអនុវត្តការវិភាគមូលធនមនុស្ស។ បញ្ហាប្រឈមសំខាន់ទីពីរនោះ គឺថានឹងមានការពិភាក្សាជាមួយវិស័យឯកជនទៀត។ បើគ្មានធនធានរបស់វិស័យឯកជននោះទេនោះការធ្វើកំណែទម្រង់នានាសូម្បីការបកស្រាយទិន្នន័យប្រកបដោយជំនាញក៏អាចមានភាពមិនត្រឹមត្រូវដែរ។ ការយល់ឃើញរបស់រដ្ឋាភិបាល គឺមានសារៈសំខាន់ណាស់ទាក់ទងនឹងការយល់ដឹងអំពីវិស័យជាច្រើនទៀតដោយផ្តើមចេញពីភាពខ្វះចន្លោះនៃជំនាញទៅផលប្រយោជន៍នៃការបណ្តុះបណ្តាលអាកប្បកិរិយារបស់និយោជិតសាជាថ្មីចំពោះកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលប្រហាក់ប្រហែលគ្នានេះ។ លើសពីនេះទៅទៀតទិន្នន័យទីផ្សារដែលក្រុមការងារអាចផ្តល់ជូនពាក់ព័ន្ធនឹងទីន្លែងដែលក្រុមការងារមើលឃើញពីវិវត្តនៃឧស្សាហកម្មនា ពេលអនាគតនោះនឹងជាគន្លឹះក្នុងការបង្កើតប្រព័ន្ធព្យាករណ៍ ថាតើសេដ្ឋកិច្ចនឹងប្រែប្រួលក្នុងឆ្នាំខាងមុខ និងសម្រាប់ធ្វើការកែសម្រួលដើម្បីការពារការអប់រំទុកជាមុនឱ្យស្របតាមតម្រូវការនាពេលអនាគតទាំងនេះ។

ដើម្បីប្រមូលព័ត៌មានវិភាគព័ត៌មាននោះ និងរកដំណោះស្រាយគោលនយោបាយត្រឹមត្រូវសម្រាប់ប្រព័ន្ធអប់រំដោយឈរលើការវិភាគនោះរដ្ឋាភិបាលនឹងត្រូវការសមត្ថភាពមូលធនមនុស្សយ៉ាងច្រើន។ ប្រសិនបើរដ្ឋាភិបាលសង្ឃឹមថា អាចមានសមត្ថភាពបំពេញកិច្ចការទាំងនេះបាន និងដោះស្រាយភាពស្មុគស្មាញផ្សេងនិងបំពេញភារកិច្ចពាក់ព័ន្ធផ្សេងៗតាមបែបរដ្ឋាភិបាលទំនើបបាននោះការអភិវឌ្ឍមូលធនមនុស្សក្នុងសេវាសាធារណៈជាអាទិភាពដ៏ចាំបាច់មួយ។

## ៤.៥ តួនាទីនៃការអភិវឌ្ឍមនុស្សក្នុងការវិនិយោគមូលធនមនុស្សនៅកម្ពុជា

ពេលអនាគតកម្ពុជាត្រូវផ្ដោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពទាំងក្នុងវិស័យឧស្សាហកម្ម សេដ្ឋកិច្ចធំៗ និងវិស័យសាធារណៈ។ ទោះបីជាយ៉ាងណាការយកចិត្តទុកដាក់របស់គោលនយោបាយលើឱនភាពនៃជំនាញក្នុងឧស្សាហកម្ម និងក្នុងរដ្ឋាភិបាល គឺភ្លេចគិតអំពីធាតុសំខាន់មួយនៃគោលនយោបាយពង្រីកនិងបង្កើនមូលធនមនុស្សឱ្យបានច្រើនជាពិសេសប្រឹងប្រែងកសាងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចពុទ្ធិសម្រាប់អនាគត។ គោលនយោបាយនេះ គឺនិយាយអំពីសមធម៌ ឱកាស និងគុណភាពជីវិតដូចបានបង្ហាញច្បាស់ក្នុងរបាយការណ៍អភិវឌ្ឍន៍មនុស្សជាបន្តបន្ទាប់របស់អង្គការ UNDP ។

សមធម៌ជាគោលបំណងមួយរបស់គោលនយោបាយធំៗ ចែងក្នុងគោលនយោបាយរបស់ប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿននៅអាស៊ីខាងត្បូង និងខាងកើត។ ហេតុផលគឺច្បាស់លាស់ណាស់។ សេដ្ឋកិច្ចស្ទើរទាំងអស់នេះ រួមមានឥណ្ឌា និងចិនបានឆ្លងកាត់ស្ថានភាពអាក្រក់បំផុតនៃសមភាពនៅពេលកំណើនសេដ្ឋកិច្ចបានចាប់ផ្ដើមចេញដំណើរ។ ហេតុផលគឺ មានច្រើន ដូចជា ការកែប្រែរចនាសម្ព័ន្ធឱ្យស្របតាមបន្ទាត់រូបមន្តសេដ្ឋកិច្ចនៃទ្រឹស្ដី "U" របស់ Kuznet ពង្រីកភាពខុសគ្នានៃប្រាក់កម្រៃការងាររវាងអ្នកមានជំនាញ និងអ្នកគ្មានជំនាញដោយសារការកើនឡើងនៃតម្រូវការសកលលោកចំពោះ ឱកាសការងារចូលបម្រើក្នុងទីផ្សារពលកម្មសកលលោកពង្រីកវិសមភាពក្នុងតំបន់កាន់តែធំដោយសារគំរូនៃនគរូបនីយកម្ម ការប្រមូលផ្ដុំនៃធនធានធម្មជាតិ និងការប្រមូលផ្ដុំនៃឧស្សាហកម្មនៅតែទីប្រជុំជនភាពខុសគ្នានៃឱកាសប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាននៅតាមតំបន់ និងទីតាំងភូមិសាស្ត្ររបស់ឧស្សាហកម្ម នៅក្បែរតំបន់សម្បូរទៅដោយមធ្យោបាយដឹកជញ្ជូន និងនាំចេញ។

នៅទីនេះមានចម្ងល់អំពីវិសមភាពពីរប្រភេទពាក់ព័ន្ធគ្នា។ ទីមួយ សន្ទុះល្បឿនយ៉ាងលឿននៃរបាយប្រាក់ចំណូលបានចាប់ផ្ដើមផ្លាស់ប្ដូរក្រោមផលប៉ះពាល់រួមនៃទីផ្សារមូលធនសកលលោក និងការប្រែប្រួលនៃរចនាសម្ព័ន្ធផលិតផលក្នុងស្រុកសរុប។ ចិនជាឧទាហរណ៍មួយដ៏ល្អអំពីល្បឿននៃវិសមភាពប្រាក់ចំណូលនេះ (រូប ៤.២) ជាពិសេសនៅតំបន់ទីប្រជុំជនអាចកើនល្បឿនយ៉ាងលឿន។ ដូចគ្នានេះដែរគឺប្រទេសឥណ្ឌា ឥណ្ឌូនេស៊ី និងថ្មីៗនេះគឺកម្ពុជា (មិនមានសូចនាករបញ្ជាក់)។

*រូប ៤.២ វិសមភាពសេដ្ឋកិច្ចប្រទេសនៅតំបន់អាស៊ីដែលបានជ្រើសរើស*




*សម្គាល់: សន្ទស្សន៍Gini: ការវាស់ស្ទង់នៃវិសមភាពរវាង០( គ្រប់អ្នកដែលមានប្រាក់ចំណូលស្មើគ្នា) និង១០០( អ្នកមានបំផុតទទួលបានប្រាក់ចំណូលទាំងអស់) ។*

*ប្រភព : UNDP របាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សឆ្នាំ ២០០៥ ទិន្នន័យរៀបចំឡើងវិញដោយក្រុម Strategic Asia ។*

ទីពីរ អន្តរកាលទៅរកសេដ្ឋកិច្ចទីផ្សាររួមផ្សំជាមួយការបាត់បង់ទីកន្លែងនៃសារពើពន្ធ និងគោល-នយោបាយក្នុងសេដ្ឋកិច្ចសកលលោកបានបង្កឱ្យមានការកាត់បន្ថយការផ្តល់ហិរញ្ញវត្ថុសម្រាប់សុខុមាលភាព និងការធានាសុវត្ថិភាពការងារ ។ អវសាននៃចលនាពលកម្មខ្លាំងក្លា និងយន្តការចរចាសមូហភាពនៃឧស្សាហកម្មក្នុងប្រទេសបានត្រឹមតែធ្វើឱ្យតួនាទីពលកម្មក្នុងប្រព័ន្ធនយោបាយចុះខ្សោយប៉ុណ្ណោះ ។ ទីបី ឧបករណ៍គោលនយោបាយដែលត្រូវបានធ្វើសិប្បរចនារួចហើយដើម្បីរក្សាវិសមភាពឱ្យនៅត្រឹមកម្រិតមួយដែលសង្គមទទួលយកបាន គឺមិនមានប្រសិទ្ធភាពរហូតទេ ។ លំអានប្រវត្តិសាស្ត្រនៃវិសមភាពតាមភូមិសាស្ត្រ និងវិសមភាពប្រាក់ចំណូលនៅតែបន្តក្លាយជាប្រភពនៃជម្លោះសង្គមនៅមូលដ្ឋាន និងជម្លោះ រើសអើងជាតិសាសន៍[២០] ហើយម្យ៉ាងទៀតបង្កឱ្យមានអស្ថិរភាពនយោបាយផងដែរ ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះបញ្ហាសមធម៌នៅក្នុងកំណើនសេដ្ឋកិច្ចកាន់តែអាក្រក់ទៅៗ ដោយសារមានការប្រែប្រួលរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប ហើយបានបង្កើនភាពមិនយឺតនៃកំណើនការងារ ប៉ុន្តែ បានបង្កើនភាពយឺតនៃការកាត់បន្ថយភាពក្រីក្រដល់កំណើនសេដ្ឋកិច្ច ។ តាមការពិតល្បឿនកំណើនយ៉ាងលឿននៅប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូងបានជួយកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរក្នុងរយៈពេលតែមួយទសវត្សរ៍ប៉ុណ្ណោះ ។ កម្ពុជាក៏ជាឧទាហរណ៍ដ៏ល្អមួយនៃទំនោរបែបនេះដែរ ។

២០ សម្រាប់ព័ត៌មានលម្អិតស្តីពីទំនាស់សូមស្វែងរក Mishra ឆ្នាំ ២០០៨ ។ តើប្រទេសឥណ្ឌូនេស៊ីងាយរងគ្រោះទៅនឹងទំនាស់ដែរឬទេ? ការវាយតម្លៃ ។

ក្នុងពិភពលោកនៃសេដ្ឋកិច្ចពុទ្ធិដែលដឹកនាំដោយនវានុវត្តភាព និងព័ត៌មានវិទ្យា សមធម៌ពិតជាត្រូវការវិសាលភាពដ៏សំខាន់មួយទៀត។ ឫសគល់នៃជោគជ័យរបស់សេដ្ឋកិច្ចពុទ្ធិ និងការកើនឡើងនូវផលិតផល និងបច្ចេកវិទ្យាថ្មីៗលើឆាកសេដ្ឋកិច្ចពិភពលោកជាការផ្សព្វផ្សាយពុទ្ធិយ៉ាងច្រើនឱ្យដល់មនុស្សស្ទើរតែគ្រប់គ្នា ក្នុងតម្លៃថោក និងចំណាយពេលវេលាសមស្រប។ នវានុវត្តភាព និងការបង្កើតផលិតផលថ្មីៗមិនត្រឹមតែជាសមិទ្ធផលសម្រេចកើតចេញពីការអប់រំក្នុងប្រព័ន្ធតាមគ្រឹះស្ថានល្បីៗធំៗទេ ប៉ុន្តែ ក៏ជាការផ្សព្វផ្សាយពុទ្ធិគ្រប់បែបយ៉ាងដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រនៃសេដ្ឋកិច្ចសកល។ សមធម៌នៃឱកាសទទួលព័ត៌មាន និងអន្តរកម្មរវាងវិស័យផ្សេងៗគ្នាជាកម្លាំងដឹកនាំសេដ្ឋកិច្ចពុទ្ធិថ្មីពីរដែលមានប្រសិទ្ធភាពបំផុត។ ដូច្នេះ ឧបករណ៍បច្ចេកវិទ្យាបានក្លាយជាក្តីកង្វល់មួយ គឺមិនមែនដោយសារឧបករណ៍បច្ចេកវិទ្យានេះបង្កើតឱ្យមានវិសមភាពប្រាក់ចំណូលរវាងតំបន់ និងមនុស្សផ្សេងៗគ្នាទេ ប៉ុន្តែឧបករណ៍បច្ចេកវិទ្យានេះដណ្តើមយក ឬឆក់យកឱកាសរបស់សហគមន៍ទាំងមូលកុំឱ្យរួមចំណែកដល់ដំណើរការបង្កើតនវានុវត្តភាព។ ដូចបានលើកឡើងខាងដើមរួចហើយ កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពទាមទារនូវកំណើនមូលធនមនុស្ស ទាំងគុណភាព និងបរិមាណ និងការចែករំលែកពុទ្ធិ និងការកែច្នៃបច្ចេកវិទ្យាទើបរកឃើញថ្មីឱ្យស្របតាមតម្រូវការនៃការប្រើប្រាស់សម្រាប់សេដ្ឋកិច្ចនៅកម្រិតមូលដ្ឋាន។ ទាំងឧត្តមភាព និងសមធម៌ជាកម្លាំងគន្លឹះដឹកមុខសេដ្ឋកិច្ចពុទ្ធិ។

តាមការពិត ការអភិវឌ្ឍមនុស្សខុសពីមូលធនមនុស្ស មិននិយាយតែអំពីផលិតភាពរបស់សហគ្រាស និងកម្មករទេ។ ការអភិវឌ្ឍមនុស្ស គឺអាស្រ័យលើទស្សនវិជ្ជាមួយដែលឱ្យនិយមន័យលើសុខុមាលភាពសង្គម ដោយមិនត្រឹមតែនិយាយអំពីប្រាក់ចំណូលមធ្យមសម្រាប់បុគ្គលម្នាក់ៗ និងអំពីអំណាចទិញ ប៉ុន្តែ ក៏និយាយអំពីសិទ្ធិសមត្ថភាព និងភាពខ្វះខាតផងដែរ។ ការអភិវឌ្ឍមនុស្សបញ្ជាក់អំពីសារៈសំខាន់នៃការពិតថាមនុស្សមិនត្រឹមតែជាកោសិកានៃមូលធនមនុស្សប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាអ្នកបញ្ចប់ដំណើរការអភិវឌ្ឍន៍ដោយខ្លួនឯងដែរ។ លាភធនសេដ្ឋកិច្ចប្រហែលជាត្រឹមត្រូវច្រើនជាងគេបំផុតនៅពេលមនុស្សមានឱកាសទទួលបានសុខភាពល្អ ការបណ្តុះបណ្តាល និងអប់រំក្នុងកម្រិតអប្បបរមាដែលអាចទទួលយកបានគ្រប់ៗគ្នា និងមានសេរីភាពចូលរួមក្នុងសកម្មភាពសង្គម និងនយោបាយក្នុងជីវិតរបស់ខ្លួនទេ។ យកទិដ្ឋភាពនេះមកវិភាគ ការពង្រីកមូលធនមនុស្សក្នុងរយៈពេលយូរមិនអាចមាននិរន្តរភាពបានទេ ប្រសិនបើពុំមានពេលវេលាដូចគ្នានឹងការលើកកម្ពស់ "ការអភិវឌ្ឍ"មនុស្ស ព្រោះការអភិវឌ្ឍមនុស្សជាចំណុចដែលមានការទទួលស្គាល់ច្រើនក្នុងឯកសារស្រាវជ្រាវទំនើបៗអំពីគុណភាពដែលខុសពីកម្រិតនៃអត្រាកំណើនសេដ្ឋកិច្ច។

*"...មនុស្សមិនត្រឹមតែជាកោសិកានៃមូលធនមនុស្សប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាអ្នកបញ្ចប់ដំណើរការអភិវឌ្ឍន៍ដោយខ្លួនឯងដែរ ។"*

*តារាង ៤.៥ អត្រាប៉ាន់ស្មាននៃភាពក្រីក្រនៅកម្ពុជាតាមរយៈការគណនាតាមបណ្តាខេត្តពីទិន្នន័យគោលឃុំ*

| ខេត្ត | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|---|
| ១. បន្ទាយមានជ័យ | ៣៩.៩ | ៣៨.៧ | ៣៧.១ | ៣៤.១ | ៣២.៥ | ៣១.៤ | ២៩.៧ |
| ២. បាត់ដំបង | ៣៧.៨ | ៣៦.៥ | ៣៥.៤ | ៣៣.៣ | ៣១.៧ | ២៩.៧ | ២៨.៧ |
| ៣. កំពង់ចាម | ៣៣.១ | ៣២.១ | ៣១.០ | ២៩.០ | ២៧.៦ | ២៥.៨ | ២៤.៣ |
| ៤. កំពង់ឆ្នាំង | ៣៧.៩ | ៣៧.២ | ៣៦.៧ | ៣៥.៦ | ៣៤.២ | ៣២.៣ | ៣០.៤ |
| ៥. កំពង់ស្ពឺ | ៤១.៤ | ៤០.៣ | ៣៩.៥ | ៣៧.៣ | ៣៥.២ | ៣២.២ | ៣០.១ |
| ៦. កំពង់ធំ | ៤១.១ | ៤០.៥ | ៣៩.៣ | ៣៧.៧ | ៣៦.៥ | ៣៤.៣ | ៣២.៧ |
| ៧. កំពត | ២៦.៦ | ២៥.៦ | ២៥.០ | ២៣.៤ | ២២.៤ | ២០.៥ | ១៩.១ |
| ៨. កណ្តាល | ២៧.៦ | ២៦.២ | ២៤.១ | ២១.២ | ១៩.៧ | ១៧.៦ | ១៥.៩ |
| ៩. កោះកុង | ៣៤.៨ | ៣៤.៧ | ៣២.៦ | ៣០.៧ | ២៩.០ | ២៦.៥ | ២៥.១ |
| ១០. ក្រចេះ | ៤៣.៩ | ៤៣.៣ | ៤២.៥ | ៤១.៥ | ៤០.២ | ៣៨.៦ | ៣៧.១ |
| ១១. មណ្ឌលគិរី | ៤៧.០ | ៤៥.១ | ៤៤.០ | ៤២.៤ | ៤០.៣ | ៣៨.០ | ៣៧.១ |
| ១២. ភ្នំពេញ | ៦.៨ | ៦.៩ | ៥.៨ | ០.៥ | ០.៣ | ០.២ | ០.១ |
| ១៣. ព្រះវិហារ | ៥០.២ | ៤៨.២ | ៤៧.២ | ៤៥.៧ | ៤៤.៥ | ៤៣.១ | ៤១.៥ |
| ១៤. ព្រៃវែង | ៣៣.២ | ៣៣.២ | ៣២.២ | ៣០.២ | ២៩.១ | ២៧.៣ | ២៥.៥ |
| ១៥. ពោធិ៍សាត់ | ៤០.៧ | ៣៩.៩ | ៣៩.០ | ៣៧.៥ | ៣៥.៨ | ៣៤.១ | ៣២.០ |
| ១៦. រតនៈគិរី | ៥០.៧ | ៤៨.៩ | ៤៦.៦ | ៤៥.០ | ៤៣.៨ | ៤១.៥ | ៤១.២ |
| ១៧. សៀមរាប | ៤២.២ | ៤០.៧ | ៣៨.៨ | ៣៦.០ | ៣៤.៤ | ៣២.៣ | ៣១.១ |
| ១៨. ព្រះសីហនុ | ៣១.៦ | ៣០.៧ | ២៩.៤ | ២៤.៨ | ២២.៨ | ២០.៥ | ១៩.៦ |
| ១៩. ស្ទឹងត្រែង | ៤៦.១ | ៤៥.៩ | ៤៦.១ | ៤៤.៣ | ៤៣.៥ | ៤២.៤ | ៤១.១ |
| ២០. ស្វាយរៀង | ៣២.៥ | ៣១.៦ | ៣០.១ | ២៧.៨ | ២៥.៩ | ២៣.៦ | ២១.៥ |
| ២១. តាកែវ | ៣១.៦ | ៣០.៧ | ២៩.២ | ២៨.១ | ២៦.៨ | ២៥.២ | ២៣.៤ |
| ២២. ឧត្តរមានជ័យ | ៤៦.៦ | ៤៥.៩ | ៤៤.០ | ៤២.៣ | ៤០.៦ | ៣៩.១ | ៣៦.៥ |
| ២៣. កែប | ៣៣.៦ | ៣៣.០ | ៣១.៥ | ២៨.៦ | ២៥.២ | ២២.៨ | ២១.៤ |
| ២៤. ប៉ៃលិន | ៤១.៧ | ៤០.៥ | ៣៨.៩ | ៣៦.៩ | ៣៥.០ | ៣១.០ | ២៨.១ |
| កម្ពុជា | ៣៥.១ | ៣៤.២ | ៣២.៩ | ៣០.៧ | ២៩.៣ | ២៧.៤ | ២៥.៨ |

*ប្រភព : របាយការណ៍គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ឆ្នាំ ២០១០ ។*

*តារាង ៤.៦ ខ្សែបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិតាមតំបន់ (ឆ្នាំ ២០០៤ និង ២០០៧)*
*(គិតជារៀលសម្រាប់ មនុស្សម្នាក់ ក្នុងមួយថ្ងៃ)*

| តំបន់ | | ២០០៤ | ២០០៧ |
|---|---|---|---|
| ភ្នំពេញ | អាហារ | ១.៧៨២ | ២.៤៤៥ |
| | មិនមែនអាហារ | ៥៦៩ | ៦៤៧ |
| | សរុប | ២.៣៥១ | ៣.០៩២ |
| តំបន់ប្រជុំជនដទៃទៀត | អាហារ | ១.៥៦៨ | ២.២៧៤ |
| | មិនមែនអាហារ | ៣៨៤ | ៤៣០ |
| | សរុប | ១.៩៥២ | ២.៧០៤ |
| តំបន់ជនបទ | អាហារ | ១.៣៩៨ | ១.៩៦៥ |
| | មិនមែនអាហារ | ៣៦៤ | ៤០២ |
| | សរុប | ១.៨២៦ | ២.៣៦៧ |
| ថ្នាក់ជាតិ | អាហារ | ១.៤៤២ | ២.០៤២ |
| | មិនមែនអាហារ | ៣៨៤ | ៤២៨ |
| | សរុប | ១.៨២៥ | ២.៤៧១ |

*ប្រភព : CSES ឆ្នាំ ២០០៧ តួលេខថ្នាក់ជាតិទទួលបានពីតំបន់នានាដោយប្រើប្រាស់ការប៉ាន់ស្មានចំនួនប្រជាជន CSES ឆ្នាំ ២០០៧*

*ប្រភព : របាយការណ៍គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ឆ្នាំ ២០១០ ។*

ដូចបានបង្ហាញក្នុង តារាង ៤.៥ និង ៤.៦ ថ្វីបើកម្ពុជាមានកំណើនថ្មីបំផុត និងគួរឱ្យភ្ញាក់ផ្អើលបំផុត ក៏កម្ពុជាត្រូវប្រឈមនឹងវិសមភាពយ៉ាងច្រើនបែបច្រើនយ៉ាងណាស់ ដូចជា វិសមភាពរវាងតំបន់ប្រជុំជន និងជនបទរវាងអ្នកមានការអប់រំខ្ពស់ និងអ្នកមានការអប់រំទាបរវាងខេត្តផ្សេងៗគ្នា ទៅតាមក្រុមអាយុ និងឧស្សាហកម្ម/មុខរបរផងដែរ ។ ផ្នែកមួយសំខាន់នៃផែនទីយុទ្ធសាស្ត្រអំពីមូលធនមនុស្ស គឺសំដៅកំណត់អំពីទំហំនៃការយកចិត្តទុកដាក់លើសមភាព និងការអភិវឌ្ឍមនុស្សក្នុងកម្មវិធីវិនិយោគមូលធនមនុស្ស ។ ការកំណត់ទំហំនៃការយកចិត្តទុកដាក់នេះមិនមែនជាទ្វេគ្រោះថ្មីទើបតែកើតឡើងទេប៉ុន្តែបញ្ហានេះបានកើតឡើងយូរហើយព្រមទាំងជំរុញបង្កើនតម្រូវការនៃការអប់រំឧត្តមសិក្សា ចលនាបំលាស់លំនៅដើម្បីការងារ និងតម្រូវការគោលនយោបាយកាន់តែច្រើនថែមទៀតនៃបញ្ហាយុវជនគ្មានការងារធ្វើ ឬយុវជនថិតក្នុងស្ថានភាពលំបាក ។

## ៤.៦ មូលធនមនុស្ស និងការទំនាក់ទំនងរវាងសង្គមស៊ីវិល-រដ្ឋ

ជាទីបញ្ចប់ការអភិវឌ្ឍមូលធនមនុស្ស គឺជាបុរេលក្ខខណ្ឌក្នុងដំណោះស្រាយថ្មីមួយនៃបញ្ហាគោលនយោបាយដែលពិបាកក្នុងការកំណត់ និងប្រហែលជាមិនត្រូវបានដោះស្រាយបានទៀតផង ប៉ុន្តែអាចត្រូវបានគ្រប់គ្រង និងរក្សាឱ្យនៅត្រឹមកម្រិតមួយសមរម្យបាន ។ "បញ្ហាលំបាក" បែបនេះ (ប្រអប់ ៤.២) បានបង្កើតឱ្យមានការសិក្សាផ្អែកលើគោលនយោបាយយ៉ាងធំធេងមួយនាពេលបច្ចុប្បន្ននេះ ។ ការពិតនៃការលំបាកនេះ

គឺបានឆ្លុះបញ្ចាំងពីបញ្ហានៃការបែងចែកប្រាក់ចំណូល ឬស្ថានភាពវប្បធម៌ ឬក្រុមជនជាតិចំពោះការអភិវឌ្ឍមានភាពពាក់ព័ន្ធគ្នា ហើយវិធីល្អបំផុតនោះដើម្បីធ្វើការដោះស្រាយគឺត្រូវបង្កើតឱ្យមានការព្រមព្រៀងទូទៅមួយលើឫសគល់នៃបញ្ហាក៏ដូចជាជម្រើសសម្រាប់ដំណោះស្រាយ ២២ "ដែលមានភាពយុត្តិធម៌" ផងដែរ។ ការព្រមព្រៀងតាមសហគមន៍បែបនេះទាមទារឱ្យមានទំនាក់ទំនង និងការពិគ្រោះយោបល់ជាបន្តបន្ទាប់រវាងរដ្ឋ-សង្គមស៊ីវិល។ កិច្ចព្រមព្រៀងទាំងនេះបានក្លាយជាលក្ខណៈសំខាន់នៃប្រជាធិបតេយ្យនាពេលបច្ចុប្បន្ននេះ បើទោះបីជាមានគំរូ និងដំណើរការផ្សេងៗគ្នាក្នុងការសម្រេចឱ្យបានកិច្ចព្រមព្រៀងបែបនេះក៏ដោយ។

នៅកម្ពុជាដំណើរការរបៀបនេះ អាចកាន់តែមានសារៈសំខាន់ក្នុងពេលអនាគត។ ហេតុផល គឺមិនត្រឹមតែនិយាយអំពីតម្រូវការក្នុងការដោះស្រាយបញ្ហានៃកំណើនវិសមភាព និងភាពអយុត្តិខាងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែ អំពីដំណើរការព្រមព្រៀងទាំងនេះនឹងមានសំខាន់ក្នុងការធ្វើពិពិធកម្មឧស្សាហកម្ម ឧ. ការជីករ៉ែ ឬក្នុងបរិបទនៃតំបន់សេដ្ឋកិច្ចពិសេសដែលបង្កើតបានជាតំបន់សេដ្ឋកិច្ចតូចៗ និងទម្រង់ថ្មីៗនៃការបែងចែកសង្គមផងដែរ។ ស្រដៀងគ្នានេះដែរទំនាក់ទំនងតាមឧស្សាហកម្មនឹងត្រូវការជាចាំបាច់ដោយរដ្ឋាភិបាល និងវិស័យឯកជន។ ហើយជាការពិតណាស់ដែលថា ការបង្កើតការត្រួតពិនិត្យជាសាធារណៈលើការផ្តល់សេវាអំពើពុករលួយក្នុងលទ្ធកម្មសាធារណៈ និងក្នុងពេលវេលាកំណត់នៃការផ្តល់សេវាប្រាកដជាមានសារៈសំខាន់ខ្លាំងណាស់ដែរ។ ជាថ្មីម្តងទៀតសមត្ថភាព និងជំនាញរបស់មន្ត្រី និងស្ថាប័នរដ្ឋាភិបាលក្នុងការបន្តកិច្ចសន្ទនា និងទំនាក់ទំនងសាជាធារណៈនេះ គឺជាទិសដៅដ៏សំខាន់មួយនៃការអភិវឌ្ឍមូលធនមនុស្សដូចដែលកម្ពុជារៀបចំសម្រាប់កំណើនសេដ្ឋកិច្ចនាពេលបន្ទាន់នេះទៀតផង។

*ប្រអប់ ៤.១ ការដោះស្រាយបញ្ហាលំបាក : ទស្សនាទាននៃគោលនយោបាយសាធារណៈ*

*ការចៀសវាងវិធីសាស្ត្រតូចចង្អៀត*

បញ្ហាគោលនយោបាយលំបាក មានភាពលំបាកក្នុងការដោះស្រាយឱ្យមានប្រសិទ្ធភាព ប្រសិនបើវិស័យសាធារណៈប្រើប្រាស់បច្ចេកទេសបុរាណ។ ទស្សនទាននៃគោលនយោបាយបុរាណបានលើកឡើងហើយថា វិធីល្អបំផុតដើម្បីឆ្លងឱ្យផុតពីបញ្ហានៃគោលនយោបាយ គឺត្រូវធ្វើដំណើរទៅតាមលំដាប់ និងមានដំណាក់កាលដោយធ្វើរដំណើរចេញពីបញ្ហាឈានទៅរកដំណោះស្រាយ។ ដំណើរការនេះជាធម្មតា នឹងចាប់ផ្តើមដោយការស្វែងយល់ និងកំណត់ពីបញ្ហា។ នៅពេលដែលកំណត់បញ្ហាបានច្បាស់លាស់រួមផ្សំនឹងការវិភាគលើភស្តុតាង និងការយល់ឃើញរបស់ភាគីពាក់ព័ន្ធ គឺអាចមានជម្រើសច្រើនព្រមទាំងជម្រើសសមរម្យមួយផងដែរ។ ដូច្នេះហើយក៏មានការកំណត់លទ្ធផលសម្រេចបានមានការរៀបចំផែនការអនុវត្ត ហើយមានគោលដៅបំពេញការងារបានយ៉ាងច្បាស់លាស់ផងដែរ។ ជាញឹកញាប់ មានការយល់ឃើញថាបញ្ហាកាន់តែស្មុគស្មាញការដោះស្រាយបញ្ហាតាមលំដាប់ក៏កាន់តែមានភាពសំខាន់ណាស់ដែរ។

ទោះជាយ៉ាងណា ក៏ការព្រមព្រៀងក្នុងការសិក្សានេះ គឺថាវិធីសាស្ត្រតាមដំណាក់កាល និងបែបបុរាណចំពោះការរៀបចំបង្កើតគោលនយាបាយមិនមែនជាមធ្យោបាយត្រឹមត្រូវសម្រាប់ធ្វើការដោះស្រាយបញ្ហាគោលនយោបាយលំបាកនោះទេ។ នេះដោយសារតែផ្នែកមួយនៃភាពលំបាកស្ថិតក្នុងអន្តរកម្មរវាងកត្តាហេតុ និងផលគោលបំណងនៃគោលនយោបាយចម្រូងចម្រាស់និងការមិនព្រមព្រៀងគ្នាលើដំណោះស្រាយសមរម្យ។ ទស្សនធ្វើតាមដំណាក់កាលមិនមានភាពសមរម្យក្នុងការបញ្ចូលអន្តរសកម្មភាព និងភាពមិនច្បាស់លាស់នេះ។ ភាពទន់ខ្សោយនៃវិធីសាស្ត្រតាមដំណាក់កាលក៏បណ្តាលមកពីភាពស្មុគស្មាញក្នុងសង្គមនៃបញ្ហាលំបាកទាំងនោះផងដែរ។

ការដោះស្រាយបញ្ហាលំបាកទាំងនោះ ទាមទារឱ្យមានទស្សនរួមជាជាងទស្សនតាមដំណាក់កាល។ ទស្សនៈនេះអាចចាប់យកអន្តរទំនាក់ទំនងរវាងបណ្តុំកត្តាហេតុ និងផលព្រមទាំងគោលបំណងនៃគោលនយោបាយបានទៀតផង។ ជាធម្មតាបញ្ហាលំបាកទាំងនោះ មានការលំបាកក្នុងការស្វែងយល់ ហេតុដូច្នេះហើយទើបមានការកំណត់ការធ្វើផែនការពីដំបូងមិនបានគ្រប់ជ្រុងជ្រោយ អាចនាំឱ្យមានការខ្វះចន្លោះពីសារៈសំខាន់នៃការដោះស្រាយបញ្ហាលំបាកទាំងនោះ។ ដោយសារតែមូលហេតុនេះ ហើយទើបធ្វើឱ្យបញ្ហាគោលចេះតែកើតមាន និងការបរាជ័យក្នុងការអនុវត្តគោលនយោបាយចេះតែកើនឡើងដោយមិនអាចដឹងមុន៧។

មានវិធីជាច្រើនដែលអង្គការនានាព្យាយាមគ្រប់គ្រងបញ្ហាលំបាកទាំងនោះ ដោយធ្វើឱ្យការដោះស្រាយបញ្ហាទាំងនោះមិនបានគ្រប់ជ្រុងជ្រោយ។ វិធីដែលសាមញ្ញបំផុត គឺការកំណតនិយមន័យនៃបញ្ហានោះ។ ជាញឹកញាប់វិធីនេះមានការដោះស្រាយបញ្ហាតូចតាចដែលអាចត្រូវបានដោះស្រាយ។ ប្រសិនជាមានបញ្ហាលើសទម្ងន់របស់កុមារនោះបញ្ហាដែលងាយក្នុងការដោះស្រាយតែបង្រួមបញ្ហាផងដែរ គឺត្រូវយកអាហារដែលគ្មានផាសុភាពចេញពីអាហារដ្ឋាននៅសាលា។

ប្រសិនបើគោលនយោបាយ និងវិធានការនៃការបំពេញការងារមានកំណត់ក្នុងការដោះស្រាយបញ្ហាតូចតាចជាងបញ្ហាលំបាកនោះការដោះស្រាយបញ្ហាតូចទាំងនោះនឹងមានរយៈពេលខ្លីបំផុត។ ឧទាហរណ៍ ប្រសិនបើវិធានការការងារ គឺជាការបញ្ឈប់ការផ្តល់អាហារគ្មានផាសុភាពក្នុងអាហារដ្ឋាន បញ្ហានេះអាចដោះស្រាយបាន។ ផលប៉ះពាល់ដោយមិនបានដឹងមុន និងភាពច្បាស់លាស់នៃបញ្ហាលំបាកនោះ គឺថាកុមារប្រហែលជាឈប់ញ៉ាំអាហារថ្ងៃត្រង់នៅអាហារដ្ឋានរបស់សាលានោះទៀត ប៉ុន្តែ ពួកគេមិនញ៉ាំអាហារថ្ងៃត្រង់ដូច្នេះហើយពួកគេអាចសន្សំប្រាក់សម្រាប់អាហារថ្ងៃត្រង់ព្រមទាំងទិញអាហារដែលគ្មានជីវជាតិនៅតាមតូបនៅតាមផ្លូវទៅសាលាជំនួសវិញ ៨។ នេះក៏ជាការលើកឡើងមួយពីផលប៉ះពាល់ដែលមិនដឹងមុនដែលអាចបណ្តាលមកពីការធ្វើអន្តរាគមន៍ក្នុងការដោះស្រាយពីបញ្ហាលំបាក។

ការលើកឡើងនេះ មិនមែនបានន័យថា នៅដំណាក់កាលមួយចំនួនក្នុងដំណើរការរៀបចំបង្កើតគោល-នយោបាយមិនចាំបាច់ក្នុងការកំណត់សមាសធាតុនៃបញ្ហាលំបាកនោះទេ និងដំណោះស្រាយជាក់ស្តែងដែលជាផ្នែកនៃវិធានការក្នុងការដោះស្រាយបញ្ហាដែលមានកិច្ចសហការ និងមានភាពទូលំទូលាយផងដែរ។ ជាការល្អការបែងចែកបញ្ហាលំបាកនេះគួរធ្វើឡើងបន្ទាប់ពីមានកំណត់ពិភាក្សា និងការដោះស្រាយគ្រប់អន្តរទំនាក់ទំនង និងភាពស៊ាំញ៉ាំក្នុងសង្គមទាំងអស់ដែលជាផ្នែកនៃយុទ្ធសាស្ត្រសម្របសម្រួលមួយ។

៧ M. Clarke និង J. Stewart ១៩៩៧ "ការដោះស្រាយបញ្ហាលំបាកបញ្ហាប្រឈមរបស់រដ្ឋាភិបាល" (មហាវិទ្យាល័យ Birmingham, School of Public Policy Discussion Paper) មហាវិទ្យាល័យ Birmingham ១៩៩៧ ទំព័រទី ៤។

៨ យោងទៅតាមកម្មវិធីទូរទស្សន៍ ABC "គំនិតខុសគ្នា" ("Beating the Bulge" ៨ មេសា ២០០៧) បញ្ហានេះបានកើតឡើងក្នុងសាលា NSW មួយចំនួនដែលបណ្តាលមកពីការទទួលយកជម្រើសនៃការទទួលទានអាហារដែលមានជីវជាតិក្នុងអាហារដ្ឋានរបស់សាលា។

*ប្រភព : ការដោះស្រាយបញ្ហាលំបាកទស្សនគោលនយោបាយសាធារណៈ ឆ្នាំ ២០០៧។*

"*ភាគីរដ្ឋមិនត្រឹមតែជាតួអង្គសំខាន់សម្រាប់ឆាកសេដ្ឋកិច្ចកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមជាស្ថានប័នប្រជាធិបតេយ្យចាក់ឫសគល់យ៉ាងរឹងមាំ។*"

## ៤.៧ សេចក្តីសន្និដ្ឋាន

ចំណុចពិភាក្សាខាងលើស្តីពីសារៈសំខាន់នៃការដាក់បញ្ចូលតម្រូវការមូលធនមនុស្ស និងភាពអវិជ្ជមានក្នុងវិស័យរដ្ឋ និងសង្គមស៊ីវិលដែលជាផ្នែកនៃយុទ្ធសាស្ត្រវិនិយោគមូលធនមនុស្សសម្រាប់កម្ពុជានាពេលអនាគត។ បញ្ហានេះជាការធ្វេសប្រហែសមួយក្នុងការយល់ឃើញថ្មីៗស្តីពីប្រធានបទនេះ។ ភាគីរដ្ឋមិន

ត្រឹមតែជាតួអង្គសំខាន់សម្រាប់ឆាកសេដ្ឋកិច្ចកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ ថែមជាស្ថានប័នប្រជាធិបតេយ្យចាក់ឫសគល់យ៉ាងរឹងមាំអស់រយៈពេលជាយូរមកហើយ ព្រមទាំងកំណែទម្រង់អភិបាលកិច្ចដែលមានអាទិភាពខ្ពស់ដែលបានបង្ហាញក្នុងយុទ្ធសាស្ត្រចតុកោណក៏ត្រូវបានអនុវត្តផងដែរ ។

លើសពីនេះទៀត ទស្សនអភិវឌ្ឍមនុស្សស្តីពីមូលធនមនុស្សដែលមានការចូលរួមយ៉ាងខ្លាំងក្លាក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ ក៏ដូចជាការបែងចែកដ៏ត្រឹមត្រូវនៃលទ្ធផលកំណើននៃការអភិវឌ្ឍនេះ គឺជាធាតុសំខាន់នៃយុទ្ធសាស្ត្រនានាស្តីពីការអភិវឌ្ឍមូលធនមនុស្ស ។ តុល្យភាពច្បាស់លាស់រវាងសមភាព និងការលើកកម្ពស់គុណភាពក្នុងសកម្មភាព និងជំនាញដែលបានកម្រិតមួយចំនួនអាចមានការកំណត់ឡើងដោយការព្រមព្រៀងថ្មីក្នុងសង្គម ។ ការចូលរួមជាសាធារណៈមានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យគុណភាពនៃទំនិញ និងសេវាសាធារណៈ ហើយកិច្ចខិតខំប្រឹងប្រែងនៃវិស័យអសន្យាណូនៃអភិបាលកិច្ចបានចូលរួមចំណែកយ៉ាងសំខាន់ផងដែរ ។ ទន្ទឹមនឹងនេះនៅមានវិស័យជាច្រើនទៀតដែលកង្វះមូលធនមនុស្សក្នុងជួររដ្ឋាភិបាលទាមទារឱ្យមានការបំពេញនូវកង្វះទាំងនេះផងដែរ ។

# ជំពូកទី ៥ : ធាតុផ្សំនៃផែនទីយុទ្ធសាស្ត្រមួយស្តីពីមូលធនមនុស្សនៅកម្ពុជា

"ទស្សនៈវិស័យនៃមូលធនមនុស្សនៅកម្ពុជាដែលកំពុងធ្វើដំណើរឆ្ពោះទៅមុខនេះ គួរប្រមូលផ្តុំការពិតដែលថា ការអប់រំត្រូវចាប់ផ្តើមពីឆ្នាំដំបូងនៃជីវិត។"

## ៥.១ តើមានផែនទីយុទ្ធសាស្ត្រស្តីពីមូលធនមនុស្សនៅកម្ពុជាដែរឬទេ?

ជំពូកមុនៗ បង្ហាញអំពីរបៀបដែលកម្ពុជាប្រឈមមុខនឹងនិន្នាការប្រែប្រួលនៃមូលធនមនុស្សដែលមានចំណងទាក់ទងផ្ទាល់រវាងការវិនិយោគលើមូលធនមនុស្សជាមួយនឹងកំណើនសេដ្ឋកិច្ច។ ខណៈពេលប្រឈមមុខនឹងស្ថានភាពបែបនេះ រដ្ឋាភិបាលកម្ពុជាក៏កំពុងប្រឈមនឹងបញ្ហាមួយក្នុងការកែប្រែទស្សនៈវិស័យអភិវឌ្ឍន៍របស់ខ្លួនតាមមធ្យោបាយដែលអាចជួយកម្ពុជាឱ្យលើកកម្ពស់ការវិនិយោគលើការអប់រំ ការបណ្តុះបណ្តាលជំនាញ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអភិវឌ្ឍភាពជាដៃគូរវាងសាធារណៈ និងឯកជនដើម្បីជាប្រយោជន៍ដល់សេដ្ឋកិច្ចទាំងរយៈពេលខ្លី និងរយៈពេលវែង។ គំនិតផ្តួចផ្តើមដែលកំពុងកើនឡើងនេះមានគោលបំណងបង្កើនភាពជាដៃគូរវាងសាធារណៈ និងឯកជនឱ្យបានច្រើន ហើយគំនិតផ្តួចផ្តើមនេះត្រូវបានគាំទ្រ និងធ្វើឱ្យប្រសើរឡើងដោយគំនិតមួយថា កំណើនសេដ្ឋកិច្ចអាចកើតឡើងបានដោយគ្រាន់តែឱ្យភាគីទាំងអស់ ទាំងរដ្ឋាភិបាល ឯកជន ម្ចាស់ជំនួយ និងសង្គមកម្ពុជាចូលរួមក្នុងដំណើរការនៃការធ្វើឱ្យប្រសើរឡើងនូវមូលធនមនុស្សប៉ុណ្ណោះ។ ថ្វីបើមានគំនិតផ្តួចផ្តើម និងសកម្មភាពបែបនេះច្រើនរួចហើយក៏ដោយ ក៏ទស្សនៈគ្រប់ជ្រុងជ្រោយនៃផែនការវិនិយោគ និងផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធដែលមានតួនាទីរួមចំណែកដល់ការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជានៅតែពុំទាន់មានភាពច្បាស់លាស់នៅឡើយដែរ។ ដោយសារមានស្ថានភាពពិបាកយល់បែបនេះភាគីពាក់ព័ន្ធទាំងអស់នៅខ្វះទស្សនៈវិស័យរួមមួយដែលអាចជួយជំរុញឱ្យធ្វើមជ្ឈការគោលនយោបាយ និងអ្នកអនុវត្តគោលនយោបាយទាំងអស់ឱ្យឈានឆ្ពោះទៅសម្រេចគោលដៅរួមតែមួយនេះ។

ទស្សនៈវិស័យនៃមូលធនមនុស្សនៅកម្ពុជាដែលកំពុងធ្វើដំណើរឆ្ពោះទៅមុខនេះ គួរប្រមូលផ្តុំការពិតដែលថាការអប់រំត្រូវចាប់ផ្តើមពីឆ្នាំដំបូងនៃជីវិត ហើយមិនត្រូវបញ្ចប់នៅត្រឹមសញ្ញាបត្រសាកលវិទ្យាល័យនោះទេ។ ជាក់ស្តែងក្នុងពេលបច្ចុប្បន្នប្រទេសជាច្រើនត្រូវប្រឈមនឹងបញ្ហានៃការរត់តាមឱ្យទាន់បំរែបំរួលសង្គម និងបច្ចេកវិទ្យា ហើយការអប់រំកំពុងវិវត្តទៅរកចំណុចមួយដែលថា ការសិក្សាមិនមែនចាប់ផ្តើមតែនៅបឋមវ័យនៃការអភិវឌ្ឍបុគ្គលដូចពីមុនទៀតទេ។ ជាក់ស្តែងសតវត្សរ៍ទី ២១ នេះ ត្រូវបានចាត់ទុកជាសតវត្សរ៍នៃ"ការសិក្សាពេញមួយជីវិត" ដែលមនុស្សជំនាន់នេះ និងជំនាន់ក្រោយៗត្រូវរំពឹងទទួលបានផលចំណេញពីការរៀនសូត្រក្នុងឱកាសកាន់តែច្រើនពេញមួយជីវិតដើម្បីបំពាក់បំប៉នចំណេះដឹងលើកកម្ពស់ជំនាញ និងធានាចីរភាពការងារ។

ប្រសិនបើការអភិវឌ្ឍមនុស្សចាប់ផ្តើមនៅថ្ងៃដំបូងនៃជីវិតមនុស្ស ហើយធានានិរន្តរភាពពេញមួយជីវិតនោះ ដំណើរការលើកកម្ពស់មូលធនមនុស្សក្នុងប្រទេសមួយមិនចាំបាច់ត្រូវការរយៈពេលវែងទេ។ ប្រសិនបើមានមនុស្សជាច្រើននាក់បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ហើយមូលដ្ឋានគ្រឹះបានចាប់ផ្តើមតាំងពីកម្រិតមត្តេយ្យ ហើយរាប់ទសវត្សរ៍អាចកន្លងហួសមុននឹងកម្មករដែលមានបំណិន និងជំនាញបំពាក់

បន្ថែមបានចូលទីផ្សារការងារ ឬមុនគោលនយោបាយអប់រំត្រូវបានគេមើលឃើញច្បាស់ថា មានកំហុសនៅពេលទីផ្សារការងារខ្វះអ្នកមានគុណវុឌ្ឍិសិក្សា។[២១ ២២ ២៣]

*ប្រអប់ ៥. ១ ការអប់រំ មូលធនមនុស្ស និងផលិតផលក្នុងស្រុកសរុប*

ឯកសារស្រាវជ្រាវភាគច្រើន អំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍មូលធនមនុស្សផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងផ្ទាល់រវាងមូលធនមនុស្ស និងផលសម្រេចបាន ឬកំណើនផលិតភាពគិតជាមធ្យម សម្រាប់មនុស្សម្នាក់ៗដែលបានវាស់ស្ទង់រួចហើយ ព្រមទាំងផ្តល់យោបល់ថា អន្តរាគមន៍នានាគួរផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់ការអប់រំឱ្យដល់មូលដ្ឋាន និងលទ្ធផលសម្រេចបានរបស់ការអប់រំ។ មូលធនមនុស្សជាទូទៅត្រូវបានវាស់ ដោយប្រើការអប់រំជារង្វាស់ -ជាទូទៅ គឺយករយៈពេលមធ្យមនៃចំនួនឆ្នាំចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងនៅឧត្តមសិក្សា។

ការក្រឡេកមើលទិន្នន័យនេះមួយភ្លែតបង្ហាញថា តំបន់ដែលមានអត្រាកំណើននៃការចូលរៀនលឿនបំផុតជាតំបន់ដែលបានចាប់ផ្តើមការចូលរៀនចាប់ពីកម្រិតទាបបំផុតដែរ។ ដូច្នេះពិបាកជឿថា ប្រទេសមួយដែលបានបង្កើនរយៈពេលមធ្យមនៃចំនួនឆ្នាំចូលរៀនពី ១ ឆ្នាំ ទៅ ២ ឆ្នាំ ពិតជាបានបង្កើនមូលធនមនុស្ស និងទិន្នផលរបស់ខ្លួនទ្វេដងណាស់[២០]។ មានទំនាក់ទំនងផ្ទាល់មួយរវាងការពិតមួយដែលថា មូលធនមនុស្សជានិទស្សន៍អនុគមន៍មួយនៃចំនួនឆ្នាំចូលរៀន និងចំណងទាក់ទងរវាងប្រាក់ចំណូល និងចំនួនឆ្នាំចូលរៀន។

Temple (២000)[២១] អះអាងថា ការស្រាវជ្រាវជាច្រើនមិនបានបញ្ចូលរង្វាស់សូចនាករនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមិនបានចាត់ទុកការបណ្តុះបណ្តាលវិជ្ជាជីវៈជាផ្នែកមួយនៃនិយមន័យមូលធនមនុស្សទេ។ ការសិក្សាស្រាវជ្រាវដោយ Broadberry និង Wagner (១៩៩៦)[២២] បានបង្ហាញថា ការបណ្តុះបណ្តាលវិជ្ជាជីវៈមានចំណងទាក់ទងយ៉ាងស្អិតរមួតជាមួយយុទ្ធសាស្ត្រផលិតកម្មរួម និងជាមួយកំណើនទិន្នផលជាតិ។ យ៉ាងណាមិញភាពសម្បូរបែបនៃអភិក្រមសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅប្រទេសនានា បង្កជាការលំបាកក្នុងការវាស់វែង និងកំណត់ចំនួនឱ្យបានច្បាស់លាស់សម្រាប់យកទៅបញ្ចូលក្នុងគំរូនៃការបណ្តុះបណ្តាលដែលអាចប្រៀបធៀបគ្នាបាននៅតាមប្រទេសនានា។ ជាញឹកញាប់ការធ្វើសេចក្តីសន្និដ្ឋានមានការលំបាក ដោយសារថានៅប្រទេសជាច្រើន ការបណ្តុះបណ្តាលតែងធ្វើឡើងតាមរយៈការអប់រំក្រៅប្រព័ន្ធវគ្គបំប៉នក្នុងពេលបំពេញការងារ ហើយមិនមានកត់ត្រាទុកជាលក្ខណៈប្រព័ន្ធទេ។

មូលធនមនុស្សមានរង្វាស់ខុសៗគ្នាច្រើន ហើយទាំងអស់សុទ្ធតែមានតម្លៃ។ រង្វាស់មូលធនមនុស្សល្អបំផុតដែលមានប្រើក្នុងពេលបច្ចុប្បន្ននេះ គឺរយៈពេលមធ្យមនៃចំនួនឆ្នាំចូលរៀនរបស់ប្រជាជនក្នុងក្រុមអាយុពី ២៥ឆ្នាំ ដល់ ៦៣ឆ្នាំ។ ដោយសារសារៈសំខាន់របស់មូលធនមនុស្សអាចកើនឡើងជាបន្តបន្ទាប់ រូបមន្តថ្មីៗនឹងត្រូវបង្កើតឡើងដោយច្របាច់បញ្ចូលគ្នានូវបរិមាណ និងគុណភាពរបស់មូលធនមនុស្ស ដូចជាបទពិសោធ និងតម្លៃព្រមទាំងការអប់រំបន្ត។

២១ OECD, Cohen កំណើន និងមូលធនមនុស្សឆ្នាំ២00៦។

២២ CEDEFOP/សហគមន៍អឺរ៉ុប Wilson និង Briscoe ផលប៉ះពាល់ផ្នែកមូលធនមនុស្សមកលើកំណើនសេដ្ឋកិច្ច : ការវាយតម្លៃ ឆ្នាំ២00៨។

២៣ CEDEFOP/សហគមន៍អឺរ៉ុប Wilson និង Briscoe ផលប៉ះពាល់ផ្នែកមូលធនមនុស្សមកលើកំណើនសេដ្ឋកិច្ច : ការវាយតម្លៃ ឆ្នាំ២00៨។

## ៥.២ កិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាល (កម្មវិធីរដ្ឋាភិបាលដែលមានស្រាប់)

ការយកចិត្តទុកដាក់ផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវកម្លាំងពលកម្មជំនាញជាតម្រូវការចាំបាច់នៅកម្ពុជាដែលមានការទទួលស្គាល់ជាយូរយារមកហើយ។ អាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០០៦-២០១០ មានដូចតទៅ :

១. ការលើកកម្ពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម
២. ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ
៣. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
៤. ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

គោលដៅទី ៤ ទាក់ទងនឹងឱនភាពនៃមូលធនមនុស្សលើកឡើងក្នុងរបាយការណ៍នេះក្នុងផ្នែកនេះ។ ផ.យ.អ.ជ. ២០០៩-២០១៣ ត្រូវបានចងក្រងក្រោមស្មារតីមួយ គឺសំដៅបង្កើនការយល់ដឹងអំពីបញ្ហាប្រឈមថ្មីៗបង្កឡើងដោយសារវិបត្តិហិរញ្ញវត្ថុខាងលើពាក់ព័ន្ធនឹងអនាគត និងការអភិវឌ្ឍរបស់កម្ពុជា។

គោលដៅទី ៤ នៃ ផ.យ.អ.ស ផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការអភិវឌ្ឍគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈដែលពាក់ព័ន្ធនឹងទីផ្សារការងារ ដោយផ្តោតលើ : (១) ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលរដ្ឋនៅតាមជនបទដើម្បីបង្កើនប្រាក់ចំណូល (២) ផ្តល់ការបណ្តុះបណ្តាល ឬការអភិវឌ្ឍជំនាញដល់កម្មកររោងចក្រដោយសហការជាមួយនិយោជក (៣) បន្តពង្រីកការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតាមខេត្តតាមរយៈកម្មវិធីបណ្តុះបណ្តាលអំពីសហគ្រិនភាព និង(៤) បង្កើតទីភ្នាក់ងារជាតិមួយសម្រាប់អាជីព និងការងារក៏ដូចជាមជ្ឈមណ្ឌលរកការងារនៅតាមខេត្ត និងយន្តការសម្រាប់ផ្សព្វផ្សាយព័ត៌មានទីផ្សារ។

### ៥.២.១ *ស្ថានភាពបច្ចុប្បន្ន ធៀបនឹងទស្សនៈវិស័យអនាគត*

បច្ចុប្បន្នរដ្ឋាភិបាលកម្ពុជាកំពុងព្យាយាមធ្វើឱ្យប្រសើរឡើងនូវកម្រិតមូលធនមនុស្សក្នុងកម្លាំងពលកម្មជាតិ។ ដោយសិក្សាលើកត្តាទាំងនេះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលគឺផ្តោតការយកចិត្តទុកដាក់លើវិធីសាស្ត្រសំខាន់ពីរក្នុងការចាត់ចែងការអប់រំ និងការបណ្តុះបណ្តាល គឺ ការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

#### ការអប់រំក្នុងប្រព័ន្ធ :

*“ការលើកកម្ពស់គុណភាពអប់រំជាកត្តាចាំបាច់មួយសម្រាប់ការអភិវឌ្ឍមនុស្ស និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។”*

ការលើកកម្ពស់គុណភាពអប់រំជាកត្តាចាំបាច់មួយសម្រាប់ការអភិវឌ្ឍមនុស្ស និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ រហូតមកដល់ទសវត្សរ៍ ១៩៩០ ចំណុចស្នូលនៃកំណែទម្រង់អប់រំ គឺកែលម្អទម្រង់នៃការផ្គត់ផ្គង់ ដូចជា ការសាងសង់សាលារៀនបន្ថែមការបង្កើនចំនួនគ្រូបង្រៀនការផ្តល់សម្ភារៈបង្រៀនបន្ថែម ។ល។ ចាប់ពីដើមទសវត្សរ៍ ២០០០ ចំណុចស្នូលនេះបានផ្លាស់ប្តូរទៅរកការបំពេញតម្រូវការដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើការផ្តល់ជំនួយដល់សិស្សានុសិស្សកម្ពុជា និងគ្រួសារដោយបំពេញតាមតម្រូវការសិក្សារបស់សិស្សានុសិស្សដែលអាចធានាឱ្យសិស្សានុសិស្សបានចូលរៀន តាមរយៈកម្មវិធីនានា ដូចជា ផែនការសកម្មភាពអាទិភាពដែលមានគោលបំណងសំដៅកាត់បន្ថយការចំណាយរបស់គ្រួសារកម្ពុជាលើការអប់រំ (ទាន ២០០៦)។

ផែនការយុទ្ធសាស្ត្រអប់រំ ២០០១-២០០៥ ជាការចូលរួមចំណែកទាន់ពេលវេលា ដល់កិច្ចការរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជំរុញសមភាពនៃឱកាសទទួលបានការអប់រំឱ្យបានទូលំទូលាយជាងមុន និងលើកកម្ពស់គុណភាពស្តង់ដារ និងការគ្រប់គ្រងសេវាអប់រំឱ្យកាន់តែប្រសើរ។ យុទ្ធសាស្ត្រនេះផ្អែកលើអភិក្រមគ្របដណ្តប់លើវិស័យ (SWAp) ដោយមានគោលដៅដោះស្រាយបញ្ហាប្រឈមចម្បងៗក្នុងវិស័យអប់រំព្រមទាំងបង្កើតភាពជាដៃគូដើម្បីអនុវត្តផែនការ និងកម្មវិធីរួមសម្រាប់ការអប់រំនៅគ្រប់កម្រិតទាំងអស់។ អភិក្រមគ្របដណ្តប់លើវិស័យនេះ (SWAp) បានបង្កើតយន្តការ ជាច្រើនឱ្យក្រសួង អ.យ.ក យកទៅប្រើដើម្បីតម្រឹមជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍ឱ្យស្របតាមតម្រូវការជាក់ស្តែងរបស់វិស័យអប់រំព្រមទាំងមានគោលបំណងកាត់បន្ថយចំណាយប្រតិបត្តិរដ្ឋបាលរបស់ក្រសួងអប់រំនិងចំណាយប្រតិបត្តិរដ្ឋបាលរបស់ដៃគូអភិវឌ្ឍន៍ផងដែរ។

បច្ចុប្បន្នយុទ្ធសាស្ត្រអប់រំថ្មីហៅថាផែនការយុទ្ធសាស្ត្រអប់រំ ២០០៦-២០១០ ផ្តោតការយកចិត្តទុកដាក់លើការធានាសម្រេចបន្ថែមលើសមិទ្ធផលកន្លងមក និងលើកកម្ពស់សមធម៌នៃឱកាសទទួលការអប់រំសម្រាប់កុមារកម្ពុជាទាំងអស់។ កម្ពុជាបន្តប្តេជ្ញាពង្រឹងគុណភាពអប់រំ និងបង្កើនវិភាជន៍ថវិកាចំណាយចរន្តឱ្យបានច្រើនសម្រាប់វិស័យអប់រំក្នុងកញ្ចប់ថវិកាជាតិដោយបង្កើនពី ១៨៣,២ ពាន់លានរៀល នៅ ឆ្នាំ២000 ឱ្យដល់ ៧៤២,៥ ពាន់លានរៀលនៅ ឆ្នាំ២០០៩។

ការរៀបរៀងផែនការវិស័យអប់រំ ២០០៦-២០១០ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត និងកម្រិតនៃការទទួលខុសត្រូវរបស់ក្រសួង អ.យ.ក ក្នុងការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍកម្ពុជាតាមរយៈការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ការធ្វើឱ្យប្រសើរឡើងនូវមូលធនមនុស្សជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រចម្បងៗចែងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទីបីនៃរដ្ឋសភាជាតិ។ ជាយុទ្ធសាស្ត្រគោលនយោបាយចតុកោណកំណត់ច្បាស់ដើម្បីបង្កើនល្បឿននៃកំណែទម្រង់អប់រំឈានទៅសម្រេចគោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ២០១៥ និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៤-២០១៥ [២៤]។

ក្រសួង អ.យ.ក កំពុងផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សដើម្បីពង្រឹងសមត្ថភាពនៃមូលធនមនុស្សរបស់ប្រទេស គឺជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រនិងដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារពលកម្ម គឺជំនាញ និងតម្លៃផ្អែកសហគ្រិនភាពច្នៃប្រឌិតការទទួលខុសត្រូវ វិន័យ សីលធម៌បុគ្គល ក្រមសីលធម៌ វិជ្ជាជីវៈ និងភាពស្មោះត្រង់[២៥]។

២៤ រាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអប់រំកម្ពុជាឆ្នាំ២០០៦-២០១០។
២៥ រាជរដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រអប់រំកម្ពុជាឆ្នាំ២០០៦-២០១០។

*ប្រអប់ ៥. ២ អន្តរាគមន៍ដឹកនាំដោយរដ្ឋាភិបាលលើមូលធនមនុស្សនៅកូរ៉េ*

ប្រទេសជាច្រើន បានឆ្លងកាត់បទពិសោធនៃការប្រែប្រួលកម្រិតមូលធនមនុស្សគួរឱ្យចាប់អារម្មណ៍កាលពី ២០ ឆ្នាំកន្លងមក។ ការប្រែប្រួលនេះអនុវត្តតាមគោលនយោបាយដែលមានគោលបំណងបង្កើនរយៈពេលមធ្យមនៃចំនួនឆ្នាំអប់រំ និងការបណ្តុះបណ្តាលជំនាញដែលមានគុណភាព។ ឧទាហរណ៍នៃការប្រែប្រួលនេះកើតមាននៅប្រទេសកូរ៉េខាងត្បូង។ ប្រទេសកូរ៉េខាងត្បូងអាចបង្កើនចំនួនសិស្សចូលរៀនច្រើនជាង ២០% ចាប់ពីឆ្នាំ១៩៨៥ និងឆ្នាំ ២០០០ និងបង្កើនរយៈពេលមធ្យមនៃចំនួនឆ្នាំចូលរៀនរហូតដល់ ១៣ឆ្នាំ។

ការប្រែប្រួលនេះអាចកើតឡើង តាមរយៈការវិនិយោគច្បាស់លាស់ក្នុងវិស័យអប់រំដែលមានថវិកាច្រើនជាង ៨% នៃផលិតផលក្នុងស្រុកសរុប និងតាមរយៈយុទ្ធសាស្ត្រនយោបាយមួយដែលមានគោលបំណងជំរុញមូលធនមនុស្សឱ្យមានសម្ទុះទៅមុខក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្ររយៈពេលវែង កំណត់យកជាពិសេសប្រជាជនពីបឋមវ័យ។

ដោយសារមានព័ត៌មានដ៏មានតម្លៃសម្រាប់ធ្វើចំណោលអំពីកំណើន ដំណើរការយឺតយ៉ាវនៃគោល-នយោបាយរយៈពេលវែងទាំងនេះ អាចបង្ហាញអំពីការអនុវត្តគោលនយោបាយសេដ្ឋកិច្ចដែលមានប្រសិទ្ធភាពស្រាប់ដោយសារនៅក្នុងបន្ទាត់នយោបាយមានរយៈពេលកំណត់ខ្លី។ កំណើនខ្ពស់មានន័យថា ផលចំណេញបានពីមូលធនមនុស្សតម្រូវឱ្យមានកំណែទម្រង់ធំៗឱ្យបានកាន់តែឆាប់កាន់តែល្អ បើទោះបីជាកំណែទម្រង់ទាំងនោះនឹងផ្តល់ផ្លែផ្កាក្នុងរយៈពេល១០ ឆ្នាំ ឬច្រើនជាងនេះទៅអនាគតទៀតក៏ដោយ។

នៅប្រទេសជាច្រើន ដូចជាកូរ៉េ ក្របខណ្ឌស្ថាប័នអប់រំមានវឌ្ឍនភាពជាច្រើនទសវត្សរ៍មកហើយ សម្រាប់ប្រើក្នុងការបង្កើនមូលធនមនុស្សឱ្យដល់កម្រិតអតិប្បបរមាឱ្យបានឆាប់រហ័សតាមរយៈគោលនយោបាយសមធមិដែលមានគោលបំណងចាត់ទុកសមធមិជាមធ្យោបាយដ៏សំខាន់បំផុតមួយក្នុងការប្រយុទ្ធនឹងភាពក្រីក្រទាំងនៅក្នុងប្រទេសអ្នកមាន និងប្រទេសក្រីក្រ។ ជាក់ស្តែងភាពខុសគ្នានៃការធានាសម្រេចគោលដៅអប់រំពន្យល់ផ្នែកសំខាន់នៃភាពខុសគ្នានៃការរកប្រាក់ចំណូលទាំងតាមបុគ្គលម្នាក់ៗ និងតាមប្រទេសនានា។

## ការបណ្តុះបណ្តាលវិជ្ជាជីវៈ :

កម្ពុជាបន្តប្រឹងប្រែងជំរុញការកសាងជំនាញតាមរយៈការអប់រំវិជ្ជាជីវៈ។ ការប្រឹងប្រែងនេះជាលទ្ធផលកើតចេញពីការពិតដែលថា សិស្សរៀនចប់មធ្យមសិក្សាជាច្រើននាក់មិនបានបន្តការអប់រំ ហើយក៏មិនបានចូលរៀនវគ្គបណ្តុះបណ្តាលជំនាញ ឬបានបន្តការសិក្សាកម្មវិធីនៅសាកលវិទ្យាល័យដែលពុំអាចរកការងារធ្វើបាន។ មុននឹងទទួលបានការងារធ្វើកម្មករវ័យក្មេងបានទទួលតិចតួច ឬមិនបានទទួលសោះនូវការត្រៀមខ្លួនសម្រាប់បង្កើតការងារសម្រាប់ខ្លួនឯង ហើយក្នុងវិស័យការងារក្នុងប្រព័ន្ធមានការងារតិចតួចណាស់សម្រាប់សិស្សទាំងនេះ។ សម្រាប់សិស្សជាច្រើននាក់ការបណ្តុះបណ្តាលវិជ្ជាជីវៈជាជម្រើសតែមួយគត់ដែលអាចបំពាក់ជំនាញមូលដ្ឋានសម្រាប់ត្រៀមធ្វើការងារ។

គោលបំណងនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺសំដៅបំពាក់ជំនាញដល់ក្មេងៗសម្រាប់ត្រៀមធ្វើការងារជីវិតសមរម្យ និងមានមុខរបរផ្ទាល់ខ្លួនអភិវឌ្ឍកម្លាំងពលកម្មដែលមានស្រាប់ជាបន្តបន្ទាប់ និងអភិវឌ្ឍខ្លួនឱ្យទាន់បច្ចេកវិទ្យា និងសកលភាវូបនីយកម្ម។ ការភ្ជាប់ទំនាក់ទំនងរវាងការបណ្តុះបណ្តាលការងារ និងមុខរបរផ្ទាល់ខ្លួន និងការជួយសិស្សបញ្ចប់ការសិក្សារកការងារធ្វើ គឺជាមូលដ្ឋានគ្រឹះនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

*“គុណវុឌ្ឍិនៃការបណ្តុះបណ្តាលវិជ្ជាជីវៈមានតម្លៃដ៏ធំសម្បើមសម្រាប់សិស្ស ប្រសិនបើកម្រិតគុណវុឌ្ឍិនោះត្រូវបានប្រើឱ្យតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពតាមស្តង់ដារដោយអ្នកផ្តល់សេវា។”*

*"កំណែទម្រង់របៀបវារៈសម្រាប់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍមូលធនមនុស្សជាអាទិភាពគន្លឹះមួយសម្រាប់កម្ពុជា ។"*

ក្នុងផែនការយុទ្ធសាស្ត្រ ២០០៦-២០១០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំណត់ផែនការលម្អិតមួយសំដៅបង្កើតកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យឆ្លើយតបតាមតម្រូវការនៃទីផ្សារការងារព្រមទាំងលើកកម្ពស់ការគ្រប់គ្រង និងផ្តល់ការងារដល់អ្នកស្វែងរកការងារផងដែរ ។ បច្ចុប្បន្នការបណ្តុះបណ្តាលវិជ្ជាជីវៈ និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីមានគោលបំណងផ្តល់ការបណ្តុះបណ្តាលជំនាញក្នុងតម្លៃថោកសមរម្យដល់សិស្សដែលពុំមានលទ្ធភាពបន្តការសិក្សានៅសាកលវិទ្យាល័យ ។

ការបណ្តុះបណ្តាលវិជ្ជាជីវៈមានតួនាទីសំខាន់មួយ គឺបង្រៀនយុវជនអំពីជំនាញដែលយុវជនត្រូវការយកទៅប្រើក្នុងកន្លែងធ្វើការជាពិសេសយុវជនក្រីក្រ ។ ដោយសារសារៈសំខាន់នេះ ជាការចាំបាច់ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវផ្តល់ប្រភេទជំនាញដែលត្រឹមត្រូវក្នុងកម្រិតគុណភាពមួយសមរម្យទទួលយកបាន ។ ជាញឹកញាប់ភាគីពាក់ព័ន្ធតែងលើកឡើង អំពីតម្រូវការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីតម្លៃនៃការបណ្តុះបណ្តាលវិជ្ជាជីវៈព្រោះការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានគុណភាពខ្ពស់ ហើយពាក់ព័ន្ធនឹងតម្រូវការនេះអាចផ្តល់ជំនាញជាក់ស្តែងដល់យុវជនដែលជំនាញនេះផ្តល់តម្លៃដោយនិយោជក ។ ប៉ុន្តែនៅតែមានទស្សនៈយល់ឃើញមួយថា ការបណ្តុះបណ្តាលវិជ្ជាជីវៈជាជម្រើសល្អបំផុតទីពីរសម្រាប់សិស្សដែលមិនបានសិក្សានៅសាកលវិទ្យាល័យ ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយនេះ គឺរកវិធីកែតម្រូវទស្សនៈយល់ខុសនេះ ។ ការយល់ខុសនេះអាចកើតឡើង មួយផ្នែកដោយសារភាពខុសគ្នានៃគុណភាពកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈខ្លះមានគុណភាពខ្ពស់ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈខ្លះទៀតមិនមានគុណភាព ហើយមិនពាក់ព័ន្ធនឹងតម្រូវការទីផ្សារការងារ ។ ការលើកដំកើងតម្លៃនៃការបណ្តុះបណ្តាលវិជ្ជាជីវៈនេះអាចទទួលបានជោគជ័យ លុះណាមានការប្រឹងប្រែងជាបន្តដើម្បីលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃការបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយនឹងតម្រូវការ ។

ប្រការសំខាន់មួយទៀតគឺថា ប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈមានទំនាក់ទំនងសមស្របជាមួយនឹងប្រព័ន្ធអប់រំឧត្តមសិក្សា ។ គុណវុឌ្ឍិនៃការបណ្តុះបណ្តាលវិជ្ជាជីវៈមានតម្លៃដ៏ធំសម្បើមសម្រាប់សិស្ស ប្រសិនបើកម្រិតគុណវុឌ្ឍិនោះត្រូវបានប្រើឱ្យតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពតាមស្តង់ដារដោយអ្នកផ្តល់សេវាអប់រំឧត្តមសិក្សា ដូចជាសកលវិទ្យាល័យជាដើម ។ ការធ្វើបែបនេះអាចជួយឱ្យសិស្សប្រើប្រាស់ការបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើជាមធ្យោបាយសម្រាប់បន្តការសិក្សាតទៅទៀត ។ ស្ថាប័នផ្តល់ការអប់រំ និងក្រសួងនានារបស់រដ្ឋាភិបាលគួររកមធ្យោបាយពង្រីកចំណងទាក់ទងគ្នារវាងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំឧត្តមសិក្សាឱ្យដល់កម្រិតអតិបរមា [២៦] ។

ផែនការយុទ្ធសាស្ត្រសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(២០០៨) ទទួលស្គាល់ពីតម្រូវការសម្រាប់ពង្រីក និងលើកកម្ពស់ជំនាញរបស់កម្លាំងពលកម្មដើម្បីបង្កើនអត្រាកំណើនសេដ្ឋកិច្ច ។ ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល (NTB) មានសមត្ថកិច្ចឆ្លើយតបនឹងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ដោយអនុវត្តតាមផែនការជាតិអភិវឌ្ឍន៍ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។ អគ្គនាយកដ្ឋានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់គ្រងយុទ្ធសាស្ត្រអនុវត្តន៍ថ្នាក់ជាតិកំណត់ដោយក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល ។ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាលអគ្គនាយកដ្ឋានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានបំណង (១) អភិវឌ្ឍន៍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រទេស

២៦ ILO យុវជន និងការងារ ការឆ្លងកាត់ការលំបាក ។

ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចស្របតាមយុទ្ធសាស្ត្រចតុកោណ (២) ផ្តល់កម្លាំងពលកម្មដែលមានជំនាញ និងសមស្របតាមតម្រូវការដល់សហគ្រាស ហើយ (៣) ឆ្លើយតបតាមតម្រូវការការងារដែលមានប្រាក់ចំណូលសមរម្យពេញមួយជីវិត ឬផ្តល់មុខរបរផ្ទាល់ខ្លួនសមស្របដោយមានការណ្តុះបណ្តាលសមស្រប។

ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល បានអនុម័តផែនការជាតិអភិវឌ្ឍន៍ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកដំបូងនៅ ឆ្នាំ២០០៦ ហើយផែនការនោះកំណត់អភិក្រមអភិវឌ្ឍន៍ពីរច្រករបស់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដោយផ្តោតអាទិភាពលើការកាត់បន្ថយភាពក្រីក្រ។ យន្តការហិរញ្ញវត្ថុពីរត្រូវបានបង្កើតឡើង ដើម្បីធានានិរន្តរភាពនៃដំណើរការការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺមូលនិធិជាតិបណ្តុះបណ្តាលគាំទ្រដោយមូលនិធិរបស់រដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ (ESDP II) គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។

រដ្ឋាភិបាលកម្ពុជាយល់ឃើញថា សម្រាប់អនាគតដ៏ខ្លីខាងមុខផែនការរយៈពេលខ្លីល្អបំផុតសម្រាប់កាត់បន្ថយភាពក្រីក្រ និងធានាកំណើន (ជាពិសេសនៅតំបន់ជនបទ) គឺការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិមានបំណងបង្កើនធនធានជនបទ តាមរយៈការបង្កើនការយកចិត្តទុកដាក់លើសកម្មភាពដែលមានផលច្រើន ដូចជា វិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងសុខាភិបាលព្រមទាំងវិស័យអប់រំ ដើម្បីបង្កើន និងធ្វើឱ្យប្រសើរឡើងនូវមូលធនមនុស្ស និងរួមចំណែកឱ្យបានកាន់តែប្រសើរដល់ការអភិវឌ្ឍន៍រួម។ រដ្ឋាភិបាលកម្ពុជាក៏ទទួលស្គាល់ផងដែរអំពីកំណើននៃសម្ពាធដែលយុវជនទើបបញ្ចប់មធ្យមសិក្សាកំពុងប្រឈម ហើយមានជម្រើសទទួលការបណ្តុះបណ្តាលតិចតួចព្រមទាំងមានការលំបាកក្នុងការជ្រើសរើសសិស្សក្រោយមធ្យមសិក្សាឱ្យចូលរៀននៅគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ដូច្នេះ រដ្ឋាភិបាលកំពុងរិះរកមធ្យោបាយពង្រឹងការអភិវឌ្ឍជំនាញតាមសហគមន៍ដោយផ្តោតការយកចិត្តទុកដាក់ថ្មីលើការពង្រឹងការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតាមគ្រឹះស្ថាន។

សមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាលត្រូវភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍជំនាញ ជាមួយតម្រូវការរបស់សហគ្រាស និងរបស់សហគមន៍ហើយត្រូវយកចិត្តទុកដាក់លើបំរែបំរួលសេដ្ឋកិច្ច និងការប្រែប្រួលផ្សេងៗកើតឡើងដោយសារមានតម្រូវការជំនាញ និងដោយសារចង្វាក់នៃការផ្គត់ផ្គង់ជំនាញទៅឱ្យទីផ្សារនាពេលបច្ចុប្បន្ន។ ប៉ុន្តែចំណុចដែលត្រូវកត់សម្គាល់គឺថា សមត្ថកិច្ចនេះត្រូវសហការយ៉ាងស្អិតរមួតរវាងក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល និងវិស័យឯកជន។ ជាក់ស្តែងកិច្ចប្រឹងប្រែងក្នុងភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ឬអាចនិយាយបានថា ការចូលរួមជាមួយគ្នារវាងវិស័យទាំងពីរនេះ គឺមានតិចតួចណាស់។

*តារាង ៥.១អត្រាកំណើននៃឧស្សាហកម្មតាមវិស័យ កំពុងកែលម្អនូវអ្វីដែលមានបង្រៀន ក្នុងការអប់រំវិជ្ជាជីវៈនៅកម្ពុជា*

| | 2005 | 2006 | 2007 |
|---|---|---|---|
| វាយនភ័ណ្ឌ | 10.3 | 21.9 | 17.6 |
| វិស័យម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | 8.0 | 2.5 | 5.0 |
| ផលិតកម្មផ្សេងៗ | 10.2 | 8.6 | 5.5 |
| អគ្គិសនី ហ្គាស និងទឹក | 4.5 | 4.7 | 6.3 |
| សំណង់ និងរ៉ែ | 20.4 | 15.5 | 11.8 |
| ឧស្សាហកម្មសរុប | 12.3 | 17.1 | 14.1 |

*ប្រភព : ផែនការយុទ្ធសាស្ត្រផ្នែកអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (EIC: Cambodia Economic Watch, April ២០០៧)។*

ទិន្នន័យទាក់ទងនឹងកំណើននៃឧស្សាហកម្មភាគច្រើនមានសារៈសំខាន់សម្រាប់បង្ហាញអំពីកំណើននៃតម្រូវការកម្មករជំនាញ និងសម្រាប់បង្ហាញអំពីវិស័យដែលមានកំណើនលឿនបំផុតដែលត្រូវផ្តោតការយកចិត្តទុកដាក់យ៉ាងឆាប់បំផុត ជាពិសេសលើការវិភាគអំពីតម្រូវការ។ របាយនៃការងារតាមវិស័យផ្សេងៗក៏អាចបញ្ជាក់អំពីសារៈសំខាន់នៃការវិនិយោគលើផលិតភាពនៅតាមជនបទផងដែរ ដូចការផ្តោតការយកចិត្តទុកដាក់លើការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងការកាត់បន្ថយភាពក្រីក្រដែរ។ របាយនៃការងារនេះទាមទារឱ្យមានវិធានការតម្រឹមកំណើននៃវិស័យផ្សេងៗឱ្យត្រូវជាមួយនឹងការវិភាគគោលនយោបាយក្នុងការបំពេញតម្រូវការពលកម្មជំនាញ។ ការផ្តោតការយកចិត្តទុកដាក់បន្ថែមលើការយល់ដឹងអំពីទីកន្លែងដែលត្រូវការការងារនៅកម្ពុជាជាការជួយព្យាករណ៍ អំពីរបាយនៃការងារ និងជំនាញសម្រាប់ផ្តល់ធាតុបញ្ចូល និងការដឹកនាំឱ្យបានត្រឹមត្រូវទៅដល់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ អន្តរាគមន៍របស់រដ្ឋាភិបាល គឺត្រូវផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្ររយៈពេលខ្លីដើម្បីបំពេញគម្លាតនៃតម្រូវការជំនាញសម្រាប់យុវជនភាគច្រើននៅកម្ពុជា។

*ប្រអប់ ៥.៣ ឱកាសទទួលទូរសិក្សា*

**UNAM (National Autonomous University of Mexico)៖**

**វិនិយោគថ្លៃសិក្សាដើម្បីបំពេញតម្រូវការ នៃសេដ្ឋកិច្ចពុទ្ធិ**

បច្ចុប្បន្នទូរសិក្សាផ្តល់ឱកាសយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋម៉ិចស៊ីកូ ជួយប្រជាពលរដ្ឋឱ្យបន្តការសិក្សាតាមល្បឿន និងពេលវេលាសមស្របតាមតម្រូវការរបស់អ្នកសិក្សា ហើយទូរសិក្សានេះក៏បានក្លាយជាជម្រើសដ៏ប្រសើរមួយសម្រាប់ការអប់រំក្នុងប្រព័ន្ធដែរ។ វិធីបណ្តុះបណ្តាលរបស់ទូរសិក្សា ក្លាយជាជម្រើសដ៏មានប្រយោជន៍មួយសម្រាប់ការបន្តការសិក្សារបស់អ្នកមានអាជីព និងមនុស្សចាស់ដោយផ្សព្វផ្សាយទស្សនៈអំពី "ការសិក្សាពេញមួយជីវិត"។ ការចាប់ផ្តើមយកថ្លៃសិក្សានៅទសវត្សរ៍ ១៩៩០ បានជួយសាកលវិទ្យាល័យរបស់ប្រទេសម៉ិចស៊ីកូឱ្យលើកកម្ពស់សមត្ថភាពរបស់ខ្លួនដើម្បីទាញយកប្រយោជន៍ពីសេដ្ឋកិច្ចពុទ្ធិ ហើយបច្ចេកវិទ្យាព័ត៌មានក៏បានចូលរួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍទូរអប់រំនៅប្រទេសម៉ិចស៊ីកូដែរ។ វិទ្យាស្ថានផ្តល់សេវាទូរសិក្សានៅប្រទេសម៉ិចស៊ីកូ ផ្តល់សេវាវគ្គសិក្សាតាមគេហទំព័រតាមរយៈខ្សែអាត់វីឌីអូ ឌីវីឌី ខ្សែអាត់សម្លេងស៊ីឌីសម្លេង និងតាមម៉ាស៊ីនចាក់ស៊ីឌី ពោលគឺអាស្រ័យលើលក្ខណៈរបស់វគ្គសិក្សានោះ ដូច្នេះតម្រូវការបង្រៀនដោយផ្ទាល់រវាងសិស្ស និងគ្រូមិនចាំបាច់ត្រូវការទៀតទេ។ ដោយសារទូរសិក្សានេះទទួលបានប្រជាប្រិយភាពកាន់តែខ្លាំងក្នុងចំណោមនិស្សិត សាកលវិទ្យាល័យកាន់តែច្រើននៅប្រទេសម៉ិចស៊ីកូ បានចាប់ផ្តើមផ្តល់សេវាទូរសិក្សានេះ។

**ការសិក្សាតាមប្រព័ន្ធអ៊ីធើណែតនៅតាមសាកលវិទ្យាល័យនៅប្រទេសអេស្ប៉ាញ***

សាកលវិទ្យាល័យ Open University of Catalonia (UOC) នៅប្រទេសអេស្ប៉ាញ មានប្រវត្តិជាយូរមកហើយក្នុងវិស័យផ្តល់សេវាសិក្សាតាមប្រព័ន្ធអ៊ីធើណែតនេះ ហើយពេលបច្ចុប្បន្នការសិក្សានៅសាកលវិទ្យាល័យនេះបានក្លាយជាការសិក្សាតាមប្រព័ន្ធអ៊ីធើណែត ១០០% ។ និស្សិតជាចំណុចចាប់អារម្មណ៍បំផុតក្នុងកម្មវិធីបណ្តុះបណ្តាលនេះ ហើយសាកលវិទ្យាល័យនេះកំពុងក្លាយជាចំណុចសំខាន់សម្រាប់វិធីសាស្ត្រសិក្សាបែបថ្មីនេះ ។ សាលាកវិទ្យាល័យនេះបានផ្លាស់ប្តូរពីដំណាក់កាលដែលសាស្ត្រាចារ្យកំពុងបង្រៀននិស្សិតទៅជាការបង្រៀនដែលសាស្ត្រាចារ្យមហាវិទ្យាល័យពិនិត្យតាមដានការសិក្សាវិញ ហើយនិស្សិតអាចទទួលបានចំណេះដឹងដែលពួកគេត្រូវការដោយផ្ទាល់ ។ ឧទាហរណ៍ កុំព្យូទ័ររបស់ UOC អនុញ្ញាតឱ្យនិស្សិតស្វែងរកអ្វីៗតាមតម្រូវការតាមបំណងតាមរយៈកំណត់សម្គាល់បង្ហាញអំពីការរៀបចំផែនការ និងការកំណត់ពេលវេលាការទំនាក់ទំនងរវាងគ្រូ និងសិស្សក្នុងថ្នាក់បណ្ណាល័យអេឡិចត្រូនិចប្រភពព័ត៌មានលើគេហទំព័រការធ្វើតេស្ត និងវាយតម្លៃលទ្ធផលសិក្សា ។

និស្សិតជាច្រើនដែលបានចូលរៀននៅ UOC ជាបុគ្គលិកធ្វើការពេញម៉ោង ឬមានគ្រួសារ ឬមានការងារផ្សេងៗ ។ និស្សិតភាគច្រើនមកសិក្សានៅ UOC ដើម្បីបន្តការសិក្សាថ្នាក់ក្រោយឧត្តមរៀនយកវិញ្ញាបនបត្រជំនាញ ឬដើម្បីបំពេញលក្ខខណ្ឌតម្រូវយកទៅបញ្ចប់បរិញ្ញាបត្រ ។ ដោយសារមានបច្ចេកវិទ្យា និងសេដ្ឋកិច្ចពុទ្ធិ UOC បានទទួលស្គាល់ថា ទូរដ្ឋានអប់រំមិនគ្រាន់តែជាការថតខ្សែវីឌីអូ និងបង្ហោះខ្សែវីឌីអូ លើប្រព័ន្ធអ៊ីធើណែតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបង្កើតមធ្យោបាយកែច្នៃតាមស្ថានការណ៍ និងមធ្យោបាយអន្តរកម្មដើម្បីជួយនិស្សិតឱ្យដំណើរការសិក្សាបានងាយស្រួល ។ កុំព្យូទ័រមិនគ្រាន់តែជាចំណុចប្រសព្វគ្នាសម្រាប់ទូរដ្ឋានសិក្សាដែលមានគុណភាពខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែបច្ចេកវិទ្យាចល័តក៏ជួយសម្រួលដល់អន្តរកម្មនៃការសិក្សាដោយបង្កើនសមត្ថភាព និងបង្កឱកាសទទួលអប់រំដល់និស្សិតកាន់តែច្រើនថែមទៀតផង ។

* អង្គភាពចារសេដ្ឋកិច្ចវិទូ "អនាគតនៃការអប់រំឧត្តមសិក្សា ៖ តើបច្ចេកវិទ្យានឹងផ្លាស់ប្តូរទម្រង់នៃការសិក្សាបានយ៉ាងដូចម្តេច" ខែតុលា ឆ្នាំ ២០០៨

## ៥.៣ គំនិតផ្តួចផ្តើមរបស់វិស័យឯកជន និងគំនិតផ្តួចផ្តើមរួមរវាងឯកជន និងរដ្ឋាភិបាល

កំណែទម្រង់របៀបវារៈសម្រាប់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍមូលធនមនុស្សជាអាទិភាពគន្លឹះមួយសម្រាប់កម្ពុជា បើទោះជាវឌ្ឍនភាពត្រូវបានរារាំងដោយសារការមិនទាន់ប្រមូលផ្តុំគ្នាក៏ដោយ ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិមានទស្សនាទានមួយ គឺវិស័យឯកជនដឹកនាំកំណើន ប៉ុន្តែ វឌ្ឍនភាពក្នុងវិស័យឯកជននេះត្រូវជួបការលំបាកដោយសារការមិនប្រមូលផ្តុំកម្លាំងរបស់រដ្ឋាភិបាល ។ ការមិនប្រមូលផ្តុំកម្លាំងគ្នាក្នុងរដ្ឋាភិបាលក៏កើតឡើងដោយសារការមិនប្រមូលផ្តុំកម្លាំងគ្នារបស់ដៃគូអភិវឌ្ឍន៍ផងដែរ ។

បច្ចុប្បន្នអន្តរាគមន៍របស់រដ្ឋាភិបាលក្នុងការកសាងជំនាញមិនមានកម្រិតទាបទៀតទេ ដោយសារ "ការបណ្តុះបណ្តាលក្នុងប្រព័ន្ធ" និងដោយសារយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍមូលធនមនុស្សកំពុងងាកមករកការចូលរួមរបស់វិស័យឯកជនផងដែរ ។ យ៉ាងណាមិញដើម្បីឱ្យវិស័យឯកជនចូលរួមចាំបាច់ត្រូវមានការលើកទឹកចិត្តសម្រាប់អនុវត្តជាស្រេចផងដែរ ។ សហគ្រិនទាមទារឱ្យមាន "ស្ថានភាពបង្កបរិយាកាសល្អ" ក្នុងការផ្តល់ការណែនាំគោលនយោបាយសេវាគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវ័ន្តជាចាំបាច់ ។ ដោយសារមានស្ថានភាពប្រព័ន្ធគាំទ្រទាំងនេះវិស័យឯកជននឹងមានឆន្ទៈកាន់តែខ្លាំងថែមទៀតក្នុងការចូលរួមអភិវឌ្ឍន៍

មូលធនមនុស្សដោយធានាសម្រេចផលប្រយោជន៍អាជីវកម្មរបស់ខ្លួន។ ឧទាហរណ៍ ផលចំណេញទទួលបានពីការចូលរួមនេះ រួមមានកំណត់របៀបវារៈដែលមានតម្លាភាព ធានាឱ្យមាន គណនេយ្យភាពរបស់វិស័យសាធារណៈ និងការប្រើប្រាស់ធនធានឱ្យដល់កម្រិតអតិប្បបរមាដោយឈរលើអាទិភាពដែលបានឯកភាពគ្នា និងដោយមានការចរចាររវាងរដ្ឋាភិបាល និងផ្នែកស៊ីវិល។

គំនិតផ្តួចផ្តើមសកម្មភាពដែលបានកំណត់រួច រួមមាន វេទិការដ្ឋាភិបាល និងឯកជន ដែលកន្លងមកទទួលបានការកោតសរសើរយ៉ាងខ្លាំង។ ប្រព័ន្ធនេះបានជួយជំរុញឱ្យដំណើរការនៃកំណែទម្រង់បានសម្រេចលទ្ធផលល្អប្រសើរ និងបង្កើតឱ្យមានផលប៉ះពាល់ជាប្រយោជន៍សេដ្ឋកិច្ចផ្ទាល់ និងអាចវាស់វែងបានផងដែរ។ ឧទាហរណ៍អំពីភាពជោគជ័យនៃគំនិតផ្តួចផ្តើមទាំងនេះ រួមមានការប្រឹក្សាស្តីពីច្បាប់វិនិយោគ និងច្បាប់ពន្ធការណែនាំឱ្យអនុវត្តការតាមដានរបស់វិស័យឯកជនក្នុងនាយកដ្ឋានគយ និងអនុវត្តស្តង់ដារពលកម្មដែលមានភាពល្អប្រសើរ។ ម្យ៉ាងវិញទៀតសភាពាណិជ្ជកម្មកម្ពុជាបានដើរតួតិចតួចក្នុងការជំរុញឱ្យរដ្ឋាភិបាលចូលរួមជាមួយវិស័យឯកជនណាស់។ ជំហរជាទូទៅរបស់ក្រុមហ៊ុនទំនងថាប្រសិនបើក្រុមហ៊ុនមិនតម្រូវឱ្យចូលជាសមាជិកសភាពាណិជ្ជកម្មនោះទេ ពួកគេនឹងមិនចូលរួមដោយស្ម័គ្រចិត្តទេ។

*ប្រអប់ ៥.៤ ការលាតត្រដាងការរស់រឿនឡើងវិញនៃសេដ្ឋកិច្ចនៅអាស៊ី*

ការសិក្សារបស់ធនាគារពិភពលោក ស្តីពី "អភូតហេតុ" នៅតំបន់អាស៊ីបូព៌ា បានផ្តល់ការកោតសរសើរខ្លះដល់ភាពជោគជ័យរបស់តំបន់អាស៊ីបូព៌ា (រួមមាន ប្រទេសថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី) ក្នុងការបង្កើតទំនាក់ទំនងរវាងសហគ្រិន និងរដ្ឋ។ ជាពិសេស ការសិក្សានេះបានបង្ហាញថា រដ្ឋបានចូលរួមភាគហ៊ុនប្រកបដោយផ្លែផ្កាជាមួយសហគ្រិនដោយទទួលបានផង និងផ្តល់ឱ្យផងនូវការណែនាំស្តីពីឧស្សាហូបនីយកម្ម។ ទន្ទឹមនឹងនោះដែរ ការចូលរួមជាមួយសហគ្រិនកំណត់ចំណាត់ថ្នាក់ប្រទេសអាស៊ីភាគខាងជើងជាមួយប្រទេសជប៉ុន ជាឧទាហរណ៍ដំបូងបំផុត។ ការប្រឹក្សាបែបនេះបានចាប់ផ្តើមក្នុងស្ថានភាពល្អប្រសើរបំផុតនៅតំបន់អាស៊ីអាគ្នេយ៍។ ប៉ុន្តែ ប្រទេសនៅតំបន់នោះបានខិតខំប្រឹងប្រែងបង្កើតយន្តការប្រឹក្សានេះឱ្យបាន។ ម៉ាឡេស៊ីជាប្រទេសមួយដែលបានបង្កើតយន្តការបែបនេះច្រើនជាងគេ ហើយការផ្តល់ប្រឹក្សាផ្លូវការធំៗបានចាប់ផ្តើមនៅ ឆ្នាំ១៩៩១។ ត្រឹម ឆ្នាំ១៩៩៣ ប្រទេសឥណ្ឌូនេស៊ីពុំទាន់មានទំនាក់ទំនងផ្លូវការរវាងរដ្ឋាភិបាល និងក្រុមហ៊ុនពាណិជ្ជកម្មសម្រាប់ការសម្របសម្រួលគោលនយោបាយ។ បើទោះបីជាប្រទេសថៃពិតជាបានបង្កើតទំនាក់ទំនងបែបនេះក៏ដោយក៏នៅមានការជជែកដេញដោលច្រើនអំពីប្រសិទ្ធភាពនៃទំនាក់ទំនងនេះ។

*ប្រភព ៖ ធនាគារពិភពលោក ដំណើរការជាថ្មីនៅអាស៊ីបូព៌ា ៖ គំនិតអំពីកំណើនសេដ្ឋកិច្ច ឆ្នាំ២០០៧។*

ថ្វីបើមានការប្រឈមទាំងនេះ មានកត្តាជំរុញបង្កើនទំនាក់ទំនងការងាររវាងវិស័យឯកជន និងរដ្ឋាភិបាល។ សហគ្រាសខ្នាតតូច និងមធ្យម (កម្ពុជាមានសហគ្រាសបែបនេះជាច្រើន) ត្រូវបានចាត់ទុកជាបញ្ហាមួយ ហើយសហគ្រាស ខ្នាតតូច និងមធ្យមទាំងនោះត្រូវបានលើកទឹកចិត្តឱ្យពិចារណាលើយុទ្ធសាស្ត្រមួយចំនួន ដូចជា ការបង្កើតកម្រងសហគ្រាស និងកសាងជំនាញដល់បុគ្គលិកគន្លឹះៗឱ្យធ្វើជាគ្រូបង្វឹកដល់បុគ្គលិកដែលមានជំនាញតិចតួច។ កម្មករក៏ត្រូវបានលើកទឹកចិត្តឱ្យស្វែងរកការគាំទ្រពីរដ្ឋាភិបាលដើម្បីជំរុញឱ្យឧស្សាហកម្មផ្តល់ការបណ្តុះបណ្តាលកម្មករ និងរៀបចំយុទ្ធសាស្ត្រចរចាជាមួយរដ្ឋាភិបាលអំពីលាភការ និងលាភចិត្តផងដែរ។ ដោយសារការចំណាយលើការបណ្តុះបណ្តាលខ្ពស់ និងមានការលំបាកក្នុងការដើរឱ្យទាន់ការផ្លាស់ប្តូរតាមបច្ចេកវិទ្យាភាពជាដៃគូកាន់តែមានសារៈសំខាន់ថែមទៀត ព្រោះភាពជាដៃគូជា

មធ្យោបាយចែករំលែកការចំណាយលើការបណ្តុះបណ្តាល និងជួយដោះស្រាយបញ្ហាប្រឈមគន្លឹះៗក្នុងការអភិវឌ្ឍជំនាញ[២៧]។

ភាគីទាំងសងខាងនឹងទទួលបានលាភចិត្តព្រោះវិស័យឯកជនចង់បានស្ថានការណ៍ល្អ និងអាចព្យាករណ៍បានដើម្បីធានាកំណើន ហើយវិស័យសាធារណៈចង់បានប្រាក់ចំណូលពន្ធ និងចង់បង្កើតការងារដែលផ្តល់ដោយកំណើននេះ។ សម្រាប់វិស័យឯកជនការអភិវឌ្ឍបែបនេះ ជាការជួយកែលម្អសកម្មភាពរបស់រដ្ឋបាលរបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការទទួលបានមូលនិធិសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗដែលក្រុមហ៊ុនត្រូវការ។ អង្គការមិនមែនរដ្ឋាភិបាលក៏ជាផ្នែកមួយនៃដំណើរការអភិវឌ្ឍន៍នេះផងដែរ ជាពិសេសជាអ្នកលើកឡើងអំពីតម្រូវការរបស់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និងដើរតួនាទីជាអ្នកឃ្លាំមើល[២៨]។ ការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍នេះតែងធ្វើឡើងតាមរយៈអង្គការតំណាងផ្សេងៗ។ នៅកម្ពុជាមានសភាពាណិជ្ជកម្ម ប៉ុន្តែការរួមចំណែករបស់សភាពាណិជ្ជកម្មគ្របដណ្តប់ដោយរដ្ឋ និងយកចិត្តទុកដាក់តែលើក្រុមហ៊ុនធំៗ។ បច្ចុប្បន្នការចូលរួមរបស់វិស័យឯកជននៅថ្នាក់ក្រោមជាតិមានតិចតួចណាស់ ហើយការរៀបចំឱ្យមានការចូលរួមពីវិស័យឯកជននេះក៏នៅមានកម្រិតទាបនៅឡើយដែរ។ ទោះបីជាយ៉ាងណាក៏ដោយក៏មានសមាគមក្រៅផ្លូវការជាច្រើនដែលកំពុងដំណើរការពិភាក្សាជាមួយរដ្ឋាភិបាលលើបញ្ហាជាច្រើនហួសពីបញ្ហាដែលទាក់ទងនឹងកិច្ចសន្យាផ្ទាល់រហូតដល់ពិភាក្សាលើបញ្ហាធំៗថែមទៀតផង។

បន្ថែមលើនេះទៀត រចនាសម្ព័ន្ធថ្នាក់ក្រោមជាតិមានសារៈសំខាន់ចំពោះការជំរុញលើកទឹកចិត្តឱ្យមានភាពជាដៃគូរវាងឯកជន និងសាធារណៈ។ ដោយសារប្រជាពលរដ្ឋពុំមានឆន្ទៈធ្វើដំណើរផ្លូវឆ្ងាយដើម្បីទទួលការបណ្តុះបណ្តាល ដូច្នេះ ការបណ្តុះបណ្តាលត្រូវឋិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ[២៩]។ សំអាងលើកត្តាកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ គប្បីស្វាគមន៍ការផ្តត់ផ្តង់សេវារបស់វិស័យឯកជន ព្រោះការផ្តត់ផ្តង់នេះមានន័យថា រដ្ឋាភិបាលពុំចាំបាច់ផ្តល់សេវាទាំងនោះទេ។ វិស័យសាធារណៈត្រូវទទួលខុសត្រូវលើ (ហើយការរៀបចំផែនការនឹងត្រូវលើកយកមកពិចារណា) សេវាផ្សេងៗដែលវិស័យឯកជនមិនអាចផ្តល់ឱ្យបាន។ សេវាដែលវិស័យឯកជនមិនអាចផ្តល់ឱ្យបានអាចចាត់ទុកជាផលិតផលសាធារណៈ "សុទ្ធ" ជាសេវាពុំផ្តល់ប្រាក់ចំណូល ឬ "ផលិតផលផ្តាច់មុខ" ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបង្កើតហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងយកថ្លៃឈ្នួលប្រើប្រាស់សេវានោះ។ ក្នុងករណីនេះភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈអាចយកមកអនុវត្តបាន។

គំនិតផ្តួចផ្តើមសកម្មភាពគន្លឹះរវាងវិស័យឯកជន និងសាធារណៈក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជារួមមានការបណ្តុះបណ្តាលតាមឃុំ និងតាមសហគ្រាស។ ភាគច្រើនប្រព័ន្ធអប់រំត្រូវតែមានអគារ និងសាលារៀន ប៉ុន្តែការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពុំចាំបាច់ប្រើមធ្យោបាយនេះទេ។ ជាទូទៅ ប្រជាពលរដ្ឋក្រីក្រតែងជួបការលំបាកក្នុងការចាកចេញពីស្រែចម្ការដើម្បីទទួលការបណ្តុះបណ្តាលអំពីការងារ។ ដូច្នេះ ការបណ្តុះបណ្តាលដល់អ្នកភូមិត្រូវមានរយៈពេលខ្លី ត្រូវជ្រើសយកពេលវេលាណាមួយក្នុងមួយថ្ងៃត្រូវរៀបចំការបណ្តុះបណ្តាលក្នុងភូមិជិតការដ្ឋានការងាររបស់អ្នកភូមិ ដើម្បីកាត់បន្ថយចំណាយ

> "បទពិសោធន៍អន្តរជាតិបង្ហាញថា ការផ្តល់ហិរញ្ញប្បទានត្រូវតែធ្វើជាដៃគូរវាងរដ្ឋសហគ្រាសសហគមន៍ និងសិក្ខាកាម។"

២៧ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៊ឡឹ សិក្ខាសាលាបច្ចេកទេសជាតិស្តីពីការអភិវឌ្ឍជំនាញ ទូទៃទាក់ទងនឹងការងារ ឆ្នាំ២០១០។

២៨ UNDP ការចូលរួមពីវិស័យឯកជននៅកម្ពុជា និងការផ្តល់សេវាក្នុងការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០។

២៩ ូណឌភ ការចូលរួមពីវិស័យឯកជននៅកម្ពុជា និងការផ្តល់សេវាក្នុងការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០។

លើការធ្វើដំណើរ។ ការរៀនសូត្រតាមគ្រឹះស្ថានសិក្សាជាទូទៅ ចំណាយខ្ពស់ ហើយជាញឹកញាប់ប្រជាពលរដ្ឋដែលត្រូវការការបណ្តុះបណ្តាលជាក់ស្តែងដើម្បីយកទៅប្រើជាបន្ទាន់តែងពុំមានឱកាសចូលរៀន។ យុទ្ធសាស្ត្រមួយដែលផ្តល់មូលនិធិដល់ការបណ្តុះបណ្តាលតាមឃុំ និងតាមសហគ្រាស ហើយបានទទួលជំនួយពីបុគ្គលិករបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ខេត្ត។ មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ខេត្តនឹងទទួលថ្លៃឈ្នួល ១០% នៃការចំណាយលើការបណ្តុះបណ្តាលនេះ គឺថ្លៃនៃការជួយរកគ្រូបណ្តុះបណ្តាល និងជួលគ្រូបណ្តុះបណ្តាលដើម្បីអនុវត្តផែនការបណ្តុះបណ្តាល។ ការធានាថា មូលនិធិជាតិបណ្តុះបណ្តាលត្រូវបែងចែកសម្រាប់ជួយដល់ការបណ្តុះបណ្តាលដែលបំពេញតាមតម្រូវការជាក់ស្តែង និងការឆ្លើយតបតាមតម្រូវការរបស់សហគមន៍/សហគ្រាសជាគន្លឹះ[៣០]។

### ៥.៣.១. *ការផ្តល់ហិរញ្ញប្បទានរបស់ដៃគូឯកជន និងសាធារណៈសម្រាប់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*[៣១]

បទពិសោធអន្តរជាតិបង្ហាញថា ការផ្តល់ហិរញ្ញប្បទានត្រូវតែធ្វើជាដៃគូរវាងរដ្ឋសហគ្រាស សហគមន៍ និងសិក្ខាកាម។ ការផ្តល់ហិរញ្ញប្បទានដល់ភាគីអ្នកទទួលផលនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាគោលដៅចម្បងនៃការអភិវឌ្ឍ និងថែទាំប្រព័ន្ធមួយដែលបំពេញតម្រូវការជាក់ស្តែងដោយឆ្លើយតបនឹងតម្រូវការជំនាញ។ ដើម្បីសម្រេចគោលដៅនេះភាពជាដៃគូរវាងឯកជន និងសាធារណៈជាលក្ខខណ្ឌតម្រូវមិនអាចខ្វះបាន។ ម្យ៉ាងវិញទៀតភាគីពាក់ព័ន្ធត្រូវចូលរួមក្នុងការបង្កើតសិប្បរចនាកម្មវិធីធ្វើសេចក្តីសម្រេចចិត្ត និងផ្តល់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រសិនបើត្រូវការឱ្យភាគីពាក់ព័ន្ធជួយគាំទ្រដល់កម្មវិធីនេះ។ យុទ្ធសាស្ត្រមួយពាក់ព័ន្ធនឹងការយកពន្ធលើប្រាក់បៀវត្សរ៍ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រាសជួយដល់ការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើតមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដោយឈរលើគោលការណ៍សហគ្រប់គ្រងរបស់សហគ្រាស។ ការបង្កើតក្រុមប្រឹក្សាវិស័យសហគ្រាស និងការចាប់ផ្តើមដំណើរការនៃការអំពាវនាវឱ្យមានការផ្តល់វិភាគទានផ្នែកហិរញ្ញវត្ថុសម្រាប់ការបណ្តុះបណ្តាលតាមកម្រិតជាបញ្ហាចោទមួយទៀត។ ការបង្កើតក្រុមប្រឹក្សាផ្តល់យោបល់សហគ្រាសមួយឱ្យនៅជាមួយក្រុមប្រឹក្សាជាតិបណ្តុះបណ្តាលក៏អាចជួយផ្តល់ធាតុបញ្ចូលរបស់វិស័យឯកជនទៅឱ្យក្រុមប្រឹក្សាជាតិបណ្តុះបណ្តាលបានដែរ។

រដ្ឋាភិបាលគប្បីពិចារណាផងដែរអំពីលទ្ធភាពនៃការបង្កើតប្រព័ន្ធឧបត្ថម្ភធន ឬប្រព័ន្ធផ្ទេរពន្ធលើប្រាក់ចំណេញរបស់សារជីវកម្មជាមួយក្រសួងហិរញ្ញវត្ថុ។ រដ្ឋាភិបាលញ្ញាឱ្យក្រុមប្រឹក្សាឃុំផ្តល់វិភាគទានចំណាយលើការបណ្តុះបណ្តាលក្នុងប្រព័ន្ធលិខិតបញ្ជាក់ ហើយដោយសារមានការទទួលស្គាល់ថា ករណីជាច្រើនមិនចាំបាច់មានវិភាគទានហិរញ្ញវត្ថុផង។ ការចាប់ផ្តើម គឺត្រូវធ្វើយ៉ាងណាផ្លាស់ប្តូរឥរិយាបថ គឺប្តូរពីការត្រឹមមានសិទ្ធិឱ្យទៅជាការចូលរួមវិញ។ សិក្ខាកាមក៏ត្រូវចូលរួមបង់វិភាគទានបន្តិចបន្តួច។ បទពិសោធមួយបង្ហាញថាទោះបីជាវិភាគទានតិចតួចយ៉ាងណាក៏ដោយក៏អាចបង្កើនការតាំងចិត្តរបស់សិក្ខាកាមឱ្យខិតខំរៀនថែមទៀតដែរ។

៣០ រដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រ TVET។
៣១ រដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រ TVET។

### ៥.៣.២ ភាពជាដៃគូរវាងឯកជន និងសាធារណៈពង្រីកការផ្តល់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ[៣២]

តួនាទីចម្បងរបស់រដ្ឋាភិបាលក្នុងការផ្តល់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺសំដៅធានាអភិវឌ្ឍប្រព័ន្ធរួមមួយផ្តល់ឱកាសចូលរៀនសម្រាប់ទាំងអស់គ្នាមានកម្លាំងពលកម្មជំនាញសម្រាប់បំពេញតម្រូវការសេដ្ឋកិច្ច និងធានាគុណភាពនៃការណ្តុះបណ្តាល។ ដើម្បីសម្រេចគោលដៅនេះស្ថាប័នផ្តល់ការបណ្តុះបណ្តាលឯកជនត្រូវការការលាភចិត្តដើម្បីឈានជើងចូលទីផ្សារបណ្តុះបណ្តាល ក្នុងការបំពេញតម្រូវការជំនាញ។ យុទ្ធសាស្ត្រមួយធ្វើឱ្យមានប្រព័ន្ធបណ្តុះបណ្តាលដែលផ្តល់ដោយស្ថាប័នឯកជនដោយប្រើថវិការបស់មូលនិធិជាតិបណ្តុះបណ្តាល និងដោយប្រើថវិកានៃប្រព័ន្ធលិខិតបញ្ជាក់ឃុំ-សហគ្រាស។ មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តនីមួយៗត្រូវបង្កើតបញ្ជីឈ្មោះនៃស្ថាប័នផ្តល់ការបណ្តុះបណ្តាលឯកជន និងអង្គការមិនមែនរដ្ឋាភិបាលផ្តល់ការបណ្តុះបណ្តាលនៅតាមខេត្តដែលស្ថាប័ន និងអង្គការផ្តល់ការបណ្តុះបណ្តាលទាំងនោះត្រូវស្នើចុះបញ្ជីជាមួយសាខាខេត្តនៃបណ្តាញគ្រូឧទ្ទេសថ្នាក់ជាតិ (NTTN) ដែលជាជំហានទីមួយនេះគឺបញ្ជាក់អំពីគុណវុឌ្ឍិក្នុងការផ្តល់ការបណ្តុះបណ្តាលក្នុងកម្មវិធីលិខិតបញ្ជាក់នេះ។

## ៥.៤ កិច្ចផ្តួចផ្តើមរបស់ទីភ្នាក់ងារអន្តរជាតិ និងម្ចាស់ជំនួយ

នៅទសវត្សរ៍ចុងក្រោយនៅកម្ពុជា ប្រសិទ្ធភាពជំនួយមានការរីវឌ្ឍច្រើន ហើយវិធានការនានាត្រូវបានបែងចែកទៅតាមវិស័យបីធំៗ ៖ (១) ពង្រឹងអភិក្រមតាមកម្មវិធី និងយុទ្ធសាស្ត្រតាមវិស័យ (២) អភិវឌ្ឍន៍សមត្ថភាព និងប្រើប្រាស់ប្រព័ន្ធជាតិដែលមានស្រាប់ និង(៣) លើកកម្ពស់ទម្លាប់ប្រតិបត្តិក្នុងភាពជាដៃគូល្អ។ ថ្វីបើអង្គការទាំងនេះមានកិច្ចប្រឹងប្រែងដ៏មានតម្លៃយ៉ាងច្រើនក៏ដោយ គេអាចមើលឃើញថាសកម្មភាពអង្គភាពទាំងអស់នេះមានលក្ខណៈខុសៗគ្នាច្រើន ហើយមិនអនុវត្តតាមផែនការរួម ឬក្របខ័ណ្ឌរួមណាមួយទេ។ ដោយសារអង្គការទាំងអស់ធ្វើការក្នុងទិសដៅមួយឈានទៅបង្កើនការអភិវឌ្ឍមនុស្ស និងសហការជាមួយរដ្ឋាភិបាលដើម្បីលើកកម្ពស់ការអភិវឌ្ឍមនុស្ស ប៉ុន្តែក៏នៅមិនទាន់មាន ឬមានការសហការគ្នាតិចតួចក្នុងចំណោមម្ចាស់ជំនួយដែរ។ កត្តានេះជំរុញឱ្យមានការជាន់ការងារគ្នា និងការធ្វើការលើការងារដូចគ្នាដដែលៗ។

### ៥.៤.១ ធនាគារអភិវឌ្ឍន៍អាស៊ី

ផែនការអភិវឌ្ឍន៍វិស័យអប់រំទី២ (ESDP II) ជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកដំបូង ហើយបានអនុម័តកាលពី ខែមីនា ឆ្នាំ២០០៦ ទទួលបានឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ ផែនការអភិវឌ្ឍន៍វិស័យអប់រំទី ២នេះ បានយកទៅអនុវត្តនៅខេត្ត៧ (ខេត្តតាកែវ កំពត សៀមរាប បាត់ដំបង កំពង់ឆ្នាំង ស្ទឹងត្រែង និងស្វាយរៀង) ប៉ុន្តែគម្រោងនេះនៅតែឋិតក្នុងដំណាក់កាលសាកល្បងនៅឡើយ។ បច្ចុប្បន្នក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានគម្រោងថ្មីមួយដែលបានបង្កើតឡើងតាមរយៈជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ គម្រោងនេះ

៣២ រដ្ឋាភិបាលកម្ពុជា ផែនការយុទ្ធសាស្ត្រ TVET ។

> “នៅទសវត្សរ៍ចុងក្រោយនៅកម្ពុជា ប្រសិទ្ធភាពជំនួយមានការរីវត្តន៍ច្រើន។”

មានគោលបំណងលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈព្រមទាំងចាប់ផ្តើមនៅឆ្នាំ២០១០ រហូតដល់ ឆ្នាំ២០១៦ ដោយអនុវត្តនៅក្នុងទាំង ២៤ ខេត្តក្រុង[៣៣] ។

ដោយមានជំនួយឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតម្រង់ទិសដើម្បីបំពេញតម្រូវការរៀបចំនៅអគ្គនាយកដ្ឋានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ការវិវត្តនេះមានចាប់ពីការផ្តោតការយកចិត្តទុកដាក់លើការផ្គត់ផ្គង់ដល់ការផ្តោតការយកចិត្តទុកដាក់លើតម្រូវការមួយទាមទារឱ្យមានការផ្លាស់ប្តូរឥរិយាបថទាំងនៅអគ្គនាយកដ្ឋានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងតាមគ្រឹះស្ថាន។ តាមរយៈការប្រើប្រាស់គម្រោងសាកល្បងមួយចំនួនក្នុងដំណាក់កាលមួយដ៏ប្រុងប្រយ័ត្នដែលមានទំនាក់ទំនងនឹងស្ថាប័ននានាចំពោះតម្រូវការរបស់សហគមន៍នេះស្ថាប័ននានាដឹងថាប្រាក់ចំណូលរបស់ខ្លួន គឺអាស្រ័យលើការឆ្លើយតបនឹងតម្រូវការ និងមិនទទួលបានដោយផ្ទាល់ពីការបណ្តុះបណ្តាលដោយមិនគិតពីលទ្ធផលការងារនោះទេ។ កម្មវិធីបណ្តុះបណ្តាលជំនាញផ្អែកលើលិខិតបញ្ជាក់ផ្តល់ឱ្យឃុំគោលដៅនូវលិខិតមួយដែលមានតម្លៃជាង ៤000 ដុល្លារក្នុងមួយឆ្នាំសម្រាប់រយៈពេលបីឆ្នាំដើម្បីសម្រេចបានផែនការសេដ្ឋកិច្ចថ្នាក់ឃុំ[៣៤] ។

ឧទាហរណ៍មួយនៃភាពជោគជ័យរបស់កម្មវិធីបណ្តុះបណ្តាលជំនាញផ្អែកលើលិខិតបញ្ជាក់នេះ គឺការពិតដែលថា កម្មវិធីនេះបានបណ្តុះបណ្តាលជំនាញផ្សេងៗដល់ប្រជាពលរដ្ឋនៅតំបន់ជនបទជាង ១៥៤ 000នាក់ដែលប្រជាពលរដ្ឋទាំងនោះ បានជ្រើសរើសដោយផ្អែកលើឱកាសផ្សេងៗនៅក្នុងភូមិ និងខេត្តដែលពួកគេរស់នៅ។ កម្មវិធីនេះនឹងបន្តពង្រីកដល់គ្រប់ខេត្តទាំងអស់នៅកម្ពុជាដោយប្រើប្រាស់ទាំងថវិការបស់រដ្ឋាភិបាល និងជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី[៣៥] ។ គណៈកម្មាធិការជាតិបណ្តុះបណ្តាលស្វែងរកមធ្យោបាយផ្សេងៗដើម្បីពង្រីក និងបន្តកម្មវិធីបណ្តុះបណ្តាលជំនាញផ្អែកលើលិខិតបញ្ជាក់នេះ និងផ្សារភ្ជាប់ការបណ្តុះបណ្តាលដែលបានផ្តល់ឱ្យបុគ្គលិកថ្មីដោយគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាថាបុគ្គលិកទាំងនេះអាចឆ្លើយតបតាមតម្រូវការដែលកំពុងកើនឡើងរបស់គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

### *៥.៤.២. អង្គការពលកម្មអន្តរជាតិ (ILO)*[36]

អង្គការពលកម្មអន្តរជាតិបានគាំទ្រដល់ការអភិវឌ្ឍជំនាញនៅកម្ពុជាចាប់តាំងពី ឆ្នាំ១៩៩០ និងបានឃើញកិច្ចផ្តួចផ្តើមមួយចំនួនដែលទទួលបានលទ្ធផលជាផ្លែផ្កា។ ជំនួយត្រូវបានផ្តល់ជូនដើម្បីពង្រីកឱកាសការងារប្រកបដោយគុណភាព កិច្ចសន្ទនាសង្គមប្រកបដោយប្រសិទ្ធភាព និងការការពារសង្គមដែលបានរីកចំរើន។ អង្គការពលកម្មអន្តរជាតិ បានកំណត់យុទ្ធសាស្ត្រសកម្មភាពមួយសម្រាប់កម្ពុជា ដោយគិតតាមកាលានុវត្តភាពនាពេលបច្ចុប្បន្ន និងផលប្រយោជន៍របស់កម្ពុជាក្នុងការអភិវឌ្ឍមូលធនមនុស្សរបស់ខ្លួន។

៣៣ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ILO សិក្ខាសាលាបច្ចេកទេសជាតិស្តីពីការអភិវឌ្ឍជំនាញ TVET ដែលពាក់ព័ន្ធនឹងការងារ ឆ្នាំ២០១០។

៣៤ រដ្ឋាភិបាលកម្ពុជាផែនការយុទ្ធសាស្ត្រ TVET ។

៣៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ILO សិក្ខាសាលាបច្ចេកទេសជាតិស្តីពីការអភិវឌ្ឍជំនាញ TVET ដែលពាក់ព័ន្ធនឹងការងារ ឆ្នាំ២០១០។

៣៦ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ILO សិក្ខាសាលាបច្ចេកទេសជាតិស្តីពីការអភិវឌ្ឍជំនាញ TVET ដែលពាក់ព័ន្ធនឹងការងារ ឆ្នាំ២០១០។

យុទ្ធសាស្ត្រនេះរួមបញ្ចូលទាំង (១) ការប្តេជ្ញាអនុវត្តតាមយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលដែលតាមដានយ៉ាងច្បាស់ពីការបង្កើតការងារ និងបង្កើនផលិតភាពដោយចាត់ទុកថាជាសសរគ្រឹះសំខាន់មួយរបស់យុទ្ធសាស្ត្រនេះ (២) ការលើកកម្ពស់ការជជែកដេញដោល និងការពិភាក្សាពីការកាត់បន្ថយភាពក្រីក្រក្នុងចំណោមឥស្សរជនសាធារណៈសំខាន់ៗអ្នកស្រាវជ្រាវសង្គមស៊ីវិល និងដៃគូអន្តរជាតិ (៣) ការបង្កើនចំនួនអ្នកចូលរួមក្នុងកម្លាំងពលកម្មថ្មីឱ្យបានចំនួនប្រមាណ ៣០០ ០០០ នាក់រៀងរាល់ឆ្នាំ និង (៤) ការអភិវឌ្ឍកម្លាំងពលកម្មដែលបានប្រចាំការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

វិធានការនានាដែល ILO បានជ្រើសរើសក្នុងវិស័យផ្សេងៗ រួមមាន៖

- **ការធ្វើមជ្ឈការការងារ ៖** ILO បានសហការជាមួយ MoLVT ដើម្បីរៀបចំយុទ្ធសាស្ត្រជាតិមួយសម្រាប់ការងារដែលរួមបញ្ចូលសមភាពយេនឌ័រ និងដោះស្រាយតម្រូវការរបស់ក្រុមប្រជាពលរដ្ឋងាយរងគ្រោះជាក់លាក់ និងកម្មករនៅតាមតំបន់ជនបទ។
- **ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ ៖** ILO បានផ្តល់ជំនួយបច្ចេកទេសក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ NTVET និង GMAP (ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ) របស់ MoLVT និង MIME ព្រមទាំងបានលើកកម្ពស់ទំនាក់ទំនងនៃការបណ្តុះបណ្តាល និងតម្រូវការរបស់ឧស្សាហកម្ម និងនិយោជក។ ផែនការអភិវឌ្ឍន៍នេះ ក៏បានធ្វើការងារសំដៅដល់ការអភិវឌ្ឍគោលនយោបាយជំនាញ និងប្រព័ន្ធផ្សេងៗ តាមរយៈដំណើរការផ្តល់សញ្ញាបត្រជំនាញដែលកើនឡើងស្របតាមតម្រូវការរបស់កម្ពុជា។ ជាកិច្ចឆ្លើយតបនឹងវិបត្តិហិរញ្ញវត្ថុជំនួយបច្ចេកទេសត្រូវបានផ្តល់ជូន MoLVT ក្នុងការបណ្តុះបណ្តាលតាមវិស័យសមស្របនានា និងការវាយតម្លៃពីតម្រូវការការងាររបស់បុគ្គលិក ក៏ដូចជាជំនួយបច្ចេកទេស និងការណែនាំស្តីពី TVET។
- **សេវាការងារ ៖** នៅឆ្នាំ២០០៩-២០១០ ILO បានបង្កើត និងរក្សាទំនាក់ទំនងរបស់មជ្ឈមណ្ឌលរកការងារនៅក្នុងខេត្តចំនួន ៤។ ក្រៅពីនេះ ILO ក៏បានអនុវត្តការងារកសាងសមត្ថភាពមួយចំនួនសម្រាប់ទីភ្នាក់ងាររកការងារជាតិ (NEA) ដែលទើបតែបង្កើតឡើងនាពេលថ្មីៗនេះដែលរួមមានការបណ្តុះបណ្តាលយ៉ាងទូលំទូលាយស្តីពីសេវារកការងារការរៀបចំគោលការណ៍ណែនាំប្រតិបត្តិការតាមស្តង់ដារសម្រាប់មជ្ឈមណ្ឌលរកការងារ និងការរៀបចំទស្សនៈកិច្ចសិក្សាទៅកាន់ប្រទេសចិនសម្រាប់ NEA និងបុគ្គលិកមជ្ឈមណ្ឌលរកការងារដើម្បីអង្កេតពីការងារផ្សេងៗនៅមជ្ឈមណ្ឌលសេវាការងារនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។
- **សមត្ថភាពស្ថាប័នសម្រាប់ការពង្រឹងសន្តិសុខសង្គម ៖** ILO បានជួយ MoLVT ធ្វើសេចក្តីព្រាងច្បាប់ និងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងរដ្ឋបាលសម្រាប់ការបង្កើតគម្រោងធានាដល់ការបង្ករបួសស្នាមក្នុងពេលបំពេញការងារ។ ILO ក៏បានជួយដល់ MoLVT, MoSAVY, និង MoH ក្នុងការរៀបចំគម្រោងសន្តិសុខសង្គមផងដែរ រួមមានការធ្វើសេចក្តីព្រាងច្បាប់ ការសិក្សាពីផ្នែកហិរញ្ញវត្ថុ និងការជួយដល់ការអនុវត្តរបស់គម្រោងនេះ។

### ៥.៤.៣. កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ

វិស័យអាទិភាពសំខាន់៧សម្រាប់ ឆ្នាំ២០១១-២០១៥ ក្របខណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ ដែលអនុលោមតាមយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និងផ្ដោតលើថាតើកម្ពុជានឹងអាចសម្រេចតាម MDGs របស់ខ្លួនដែរឬទេ។ គោលបំណងទាំងនេះ រួមមានការលើកកម្ពស់ និងការជួយដល់ (១) អភិបាលកិច្ចល្អនិងការលើកកំពស់សិទ្ធិមនុស្ស (២) គាំទ្រវិស័យកសិកម្មនិងកាត់បន្ថយភាពក្រីក្រ (៣) កសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់វិស័យសង្គមនានា (៤) គាំទ្រផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (២០០៦-២០១០)។

ផែនការសកម្មភាពសម្រាប់កម្មវិធីថ្មីនៅកម្ពុជា ឆ្នាំ២០១១-២០១៥ សម្រាប់ UNDP ត្រូវបានរៀបចំឡើងដោយសម្របតាម UNDAF របស់ខ្លួនដើម្បីឆ្លើយតបនឹងអាទិភាពជាតិក្នុង NSDP ដោយផ្ដោតជាពិសេសលើការជួយបង្កើនល្បឿនដំណើរការឆ្ពោះទៅ CMDGs មុនឆ្នាំ២០១៥។

ការផ្ដោតជាសំខាន់នេះនឹងត្រូវអនុវត្តក្នុងគម្រោង MDG និងការកាត់បន្ថយភាពក្រីក្រការអភិវឌ្ឍបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តភាពអភិបាលកិច្ចប្រជាធិបតេយ្យ និងសមភាពយេនឌ័រ។

ដោយមានបំណងពង្រឹងសមត្ថភាពថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពច្នៃប្រឌិត និរន្តភាព និងសមភាពនោះ UNDP នឹងគាំទ្រដល់ការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រចាំបាច់មួយចំនួនសម្រាប់វិស័យដែលកំពុងអភិវឌ្ឍខ្លាំងដើម្បីពង្រីក និងចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍មូលធនមនុស្សនឹងត្រូវគាំទ្រដើម្បីជួយដល់ការបង្កើតជំនាញ និងតម្រូវការរបស់វិស័យឯកជន។

### ៥.៤.៤. ធនាគារពិភពលោក

ធនាគារពិភពលោក ផ្ដល់ឥណទានដល់រដ្ឋាភិបាលកម្ពុជាតាមរយៈសមាគមអភិវឌ្ឍន៍អន្តរជាតិ។ គម្រោងជាច្រើនផ្ដោតលើហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍជនបទដោយសារប្រជាពលរដ្ឋក្រីក្រភាគច្រើនរស់នៅតំបន់ជនបទទាំងនោះ។ បច្ចុប្បន្នធនាគារពិភពលោកកំពុងជ្រើសរើសយុទ្ធសាស្ត្រជំនួយប្រទេសថ្មីសម្រាប់កម្ពុជាដោយផ្ដោតលើអភិបាលកិច្ច និងការកាត់បន្ថយភាពក្រីក្រ និងប្រភពកំណើនសេដ្ឋកិច្ច។

តាមរយៈយុទ្ធសាស្ត្រជំនួយប្រទេសនេះ (CAS) ធនាគារពិភពលោក បានបង្ហាញពីវិស័យអាទិភាពដើម្បីជួយដល់ប្រទេសដែលជាអតិថិជនដោយប្រើប្រាស់កម្មវិធីអភិវឌ្ឍន៍របស់ខ្លួនផ្ទាល់។ ជំនួយទាំងនេះរួមមានការផ្ដល់ឥណទាន ការសិក្សា និងតាមរូបភាពជំនួយបច្ចេកទេស។ យុទ្ធសាស្ត្រប្រចាំឆ្នាំ២០០៥-២០០៨ ធនាគារពិភពលោក បានកំណត់ពីបញ្ហាអភិបាលកិច្ចដោយចាត់ទុកថាបញ្ហាទាំងនោះគឺជាឧបសគ្គចម្បងចំពោះការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាប្រកបដោយនិរន្តភាព ដោយជំនួយនេះក៏ផ្ដោតលើការសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងការគាំទ្រដល់យុទ្ធសាស្ត្រ និងការវិនិយោគដែលត្រូវការសម្រាប់ភាពជោគជ័យរបស់ខ្លួនផងដែរ។ កាលពីទសវត្សរ៍មុនធនាគារពិភពលោកបាន និងកំពុងបំពេញការងារយ៉ាងសកម្មដើម្បីបំពេញចន្លោះខ្វះខាតរវាងជំនួយដឹកនាំដោយម្ចាស់ជំនួយដែលគ្មានការសហការគ្នា និងដែលតែងតែធ្វើឱ្យការអភិវឌ្ឍអភិបាលកិច្ចល្អមានភាពយឺតយ៉ាវ។ យុទ្ធសាស្ត្ររបស់ធនាគារពិភពលោកបាននិងកំពុងផ្ដោតការ

យកចិត្តទុកដាក់លើមេរៀនជាបទពិសោធដោយយកចិត្តទុកដាក់ចំពោះការផ្តោតលើអភិបាលកិច្ចកាន់តែខ្លាំងថែមទៀត តាមរយៈកម្មវិធីក្នុងស្រុកការលើកកម្ពស់ការសហការគ្នា និងភាពជាដៃគូម្ចាស់ជំនួយព្រមទាំងផ្តោតលើតម្រូវការពិនិត្យលទ្ធផលអភិវឌ្ឍន៍ឱ្យបានច្បាស់លាស់ ។

ជំនួយរបស់ធនាគារពិភពលោកដល់កម្ពុជាបានជួយបង្កើតការផ្លាស់ប្តូរជាវិជ្ជមានក្នុងវិស័យអប់រំដោយផ្ទាល់ ។ តាមរយៈគម្រោងលើកកម្ពស់គុណភាពអប់រំ គ្រូបង្រៀន អ្នកគ្រប់គ្រង និងសហគមន៍ផ្សេងៗមកពីខេត្តតាកែវ កណ្តាល និងកំពត ឥឡូវកំពុងសហការគ្នាកំណត់សកម្មភាពលើកកម្ពស់សាលារៀនដែលបានទទួលហិរញ្ញប្បទានតាមរយៈជំនួយឥតសំណងដល់កម្រងសាលាប្រចាំឆ្នាំដើម្បីអភិវឌ្ឍការអប់រំរបស់កុមារ ។ សកម្មភាពទាំងនេះ រួមមាន ការសាងសង់បណ្ណាល័យថ្មីៗ ការចំណាយលើសម្ភារៈអប់រំ ការផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀន និងការលើកកម្ពស់បរិស្ថានជុំវិញសាលារៀន ។

ជាងនេះទៀត មូលនិធិអភិវឌ្ឍន៍គម្រោងមេគង្គរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិកំពុងជួយដល់ការអភិវឌ្ឍន៍របស់សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា ។ អាទិភាពមួយក្នុងចំណោមអាទិភាពរបស់មូលនិធិនេះ គឺធ្វើសមាហរណកម្មកម្មវិធីបណ្តុះបណ្តាលស្ត្រីក្រីក្រ និងកូនរបស់ស្ត្រីទាំងនេះនៅតាមសហគ្រាស និងនៅពេលបំពេញការងារដែលនេះជាកិច្ចផ្តួចផ្តើមមួយក្នុងចំណោមកិច្ចផ្តួចផ្តើមធំៗប្រឆាំងនឹងភាពក្រីក្រ ។

### ៥.៤.៥. សហគមន៍អឺរ៉ុប[៣៧]

កិច្ចសហប្រត្តិបត្តិការរបស់គណៈកម្មាការអឺរ៉ុបនៅកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានបង្ហាញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) របស់រាជរដ្ឋាភិបាល ។ គណៈកម្មាការអឺរ៉ុបនៅកម្ពុជានេះ ក៏អនុវត្តតាមគោលនយោបាយសហប្រតិបត្តិការអភិវឌ្ឍន៍រួមរបស់សហគមន៍អឺរ៉ុបដែរ ។ ចំនួនវិស័យស្នូលតិចតួចត្រូវបានព្រមព្រៀងរួមគ្នាក្នុងឯកសារយុទ្ធសាស្ត្រកម្ពុជា-EC (CSP) ឆ្នាំ២០០៧-២០១៣ :

១. គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ដែលរួមមានការគាំទ្រដល់កំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)

២. គាំទ្រដល់ការអប់រំកម្រិតមូលដ្ឋាន (សហគមន៍អឺរ៉ុប បានផ្តល់ជំនួយអភិវឌ្ឍន៍ជាច្រើន និងបានរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយកម្ពុជា ។ កិច្ចព្រមព្រៀងសហប្រតិបត្តិការ EU-កម្ពុជាផ្តល់ក្របខណ្ឌការងារសម្រាប់ទំនាក់ទំនង និងកំណត់វិស័យផ្សេងៗ ដែលត្រូវធ្វើកិច្ចសហប្រតិបត្តិការរួមគ្នា ។ កិច្ចសហប្រតិបត្តិការរវាងសហគមន៍អឺរ៉ុប និងកម្ពុជាក៏កើតឡើងនៅក្នុងតំបន់ទូទាំង ASEAN និង ASEំ ។

៣៧ សម្រាប់ព័ត៌មានលម្អិតស្តីពីទំនាក់ទំនងរវាងសហគមន៍អឺរ៉ុប និងកម្ពុជាសូមចូលទៅកាន់គេហទំព័រសហគមន៍អឺរ៉ុប : http://ec.europa.eu/delegations/cambodia/eu_cambodia/index_en.htm ។

# ជំពូកទី៦ : ផែនទីយុទ្ធសាស្ត្រមូលធនមនុស្សសម្រាប់កម្ពុជា និងហេតុផលសុទិដ្ឋិនិយម

ដើម្បីបង្កើតផែនការមួយបង្ហាញផ្លូវកម្ពុជាឱ្យបំពេញការងារ ក្នុងការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និង ប្រព័ន្ធអប់រំ ទាំងផែនការរយៈពេលខ្លី និងផែនការរយៈពេលវែង សុទ្ធតែសំខាន់ទាំងអស់។

## ៦.១ អន្តរាគមន៍រយៈពេលខ្លី

### *៦.១.១ ការបំពេញភាពខ្វះចន្លោះនៃជំនាញ*

វាប្រាកដណាស់ថា ការបណ្តុះបណ្តាលមនុស្សជាជំហានដំបូងក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់និយោជក។ ប៉ុន្តែការបណ្តុះបណ្តាលមនុស្សនៅកម្រិតមូលដ្ឋាន ប្រហែលជាមិនមានលក្ខណៈគ្រប់គ្រាន់ទេ ដោយសារថា ជាញឹកញាប់គ្រូឧទ្ទេសមិនបានគិតគូរពីអ្វីដែលមនុស្សរំពឹងថានឹងទទួលបានក្រៅពីការងារបណ្តុះបណ្តាលឡើយ។ ការវាយតម្លៃពីចំណាប់អារម្មណ៍របស់មនុស្ស និងកម្រិតជំនាញសម្រាប់ការងារសក្តានុពលក្នុងមុខតំណែងការងារបច្ចេកទេសជំនាញ គឺមានសារៈសំខាន់ស្មើគ្នា។ តាមរយៈការផ្តោតលើជំនាញមូលដ្ឋានដែលជាកត្តាចាំបាច់ដើម្បីទទួលបានជោគជ័យនោះ កម្មវិធីបណ្តុះបណ្តាលផ្សេងៗ ក៏គួរតែត្រូវបានណែនាំឱ្យដាក់បញ្ចូលការបង្ហាត់បង្រៀនពីការងារសញ្ញាបត្រ និងកម្មវិធីផ្សេងៗផងដែរ និងត្រូវផ្តោតលើការលើកកម្ពស់ជំនាញសក្តានុពលរបស់មនុស្សម្នាក់ៗផងដែរ។

#### ៦.១.១.១ ការបណ្តុះបណ្តាលដោយផ្តោតលើជំនាញមួយមុខ ធៀបនឹងវិធីបណ្តុះបណ្តាលជំនាញចម្រុះ

> *"ការបណ្តុះបណ្តាលដោយផ្តោតលើជំនាញមួយមុខ គឺចាំបាច់ដើម្បីទទួលខុសត្រូវលើការងារសំខាន់ដែលទាក់ទងនឹងជំនាញ។"*

ការបណ្តុះបណ្តាលដោយផ្តោតលើជំនាញមួយមុខ គឺចាំបាច់ដើម្បីទទួលខុសត្រូវលើការងារសំខាន់ដែលទាក់ទងនឹងជំនាញ ប៉ុន្តែនៅកម្ពុជាក៏ត្រូវការជាចាំបាច់នូវវិធីសាស្ត្របណ្តុះបណ្តាលកាន់តែទំនើប និងវិជ្ជមានមួយផងដែរ។ ចំពោះហេតុផលនេះប្រការសំខាន់នោះគឺយើងត្រូវដឹងថា តើមធ្យោបាយអ្វីខ្លះដែលមានប្រសិទ្ធភាពបំផុតដើម្បីអភិវឌ្ឍមនុស្ស និងវិធីលើកកម្ពស់មូលធនមនុស្សរបស់កម្ពុជាដោយផ្លាស់ប្តូរពីវិធីសាស្ត្របណ្តុះបណ្តាលជំនាញមួយមុខសម្រាប់ការបណ្តុះបណ្តាលជំនាញ។ ប្រជាពលរដ្ឋកម្ពុជាអនុវត្តការបណ្តុះបណ្តាលដែលទាក់ទងនឹងការងារជាច្រើន ប៉ុន្តែនៅទីបំផុតពួកគេប្រហែលជាយល់ថា ការបណ្តុះបណ្តាលបែបនេះមិនមានប្រយោជន៍ទេដោយសារពួកគេយល់ថា នឹងទទួលបានប្រាក់បៀវត្សរ៍តិចតួចដែលមិនអាចជួយដល់ពួកគេឱ្យចាកផុតពីភាពក្រីក្របាន។ នៅពេលងាកចេញពីទស្សនៈផ្តល់ "ការបណ្តុះបណ្តាលជំនាញទាក់ទងនឹងការងារមូលដ្ឋាន" និងផ្លាស់ប្តូរទៅរកវិធីសាស្ត្របណ្តុះបណ្តាលមួយដែលផ្តោតលើការផ្តល់លទ្ធភាព "ការសិក្សាសម្រាប់ប្រជាពលរដ្ឋជាលក្ខណៈបុគ្គល" នោះផលប៉ះពាល់នៃការបណ្តុះបណ្តាលនឹងកើនឡើងតាមរូបភាពផ្សេងៗដែលហួសពីជំនាញការងារ និងចំណេះដឹងជាលក្ខណៈប្រពៃណីតាមរយៈការបង្កើតកាលានុវត្តភាពដ៏ល្អ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងនិយោជក។

វិស័យជាច្រើននៅកម្ពុជាកំពុងប្រឈមនឹងសម្ពាធធ្ងន់ធ្ងរដើម្បីលើកកម្ពស់ជំនាញផ្នែករឹង និងជំនាញផ្នែកទន់របស់និយោជិត មិនតែប៉ុណ្ណោះបច្ចុប្បន្ននេះពុំមានយន្តការណាមួយដើម្បីសម្របសម្រួល និងលើកទឹកចិត្តដល់ការអភិវឌ្ឍ និងជោគជ័យរបស់បុគ្គលិកទេ និងដើម្បីកែលម្អឥរិយាបថនៅពេលបំពេញការងារ

ក្រៅពីការបណ្តុះបណ្តាលតាមលក្ខណៈប្រពៃណី។ អង្គភាពនានាដែលមានលទ្ធភាពផ្តល់ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ពីប្រភពដែលកាន់តែមានប្រយោជន៍ និងមានគោលជំហរផ្តោតលើនិយោជិតអាចលើកទឹកចិត្តឱ្យបុគ្គលិកធ្វើការងារ និងអនុវត្តការងារបានយ៉ាងល្អ ហើយបុគ្គលិកទំនងជានឹងបម្រើការងារនៅក្រុមហ៊ុនដដែលនោះក្នុងរយៈពេលយូរដោយផ្តល់លទ្ធភាពឱ្យពួកគេលើកកម្ពស់ជំនាញពាក់ព័ន្ធនឹងការបង្កើនផលិតភាពរបស់ខ្លួនក៏ដូចជាជួយបណ្តុះបណ្តាលបុគ្គលិកផ្សេងទៀត។

ពិតប្រាកដណាស់ការយល់ដឹងច្រើន និងការរំពឹងទុកពីអ្វីដែលត្រូវដាក់បញ្ចូលក្នុងការបណ្តុះបណ្តាលនោះមិនអាចផ្លាស់ប្តូរបានយ៉ាងឆាប់រហ័សទេ។ វិស័យភាគច្រើនយល់ថា ការបណ្តុះបណ្តាលនៅមានកម្រិតនៅឡើយសម្រាប់ជំនាញបំពេញការងារ ប៉ុន្តែប្រសិនបើយើងចាត់ទុកថា ការបណ្តុះបណ្តាលជា"ការអភិវឌ្ឍមនុស្ស" ដូច្នេះការបណ្តុះបណ្តាលមិនត្រូវផ្តោតតែលើការបណ្តុះបណ្តាលជំនាញតែមួយមុខទេ ប៉ុន្តែត្រូវរាប់បញ្ចូលទាំងគោលនយោបាយផ្សេងៗដែលសំដៅដល់ការផ្តល់លទ្ធភាពសិក្សា ការសម្របសម្រួលដល់ការអភិវឌ្ឍខ្លួនឯងប្រកបដោយអត្ថន័យ និងការអភិវឌ្ឍទំនាក់ទំនងរវាងភាពជោគជ័យរបស់បុគ្គលិក និងភាពជោគជ័យលើការងាររបស់អ្នកទាំងនោះផងដែរ។[៣៨]

ការបណ្តុះបណ្តាលតាមលក្ខណៈប្រពៃណី តែងតែភ្លេចពីការផ្តល់ការណែនាំស្តីពីជំនាញផ្នែកទន់ដែលជាធម្មតាជំនាញ នេះគឺជាអ្វីដែលនិយោជកគិតថា បុគ្គលិកគ្រប់រូបត្រូវតែមាន។ ដូច្នេះ ការបណ្តុះបណ្តាលត្រូវផ្តោតលើវិធីសាស្ត្រកាន់តែទូលំទូលាយមួយដោយពិចារណាទៅលើអ្វីដែលអាចជួយដល់បុគ្គលិកម្នាក់បង្កើនសមត្ថភាព ជំនាញ ទំនុកចិត្ត ភាពអត់ធ្មត់ ការប្តេជ្ញាចិត្ត គំនិតផ្តួចផ្តើម ជំនាញប្រាស្រ័យទាក់ទង និងការយល់ដឹងរបស់ខ្លួនបាន។

លើសពីនេះ ការបណ្តុះបណ្តាលជំនាញមួយមុខផ្តល់បច្ចេកទេស និងវិធីសាស្ត្រថ្មីៗដល់បុគ្គលិក ប៉ុន្តែការបណ្តុះបណ្តាលនេះនឹងមិនអភិវឌ្ឍភាពចាស់ទុំ ជំនឿ ឬភាពក្លាហានរបស់បុគ្គលិកម្នាក់ៗទេ ដែលកត្តាទាំងនេះសុទ្ធតែចាំបាច់សម្រាប់ការអភិវឌ្ឍសមត្ថភាពយុទ្ធសាស្ត្រ។ ការទទួលបានបទពិសោធពីការសិក្សាសម្រាប់ការអភិវឌ្ឍខ្លួនឯង និងជោគជ័យផ្ទាល់របស់បុគ្គលិកម្នាក់ៗមានទាក់ទងនឹងការបំពេញការងារ និងសមត្ថភាពតែវាក៏អាស្រ័យជាពិសេសលើឥរិយាបថនិងភាពចាស់ទុំរបស់បុគ្គលម្នាក់ៗផងដែរ។នៅពេលដែលបុគ្គលិកមានទំនុកចិត្ត និងភាពសុច្ចរិតនោះពួកគេនឹងកាន់តែសកម្មនឹងការងារផ្តោតលើដំណោះស្រាយមានការទទួលខុសត្រូវ និងជួយបង្កើតកត្តាជំរុញចាំបាច់សម្រាប់ បុគ្គលិកដើម្បី អភិវឌ្ឍ និងផ្លាស់ប្តូរ។

---

៣៨ យើងអាចផ្តល់ការបណ្តុះបណ្តាលជាច្រើនប្រភេទ ដូចជា : ការបណ្តុះបណ្តាលនៅពេលបំពេញការងារការបណ្តុះបណ្តាលក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលក្នុងថ្នាក់រៀនវគ្គបណ្តុះបណ្តាលផ្ទៃក្នុង វគ្គបណ្តុះបណ្តាលខាងក្រៅ ការហ្វឹកហាត់ការងារ ការបង្ហាត់បង្រៀនពីជីវិត ការណែនាំ កិច្ចការ និងការងារបណ្តុះបណ្តាល ការបណ្តុះបណ្តាលជំនាញ ការបណ្តុះបណ្តាលពីផលិតផលការបណ្តុះបណ្តាលបច្ចេកទេស ការបណ្តុះបណ្តាលពីអត្តចរិត ការអភិវឌ្ឍនិងការបណ្តុះបណ្តាលឥរិយាបថ ការបណ្តុះបណ្តាល និងសិក្សាដែលបានទទួលស្គាល់ទូរសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈដែលការបណ្តុះបណ្តាលទាំងអស់នេះអាចរៀបចំទៅតាមតម្រូវការការបណ្តុះបណ្តាលរបស់បុគ្គលិកម្នាក់ៗ តាមវិស័យប្រវត្តិសិក្សារបស់បុគ្គលិក និងការតម្រង់ទិសរបស់បុគ្គលិក។ ទស្សនៈពាក់ព័ន្ធនឹងវិធីសាស្ត្របណ្តុះបណ្តាលដើម្បីជួយដល់ការអភិវឌ្ឍខ្លួនឯងជុំវិញការបណ្តុះបណ្តាល និងការសិក្សាមានដូចជា (១) ការវាយតម្លៃ និងការព្រមព្រៀងគ្នាលើតម្រូវការការបណ្តុះបណ្តាលតាមរយៈការវិភាគពីតម្រូវការការបណ្តុះបណ្តាលមួយចំនួន (២) រៀបចំលក្ខណៈពិសេសសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍដោយបំបែកការបណ្តុះបណ្តាល និងការសិក្សាជាផ្នែកសំខាន់ៗបំផុត (៣) ពិនិត្យមើលរបៀបសិក្សា និងបុគ្គលិកលក្ខណៈ ដែលអាចប៉ះពាល់ដល់ប្រភេទនៃការបណ្តុះបណ្តាលដែលបុគ្គលិកម្នាក់យល់ថាងាយស្រួលបំផុត និងមានប្រសិទ្ធភាពបំផុត (៤) រៀបចំការបណ្តុះបណ្តាល និងការវាយតម្លៃដោយពិនិត្យមើលការវាយតម្លៃពីប្រសិទ្ធភាពបណ្តុះបណ្តាលមុន និងក្រោយពេលវាយតម្លៃ (៥) រៀបចំសម្ភារសិក្សា វិធីសាស្ត្រ និងផ្តល់ការបណ្តុះបណ្តាលដោយពិនិត្យមើលវិធីសាស្ត្រទំនើប និងមានគំនិតច្នៃប្រឌិតថ្មី។

### ៦.១.១.២ ការផ្តល់ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាពដល់និយោជិតថ្មីៗ

ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព ជាពិសេស សម្រាប់និយោជតិវ័យក្មេងមានសារៈសំខាន់ណាស់ ហើយនិយោជកគប្បីអនុវត្តការបណ្តុះបណ្តាលណែនាំការងារដែលសមស្របដល់ពួកគេ។ នេះក៏ដោយសារតែការបណ្តុះបណ្តាលណែនាំការងារនេះធានាឱ្យនិយោជិតថ្មីៗ មានលទ្ធភាពដោះស្រាយបញ្ហាបានឆាប់រហ័ស និងរីករាយ។ ការបណ្តុះបណ្តាលណែនាំការងារ មិនគ្រាន់តែជាការបណ្តុះបណ្តាលជំនាញតែប៉ុណ្ណោះទេ វាថែមទាំងជាការបណ្តុះបណ្តាល អំពីជំនាញមូលដ្ឋានដែលបុគ្គលិកជាន់ខ្ពស់ភាគច្រើនមិនបានយកចិត្តទុកដាក់។ និយោជិតថ្មីៗ ត្រូវស្វែងយល់ពីអង្គភាពមួយ សកម្មភាព និងគោលដៅរបស់អង្គភាពនោះព្រមទាំងត្រូវយល់ឱ្យបានច្បាស់ពីវិធីសាស្ត្រ ពេលវេលា និងការរំពឹងទុករបស់អង្គភាពនោះផងដែរ។

គោលការណ៍បណ្តុះបណ្តាលណែនាំការងារផ្អែកលើក្រមសីលធម៌មូលដ្ឋាន និងជំនាញផ្នែកទន់ព្រមទាំងមានសារៈសំខាន់ចំពោះបុគ្គលិកថ្មីៗដើម្បីដោះស្រាយ និងរីករាយក្នុងការបំពេញការងាររបស់ខ្លួន។ គ្រូឧទ្ទេសត្រូវលើកឡើងអំពីការអភិវឌ្ឍសមត្ថភាពបុគ្គល គោលដៅរយៈពេលវែង និងកាលានុវត្តភាពផ្សេងៗរបស់បុគ្គលិកថ្មីៗ។ ការណែនាំ និងការបង្ហាត់បង្រៀនសមស្របត្រូវយកមកប្រើប្រាស់ជាមួយនឹងការបណ្តុះបណ្តាលតាមរចនាសម្ព័ន្ធផ្លូវការ។

### ៦.១.១.៣ គន្លឹះក្នុងការបណ្តុះបណ្តាល

វាជាការលំបាកក្នុងការផ្តល់ជំនាញដែលមានលក្ខណៈស្តង់ដា និងមានសារៈសំខាន់ចំពោះការអភិវឌ្ឍខ្លួនឯង និងការសម្របសម្រួលដល់ការសិក្សាដោយសារលក្ខណៈនៃការសិក្សាទាក់ទងនឹងវិធីសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ និងបទពិសោធ។ ដូច្នេះ វាមិនគ្រប់គ្រាន់ទេ ដើម្បីបង្កើតការបណ្តុះបណ្តាលដែលពាក់ព័ន្ធនឹងការកំណត់តួនាទី និងភារកិច្ចការងារនោះ។ យើងចាំបាច់ត្រូវអនុវត្តឱ្យលើសពីជំនាញផ្សេងៗដោយបង្កើតជាគំរូតរិយាបថមួយ បើទោះជាការបង្កើតជាគំរូតរិយាបថនេះពិបាកធ្វើការវាយតម្លៃក៏ដោយ។ យើងចាំបាច់ត្រូវសិក្សាជាបន្តពីការបណ្តុះបណ្តាលជំនាញ លក្ខណៈ សម្បត្តិ កម្រិតការងារ និងកម្រិតដែលត្រូវផ្តល់រង្វាន់ដោយសារសកម្មភាពទាំងនេះមានជាប់ពាក់ព័ន្ធគ្នាដោយមិនអាចកាត់ផ្តាច់បាន ហើយយើងអាចសង្កេតមើល និងយល់ដឹងពីភាពពាក់ព័ន្ធនេះបានយ៉ាងងាយ។ ក្រៅពីជំនាញការងារតែមួយមុខបញ្ហាអភិវឌ្ឍខ្លួនឯង និងសិក្សាសម្រាប់ជីវិតដែលមិនមែនសម្រាប់តែការងារនោះ គឺជាផ្នែកសំខាន់បំផុតដែលអ្នកបង្កើតគោលនយោបាយអភិវឌ្ឍខ្លួនឯងត្រូវយកចិត្តទុកដាក់។

វិទ្យាស្ថានអប់រំក្រោយមធ្យមសិក្សាទុតិយភូមិ និងនិយោជកត្រូវសហការគ្នាប្រកបដោយគំនិតច្នៃប្រឌិតដើម្បីឆ្លើយតបតាមតម្រូវការរបស់សិស្សនាពេលបច្ចុប្បន្ន និងតម្រូវការកម្លាំងពលកម្មជំនាញដែលកំពុងកើនឡើងនេះ។ កម្មវិធីបណ្តុះបណ្តាលនឹងផ្តល់ការណែនាំច្បាស់លាស់ល្អមួយដល់សិស្សតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងវិស័យការងារដែលកំពុងកើនឡើង និងទទួលបានប្រាក់បៀវត្សរ៍ខ្ពស់។ ជាងនេះទៀតមជ្ឈមណ្ឌលបណ្តុះបណ្តាលត្រូវធ្វើជាដៃគូជាមួយនឹងវិទ្យាស្ថានអប់រំ វិស័យឧស្សាហកម្ម និងរដ្ឋាភិបាល ព្រមទាំងផ្តោតការយកចិត្តទុកដាក់លើការបង្កើតចំនួននិយោជិតដែលអាចឆ្លើយតបតាមតម្រូវការសេដ្ឋកិច្ចប្រទេសរបស់ខ្លួន។

ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព គួរតែអាចផ្តល់វិធីសាស្ត្រដែលបានរៀបចំសម្រាប់ការចូលកាន់មុខតំណែងបច្ចេកទេសជំនាញ ដោយមានមុខវិជ្ជាសិក្សាដើម្បីកាន់ការងារកម្រិតខ្ពស់នៅតាមកន្លែងការងារផ្សេងៗ។ ប្រសិនបើវិធីសាស្ត្រនោះទទួលបានជោគជ័យគោលនយោបាយប្រភេទនេះនឹងអាចជួយ

*"ការអប់រំ ជាចំណុចសំខាន់នៃគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយជំរុញកំណើនសេដ្ឋកិច្ចនៅប្រទេសអភិវឌ្ឍ ។"*

លើកកម្ពស់ជីវភាពរស់នៅរបស់និយោជិតវ័យក្មេងដែលមានប្រាក់ចំណូលទាប តាមរយៈការផ្តល់វិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពដល់និយោជិតទាំងនោះ ដោយពួកគេមិនត្រឹមតែអាចទទួលបាននូវជំនាញដើម្បីជៀសផុតពីភាពគ្មានការងារធ្វើប៉ុណ្ណោះទេ ថែមទាំងអាចបន្តកសាងជំនាញទាំងនោះដើម្បីឈានទៅចាប់យកអាជីព និងមានជីវភាពកាន់តែប្រសើរ ។ ការធ្វើបែបនេះនឹងផ្តល់ការងារដល់និយោជិតទាំងនោះដែលត្រូវការជំនាញទាំងនេះ និងផ្គត់ផ្គង់កម្លាំងពលកម្មជំនាញដល់ឧស្សាហកម្មផ្សេងៗ ទន្ទឹមនឹងនោះដែរក៏ជួយដល់ការលើកកម្ពស់សេដ្ឋកិច្ចជាតិតាមរយៈការបង្កើនសមត្ថភាពកម្លាំងពលកម្មរបស់ខ្លួន មិនត្រឹមតែចំពោះកម្លាំងពលកម្មដែលគ្មានជំនាញនោះទេ ថែមទាំងបង្កើតឱកាសបន្ថែមសម្រាប់ខ្លួនឯង ក្រុមហ៊ុន និងឧស្សាហកម្មរបស់ខ្លួនផងដែរ ។

### *៦.១.២ ការបញ្ឈប់កុមារពីការបោះបង់ការសិក្សា*

សិស្សតែងតែរាយការណ៍ពីហេតុផលខុសៗគ្នាជាច្រើនអំពីការបោះបង់ការសិក្សា (ដូចបានពិភាក្សាក្នុងជំពូក២) ដូច្នេះ វិធីសាស្ត្រដើម្បីរារាំងដល់ការបោះបង់ការសិក្សាត្រូវមានយុទ្ធសាស្ត្រដែលមានវិសាលភាពចម្រុះមួយ ។ យុទ្ធសាស្ត្រទាំងនេះ រួមមានការពិនិត្យតាមដាន ការបង្ហាត់បង្រៀន ការសិក្សាពីសេវាសាលាជម្រើស និងឱកាសបន្ទាប់ពីការសិក្សា ។

ការអប់រំ ជាចំណុចសំខាន់នៃគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយជំរុញកំណើនសេដ្ឋកិច្ចនៅប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍន៍ ហើយការអប់រំត្រូវបានគេចាត់ទុកថាជាកត្តាកំណត់សំខាន់មួយនៃការអភិវឌ្ឍ និងសម្រាប់សមត្ថភាពរបស់ប្រទេសមួយដើម្បីតាមដានការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងការសម្រេចបានការអភិវឌ្ឍបច្ចេកវិទ្យា ។ គោលនយោបាយនេះ គឺជាមូលដ្ឋាននៃការផ្តោតការយកចិត្តទុកដាក់ទូទាំងពិភពលោកលើបញ្ហាបោះបង់ការសិក្សា និងចំនួនគោលនយោបាយដែលមានបំណងកាត់បន្ថយអត្រាបោះបង់ការសិក្សានេះ ។ ឧទាហរណ៍ ការប្រើប្រាស់វិធីសាស្ត្រផ្តល់ការអប់រំដោយឥតគិតថ្លៃនៅកម្រិតមធ្យមសិក្សា និងការបង្កើនអាយុកុមារដែលចាំបាច់ត្រូវចាកចេញពីសាលារៀន ។ ការវាយតម្លៃកម្មវិធីនេះអាចផ្តល់ព័ត៌មានដ៏មានតម្លៃថាតើឧបត្ថមធនផ្សេងៗអាចកាត់បន្ថយចំណាយអប់រំ និងកាត់បន្ថយអត្រាបោះបង់ការសិក្សាបានដែរឬទេ ។ ផលប៉ះពាល់របស់ឧបត្ថមធនមានច្រើនគួរឱ្យកត់សម្គាល់ ជាពិសេសចំពោះសិស្សដែលមានសវតារក្រីក្រដោយសារទាំងសិស្សប្រុស និងសិស្សស្រីដែលមកពីគ្រួសារមានសាវតារសេដ្ឋកិច្ចសង្គមទាបមានអត្រាបោះបង់ការសិក្សាខ្ពស់ ហើយកម្មវិធីផ្ទេរសាច់ប្រាក់អាចបង្ហាញពីប្រសិទ្ធភាពបញ្ឈប់ និងកាត់បន្ថយអត្រាបោះបង់ការសិក្សាសម្រាប់ក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត ។

"យន្តការឆ្លើយតបវិបត្តិទាមទារឱ្យអង្គការអន្តរជាតិ និងរដ្ឋាភិបាលសហការគ្នា។"

*ប្រអប់ ៦.១ ការអប់រំមានប្រាក់ឧបត្ថម (EMA)*[៣៩]

នេះគឺជាគំនិតផ្តួចផ្តើមមួយដែលបានអនុវត្តសាកល្បងជាលើកដំបូងនៅឆ្នាំ១៩៩៩ នៅប្រទេសអង់គ្លេស ក្នុងអង្គភាពអប់រំចំនួន ១០។ គម្រោងនេះផ្តល់អត្ថប្រយោជន៏ដល់សិស្សអាយុចាប់ពី ១៦ឆ្នាំ ដល់ ១៨ឆ្នាំ ដែលនៅបន្តការសិក្សាពេញម៉ោងបន្ទាប់ពីបញ្ចប់ថ្នាក់ទី១១ នៅពេលដែលការអប់រំលែងក្លាយជាកាតព្វកិច្ចសម្រាប់សិស្សទាំងនោះ។ការចំណាយនានារួមមាន(១) ប្រាក់ឧបត្ថម្ភប្រចាំសប្តាហ៍(ក្នុងអំឡុងពេលសិក្សាតែប៉ុណ្ណោះ) (២) ប្រាក់លើកទឹកចិត្តសម្រាប់ការបន្តសិក្សារាល់វគ្គសិក្សាសម្រាប់សិស្សដែលចូលរៀនជាប្រចាំនិង(៣) ប្រាក់លើកទឹកចិត្តសម្រាប់ភាពជោគជ័យក្នុងការសិក្សាដែលនឹងផ្តល់ជូននៅចុងវគ្គសិក្សា ប្រសិនបើ សិស្សណាអាចសម្រេចបានតាមគោលដៅដែលបានព្រមព្រៀងក្នុងកិច្ចព្រមព្រៀងសិក្សា ដែលចុះហត្ថលេខាដោយមាតិបិតា និងសិស្សនៅពេលចូលរួមក្នុងកម្មវិធី EMAនេះ។ ទឹកប្រាក់អតិបរមាមានចំនួន ៣0 ទៅ ៤0 ផោន ត្រូវបែងចែកដល់សិស្សដែលមកពីក្រុមគ្រួសារមានប្រាក់ចំណូលក្រោម ១៣ 0000ផោន ក្នុងមួយឆ្នាំ។ គម្រោងផ្សេងទៀតដែលមានរង្វាន់លើកទឹកចិត្តតិចជាងនេះ ត្រូវបានរៀបចំឡើងសម្រាប់ក្រុមគ្រួសារនានាដែលមានប្រាក់ចំណូលពី ១៣ 000ផោន ដល់ ៣0 000 ផោនក្នុងមួយឆ្នាំ។

កម្មវិធី EMA នេះ ធ្វើឱ្យមានកំណើនសិស្សចូលរួមដែលបង្ហាញថាគោលនយោបាយប្រភេទនេះ ពិតជាមានប្រសិទ្ធភាព។ កម្មវិធីនេះ បានជះឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងដល់ការចូលរួមក្នុងការអប់រំក្រោយពេលចប់កាតព្វកិច្ចក្នុងចំណោមសិស្សក្មេងៗដែលមានសិទ្ធិចូលរួមក្នុងគម្រោងនេះ។

## *៦.១.៣ ការដោះស្រាយបញ្ហានិកម្មភាពនៅកម្ពុជាតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រីក្រដោយចាត់ទុកថាជាយុទ្ធសាស្រ្តឆ្លើយតបនឹងវិបត្តិមួយ*

ប្រទេសជាច្រើនបានរងឥទ្ធិពលពីវិបត្តិហិរញ្ញវត្ថុក្រោមរូបភាពខុសគ្នា ហើយប្រទេសដែលមានសេដ្ឋកិច្ចពាក់ព័ន្ធខ្លាំងលើការនាំចេញច្រើនតែប៉ះពាល់ខ្លាំងជាងប្រទេសដែលមានទីផ្សារក្នុងស្រុកធំ។ ប្រទេសដែលប្រឈមនឹងហានិភ័យកាន់តែខ្ពស់នោះ គឺប្រទេសដែលងាយរងគ្រោះស្រាប់មុនពេលមានវិបត្តិនេះ និងមានយន្តការដោះស្រាយតិចតួច ហើយប្រជាពលរដ្ឋដែលរងផលវិបាកច្រើនជាងគេបំផុត គឺតែងតែជាប្រជាពលរដ្ឋក្រីក្រ និងសមាជិកគ្រួសារក្នុងបន្ទុករបស់ប្រជាពលរដ្ឋទាំងនោះ។ វិធីសាស្រ្តឆ្លើយតបវិបត្តិចាំបាច់ត្រូវកំណត់ប្រជាពលរដ្ឋដែលងាយរងគ្រោះនៅតាមតំបន់ជនបទ និងតំបន់ប្រជុំជនដែលជីវភាពរបស់ប្រជាពលរដ្ឋទាំងនោះទំនងជារងផលប៉ះពាល់ធ្ងន់ធ្ងរដោយវិបត្តិនេះ។ ក្រុមប្រជាពលរដ្ឋទាំងនេះត្រូវការជំនួយសង្គមបន្ថែម ដោយសារពួកគេតែតែងត្រូវបានដកចេញពីកញ្ចប់ជំរុញសេដ្ឋកិច្ច ប្រសិនបើប្រជាពលរដ្ឋទាំងនោះរស់នៅក្នុងតំបន់នោះជាលើកដំបូង។

យន្តការឆ្លើយតបវិបត្តិទាមទារឱ្យអង្គការអន្តរជាតិ និងរដ្ឋាភិបាលសហការគ្នាដើម្បីដោះស្រាយវិបត្តិនេះ និងកាត់បន្ថយផលប៉ះពាល់ពីវិបត្តិនេះ។ ជាពិសេសកម្ពុជាជាប្រទេសងាយរងគ្រោះពីវិបត្តិហិរញ្ញវត្ថុពិភពលោកនេះដោយសារការបើកចំហរពាណិជ្ជកម្ម និងការវិនិយោគរបស់ខ្លួន។ ភាពក្រីក្រនៅតែបន្តរីករាលដាល ចំណែកឯប្រជាជនជិតក្រីក្រកំពុងប្រឈមនឹងហានិភ័យនៃការធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ។ កម្ពុជាខ្វះគម្លាតសារពើពន្ធដើម្បីសម្រេចបានកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ចមួយ។ រដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្រ្តមួយដើម្បីការពារសង្គមដោយសហការជាមួយដៃគូអភិវឌ្ឍន៏ផ្សេងៗ ដោយរៀបចំផែនការបង្កើតបណ្តាញសុវត្ថិភាពសង្គមដែលអាចកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានរបស់វិបត្តិនេះ មកលើប្រជាពលរដ្ឋ

៣៩ http://www.aeaweb.org/annual_mtg_papers/2005/0107_0800_0801.pdf ។

ក្រីក្រ និងងាយរងគ្រោះ ។ បណ្តាញសុវត្ថិភាពសង្គមបានបង្កើតជាកម្មវិធីផ្ទេរសាច់ប្រាក់ និងមិនមែនជាសាច់ប្រាក់ដែលរួមមានគម្រោងការងារសាធារណៈផ្តល់ការងារចម្រុះជាច្រើន ។

កញ្ចប់ថវិកាជំរុញសេដ្ឋកិច្ច និងបណ្តាញសុវត្ថិភាពសង្គមផ្តល់កាលានុវត្តភាពមួយក្នុងការលើកកម្ពស់ការកំណត់តួនាទី និងការទទួលខុសត្រូវលើការងារមើលចេញពីវិបត្តិសេដ្ឋកិច្ចនេះ ។ ប៉ុន្តែប្រទេសជាច្រើនត្រូវមានគម្លាតសារពើពន្ធគ្រប់គ្រាន់ដើម្បីរៀបចំកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ចមួយឱ្យបានរួចរាល់ជាស្រេច ចំណែកឯប្រទេសក្រីក្រ ដូចជាកម្ពុជានឹងកាន់តែពឹងផ្អែកថែមទៀតលើជំនួយអន្តរជាតិដើម្បីរៀបចំបណ្តាញសុវត្ថិភាពសង្គមរបស់ខ្លួនឆ្លើយតបនឹងវិបត្តិហិរញ្ញវត្ថុពិភពលោកនេះ ។

*ប្រអប់ ៦.២ បណ្តាញសុវត្ថិភាពសង្គម និងការជួយដល់និកម្មជន*

នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចប្រែប្រួលយ៉ាងឆាប់រហ័សនាពេលបច្ចុប្បន្ន មនុស្សម្នាក់ៗ និងគ្រួសារដែលកំពុងបម្រើការងារត្រូវការបណ្តាញសុវត្ថិភាពសង្គមដ៏រឹងមាំដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលឡើងវិញព្រមទាំងជំនួយស្វែងរកការងារធ្វើនៅពេលដែលសេដ្ឋកិច្ចមានវិបត្តិ ។ ប៉ុន្តែនៅប្រទេសកំពុងអភិវឌ្ឍន៍បណ្តាញសុវត្ថិភាពសង្គមសម្រាប់និកម្មជនដែលមានស្រាប់មិនបានតាមដានការប្រែប្រួលកម្លាំងពលកម្មនេះទេ ជាពិសេស កំណើនកម្លាំងពលកម្មជាស្ត្រី និងបុគ្គលិកដែលបំពេញការងារមិនពេញម៉ោង និងទទួលបានប្រាក់ឈ្នួលតិចតួច ។

ជាពិសេស និយោជិតដែលទទួលបានប្រាក់ឈ្នួលតិចមានការលំបាកនៅពេលគ្មានការងារធ្វើ និងទំនងជាជួបប្រទះនឹងភាពគ្មានការងារធ្វើច្រើនជាងនិយោជិតដែលទទួលបានប្រាក់ឈ្នួលខ្ពស់ ។ ដោយនិកម្មភាពក្លាយជារឿងសាមញ្ញសេដ្ឋកិច្ចរបស់ប្រទេសមួយ ពឹងផ្អែកលើអត្ថប្រយោជន៍ធានារ៉ាប់រងលើនិកម្មភាព ដើម្បីដោះស្រាយការលំបាកដែលមិនអាចព្យាករបានដល់និយោជិតជាច្រើន និងគ្រួសាររបស់ពួកគេនៅពេលដែលនិយោជិតទាំងនោះបាត់បង់ការងារ ។ អត្ថប្រយោជន៍ទាំងនេះអាចផ្តល់លទ្ធភាពឱ្យនិយោជិតទាំងនោះគេចផុតពីភាពក្រីក្រជាបណ្តោះអាសន្ន ហើយបញ្ចប់ការលំបាកផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីការបាត់បង់ការងារ ។

សញ្ញាណដែលថា ការបង្កើតសង្គមមួយដែលមានបណ្តាញសុវត្ថិភាពសង្គមរឹងមាំ ដូចជា ការធានារ៉ាប់រងលើនិកម្មភាពធ្វើឱ្យធ្លាក់ចុះចេតនាបំពេញការងារមិនមែនជាការពិតទេ ។ កម្មវិធីសុខុមាលភាព និងកម្មវិធីជំនួយសង្គមបង្ហាញភស្តុតាងដោយលើកឡើងថា នៅក្នុងសង្គមដែលមានកម្មវិធីបណ្តាញសុវត្ថិភាពសង្គមរឹងមាំតែងផ្តល់សុភមង្គល និងការពេញចិត្តសម្រាប់និយោជិកភាគច្រើនដូចដែលធ្លាប់ការងារតែងផ្តល់ឱ្យផងដែរ ។

នៅ OECD មានកម្មវិធីជាច្រើនប្រភេទដែលផ្តល់ឧទាហរណ៍ជាច្រើន ឬគំរូសក្តានុពលសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ ទន្ទឹមនឹងនោះដែរកម្មវិធីគ្រប់គ្រងខុសគ្នាច្រើនពីប្រទេសមួយទៅប្រទេសមួយខាងក្រោមនេះគឺជាប្រភេទកម្មវិធីផ្ទេរសង្គមសំខាន់មួយចំនួន ។

- កម្មវិធីប្រាក់ចំណូលអប្បបរមាដែលរដ្ឋាភិបាលមានលទ្ធភាពផ្តល់ជំនួយហិរញ្ញវត្ថុប្រាក់ចំណូលអប្បបរមាដល់ប្រជាពលរដ្ឋដែលគ្មានធនធាន ។
- អត្ថប្រយោជន៍ក្នុងផ្ទះដោយផ្តល់ប្រាក់ចំណាយពាក់ព័ន្ធនៅក្នុងផ្ទះតាមរូបភាពផ្សេងៗ
- អត្ថប្រយោជន៍ប្រចាំគ្រួសារ គឺជាអត្ថប្រយោជន៍ដែលផ្តល់ឱ្យដោយផ្ទាល់ដល់គ្រួសារដែលមានកូនច្រើនក្នុងគ្រួសារដើម្បីជួយដល់ការអភិវឌ្ឍគ្រួសារទាំងនោះ
- អត្ថប្រយោជន៍សម្រាប់គ្រួសារដែលមានតែម្តាយ ឬឪពុកក្នុងបំណងកាត់បន្ថយហានិភ័យនៃភាពក្រីក្របំផុតសម្រាប់គ្រួសារដែលមានតែម្តាយ ឬឪពុកនេះ

- អត្ថប្រយោជន៍មានការងារដែលជាប់លក្ខខណ្ឌសម្រាប់បុគ្គលិកដែលមិនពិការ ក្នុងគោលបំណងធានាថា យ៉ាងហោចណាស់ប្រាក់លើកទឹកចិត្តមួយចំនួនដើម្បីបំពេញការងារត្រូវបានរក្សាទុកដោយអនុញ្ញាតឱ្យអ្នកទទួលផលប្រយោជន៍នេះ បំពេញការងារតាមចំនួនម៉ោងជាក់លាក់ដោយមិនបញ្ចប់សិទ្ធិទទួលបានប្រាក់លើកទឹកចិត្តនេះ ឬការបង់ពន្ធលើប្រាក់ចំណូលទាំងស្រុងដែលបានរកមកខណៈដែលពួកគេវិលត្រលប់ចូលបម្រើការងារវិញ។
- អត្ថប្រយោជន៍ថែទាំកូនជំនួយហិរញ្ញវត្ថុសម្រាប់គ្រួសារដែលមានកូនតូចដើម្បីផ្តល់ក្នុងការចិញ្ចឹមបីបាច់កូន។

សម្ពាធដែលកើតមាននៅតាមប្រទេសអភិវឌ្ឍន៍ជាច្រើនបានដឹកនាំការបង្កើតកំណែទម្រង់គោលនយោបាយសម្រាប់សេវាសង្គមតាមការណែនាំរូមតិចតួចមួយ។ តាមធម្មតាបណ្តាញសុវត្ថិភាពសង្គមត្រូវបានរៀបចំឡើងដើម្បីការពារប្រជាពលរដ្ឋចាស់ៗ និកម្មភាពរយៈពេលខ្លីជនពិការ និងប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប។ ប៉ុន្តែថ្មីៗនេះរបបគោលនយោបាយគាំពារសង្គមត្រូវបានរៀបចំឡើងដើម្បីដោះស្រាយ :

- កំណើនប្រជាពលរដ្ឋគ្មានការងារធ្វើរយៈពេលវែងដោយសារការប្រែប្រួលទីផ្សារធ្ងន់ធ្ងរ និងសកលភាវូបនីយកម្មនៃផលិតកម្មដែលបណ្តាលមកពីការកាត់បន្ថយចំនួនការងារគ្មានជំនាញ។
- ការចម្រើនវ័យរបស់ប្រជាពលរដ្ឋដែលមិនត្រឹមតែបានធ្វើឱ្យការពឹងផ្អែកលើការធានារ៉ាប់រងសង្គមកើនឡើង ប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យជំនួយសង្គមដែលបានកំណត់គោលដៅសម្រាប់ប្រជាពលរដ្ឋចាស់ៗដែលមានប្រាក់ចំណូលទាបកើនឡើងផងដែរ។
- ការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រួសារដោយចំនួនគ្រួសារដែលមានតែម្តាយ ឬឪពុកកំពុងកើនឡើង។
- ភាពតានតឹងក្នុងការផ្តល់មូលនិធិ និងសេវារវាងអាជ្ញាធរថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានដែលមានរដ្ឋាភិបាលគ្រប់គ្រងតាមតំបន់កំពុងទាមទារសមត្ថកិច្ចថែមទៀតក្នុងការផ្តល់ហិរញ្ញប្បទាន និងគ្រប់គ្រងអត្ថប្រយោជន៍គាំពារសង្គម។

ប្រទេសកំពុងអភិវឌ្ឍន៍អាចរៀនសូត្រពីបទពិសោធរបស់ប្រទេសអភិវឌ្ឍន៍ និងប្រើប្រាស់បណ្តាញសុវត្ថិភាពសង្គមរបស់ប្រទេសទាំងនោះធ្វើជាករណីសិក្សាដោយជ្រើសរើសយកបណ្តាញសុវត្ថិភាពសង្គមពីប្រទេសណាមួយ និងជ្រើសរើសការងារដែលសមស្របបំផុតសម្រាប់ស្ថានភាពជាក់លាក់ក្នុងប្រទេសរបស់ខ្លួន។ ការរៀបចំគោលនយោបាយគំរូ និងការបង្កើតការស្រាវជ្រាវដែលសំអាងលើបទពិសោធដែលជាកត្តាចាំបាច់ដើម្បីរៀបចំឯកសារការងារដ៏ល្អបំផុត ជាពិសេសក្នុងពេលមានវិបត្តិការងារទាំងនេះនឹងក្លាយជាគន្លឹះដើម្បីជំរុញសេដ្ឋកិច្ច និងកាត់បន្ថយទុក្ខលំបាក។

កម្ពុជាខ្វះគម្លាតសារពើព័ន្ធដើម្បីរៀបចំ និងអនុវត្តកញ្ចប់ថវិកាជំរុញសេដ្ឋកិច្ច ដើម្បីកាត់បន្ថយផលប៉ះពាល់របស់វិបត្តិដែលកន្លងទៅនាពេលថ្មីៗនេះ កម្ពុជាត្រូវសម្រេចអនុវត្តការផ្តល់បណ្តាញសុវត្ថិភាពសង្គម។ បណ្តាញសុវត្ថិភាពសង្គមជាច្រើនត្រូវបានប្រើប្រាស់នៅកម្ពុជាដើម្បីកាត់បន្ថយភាពក្រីក្រ និងជួយដល់ប្រជា-ពលរដ្ឋងាយរងគ្រោះដោះស្រាយវិបត្តិសេដ្ឋកិច្ច និងសង្គម។ ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចការសាធារណៈបានក្លាយជាធាតុផ្សំយ៉ាងសំខាន់របស់បណ្តាញសុវត្ថិភាពសង្គម (សាច់ប្រាក់ពលកម្ម និងស្បៀងពលកម្ម)។

ការពឹងផ្អែកលើបណ្តាញសុវត្ថិភាពសង្គមដើម្បីកាត់បន្ថយផលប៉ះពាល់របស់វិបត្តិសេដ្ឋកិច្ចនោះ គឺកម្ពុជានឹងត្រូវការហិរញ្ញប្បទានគ្រប់គ្រាន់តែមួយមុខគត់។ ការអភិវឌ្ឍបណ្តាញសុវត្ថិភាពសង្គមដែលអាចអនុវត្តបាន និងប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក្រីក្រត្រូវការដៃគូអភិវឌ្ឍន៍ដើម្បីផ្តល់ហិរញ្ញប្បទាន។ យោងតាម ILO កម្ពុជា ខ្វះប្រព័ន្ធសមាហរណកម្ម ឬកម្មវិធីប្រកបដោយនិរន្តភាពមួយដែលអាចឆ្លើយតបនឹងបញ្ហានេះនៅពេលដែលមានវិបត្តិផ្សេងទៀតកើតឡើង។ កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្ន មិនទាន់

*"អ្វីដែលសំខាន់ផងដែរនោះគឺថា វិធីដែលអាចទទួលបាន និងវាយតម្លៃពីលទ្ធផលសិក្សា គឺត្រូវធ្វើឡើងតាមលក្ខណៈបត់បែន ។"*

គ្រប់គ្រាន់នៅឡើយទេ ពោលគឺមានលក្ខណៈដាច់ដោយឡែក និងមិនមានការសហការគ្នា ហើយយើងត្រូវការកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីរៀបចំបណ្ដាញសុវត្ថិភាពសង្គមដែលអាចអនុវត្តបានប្រកបដោយនិរន្តភាពសម្រាប់រដ្ឋាភិបាលកម្ពុជា ។

## ៦.២ អន្តរាគមន៍រយៈពេលខ្លីដល់រយៈពេលវែង :

### *៦.២.១ ការបណ្តុះបណ្តាលវិជ្ជាជីវៈ*

បច្ចេកវិទ្យា និងបច្ចេកវិទ្យាព័ត៌មានកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ហើយទីផ្សារការងារត្រូវការកម្លាំងពលកម្មដែលមានសមត្ថភាពខ្ពស់ ។ ភាពជាដៃគូសាធារណៈ និងឯកជនខ្សោយ ជាពិសេសក្នុងចំណោមវិទ្យាស្ថាន TVET និងសាលារៀនមិនបានបង្កើតទំនាក់ទំនងជាមួយឧស្សាហកម្មផ្សេងៗ និងសាលារៀន និងមិនអាចផ្តល់ជំនាញពេញលេញដែលបុគ្គលិកត្រូវការនៅក្នុងទីផ្សារការងារនេះទេ ។ កង្វះប្រព័ន្ធព័ត៌មានអំពីទីផ្សារការងារធ្វើឱ្យភាគីពាក់ព័ន្ធមិនយល់ពីតម្រូវការរបស់ទីផ្សារការងារនេះ ។ ការកសាងសមត្ថភាពរបស់គ្រូបង្រៀន TVET នៅមានកម្រិត ហើយជំនាញមួយចំនួនពុំមានគ្រូបង្រៀន និងអ្នកត្រួតពិនិត្យណែនាំទេ ។ សម្ភារៈសិក្សាដែល TVET បានផ្តល់ឱ្យហួសសម័យ ហើយកម្មវិធីសិក្សាមិនមានលក្ខណៈបត់បែន ចំណែកឯវិទ្យាស្ថាន TVET វិញ ពឹងផ្អែកលើពេលវេលាលើគ្រូឧទ្ទេស និងលើសាលារៀន ។ ប្រជាពលរដ្ឋត្រូវមានលទ្ធភាពទទួលបានជំនាញ ចំណេះដឹង និងសមត្ថភាពនានាដែលពួកគេត្រូវការនៅក្នុងសេដ្ឋកិច្ចផ្អែកលើពុទ្ធិនាពេលបច្ចុប្បន្ន ។ ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើរតួនាទីសំខាន់មួយក្នុងការធានាថា ទីផ្សារការងារបើកទ្វារស្វាគមន៍ប្រជាពលរដ្ឋទាំងអស់ ។

អ្វីដែលសំខាន់ផងដែរនោះគឺថា វិធីដែលអាចទទួលបាន និងវាយតម្លៃពីលទ្ធផលសិក្សា គឺត្រូវធ្វើឡើងតាមលក្ខណៈបត់បែន ។ ការវាយតម្លៃនេះរួមមានតម្រូវការលើកកម្ពស់ការផ្តល់ TVET របស់និយោជក អ្នកផ្តល់សេវាបណ្តុះបណ្តាលដំបូងតាមលក្ខណៈប្រពៃណី និងវិទ្យាស្ថានអប់រំឧត្តមសិក្សាដែលស្ថាប័នទាំងអស់កំពុងជួយបញ្ជាក់ពីតម្លៃជំនាញដែលទទួលបានក្រៅពីការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាល ។ ទន្ទឹមនឹងនោះដែរដំណើរការរវាង TVET និងការអប់រំឧត្តមសិក្សាត្រូវបានបង្កើតឡើង ហើយកម្មវិធី TVET កម្រិតឧត្តសិក្សាគប្បីត្រូវរៀបចំឡើងផងដែរ ។ ការផ្លាស់ប្តូរពីការបណ្តុះបណ្តាលទៅការងារ ក៏ដូចជារវាងការងារ និងការងារ ក៏ត្រូវបានសម្របសម្រួលផងដែរដែលគប្បីត្រូវផ្តល់សេវាណែនាំ និងផ្តល់ប្រឹក្សា ។

ការលើកកម្ពស់គុណភាព ប្រសិទ្ធភាពអប់រំ បណ្តុះបណ្តាល ព្រមទាំងការលើកកម្ពស់ និងប្រសិទ្ធភាពរបស់គ្រូបង្រៀន គ្រូឧទ្ទេស គឺជាគន្លឹះសម្រាប់បង្កើនភាពពាក់ព័ន្ធរបស់ TVET សម្រាប់ទីផ្សារការងារ ។ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចាំបាច់ត្រូវមានប្រព័ន្ធ (១) ធានាគុណភាពដែលត្រូវអនុវត្តនៅថ្នាក់ជាតិតាមស្តង់ដារដែលបានព្រមព្រៀងជាលក្ខណៈអន្តរជាតិ (២) បន្តអភិវឌ្ឍជំនាញ និងសមត្ថភាពរបស់គ្រូបង្រៀន និងប្រព័ន្ធបណ្តុះបណ្តាលដោយវាយតម្លៃផ្អែកលើតួនាទីដែលកំពុងអភិវឌ្ឍន៍ជាបន្តបន្ទាប់របស់គ្រូបង្រៀន និងប្រព័ន្ធបណ្តុះបណ្តាលទាំងនោះ (៣) ពង្រឹងការអភិវឌ្ឍសមត្ថភាពសំខាន់ៗជាមួយនឹងជំនាញវិជ្ជាជីវៈដែលពាក់ព័ន្ធនឹងតម្រូវការទីផ្សារការងារនេះ ជាពិសេស តាមរូបភាពផ្សេងៗនៃការសិក្សាតាមរយៈការបំពេញការងារ និង (៤) ការបង្កើតឧបករណ៍ រៀបចំផែនការឱ្យត្រូវជំនាញ និងការងារ និងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធដើម្បីពង្រឹងភាពពាក់ព័ន្ធក្នុងទីផ្សារការងារ ។

ការបណ្តុះបណ្តាលវិជ្ជាជីវៈ គប្បីត្រូវផ្តោតលើមធ្យោបាយនានាដើម្បីលើកកម្ពស់សមភាព សម្ព័ន្ធភាពក្នុងសង្គមប្រជាពលរដ្ឋសកម្ម និងកំណើនរួម។ សិស្សដែលមានការចាញ់ប្រៀបអាចទទួលបានផលប្រយោជន៍កាន់តែច្រើនពីការសិក្សាមិនផ្អែកលើថ្នាក់រៀនដែលពាក់ព័ន្ធនឹងទីផ្សារពលកម្មរបស់ប្រទេស/តំបន់។ ដោយបានធ្វើសមាហរណកម្មបញ្ជ្រាបការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈការបណ្តុះបណ្តាលត្រូវមានលក្ខណៈបត់បែន និងជាគំរូដោយផ្តល់ដំណើរការសិក្សាផ្ទាល់។ ចល័តភាពសង្គមក៏ត្រូវបានលើកកម្ពស់ផងដែរតាមរយៈការសម្របសម្រួលការផ្លាស់ប្តូរពីការបណ្តុះបណ្តាលវិជ្ជាជីវៈទៅប្រព័ន្ធអប់រំឧត្តមសិក្សា ហើយសេវាណែនាំដែលអាចទទួលបាន និងដែលបានកំណត់គោលដៅត្រូវបានរៀបចំរួចជាស្រេច។

ការលើកកម្ពស់គំនិតច្នៃប្រឌិត នវានុវត្តន៍ គតភណ្ឌ និងសហគ្រិនភាពនៅក្នុងក្របខណ្ឌបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានសារៈសំខាន់ណាស់។ ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវផ្តល់ និងជួយអភិវឌ្ឍគំនិតច្នៃប្រឌិត និងលើកទឹកចិត្តដល់ការទទួលយកហានិភ័យ និងការធ្វើពិសោធ។ ការសិក្សាដែលអាចទទួលយកបានមានលក្ខណៈបត់បែនផ្អែកលើបទពិសោធ និងសកម្មគប្បីត្រូវបានផ្សព្វផ្សាយនៅកម្ពុជា។ ការអប់រំ និងសហគ្រិនភាពក៏គួរត្រូវផ្សព្វផ្សាយផងដែរដើម្បីណែនាំ គំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត និងសមត្ថភាពសម្រេចបាននូវទស្សនៈទាំងនេះ។ សហគ្រិនភាពក៏ត្រូវបង្កើតជាផ្នែកនៃប្រព័ន្ធសិក្សារបស់ស្ថាប័នដែលផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅក្នុងក្របខណ្ឌសមត្ថកិច្ចមួយ។

លើសពីនេះកិច្ចពិភាក្សា និងការសិក្សាពីគ្នាទៅវិញទៅមកគប្បីត្រូវអភិវឌ្ឍ និងផ្លាស់ប្តូរជាមួយនឹងសហគមន៍ អន្តរជាតិ តាមរយៈបណ្តាញបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងតំបន់ ហើយត្រូវមានកិច្ចសហប្រតិបត្តិការជារចនាសម្ព័ន្ធដែលមានទស្សនៈអភិវឌ្ឍ (១) កិច្ចសហការប្រតិបត្តិការណ៍ (២) ការអភិវឌ្ឍតំបន់ (៣) ការគ្រប់គ្រងចល័តភាពច្បាប់។ សហប្រតិបត្តិការក្នុងសកម្មភាពស្រាវជ្រាវ និងការបង្កើតគោលនយោបាយផ្អែកលើភស្តុតាងត្រូវបន្តលើកកម្ពស់ជាមួយអង្គការម្ចាស់ជំនួយអន្តរជាតិ។

ដោយសារវិស័យគោលដៅទាំងនេះ យើងត្រូវពិចារណាលើអន្តរាគមន៍គោលនយោបាយខាងក្រោមនេះ ៖

១. យុទ្ធសាស្ត្រដំបូងក្នុងការដោះស្រាយភាពខ្វះចន្លោះនាពេលបច្ចុប្បន្ន គឺត្រូវលើកកម្ពស់យន្តការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលមានស្រាប់។ គោលនយោបាយនេះពាក់ព័ន្ធនឹងការជំរុញក្រុមប្រឹក្សាជាតិបណ្តុះបណ្តាល (NTB) គណៈកម្មាធិការប្រឹក្សាបច្ចេកទេសឧស្សាហកម្ម (AITC) និងក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ខេត្ត (PTB) ឱ្យផ្តល់សកម្មភាពបន្ថែមដោយផ្តោតលើលទ្ធផលចាំបាច់ដើម្បីឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍ ឧស្សាហកម្មនាពេលបច្ចុប្បន្ននៅកម្ពុជា។ គោលនយោបាយនេះចាំបាច់ត្រូវអនុវត្តតាមរយៈសកម្មភាពនានាដែលមានគោលបំណងពង្រឹង និងពង្រីក PPPs ជាពិសេសស្ថាប័នផ្តល់ TVET និងផ្សារភ្ជាប់ស្ថាប័នទាំងនោះទៅនឹងឧស្សាហកម្មផ្សេងៗ តាមរយៈការបង្កើតក្រុមប្រឹក្សាផ្តល់យោបល់ និងការលើកកម្ពស់ទំនាក់ទំនងរវាងការិយាល័យ អង្គភាពអភិវឌ្ឍន៍កម្មវិធីសិក្សា និងសាស្ត្រាចារ្យដែលកំពុងបម្រើការជាមួយនឹងឧស្សាហកម្មទាំងនោះ។ ទីបំផុតយុទ្ធសាស្ត្រនេះនឹងរីកចម្រើនដើម្បីអភិវឌ្ឍសមត្ថភាពជំនាញជាតិ និងបទដ្ឋាននានាដែលនាំមុខដោយទីផ្សារការងារខ្លួនឯងតាមរយៈការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងអាស៊ាន។

២. យុទ្ធសាស្ត្រទីពីរ អាចពាក់ព័ន្ធនឹងការលើកកម្ពស់គុណភាពបង្រៀន TVET និងកម្មវិធីសិក្សា។ គោលនយោបាយនេះនឹងពាក់ពន្ធនឹងការផ្លាស់ប្តូរកម្មវិធីសិក្សាពីការផ្អែកលើពេលវេលា និងផ្អែកលើ

គ្រូឧទ្ទេសទៅជាការផ្អែកលើគំរូ និងផ្អែកលើសមត្ថភាព ឬការផ្តោតលើវិស័យជាក់លាក់។ កម្មវិធីសិក្សានេះពាក់ព័ន្ធនឹងកម្មវិធីអភិវឌ្ឍន៍ និងលើកកម្ពស់ដែលនឹងត្រូវអនុវត្តនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់តាមរយៈអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបច្ចេកទេសថ្មី ដែលមានជំនាញអនុវត្តជាក់ស្តែង និងចំណេះដឹងផ្នែកអភិវឌ្ឍ ពាណិជ្ជកម្ម ក៏ដូចជាចំណេះដឹងផ្នែកឧស្សាហកម្មដែលកំពុងបម្រើការងារផ្ទាល់ និងតម្រូវការរបស់ឧស្សាហកម្ម។ ការដាក់បញ្ចូលកម្មវិធីអាជីវកម្មខ្នាតតូចទៅក្នុងកម្មវិធីសិក្សារបស់ TVET ដោយមាននិស្សិតបញ្ចប់ការសិក្សាដែលមានជំនាញ និងចំណេះដឹងពីអាជីវកម្មខ្នាតតូចនេះច្បាស់លាស់អាចបន្តបំពេញបន្ថែមឱ្យកម្មវិធីនេះ។ TVET ក៏ត្រូវជំរុញដល់ការផ្សព្វផ្សាយកម្មវិធីផ្លាស់ប្តូរសម្រាប់ការចែករំលែកបទពិសោធ ដែលអាចលើកកម្ពស់គុណភាពពិនិត្យតាមដាន និងវាយតម្លៃ។

៣. យុទ្ធសាស្រ្តទីបី រួមមានការលើកកម្ពស់គុណភាពសេវាអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧបករណ៍ប្រើប្រាស់។ ការពង្រីកកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈអាចលើកកម្ពស់វិសាលភាពរបស់សិស្សដែលកំពុងទទួលការបណ្តុះបណ្តាលបច្ចេកទេស ហើយការកែលម្អ និងការបំពាក់ឧបករណ៍ប្រើប្រាស់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលដើម្បីផ្តល់សិក្ខាសាលាថ្មីដល់មជ្ឈមណ្ឌលទាំងនោះទៅតាមតម្រូវការទីផ្សារ ការងារ គឺជាអាទិភាពមួយ។

៤. អន្តរាគមន៍ទីបួន ត្រូវផ្តោតលើការលើកកម្ពស់សមត្ថភាពរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ដោយបង្កើតកម្មវិធីដែលប្រជាពលរដ្ឋមានលទ្ធភាពទទួលការបណ្តុះបណ្តាលទូទាំងប្រទេស។ ប្រព័ន្ធបណ្តុះបណ្តាលបែបនេះត្រូវបានអនុវត្តជាមួយនឹងគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមសមត្ថកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីផ្តល់វគ្គបណ្តុះបណ្តាលជំនាញដល់យុវជនបោះបង់ការសិក្សាពីកម្រិតអប់រំមធ្យមសិក្សាចំណេះទូទៅ។

៥. អន្តរាគមន៍ទី ៥ ផ្តោតលើការពង្រីកវិស័យឯកជន ឬស្ថាប័ន NGO ដែលផ្តល់សេវា TVET និងការធានាគុណភាពអប់រំ។ អន្តរាគមន៍នេះត្រូវបានដាក់បញ្ចូលជាមួយនឹងច្បាប់សម្រាប់ការចុះឈ្មោះគ្រូឧទ្ទេសវិស័យឯកជន (PSTs) ជាប្រព័ន្ធមួយនៃការគ្រប់គ្រងគុណភាពសេវាដែលបានផ្តល់ក្នុងកម្មវិធីបណ្តុះបណ្តាល។

៦. អន្តរាគមន៍ទី ៦ ត្រូវផ្តោតលើការពង្រីកកម្មវិធីមជ្ឈមណ្ឌលការងាររបស់អង្គការ ILO ដើម្បីផ្គូរផ្គងការបណ្តុះបណ្តាល និងតម្រូវការរបស់ឧស្សាហកម្ម។ គោលនយោបាយនេះអាចធ្វើឱ្យការបណ្តុះបណ្តាលស្របតាមតម្រូវការជំនាញរបស់សហគ្រាសទន្ទឹមនឹងនោះទីភ្នាក់ងារការងារជាតិរៀបចំខ្លួនរួចជាស្រេចធ្វើជាទីភ្នាក់ងារប្រតិបត្តិការពិសេសមួយ (SOA) ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាបណ្តុះបណ្តាលជាតិ។

៧. អន្តរាគមន៍ចុងក្រោយដើម្បីលើកកម្ពស់ TVET ត្រូវផ្តោតលើវិមជ្ឈការ និងមជ្ឈការនៃកម្មវិធី TVET ដោយបង្កើតក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ខេត្ត ដោយចាត់ទុកថាជាការពង្រីករបស់ក្រុមប្រឹក្សាជាតិបណ្តុះបណ្តាលដើម្បីវាយតម្លៃតម្រូវការជំនាញក្នុងស្រុក និងស្នើសុំការបណ្តុះបណ្តាលពី NTB។ វិទ្យាស្ថាន TVET ក៏ត្រូវបានលើកកម្ពស់ផងដែរដើម្បីវាយតម្លៃ និងឆ្លើយតបនឹងតម្រូវការរបស់ឧស្សាហកម្មក្នុងស្រុក និងតម្រូវការសហគមន៍។

*ប្រអប់ ៦.៣ លក្ខណៈនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការចូលរួមចំណែកនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងការកសាងមូលធនមនុស្សទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង*

យោងតាម UNESCO (ឆ្នាំ២០០៤) "[...] ចាប់តាំងពីគេចាត់ទុកថា ការអប់រំគឺជាគន្លឹះដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ត្រូវតែជាគន្លឹះសំខាន់ដែលអាចកាត់បន្ថយភាពក្រីក្រជំរុញឱ្យមានសន្តិភាព អភិរក្សបរិស្ថាន លើកកម្ពស់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋទាំងអស់ព្រមទាំងជួយឱ្យសម្រេចបានការអភិវឌ្ឍប្រកបដោយនិរន្តរភាព[៤០] [...]"។ជាក់ស្តែង អ្នកបង្កើតគោលនយោបាយអង្គការអភិវឌ្ឍន៍ និងសហគមន៍ម្ចាស់ជំនួយមានការយល់ដឹងច្បាស់ និងច្រើនចំពោះតួនាទីដ៏សំខាន់ដែល TVET អាចដើរតួក្នុងការអភិវឌ្ឍជាតិ និងលើកកម្ពស់មូលធនមនុស្សរបស់ប្រទេសមួយ។

សារៈសំខាន់របស់ TVET នាពេលបច្ចុប្បន្នត្រូវបានឆ្លុះបញ្ចាំងតាមរូបភាពផ្សេងគ្នាជាច្រើន ឧទាហរណ៍ការសហការរបស់ TVET ក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ឬក្នុងផែនការអភិវឌ្ឍន៍ជាតិ ដោយសារការតម្រង់ទិសរបស់ TVET សំដៅដល់ពិភពការងារដោយ TVET នេះ ផ្តោតពីកម្មវិធីសិក្សាដើម្បីទទួលបានជំនាញដែលអាចរកការងារធ្វើបាន។ TVET ត្រូវបានរៀបចំយ៉ាងល្អដើម្បីលើកកម្ពស់ជំនាញកម្លាំងពលកម្មដែលបង្កើតមាតិកាស្វែងរកទ្រព្យ និងចាកផុតពីភាពក្រីក្រ ហើយវិទ្យាស្ថាន TVET វិញ ក៏អាចផ្តល់ការបណ្តុះបណ្តាលជំនាញនៅកម្រិតជឿនលឿនខុសគ្នាផងដែរដើម្បីឆ្លើយតបនឹងតម្រូវការខុសគ្នារបស់សិស្សដែលមានប្រវត្តិសង្គមសេដ្ឋកិច្ច និងប្រវត្តិសិក្សាខុសគ្នា និងដើម្បីរៀបចំឱ្យសិស្សទាំងនោះមានការងារដែលទទួលបានប្រាក់កម្រៃខ្ពស់ និងប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។ ជាពិសេស យុវជន និងប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុតអាចទទួលបានផលប្រយោជន៍ក្រៅពី TVET នេះ។

ដោយសារលក្ខណៈបត់បែនរបស់វា ការសិក្សាតាមរយៈការផ្សព្វផ្សាយ TVET អាចជាអន្តរាគមន៍ទាំងរយៈពេលខ្លី និងរយៈពេលវែងសម្រាប់ប្រទេសមួយដើម្បីបំពេញភាពខ្វះចន្លោះផ្នែកជំនាញដែលនិយោជិតនាពេលបច្ចុប្បន្នត្រូវការជាបន្ទាន់ និងក្នុងរយៈពេលវែងដើម្បីផ្តល់ជូននិយោជិតទាំងនោះនូវមាតិកាដើម្បីលើកកម្ពស់ជំនាញរបស់ខ្លួនទទឹមនឹងនោះដែរផ្តល់ និងបំពេញបន្ថែមនូវជម្រើសអប់រំកម្រិតឧត្តមសិក្សា និងចម្ងល់ផ្សេងៗអំពីសមភាពដែលពាក់ព័ន្ធនឹងការអប់រំនោះ។ ដូច្នេះ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺជាមធ្យោបាយមួយនៃការផ្តល់អំណាចដល់បុគ្គលម្នាក់ៗដើម្បីគ្រប់គ្រងជីវិតរបស់ខ្លួន និងគប្បីត្រូវបានចាត់ទុកថាជាការបំពេញបន្ថែមដល់ប្រព័ន្ធអប់រំទូទៅ។ ជាក់ស្តែងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនកំពុងទទួលស្គាល់ការពិតដែលចំនួនប្រជាពលរដ្ឋក្មេងៗជាច្រើនឋិតនៅក្រៅប្រព័ន្ធអប់រំក្នុងប្រព័ន្ធ ហើយវិធីសាស្ត្រអប់រំក្រៅប្រព័ន្ធ និងកម្មវិធីអក្ខរកម្មកំពុងទទួលបានប្រយោជន៍ពីការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនេះ។

អ្វីដែលកាន់តែពិសេសជាងនេះទៀតនោះគឺ ការចូលរួមចំណែករបស់ TVET ក្នុងការលើកកម្ពស់មូលធនមនុស្សរួមមានការចូលរួមចំណែករយៈពេលខ្លី និងរយៈពេលវែងដោយ :

- ផ្តល់ជំនាញដល់បុគ្គលម្នាក់ៗដែលមិនទទួលនៅសាកលវិទ្យាល័យ
- ផ្តល់អំណាចដល់បុគ្គលម្នាក់ៗដោយពង្រីកលទ្ធភាព និងការចូលរួមជាមួយដោយផ្តោតលើក្រុមដែលពុំបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ទាំងយុវជន និងមនុស្សពេញវ័យ
- កាត់បន្ថយការបោះបង់ការសិក្សានៅកម្រិតអប់រំទាប និងចាត់ទុកថាជាមធ្យោបាយលើកកម្ពស់លទ្ធភាពរកការងារបានធ្វើ ឬការងាររយៈពេលវែង
- បន្ថែមលើបញ្ហានៃការសិក្សាពេញមួយជីវិតដោយធ្វើឱ្យកម្លាំងពលកម្មមានលក្ខណៈសមស្របនឹងតម្រូវការទីផ្សារ

៤០ ដកស្រង់ចេញពីការប្រកាសរបស់សិក្ខាកាមក្នុងកិច្ចប្រជុំ UNESCO ក្រុមអ្នកជំនាញ TVET ស្តីពី ការសិក្សាដើម្បីការងារ ប្រជាពលរដ្ឋ និងនិរន្តរភាព ៧វិនន ឆ្នាំ ២០០៤។

*"អ្នកបង្កើតគោលនយោបាយតាមប្រទេសស្ទើរតែទាំងអស់ឯកភាពគ្នាលើសារៈសំខាន់នៃការអប់រំ និងជំនាញ ដើម្បីធានាឱ្យមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅពេលអនាគត ។"*

- នាំមកនូវការចូលរួមចំណែកផ្សេងៗជាច្រើន ដែលរួមមានការក្លាយជាមធ្យោបាយមួយសម្រាប់កិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដោយសារវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍបច្ចេកវិទ្យា ថាមពល ពាណិជ្ជកម្ម ទេសចរណ៍ កសិកម្ម និងអភិបាលកិច្ចល្អ
- ពង្រឹងការងារដែលកំពុងធ្លាក់ចុះ ឬការងារដែលមិនឡើងប្រាក់ឈ្នួល ជាពិសេស នៅក្នុងវិស័យឧស្សាហកម្ម
- លើកកម្ពស់ជំនាញរបស់អ្នកដែលទទួលបានការអប់រំតិចតួច យុវជនគ្មានជំនាញ និងមិនមានការងារធ្វើ
- បំពេញភាពខ្វះចន្លោះដែលបណ្ដាលមកពីកត្តាភូមិសាស្ត្រ យេនឌ័រ និងវិសមភាពសេដ្ឋកិច្ច

ដើម្បីសម្រេចទស្សនវិស័យរយៈពេលខ្លីនិងរយៈពេលវែងរបស់TVET យើងចាំបាច់ត្រូវដោះស្រាយបញ្ហាយុទ្ធសាស្ត្រដែលរួមមាន (១) កែលម្អទស្សនៈមិនល្អចំពោះ TVET (២)បង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន (៣) បង្កើតទំនាក់ទំនងកាន់តែច្បាស់លាស់រវាងការអប់រំវិជ្ជាជីវៈ និងការអប់រំទូទៅដែលធ្វើឱ្យសិស្សយល់ថាការបណ្តុះបណ្តាលវិជ្ជាជីវៈមានលក្ខណៈអន់ជាងការអប់រំផ្សេងទៀត (៤) ទំនាក់ទំនងកាន់តែប្រសើររវាងTVET និងទីផ្សារ ការងារ ដោយមានទំនាក់ទំនងសេដ្ឋកិច្ចសង្គម (៥) ការសម្របសម្រួលកាន់តែប្រសើរនូវកម្មវិធី TVET និងចំណេះវិជ្ជាដែលទទួលបានពីការបណ្តុះបណ្តាលនេះ ។

លើសពីនេះ គោលបំណងជាយុទ្ធសាស្ត្រមួយចំនួនដែលរួមមានការផ្តល់ TVET ប្រកបដោយគុណភាព ដោយធានានូវលទ្ធភាពទទួលបានការងារធ្វើរបស់សិក្ខាកាមលើកកម្ពស់ភាពស៊ីសង្វាក់គ្នា និងការគ្រប់គ្រងការផ្តល់ការបណ្តុះបណ្តាលផ្សព្វផ្សាយទស្សនៈសិក្សាពេញមួយជីវិត និងលើកកម្ពស់ស្ថានភាព និងភាពទាក់ទាញរបស់កម្មវិធី TVET ក៏គប្បីត្រូវលើកឡើងផងដែរ ។

ជាក់ស្តែងលក្ខណៈបត់បែនរបស់ TVET ដែលមានវិសាលភាពរយៈពេលខ្លី និងរយៈពេលវែងតាមអ័ក្សដេក និងអ័ក្សឈរ លើកឡើងថា ការអនុវត្តយុទ្ធសាស្ត្រដើម្បីស្តារវិស័យអប់រំ និងការរួមចំណែកទាំងស្រុងក្នុងការកសាងជំនាញ និងការអភិវឌ្ឍមូលធនមនុស្សនៅក្នុងប្រទេសជាក់លាក់ណាមួយអាចទទួលបានជោគជ័យ ប្រសិនបើការអនុវត្តយុទ្ធសាស្ត្រនេះបានធ្វើសមាហរណកម្មសមស្របជាមួយក្របខណ្ឌគោលនយោបាយជាតិដោយមានគោលការណ៍ណែនាំអនុវត្តច្បាស់លាស់ និងតួនាទីគោលនយោបាយសម្រាប់អ្នកអនុវត្តយុទ្ធសាស្ត្រផ្សេងៗ ។

## ៦.៣. អន្តរាគមន៍រយៈពេលវែង

ផែនទីយុទ្ធសាស្ត្រដើម្បីលើកកម្ពស់មូលធនមនុស្សនៅកម្ពុជាចាំបាច់ត្រូវផ្តោតលើតុល្យភាពអន្តរាគមន៍រយៈពេលវែងរួមផ្សំជាមួយនឹងអន្តរាគមន៍រយៈពេលខ្លី ។

កាលពីពីរទសវត្សរ៍កន្លងទៅសារៈសំខាន់នៃមូលធនបញ្ញវន្ត បាននិងកំពុងកើនឡើងដោយសារការផ្លាស់ប្តូរជាសាកលឆ្ពោះទៅរកផលិតកម្មផ្អែកលើពុទ្ធិ ជាជាងផលិតកម្មផ្អែកលើកម្មន្តសាល ។ លោក Lynn (១៩៩៨)[៤១] បានអះអាងថា មានការប្រែប្រួលទាំងស្រុងមួយពីធនធាននិងសេដ្ឋកិច្ចផ្អែកលើផលិតកម្មទៅជាធនធាន និងសេដ្ឋកិច្ចដែលមានចំណេះដឹង និងសេវាដែលជាកត្តាជំរុញសំខាន់ចំពោះកំណើនសេដ្ឋកិច្ច ។ ចំណេះដឹងភាគច្រើននាពេលបច្ចុប្បន្នត្រូវបានបង្កើតឡើង តាមរយៈការវិនិយោគមូលធនមនុស្សដោយមាន

៤១ Lynn, B.E. ការគ្រប់គ្រងមូលធនបញ្ញវន្ត : បញ្ហា និងការអនុវត្ត : ការគ្រប់គ្រងសង្គមគណនេយ្យករប្រទេសកាណាដា ១៩៩៨ នៅ CEDEFOP/សហគមន៍អឺរ៉ុប Wilson និង Briscoe ផលប៉ះពាល់មូលធនមនុស្សមកលើកំណើនសេដ្ឋកិច្ច : ការវាយតម្លៃ ឆ្នាំ២០០៤ ។

ការអប់រំកម្រិតខ្ពស់ និងធនធានបណ្តុះបណ្តាល[៤២]។ ជាការពិតណាស់ ការរួមបញ្ចូលជាមួយនឹងកត្តានេះ គឺជាភស្តុតាងបង្ហាញពីផលប៉ះពាល់ជាវិជ្ជមានរបស់ការអប់រំ ការបណ្តុះបណ្តាល និងជំនាញមកលើការអនុវត្តរបស់បុគ្គលម្នាក់ៗ និងមកលើសេដ្ឋកិច្ចជាតិ។ លើសពីនេះការសិក្សាភាគច្រើន បង្ហាញថា មានកត្តាសំខាន់នៃឥទ្ធិពលនិងផលប៉ះពាល់ និងកត្តាខាងក្រៅ ដែលបណ្តាលមកពីកម្រិត មូលធនមនុស្សខ្ពស់។

ដូច្នេះ មូលធនបញ្ញវន្ត កាន់តែមានសារៈសំខាន់ថែមទៀតនៅក្នុងសេដ្ឋកិច្ចពិភពលោកដែលកំពុងផ្លាស់ប្តូរមួយនេះដើម្បីផ្តោតលើការអភិវឌ្ឍមូលធនមនុស្សរយៈពេលវែង ដែលមានកម្រិតខ្ពស់ជាងការអប់រំកម្រិតមូលដ្ឋានឆ្ពោះទៅរកផ្នែកជំនាញខ្ពស់ដែលទាមទាររយៈពេលវែងសម្រាប់ការអប់រំកម្រិតឧត្តមសិក្សាក្នុងប្រព័ន្ធ ក៏ដូចជា ការបណ្តុះបណ្តាល និងការអភិវឌ្ឍចំណេះដឹងជាបន្តតាមរយៈអាជីពរបស់បុគ្គលម្នាក់ៗ។ គោលដៅបែបនេះមិនអាចសម្រេចបានក្នុងរយៈពេលខ្លីទេ ឬអាចសម្រេចបានដោយពុំមានផែនការរយៈពេលវែងល្អិតល្អន់គិតគូរច្បាស់លាស់ និងទូលំទូលាយមួយដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំរបស់ជាតិមួយនោះទេ។

### *៦.៣.១ ការសិក្សាពេញមួយជីវិត និងការផ្លាស់ប្តូរទស្សនៈអប់រំឧត្តមសិក្សា*

អ្នកបង្កើតគោលនយោបាយតាមប្រទេសស្ទើរតែទាំងអស់ឯកភាពគ្នាលើសារៈសំខាន់នៃការអប់រំ និងជំនាញដើម្បីធានាឱ្យមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅពេលអនាគត។ ការសិក្សាជាច្រើនបង្ហាញថា ប្រទេសដែលមានការអប់រំ និងជំនាញកម្រិតខ្ពស់បំផុតជាមធ្យមមានផលិតភាព និងកំណើនសេដ្ឋកិច្ចកាន់តែខ្ពស់។ បញ្ហាអប់រំ និងផលប៉ះពាល់របស់វាមកលើកំណើនសេដ្ឋកិច្ចរយៈពេលវែង មានសារៈសំខាន់ចំពោះទស្សនៈសង្គមវិទ្យាសាស្ត្រចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ដោយមានសម្មតិកម្មសំខាន់បំផុតដែលការអប់រំនឹងប៉ះពាល់ជាវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ដោយសារការអប់រំបង្កើនកម្រិតជំនាញបញ្ញារបស់កម្លាំងពលកម្ម និងបង្កើនផលិតភាពរបស់ខ្លួនជាបន្តបន្ទាប់។

ការអប់រំឧត្តមសិក្សា ត្រូវបានទទួលស្គាល់ថាជាក្បាលម៉ាស៊ីនមួយសម្រាប់កំណើនសេដ្ឋកិច្ចជាតិ ហើយបទពិសោធអន្តរជាតិ បង្ហាញថាការអប់រំឧត្តមសិក្សាបានក្លាយជាអាទិភាពមួយក្នុងរបៀបវារៈសាធារណៈសម្រាប់ប្រទេសជាច្រើន។ ការអប់រំឧត្តមសិក្សាពិតជាមានអាទិភាពកាន់តែខ្លាំងបែបនេះមែនក្នុងបរិបទសាកលនាពេលបច្ចុប្បន្នដែលមានការអភិវឌ្ឍទាំងផ្នែកសង្គម និងបច្ចេកវិទ្យាក្នុងកម្រិតលឿនលឿនបំផុត ការអប់រំពាក់ព័ន្ធនឹងចំណុចដែលការសិក្សាមិនអាចកំណត់ ចំពោះតែបឋមវ័យនៃការអភិវឌ្ឍផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់បានទៀតទេ ពោលគឺធ្វើឱ្យមានចំណាប់អារម្មណ៍កាន់តែច្រើនចំពោះការសិក្សាពេញមួយជីវិត។ លើសពីនេះសកលភាវូបនីយកម្មសេដ្ឋកិច្ច និងវិប្បធម៌កាលពី ២០ឆ្នាំមុន បានបង្កើតទំព័រ សករាជថ្មីមួយសម្រាប់វិស័យអប់រំឧត្តមសិក្សាក្នុងការរៀបចំការគ្រប់គ្រង អភិបាលកិច្ច និងហិរញ្ញវត្ថុ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ គំរូស្រដៀងគ្នាជាច្រើនបានកើតឡើងនៅក្នុងប្រទេសនានាដែលមានប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចប្លែកៗពីគ្នាការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងបច្ចេកវិទ្យាក្នុងដំណាក់កាលខុសគ្នា និងការអនុវត្តការអប់រំឧត្តមសិក្សាខុសគ្នា។

ទោះបីជាយ៉ាងនេះក្តី វិស័យអប់រំឧត្តមសិក្សាបច្ចុប្បន្នកំពុងជួបប្រទះនឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុមួយចំនួនដែលជាលទ្ធផលនៃនិន្នាការតម្រូវការដែលកំពុងកើនឡើងយ៉ាងឆាប់រហ័សលើផ្នែកតែម្ខាង ហើយ

៤២ CEDEFOP/ សហគមន៍អឺរ៉ុប Wilson និង Briscoe ផលប៉ះពាល់មូលធនមនុស្សមកលើកំណើនសេដ្ឋកិច្ច: ការវាយតម្លៃ ឆ្នាំ២០០៤។

*“យើងចាំបាច់ត្រូវបង្កើតវដ្តសិក្សាពេញមួយជីវិតសម្រាប់កម្ពុជា។”*

អសមត្ថភាពរបស់រដ្ឋក្នុងការឆ្លើយតបនឹងធនធានសាធារណៈដែលត្រូវការសម្រាប់គ្រឹះស្ថានអប់រំឧត្តមសិក្សានៅផ្នែកម្ខាងទៀត។ ក្នុងបរិបទនេះដែរគ្រឹះស្ថានអប់រំឧត្តមសិក្សាកំពុងប្រឈមនឹងតម្រូវការដែលកំពុងកើតឡើងក្នុងការធានានូវមូលនិធិដែលទទួលបានពីប្រភពខុសគ្នា ហើយនិន្នាការអន្តរជាតិនេះហាក់ដូចជាបង្ហាញថាមធ្យោបាយសំខាន់ដើម្បីបំពេញភាពខ្វះចន្លោះនេះ គឺត្រូវផ្លាស់ប្តូរចំណាយសម្រាប់សិស្ស និងគ្រួសារ។ ប្រសិនបើប្រទេសជាច្រើនត្រូវបង្កើន និងអភិវឌ្ឍចំនួនមូលធនមនុស្សរបស់ខ្លួននោះការបន្តការគាំទ្ររបស់រដ្ឋាភិបាល (ទាំងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងក្នុងសម្រេចចិត្តលើគោលនយោបាយ) សម្រាប់គ្រឹះស្ថានអប់រំឧត្តមសិក្សា គឺជាកត្តាចាំបាច់។

### *៦.៣.២ ទស្សនៈរយៈពេលវែង*

យើងចាំបាច់ត្រូវបង្កើតវដ្តសិក្សាពេញមួយជីវិតសម្រាប់កម្ពុជា។ កត្តារួមផ្សំដែលចាំបាច់ រួមមានទស្សនវិស័យរយៈពេលវែង ការរៀបចំយុទ្ធសាស្ត្រជំនាញឧស្សាហកម្ម និងការរៀបចំប្រព័ន្ធដែលប្រទេសកម្ពុជាមានលទ្ធភាពដោះស្រាយបានចំពោះផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងវិបត្តិរបស់ខ្លួន។

ដូច្នេះ ទស្សនវិស័យរយៈពេលវែងត្រូវការថវិកា ការធានាគុណភាព រយៈពេលដំណើរការផែនការរយៈពេលវែង (១០ឆ្នាំ) ការបង្កើនអត្រាចុះឈ្មោះចូលរៀនការកាត់បន្ថយចំនួនសិស្សបោះបង់ការសិក្សា និងការកាត់បន្ថយភាពខ្វះចន្លោះដែលមានស្រាប់។ បទពិសោធជាអន្តរជាតិ បង្ហាញថាមានបញ្ហាពាក់ព័ន្ធចំនួន ៥ ចំពោះបញ្ហាប្រឈមទាំងនេះ :

១. **លទ្ធភាពចូលរៀន និងសមភាព :** ទស្សនៈនេះ រួមមាន ការលើកកម្ពស់ការពង្រីក និងការផ្សព្វផ្សាយរបស់វិទ្យាស្ថានការលើកឡើងពីវិធីដាក់បញ្ចូលចំនួនសិស្សជាច្រើនដែលមានប្រវត្តិសិក្សាខុសៗគ្នា ការបង្កើនអត្រាចុះឈ្មោះចូលរៀន និងអត្រាចូលរួម និងការបង្កើនចំនួន និងប្រភេទវិទ្យាស្ថានអប់រំ។ កត្តាជំរុញសំខាន់ៗដើម្បីសម្រេចបានទស្សនៈនេះ រួមមាន : ១) ការពង្រីកការអប់រំបឋមសិក្សា និងមធ្យមសិក្សាការបង្កើតតម្រូវការអប់រំ ឧត្តមសិក្សាឱ្យកាន់តែទូលំទូលាយថែមទៀត ២) តម្រូវការកាន់តែច្រើនពីទីផ្សារការងារដែលផ្អែកលើសេវាដែលកំពុងកើនឡើងយ៉ាងខ្លាំង រួមជាមួយនឹងដំណើរការនគរូបនីយកម្មដើម្បីឆ្លើយតបតម្រូវការរបស់ពិភពដ៏ជឿនលឿននេះ និង ៣) បង្កើនការលើកទឹកចិត្តពីរដ្ឋាភិបាលដើម្បីផ្តល់លទ្ធភាពស្មើគ្នាដល់សិស្សឱ្យទទួលបានការអប់រំកម្រិតឧត្តមសិក្សា។

២. **ហិរញ្ញប្បទាន :** ការធ្វើកំណែទម្រង់អភិបាលកិច្ចសារពើពន្ធរបស់វិទ្យាស្ថានអប់រំឧត្តមសិក្សា គឺជាកត្តាសំខាន់មួយដើម្បីធានាដល់ការផ្តល់មូលនិធិគ្រប់គ្រាន់តាមរយៈប្រភពធនធានដ៏សម្បូរបែប និងធ្វើឱ្យសិស្សដែលមកពីគ្រួសារក្រីក្រ មានលទ្ធភាពចូលរៀនកាន់តែច្រើននៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ជាក់ស្តែងលទ្ធភាពបង់ថ្លៃសាលា និងចំណាយផ្សេងៗ គឺជាបញ្ហាសំខាន់មួយចំពោះសិស្សជាច្រើន ហើយបញ្ហានេះ ត្រូវដោះស្រាយដោយប្រុងប្រយ័ត្ន ជាពិសេស ការចំណាយលើការអប់រំកម្រិតឧត្តមសិក្សាកំពុងកើនឡើងច្រើនជាងការចំណាយលើសេដ្ឋកិច្ចទូទៅដែលជានិន្នាការមួយកើនឡើងដោយសារកំណើនចំណាយខ្ពស់លើផ្នែកបច្ចេកវិទ្យា។

៣. **គណនេយ្យភាព ៖** គណនេយ្យភាពនេះ បង្ហាញពីការបង្កើតរចនាសម្ព័ន្ធផ្ទៃក្នុងកាន់តែប្រសើរដើម្បីផ្ដល់សេវាគ្រប់គ្រងដែលបានកែលម្អ និងការឆ្លើយតបនឹងតម្រូវការគណនេយ្យភាពកាន់តែប្រសើរពីវិទ្យាស្ថាន និងមហាវិទ្យាល័យ ចំពោះសិស្ស និយោជក និងអ្នកជាប់ពន្ធ។ នេះគឺដោយសារមានទស្សនៈរួមមួយដែលថាគ្រឹះស្ថានឧត្តមសិក្សាមានលទ្ធភាពទទួលខុសត្រូវមិនគ្រប់គ្រាន់ចំពោះសិស្ស និងរដ្ឋាភិបាល។

៤. **ការស្រាវជ្រាវ និងភាពពាក់ព័ន្ធ ៖** ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវរបស់វិទ្យាស្ថានអប់រំឧត្តមសិក្សាតាមរយៈការលើកកម្ពស់សមត្ថភាព និងវត្តមាននៅក្នុងពិភពមួយដែលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការប្រកួតប្រជែងជាអន្តរជាតិកំពុងតែដើរតួនាទីកាន់តែសំខាន់ក្នុងចក្ខុវិស័យសេដ្ឋកិច្ចនាពេលអនាគតរបស់ប្រទេសមួយក្នុងចំណោម ប្រទេសផ្សេងទៀតការស្រាវជ្រាវនេះ មានន័យថាការឆ្លើយតបនឹងបញ្ហាប្រឈមជាអន្តរជាតិ និងការបញ្ជ្រាបទស្សនៈសិក្សាពេលមួយជីវិតដើម្បីបង្កើនគុណភាពកម្លាំងពលកម្មនាពេលអនាគតឱ្យសមស្របទៅនឹងដំណោះស្រាយ និងការតម្រង់ទិសរបស់ទីផ្សារសកលភាវូបនីយកម្មមួយ។

៥. **គុណភាព និងប្រសិទ្ធភាព ៖** ផ្នែកនេះពាក់ព័ន្ធនឹងការវាយតម្លៃ និងការធ្វើកំណែទម្រង់កម្មវិធីសិក្សានិងការរៀបចំវគ្គសិក្សា និងកម្មវិធីសិក្សាឱ្យកាន់តែស្របទៅនឹងពិភពការងារទំនើប។ កិច្ចការនេះផ្ដោតលើកត្តាសំខាន់នៃការគ្រប់គ្រងបញ្ហាដែលបានលើកឡើងលើផ្នែកគុណភាព និងអត្តចរិតរបស់បុគ្គលិកបង្រៀន ឬកម្មវិធីសិក្សាមិនសមស្របដែលអាចមិនទាក់ទងនឹងតម្រូវការរបស់សេដ្ឋកិច្ចជាក់ស្ដែង។ លើសពីនេះ ប្រការសំខាន់នោះ គឺត្រូវលើកកម្ពស់គុណភាពអគារសិក្សាបណ្ណាល័យ កុំព្យូទ័រ និងសម្ភារៈផ្សេងៗ។

ដូច្នេះ ដើម្បីធ្វើកិច្ចការនេះសម្រាប់កម្ពុជាក្របខណ្ឌស្ថាប័ន ឬធាតុផ្សំសម្រាប់ទស្សនវិស័យមូលធនមនុស្សដ៏ទូលំទូលាយមួយដែលកម្ពុជាត្រូវការ ៖

*ប្រអប់ ៦.៤ ដើម្បីលើកកម្ពស់មូលធនមនុស្សនៅកម្ពុជា យើងត្រូវការយុទ្ធសាស្ត្ររយៈពេលវែងដែលមានធាតុផ្សំរយៈពេលខ្លី*

ការសម្របសម្រួលរបស់រដ្ឋាភិបាលតាមក្រសួងផ្សេងៗ :

ចាំបាច់ត្រូវស្វែងយល់ពីការអនុវត្តអភិបាលកិច្ចល្អសម្រាប់ការសម្របសម្រួល និងការផ្តល់ផែនទីបង្ហាញផ្លូវដល់ស្ថាប័ននូវការបែងចែកតួនាទី និងភារកិច្ចក្នុងការរៀបចំ ការគ្រប់គ្រង និងការអនុវត្ត ។ ការស្វែងយល់ពីយន្តការសម្របសម្រួលសំខាន់ៗ និងកង្វះសមត្ថភាព គឺជាកត្តាសំខាន់រួមជាមួយនឹងការវាយតម្លៃពីអត្ថប្រយោជន៍ និងផលវិបាករបស់យន្តការអភិបាលកិច្ចដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីកាត់បន្ថយភាពខ្វះចន្លោះទាំងនេះ ។

ការសម្របសម្រួលជាមួយក្រសួងហិរញ្ញវត្ថុសម្រាប់ការផ្តល់ថវិកាចំណាយដល់វិស័យអប់រំ :

ដើម្បីរក្សាដំណើរការមួយដែលអាចលើកកម្ពស់ប្រព័ន្ធអប់រំកម្រិតឧត្តមសិក្សាប្រទេសនេះ ចាំបាច់ត្រូវមានដំណើរការមួយដើម្បីរៀបចំផែនការជាមុនសម្រាប់រយៈពេល ១០ឆ្នាំ និងផ្តល់ការសន្យាផ្នែកហិរញ្ញវត្ថុដែលអាចគាំទ្រដល់ដំណើរការនេះ ។ នេះសំដៅដល់ការសន្យាយ៉ាងមុតមាំពីក្រសួងហិរញ្ញវត្ថុក្នុងការរៀបចំផែនការ និងការរៀបចំថវិកាសម្រាប់រយៈពេល ១០ឆ្នាំនេះ ។ ប៉ុន្តែ អ្វីដែលមន្ត្រីវិស័យអប់រំអាចធ្វើបានពោលគឺក្នុងបរិបទដែលមន្ត្រីអប់រំទាំងនោះកំពុងធ្វើ គឺតែងតែហួសពីសមត្ថភាពដែលពួកគេមាន ។ ក្នុងសម័យកាលដែលមានការស្រេកឃ្លានចំណេះវិជ្ជាយ៉ាងខ្លាំងនេះ ការផ្តល់ហិរញ្ញប្បទានទាំងស្រុងលើការអប់រំកម្រិតឧត្តមសិក្សា គឺមានតម្លៃថ្លៃគ្រប់កន្លែងនៅក្នុងពិភពលោក ។ មានការប្រកួតប្រជែងជាច្រើនការចំណាយរបស់រដ្ឋាភិបាលភ្លាមៗ និងការកាត់បន្ថយថវិកាដែលពាក់ព័ន្ធនឹងពន្ធរួមមានន័យថា ជាជម្រើសមិនល្អ ។

ការសម្របសម្រួលជាមួយស្ថាប័នកម្ពុជា និងស្ថាប័នផ្សេងទៀតទូទាំងអាស៊ី (ឧ. ផ្នែកនៃទីផ្សារអាស៊ានកាន់តែទូលំទូលាយមួយ) :

ប្រទេសជាច្រើននៅតំបន់អាស៊ី និងប៉ាស៊ីភិច ត្រូវប្រឈមនឹងបញ្ហាដែលកំពុងកើនឡើងមួយដើម្បីឆ្លើយតបនឹងជំនាញដែលកម្លាំងពលកម្មរបស់ខ្លួនត្រូវការនៅក្នុងពិភពភាវូបនីយកម្ម និងប្រកួតប្រជែងខាងបច្ចេកវិទ្យាដែលកំពុងរីកចម្រើនយ៉ាងខ្លាំងនេះ ។ យុទ្ធសាស្ត្រជំនាញជាតិត្រូវឆ្លើយតប និងគាំទ្រដល់កំណើនសេដ្ឋកិច្ច និងការងារហើយគួរតែឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋងាយរងគ្រោះបំផុតផងដែរ ។ កម្ពុជាក៏គួរតែផ្តោតលើការធ្វើសមាហរណកម្មជាមួយចលនាអាស៊ានរបស់កម្មករជំនាញនៅត្រឹម ឆ្នាំ២០១៥ ដោយធានាបាននូវសុខដុមនីយកម្មនៃស្តង់ដារផ្អែកលើសមត្ថភាព ។[៤៣]

ភាពជោគជ័យ ឬបរាជ័យសម្រាប់កម្ពុជាបន្ទាប់ពីកម្ពុជាបានចូលជាសមាជិករបស់អង្គការ WTO នៅឆ្នាំ២០០៤ នឹងអាស្រ័យលើថាតើកម្ពុជាមានលទ្ធភាពដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ការសមត្ថភាពប្រកួតប្រជែងពាណិជ្ជកម្មអន្តរជាតិរបស់ខ្លួន និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានក្នុងការចូលជាសមាជិករបស់ WTO នេះដោយរបៀបណា ជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រ ។ បញ្ហាជាច្រើនមានពាក់ព័ន្ធនឹងអភិបាលកិច្ចដែលកន្លងមកជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា (ឧ. អំពើពុករលួយ) ដែលរារាំងដល់ការបង្កើតការងារ និងកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះការចូលជាសមាជិករបស់អង្គការ WTO បង្ហាញពីការលើកកម្ពស់ផលិតកម្មជាតិ និងសមត្ថភាពប្រកួតប្រជែងព្រមទាំងពាណិជ្ជកម្មអនុតំបន់ទន្ទឹមនឹងនោះដែរបង្ហាញពីការទទួលស្គាល់ពីតម្រូវការដើម្បីបង្កើនល្បឿនកំណែទម្រង់ក្របខណ្ឌច្បាប់ និងតុលាការដើម្បីឱ្យវិស័យឯកជនអាចប្រតិបត្តិការក្រោមច្បាប់ទីផ្សារកាន់តែច្បាស់លាស់ថែមទៀត ។

៤៣ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ILO សិក្ខាសាលាបច្ចេកទេសជាតិស្តីពីការអភិវឌ្ឍជំនាញ TVET ពាក់ព័ន្ធនឹងការងារ ឆ្នាំ២០១០ ។

## ៦.៤ ផែនទីយុទ្ធសាស្ត្រស្ដីពីមូលធនមនុស្សនៅកម្ពុជា

កម្ពុជាត្រូវបានទទួលស្គាល់ច្រើនដែលក្រៅពីប្រវត្តិនៃជម្លោះផ្ទៃក្នុង និងអស្ថិរភាពសេដ្ឋកិច្ចនយោបាយ។ ព្រឹត្តិការណ៍ដែលកម្ពុជាបានឆ្លងកាត់ទាំងនេះ បានជំរុញឱ្យប្រទេសផ្សេងទៀតជាច្រើនធ្លាក់ចូលក្នុងស្ថានភាពដុនដាបតាមស្ថាប័នរយៈពេលយូរមួយ និងបំផ្លាញដល់សេដ្ឋកិច្ចជាតិមិនបានរារាំងដល់សមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការដាក់បញ្ចូលប្រព័ន្ធនយោបាយថ្មីមួយនៃលិទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោតដើម្បីបង្ហាញពីកំណើនខ្ពស់បំផុតក្នុងរយៈពេលមួយ និងបានបង្កើនលទ្ធផលអភិវឌ្ឍន៍មនុស្សរបស់ខ្លួនយ៉ាងខ្លាំង។

ក្រៅពីមូលដ្ឋានសេដ្ឋកិច្ចទាបមួយដែលជាផ្នែកជាក់លាក់នៃការពន្យល់នេះ ដូចជាសន្តិភាពតែមួយគត់ដែលទទួលបាននៅចុងរបបខ្មែរក្រហមមិនមែនជារឿងរ៉ាវទាំងស្រុងនោះទេ។ កត្តាបែបនេះមិនអាចរៀបរាប់អំពីមូលហេតុដែលប្រទេសមួយចំនួនអាចចាប់ផ្តើមផ្លាស់ប្តូររចនាសម្ព័ន្ធដ៏ធំ និងបង្កើតសមត្ថភាពវិស័យឧស្សាហកម្ម និងសេវាកម្មថ្មីខណៈដែលប្រទេសផ្សេងទៀតគ្រាន់តែធ្វើដំណើរត្រលប់ទៅរកកម្រិតកំណើនកសិកម្មនាពេលកន្លងមកតែប៉ុណ្ណោះ ដូច្នេះហើយទើបកម្ពុជាមិនបានទទួល ទទួលស្គាល់ពេញលេញ។

កម្ពុជាមិនត្រឹមតែមិនទាន់បានធូរស្រាលពីជម្លោះសង្គម និងការសម្លាប់រង្គាលប៉ុណ្ណោះទេ ថែមទាំងបានអនុវត្តការផ្លាស់ប្តូរស្ថាប័នលក់ដុំដែលបានបង្កើតប្រភពកំណើនដ៏ថ្មីស្រលាង និងការងារជាច្រើន ដូចជាការបង្កើតការងារឱ្យស្ត្រីជាច្រើននាក់ ការចាកចេញពីប្រព័ន្ធសេដ្ឋកិច្ចផែនការមជ្ឈមទៅជាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីមួយ ដោយមិនរារែកក្នុងការទំនាក់ទំនងអង្គការ និងទីភ្នាក់ងារអន្តរជាតិ និងអន្តរតំបន់ (ដូចជាអាស៊ាន) និងការបង្កើតប្រព័ន្ធពិភាក្សាជាប្រចាំផ្លូវការមួយជាមួយវិស័យឯកជន។ កម្ពុជាក៏ត្រូវប្រយុទ្ធប្រឆាំងនឹងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរពីវិបត្តិសេដ្ឋកិច្ចដ៏ធំចំនួនពីរដងដែរដែលលើកទីមួយ ក្រោមរូបភាពវិបត្តិសេដ្ឋកិច្ចអាស៊ីនៅក្នុងប្រទេសជិតខាងរបស់ខ្លួន និងទីពីរ គឺវិបត្តិសេដ្ឋកិច្ចពិភពលោកដែលបានបង្កឡើងដោយវិបត្តិបំណុលអចលនទ្រព្យរបស់អាមេរិក។ វិបត្តិនេះក៏ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់កម្ពុជាផងដែរដែលកម្ពុជាបានចូលជាសមាជិកអាស៊ានមិនចំកាលៈទេសៈល្អតែចំពេលដែលអាស៊ានជួបនឹងវិបត្តិដ៏អាក្រក់នេះ។ វាស្មើនឹងកេរ្តិ៍ឈ្មោះរបស់កម្ពុជាដែលការដួលរលំមួយផ្នែករបស់ឧស្សាហកម្មនាំចេញសំខាន់របស់កម្ពុជា ហើយនិយោជិតឧស្សាហកម្មមិនបានបញ្ចុះបញ្ចូលកម្ពុជាឱ្យចូលទៅក្នុងដំណើរការពារ ឬការជាប់គាំងផ្នែកគោលនយោបាយនោះទេ។ ផ្ទុយទៅវិញកម្ពុជាបានបង្កើនការចូលរួមរបស់ខ្លួនជាមួយវិស័យឯកជន ព្រមទាំងបានអញ្ជើញអង្គការផ្តល់ជំនួយឱ្យសហការជាមួយខ្លួនលើផ្នែកស្មុគស្មាញ ជាច្រើននៃគោលនយោបាយសេដ្ឋកិច្ចចាប់ពីប្រសិទ្ធភាពជំនួយដល់ភាពប្រកួតប្រជែងជាអន្តរជាតិ បរិយាកាសវិនិយោគ ទីផ្សារការងារ និងតម្រូវការមូលធនមនុស្ស។

ជាក់ស្តែងទោះបីជានៅពេលមានវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរក៏ដោយក៏កម្ពុជា បានប្រកាន់ខ្ជាប់នូវយុទ្ធសាស្ត្រចតុកោណរបស់ខ្លួនដែរដោយគូសបញ្ជាក់ពីទំនាក់ទំនងទៅវិញទៅមកជាច្រើនដែលមានជាប់ជាមួយនឹងយុទ្ធសាស្ត្រនេះរវាងកំណើនសេដ្ឋកិច្ច អភិបាលកិច្ច និងសុខុមាលភាពសង្គម។ ទីភ្នាក់ងារគោលនយោបាយសំខាន់របស់កម្ពុជា SNEC មានជាប់ពាក់ព័ន្ធនឹងបញ្ហារចនាសម្ព័ន្ធផលិតកម្មនាពេលអនាគត និងកំណើនសេដ្ឋកិច្ច ធនធានរូបវ័ន្ត និងមូលធនមនុស្សដែលត្រូវការដើម្បីសម្រេចតាមយុទ្ធសាស្ត្រនេះព្រមទាំងជម្រើសជំនួយអន្តរជាតិ និងឥណទានទ្វេរភាគីដែលអាចជួយបង្កើនផលធៀបប្រាក់សន្សំក្នុងស្រុក និង GDP។ របៀបវារៈគោលនយោបាយនេះនៅមិនទាន់បានផ្តល់ដល់សមត្ថកិច្ចដោះស្រាយដែលទទួលបានពីម្ចាស់ជំនួយអន្តរជាតិ

និងសង្គមស៊ីវិលដែលមានជម្រើសសេវាស៊ីវិលច្រើនលើសលុបរវាងបេសកម្មរបស់ម្ចាស់ជំនួយម្នាក់ និងម្ចាស់ជំនួយផ្សេងទៀតនៅឡើយទេ[៤៤]។

ប្រការចាំបាច់ត្រូវចាំថានៅពេលដែលកំណើនសេដ្ឋកិច្ចនាពេលអនាគតមិនទំនងជាកើតឡើងដូចកំណើនសេដ្ឋកិច្ចនាពេលកន្លងមកនោះ ដូចដែលមានការពិនិត្យយ៉ាងល្អិតល្អន់លើរបាយការណ៍វិភាគកំណើនសេដ្ឋកិច្ចរបស់ធនាគារពិភពលោក ហើយបញ្ជាក់នៅក្នុងរបាយការណ៍នេះតែទស្សនៈវិស័យហាក់ដូចជា មិនអាក្រក់ដូចអ្វីដែលលេចចេញពីការដកស្រង់ចេញពីទិន្នន័យសេដ្ឋកិច្ចពិភពលោកការអង្កេតស្ដីពីភាពប្រកួតប្រជែង ឬគុណភាពនៃការវិនិយោគពីបរទេសផ្ទាល់ និងសភាពងាយរុះរើរបស់ឧស្សាហកម្មកាត់ដេរអន្ដរជាតិនោះទេ។

មានហេតុផលជាច្រើនសម្រាប់ទស្សនៈសុទិដ្ឋិនិយមចំពោះអនាគតសេដ្ឋកិច្ចរបស់កម្ពុជា។ ដូចបានពិភាក្សាអំពី បញ្ហានេះខាងលើរួមមកហើយកម្ពុជាមិនដូចប្រទេសកំពុងអភិវឌ្ឍដែលមានប្រាក់ចំណូលទាបដ៏ទៃទៀតទេ កម្ពុជាបានប្រើប្រាស់ប្រព័ន្ធនយោបាយប្រកបដោយស្ថិរភាពមួយ ដោយបើកឱ្យពាណិជ្ជកម្មឯកជនចូលមក និងចាកចេញពីទីផ្សារ។ កម្ពុជាបានឆ្លងកាត់វិបត្តិដែលបង្កឡើងដោយវិបត្តិសេដ្ឋកិច្ចអាស៊ីនៅឆ្នាំ ១៩៩៧,៩៨ ដោយជោគជ័យ ហើយបានចរចា ចូលជាសមាជិកអាស៊ាននៅពេលដែលអាស៊ានមានបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរ។ កម្ពុជាបានរៀបចំកត្តាជំរុញសារពើពន្ធសំខាន់មួយ ខណៈកម្ពុជាកំពុងរក្សាអាទិភាពសារពើពន្ធដើម្បីកាត់បន្ថយផលប៉ះពាល់វិបត្តិសេដ្ឋកិច្ចនាពេលកន្លងទៅថ្មីៗនេះមកលើសង្គម។ ហើយកម្ពុជាពិតជាបានព្យាយាមពិភាក្សាជាមួយវិស័យឯកជនក្នុងស្រុក និងអន្ដរជាតិស្វែងរកមធ្យោបាយល្អបំផុតដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែងថ្នាក់អន្ដរជាតិ។

លើសពីនេះ (អានឧបសម្ព័ន្ធក្នុងប្រអប់ ក.៨) កម្ពុជាកំពុងបង្កើនការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចអាស៊ីថ្នាក់តំបន់ដោយផ្លាស់ប្ដូរលំនាំពាណិជ្ជកម្ម វិនិយោគ និងទិសដៅទេសចរណ៍។ កម្ពុជាបានរក្សាកំណែទម្រង់អភិបាលកិច្ចក្នុងរបៀបវារៈ នយោបាយរួមមានការលុបបំបាត់អំពើពុករលួយ។ លើសពីនេះជោគជ័យរបស់ប្រទេសជាច្រើនដែលនៅជិតខាងកម្ពុជា រួមមាន វៀតណាម ចិន ឥណ្ឌា និងឥណ្ឌូនេស៊ីនាពេលបច្ចុប្បន្នបានផ្ដល់បទពិសោធជាការអនុវត្តល្អៗជាច្រើន ដែលអាចឱ្យកម្ពុជាយកឈ្នះប្រទេសកំពុងអភិវឌ្ឍផ្សេងទៀតជាច្រើន ដើម្បីទទួលបានសេដ្ឋកិច្ចដែលមានគំនិតកែច្នៃរឹងមាំមានបច្ចេកវិទ្យាជឿនលឿន និងផ្អែកលើពុទ្ធិ។

## ៦.៤.១ ពិពិធកម្មសេដ្ឋកិច្ច ឧត្តមភាពប្រកួតប្រជែង និងមូលធនមនុស្ស

រាជរដ្ឋាភិបាលកម្ពុជា បានទុកពិពិធកម្មឧស្សាហកម្មជាអាទិភាពខ្ពស់បំផុត ដោយចាត់ទុកថាជាផ្នែកនៃការសិក្សាសំខាន់ពីវិបត្តិសេដ្ឋកិច្ចនាពេលកន្លងទៅថ្មីៗនេះ។ ប្រសិនបើយើងយកកម្មវិធីបែបនេះមកអនុវត្តវាមិនត្រឹមតែត្រូវការការវិនិយោគមូលធនរូបវ័ន្តតែប៉ុណ្ណោះទេ ថែមទាំងត្រូវការការវិនិយោគច្រើនលើការបង្កើតមូលធនមនុស្សទៀតផង។ ដោយសារការវិនិយោគក្នុងវិស័យជាច្រើនរបស់សហគ្រាស ការអភិវឌ្ឍមូលធនមនុស្សទាក់ទងនឹងរយៈពេលអភិវឌ្ឍវែងជាងមូលធនរូបវ័ន្ត។ រដ្ឋាភិបាលកម្ពុជាកំពុងប្រឈមនឹងការលំបាកក្នុងការសម្រេចចិត្ត ថាតើត្រូវរៀបចំផែនការពិពិធកម្មឧស្សាហកម្មមួយនាពេលអនាគតដោយ

៤៤ ដូចជា ករណីរបស់ប្រទេសសេដ្ឋកិច្ចខ្លាមួយចំនួនក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ី។ ប្រទេសឥណ្ឌូនេស៊ី បានរងផលប៉ះពាល់ពីវិបត្តិនេះធ្ងន់ធ្ងរជាងគេ ដោយសារការដួលរលំផ្នែកនយោបាយ និងការដួលរលំសេដ្ឋកិច្ច។

របៀបណា ថាតើជាបឋមរដ្ឋាភិបាលគួរតែស្វែងយល់ពីឧស្សាហកម្មដើម្បីកំណើននាពេលអនាគតដោយផ្អែកលើចំនួនមូលធនមនុស្សដែលបានកំណត់ និងមានស្រាប់ ឬជ្រើសរើសវិស័យឧស្សាហកម្មដែលផ្អែកលើទិន្នាការសេដ្ឋកិច្ចពិភពលោក និងបច្ចេកវិទ្យា ឬផ្លាស់ប្តូរលំនាំនៃការធ្វើសមាហរណកម្មថ្នាក់តំបន់ ហើយបន្ទាប់មកស្វែងរកមធ្យោបាយដែលមានប្រសិទ្ធភាពបំផុតក្នុងការឆ្លើយតបនឹងតម្រូវការមូលធនមនុស្សរបស់ឧស្សាហកម្មថ្មីៗ ។

ការលំបាកមួយទៀតក្នុងការសម្រេចចិត្តគឺ ថាតើត្រូវបង្កើតគោលនយោបាយឧស្សាហកម្មមួយ ឬត្រូវផ្តោតលើ ការលើកកម្ពស់បរិយាកាសវិនិយោគ និងកាត់បន្ថយចំណាយធ្វើពាណិជ្ជកម្មវិញដើម្បីក្លាយជាគោលដៅដ៏ល្អមួយសម្រាប់ FDI និងការវិនិយោគក្នុងស្រុកបន្ថែមនាពេលអនាគត ។ ដូចបានពិភាក្សានៅក្នុងជំពូកទីមួយក្នុងរបាយការណ៍នេះរួចមកហើយតួនាទីរបស់រដ្ឋក្នុងការគ្រប់គ្រងសេដ្ឋកិច្ចក៏ដូចជាកម្រិតដែលរដ្ឋអាចកំណត់នូវមាគ៌ាអភិវឌ្ឍរបស់ខ្លួនបានដោយជោគជ័យ គឺនៅតែជាបញ្ហាសម្រាប់ការជជែកដេញដោលខ្លាំងនៅឡើយ ។ ជាក់ស្តែងនោះ គឺថាប្រទេសអភិវឌ្ឍស្ទើរតែទាំងអស់ក៏ដូចជាប្រទេសនៅអាស៊ីដែលទទួលបានជោគជ័យទាំងអស់បានប្រើប្រាស់ការដឹកនាំសេដ្ឋកិច្ចរបស់រដ្ឋ ដើម្បីបង្កើតទស្សនវិស័យអភិវឌ្ឍន៍ និងឧស្សាហកម្មពិសេសដែលបានកំណត់សម្រាប់ជួយដល់សេដ្ឋកិច្ចពិសេស និងសារពើពន្ធ ។ ឧទាហរណ៍ ប្រទេសកូរ៉េ បង្ហាញជាពិសេសនូវលទ្ធផលដ៏ធំធេងរបស់រដ្ឋ និងវិស័យឯកជនដែលកំពុងសហការគ្នាដើម្បីបង្កើតលំនាំឧត្តមភាពប្រៀបធៀបថ្មីៗ ដែលមានលក្ខណៈខុសប្លែកពីអ្វីដែលមានពីមុនមក ។

យ៉ាងណាមិញ អ្វីដែលជាក់ស្តែងបំផុតនោះគឺ ការជជែកដេញដោលពីការអភិវឌ្ឍបានធ្វើឡើងពីការពិភាក្សារបស់ រដ្ឋធំ/រដ្ឋតូច ឬពីតម្រូវការជ្រើសរើសអ្នកទទួលបានជោគជ័យផ្នែកឧស្សាហកម្ម ឬការលើកកម្ពស់ FDI ដោយផ្ទាល់ តាមរយៈការអភិវឌ្ឍបរិយាកាសវិនិយោគ ។ កាលពី១៥ឆ្នាំមុនកិច្ចព្រមព្រៀងអភិវឌ្ឍន៍ថ្មីមួយត្រូវបានបង្កើតឡើង ពោលគឺ កិច្ចព្រមព្រៀងមួយដែលផ្អែកលើសារៈសំខាន់ចាំបាច់នៃសេដ្ឋកិច្ចពុទ្ធិដែលវិនិយោគក្នុងមូលធនមនុស្សទំនងជាផ្តល់ប្រាក់ចំណេញខ្ពស់ជាងការវិនិយោគលើមូលធនរូបវ័ន្ត ។ ការផ្សព្វផ្សាយពីលទ្ធផលនេះ គឺជាទំនាក់ទំនងរវាងមូលធនមនុស្ស និងផលិតភាពទាំងតាមរយៈសមត្ថភាពឆ្ពោះទៅរកខ្សែសង្វាក់តម្លៃនៅក្នុងឧស្សាហកម្មដ៏ជាក់លាក់មួយ ក៏ដូចជាតាមរយៈការពង្រីកការផ្គត់ផ្គង់ផលិតផលពុទ្ធិថ្មីៗចូលទៅក្នុងទីផ្សារ ។ ទន្ទឹមនឹងនោះដែរភស្តុតាងវាស់វែងសេដ្ឋកិច្ចសុទ្ធនៃកត្តាទាំងនេះកំពុងបង្កឱ្យមានលំនាំច្បាស់លាស់មួយ ហើយអត្រាកំណើននៅតែអវត្តមាននោះមានកិច្ចព្រមព្រៀងរួមមួយដែលមូលធនមនុស្ស និងចំណេះដឹងនឹងកាន់តែមានសារៈសំខាន់ថែមទៀតនាពេលអនាគត ។ ជាងនេះទៀតប្រទេសអភិវឌ្ឍន៍ភាគច្រើន និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានចាប់ផ្តើមអនុវត្តកម្មវិធីគាំទ្រមួយនៃការលើកកម្ពស់បច្ចេកវិទ្យា និងកំណែទម្រង់ការអប់រំឧត្តមសិក្សាតែងតែធ្វើឡើងក្នុងភាពជាដៃគូជាមួយពាណិជ្ជកម្មដោយខ្លួនឯង ។ នេះគឺជាការបង្កើនការប្រកួតប្រជែងដោយខ្លួនឯងសម្រាប់ប្រទេសទាំងនោះដែលមិនបានអនុវត្តក្នុងការលើកកម្ពស់បច្ចេកវិទ្យា និងការបង្កើនសមត្ថភាពផ្នែកនវានុវត្តភណ្ឌ ។ ប្រទេសមួយមិនអាចរងចាំលទ្ធផលវាស់វែងសេដ្ឋកិច្ចដែលអាចជឿជាក់បានទាំងស្រុងស្តីពីផលប៉ះពាល់នៃការវិនិយោគក្នុងវិស័យអប់រំមុនពេលរៀបចំពិភពសេដ្ឋកិច្ចថ្មីនោះទេ ។

សំណួរដ៏គួរឱ្យចាប់អារម្មណ៍មួយទាក់ទងនឹងពិភពសេដ្ឋកិច្ចថ្មីនេះគឺថា តើការមកដល់របស់សេដ្ឋកិច្ចពុទ្ធិនេះកំពុងចាប់ផ្តើមផ្លាស់ប្តូរអត្ថន័យនៃពិពិធកម្មឧស្សាហកម្មផ្ទាល់ដែរឬទេ ។ ពេលដែលការសិក្សារបស់

*"រាជរដ្ឋាភិបាលកម្ពុជា បានទុកពិពិធកម្មឧស្សាហកម្ម ជាអាទិភាពខ្ពស់បំផុត ដោយចាត់ទុកថាជាផ្នែកនៃការសិក្សាសំខាន់ពីវិបត្តិសេដ្ឋកិច្ចនាពេលកន្លងទៅថ្មីៗនេះ ។"*

*"មិនថាកម្ពុជាជ្រើសរើសវិធីណាទេ ការវិនិយោគមូលធនមនុស្សតាមរូបភាពផ្សេងៗទំនងជានៅតែត្រូវលើកយកមកពិចារណានៅពេលណាមួយជាមិនខាន។"*

អង្គការ UNESCO/ធនាគារពិភពលោក និងការសិក្សាស្រដៀងគ្នាជាច្រើនផ្សេងទៀតលើកឡើងថា ប្រទេសនានាពឹងផ្អែកខ្លាំងលើអ្វីដែលប្រទេសមួយសំដៅលើ "ការជ្រើសរើសអ្នកទទួលបានជោគជ័យ" ក្នុងការជ្រើសរើសគោលនយោបាយឧស្សាហកម្ម។ ការជ្រើសរើសគោលនយោបាយឧស្សាហកម្មនេះអាចធ្វើឡើងក្នុងកម្រិតជំនាញផ្សេងគ្នាចាប់ពីវិស័យកាត់ដេរដល់វាយនភណ្ឌ ពីទេសចរណ៍ក្នុងស្រុកដល់ទេសចរណ៍អន្តរជាតិពីឧស្សាហកម្មម៉ូតូ រថយន្ត ដល់យាន្តជំនិះ ការកិនស្រូវជំនួសឱ្យការបង្កបង្កើនស្រូវការកែច្នៃម្ហូបអាហារជំនួសឱ្យការដាំដំណាំ។ គោលនយោបាយឧស្សាហកម្មនេះនឹងកាន់តែមានលក្ខណៈច្បាស់លាស់ថែមទៀតជាមួយនឹងទំនាក់ទំនងបច្ចេកវិទ្យា ឬទំនាក់ទំនងរៀបចំតាមវិធីដែលយើងកំពុងពិភាក្សាកាន់តែច្រើនពីព័ត៌មាន ស្ដីពីឧស្សាហកម្ម ឬឧស្សាហកម្មប្រកបដោយគំនិតច្នៃប្រឌិត (ដូចជា ខ្សែភាពយន្ត ឬ ការអប់រំ) ឬជាមួយនឹងទំនាក់ទំនងនៃអត្តចរិតដែលបានកំណត់ដូចមាននៅក្នុងករណីរបស់ឧស្សាហកម្មសេវាកំសាន្ត។ ជម្រើសជាច្រើនប្រភេទត្រូវបានបង្ហាញក្នុងកំណើន និងការសិក្សាពីឧស្សាហកម្មដោយមានការលើកឡើងថា កម្ពុជាគួរផ្ដោតជាដំបូងលើការធ្វើពិពិធកម្មវិស័យដែលមានឧត្ដមភាពប្រៀបធៀបទូលំទូលាយរបស់ខ្លួនមុនពេលកម្ពុជាព្យាយាមលើកកម្ពស់ឧស្សាហកម្មថ្មីៗ ដូចជា បច្ចេកវិទ្យាព័ត៌មាន ឬអេឡិចត្រូនិចតាមរយៈការគាំទ្ររបស់រដ្ឋ។

ការមកដល់របស់សេដ្ឋកិច្ចពុទ្ធិនេះ កំពុងផ្ដល់លទ្ធភាពយកឈ្នះផ្នែកបច្ចេកវិទ្យា ស្របពេលដែលមានឱនភាព មូលធនមនុស្សរបស់កម្ពុជាផ្ទាល់ជំរុញឱ្យផ្ដោតការយកចិត្តទុកដាក់លើអ្វីដែលមានប្រយោជន៍ភ្លាមៗ ដូចជាការបណ្ដុះបណ្ដាលនិយោជិត ការលើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍រកការងារធ្វើ និងការនាំចូលបច្ចេកវិទ្យាថ្មីៗ តាមរយៈសម្ភារនាំចូល និង FDI។ មិនថាកម្ពុជាជ្រើសរើសវិធីណាទេការវិនិយោគមូលធនមនុស្សតាមរូបភាពផ្សេងៗទំនងជានៅតែត្រូវលើកយកមកពិចារណានៅពេលណាមួយជាមិនខាន។ លើសពីនេះទៅទៀតអាទិភាពស្ដីពីការវិនិយោគមូលធនមនុស្សទំនងជាបង្ហាញថា សេដ្ឋកិច្ចកម្ពុជា នឹងចូលរួមកាន់តែខ្លាំងទៅក្នុងសេដ្ឋកិច្ចអាស៊ីថ្នាក់តំបន់ និងក្នុងទីផ្សារពិភពលោកកាន់តែធំ។

## ៦.៤.២ ការសម្រេចបានផែនទីយុទ្ធសាស្ត្រស្ដីពីមូលធនមនុស្សនៅកម្ពុជា

ការសន្និដ្ឋានដ៏សំខាន់មួយបានពីការសិក្សានេះ គឺតម្រូវការផែនទីយុទ្ធសាស្ត្រស្ដីពីមូលធនមនុស្សដ៏ទូលំទូលាយមួយដើម្បីដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្រោយពេលមានវិបត្តិ។ លើសពីនេះទៅទៀត ផែនទីយុទ្ធសាស្ត្របែបនេះចាំបាច់ត្រូវមានតុល្យភាព មិនត្រឹមតែនៅក្នុងការបណ្ដុះបណ្ដាលភ្លាមៗ និងតម្រូវការបណ្ដុះបណ្ដាលវិជ្ជាជីវៈនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជាប៉ុណ្ណោះទេ ថែមទាំងក្នុងសេណារីយ៉ូជម្រើសដែលផ្ដោតលើលទ្ធភាពនៃការធ្វើពិពិធកម្មឧស្សាហកម្មនៅកម្ពុជា ក៏ដូចជាកិច្ច ខិតខំប្រឹងប្រែងរួមគ្នាកាន់តែខ្លាំង និងទូលំទូលាយទាំងអស់ដើម្បីកសាងមូលដ្ឋានសេដ្ឋកិច្ចពុទ្ធិនាពេលអនាគត។ ការធ្វើបែបនេះមិន មែនមានន័យថាកម្ពុជាត្រូវខិតខំប្រឹងប្រែងវិនិយោគយ៉ាងខ្លាំងលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ឬក្នុងការ អភិវឌ្ឍភ្លាមៗនៃបណ្ដាញការងារច្នៃប្រឌិតជាមួយនឹងពាណិជ្ជកម្មឯកជននោះទេ។ ប៉ុន្តែ វាពិតជាមានន័យថាការផ្ដោតលើធាតុផ្សំទាំងអស់ដែលចូលរួមចំណែកបង្កើតក្របខណ្ឌសេដ្ឋកិច្ចពុទ្ធិដ៏រឹងមាំមួយ ពោលគឺ ចាប់ពីការអប់រំកម្រិតឧត្ដមសិក្សានៅក្នុងប្រព័ន្ធសិក្សារៅដ្ឋជីវិត និងការសម្របសម្រួលវិទ្យាស្ថានដែលផ្ដល់ចំណេះដឹងពាក់ព័ន្ធរហូតដល់ការចូលរួមក្នុងភាពជាដៃគូជាយូរអង្វែងជាមួយវិទ្យាស្ថានផ្ដល់ចំណេះដឹងអន្តរជាតិ និងការផ្គត់ផ្គង់ធនធាន។

អានុសាសន៍ជាក់លាក់ និងវិធានការដែលត្រូវការត្រូវបានកត់ត្រាចូលក្នុងតារាងម៉ាទ្រិចគោលនយោបាយមួយដែលបានភ្ជាប់ទៅនឹងរបាយការណ៍នេះ និងបានរៀបរាប់លម្អិតខ្លះនៅផ្នែកខាងលើ។ អានុសាសន៍ និងវិធានការទាំងនេះរួមមានទាំងវិធានការរយៈពេលវែងដែលកំពុងបង្កើតស្ថាបត្យកម្មវិទ្យាស្ថាននៃសេដ្ឋកិច្ចពុទ្ធិមួយ និងការគ្រប់គ្រងវិបត្តិរយៈពេលខ្លីព្រមទាំងការប្រើប្រាស់វិធានការនៃការស្តារឱ្យមានការងារធ្វើឡើងវិញដែលវិធានការមួយចំនួនត្រូវបានកំពុងប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះ អានុសាសន៍ និងវិធានការទាំងនេះក៏រួមមានទាំងឱកាសសម្រាប់ការកសាងភាពជាដៃគូចំណេះដឹងកម្រិតអន្តរជាតិផងដែរ។ នេះប្រហែលជាវិធីដ៏ប្រសើរបំផុតដែលអាចអនុវត្តបានទាំងក្នុងការណែនាំទូលំទូលាយនូវផែនការមូលធនមនុស្សដោយសារការខ្វះនូវយុទ្ធសាស្ត្រឧស្សាហកម្មច្បាស់លាស់មួយ និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័សនេះនៅអាស៊ាន។ ម្យ៉ាងវិញទៀត កម្ពុជាមិនបានរៀបចំពេលវេលាដើម្បីពិចារណាអំពីតម្រូវការមូលធនមនុស្ស ការវិនិយោគ និងរចនាសម្ព័ន្ធវិទ្យាស្ថានទេដោយសារកម្ពុជាកំពុងស្វែងរកវិធីដ៏ប្រសើរបំផុតដើម្បីកំណើនសេដ្ឋកិច្ចនៅក្នុងពិភពភាវូបនីយកម្មមិនច្បាស់លាស់មួយ។

លក្ខណៈពិសេសនៃរបាយការណ៍នេះ គឺការគូសបញ្ជាក់ពីការស្វែងយល់ និងការកែតម្រូវឱនភាពមូលធនមនុស្សក្នុងជួររដ្ឋាភិបាល និងសង្គមស៊ីវិលដែលពាក់ព័ន្ធ។ ហេតុផលសំខាន់សម្រាប់របាយការណ៍នេះ បានបង្កើតតួនាទីរបស់រដ្ឋយ៉ាងច្រើនក្នុងការបង្កើតមូលដ្ឋានសេដ្ឋកិច្ចពុទ្ធិ ពោលគឺការអប់រំឧត្តមសិក្សា និងការបណ្តុះបណ្តាលក្នុងពេលបំពេញការងារការគាំទ្រដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបណ្តាញនវានុវត្តន៍ ការពង្រីកវិសាលភាពបច្ចេកវិទ្យាព័ត៌មាន និងបណ្តាញចែកចាយព័ត៌មានការកំណត់ដៃគូផ្តល់ចំណេះដឹងខាងក្រៅ និងការសម្របសម្រួលមជ្ឈមណ្ឌលផ្តល់ចំណេះដឹង និងភាពជាដៃគូ ការលើកកម្ពស់កិច្ចពិភាក្សាសាធារណៈស្តីពីគុណភាព និងលទ្ធភាពទទួលបានសេវាសាធារណៈ ដូចជា សេវាអប់រំ និងសុខភាព។ ប្រការសំខាន់នោះគឺត្រូវពិចារណាពីឱនភាពមូលធនមនុស្សរបស់រដ្ឋាភិបាល/រដ្ឋ ដោយសារបទពិសោធអន្តរជាតិបង្ហាញថា ទំហំរបស់រដ្ឋទំនងជាបន្តកើនឡើងនៅកម្ពុជា។ នេះបង្ហាញថាជាការព្រមានជាបឋមពីបញ្ហាដែលបម្រុងនឹងកើតឡើង និងលទ្ធភាពដោះស្រាយបញ្ហាជាមុនដោយប្រើប្រាស់អភិបាលកិច្ច តាមអ៊ីធើណែតទម្រង់ថ្មីនៃទំនាក់ទំនងសាធារណៈ និងកិច្ចពិភាក្សា ព្រមទាំងការចែករំលែកចំណេះដឹងតាមរយៈការស្រាវជ្រាវគោលនយោបាយសាធារណៈ និងក្រុមអ្នកជំនាញ។

វិសាលភាពសំខាន់ផ្សេងទៀតនៃផែនទីយុទ្ធសាស្ត្រមូលធនមនុស្ស គឺការធ្វើសមាហរណកម្មនៃការអភិវឌ្ឍមនុស្សទៅក្នុងការរៀបចំផែនការ និងការវិនិយោគមូលធនមនុស្ស។ ការយកចិត្តទុកដាក់លើការអភិវឌ្ឍមនុស្ស គឺជាមធ្យោបាយសំខាន់មួយដើម្បីលើកកម្ពស់ "គុណភាពនៃកំណើន" តាមការពង្រីកអត្ថប្រយោជន៍នៃកំណើនលើក្រុមប្រជាពលរដ្ឋដ៏ច្រើនរបស់តំបន់ និងគ្រួសារ។ ដូចបានពិភាក្សានៅក្នុងជំពូកទី៤រួចមកហើយការលើកកម្ពស់ការអភិវឌ្ឍមនុស្សគឺស្របនឹងតម្រូវការនៃសេដ្ឋកិច្ចពុទ្ធិ ដោយហេតុថានវានុវត្តន៍ដោយផ្ទុយពីការសិក្សាក្នុងប្រព័ន្ធជាផលិតផលដ៏មានសារៈសំខាន់មួយនៃការចែករំលែកចំណេះដឹង តាមរយៈលទ្ធភាពទទួលបានជាសកលនូវបច្ចេកវិទ្យាគ្មានព្រំដែន និងផលិតផលពុទ្ធិ។

ការចូលរួមចំណែកសំខាន់មួយទៀតនៃការបង្កើនសូចនាករអភិវឌ្ឍន៍មនុស្ស គឺត្រូវបង្កើតរង្វាន់លើកទឹកចិត្តសម្រាប់ការបន្តសិក្សា និងការបង្កើនជំនាញថ្មីៗដោយសារការបង្កើតជំនាញមូលដ្ឋានជាសកល និងអត្រាកំណត់សុខភាព ក៏ដូចជាការកាត់បន្ថយភាពងាយរងគ្រោះចំពោះភាពក្រីក្រទាំងស្រុង។ ការអភិវឌ្ឍ

មនុស្សនេះនឹងពង្រីកជម្រើសរបស់គ្រួសារ និងរបស់បុគ្គលម្នាក់ៗក្នុងការស្វែងរកការងារធ្វើ និងការផ្លាស់ទីក្នុងរយៈពេលដ៏យូរក្នុងការរងចាំការងារសមរម្យដែលត្រូវតាមជំនាញ និងក្នុងការកាត់បន្ថយចំនួនសិស្សបោះបង់ការសិក្សា។

សរុបមករបាយការណ៍នេះ បង្ហាញថាមានចំណុចសុទិដ្ឋិនិយមច្រើនចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនាពេលអនាគតរបស់កម្ពុជា។ របាយការណ៍នេះ បានតាមដានពីការលំបាក និងភាពមិនប្រាកដប្រជាសំខាន់រយៈពេលបីទសវត្សរ៍ ហើយរបាយការណ៍នេះមានពាក់ព័ន្ធនឹងបញ្ជីឯកសារដែលកំពុងកើនឡើងរបស់ប្រទេសមានប្រាក់ចំណូលទាបដែលបានធ្លាក់ចូលក្នុងវដ្តទន់ខ្សោយនៃជម្លោះសង្គមបរាជ័យរបស់រដ្ឋ ឬការឃាត់ខ្លួនរចនាសម្ព័ន្ធផលិតកម្មទ្រឹង ការតម្រង់ទិសផ្ទៃក្នុង និងអស្ថិរភាពនយោបាយ។ ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍមនុស្សមួយចាំបាច់ត្រូវទាក់ទងយ៉ាងខ្លាំងចំពោះវិសាលភាពរបស់មនុស្សក្នុងការបង្កើតគោលនយោបាយ និងការបាត់បង់យ៉ាងធ្ងន់ធ្ងរនៃធនធានមនុស្សដែលមានស្រាប់ចាប់តាំងពីការចាប់ផ្តើមនៃរបបខ្មែរក្រហមរហូតមកដល់ទសវត្សរ៍ចុងក្រោយនេះ។ ក្នុងការស្វែងរកផែនការពិពិធកម្មសេដ្ឋកិច្ចថ្មី ការអភិវឌ្ឍ មូលធនមនុស្ស និងការអភិវឌ្ឍមនុស្សអាចជាសកម្មភាពដ៏ប្រសើរបំផុតក្នុងពេលខាងមុខទៀត។

*"ក្នុងការស្វែងរកផែនការពិពិធកម្មសេដ្ឋកិច្ចថ្មី ការអភិវឌ្ឍមូលធនមនុស្ស និងការអភិវឌ្ឍមនុស្សអាចជាសកម្មភាពដ៏ប្រសើរបំផុតក្នុងពេលខាងមុខទៀត។"*

# ឯកសារពិគ្រោះយោបល់


Aghion, P., L. Boustan, C. Hoxby and J. Venderbussche 2009. "The Causal Impact of Education on Economic Growth: Evidence from the United States". Brookings Papers on Economic Activity. Brookings Institution: Washington, DC.

Alam, S.A. 2008. *Expansion of Tourism Sector in Bangladesh*. University of Chittagong, Bangladesh.

Ali, M.M. and R. Parvin. 2010. "Strategic Management of Tourism Sector in Bangladesh to Raise Gross Domestic Product: An Analysis". AIUB Bus Econ Working Paper Series. American International University-Bangladesh: Dhaka.

Altbach, P.G., L. Reisberg, L.E. Rumbley. 2009. "Trends in Global Higher Education: Tracking an Academic Revolution". Report prepared for the UNESCO 2009 World Conference on Higher Education. UNESCO: Paris.

Anderson, Lisa (ed.). 1999. *Transitions to Democracy*, Columbia University Press: New York.

Antonio, E.T., W. Conrad, B. Padojinog, C.L.S. Rodolfo, and L. Molina. "Directions for Industrial Restructuring in the Twenty-First Century: The Philippine Case". In *Industrial Restructuring in East Asia: Towards the 21st Century*, pp. 72-108. Masuyama, S., D. Vandenbrik, C.S. Yue (eds.). 2001. Institute of Southeast Asian Studies (ISEAS): Singapore.

Asian Development Bank (ADB). 2007. "Development Effectiveness Country Brief: Cambodia". ADB: Phnom Penh.

______. 2008. *Asian Development Outlook 2008 Update*. ADB: Manila.

______. 2009a. *Building a Sustainable Energy Future: The Greater Mekong Sub Region*. ADB: Manila.

______. 2009b. "Fact Sheet: Cambodia". ADB: Phnom Penh.

______. 2009c. "Greater Mekong Subregion: Maturing and Moving Forward". ADB Learning Curves. ADB: Manila.

______. 2009d. *Key Indicators for Asia and the Pacific 2009: Cambodia*. ADB: Manila.

______. 2009e. "Enterprises in Asia: Fostering Dynamism in SMEs". In *Key Indicators for Asia and the Pacific 2009*. ADB: Manila.

______. 2009f. "Tourism Sector in the Greater Mekong Subregion". ADB: Manila.

______. 2009g. "Transport and Trade Facilitation in the Greater Mekong Subregion: Time to Shift Gears". ADB: Manila.

Bakht, Z., Md. Salimullah, T. Yamagata, and M. Yunus. 2008. "Competitiveness of the Knitwear Industry in Bangladesh: Background of Its Development amid Global Competition". IDE Discussion Paper No. 169. Institute of Developing Economies, Japan External Trade Organization (IDE-JETRO): Chiba, Japan.

Bannon, I. and P. Collier. 2003. *Natural resources and violent conflict*. World Bank: Washington, DC.

Bardhan, P.. "Sharing the Spoils: Group Equity, Development and Democracy". In *The Success of India's Democracy*, Kohli, A. (ed.). 2001. pp. 226-241.

Barr, N. 2005. "Financing Higher Education". *Finance and Development*, 42(2), pp. 34-37.

Bauer, A. and M. Thant (eds.). 2010. *Poverty and Sustainable Development in Asia: Impacts and Responses to the Global Economic Crisis*. ADB: Manila.

Bhattacharya, D., M. Rahman, A. Raihan. 2002. "Contribution of the RMG Sector to the Bangladesh Economy". CPD Paper 50. Centre for Policy Dialogue: Dhaka.

Booth, A.1999. "Education and Economic Development in Southeast Asia: Myth and Realities", *ASEAN Economic Bulletin*, 16(3).

Broadberry, S. and K. Wagner. 1994. "Human Capital and Productivity in Manufacturing during the Twentieth Century: Britain, Germany and the United States". CEPR Discussion Papers 1036.

Cabinet Office of the UK. 1999. "Modernising Government". A Labour government white paper.

Cambodian Federation of Employers and Business Associations (CAMFEBA). 2008. *Youth and Employment: Bridging the Gap*. CAMFEBA: Phnom Penh.

CAMFEBA and EDLink (Cambodia) Co., Ltd. 2010. *Understanding the Impact of the Global Economic Crisis on the Cambodian Garment Sector*. ILO: Phnom Penh.

Chandararot, K. and L. Dannet. 2010. "Tracking Study of Cambodian Garment Sector Workers Affected by the Global Economic Crisis: First Tracking Report". Cambodian Institute of Development Studies: Phnom Penh.

Chandararot, K., S. Sina, L. Dannet. 2009. "Rapid Assessment of the Impact of the Financial Crisis in Cambodia". ILO Asia-Pacific Working Paper Series. ILO: Phnom Penh.

Chea, S., D. Sarin, and H. Sok. Undated. "ASEAN Economic Forum: Trade in Services in Cambodia". World Bank: Washington, DC.

Chen, C.Y., P. Sok, K. Sok. 2007. "Benchmarking Potential Factors Leading to Education Quality: A Study of Cambodian Higher Education". *Quality Assurance in Education* 15(2).

Chheang, V. 2009. "Hun Sen's Talks and Cambodia's Tourism Development: The Discourse of Power***". Ritsumeikan Journal of Asia Pacific Studies* **25(March 20090.** Ritsumeikan Center for Asia Pacific Studies (RCAPS): Beppu-City, Oita, Japan.

Chhibber, A., J. Ghosh, and T. Palanivel. 2009. *Asia Rebounds but Lasting Recovery Needs New Paradigm: A Synthesis Study Incorporating Evidence from Country Case Studies*. UNDP Regional Centre for Asia and the Pacific: Bangkok.

Chhingh, S. and S.S. Dy. 2009. "Education Reform Context and Process in Cambodia". In Hirosato Y. and Y. Kitamura (eds.). *The Political Economy of Educational Reforms and Capacity Development in Southeast Asia*, pp.113-129. Springer: New York.

Cimoli, Mario, G. Dosi and J. Stiglitz. 2009. "The Future of Industrial Policies in the New Millennium: Toward a Knowledge-Centred Development Agenda". Initiative for Policy Dialogue Working Paper Series. Initiative for Policy Dialogue: New York.

Cohen, D. and M. Soto. 2006. "Growth and Human Capital: Good Data, Good Results". *PSE, OECD Development Centre and CEPR.*

Collier, P. and A. Hoeffler. 1998. "On Economic Causes of Civil War". *Oxford Economic Papers* 50(4):563-573.

______. 2004. "Aid, Policies and Growth in Post-Conflict Societies". *European Economic Review,* 8(5).

Collier, P., A. Hoeffler and M. Soderbom. 2006. "Post-Conflict Risks". *Journal of Peace Research*, 45(4).

Collier, P., V.L. Elliott, H. Hegre, A. Hoeffler, M. Reynal-Querol, N. Sambanis. 2003. "Breaking the Conflict Trap (Civil War and Development Policy)". World Bank Policy Research Report. World Bank: Washington, DC.

Commonwealth of Australia. 2007. *Tackling Wicked Problems: A Public Policy Perspective*. Government of Australia: Canberra.

Dahrendorf, R. 1990. *The Modern Social Conflict: An Essay on the Politics of Liberty*. University of California Press: Berkeley.

Dearden, L., C. Emmerson, C. Frayne and C. Meghir, "Can Education Subsidies Stop School Drop-outs? An Evaluation of Education Maintenance Allowances in England." http://www.aeaweb.org/annual_mtg_papers/2005/0107_0800_0801.pdf. Accessed August 2004.

Diamond, L. and M.F. Plattner (eds.). 1996. *The Global Resurgence of Democracy*. John Hopkins Press: Baltimore.

Dy, S.S. 2004. "Strategies and Policies for Basic Education in Cambodia: Historical Perspectives". *International Education Journal* 5(1), pp. 90-97.

Ericson, E. and A. Ronning. 2008. "Sustainable Tourism Development in Cambodia: A Report about Positive and Negative Effects of International Tourism". Karlstads University: Karlstads, Sweden.

Fernandez, S.M. and M. Powell. 2009. *Employment and Skills Strategies in Southeast Asia: Setting the Scene*. Organization for Economic Cooperation and Development (OECD): Paris.

Ferreira, F.H.G., D. Filmer, N. Schady. 2009. "Own and Sibling Effects of Conditional Cash Transfer Programmes: Theory and Evidence from Cambodia". World Bank Policy Research Working Paper 5001. World Bank: Washington, DC.

Filmer, D. and N. Schady. 2006. "Getting Girls into School: Evidence from a Scholarship Programme in Cambodia". World Bank Policy Research Working Paper 3910. World Bank: Washington, DC.

______. 2009. "School Enrollment, Selection, and Test Scores". World Bank Policy Research Working Paper 4998. World Bank: Washington, DC.

Fukase, E. and W. Martin. 2001. "Free Trade Area Membership as a Stepping Stone to Development: the Case of ASEAN". Wold Bank Discussion Paper No.421. World Bank: Washington, DC.

Gereffi, G. 2002. "The International Competitiveness of Asian Economist in the Apparel Commodity Chain". ERD Working Paper Series No.5. ADB: Manila.

Ginting, E. and K. Bird. 2009. "Explaining Inflation in Cambodia". Presentation at the Third Economic Forum, Phnom Penh, 5 February 2009.

Gropello, E.D. and C. Sakellariou. 2010. "Industry and Skill Wage Premiums in East Asia". World Bank Policy Research Working Paper 5379. World Bank: Washington, DC.

Guarcello, L. and. F.C. Rosati. 2007. "Does School Quality Matter for Working Children". Working Paper. World Bank: Washington, DC.

Guimbert, S. 2010. "Cambodia 1998-2008: An Episode of Rapid Growth". World Bank Policy Research Working Paper 5271. World Bank: Washington, DC.

Hill, H. (ed). 2002. *The Economic Development of Southeast Asia Volume II*. Edward Elgar Publishing: Cheltenham.

HR, Inc. 2010. "Higher Education and Skills for the Labor Market in Cambodia". HR, Inc.: Phnom Penh.

Hughes, C. 2008. "Cambodia in 2007: Development and Dispossession". *Asian Survey* 4(1): 69-74.

International Finance Corporation (IFC). 2006a. Public-Private Dialogue. "The PPD Handbook and Assessing the Impact of the Mekong Business Forums on the Business Environment". Presentation at "Creating Better Business Environments for Enterprise Development; Regional and Global Lessons for More Effective Donor Practices". 30 November 2006 at the Imperial Queen's Park Hotel, Bangkok, Thailand.

______. 2006b. "Ready-Made Garments: Challenges in Implementing a Sector Strategy". *IFC Monitor*. IFC: Washington, DC.

______. 2008. "The Tourism Law in Cambodia: Balancing Regulation and Facilitation of the Sector". IFC: Phnom Penh.

______. 2009a. "The Establishment of Commercial Arbitration Services in Cambodia". Private Sector Discussion Paper No. 24. IFC: Washington, DC.

______. 2009b. *The Provincial Business Environment Scorecard in Cambodia: A Measure of Economic Governance and Regulatory Policy*. IFC: Washington, DC.

International Labour Organization (ILO). 2007. "Developing National Skills Strategies". Report of ILO/SKILLS-AP/Japan Regional Technical Meeting on Developing National Skills Strategies. Chiba, Japan, 27-30 March 2007. ILO Regional Centre for Asia and the Pacific: Bangkok.

______. 2008. "Labour and Social Trends in ASEAN 2008: Driving Competitiveness and Prosperity with Decent Work". ILO Regional Centre for Asia and the Pacific: Bangkok.

______. 2009. "The Work of the ILO in Cambodia". Video message by ILO Director General Juan Somavia on ILO's 90th Anniversary, 21 April 2009.

______. 2010a. *Labour and Social Trends in ASEAN 2010: Sustaining Recovery and Development through Decent Work*. ILO Regional Centre for Asia and the Pacific: Bangkok.

______. 2010b. *Labour and Social Trends in Cambodia*. ILO: Phnom Penh.

International Monetary Fund (IMF). 2007. *Cambodia Country Report 2007*. IMF: Washington, DC.

______. 2009a. *Cambodia Country Report 2008*. IMF: Washington, DC.

______. 2009b. *Cambodia Country Report 2009*. IMF: Washington, DC.

International Telecommunications Union (ITU). 2008. *Asia-Pacific Telecommunication/ICT Indicators 2008: Broadband in Asia-Pacific Too Much Too Little?* ITU: Geneva.

Islam, M.A. and C. Deegan. 2007. "Motivations for an Organisation within a Developing Country to Report Social Responsibility Information: Evidence from Bangladesh". School of Accounting and Law, Royal Melbourne Institute of Technology.

Jalilian, H. and G. Reyes. 2010. "Cambodia Phase 2". Global Financial Crisis Discussion Series, Paper 14. ODI: London.

Kanapathy, V. 2001. "Industrial Restructuring in Malaysia: Policy Shift and the Promotion of New Sources of Growth". In *Industrial Restructuring in East Asia: Towards the 21st Century,* pp. 108-138. Masuyama, S. et al. 2001. ISEAS: Singapore.

Kanbur, R. and A.J. Venables (eds.). 2005. *Spatial Inequality and Development*. Oxford University Press: Oxford.

Khin, P. and R.R. Kato. 2010. "The Impact of the Global Economic Crisis on Cambodia". Working Paper no.A-21. Shiga University, Japan.

Khoman, S. 1995. "Thailand's Industrialization: Implications for Health, Education, Science and Technology. In *The Economic Development of Southeast Asia Volume II*, pp. 346-362. Hill, H. (ed). 2002. Edward Elgar Publishing: Cheltenham.

King, V.T. 2008. "Tourism in Asia: A Review of the Achievements and Challenges". *Sojourn: Journal of Social Issues in Southeast Asia* 23(1): pp.104-136.

Knight, J. (ed.). 2009. *Financing Access and Equity in Higher Education.* Ontario Institute for Studies in Education, University of Toronto: Toronto.

Lensink, R. and O. Morrissey. 2001. "Foreign direct investment: Flows, volatility and growth in developing countries". Credit Research paper. University of Nottingham: Nottingham, UK.

Lin, T and F.D. de Guzman. 2007. "Tourism for Pro-Poor and Sustainable Growth: Economic Analysis of Tourism Projects". Economics and Research Department, Technical Note Series No. 20. ADB: Manila.

Lynn, B.E. "The management of intellectual capital: the issues and the practice". In "The impact of human capital on economic growth: a review". 2004. Third report on vocational training research in Europe: Background report. Office for Official Publications of the European Communities: Luxembourg.

Maddock, N. Unpublished. "Private Sector Engagement and Service Provision in Sub-national Planning under Deconcentration and Decentralisation in Cambodia". Background paper written for UNDP Cambodia.

Masuyama, S., D. Vandenbrik and C.S. Yue (eds.). 2001. *Industrial Restructuring in East Asia: Towards the 21st Century*. ISEAS: Singapore.

Ministry of Commerce (MoC). 2004. "Cambodia's Garment Industry" Meeting the Challenges of the Post-Quota Environment". MoC and ADB: Phnom Penh.

Ministry of Education, Youth and Sport (MoEYS). 2005. "Cambodia Education Strategic Plan 2006-2010".

_____. 2009. "National Education Congress Summary Report on the Education, Youth, and Sport Performance for the Academic Year 2007-08 and the Academic Year 2008-2009 Goals".

_____. 2010. "Education Strategic Plan 2009-2013".

Ministry of Labour and Vocational Training (MoLVT). 2010. "Labour Migration Policy for Cambodia".

MoLVT and ILO. 2010. National Technical Workshop on Developing Skills TVET linked to employment.

MoLVT (Directorate General of TVET). 2010. Challenges and Strategic Development of TVET linked with Employment in Cambodia, March 2010

Ministry of Planning (MoP). 2010. "Achieving Cambodia's Millennium Development Goals". MoP: Phnom Penh.

Ministry of Tourism (MoT). 2009. "Tourism Statistics: Annual Report 2009". MoT: Phnom Penh.

Ministry of Tourism (MoT). 20010. "Tourism Statistics: Annual Report 2010". MoT: Phnom Penh.

Mishra, S. 2009. "Economic Inequality in Indonesia: Trends, Causes, and Policy Responses". Report prepared by Strategic Asia, commissioned by UNDP Regional Office Colombo.

Morris, E. 2007. *Promoting Employment in Cambodia: Analysis and Options*. ILO Regional Centre for Asia and the Pacific: Bangkok.

Naron, H.C. 2009. *Cambodian Economy: Charting the Course of a Brighter Future, a Survey of Progress, Problems, and Prospects*. Ministry of Economy and Finance: Phnom Penh

National Institute of Statistics (NIS). 2004. Cambodia Socio-Economic Survey 2004. NIS: Phnom Penh.

NIS. 2007. Cambodia Socio-Economic Survey 2007. NIS: Phnom Penh.

NIS. 2009. "Education 2007". NIS: Phnom Penh.

NGO Forum on Cambodia. 2009. "Analysis of 2009 Draft Budget Law: Budget Trend for Ministries of Agriculture, Rural Development, and Water Resources". NGO Forum on Cambodia: Phnom Penh.

_____. 2010. "Analysis of the Draft Law on Finance for 2010 Management: Draft National Budget Law 2010". *Cambodia Development Watch*, 7(1).

Nuruzzaman, Md. and A. Haque. 2009. "Lead time Management in the Garment Sector of Bangladesh: An Avenues for Survival and Growth". *European Journal of Scientific Research* 33(4): pp. 617-629.

O'Callaghan, B.A. 2002. "Human Capital Accumulation and Economic Growth in Asia". Paper prepared for the Workshop on Asia-Pacific Studies in Australia and Europe, Australian National University, 5-6 July 2002.

Olson, M. 2000. *Power and Prosperity: Outgrowing Communist and Capitalist Dictatorships.* Basic Books: New York.

Organization for Economic Co-operation and Development (OECD). 2009a. "Cambodia: Aid for Trade Figures". OECD: Paris.

Phoumin, H. 2008. "Human Capital and Hours Worked of Children in Cambodia: Empirical Evidence for Policy Implications". *Asian Economic Journal* 22(1):25-46.

Poapongsakorn, N. and S. Tangkitvanich. 2001. "Industrial Restructuring in Thailand: A Critical Assessment". In Masuyama, S., D. Vandenbrik and C.S. Yue. 2001. *Industrial Restructuring in East Asia: Towards the 21st Century*, pp. 73-108. ISEAS: Singapore.

Prime Minister's Strategy Unit (UK). 2004. "Strategy Survival Guide".

Rahman, M. and A. Anwar. 2006. "Bangladesh Apparels Export to the US Market: An Examination of Her Competitiveness vis-a-vis China". CPD Paper 62. Center for Policy Dialogue: Dhaka.

Rahman, S. 2006. "Is the High-Road Strategy Enough: Vulnerability of the Garment Industry in Bangladesh". *Labour and Management in Development Journal* 7(3):1-16

Rasiah, R. 2007. "Garment Exports from Asian LDEs: Can it be Sustained?" Background paper for *Least Developed Countries Report 2007: Knowledge, Technological Learning and Innovation for Development*. UNCTAD: New York.

Rodrik, D. 1997. *Has Globalization Gone Too Far?* Institute for International Economics: Washington DC.

RGC. 2008. "National TVET Development Plan-2008".

______. 2010a. "Law on Finance for 2010 Management".

______. 2010b. "National Strategic Development Plan Update 2009-2013".

Saktheara, M. 2009. "Concept Paper on the Strategy Framework for 2010-2015 (Strategy 2015)". Ministry of Industry, Mines, and Energy: Phnom Penh.

Sen, A. 1997. "***What›s the point of a development strategy?"*** DEDPS, 3. Suntory and Toyota International Centres for Economics and Related Disciplines., London School of Economics and Political Science, London, UK.

Sen, A. 1999. "Democracy as a Universal Value". *Journal of Democracy* 10(3):3-17.

Sen, A. 1999. *Development as Freedom*. Oxford University Press: Oxford.

Sen, A. 2008. "Global Doubts". Commencement address delivered at Harvard University. 8 June 2000.

Segerera, F.L. 2009. "Trends and Innovations of Higher Education Worldwide and in Latin America and the Caribbean". Research and Occasional Paper Series. Centre for Studies in Higher Education. University of California, Berkeley.

Son, H.H. Undated. "Human Capital and Economic Growth". Draft.

Stewart, F. 2002. "Horizontal Inequalities: A Neglected Dimension of Development". Working Paper Number 81. Centre for Research on Inequality, Human Security and Ethnicity (CRISE). Oxford University: Oxford.

Stewart, F., G. Brown and L. Mancini. 2005. "Why Horizontal Inequality Matter: Some Implications for Measurement". Working Paper No. 19. CRISE. Oxford University: Oxford.

Stiglitz, J.E. 1998. "More Instruments and Broader Goals: Moving Toward the Post-Washington Consensus". Address to the 1998 WIDER Annual Lecture, Helsinki, Finland, 7 January 1998.

Strategic Policy Making Team for the Cabinet Office of the UK. 1999. "Professional Policy Making for the twenty first century".

______. 2001. "Better Policy Delivery and Design".

Supreme National Economic Council (SNEC). 2009. "Labor Market and Youth Employment". SNEC: Phnom Penh.

Taliercio,R.R. Undated. "From a Whole of Government to a Whole of Reform Approach? Reforming the Cambodian Civil Service". World Bank: Phnom Penh.

Tan, C. 2006. "Education reforms in Cambodia: Issues and Concerns". *Educational Research for Policy and Practice* 6(1):15–24.

Tang, T.C. and K.N. Wong. 2007. "Foreign Direct Investment, Merchandise and Service Trade in a Transition Economy: The Case of Cambodia". Asian Business and Economics Research Unit Discussion Paper 46. Monash University: Melbourne.

Tanzi, V. and L. Schuknecht. 2000. *Public Spending in the 20th Century: A Global Perspective*. Cambridge University Press: Cambridge.

Tanzi, V. 2004. "A Lower Tax Future? The Economic Role of the State in the 21st Century". Policy Series No. 44. Politeia: London.

Task Force on Higher Education and Society. 2000. *Higher Education in Developing Countries: Peril and Promise.* World Bank: Washington, DC.

Temple, J. 2000. "Growth effects of education and social capital in the OECD countries". ECO/WKP(2000)36. OECD: Paris.

Thomsen, L. 2007. "Accessing the Global Value Chains? The Role of Business-State Relations in the Private Clothing Industry in Vietnam". *Journal of Economic Geography*, 7(6):753-776.

Ty, M., J. Walsh and P. Anurit. 2008. «Training and Development in Social Enterprises in Cambodia» in *Proceedings of the Second International Colloquium on Business and Management in conjunction with the International Conference on Business and Management Education.* School of Management, Shinawtra University: Bangkok.

Um, K . 2008. "Cambodia: A Decade after the Coup". *Southeast Asian Affairs,* 1(2008):107-120.

UN Educational, Scientific and Cultural Organization (UNESCO). 2010. "TVET Policy Review Malawi". UNESCO: Paris.

______. "The Bonn Declaration on Learning for Work, Citizenship and Sustainability". International Experts Meeting on Technical and Vocational Education and Training. Bonn, Germany, 29 October 2004.

UNESCO - Centre for Technical and Vocational Education and Training (UNEVOC). 2006. *Participation in Formal Technical and Vocational Education and Training Programmes World Wide: An Initial Statistical Study.* UNESCO-UNEVOC: Bonn.

UN Development Programme (UNDP). 2006. "A SWOT Analysis of the Cambodian Economy". Discussion Paper No. 1. UNDP: Phnom Penh.

______. 2007. *Cambodia Human Development Report 2007*: *Expanding Choices for Rural People*. Ministry of Planning and UNDP Cambodia: Phnom Penh.

______. 2009. "Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction". Discussion Paper No. 7. UNDP: Phnom Penh.

______. Human Development Report. UNDP: New York.

United Nations (UN). 2009. *The Global Economic Downturn: Opportunity or Crisis*. UN in Cambodia: Phnom Penh.

______. 2010. "Cambodia Common Country Assessment 2009". UN in Cambodia: Phnom Penh.

UN Conference on Trade and Development (UNCTAD). 2001. "Country Presentation by the Royal Government of Cambodia". Third UN Conference on the Least Developed Countries. Brussels, 14-20 May 2001.

______. 2003. *An Investment Guide to Cambodia: Opportunities and Conditions*. UNCTAD: New York.

______. 2009. "Multi-Year Expert Meeting on Services, Development, and Trade: The Regulatory and Institutional Dimension, Cambodia Country Report". UNCTAD: New York.

United States Agency for International Development (USAID). 2005. "Measuring Competitive-ness and Labor Productivity in Cambodia's Garment Industry". Trade Developments paper.

______. 2009. "Garment Industry Productivity Center, Cambodia: Final Report".

Walque, D.D. 2004. "The Long-Term Legacy of the Khmer Rouge Period in Cambodia". World Bank Policy Research Working Paper 3446. World Bank: Washington, DC.

______. D.D. 2008. "Armed Conflict and Schooling: Long-term Evidence from Cambodia and Rwanda". Research Brief. World Bank: Washington, DC.

Warren, C. and R. Robertson. 2010. "Globalization, Wages, and Working Conditions: A Case Study of Cambodian Garment Factories". Honors Projects. Paper 25. Macalester College: St. Paul.

Wilson, R.A. and G. Briscoe. 2004. "The impact of education and training". In "The impact of Human capital on economic growth: a review". Third report on vocational training research in Europe: background report". Luxembourg: Office for Official Publications of the European Communities.

Woo, C. 2001. Industrial Upgrading of Korea: Process, Prospects, and Policies. In *Industrial Restructuring in East Asia: Towards the 21st Century*, pp. 256-306. Masuyama, S., D. Vandenbrik, C.S. Yue (eds.). 2001. ISEAS: Singapore.

World Bank. 1993. "The East Asian Miracle: Economic Growth and Public Policy". World Bank Policy Research Report. World Bank: Washington, DC.

______. 2000. "Higher Education in Developing Countries: Perils and Promise. The Task Force on Higher Education and Society". World Bank: Washington, DC.

______. 2005. "Corporate Responsibility and the Tourism Sector in Cambodia". World Bank: Washington, DC.

______. 2006. *World Development Report 2006: Equity and Development*. World Bank and Oxford University Press: New York.

______. 2007a. "Building Knowledge Economies: Advanced Strategies for Development". World Bank Development Studies. World Bank: Washington, DC.

______. 2007b. "An East Asian Renaissance: Ideas for economic growth". World Bank: Washington, DC.

______. 2008. "Doing Business in Cambodia 2008". World Bank: Washington, DC.

______. 2009a. "Doing Business in Cambodia 2009". World Bank: Washington, DC.

______. 2009b. "Sustaining Rapid Growth in a Challenging Environment: Cambodia Country Economic Memorandum". World Bank: Washington, DC.

______. 2010a. "Do Scholarships Help Students Continue their Education?" Note Series from Evidence to Policy. World Bank: Washington, DC.

______. 2010b. "Doing Business in Cambodia 2010". World Bank: Washington, DC.

______. 2010c. "Providing Skills and for Equity and Growth: Preparing Cambodia's Youth for the Labor Market". World Bank: Washington, DC.

World Travel & Tourism Council (WTTC). 2010a. "World Travel and Tourism Economic Impact 2010: Cambodia". WTTC: London.

______. 2010b. "World Travel and Tourism Economic Impact 2010: Laos". WTTC: London.

______. 2010c. "World Travel and Tourism Economic Impact 2010: Thailand". WTTC: London.

______. 2010d. "World Travel and Tourism Economic Impact 2010: Vietnam". WTTC: London.

Yue, C.S. 2001. "Singapore: Towards a Knowledge-based Economy". In *Industrial Restructuring in East Asia: Towards the 21st Century*, pp. 169-208. Masuyama, S., D. Vandenbrik, C.S. Yue (eds.). 2001. ISEAS: Singapore.

Zakaria, F. 2003. *The Future of Freedom: Illiberal Democracy at Home and Abroad*. W.W. Norton: New York.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ : យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា : បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៩-២០១៣

| *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩)*<br>*បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣* | |
|---|---|
| **គោលបំណងជាក់លាក់នៃយុទ្ធសាស្ត្រចតុកោណ** | យុទ្ធសាស្ត្រចតុកោណបានវិភាគ និងបញ្ចូលធាតុផ្សំសំខាន់ៗពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០១-២០០៥ (ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច II) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជាឆ្នាំ២០០៣-២០០៥ (យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ) និងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទម្រង់សំខាន់ៗដទៃ ទៀតដែលបានបង្កើតឡើងតាមរយៈការប្រឹក្សាយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ។ គោលបំណងចម្បងនៃយុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារប្រកបសមភាព និងប្រសិទ្ធភាព ជាការលើកកម្ពស់កំណើនសេដ្ឋកិច្ច ការបង្កើតនិកម្មភាពសម្រាប់ប្រជាជនកម្ពុជា ការធានាឱ្យមានសមធម៌ និងយុត្តិធម៌ក្នុងសង្គម និងការពង្រឹងប្រសិទ្ធភាពវិស័យសាធារណៈ តាមរយៈការអនុវត្តអភិបាលកិច្ច ផែនការសកម្មភាព និងកំណែទម្រង់ស៊ីជម្រៅដែលបានសម្របសម្រួល និងធ្វើឱ្យមានភាពស៊ីសង្វាក់គ្នានៅគ្រប់កម្រិត និងគ្រប់វិស័យទាំងអស់ ។ |
| **ស្នូលនៃយុទ្ធសាស្ត្រចតុកោណ** | **អន្តរាគមន៍តាមផ្នែក** |
| | **អភិបាលកិច្ចល្អ :** ស្នូលនៃយុទ្ធសាស្ត្រចតុកោណទាមទារឱ្យមានការចូលរួមជាសាធារណៈប្រកបដោយសមធម៌ និងយុត្តិធម៌ពីធាតុផ្សំលើកឡើងខាងលើនៅគ្រប់បញ្ហាទាំងអស់ តាមរយៈវិធីសាស្ត្របែបប្រជាធិបតេយ្យ និងសន្តិភាពដើម្បីធានាឱ្យមានការទទួលយក និងអនុវត្តឱ្យបានច្រើននូវឆន្ទៈ សេរី និងជម្រើសក្នុងការទទួលបានព័ត៌មានគ្រប់គ្រាន់ ខណៈពេលដែលសិទ្ធិ និងសុខុមាលភាពទទួលបានការការពារបានតិចតួច ។ |
| | ការប្រយុទ្ធប្រឆាំងអំពើពុករលួយ : រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតវិធីសាស្ត្ររួមមួយ ដើម្បីប្រយុទ្ធ ប្រឆាំងនឹងអំពើពុករលួយដែលវិធីសាស្ត្រនេះបានកំណត់ពីកម្រិតនៃក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ក៏ដូចជាសមត្ថភាពរបស់ស្ថាប័នដែលកំពុងដំណើរការ ជាពិសេសប្រព័ន្ធច្បាប់ និងតុលាការ ។ វិធីសាស្ត្រនេះបង្ហាញថា ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងត្រូវពង្រឹងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយដែលមានស្រាប់ ។ |

| *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩)<br>បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣* | |
|---|---|
| | **កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ :** រាជរដ្ឋាភិបាលប្តេជ្ញាចិត្តក្នុងការបង្កើនដំណើរការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលបានបង្កើត ឡើងនៅ ខែមិថុនា ឆ្នាំ២០០២ មានភារកិច្ចទទួលខុសត្រូវលើ "ការបង្កើត និងជំរុញដំណើរការ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតាមដានការអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ស្របតាមគោលដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ"។ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានគោលដៅយុទ្ធសាស្ត្រចំនួន៧ ដូចជា : (១) ការពង្រឹងការការពារសិទ្ធិ និងសេរីភាពបុគ្គល (២) ទំនើបកម្មក្របខ័ណ្ឌច្បាប់ (៣) ការផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានស្តីពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង (៤) ការបង្កើនឡើងនូវគុណភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ (៥) ការពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មអយ្យការ (៦) ការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (៧) ការពង្រឹងស្ថាប័នទាក់ទងនឹងវិស័យច្បាប់ និងយុត្តិធម៌ឱ្យបំពេញអាណត្តិរបស់ខ្លួន។ |
| | **កំណែទម្រង់រដ្ឋបាលសាធារណៈ :** រដ្ឋបាលសាធារណៈជាមធ្យោបាយយុទ្ធសាស្ត្រមួយសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ។ ចាប់តាំងពី ឆ្នាំ២០០០ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានអនុវត្តកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលជាច្រើនដើម្បីប្រែក្លាយសេវារដ្ឋបាល និងសេវាស៊ីវិលតាមលក្ខណៈ ប្រព័ន្ធ និងបន្តិចម្តងៗឱ្យក្លាយទៅជាអ្នកផ្តល់សេវាសាធារណៈដែលមានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ប្រកបដោយទំនុកចិត្ត។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងបន្តអនុវត្តកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល ដើម្បីកែប្រែ សេវារដ្ឋបាល និងសេវាស៊ីវិលឱ្យក្លាយទៅជាអ្នកផ្តល់សេវាសាធារណៈដែលមានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍន៍ប្រកបដោយទំនុកចិត្ត។<br>កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ : ដើម្បីសម្រេចបានការអភិវឌ្ឍដ៏ទូលំទូលាយ និងមាននិរន្តរភាព និងដើម្បីពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចថ្នាក់តំបន់ឱ្យមានភាពរឹងមាំ ប្រជាជន ទាំងអស់ត្រូវមានឱកាសស្មើគ្នាចូលរួមក្នុងការអភិវឌ្ឍក្នុងតំបន់ គ្រប់គ្រងបរិស្ថាន និងធនធាន ធម្មជាតិប្រកបដោយប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាពដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ និងដើម្បីកាត់បន្ថយភាពក្រីក្រដោយផ្តោតការយកចិត្តទុកដាក់លើក្រុមងាយរងគ្រោះក្រុមជនជាតិភាគតិច ស្ត្រី និងកុមារ។ |
| | **កំណែទម្រង់កងយោធពលខេមរភូមិន្ទ :** កំណែទម្រង់កងយោធពលខេមរភូមិន្ទដែលជាមុំមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទាមទារឱ្យកងយោធពលខេមរភូមិន្ទឆ្លើយតបប្រកបដោយប្រសិទ្ធភាពក្នុងកំណែទម្រង់របស់ខ្លួនដើម្បីធានាឱ្យមានសន្តិភាព ស្ថិរភាព សន្តិសុខ អធិបតេយ្យភាព បូរណភាពទឹកដី និងការអភិវឌ្ឍជាតិបានពេញលេញ។ ផ្អែកលើ "របាយការណ៍ ស្តីពីការការពារ" ដែលជួយចង្អុលបង្ហាញដល់កងយោធពលខេមរភូមិន្ទក្នុងការអនុវត្តគោលនយោបាយការពាររាជរដ្ឋាភិបាលកម្ពុជាឱ្យបានជោគជ័យ ការធ្វើកំណែទម្រង់ និងការពង្រឹងសមត្ថភាពបន្ថែមរបស់កងកម្លាំងប្រដាប់អាវុធកំពុងដំណើរការដោយផ្អែកលើផែនការកាត់វិសាយកងកម្លាំងប្រដាប់អាវុធ និងការបង្កើតកងកម្លាំងប្រដាប់អាវុធឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ |

<table>
<tr><th colspan="2">យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩)<br>បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣</th></tr>
<tr><td>១. ការពង្រឹងវិស័យកសិកម្ម</td><td>ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម : "ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យកសិកម្ម : ឆ្នាំ២០០៦-២០១០" បានកំណត់គោលដៅយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ៧ ដូចខាងក្រោម :<br>• សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម។<br>• លើកកម្ពស់ និងពង្រឹងប្រព័ន្ធស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម។<br>• ការផ្តល់ឱ្យមានទីផ្សារសម្រាប់ផលិតផលកសិកម្ម។<br>• ក្របខ័ណ្ឌអភិវឌ្ឍន៍ស្ថាប័ន និងច្បាប់។<br>• កំណែទម្រង់ដីធ្លី - ការអភិវឌ្ឍទីផ្សារអចលនទ្រព្យ និងការគាំទ្រការផ្តល់ដីធ្លីដល់ប្រជាជនក្រីក្រ។<br>• កំណែទម្រង់នេសាទ និងជលផល-ការទទួលបានប្រកបដោយនិរន្តរភាព។<br>• កំណែទម្រង់ព្រៃឈើ-លើកកម្ពស់ការអភិរក្ស និងគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពធានាឱ្យមានការគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យបានកាន់តែប្រសើរ។<br><br>ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រទាំង៧នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសកម្មភាពនានាក្នុងកម្មវិធីទាំង៥ ដូចខាងក្រោម :<br><br>កម្មវិធី ១ : ការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម។<br>កម្មវិធី ២ : ការលើកកម្ពស់ការផ្តល់ឱ្យមានទីផ្សារសម្រាប់ផលិតផលកសិកម្ម។<br>កម្មវិធី ៣ : ការពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និងការអភិវឌ្ឍធនធានមនុស្ស។<br>កម្មវិធី ៤ : ការគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព។<br>កម្មវិធី ៥ : ការគ្រប់គ្រងធនធានព្រៃឈើឱ្យមាននិរន្តរភាព។</td></tr>
</table>

| យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩) បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ | |
| --- | --- |
| | **កំណែទម្រង់ដីធ្លី និងការបោសសម្អាតគ្រាប់មីន :** សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលបានផ្តោតជាសំខាន់លើការពង្រឹងសុវត្ថិភាពក្នុងផ្តល់កម្មសិទ្ធិលើដីរដ្ឋ ដីឯកជន និងដីរបស់សហគមន៍ជនជាតិភាគតិចតាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ដើម្បីចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនដល់ប្រជាជនទូទៅ ស្ថាប័ន និងសហគមន៍ជនជាតិដើមភាគតិចដែលមានសិទ្ធិកាន់កាប់ដី ។ ដើម្បីពង្រឹងការគ្រប់គ្រងដីធ្លី គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងគតិយុត្តិដែលចាំបាច់សម្រាប់អនុវត្តច្បាប់ភូមិបាលឱ្យមានប្រសិទ្ធភាព ក៏បានបង្កើត និងអនុម័តផងដែរ ។ ការងារដែលសម្រេចបាននាពេលកន្លងមក រួមមាន : (ក) អនុក្រឹត្យស្តីការគ្រប់គ្រងដីរដ្ឋ (ខ) អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិ ដើមភាគតិច (គ) អនុក្រឹត្យស្តីពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីឃុំ (ឃ) អនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អាគារសហកម្មសិទ្ធិ (ង) សារាចរស្តីពីការកាន់កាប់ដីរដ្ឋខុសច្បាប់ (ច) ប្រកាសរួមស្តីពីការធ្វើអត្តសញ្ញាណកម្មចំណាត់ថ្នាក់ និងផែនទីដីរដ្ឋ (ឆ) ប្រកាសរួមស្តីពីយន្តការ សម្រាប់ផ្តល់សេវាផ្សព្វផ្សាយពីកសិកម្មដល់កសិករ ដោយប្រើប្រាស់ដីសម្បទានសង្គម (ជ) សេចក្តីណែនាំរួមស្តីពីការពង្រឹងការអនុវត្តការងាររបស់គណៈកម្មាការសុរិយោដីនៅគ្រប់លំដាប់ថ្នាក់ (ឈ) សេចក្តីព្រាងច្បាប់ស្តីពីការផ្តល់សិទ្ធិភោគៈរបស់អង្គភាពឯកជនលើអាគារសហកម្មសិទ្ធិដល់ជនបរទេស (សេចក្តីព្រាងច្បាប់នេះកំពុងស្នើសុំការអនុម័តពីស្ថាប័នច្បាប់) ។ |
| | **កំណែទម្រង់ជលផល :** ច្បាប់ជលផលថ្មីត្រូវបានប្រកាសឱ្យចូលជាធរមាននៅខែឧសភា ឆ្នាំ២០០៦ ។ ដោយសារតែវិស័យជលផលបានធ្វើកំណែទម្រង់សំខាន់ៗ បច្ចុប្បន្នវិស័យជលផលមានវិធីសាស្ត្រ ជាច្រើនដែលផ្តោតលើភាពក្រីក្រ ។ ផែនការជាច្រើនបានបង្កើតឡើងដោយផ្អែកលើក្រមសីលធម៌កម្ពុជាសម្រាប់វិស័យជលផលដែលមានការទទួលខុសត្រូវខ្ពស់ ។ ចាប់តាំងពីមានការអនុញ្ញាតឱ្យប្រើប្រាស់ឡូត៍នេសាទសម្រាប់សហគមន៍មកមានសហគមន៍នេសាទចំនួន ៤៦៨ បានបង្កើតឡើង (សហគមន៍ចំនួន ៤៣៣ ជាសហគមន៍នេសាទទឹកសាប និងសហគមន៍ចំនួន ៣៥ ជាសហគមន៍នេសាទ ទឹកប្រៃ) ដែលក្នុងនោះសហគមន៍ចំនួន ១៧៣ បានចុះឈ្មោះបញ្ជីដោយស្របច្បាប់នៅ ខែតុលា ឆ្នាំ២០០៨ ។ លើសពីនេះទៀត សហគមន៍ជម្រកមច្ឆាចំនួន ២៣៥ ក៏បានបង្កើតឡើងដែលភាគច្រើននៅតាមតំបន់ដាច់ស្រយាលឆ្ងាយពីប្រភពទឹកសំខាន់ៗ ។ |
| | **កំណែទម្រង់ព្រៃឈើ :** ការដាំព្រៃឈើឡើងវិញ/ការដាំដើមឈើ ការបង្កើតសហគមន៍ព្រៃឈើការកំណត់ព្រំប្រទល់ព្រៃឈើ ការស្រាវជ្រាវ និងអភិរក្សសត្វព្រៃ និងព្រៃឈើ និងការបង្កើតកម្មវិធីព្រៃឈើជាតិត្រូវបានអនុវត្តយ៉ាងសកម្មតាមការគ្រោងទុក ចំណែករដ្ឋបាលព្រៃឈើ ក្នុងនាម ជារាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដំណើរការគម្រោងឥណទានកាបូនព្រៃឈើកម្ពុជា (Cambodian Forest Carbon Credit) តាមរយៈការអនុវត្តគម្រោងគំរូមួយស្តីពីឥណទាន កាបូន (Carbon Credit) សម្រាប់សហគមន៍ព្រៃឈើក្នុងខេត្តបន្ទាយមានជ័យ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទ និងដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងកំណើនកំដៅពិភពលោក ។ ក្នុងការបង្កើតនិកម្មភាពក្នុងវិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ និងឯកភាពថា វិស័យឯកជនជាវិស័យដ៏សំខាន់ដែលជាក្បាលម៉ាស៊ីនចម្បងក្នុងការវិនិយោគ និងកំណើនក្នុងប្រទេសកម្ពុជា ។ តួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាគឺជាអ្នកជំរុញអ្នកលើកកម្ពស់អ្នកបង្កើនអ្នកសម្របសម្រួល និងជានិយ័តករ ។ |

| *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩) បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣* | |
|---|---|
| **២. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត** | **ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ :** ក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ រូបវ័ន្ត មានការអភិវឌ្ឍជាច្រើនទាក់ទងនឹងបណ្តាញផ្លូវជាតិ កំពង់ផែ និងអាកាសយានដ្ឋានសំខាន់ៗដែលមានរួចជាស្រេចដើម្បីភ្ជាប់បណ្តាញគមនាគមន៍ទៅគ្រប់ផ្នែកទាំងអស់ក្នុងប្រទេសរួមទាំងប្រទេសជិតខាងផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ក្នុងការធានាឱ្យមានការថែទាំបណ្តាញគមនាគមន៍ឱ្យបានសមស្រប និងបានជំរុញ និងលើកកម្ពស់ដល់ការចូលរួមពីវិស័យឯកជនក្នុងដំណើរការអភិវឌ្ឍ និងការថែរក្សាបណ្តាញគមនាគមន៍នេះ ។ |
| | **ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ :** ក្រសួងធនធានទឹក និងឧតុនិយមបានទទួលជោគជ័យគួរឱ្យកត់សម្គាល់ក្នុងអំឡុងឆ្នាំ២០០៦-២០០៨ ក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដើម្បីពង្រីកសមត្ថភាពប្រព័ន្ធធារាសាស្ត្រ និងដើម្បីការពារទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិ (ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត) ដែលមិនអាចព្យាករណ៍បានដោយសារតែការប្រែប្រួលអាកាសធាតុ ។ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកបានអនុម័ត និងចូលជាធរមាននៅ ខែមិថុនា ឆ្នាំ២០០៧ ។ |
| | **ការអភិវឌ្ឍវិស័យថាមពល :** ដើម្បីជំរុញឱ្យមានការអភិវឌ្ឍវិស័យថាមពលផែនការអភិវឌ្ឍន៍វិស័យថាមពលឆ្នាំ២០០៥-២០២៤ ត្រូវបានរៀបចំឡើង ។ ផែនការមេស្តីពីអគ្គិសនីភាវូបនីយកម្មជនបទដែលផ្តោតលើការប្រើប្រាស់ថាមពលកកើតឡើងវិញក៏បានរៀបចំ និងកំពុងតែអនុវត្តផងដែរ ។ ធនធានប្រេង និងឧស្ម័នក្នុងសមុទ្រជាទ្រព្យសម្បត្តិរួមរបស់ប្រជាជនកម្ពុជាទាំងអស់នាពេលបច្ចុប្បន្ន និងអនាគត ។ |
| | ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ : បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ រួមមាន ទូរស័ព្ទ និងទូរគមនាគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ ។ ដោយមានការកើនឡើងនូវការប្រកួតប្រជែង និងការគ្រប់គ្រងដោយផ្នែកឯកជនជាច្រើនកម្ពុជាមានភាពរីកចម្រើនក្នុងការប្រើប្រាស់ទូរស័ព្ទដៃ ។ |

| *យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩) បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣* | |
|---|---|
| **៣. ការអភិវឌ្ឍ វិស័យឯកជន និងការបង្កើតនិកម្មភាព** | **ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ :** វេទិការដ្ឋាភិបាល-វិស័យឯកជន ដែលធ្វើ ឡើងជារៀងរាល់ ៦ខែម្តង ក៏ដូចជាគណៈកម្មាធិការដឹកនាំការងារ និងអនុគណៈកម្មាធិការ ជាច្រើនទៀត បានផ្តល់នូវកិច្ចសហការ និងការយោគយល់គ្នាដ៏សំខាន់រវាងរដ្ឋាភិបាល និងវិស័យ ឯកជនប្រកបដោយអត្ថន័យ ។ លើសពីនេះ ក៏មានការបង្កើតក្រុមការងារសម្រាប់លើកកម្ពស់ទំនាក់ទំនងរវាងនិយោជក និងនិយោជិតផងដែរ ។ ដើម្បីកាត់បន្ថយឧបសគ្គក្នុងការស្វែងរកការឯកភាពពីក្រសួងសាមី និងទីភ្នាក់ងាររាជរដ្ឋាភិបាលបានបង្កើតយន្តការ "ច្រកចេញចូលតែមួយ" ដោយអ្នកវិនិយោគទុនអាចទទួលបានការយល់ព្រមជាកញ្ចប់ពេញលេញលើលក្ខខណ្ឌទាំងអស់ដែលខ្លួនបានស្វែងរកការយល់ព្រមលើពាក្យស្នើសុំធ្វើការវិនិយោគ ។ CIB/CDC ក៏បានបង្កើតនូវយន្តការ "Investor Aftercare" និង "Investor Tracing System" ដើម្បីដោះស្រាយបញ្ហា ប្រឈមដែលអ្នកវិនិយោគជួបប្រទះ និងដើម្បីត្រួតពិនិត្យលើភាពរីកចម្រើនក្នុងការបង្កើតគម្រោង វិនិយោគដែលបានអនុម័តយល់ព្រមរួច ។ ក្រសួងពាណិជ្ជកម្មបាន និងកំពុងរៀបចំនីតិវិធីក្នុងការចុះ បញ្ជីអាជីវកម្មថ្មីតាមរយៈការផ្តល់ព័ត៌មានទីផ្សារ ការរៀបចំសមាគមផលិតផល ការអនុវត្តកម្មវិធី "រោងចក្រល្អប្រសើរ" ការសម្របសម្រួល និងលើកកម្ពស់ពាណិជ្ជកម្ម និងការពង្រឹងច្បាប់ ស្តីពីកម្មសិទ្ធិបញ្ញា ។ |
| | **ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរ :** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាន និងកំពុងផ្តល់សេវារកការងារដើម្បីជួយដល់អ្នកកំពុងស្វែងរកការងារតាមស្ថាប័នឯកជនក្នុងប្រទេស និងក្រៅប្រទេស ។ ដើម្បីធានាឱ្យមានលក្ខខណ្ឌការងារល្អប្រសើរក្រសួងបានបន្ត ផ្តោតការយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តច្បាប់ការងារ និងបទប្បញ្ញត្តិផ្សេងៗ ការផ្សព្វផ្សាយព័ត៌មានស្តីពីច្បាប់ការងារការត្រួតពិនិត្យលើលក្ខខណ្ឌការងារ អនាម័យ និងសុវត្ថិភាពការងារ ពលកម្មកុមារ និងនិយោជិតបរទេសក្នុងការធ្វើពាណិជ្ជកម្មនៅទូទាំងប្រទេស ។ |
| | **ការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម :** ការងារដែលបានគ្រោងទុកជាមុន នឹងផ្តោតលើ ចំណុចសំខាន់បី ដូចជា (១) ក្របខ័ណ្ឌច្បាប់ និងនិយ័តកម្ម - ការកំណត់ពីនីតិវិធី និងគោលការណ៍ក្នុងការត្រួតពិនិត្យ និងបញ្ជាក់ពីផលិតផលនាំចូល និងនាំចេញដោយមិនមានការបញ្ជាក់ពីគុណភាពផលិតផលដែលចាំបាច់ ការរៀបចំ និងអនុម័តអនុក្រឹត្យស្តីពីការសម្របសម្រួលធុរកិច្ចតាមរយៈវិធីសាស្ត្រគ្រប់គ្រងហានិភ័យ និងការជំរុញឱ្យមានការចុះបញ្ជីតាមប្រព័ន្ធអ៊ីនធើរណិត (២) ការផ្តល់ហិរញ្ញប្បទាន ការបង្កើតក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុការបែងចែកប្រភេទក្រុមហ៊ុនតាមលទ្ធភាពផ្តល់ឥណទាន និងការពង្រឹងអភិបាលកិច្ច និងរបាយការណ៍ហិរញ្ញវត្ថុ និង(៣) សកម្មភាពគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម - ការបង្កើតសេវាថ្មីមួយស្តីពីការបង្កើតធុរកិច្ចថ្មីមួយការទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ ការផ្តល់ឧបត្ថម្ភធនដល់សហគ្រាសធុនតូច និងមធ្យមលើការនាំចេញ និងការបញ្ចូលសហគ្រាសធុនតូច និងមធ្យមទៅក្នុងខ្សែសង្វាក់តម្លៃជាសកល ។ ការអនុម័ត និងជំរុញចលនា "ភូមិមួយផលិតផលមួយ" គឺជាវិធានការមួយក្នុងចំណោមវិធានការជាច្រើនដទៃទៀតដែលត្រូវអនុវត្ត ។ |

| យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩) បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ | |
|---|---|
| | **ការរៀបចំបណ្តាញសុវត្ថិភាពសង្គម ៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានតួនាទីគ្រប់គ្រងដំណើរការ និងប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់អ្នកដែលមិនទទួលបានការពារពីច្បាប់ការងារ ។ មូលនិធិរបបសន្តិសុខសង្គម និងមូលនិធិសុវត្ថិភាពសង្គមជាតិសម្រាប់មន្ត្រីរាជការត្រូវបានបង្កើតឡើង ។ គណៈកម្មាធិការជាតិដោះស្រាយបញ្ហាប្រជាជនគ្មានទីជម្រកនៅថ្នាក់ជាតិ និងអនុគណៈកម្មាធិការដោះស្រាយបញ្ហាប្រជាជនគ្មានទីជម្រកនៅកម្រិតក្រុងថ្នាក់ក្រោមជាតិក៏បានបង្កើតឡើងផងដែរ ។ សិទ្ធិជាមូលដ្ឋាន ៤ របស់កុមារបានបញ្ជ្រាបចូលទៅក្នុងកម្មវិធីដែលដាក់ចេញដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងផ្តល់កម្មវិធីអប់រំស្តីពីការប្រព្រឹត្តបទល្មើស និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀនដល់កុមារ និងយុវជនវ័យជំទង់នៅទូទាំងប្រទេស ។ |
| **៤. ការកសាង សមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស** | **ការពង្រឹងគុណភាពអប់រំ ៖** ជាចុងក្រោយចតុកោណស្តីពី "កំណើន" នៃយុទ្ធសាស្ត្រចតុកោណគ្របដណ្តប់ភាគច្រើនលើវិស័យឯកជន ដូចជា (១) ការពង្រឹងគុណភាពអប់រំ (២) ការធានាឱ្យមានសេវាសុខភាពល្អប្រសើរ (៣) ការអនុវត្តគោលនយោបាយយេនឌ័រ និង (៤) ការអនុវត្តគោលនយោបាយប្រជាជន ។ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងក្នុងវិស័យអប់រំ និងសុខាភិបាលនៅពេលដែលយន្តការសហប្រតិបត្តិការ និងសម្របសម្រួលរវាងភាគីពាក់ព័ន្ធជាច្រើនបានចាប់ផ្តើមអនុវត្ត បើទោះបីជាមានការការណែនាំឱ្យអនុវត្តយន្តការ TWG នៅចុងឆ្នាំ២០០៣ ពីមុនមកក៏ដោយ ។ យុទ្ធសាស្ត្រតាមវិស័យក្នុងវិស័យសំខាន់ទាំងពីរនេះកំពុងបានបង្កើត និងអនុវត្តបានយ៉ាងរលូន ហើយភាពរីកចម្រើនទទួលបានពីការអនុវត្តយុទ្ធសាស្ត្រនេះបានត្រួតពិនិត្យយ៉ាងទៀងទាត់ និងទាន់ពេលវេលា ។ |
| | **ការលើកកម្ពស់សេវាសុខាភិបាល៖** ការលើកកម្ពស់ការផ្តល់សេវាសុខាភិបាលមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ។ ចាប់តាំងពីពេលមុនមករាជរដ្ឋាភិបាលកម្ពុជាបានបង្កើតវិធីសាស្ត្រគ្រប់គ្រងដែលគ្របដណ្តប់ទូទាំងវិស័យសុខាភិបាល ដើម្បីជួយដល់ការអភិវឌ្ឍវិស័យនេះ ។ ដំណើរការនៃកិច្ច ពិភាក្សាជាមួយដៃគូសហការអភិវឌ្ឍ បានចាប់ផ្តើមអនុវត្តក្នុង ឆ្នាំ១៩៩៩ ចំណែកការបូកសរុប វាយតម្លៃលើវិស័យសុខាភិបាលជារួមបានធ្វើឡើងនៅឆ្នាំ២០០០ ។ បន្ទាប់មកផែនការយុទ្ធសាស្ត្រសុខាភិបាលក៏បានរៀបចំបង្កើតឡើងផងដែរ ។ ផែនការនេះ ផ្តល់ក្របខ័ណ្ឌសម្រាប់ដៃគូសហការអភិវឌ្ឍចំនួន៣ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី DFID និងធនាគារពិភពលោក ដើម្បីសម្របសម្រួលការផ្តល់ធនធានហិរញ្ញប្បទានដល់វិស័យសុខាភិបាល តាមរយៈកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលសម្រាប់ឆ្នាំ២០០៣-២០០៧ ។ ការពិនិត្យវាយតម្លៃដ៏ទូលំទូលាយនៃកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧ បានធ្វើឡើង ហើយកម្មវិធីទ្រទ្រង់វិស័យសុខាភិបាលឆ្នាំ ២០០៨-២០១៥ ក៏បានបង្កើតឡើងដោយផ្តោតលើលទ្ធផលរកឃើញពីការពិនិត្យវាយតម្លៃនេះ ។ ការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ២ បានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៨ ។ ការពិនិត្យ វាយតម្លៃការងាររួមប្រចាំឆ្នាំត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ២០០២ ដើម្បីវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ។ |

| យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០០៩)<br>បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ | |
|---|---|
| | **ការអនុវត្តគោលនយោបាយយេនឌ័រ :** តាមរយៈការអនុវត្តកម្មវិធីនារីរតនៈ II របស់រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០០៤-២០០៨) ដោយក្រសួងកិច្ចការនារី គេឃើញមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើនក្នុងការឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបង្កើនតម្លៃដល់ការគាំទ្រដែលផ្តល់ដោយដៃគូសហការអភិវឌ្ឍ និងអង្គការជាតិ និងអន្តរជាតិក្នុងការអនុវត្តកម្មវិធីនារីរតនៈ II ។ កម្មវិធីនារីរតនៈ II ផ្តោតលើវិស័យអាទិភាពដូចខាងក្រោម :<br>• ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច<br>• ការលើកកម្ពស់ការអប់រំស្ត្រី និងកុមារី<br>• ការការពារស្ត្រី និងកុមារីតាមផ្លូវច្បាប់<br>• ការលើកកម្ពស់សុខភាពស្ត្រី និងកុមារី<br>• ការលើកទឹកចិត្តដល់ស្ត្រីក្នុងការសម្រេចចិត្ត<br>• ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយជាតិ និងកម្មវិធី ។ |
| | **ការអនុវត្តគោលនយោបាយប្រជាជន :** គោលនយោបាយប្រជាជនគាំទ្រដល់សកម្មភាព និងមានការ រៀបចំបានល្អ រួមមានសកម្មភាពនានាក្នុងវិស័យជាច្រើន ដូចជា វិស័យសុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច យេនឌ័រ អន្តោប្រវេសន៍ យុវជន មនុស្សចាស់ និងវិស័យផ្សេងទៀត។ គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍបាន និងកំពុងខិតខំពង្រឹងធនធានមនុស្សដើម្បីបញ្ចូលបញ្ហាទាក់ទងនឹងប្រជាជនទៅក្នុងដំណើរការផែនការអភិវឌ្ឍនៅគ្រប់កម្រិតទាំងអស់សម្រាប់អ្នករៀបចំផែនការ និងអ្នកបង្កើតគោលនយោបាយ ។ គណៈកម្មការបានបង្កើតឯកសារយោងប្រជាជនស្តីពីគោលនយោបាយជាតិប្រជាជន តារាងតទិន្នន័យប្រជាជន នគរូបនីកម្ម ការធ្វើចំណាកស្រុក យុវជន មនុស្សចាស់ និងសូចនាករគោលនយោបាយជាតិប្រជាជន។ ឯកសារ យោងទាំងនេះត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយពីគោលនយោបាយជាតិប្រជាជន និងទំនាក់ទំនងប្រជាជន និងការអភិវឌ្ឍទៅនឹងសភារដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាននៅទូទាំង ២៤ខេត្តក្រុង និងរាជធានីភ្នំពេញ។ |

## ឧបសម្ព័ន្ធ ២៖ ប្រទេសកម្ពុជាក្នុងផែនទីយុទ្ធសាស្ត្រស្ដីពីមូលធនមនុស្ស និងអន្តរាគមន៍ដែលអាចធ្វើទៅបាន

*តារាងសង្ខេបគម្រោង*

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| ការធ្វើអន្តរាគមន៍ភ្លាមៗ | | | | | | | |
| **ការឆ្លើយតបនឹងវិបត្តិ និងការធ្វើឱ្យមានភាពប្រសើរឡើងវិញ** | ការកាត់បន្ថយភាពក្រីក្រ | ការកាត់បន្ថយចំនួនប្រជាជនងាយរងគ្រោះបំផុត<br>ការកាត់បន្ថយភាពប្រឈមរបស់ប្រជាជនងាយរងគ្រោះបំផុតទៅនឹងផលប៉ះពាល់នៃសេដ្ឋកិច្ចពិភពលោក<br>ការធានាឱ្យមានការដាក់បញ្ចូលអ្នកងាយរងគ្រោះបំផុតទៅក្នុងផែនការអភិវឌ្ឍន៍មូលធនមនុស្សដើម្បីប្រទេសកម្ពុជា<br>ការធានាដល់សមត្ថភាពរបស់ប្រជាជនងាយរងគ្រោះក្នុងការរក្សាជីវភាពរស់នៅរបស់ពួកគេ។ | ចំនួនប្រជាជនដែលរិតនៅក្រោមខ្សែបន្ទាត់ក្រីក្រខ្លាំង<br>ចំនួនប្រជាជនដែលមានការងារធ្វើជាផ្លូវការ<br>ចំនួនប្រជាជនដែលទទួលបានជំនួយពីរដ្ឋាភិបាល និងចូលរួមក្នុងកម្មវិធីគាំទ្ររបស់រដ្ឋាភិបាល<br>អត្រានៃការអភិវឌ្ឍវិស័យឧស្សាហកម្មអត្រាកំណើននិងការវិនិយោគផ្ទាល់ពីបរទេស | របាយការណ៍រដ្ឋាភិបាល និងតួលេខ<br>របាយការណ៍ម្ចាស់ជំនួយ<br>របាយការណ៍វាយតម្លៃ និងអង្កេតលើកំណើន<br>អនិកម្មភាព និង ការអង្កេតតាមដានលើចំណូល និងចំណាយក្នុងគ្រួសារ | ការខកខានមិនបានបែកចែកសភាគកម្មនៃការគាំទ្រដល់រដ្ឋាភិបាល<br>ការខកខានក្នុងការកំណត់ពីប្រជាជនងាយរងគ្រោះបំផុត<br>ការមិនព្រមព្រៀងក្នុងវិស័យឯកជន ការមិនមានចក្ខុវិស័យវែងឆ្ងាយដើម្បីដាក់បញ្ចូលប្រជាជនងាយរងគ្រោះបំផុតទៅក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា | ក្រសួងជាច្រើនក្នុងរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ | ៦ខែក្រោយ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និង វិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនបណ្តាញសុវត្ថិភាពសង្គម និងការធានាឱ្យមានហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់បណ្តាញសុវត្ថិភាព | ការរក្សាប្រាក់ចំណូលឱ្យមាននិរន្តរភាព ទោះបីជាមានផលប៉ះពាល់សេដ្ឋកិច្ច ឬវិស័យឧស្សាហកម្មនៅមានភាពទន់ខ្សោយ<br>ការរក្សាប្រាក់ចំណូលឱ្យមាននិរន្តរភាពទោះបីមានការផ្លាស់ប្តូរការកំណត់ទិសដៅវិស័យឧស្សាហកម្ម<br>ការកាត់បន្ថយភាពងាយរងគ្រោះនៃអនិកម្មភាព<br>ការបង្កើនសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាគាំទ្រសង្គមដោយមានហិរញ្ញប្បទានដែលមាននិរន្តរភាព | ការកើនឡើងនៃចំនួនហិរញ្ញប្បទានរបស់រដ្ឋាភិបាលទៅលើបណ្តាញសុវត្ថិភាពសង្គម និងសេវាគាំទ្រសង្គម<br>ចំនួនអ្នកទទួលផលដែលទទួលបានហិរញ្ញប្បទានតាមរយៈសេវាគាំទ្រសង្គមក្នុងពេលមានវិបត្តិ<br>ការបង្កើនចំនួនកម្មវិធីដើម្បីរក្សាគោលនយោបាយបណ្តាញសុវត្ថិភាពសង្គមឱ្យមាននិរន្តរភាព | របាយការណ៍ស្ថិតិស្តីពីការទទួលបានប្រព័ន្ធគាំទ្រសង្គម<br>ផែនការអភិវឌ្ឍជាតិ<br>របាយការណ៍ត្រួតពិនិត្យ<br>ការអង្កេតលើអ្នកទទួលផល | ការបែងចែកសេវាគាំទ្រសង្គមមិនស្មើភាពគ្នា<br>មិនមានការផ្លាស់ប្តូរក្នុងការផ្តល់ប្រព័ន្ធ និងកម្មវិធីបណ្តាញសុវត្ថិភាពសង្គម<br>ការថយចុះ ឬកង្វះខាតការគាំទ្រពីដៃគូអភិវឌ្ឍន៍ | ក្រសួងហិរញ្ញវត្ថុ ក្រសួងផែនការ ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១២ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការដោះស្រាយបញ្ហាចំណាកស្រុកក្នុងប្រទេស | ប្រព័ន្ធគាំទ្រកាន់តែប្រសើរសម្រាប់អ្នក ធ្វើចំណាកស្រុកទៅកាន់តំបន់ថ្មី<br>កិច្ចសហការដ៏ល្អរវាងរដ្ឋាភិបាល និងវិស័យឯកជនដើម្បីបង្កើតនិកម្មភាពដល់ជនចំណាកស្រុក<br>ការផ្តល់ឱកាសដល់ជនចំណាកស្រុកឱ្យទទួលបានការអប់រំ<br>ការបង្កើនភាពងាយស្រួលដល់អកធ្វើការក្នុងការផ្លាស់ប្តូរការងារពី វិស័យមួយទៅវិស័យមួយផ្អែកលើជំនាញនិងសមត្ថភាព | តួលេខស្ថិតិពីការធ្វើចំណាកស្រុក និកម្មភាព និងកំណើនសេដ្ឋកិច្ច<br>អត្រាលំហូរចូល និងចេញនៃការវិនិយោគពីបរទេសចំនួនកម្មវិធីគាំទ្ររបស់រដ្ឋាភិបាលទាក់ទងនឹងជនចំណាកស្រុក<br>តួលេខស្ថិតិពីជំនាញ និងកម្រិតនៃការអប់រំរបស់អ្នកធ្វើការជាជនចំណាកស្រុក | របាយការណ៍របស់រដ្ឋាភិបាលរបាយការណ៍ស្ថិតិនិកម្មភាព<br>ទិន្នន័យជំរឿន<br>ការអង្កេតលើជនចំណាកស្រុក<br>របាយការណ៍ត្រួតពិនិត្យ<br>របាយការណ៍របស់ដៃគូអភិវឌ្ឍន៍ | ជនចំណាកស្រុកដែលមិនមានបំណង ឬមិនមានចំណាប់អារម្មណ៍ចូលរួមក្នុងកម្មវិធីគាំទ្រផ្សេងៗ<br>ការមិនមានសមត្ថភាពផ្តល់ភាពងាយស្រួលដល់ជនចំណាកស្រុកឱ្យទទួលបានការបណ្តុះបណ្តាល និងបង្កើន ជំនាញបានជាលក្ខណៈប្រព័ន្ធ<br>ការមិនមានកិច្ចសហការគ្រប់គ្រាន់ជាមួយដៃគូអភិវឌ្ឍន៍ | ក្រសួងការងារវិស័យឯកជនដៃគូអភិវឌ្ឍន៍ | ១ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការលើកកម្ពស់ការអភិវឌ្ឍ និងកិច្ចសហការក្នុងវិស័យ ឯកជន | ការធានាឱ្យមានលំហូរចូលនៃការវិនិយោគផ្ទាល់បរទេសប្រកបដោយនិរន្តរភាពតាមរយៈបរិយាកាសវិនិយោគអំណោយផល<br>ការធានាឱ្យបាននូវផលិតកម្មដ៏រឹងមាំផ្អែកលើឧស្សាហកម្ម<br>ការធ្វើកិច្ចសន្ទនាជាប្រចាំរវាងវិស័យឯកជន និងរដ្ឋាភិបាល<br>ការរក្សាឱ្យបាននូវកំណើនរួមនៃសេដ្ឋកិច្ចកម្ពុជា<br>ការដោះស្រាយភាពខ្វះចន្លោះនៃជំនាញ និងព័ត៌មានស្តីពីទីផ្សារការងារ | អត្រាលំហូរចូលនៃការវិនិយោគពីបរទេសមកក្នុងប្រទេសកម្ពុជា<br>តួលេខស្តីពីនិកម្មភាពពិពិធភាវូបនីយកម្ម ឧស្សាហកម្ម និងកំណើន<br>អត្រានៃការវិនិយោគរួមនៃសេដ្ឋកិច្ចកម្ពុជា<br>ចំនួនអ្នកធ្វើការដែលសមស្របតាមជំនាញ និងតម្រូវការសមត្ថភាព ការងារ | របាយការណ៍ស្តីពីនិកម្មភាពកំណើន និងឧស្សាហកម្ម<br>ការអង្កេតលើវិស័យឧស្សាហកម្ម<br>របាយការណ៍របស់ដៃគូអភិវឌ្ឍន៍<br>ការត្រួតពិនិត្យ និងវាយតម្លៃ | ការអភិវឌ្ឍវិស័យដែលបានជ្រើសរើសដោយមិនមានពិពិធភាវូបនីយកម្មលើសេដ្ឋកិច្ច<br>ការមិនមានកិច្ចពិភាក្សាបានគ្រប់គ្រាន់រវាងរដ្ឋាភិបាល និងវិស័យឯកជន<br>ការបន្តផលប៉ះពាល់ពីខាងក្រៅ<br>ការមិនមានពលករដែលមានជំនាញគ្រប់គ្រាប់<br>ក្រុមហ៊ុនបរទេសមិនសូវមានចំណាប់អារម្មណ៍ចំពោះការវិនិយោគក្នុងប្រទេសកម្ពុជា | ក្រសួងជាច្រើន វិស័យឯកជន | ១ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| **ការដោះស្រាយអនិកម្មភាព** | ការកំណត់ប្រជាជន និងសហគមន៍គោលដៅនៅតាមជនបទ និងក្រីក្រ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចខ្លាំងបំផុត | ការកាត់បន្ថយអនិកម្មភាពក្នុងចំណោមប្រជាជនក្រីក្ររស់នៅតាមជនបទ<br>ការពង្រឹងសមត្ថភាពរបស់រោងចក្រឧស្សាហកម្មសំខាន់ៗ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់សេដ្ឋកិច្ចពី ខាងក្រៅ<br>ការផ្តល់លទ្ធភាពដល់ប្រជាជនក្រីក្រនៅតាមជនបទឱ្យទទួលបានឱកាសជ្រើសរើសការងារផ្សេងៗ<br>ការបញ្ចូលប្រជាជន និងសហគមន៍គោលដៅទាំងនេះទៅក្នុងយុទ្ធសាស្ត្រពិពិធភាវូបនីយកម្មឧស្សាហកម្មជាតិ | ចំនួនអ្នកមិនមានការងារធ្វើគ្រប់គ្រាន់ក្នុងចំណោមប្រជាជនក្រីក្រនៅតាមជនបទ<br>ការបង្កើនការផ្តល់វិធីសាស្ត្រការងារមិនមែនជាលក្ខណៈប្រពៃណី<br>ចំនួនក្រុម និងអ្នកដែលទទួលបានការបណ្តុះបណ្តាលការងារផ្លូវការ (បំណិនជីវិត និងជំនាញបច្ចេកទេស) ដើម្បីធ្វើឱ្យភាពដែលអាចមាននិកម្មភាពបានមាននិរន្តរភាព<br>ការបង្កើតផែនទីយុទ្ធសាស្ត្រសម្រាប់ប្រជាជនគោលដៅក្នុងយុទ្ធសាស្ត្រពិពិធភាវូបនីយកម្មឧស្សាហកម្មជាតិ | ការអង្កេតលើស្ថិតិនិកម្មភាពក្នុងចំណោមប្រជាជនក្រីក្រនៅតាមជនបទ<br>របាយការណ៍ពិនិត្យតាមដានរបស់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនរបាយការណ៍ស្តីពីការបណ្តុះបណ្តាល<br>ការពិនិត្យវាយតម្លៃលើការផ្លាស់ប្តូរជាយុទ្ធសាស្ត្រពិពិធភាវូបនីយកម្មឧស្សាហកម្មជាតិ | ការធ្វើអន្តរាគមន៍ដោយផ្តោតជាសំខាន់លើប្រជាជនក្រីក្ររស់នៅតាមជនបទជាជាងការផ្តោតលើយុទ្ធសាស្ត្ររួមទាំងអស់<br>ការមិនមានការសម្របសម្រួលគ្រប់គ្រាន់រវាងរដ្ឋាភិបាល និងអ្នកផ្តល់ការងារ<br>ការបន្តមានភាពទន់ខ្សោយផ្នែកឧស្សាហកម្មរបស់ប្រទេសកម្ពុជាដែលបណ្តាលមកពីទទួលរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក | ក្រសួងអប់រំ យុវជន និងកីឡាទទួលបានការគាំទ្រពីឧស្សាហកម្មឯកជន និងដៃគូអភិវឌ្ឍន៍<br>អ្នកផ្តល់ការបណ្តុះបណ្តាល | ឆ្នាំ២០១២ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធដែលជាការវិនិយោគមានតម្រូវការការងារខ្ពស់ និងជម្រុញដល់ការអភិវឌ្ឍក្នុងស្រុក | ការកើនឡើងនូវនិកម្មភាពប្រកបដោយនិរន្តរភាព<br>ការបង្កើនគុណភាពការងារ និងការកាត់បន្ថយការមិនមាននិកម្មភាពគ្រប់គ្រាន់<br>ការផ្លាស់ប្តូរផ្នត់គំនិតរបស់និយោជិតដើម្បីជំរុញឱ្យមានការលើកទឹកចិត្ត និងឱកាសទទួលបានការងារ<br>ការវិនិយោគដោយបង្កើននូវលទ្ធភាពអាចមាននិកម្មភាពសម្រាប់អ្នកគ្មានការងារធ្វើ<br>ការដោះស្រាយតម្រូវការសម្រាប់ យុទ្ធសាស្ត្រពិពិធភាវូបនីយកម្ម ឧស្សាហកម្មនិងផែនទីយុទ្ធសាស្ត្ររយៈពេលវែងស្តីពីមូលធនមនុស្ស | ចំនួនប្រជាជនមានការងាររហូត<br>ចំនួនប្រជាជនដែលមិនមានការងារធ្វើគ្រប់គ្រាន់<br>ចំនួនអ្នកដែលពេញចិត្តចំពោះការងារ<br>អត្រានៃការដំឡើងតំណែង និង/ឬ ប្រាក់បៀវត្ស<br>អត្រានៃការប្រែប្រួលចំនួនណិកម្មជននិងមានការងារធ្វើមិនគ្រប់គ្រាន់<br>ចំនួនការបណ្តុះបណ្តាលបំណិនជីវិតដែលផ្តល់ដោយនិយោជក | ស្ថិតិជាតិស្តីពីអនិកម្មភាព និងការមិនមានការងារធ្វើគ្រប់គ្រាន់<br>ការអង្កេតលើនិយោជិត<br>ការអង្កេតលើនិយោជក<br>របាយការណ៍ពិនិត្យតាមដានរៀបចំដោយដៃគូអភិវឌ្ឍន៍ជាច្រើនរបាយការណ៍ស្តីពីការបណ្តុះបណ្តាល | ការមិនធ្លាក់ចុះនៃអនិកម្មភាព<br>ការកើនឡើងភាពមានការងារធ្វើមិនគ្រប់គ្រាន់<br>ភាពគ្មានការងារធ្វើគ្រប់គ្រាន់ធ្លាក់ចុះតែក្នុងទីប្រជុំជនសំខាន់ៗ ប៉ុណ្ណោះ ប៉ុន្តែការធ្លាក់ ចុះនេះមិនមានកម្រិត ដូចគ្នានៅទូទាំងប្រទេសនោះទេ<br>ការមិនមានលក្ខខណ្ឌសេដ្ឋកិច្ចដែលជម្រុញឱ្យមានលទ្ធភាពអាចមាននិកម្មភាព និងការបង្កើតការងារ | ក្រសួងអប់រំ យុវជន និងកីឡា វិស័យឯកជន<br>ដៃគូអភិវឌ្ឍន៍ | នៅចុងឆ្នាំ ២០១១ ដើម្បីកាត់បន្ថយ អនិកម្ម ភាព<br>នៅចុងឆ្នាំ ២០១២ សម្រាប់ អនុវត្ត សកម្មភាព ការងារ ប្រកប ដោយ និរន្តរភាព |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការកែលម្អព័ត៌មានស្ដីពីទីផ្សារការងារ | អ្នកដែលធ្វើការងារក្នុងវិស័យស្របនឹងជំនាញរបស់ខ្លួន<br>ការកែលម្អប្រព័ន្ធសម្រាប់អ្នកស្វែងរកការងារធ្វើ<br>ការកាត់បន្ថយនិកម្មភាព និងការមានការងារធ្វើមិនគ្រប់គ្រាន់<br>ការកសាងសមត្ថភាពឱ្យបានពេញលេញដើម្បីកំណត់ពីការប្រែប្រួលក្នុងឧស្សាហកម្ម និងសេដ្ឋកិច្ច<br>ការយល់ដឹងបានប្រសើរលើកិច្ចខិតខំប្រឹងប្រែងធ្វើពិពិធភាវូបនីយកម្ម ឧស្សាហកម្មរបស់ប្រទេសដែលនាំឱ្យមានការយកចិត្តទុកដាក់ច្រើនលើការអភិវឌ្ឍជំនាញ | អត្រានៃនិកម្មភាព និងការមានការងារធ្វើមិនគ្រប់គ្រាន់ ចំនួនអ្នកដែលទទួលបានការងារធ្វើផ្អែកលើការអប់រំ និងជំនាញ<br>ចំនួននិយោជកដែលមាននិយោជិតមានជំនាញសមស្រប<br>ចំនួនអ្នកទទួលបានជំនាញថ្មីៗផ្អែកលើព័ត៌មានទីផ្សារការងារ | តួលេខនិកម្មភាព<br>តួលេខនៃការធ្វើពិពិធភាវូបនីយកម្មឧស្សាហកម្ម<br>របាយការណ៍របស់រដ្ឋាភិបាល<br>ការអង្កេតលើនិយោជិត និងនិយោជក | ភាពគ្របដណ្ដប់មិនស្មើគ្នានៅថ្នាក់ជាតិ ឬ អសមត្ថភាពក្នុងការចូលទៅដល់គ្រប់ តំបន់ទាំងអស់<br>ការមិនមានការអប់រំកម្រិតមូលដ្ឋានគ្រប់គ្រាន់ដែលជួយបង្កើនការបណ្ដុះបណ្ដាល<br>ការមិនមានកិច្ចសហការពីវិស័យឯកជន<br>ការមិនមានការណែនាំលើជំនាញដែលចាំបាច់ | ក្រសួងការងារ ដោយ-មានកិច្ចសហការជាមួយវិស័យឯកជន | ១ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| **ការកាត់បន្ថយការបោះបង់ចោលការសិក្សា** | ការបង្កើនជំនួយហិរញ្ញវត្ថុសម្រាប់បន្តការអប់រំ | ការកាត់បន្ថយចំនួនសិស្សបោះបង់ការសិក្សាតាមរយៈការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ និងអត្រាគង់វង្ស ព្រមទាំងបង្កើនការលើកទឹក ចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់គ្រួសារដែលមានកូនសិក្សាក្នុងសាលារៀន<br>ការបង្កើនចំនួនអ្នកទទួលផលឱ្យបានទូលំទូលាយ | ចំនួននៃជំនួយផ្នែកហិរញ្ញវត្ថុដែលត្រូវបានបែងចែក<br>ភាពខុសគ្នានៃអត្រា គង់វង្ស និងអត្រាឆ្លងថ្នាក់<br>ចំនួនគ្រួសារដែលទទួលបានជំនួយហិរញ្ញវត្ថុ<br>ចំនួនអ្នកទទួលផល | ការគណនាពីចំនួនប្រាក់ដែលត្រូវបានចំណាយ<br>របាយការណ៍ស្ថិតិការវិភាគស្ថិតិនៃការអង្កេតលើអត្រាគង់វង្សរបស់សិស្ស | ប្រាក់ដែលមិនត្រូវបានចំណាយដូចគ្នានៅទូទាំង ប្រទេស (តំបន់ជនបទប្រហែលជាត្រូវដកចេញ)<br>ការផ្តល់បរិយាកាសសិក្សាមិនត្រូវបានលើកកម្ពស់ | ក្រសួងអប់រំ យុវជន និងកីឡា | ក្នុងរយៈពេល ១ឆ្នាំ |
| | ការពង្រឹង និងពង្រីកកម្មវិធីអាហារូបករណ៍<br>សម្រាប់ប្រជាជន ក្រីក្រ (អាហារូបករណ៍សម្រាប់កម្រិតអនុវិទ្យាល័យ និងគំរូអាហារូប-ករណ៍សាកល្បងសម្រាប់កម្រិតបឋមសិក្សា) | ការកែលម្អការគ្រប់ដណ្តប់ថ្នាក់ជាតិ<br>ការពង្រីកមូលដ្ឋានកម្មវិធីដល់កុមាររៀននៅបឋមសិក្សា<br>ការបង្កើនសមភាពជាមូលដ្ឋានសម្រាប់អ្នកទទួលផល<br>ការរៀបចំបម្រុងទុកសាជាថ្មីនូវហិរញ្ញវត្ថុសាធារណៈសម្រាប់គាំទ្រដល់វិស័យឧស្សាហកម្មដែលជាវិស័យអាទិភាព | ការធានាឱ្យមានមូលដ្ឋានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីធ្វើឱ្យកម្មវិធីមាននិរន្តរភាព<br>ចំនួនតំបន់ដែលទទួលបានការកើនឡើងមូលនិធិ<br>ចំនួនអ្នកទទួលផលដែលទទួលបានមូលនិធិ<br>ចំនួនប្រាក់ចំណាយរវាងអ្នកទទួលផលតាមប្រភេទ (ក្រីក្របំផុត ក្រីក្រ និងប្រជាជនមានប្រាក់ចំណូលមធ្យម) | ស្ថិតិស្តីពីអ្នកទទួលផល<br>ការអង្កេតតាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន<br>ការវិភាគលើការប្រមូលទិន្នន័យតាមរយៈទិន្នន័យគោលរួម | ប្រាក់ដែលមិនត្រូវបានចំណាយដូចគ្នា<br>ការបែងចែកមូលនិធិមិនស្មើគ្នាដល់អ្នកទទួលផលតាមប្រភេទ | ក្រសួងអប់រំ យុវជន និង កីឡា រួមជាមួយការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ | ក្នុងរយៈពេល ១ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការធ្វើឱ្យអត្រាកុមារបោះបង់ការសិក្សាមានកម្រិតបំផុត | ការកាត់បន្ថយអត្រាបោះបង់ការសិក្សា<br>ការបង្កើនអត្រាអប់រំរួម<br>ការបង្កើនអត្រាបញ្ចប់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា និង ឧត្តមសិក្សា | ចំនួនសិស្សដែលបញ្ចប់ការសិក្សាក្នុងកម្រិតឧត្តមសិក្សា<br>ចំនួនសិស្សដែលឆ្លងថ្នាក់ និងអត្រាគង់វង្ស<br>ចំនួនប្រជាជនវ័យក្មេងមានកម្រិតអប់រំខ្ពស់ដែលមានការងារធ្វើ | ស្ថិតិស្តីពីទិន្នន័យគោល<br>របាយការណ៍សំខាន់ៗ ស្តីពីការអប់រំ<br>(ឧ. របាយការណ៍ស្តីពីគោលដៅ អភិវឌ្ឍន៍ សហស្សវត្សរ៍)<br>ទិន្នន័យបានពីក្រសួងអប់រំ យុវជន និងកីឡា ការអង្កេតលើនិយោជក<br>របាយការណ៍ត្រួតពិនិត្យលើការអប់រំ (បានពីដៃគូអភិវឌ្ឍន៍ផ្សេងៗ) | ការអប់រំកម្រិតឧត្តមមិនស្របទៅនឹងការលើកកម្ពស់គុណភាព និងជំនាញនោះទេ<br>ការបែងចែកមិនស្មើគ្នានូវប្រភេទនៃអ្នកបញ្ចប់ការសិក្សានៅ ទូទាំងខេត្ត (យេនឌ័រ និងប្រាក់ចំណូល) | ក្រសួងអប់រំ យុវជន និង កីឡាទទួលបានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១២ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| **ការបង្កើតប្រព័ន្ធមួយដែលអាចរួមបញ្ចូលទិន្នន័យ និងព័ត៌មានស្តីពីស្ថិតិការអប់រំ និងស្ថិតិឧស្សាហកម្មដែលពាក់ព័ន្ធ** | ការបង្កើតប្រព័ន្ធព័ត៌មានស្តីពីស្ថិតិការអប់រំ និងឧស្សាហកម្ម | ការបង្កើតប្រព័ន្ធព័ត៌មានដ៏ទូលំទូលាយ ដែលផ្ទុករាល់ទិន្នន័យ និងស្ថិតិសំខាន់ៗស្តីពីការអប់រំ<br>ការកំណត់ពីសូចនាករបំពេញការងារដែលពាក់ព័ន្ធ<br>ការបង្កើតប្រព័ន្ធដែលអាចបង្ហាញពី ឥទ្ធិភាពជាក់ស្តែងនៃការអប់រំ និងឧស្សាហកម្ម<br>ប្រព័ន្ធដែលអាចព្យាករណ៍ និងដោះស្រាយបញ្ហា និងបញ្ហាប្រឈមបានទូលំទូលាយ និងមានលក្ខណៈយុទ្ធសាស្ត្រ | ចំនួនស្ថិតិដែលអាចរកបាន ភ្លាមៗសម្រាប់វិភាគលើគោលនយោបាយអប់រំ និង-គោលបំណងក្នុងការអភិវឌ្ឍ<br>ការបង្កើនតម្រូវការសម្រាប់ព័ត៌មានស្ថិតិ ដើម្បីធ្វើការសម្រេចចិត្តផ្អែកលើភស្តុតាង<br>ការបង្កើតរចនាសម្ព័ន្ធគោលនយោបាយ និង-ការត្រួតពិនិត្យលើការវាយតម្លៃ | រដ្ឋាភិបាលកំណត់ពីសូចនាករសំខាន់ៗ ដោយសហការជាមួយវិស័យឯកជន<br>ការប្រមូល និងការបង្កើតទិន្នន័យត្រឹមត្រូវ<br>ការបង្កើនការប្រើប្រាស់ទិន្នន័យដែលអាចរកបាន និងមានភាពជឿជាក់<br>ការបង្កើត និងបង្កើនធនធានមនុស្សដែលអាចប្រមូល និងវិភាគទិន្នន័យបាន | ការប្រមូលទិន្នន័យ និងព័ត៌មានដែលមិនមាននិរន្តរភាព និងមិនមានលក្ខណៈជាប្រព័ន្ធ<br>ការមិនមានមូលធនមនុស្សដែលមានជំនាញគ្រប់គ្រាន់ដើម្បីប្រមូល និងវិភាគទិន្នន័យ | វិទ្យាស្ថានជាតិស្ថិតិ<br>ក្រសួងផែនការ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ | ចុងឆ្នាំ ២០១១ ដើម្បីបង្កើតប្រព័ន្ធ<br>ចុងឆ្នាំ ២០១២ ដើម្បី ប្រ-មូល ទិន្នន័យ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើតប្រព័ន្ធដែលអាចវិភាគ និងដំណើរការព័ត៌មានដែលប្រមូលបានពីទិន្នន័យព័ត៌មាន គោលដើម្បីបង្កើតគោលនយោបាយសមស្រប | ការផ្តោតការយកចិត្តទុកដាក់បន្ថែមទៅលើអន្តរាគមន៍គោលនយោបាយដែលសមស្របទៅ នឹងវិស័យអាទិភាពដែលត្រូវអភិវឌ្ឍក្នុងប្រទេសកម្ពុជាការបង្កើតបណ្តាញផ្សព្វផ្សាយជាអចិន្ត្រៃយ៍ដែលបម្រើឱ្យតម្រូវក្នុងការអភិវឌ្ឍ<br>ការកសាងសមត្ថភាពរបស់រដ្ឋាភិបាលដើម្បីផ្តល់ការណែនាំដល់ ដៃគូអភិវឌ្ឍន៍ (កម្មសិទ្ធិ) | ចំនួនដងដែលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធព័ត៌មាន<br>ចំនួនសូចនាករបំពេញការងារដែលមានអត្ថប្រយោជន៍ និងយកមកប្រើប្រាស់ជាញឹកញាប់<br>ចំនួនអនុសាសន៍គោលនយោបាយដែលបានអនុវត្តស្របតាមអាទិភាពរបស់ប្រទេសដោយផ្អែកលើទិន្នន័យប្រមូលបាន | ការរួមបញ្ចូលសូចនាករនៃការបំពេញការងារទៅក្នុងផែនការអភិវឌ្ឍជាតិ<br>ដៃគូអភិវឌ្ឍន៍បានប្រើប្រាស់ទិន្នន័យដែលមានថ្មីៗសម្រាប់បង្កើតគោលនយោបាយ និងសរសេររបាយការណ៍<br>របាយការណ៍ត្រួតពិនិត្យ<br>ផលប៉ះពាល់ផ្អែកលើភស្តុតាងនៃកម្មវិធីអភិវឌ្ឍស្របតាមទិន្នន័យដែលបានផ្តល់ឱ្យ | សូចនាករដែលបានជ្រើសរើសសម្រាប់ទិន្នន័យគោលមិនមានគ្រប់គ្រាន់ ឬមិនឆ្លុះបញ្ចាំងពីវិស័យនានាឱ្យបានគ្រប់ជ្រុងជ្រោយ<br>ការប្រមូលទិន្នន័យមិនគ្រប់គ្រាន់សម្រាប់ទិន្នន័យគោល ការមិនមាននិរន្តរភាពនៃការគាំទ្របានគ្រប់គ្រាន់ពីដៃគូអភិវឌ្ឍន៍ដើម្បីកសាងសមត្ថភាព | វិទ្យាស្ថានជាតិស្ថិតិ<br>ក្រសួងផែនការ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១២ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| ការធ្វើអន្តរាគមន៍រយៈពេលខ្លី | | | | | | | |
| **ការបំពេញភាពខ្វះចន្លោះនៃជំនាញ** | ការលើកកម្ពស់ការបណ្តុះបណ្តាលផ្លូវការដើម្បីអភិវឌ្ឍបំណិនជីវិត និងជំនាញបច្ចេកទេស | ការកំណត់ពីជំនាញសំខាន់ៗទាក់ទងនឹងការងារខណៈពេលផ្តោតលើការផ្លាស់ប្តូរពីការបណ្តុះបណ្តាលជំនាញមូលដ្ឋានទៅការសិក្សាដោយខ្លួនឯង<br>ការបណ្តុះបណ្តាលនេះបង្កើតឱ្យមានការសិក្សាការសម្របសម្រួលដល់ការអភិវឌ្ឍខ្លួនឯងប្រកបដោយអត្ថន័យ និងជួយឱ្យមនុស្សយល់ដឹងពីសក្តានុពលរបស់ខ្លួន | ការកើនឡើងចំនួនប្រជាជនដែលមានបំណិនជីវិតនិងជំនាញបច្ចេកទេស<br>ចំនួនអ្នកដែលបានទទួលផលពីការអប់រំទាក់ទងនឹងការងារព្រមទាំងការអភិវឌ្ឍខ្លួនឯង<br>តួលេខទាក់ទងនឹងភាពខ្វះចន្លោះនៃជំនាញដែលនៅតែមានក្នុងទីផ្សារការងារ | ការអង្កេតលើនិយោជិត និងនិយោជក<br>ទិន្នន័យស្តីពីតម្រូវការនៃទីផ្សារការងារ<br>ការត្រួតពិនិត្យនិងវាយតម្លៃលើ<br>របាយការណ៍បណ្តុះបណ្តាល | ការមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីវាយតម្លៃឱ្យបានសមស្របលើតម្រូវការទីផ្សារការងារ ការមិនមានគ្រូបង្រៀន និងបុគ្គលិកបណ្តុះបណ្តាលដែលមាន<br>ជំនាញគ្រប់គ្រាន់ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡាសហការជាមួយវិស័យ ឯកជននិងដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១៤ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការកំណត់ និងពង្រីកការបណ្តុះបណ្តាលលើវិស័យសំខាន់ៗដែលទាមទារឱ្យបង្កើនការផ្តល់ជំនាញ | ប្រជាជនគួរទទួលបានការបណ្តុះបណ្តាលយ៉ាងល្អពីបំណិនជីវិត និងជំនាញបច្ចេកទេសសំខាន់ៗ ដើម្បីបំពេញតម្រូវការការងាររបស់ខ្លួន<br>កម្លាំងពលកម្មអាចជួយបំពេញតម្រូវការទីផ្សារ និងតម្រូវការរបស់និយោជកម្នាក់ៗ<br>ការបង្កើតកម្លាំងការងារដែលមាន សមត្ថភាពខ្ពស់ក្នុងវិស័យជាច្រើន | ចំនួនប្រជាជនដែលទទួល បានការបណ្តុះបណ្តាលគ្រប់គ្រាន់ពីជំនាញដែលចាំបាច់សម្រាប់ការងាររបស់ពួកគេ<br>ការកើនឡើងចំនួននិយោជកដែលពេញចិត្តចំពោះជំនាញផ្តល់ដោយនិយោជិតរបស់ខ្លួន<br>ការកើនឡើងផលិតភាពនៃកម្លាំងការងារ | ការអង្កេតលើនិយោជក និងនិយោជិត<br>ការត្រួតពិនិត្យ និងការវាយតម្លៃ<br>របាយការណ៍ស្តីពីដំណើរការជ្រើសរើសបុគ្គលិក | ការបណ្តុះបណ្តាលមិនបានផ្តោតការយកចិត្ត ទុក-ដាក់ឱ្យបានគ្រប់ ជ្រុងជ្រ-ជាយក្នុងការដោះស្រាយបញ្ហាខ្វះចន្លោះនៃជំនាញ<br>ការមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីវាយតម្លៃឱ្យបានសមស្របពីតម្រូវការនៃទីផ្សារការងារ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡាសហការជាមួយវិស័យ ឯកជន និងដៃគូ អភិវឌ្ឍន៍ | ឆ្នាំ២០១៥ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការធានាឱ្យមានការគាំទ្រហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាលថ្មី និងកម្មវិធីអភិវឌ្ឍន៍ជំនាញ | ការសន្យាផ្តល់ថវិកាជាប្រចាំដើម្បីកសាង និងបណ្តុះបណ្តាលជំនាញការកសាងសមត្ថភាព និង ការបង្កើតកម្មវិធីបណ្តុះបណ្តាលនានាជាបន្តបន្ទាប់ សម្រាប់និយោជិត | ភាគរយនៃកញ្ចប់ថវិកាដែលបានបែងចែកទៅសាលារៀនការបណ្តុះបណ្តាល និងការបង្កើនគុណភាពជំនាញរួមទាំងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>តួលេខនៃការសន្យាផ្តល់ថវិកាជាប្រចាំ និងផលប៉ះពាល់លើ ភាពគ្របដណ្តប់ និងគុណភាពសេវា | របាយការណ៍ស្តីពីកញ្ចប់ថវិការបស់រដ្ឋាភិបាល<br>របាយការណ៍ស្តីពីកញ្ចប់ថវិកាដែលបានពីវិទ្យាស្ថានបណ្តុះបណ្តាលនានា<br>ការត្រួតពិនិត្យឡើងវិញលើចំណាយជាសាធារណៈ | ការបង្កើនហិរញ្ញប្បទានដែលមាននិរន្តរភាពមិនបានជួយបង្កើនគុណភាពនៃការបណ្តុះបណ្តាលផ្តល់ឱ្យនោះទេ<br>ការផ្តល់មូលនិធិធ្វើឡើងខុសៗគ្នាទៅតាមតំបន់មិនមែនធ្វើឡើងដូចៗគ្នានៅគ្រប់តំបន់នោះទេ | ក្រសួងហិរញ្ញវត្ថុសហការជាមួយក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និង កីឡា | ២ ទៅ ៣ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| ការធ្វើអន្តរាគមន៍ពីរយៈពេលខ្លីទៅរយៈពេលវែង | | | | | | | |
| **ការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ** | ការបង្កើនភាពងាយស្រួល និងការកែសម្រួល ការបណ្តុះបណ្តាល | ការផ្តល់វិធីសាស្ត្រ សិក្សារៀងៗខ្លួន<br>ការធ្វើវិមជ្ឈការបានល្អប្រសើរជាងមុន និងការមានសមត្ថភាពលើកម្មវិធី អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីឆ្លើយតបនឹងតម្រូវការក្នុងតំបន់ខុសៗគ្នា<br>ការប្រើប្រាស់យ៉ាងទូលំទូលាយនូវការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីលើកកម្ពស់គុណភាពជំនាញ<br>ការឆ្លើយតបយ៉ាងទូលំទូលាយដើម្បី បំពេញតម្រូវការទីផ្សារការងារ និង ភាពខ្វះចន្លោះនៃជំនាញ<br>ការជម្រុញឱ្យមានភាពច្នៃប្រឌិតការបង្កើតថ្មី និងភាពជាសហគ្រិនក្នុងក្របខណ្ឌការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការកើនឡើងចំនួនអ្នកទើបបញ្ចប់ការសិក្សាដែលទទួលបានការងារធ្វើដោយមានការបណ្តុះបណ្តាលសមស្របតាមស្ថានភាព និងមានការកែសម្រួល<br>ចំនួនកម្មវិធីអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលត្រូវបានកែសម្រួលឱ្យស្របតាមការប្រែប្រួលក្នុងស្រុក និងទីផ្សារការងារ<br>ការកើនឡើងនូវកម្មសិទ្ធិភាពច្នៃប្រឌិត និងការប្តេជ្ញារបស់សិក្ខាកាមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការអង្កេតលើអ្នកបញ្ចប់ការសិក្សាទាក់ទងនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ថ្មីៗ<br>ការអង្កេតលើអ្នកផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ការអង្កេតលើនិយោជក និងនិយោជិត<br>របាយការណ៍បានពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការប្រែប្រួលក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ<br>ការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការមិនមានគុណភាពគ្រប់គ្រាន់បើទោះជាមានការកែប្រែក្នុងការបណ្តុះបណ្តាល និងការរៀបចំកម្មវិធី<br>ការសម្របសម្រួលលើបញ្ហារវាងប្រភេទនៃការបណ្តុះបណ្តាលដែលបានផ្តល់ឱ្យ និងជំនាញដែលចាំបាច់សម្រាប់ទីផ្សារការងារ<br>ការសម្របសម្រួលលើបញ្ហារវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងអប់រំ យុវជន និងកីឡា | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា | ចុងឆ្នាំ ២០១៤ ប៉ុន្តែមាននិរន្តរភាពសម្រាប់ដំណើរការរយៈពេលវែង (យ៉ាងតិច ១០ឆ្នាំ) |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនប្រព័ន្ធធានាគុណភាពក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការបង្កើតជំនាញ និងកសាងសមត្ថភាពរបស់គ្របង្រៀន និងប្រព័ន្ធបណ្តុះបណ្តាល<br>ការបង្កើតឧបករណ៍រៀបចំផែនការ ទុកជាមុន ដើម្បីធ្វើឱ្យជំនាញមានសង្គតិភាពជាមួយ ការងារដែល-មាន<br>ការបង្កើនភាពជាដៃគូជាមួយភាគីពាក់ព័ន្ធសម្រាបផ្តល់ការអប់រំបច្ចេកទេស បណ្តុះបណ្តាលវិជ្ជាជីវៈ | ចំនួនអ្នកដែលចូលរួមការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទទួលបានជំនាញសំខាន់ៗ<br>ចំនួនគ្រូដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ចំនួនសិក្ខាសាលា និងការបណ្តុះបណ្តាលដែលបានផ្តល់<br>ចំនួននៃភាពជាដៃគូជាមួយអង្គភាពដែលមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការអង្កេតលើនិយោជក និងនិយោជិត<br>ការស្រាវជ្រាវ និងការអង្កេតដែលត្រូវបានបង្កើតឡើងដើម្បីផ្ទៀងផ្ទាត់ពីផលប៉ះពាល់របស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការត្រួតពិនិត្យ និងការវាយតម្លៃរបស់រដ្ឋាភិបាល និងភាពជាដៃគូនៃវិស័យឯកជនក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការបង្កើនចំនួនកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយមិនមានការបង្កើនគុណភាព ឬការផ្សព្វផ្សាយសមត្ថភាពរបស់វិស័យឯកជន និងរដ្ឋាភិបាលក្នុងការធ្វើការងាររួមគ្នា ការមិនសូវមានចំណាប់អារម្មណ៍ក្នុងចំណោមប្រជាជនក្នុងការចូលរួមកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ទទួលបានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ដោយមានកិច្ចសហការជាមួយវិស័យឯកជន | ២ទៅ ៣ឆ្នាំ ប៉ុន្តែមាននិរន្តរភាពសម្រាប់ដំណើរការរយៈពេលវែង (យ៉ាងតិច ១០ឆ្នាំ) |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | លើកកម្ពស់គុណភាពស្ថាប័ន និងសម្ភារ សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ចំនួនប្រជាជនដែលបានទទួលជំនាញសមស្របសម្រាប់ទីផ្សារការងារ<br>ការលើកទឹកចិត្តចំពោះសិក្ខាកាមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ការបង្រៀនដែលមានការផ្តោតការយកចិត្តទុកដាក់ និងមានប្រសិទ្ធភាព<br>ការកើនឡើងនូវចំនួនសិក្ខាកាមចូលរួមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការកើនឡើងចំនួនសិក្ខាកាមចូលរួមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ចំនួនសម្ភាររូបវ័ន្តដែលបានផ្តល់ឱ្យវិទ្យាស្ថានដែលមានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ចំនួនអ្នកដែលបានទទួលជំនាញសមស្របសម្រាប់ការប្រកបការងារ | ការអង្កេតលើសិក្ខាកាមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកញ្ចប់ថវិការបស់រដ្ឋាភិបាល/អ្នកផ្តល់ដោយឯករាជ្យនូវសម្ភារសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ទិន្នន័យលើការចូលរួម ក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ពិនិត្យតាមដាន និងវាយតម្លៃ) | ការកើនឡើងនៃកញ្ចប់ថវិកាមិនជំរុញឱ្យមានការលើកកម្ពស់គុណភាពនៃឧបករណ៍ និងការបណ្តុះបណ្តាល<br>ការបង្កើនកញ្ចប់ថវិកា និងគុណភាពស្ថាប័នឱ្យបានល្អប្រសើរមិនបានបង្កើនចំណាប់អារម្មណ៍ជាសាធារណៈក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនោះទេ | ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និង កីឡា ទទួលបាន ការគាំទ្រពីសំណាក់ដៃគូ អភិវឌ្ឍន៍ និង អ្នកផ្តល់កម្មវិធីអប់រំបណ្តុះ បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២ឆ្នាំ<br>ប៉ុន្តែមាននិរន្តរភាពសម្រាប់ដំណើរការរយៈពេលវែង (យ៉ាងតិច ១០ឆ្នាំ) |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និង វិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើតទំនាក់ទំនងរវាងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា | ការបង្កើតកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅកម្រិតឧត្តមសិក្សា<br>ការបង្កើនភាពជាដៃគូរវាងវិទ្យាស្ថានដែលមានចំណាប់អារម្មណ៍<br>ការសម្របសម្រួលល្អប្រសើររវាងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សាក្នុងការផ្តល់ជំនាញដែលចាំបាច់សម្រាប់ទីផ្សារការងារ | ចំនួននៃអ្នកផ្តល់សេវាកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយមានកិច្ចសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា<br>ការកើនឡើងទំនាក់ទំនងពីរដ្ឋាភិបាលដើម្បីបង្កើតភាពជាដៃគូរវាងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សា | របាយការណ៍គូសបញ្ជាក់ពីភាពជាដៃគូដែលទទួលបានជោគជ័យ និងផលប៉ះពាល់នៃភាពជាដៃគូទាំងនេះលើការបណ្តុះបណ្តាលដែលបានផ្តល់<br>ការត្រួតពិនិត្យ និងការវាយតម្លៃពីផលប៉ះពាល់នៃភាពជាដៃគូ<br>ការអង្កេតលើចំណាប់អារម្មណ៍ | ការមិនមានការផ្លាស់ប្តូរក្នុងគ្រឹះស្ថាន<br>ភាពមិនអើពើរបស់គ្រឹះស្ថានឧត្តមសិក្សានិងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធ្វើការសហការ<br>ការមិនមានការសម្របសម្រួល និងភាពជាអ្នកដឹកនាំគ្រប់គ្រាន់ក្នុង និងរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ឆ្នាំ ២០១៣ ប៉ុន្តែមាននិរន្តរភាពសម្រាប់ដំណើរការរយៈពេលវែង (យ៉ាងតិច ១០ឆ្នាំ) |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និង វិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនចំនួនអ្នកផ្តល់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាលក្ខណៈឯកជន និងតាមអង្គការមិនមែនរដ្ឋាភិបាល | ភាពគ្រប់ដណ្តប់កាន់តែល្អប្រសើរនៃគ្រឹះស្ថានដែលមានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ការកើនឡើងនូវជំនាញមូលដ្ឋានក្នុងកម្លាំងការងារ<br>ការកើនឡើងនូវភាពសម្បូរបែបនៃកម្មវិធីដែលផ្តល់ដោយកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ចំនួនគ្រឹះស្ថានដែលមានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គ្រប់គ្រងដោយអ្នកផ្តល់ឯករាជ្យ<br>ចំនួនប្រជាជនដែលចូលរួមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលផ្តល់ដោយអ្នកឧបត្ថម្ភឯករាជ្យ<br>ការកើនឡើងលទ្ធភាពទទួលបានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | របាយការណ៍របស់រដ្ឋាភិបាលស្តីពីគ្រឹះស្ថានដែលមានកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការត្រួតពិនិត្យ និងការវាយតម្លៃ<br>ការអង្កេតលើនិយោជក និងនិយោជិត | ការមិនមានការសម្របសម្រួលបានគ្រប់គ្រាន់រវាងអ្នកផ្តល់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>ការមិនមានភាពជាអ្នកដឹកនាំពីសំណាក់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបង្កើតអ្នកផ្តល់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជា ជីវៈ<br>អ្នកផ្តល់ដោយឯករាជ្យនូវកម្មវិធីអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២ ទៅ ៣ឆ្នាំ<br>ប៉ុន្តែ មាននិរន្តរភាពសម្រាប់ដំណើរការរយៈពេលវែង (យ៉ាងតិច ១០ឆ្នាំ) |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| ការធ្វើអន្តរាគមន៍រយៈពេលវែង | | | | | | | |
| **កំណែទម្រង់ការអប់រំកម្រិតឧត្តមសិក្សា** | ការរៀបចំឡើងវិញលើការគ្រប់គ្រងអភិបាលកិច្ច និងការផ្តល់ហិរញ្ញវត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សា | ការផ្តល់លទ្ធភាពដល់ប្រជាជនកម្ពុជាទទួលបានប្រព័ន្ធឧត្តមសិក្សាដែលមានសមភាពជាងមុន<br>ការគ្រប់គ្រងប្រព័ន្ធឧត្តមសិក្សាប្រកបដោយប្រសិទ្ធភាព សមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលក្នុងទីផ្សារការងារ និងធ្វើកំណែទម្រង់ឱ្យសមស្របទៅនឹងប្រព័ន្ធអប់រំការធ្វើឱ្យមានសង្គតិភាពនៃជំនាញរវាងអ្នកបញ្ចប់ការសិក្សា និងទីផ្សារការងារ | ចំនួនអ្នកបញ្ចប់ការសិក្សាថ្មីៗដែលទទួលបានការងារធ្វើភ្លាមៗបន្ទាប់ពីបញ្ចប់ការសិក្សា<br>ចំនួនអ្នកដែលទទួលបានការអប់រំកម្រិតឧត្តម ចំនួនអ្នកសិក្សាក្នុងកម្រិតឧត្តមសិក្សាដែលមកពីវិស័យផ្សេងៗគ្នាក្នុងសង្គម (សមភាព)<br>ទិន្នន័យស្តីពីការគ្រប់គ្រងលើការអប់រំកម្រិតឧត្តមសិក្សាដែលគ្រប់គ្រងដោយរដ្ឋាភិបាល និងដៃគូរបស់ខ្លួន | ការត្រួតពិនិត្យ និងការវាយតម្លៃការអង្កេតលើនិយោជក និងនិយោជិត<br>ការបង្កើតគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីធ្វើកំណែទម្រង់ និងបង្កើតប្រព័ន្ធសិក្សាកម្រិតឧត្តមសិក្សាកញ្ចប់ថវិការបស់រដ្ឋាភិបាល<br>របាយការណ៍ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា របាយការណ៍របស់ដៃគូ អភិវឌ្ឍន៍លើប្រព័ន្ធអប់រំ | ការមិនមានការប្តេជ្ញាចិត្តគ្រប់គ្រាន់ពីរដ្ឋាភិបាលដើម្បីបង្កើតប្រព័ន្ធអប់រំឧត្តមសិក្សាដែលមាននិរន្តរភាព<br>ការមិនមានចក្ខុវិស័យគ្រប់គ្រាន់ពីសំណាក់ដៃគូអភិវឌ្ឍន៍ | ក្រសួងអប់រំ យុវជន និង កីឡា រួមជាមួយការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ | ១០ ទៅ ១៥ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនហិរញ្ញប្បទានដែលមាននិរន្តរភាពដល់ការអប់រំកម្រិតឧត្តមសិក្សា | ការបង្កើនហិរញ្ញប្បទានលើការណែនាំការធ្វើប្រតិបត្តិការ ការវិនិយោគ បរិក្ខា និងឧបករណ៍<br>ការបន្តហិរញ្ញប្បទានសម្រាប់អាហារូបករណ៍សម្ព័ន្ធភាព និងកម្មវិធីស្រាវជ្រាវ<br>ហិរញ្ញប្បទានដោយប្រយោលដែលគាំទ្រដល់សិស្ស និងគ្រួសារ | ភាគរយនៃកញ្ចប់ថវិការបស់រដ្ឋាភិបាលដែលបែងចែកសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា<br>ចំនួននៃអ្នកទទួលអាហារូបករណ៍/ជំនួយសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា<br>ចំនួននៃអ្នកទទួលបានហិរញ្ញប្បទានផ្នែកអប់រំដោយប្រយោល<br>ចំនួនក្រុមប្រជាជនក្រីក្របំផុតក្នុងសង្គមដែលទទួលផលពីប្រព័ន្ធគាំទ្រការអប់រំរបស់រដ្ឋាភិបាល | ការត្រួតពិនិត្យលើចំណាយកញ្ចប់ថវិការបស់រដ្ឋាភិបាល<br>ការដាក់បញ្ចូលចំណុចនេះជាអាទិភាពមួយនៃផែនការអភិវឌ្ឍជាតិ | ការបែងចែកមូលនិធិមិនស្មើគ្នានៅទូទាំងប្រទេស<br>ការមិនមានចក្ខុវិស័យ និងការណែនាំរបស់រដ្ឋាភិបាលគ្រប់គ្រាន់នាំឱ្យមានការថយចុះនៃការប្តេជ្ញាចិត្ត | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងហិរញ្ញវត្ថុ | ១០ ទៅ ២០ឆ្នាំ រួមជាមួយការប្តេជ្ញាចិត្តជាប់ជានិច្ច |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| **កំណែទម្រង់ស្ថាប័នរបស់រដ្ឋាភិបាល** | ការផ្តោតការយកចិត្តទុកដាក់របស់រដ្ឋាភិបាលលើការផ្លាស់ប្តូរដែលនាំឱ្យមានការចូលរួមកាន់តែច្រើនក្នុងប្រព័ន្ធអប់រំឧត្តមសិក្សា | ការបង្កើនកិច្ចសហការនៅតាមក្រសួងផ្សេងៗ<br>ការផ្តួចផ្តើមរួមក្នុងការបង្កើតកម្មវិធីនិងប្រព័ន្ធថ្មីៗសម្រាប់វិស័យអប់រំ<br>ការបង្កើនសមត្ថភាពដើម្បីរួមគ្នាបង្កើតគោលនយោបាយ | ចំនួនកម្មវិធីអប់រំដែលបង្កើតឡើងដោយក្រសួងពីរឬច្រើនជាងនេះ<br>ភាគរយនៃមូលនិធិដែលបែងចែកមកពីក្រសួងផ្សេងៗសម្រាប់កម្មវិធីអប់រំ (សមភាព) | របាយការណ៍នៃកញ្ចប់ថវិការបស់រដ្ឋាភិបាលផែនការអភិវឌ្ឍជាតិ<br>របាយការណ៍ត្រួតពិនិត្យបានមកពីម្ចាស់ជំនួយ<br>ការវាយតម្លៃបានមកពីវិស័យអប់រំស្តីពីការចូលរួមរបស់ក្រសួងផ្សេងៗ | ការប្រកួតប្រជែងរវាងក្រសួងនានាក្នុងវិស័យផ្សេងៗ<br>ភាពត្រួតស៊ីគ្នានៃអាណត្តិនិងសមត្ថភាពរវាងក្រសួងនានាការខ្វះខាតកិច្ចព្រមព្រៀងពីក្រសួងដែលបានជ្រើសរើសស្តីពីវិធីសាស្ត្រសម្រាប់កិច្ចសហការ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងបណ្តុះបណ្តាលនិងវិជ្ជាជីវៈ<br>ក្រសួងពាក់ព័ន្ធផ្សេងៗ<br>ភាពជាអ្នកដឹកនាំបានមកពីក្រុមប្រតិបត្តិ | ៥ ទៅ ១០ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនកិច្ចសហការរវាងរដ្ឋាភិបាលនិងវិស័យឯកជន | ការបង្កើនការចូលរួមរបស់រដ្ឋាភិបាលជាមួយឯកជនស្តីពីការអប់រំ<br>ការលើកកម្ពស់ភាពជាដៃគូក្នុងផ្នែកសាធារណៈ-ឯកជន<br>ការបង្កើនការចូលរួមរបស់វិស័យឯកជនក្នុងដំណើរការកំណែទម្រង់វិស័យអប់រំ<br>ការជម្រុញរបស់រដ្ឋាភិបាលលើការផ្តួចផ្តើមរបស់វិស័យឯកជនដោយឯករាជ្យ | ចំនួនកម្មវិធីអប់រំបង្កើតឡើងដោយឯកជន<br>ចំនួននៃការផ្តួចផ្តើមភាពជាដៃគូនៃផ្នែកសាធារណៈ-ឯកជន<br>ចំនួននៃការពិគ្រោះយោបល់រវាងវិស័យសាធារណៈ និងឯកជនស្តីពីកំណែទម្រង់លើការអប់រំ<br>ចំនួនសហគ្រាសឯកជនដែលត្រូវបានប្រមូលផ្តុំក្រោមអាណត្តិរបស់រដ្ឋាភិបាលមួយ<br>ចំនួននៃការវិនិយោគ-ក្នុង ការអប់រំ និងការបណ្តុះបណ្តាល | របាយការណ៍របស់រដ្ឋាភិបាល រួមមានការវិនិយោគពីខាងក្រៅក្នុងវិស័យអប់រំ<br>របាយការណ៍របស់វិស័យឯកជន<br>របាយការណ៍របស់ដៃគូអភិវឌ្ឍន៍<br>របាយការណ៍ត្រួតពិនិត្យ | ការមិនសូវមានចំណាប់អារម្មណ៍ពីវិស័យឯកជនក្នុងការវិនិយោគលើវិស័យអប់រំ និងការបណ្តុះបណ្តាល<br>ការមិនមានការគាំទ្រពីបានគ្រប់គ្រាន់ពីដៃគូអភិវឌ្ឍន៍ក្នុងការបង្កើតយន្តការនានា និងការបង្កើតកិច្ចសហការបែបនេះ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងបណ្តុះបណ្តាល និងវិជ្ជាជីវៈ<br>វិស័យឯកជនគាំទ្រដោយដៃគូអភិវឌ្ឍន៍ | ៥ ទៅ ១០ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| ការសិក្សាពេញមួយជីវិត | ការបង្កើតទស្សនៈនៃការសិក្សាពេញមួយជីវិតសម្រាប់ប្រទេសកម្ពុជា | ការបង្កើតយុទ្ធសាស្ត្រឧស្សាហកម្មទូទៅ និងជាក់លាក់រយៈពេលវែង និងចក្ខុវិស័យ<br>ការបង្កើតប្រព័ន្ធដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចនាពេលអនាគត<br>ការបង្កើតប្រព័ន្ធដើម្បីជំរុញឱ្យមានការការចូលរួមបន្តក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលក្នុងចំណោមប្រជាជនកម្ពុជា<br>ការបង្កើតយន្តការដើម្បីជំរុញឱ្យមាន សហប្រតិបត្តិការរវាងវិស័យឯកជន ការអប់រំកម្រិតឧត្តមសិក្សា និងរដ្ឋាភិបាល | ចំនួនគ្រឹះស្ថានអប់រំឧត្តមសិក្សាដែលបានចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចពុទ្ធិ<br>ចំនួនសិស្សដែលសិក្សាក្នុងកម្រិតឧត្តមសិក្សា<br>ចំនួនអ្នកដែលសិក្សា និងទទួលការបណ្តុះបណ្តាលក្នុងពេលធ្វើការ | ការបង្កើតគោលនយោបាយរដ្ឋាភិបាលដើម្បីលើកកម្ពស់ការអប់រំពេញមួយជីវិត<br>ការជំរុញឱ្យមានការសន្យាផ្តល់មូលនិធិពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍<br>របាយការណ៍សកម្មភាពស្តីពីចំណុចដៅក្នុងការបង្កើតប្រព័ន្ធអប់រំ<br>របាយការណ៍ត្រួតពិនិត្យស្តីពីភាពរីកចម្រើនក្នុងវិស័យអប់រំកម្រិតឧត្តមសិក្សា | ការមិនមានឆន្ទៈគ្រប់គ្រាន់ពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចពុទ្ធិ<br>ការបង្កើតប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីធានាថាប្រព័ន្ធអប់រំមានភាពស៊ីសង្វាក់ និងមានទំនាក់ទំនងគ្នា | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ដៃគូអភិវឌ្ឍន៍ | ១០ ទៅ ១៥ ឆ្នាំ ដោយមានការប្តេជ្ញាចិត្តជាប់ជានិច្ច |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនការយកចិត្តទុកដាក់លើអ្វីដែលបុគ្គលម្នាក់ៗទទួលបានពីការរៀនសូត្រក្នុងជីវិតរបស់ខ្លួន | គោលបំណងក្នុងការបង្កើនចំណេះដឹង និងលើកកម្ពស់ជំនាញបន្ទាប់ពីការបញ្ចប់ដំណើរការអប់រំក្នុងប្រព័ន្ធដើម្បីពង្រឹងដល់សមត្ថភាពទទួលបានការងារ<br>ការឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ចពិភពលោកដែលផ្ដោតលើការបង្កើនចំណេះដឹង<br>ការបង្កើនសមត្ថភាពក្នុងការសម្របខ្លួន និងការប្រែប្រួលសេដ្ឋកិច្ចកម្ពុជាដើម្បីធ្វើការផ្លាស់ប្ដូរក្នុងទីផ្សារ និងឧស្សាហកម្ម | ចំនួនសិស្សសិក្សាថ្នាក់ឧត្ដមសិក្សាចំនួនសិស្សចូលរួមក្នុងការការអប់រំ និងការបណ្ដុះបណ្ដាលក្នុងពេលធ្វើការ<br>ចំនួនប្រជាជនដែលក្លាយជាសហគ្រិន និងចាប់ផ្ដើមផលិតផលិតផលទាក់ទងនឹងសេដ្ឋកិច្ចពុទ្ធិ (សេវា) | ការអង្កេតពីនិយោជិត និងនិយោជក<br>របាយការណ៍ស្ដីពីការលើកកម្ពស់វិស័យអប់រំកម្រិតឧត្ដមសិក្សា<br>ទិន្នន័យស្ដីពីការកើតឡើងនូវព្រឹត្តិកម្មឧស្សាហកម្មដែលបណ្ដាលមកពីការយល់ ដឹងពីផលិតផល និងសេវាតាមជំនាញខ្ពស់ | ភាពខ្វះខាតឯកភាពរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដើម្បីធ្វើឱ្យវិស័យអប់រំក្លាយទៅជាសេដ្ឋកិច្ចពុទ្ធិ<br>និរន្តរភាពហិរញ្ញប្បទាន<br>ភាពជោគជ័យធំធេងលើការបំពេញបានការអប់រំកម្រិតទាបរវាងនិយោជិតកម្ពុជា។ | ក្រសួងអប់រំ យុវជន និងកីឡា<br>និងដៃគូអភិវឌ្ឍន៍ | ១០ ទៅ ១២ ឆ្នាំ |

| អនុសាសន៍គោលនយោបាយ | គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុក | សូចនាករដែលអាចផ្ទៀងផ្ទាត់បាន | ប្រភព និងវិធីផ្ទៀងផ្ទាត់ | ហានិភ័យ | អ្នកដឹកនាំ | ពេលវេលា |
|---|---|---|---|---|---|---|---|
| | ការបង្កើនការសម្របសម្រួល និងការកាត់បន្ថយ វិសមភាពក្នុងស្តង់ដារនៃគុណភាពអប់រំ | ការបង្កើតស្តង់ដារទូទៅដែលការទទួលស្គាល់យ៉ាងទូលំទូលាយសម្រាប់ការអភិវឌ្ឍគ្រប់វិស័យនៃការអប់រំ និងការបណ្តុះបណ្តាល<br>ការបង្កើតជំនាញ និងការបណ្តុះបណ្តាលផ្លូវការដែលមានគុណភាព<br>ការង្កើនការសម្របសម្រួលរវាងគ្រឹះស្ថាន និងប្រព័ន្ធអប់រំដែលគោរពតាមស្តង់ដារ | ចំនួនសិស្សដែលបញ្ចប់ការសិក្សាដោយទទួលបានវិញ្ញាបនប័ត្រក្នុងក្របខ័ណ្ឌដែលមានគុណភាព<br>ចំនួនគ្រឹះស្ថានដែលគោរពទៅតាមស្តង់ដារគុណភាព<br>ចំនួនគ្រឹះស្ថាន និងគ្រូបង្រៀនមានស្តង់ដារគុណភាពអប់រំ<br>ចំនួននិយោជកដែលស្វែងរកនិយោជិតមានជំនាញសមស្របតាមស្តង់ដារគុណភាព | របាយការណ៍និយោជក<br>របាយការណ៍រដ្ឋាភិបាល<br>ស្ថិតិជាតិស្តីពីចំនួនសិស្សដែលបញ្ចប់ការសិក្សា និងការចូលរួមក្នុងក្របខ័ណ្ឌគុណភាព<br>របាយការណ៍ស្តីពីការប្រើប្រាស់ និងការទទួលស្គាល់ស្តង់ដារក្របខ័ណ្ឌគុណភាពដែលបានមកពីគ្រឹះស្ថានអប់រំ | ការបង្កើតក្របខ័ណ្ឌគុណភាពដោយមិនមានការសម្របសម្រួលជាមួយវិស័យឯកជន<br>ការបង្កើតក្របខ័ណ្ឌគុណភាពដោយមិនមានការធានាចំពោះជំនាញទាក់ទងនឹងគុណភាព<br>ការមិនមានការប្តេជ្ញាចិត្តបានគ្រប់គ្រាន់ | ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានអប់រំវិស័យឯកជន | ៨ ទៅ ១០ ឆ្នាំ |

# ឧបសម្ព័ន្ធស្ថិតិ

*រូបទី១ : កំណើនផលិតផលក្នុងស្រុកសរុបរបស់សាធារណរដ្ឋកូរ៉េ និងប្រទេសហ្គាណាក្នុងរយៈពេល៥០ឆ្នាំ*




*ប្រភព : ការសិក្សាលើការអភិវឌ្ឍរបស់ធនាគារពិភពលោក ឆ្នាំ២០០៧ ។ ការលើកកម្ពស់សេដ្ឋកិច្ចពុទ្ធិ : យុទ្ធសាស្ត្រ ឈានមុខដើម្បីការអភិវឌ្ឍ ។ ធនាគារពិភពលោក ទំព័រទី៤ ។*

*រូបភាពទី២ : សរសរស្តម្ភទាំងបួននៃសេដ្ឋកិច្ចពុទ្ធិដែលមានទំនាក់ទំនងគ្នា*




*ប្រភព : ការសិក្សាលើការអភិវឌ្ឍរបស់ធនាគារពិភពលោក ឆ្នាំ២០០៧ ។ ការលើកកម្ពស់សេដ្ឋកិច្ចពុទ្ធិ : យុទ្ធសាស្ត្រ ឈានមុខដើម្បីការអភិវឌ្ឍ ។ ធនាគារពិភពលោក ទំព័រទី២៧ ។*

*រូបទី៣ : អត្រាចុះឈ្មោះចូលរៀនដុលជាមធ្យមនៅកម្រិតឧត្តមសិក្សាតាមប្រាក់ចំណូលជាតិ ឆ្នាំ១៩៦៥ និង ១៩៩៥*




*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០០០។ ការអប់រំកម្រិតឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ : គ្រោះថ្នាក់ និងការសន្យា ក្រុមការងារលើការអប់រំកម្រិតឧត្តមសិក្សា និងធនាគារពិភពលោកដើម្បីសង្គម ទំព័រទី២៨។*

*រូបទី៤ : អត្រាចុះឈ្មោះចូលរៀនដុលក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន ឆ្នាំ២០០១-២០០៨*




*ប្រភព : វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូនៅឆ្នាំខុសៗគ្នា។*

*រូបទី៥ : អត្រាចុះឈ្មោះចូលរៀនសរុបនៅបណ្តាប្រទេសជាសមាជិកអង្គការសហការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ឆ្នាំ២០០៨*




*ប្រភព : វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ ឆ្នាំ២០០៩។*

*រូបទី៦ : ការចុះឈ្មោះចូលរៀនតាមសាលា និងគ្រឹះស្ថានឯកជនគិតជាភាគរយតាមប្រទេសក្នុងទ្វីបអាស៊ី (ឆ្នាំ២០០១-២០០៧)*




*ប្រភព : អង្គការយូណេស្កូ ឆ្នាំ២០០៩។ កត្តាជំរុញថ្មីមួយ : ការអប់រំកម្រិតឧត្តមសិក្សាឯកជន។*

*រូបទី៧ : ចំណាយសាធារណៈ និងអត្រាចុះឈ្មោះចូលរៀនដុលសម្រាប់ប្រទេសដែលបានជ្រើសរើសក្នុងទ្វីបអាស៊ី*

| | ចំណាយសាធារណៈសម្រាប់សិស្សម្នាក់/ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ (%) | | អត្រាចុះឈ្មោះចូលរៀនដុល (GER) | |
|---|---|---|---|---|
| **Country** | **1980** | **1997** | **1985** | **2002** |
| China | 246.2 | 65.3 | 2.9 | 13.2 (2001) |
| India | 83.3 | 92.5 | 6.0 | 6.5 (1995) |
| Indonesia | 25 (1985) | 12.3 | 8.5 | 12.8 |
| Thailand | 59.7 | 25.4 | 18.1 | 31.92 |
| Malaysia | 140.6 | 53.6 | 5.8 | 28.26 |
| Philippines | 13.7 | 14.8 | N/A | 29.45 (1999) |
| Viet Nam | N/A | 86.1 | 2.3 | 9.66 (2000) |

*ប្រភព : យុទ្ធសាស្ត្រអប់រំកម្រិតឧត្តមសិក្សារយៈពេលវែងរបស់ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ២០០៣-២០១០ : ១០ ។*

*រូបទី៨ : ថវិកាសម្រាប់ការអប់រំក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ (ផលិតផលក្នុងស្រុកសរុបគិតជា%)*




*ប្រភព : Moelidihardjo និងអ្នកផ្សេងទៀតការវាយតម្លៃលើវិស័យអប់រំកម្រិតឧត្តមសិក្សារបស់ធនាគារពិភពលោក ឆ្នាំ២០១០ : ទំព័រទី៧៤ ។*

*តារាងទី១ ភាគរយនៃការអប់រំឧត្តមសិក្សាផ្នែកឯកជន និងសាធារណៈរបស់ប្រទេសក្នុងទ្វីបអាស៊ី ឆ្នាំ២០០១-២០០៨*, **, ***, ****, ******

| Country | Private % of total HEI enrolment | Year | Private % of total HEIs | Year | Private % of total Univ. enrolment | Year | Private % of total Univs. | Year |
|---|---|---|---|---|---|---|---|---|
| Australia | 3.5 (40,000/N/A) | 2008 | — | — | — | — | — | — |
| Bangladesh | 14.4 (61,108/423,236) | 2003-04 | 48.6 (54/111) | 2005-06 | 44.2 (91,648/207,577) | 2005 | 71.6 (53/74) | 2005 |
| Cambodia | 58.0 (56,563/97,524) | 2006 | 64.5 (40/62) | 2006 | — | — | 69.2 (18/26) | 2004 |
| China | 19.9 (4,013,010/20,210,249) | 2008 | 28.3 (640/2,263) | 2008 | 0 | 2008 | 0 | 2008 |
| Hong Kong, China | 59.0 (127,256/215,637) | 2007-08 | 54.5 (12/22) | 2007-08 | 59.4 (95,238/160,295) | 2007-08 | 22.2 (2/9) | 2007-08 |
| India | 30.7 (3,219,000/10,481,000) | 2005-06 | 42.9 (7,720/17,973) | 2005-06 | — | — | — | — |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Indonesia | 71.0 (2,392,417/3,371,156) | 2007 | 95.5 (2,766/2,897) | 2007 | — | — | 89.0 (372/418) | 2007 |
| Japan | 77.4 (2,924,022/3,776,623) | 2007 | 89.6 (4,199/4,689) | 2007 | 73.2 (2,071,642/2,828,635) | 2007 | 76.7 (580/756) | 2007 |
| Kazakhstan | 46.5 (347,100/747,100) | 2004 | 71.8 (130/181) | 2004 | — | — | — | — |
| Kyrgyzstan | 7.2 (15,800/218,300) | 2004 | 32.7 (16/49) | 2004 | — | — | — | — |
| Lao PDR | 32.4 (14,371/44,289) | 2004-05 | 79.5 (31/39) | 2005 | — | — | — | — |
| Malaysia | 50.9 (322,891/634,033) | 2004 | 97.0 (559/576) | 2004 | 7.5 | 2000 | 39.3 (11/28) | 2004 |
| Myanmar | 0 (0/156) | 2005 | 0 | 2005 | 0 | 2005 | 0 | 2005 |
| Mongolia | 26.0 | 2003 | 64.2 | 2003 | 8.3 | 2003 | 27.2 | 2003 |
| New Zealand | 9.3 (23,763/256,468) | 2006 | 85.6 (172/201) | 2007 | 0 | 2007 | 0 | 2007 |
| Pakistan | 23.8 (103,466/435,130) | 2007-08 | 46.0 (57/124) | 2007-08 | — | — | 42.6 (40/94) | 2007-08 |
| Philippines | 65.1 (1,589,866/2,438,855) | 2005-06 | 89.4 (1,431/1,599) | 2005 | — | — | — | — |
| South Korea | 80.0 (2,565,888/3,204,036) | 2006 | 87.0 (280/322) | 2002 | 78.4 (1,439,297/1,836,649) | 2004 | 84.8 (145/171) | 2004 |
| Taiwan | 71.9 | 2004 | 65.8 | 2004 | 66.8 | 2004 | 64.1 | 2004 |
| Thailand | 9.9 (173,007/1,750,777) | 2007 | 46.9 (70/149) | 2007 | 16.8 | 2001 | 28.3 | 2003 |
| Viet Nam | 10.4 (137,760/1,319,754) | 2005 | 12.6 (29/230) | 2005 | — | — | — | — |

*កំណត់សម្គាល់ :*

* *ប្រសិនបើយើងធ្វើការបូកសរុបទិន្នន័យនៃការចុះឈ្មោះចូលរៀនទាំងអស់នៅបណ្តាប្រទេសក្នុងទ្វីបអាស៊ី យើងឃើញថាការចុះឈ្មោះចូលរៀនផ្នែកឯកជនមានចំនួន ៣៦.៤% ដោយមិនរាប់បញ្ចូលប្រទេស និងតំបន់ដែលមិនមានទិន្នន័យនៃការចុះឈ្មោះចូលរៀនផ្នែកឯកជន ឬការចុះចូលរៀនសរុបឡើយ ។*

** *ទោះបីជាទិន្នន័យដែលទទួលបានពីប្រភពដែលអាចទុកចិត្តបានបំផុត-ជាធម្មតា ទទួលបានពីប្រភព ផ្លូវការ-ក៏ដោយ ក៏លក្ខខណ្ឌ និងការបញ្ចូលគ្នាមានភាពខុសគ្នាដ៏ខ្លាំងពីប្រទេសមួយទៅប្រទេសមួយ ដូច្នេះហើយគួរតែមានការប្រៀបធៀបដោយធ្វើឡើងដោយមានការយកចិត្តទុកដាក់ខ្ពស់បំផុត ។ ឧទាហរណ៍ ភាពខុសគ្នារវាងអត្ថន័យនៃពាក្យការអប់រំឧត្តមសិក្សាសាកលវិទ្យាល័យ និងឧត្តមសិក្សា ។ ក្នុងទិន្នន័យមូលដ្ឋានមួយចំនួនមានតែគ្រឹះស្ថានដែលមានការទទួលស្គាល់ ឬទទួលបានអាជ្ញាបណ្ណប៉ុណ្ណោះត្រូវបានរាប់បញ្ចូលជាគ្រឹះស្ថានសិក្សាម្យ៉ាងវិញទៀត តួលេខត្រូវមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ការរាប់ចំនួនសិស្សចុះឈ្មោះចូលរៀន និងចំណុចលម្អិតដទៃទៀតក៏មានភាពខុសគ្នាដែរ ។ សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌបន្ថែមស្តីពីតារាងទិន្នន័យអន្តរជាតិ សូមមើលគេហទំព័រhttp://www.albany.edu/dept/eaps/prophe/data/international.html ។ ចំណុចនីមួយៗលើបញ្ហាទាំងនេះ មានបញ្ជាក់ច្បាស់នៅក្នុងឯកសារទិន្នន័យស៊ីជម្រៅក្នុង PROPHEE ពីប្រទេសនីមួយៗសូមមើលគេហំព័រ http://www.albany.edu/dept/eaps/prophe/data/national.html.*

*** *ប្រទេសហ្សកហ្ស៊ី អ៊ីស្រាអែល រុស្ស៊ី និងទួរគី ជាប្រទេសមានឈ្មោះក្នុងតារាងទិន្នន័យអឺរ៉ុប បើទោះជាប្រទេសទាំងនេះមានឈ្មោះក្នុងតារាងទិន្នន័យអាស៊ីក៏ដោយ ។*

**** *ទោះបីជាទិន្នន័យរបស់ប្រទេសទាំងនេះ មានបង្ហាញពីប្រភពទិន្នន័យក៏ដោយ ក៏ប្រទេសទាំងនេះពុំមានទិន្នន័យគ្រប់គ្រាន់ដើម្បីបញ្ចូលក្នុងតារាងនោះទេ ជាពិសេសទិន្នន័យទាក់ទងនឹងភាពមិនស្របគ្នាចំពោះការអប់រំឧត្តមសិក្សា ។*

***** *អ្នករៀបចំតារាងនេះ រួមមាន Yingxia Cao, Daniel Levy, Prachayani Praphamontripong និង Chunyue Zhang ។*

*ប្រភព : ទិន្នន័យមូលដ្ឋានអន្តរជាតិ PROPHE អាចរកបានតាមរយៈគេហទំព័រ ។*

*http://www.albany.edu/dept/eaps/prophe/data/international.html.*

**តារាងទី២ បុគ្គលិកបង្រៀនពេញម៉ោង និងក្រៅម៉ោងនៅកម្រិតឧត្តមសិក្សាក្នុងបណ្ដាប្រទេសដែលបានជ្រើសរើសក្នុងទ្វីបអាស៊ី ឆ្នាំ២០០០ និង ២០០៧**

| Country | 2007 Total | 2007 Part-time | 2007 Total | 2007 Part-time |
|---|---|---|---|---|
| Cambodia | 1,664 | — | 3,261 | 830 |
| China | 523,326 | — | 1,326,058 | 303,764 |
| India | 399,023 | — | — | — |
| Indonesia | 217,403 | — | 265,527 | — |
| Malaysia | 29,915 | — | 39,809 | — |
| Philippines | 93,956 | — | 112,941 | — |
| Thailand | 50,639 | 3,738 | 75,398 | — |
| Viet Nam | 30,309 | — | 53,518 | — |
| Singapore | — | — | 14,209 | 6,118 |

*កំណត់សម្គាល់ : តារាងនេះ បង្ហាញពីចំនួនប្រទេសដែលបានជ្រើសរើសសម្រាប់បុគ្គលបង្រៀនពេញម៉ោងនិងក្រៅម៉ោងក្នុងឆ្នាំ២០០០ និង២០០៧ ។ អង្គការយូណេស្កូលើកឡើងថាគ្រូបង្រៀន ឬបុគ្គលិកបង្រៀនជាបុគ្គលដែលជួលឱ្យធ្វើការងារពេញម៉ោង ឬក្រៅម៉ោងដែលមានតួនាទីជាផ្លូវការដើម្បីជួយណែនាំ និងផ្ដល់បទពិសោធន៍សិក្សាដល់កុមារ និងសិស្ស និងនិសិត្ស ដោយមិនគិតទៅលើគុណសម្បត្តិ ឬយន្ដការក្នុងការបង្រៀនរបស់ពួកគេនោះទេ ។ ការលើកឡើងនេះមិនរួមបញ្ចូលបុគ្គលិកដែកមិនមានមុខងារបង្រៀន និងបុគ្គលដែលធ្វើការងារម្ដងម្កាល ឬក្នុងនាមជាអ្នកស្ម័គ្រចិត្តក្នុងគ្រឹះស្ថានអប់រំនោះទេ ។*

*ប្រភព : Altbach,P.G និងអ្នកផ្សេងទៀត ឆ្នាំ២០០៩ ។ និន្នាការ ក្នុងការអប់រំឧត្តមសិក្សាជាសកល : ការតាមដានការផ្លាស់ប្ដូរការអប់រំ ។ របាយការណ៍សម្រាប់ប្រើប្រាស់ក្នុងសន្និសីទអន្ដរជាតិឆ្នាំ២០០៩ របស់អង្គការយូណេស្កូស្ដីពីការអប់រំឱ្យឧត្តមសិក្សា ។ អង្គការយូណេស្កូ ។*

**តារាងទី៣ : ចំនួនសេវាស៊ីវិល ឆ្នាំ២០០៣**

| ប្រភេទ | ប្រភេទ | ការអប់រំ | មិនមែនការអប់រំ | % |
|---|---|---|---|---|
| A | 6,747 | 12,061 | 18,808 | 11% |
| B | 21,713 | 18,203 | 39,916 | 24% |
| C | 51,601 | 15,961 | 67,562 | 40% |
| D | 4,395 | 27,324 | 31,719 | 19% |
| Other a/ | 606 | 8,261 | 8,867 | 5% |
| Total | 85,062 | 81,810 | 166,872 | 100% |

*ប្រភព : Taliercio,R.R. មិនដឹងឆ្នាំ ។ ពីរដ្ឋាភិបាលទាំងមូលទៅជាវិធីសាស្ត្រកំណែទម្រង់ទាំងស្រុង ? : ការធ្វើកំណែទម្រង់សេវាស៊ីវិលនៅប្រទេសកម្ពុជា ។*

**តារាងទី៤ : ភាគហ៊ុនទីផ្សារពិភពលោកអាស៊ានតាមវិស័យអាទិភាព ឆ្នាំ២០០៤-២០០៨**

| | Share of world merchandise exports (%) | | | | |
|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2008 |
| Agro-based products | 8.8 | 7.9 | 8.5 | 10.1 | 10.4 |
| Automotives | 1.5 | 1.8 | 2.0 | 2.3 | 2.6 |
| Electronics | 12.3 | 12.3 | 12.2 | 12.7 | 11.8 |
| Healthcare | 1.5 | 1.9 | 2.4 | 2.5 | 2.1 |
| Textiles and apparel | 4.4 | 3.9 | 3.9 | 4.3 | 4.5 |
| Wood-based products | 6.7 | 6.7 | 7.1 | 7.4 | 7.7 |
| Total, all products | 6.2 | 6.6 | 6.3 | 6.2 | 5.5 |

*ប្រភព : គណៈកម្មការពាណិជ្ជកម្មអន្តរជាតិប្រចាំសហរដ្ឋអាមេរិក ឆ្នាំ២០១០ ។ អាស៊ាន : និន្នាការនៃសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ការប្រកួតប្រជែងក្នុងការនាំចេញ និងការវិនិយោគក្នុងប្រទេសសម្រាប់ឧស្សាហកម្មដែលបានជ្រើសរើស ។ ទំព័រទី២ ចំណុច១៧ ។*

*តារាងទី៥ : ពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា និងក្នុងតំបន់*

| | 1998 | | | | 2007 | | | | 1998-2007 annual growth | |
|---|---|---|---|---|---|---|---|---|---|---|
| | Total exports (US$ b) | % to Asia | % re-gional ex-ports | % intra-regional exports | Total exports (US$ b) | % to Asia | % regional exports | % intra-regional exports | Total exports | Intra-regional exports |
| **Cambodia** | **0.9** | **52.9** | **0.1** | **0.1** | **4.1** | **13.1** | **0.1** | **0.0** | **17.8** | **0.8** |
| China | 183.7 | 49.0 | 13.9 | 15.9 | 1,218.1 | 38.0 | 32.4 | 25.0 | 23.4 | 19.9 |
| Hong Kong, China | 173.7 | 48.9 | 13.1 | 15.0 | 344.7 | 63.2 | 9.2 | 11.8 | 7.9 | 11.0 |
| Indonesia | 48.9 | 54.1 | 3.7 | 4.7 | 114.1 | 59.2 | 3.0 | 3.7 | 9.9 | 11.0 |
| Japan | 388.0 | 33.7 | 29.4 | 23.0 | 714.3 | 46.9 | 19.0 | 18.1 | 7.0 | 11.0 |
| Korea (DPRK) | 0.9 | 35.9 | 0.1 | 0.1 | 1.6 | 41.0 | 0.0 | 0.0 | 6.9 | 8.6 |
| Korea (Rep.) | 132.8 | 40.7 | 10.0 | 9.5 | 371.4 | 48.2 | 9.9 | 9.7 | 12.1 | 14.2 |
| Lao PDR | 0.4 | 48.4 | 0.0 | 0.0 | 1.3 | 63.1 | 0.0 | 0.0 | 15.2 | 18.6 |
| Malaysia | 73.5 | 48.3 | 5.6 | 6.3 | 176.2 | 54.6 | 4.7 | 5.2 | 10.2 | 11.7 |
| Mongolia | 0.3 | 47.6 | 0.0 | 0.0 | 1.7 | 74.2 | 0.0 | 0.1 | 19.2 | 25.2 |
| Myanmar | 1.1 | 35.2 | 0.1 | 0.1 | 4.8 | 67.0 | 0.1 | 0.2 | 17.2 | 25.9 |
| Papua New Guinea | 2.4 | 27.4 | 0.2 | 0.1 | 7.4 | 20.7 | 0.2 | 0.1 | 13.6 | 10.1 |
| Philippines | 29.5 | 40.6 | 2.2 | 2.1 | 50.5 | 60.8 | 1.3 | 1.7 | 6.1 | 11.0 |
| Singapore | 109.9 | 48.8 | 8.3 | 9.5 | 299.2 | 63.2 | 8.0 | 10.2 | 11.8 | 15.0 |
| Taiwan, China | 110.8 | 43.7 | 8.4 | 8.5 | 244.1 | 65.7 | 6.5 | 8.7 | 9.2 | 14.2 |
| Thailand | 55.4 | 43.2 | 4.2 | 4.2 | 152.5 | 52.9 | 4.1 | 4.4 | 11.9 | 14.4 |
| Viet Nam | 9.3 | 55.8 | 0.7 | 0.9 | 48.6 | 41.6 | 1.3 | 1.1 | 20.1 | 16.3 |
| Total Asia | 1.322 | 42.9 | 100.0 | 100.0 | 3.754 | 49.2 | 100.0 | 100.0 | 12.3 | 14.0 |

*កំណត់សម្គាល់ : (*) យោងតាមប្រទេសទាំង១៧ខាងលើ % នៃការនាំចេញពីតំបន់ គឺជារចនាសម្ព័ន្ធនៃការនាំចេញសរុបក្នុងតំបន់ ។ % នៃការនាំចេញក្នុងតំបន់ គឺជារចនាសម្ព័ន្ធនៃការនាំចេញរវាងបណ្តាប្រទេសក្នុងតំបន់ ។*

*ប្រភព : ធនាគារពិភពលោក ឆ្នាំ២០០៩ ។ ការរក្សាកំណើនដ៏ឆាប់រហ័សក្នុងបរិយាកាសដ៏លំបាក ។ ទំព័រទី៤៦ ។*

### *ប្រអប់ ក.១ ចំណេះដឹង និងកំណើន : ភស្តុតាងជាក់ស្តែង*

**ការអប់រំ**

ការសិក្សានាពេលថ្មីៗនេះស្តីពីភាពខុសគ្នាជាសកលនៃលទ្ធផលរបស់អ្នកធ្វើការម្នាក់ៗ និងអត្រាកំណើនសេដ្ឋកិច្ចបានផ្តោតលើតួនាទីរបស់មូលធនមនុស្សក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ។ ជាការពិតណាស់ (ក្នុងករណីតែស្តែង) ការសិក្សាក្នុងបណ្តាលប្រទេសនីមួយៗស្តីពីកំណើនរយៈពេលវែង បច្ចុប្បន្ននេះបានរួមបញ្ចូលវិធានការមួយចំនួននៃមូលធនមនុស្ស ។ Barro (១៩៩១) តាមរយៈការប្រើប្រាស់ទិន្នន័យពី ៩៨ ប្រទេសចាប់ពីឆ្នាំ១៩៦០-៨៥ និងអត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ជាតួលេខតំណាងឱ្យមូលធនដំបូងបានរកឃើញថាអត្រាចុះឈ្មោះចូលរៀនមានមានឥទ្ធិពលជាវិជ្ជមាននៅក្នុងស្ថិតិទៅលើកំណើនផលិតផលក្នុងស្រុកសរុបជាក់ស្តែងក្នុងមនុស្សម្នាក់ ។ ស្រដៀងគ្នានេះដែរ Cohen និង Soto (ឆ្នាំ២០០១) តាមរយៈការប្រើប្រាស់ទិន្នន័យប្រមូលតាមពេលវេលាក្នុងបណ្តាលប្រទេសទាក់ទងនឹងលទ្ធផលសិក្សា (ឬចំនួនឆ្នាំសិក្សាជាមធ្យមដែលរៀនចប់) បានរកឃើញថា ការអប់រំមានឥទ្ធិពលវិជ្ជមានទៅលើកំណើនសេដ្ឋកិច្ច ។ Hanushek និង Kimko (២០០០) បានផ្តោតការយកចិត្តទុកដាក់ទៅលើឥទ្ធិពលនៃគុណភាពអប់រំមានលើកំណើនសេដ្ឋកិច្ច ។ ការប្រើប្រាស់ពិន្ទុសាកល្បងអន្តរជាតិជាតួលេខតំណាងឱ្យគុណភាពនៃប្រព័ន្ធអប់រំពួកគេបានបង្ហាញថាគុណភាពអប់រំមានឥទ្ធិពលវិជ្ជមានលើកំណើនសេដ្ឋកិច្ច ។

**បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍**

មានភស្តុតាងជាច្រើនបង្ហាញថា ICTs មិនត្រឹមតែចូលរួមចំណែកក្នុងកំណើនសេដ្ឋកកិច្ច ទូទៅរបស់ប្រទេសប៉ុណ្ណោះទេ-ហើយថែមទាំងចូលរួមក្នុងកំណើនក្នុងវិស័យ ICTs របស់ខ្លួនទៀតផង។ ការសិក្សានាពេលថ្មីៗដោយសាលាពាណិជ្ជសាស្ត្រទីក្រុងឡុងដ៏បានបង្ហាញថា ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយកំណើនលើការប្រើប្រាស់ទូរស័ព្ទចំនួន១០ក្នុងមនុស្សចំនួន ១០០នាក់ ធ្វើឱ្យមានកំណើនផលិតផលក្នុងស្រុកសរុបត្រឹម ០.៦ ភាគរយ (ដកស្រង់ចេញពីអត្ថបទ "Calling Across the Divide," én The Economist ចេញផ្សាយថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥)។ ការសិក្សាដទៃទៀតលើកឡើងថា ICT បានចូលរួមចំណែកក្នុងផលិតភាពការងារតាមរយៈកំណើនវិនិយោគទុន ICT និងកំណើនខាងវិស័យនានាដែលបង្កើត នូវ ICTs (Zhen-Wei Quiang, Pitt, និង Ayers ២០០៤)។ ទោះបីជាក្រុមហ៊ុន ឬវិស័យនីមួយៗមិនបង្កើតបានផលិផលច្រើន និងការប្រកួតប្រជែងតាមរយៈ ICTs ដោយស្វ័យប្រវត្តិក៏ដោយក៏អាចទទួលផលប្រយោជន៍បានច្រើនដែរ។ របាយការណ៍ថ្មីមួយស្តីពី ICTs និងកំណើនសេដ្ឋកិច្ចក្នុងសេដ្ឋកិច្ចអន្តរកាល បង្ហាញថា ICTs គឺជាអ្នកចូលរួមចំណែកដ៏សំខាន់ក្នុងផលិតកម្ម ការរកប្រាក់ចំណេញ និងកំណើនរបស់ក្រុមហ៊ុន (InfoDev ឆ្នាំ២០០៦)។

**នវានុវត្តន៍**

ការសិក្សាជាច្រើនបានបង្ហាញថា នវានុវត្តន៍ និងការបង្កើតចំណេះដឹងបច្ចេកទេសមានឥទ្ធិពល វិជ្ជមានទៅលើកំណើនសេដ្ឋកិច្ច និងកំណើនផលិតកម្ម។ ឧទាហរណ៍ Lederman និង Maloney (ឆាំ២០០៣) ដោយប្រើទិន្នន័យដើមជាមធ្យម៥ឆ្នាំក្នុងចន្លោះឆ្នាំ១៩៧៥ និង ២០០០ សម្រាប់ប្រទេសចំនួន ៥៣ បានរកឃើញថាកំណើន ១ ភាគរយនៃអត្រាចំណាយសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍន៍លើផលិតផលក្នុងស្រុកសរុបធ្វើឱ្យមានអត្រាកំណើននៃផលិផលក្នុងស្រុកសរុបដល់ ០.៧៨ភាគរយ។ Cincera និង van Pottelsberghe (ឆ្នាំ២០០១) បានអង្កេតលើឥទ្ធិពលដែលមានរយៈពេលវែងតាមប្រភេទផ្សេងៗនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍នៃកំណើនផលិតកម្មចម្រុះវិស័យដោយប្រើប្រាស់បណ្តុំទិន្នន័យ វ៉ែដែឌ ក្នុងរយៈពេល ១៩៨០-៩៨ក។ ពួកគាត់រកឃើញថា ការស្រាវជ្រាវ និងអភិវឌ្ឍន៍ខាងផ្នែកពាណិជ្ជកម្មសាធារណៈ និងបរទេសទាំងអស់មានឥទ្ធិពលវិជ្ជមានយ៉ាងច្រើនទៅលើកំណើនផលិតកម្ម។Adam (១៩៩០) បានប្រើប្រាស់ឯកសារវិទ្យាសាស្ត្រអប់រំជាច្រើនក្នុងវិស័យវិទ្យាសាស្ត្រខុសៗគ្នាធ្វើជាតួលេខតំណាងឱ្យឃ្លាំងចំណេះដឹង បានរកឃើញថា ចំណេះដឹងបច្ចេកវិទ្យាបានចូលរួមចំណែកយ៉ាងច្រើនក្នុងកំណើនផលិតកម្មសរុបនៃឧស្សាហកម្មអាមេរិកចាប់ពី ១៩៥៣-៨០ខ។

ក. Cincera និង van Pottelsberghe (ឆ្នាំ២០០១) សន្មត់យកពាក្យការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាសាធារណៈ ថាជាការស្រាវជ្រាវ និងអភិវឌ្ឍន៍ដែលដំណើរការដោយរដ្ឋាភិបាល និងវិស័យអប់រំឧត្តមសិក្សា ហើយការស្រាវជ្រាវ និងអភិវឌ្ឍន៍បរទេស ថាជាការស្រាវជ្រាវ និងអភិវឌ្ឍន៍ពាណិជ្ជកម្មដែលដំណើរការក្នុងប្រទេស OECD ចំនួន១៥។

ខ. Adams (ឆ្នាំ១៩៩០) បានប្រើប្រាស់ចំនួនប្រជាជននៅទូទាំងពិភពលោកប្រចាំឆ្នាំសម្រាប់ការចេញផ្សាយក្នុងមុខវិជ្ជាសិក្សា ចំនួន៩ : កសិកម្ម ជីវវិទ្យា គីមីវិទ្យា វិទ្យាកុំព្យូទ័រ វិស្វកម្ម ភូគព្ភសាស្ត្រ គណិតវិទ្យា និងស្ថិតិ ឱសថសាស្ត្រ និងរូបវិទ្យា។

*ប្រភព : ការសិក្សាលើការអភិវឌ្ឍរបស់ធនាគារពិភពលោក ឆ្នាំ២០០៧។ ការលើកបណ្តុះសេដ្ឋកិច្ចពុទ្ធិ : យុទ្ធសាស្ត្រឈានមុខដើម្បីការអភិវឌ្ឍ។ ធនាគារពិភពលោក ទំព័រទី២៧។*

| *ប្រអប់ ក.២ គំនិតសំខាន់ៗនៃការអប់រំទូទៅ និងការអប់រំវិជ្ជាជីវៈ* | |
|---|---|
| ការអប់រំទូទៅ | ការអប់រំវិជ្ជាជីវៈ |
| បង្កើត "មូលធនមនុស្សទូទៅ" | បង្កើត "មូលធនមនុស្សជាក់លាក់" |
| គុណសម្បត្តិ: ការអប់រំទូទៅផ្តល់ឱ្យមានការងារពលកម្ម ដែលមានចំណេះដឹងច្រើនដល់កម្មករដែលអាចប្តូរការងារ ឬប្រភេទការងារផ្សេងទៀតបានដោយងាយស្រួល | គុណសម្បត្តិ : ការអប់រំវិជ្ជាជីវៈ ផ្តល់ឱ្យមានជំនាញទាក់ទងនឹងការងារជាក់លាក់ដែលអាចធ្វើឱ្យកម្មករត្រៀមខ្លួនរួចជាស្រេចក្នុងការធ្វើការងារ និងអាចធ្វើឱ្យពួកគាត់ធ្វើការងារបានល្អ។ |
| ចេះបត់បែនសម្របទៅតាមការងារដោយសារតែមានចំណេះដឹងទាំងនេះចាប់ខ្លួន និងពីកន្លែងធ្វើការមួយទៅកន្លែងធ្វើការមួយ | មានជំនាញជាក់លាក់ ដូច្នេះមានការលំបាកក្នុងការស្វែងរកការងារក្រៅពីជំនាញរបស់ខ្លួន។ |

*ប្រភព : Tillak, J.B.G ។ ឆ្នាំ២០០២ ។ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅអាស៊ី ។*

*ប្រអប់ ក.៣ ស្ថាប័នស្រាវជ្រាវ និងផ្តល់ប្រឹក្សារបស់រដ្ឋាភិបាលអូស្ត្រាលី*

ព័ត៌មានខាងក្រោមនេះស្តីអំពីស្ថាប័នស្រាវជ្រាវ និងផល់ប្រឹក្សារបស់រដ្ឋាភិបាលអូស្ត្រាលីជាស្ថាប័នឯករាជមួយសម្រាប់ការស្រាវជ្រាវ និងផ្តល់ប្រឹក្សាដោយធ្វើការសិក្សាលើវិស័យនានាដើម្បីបង្កើនសមត្ថភាពរដ្ឋាភិបាលអូស្ត្រាលីក្នុងការធ្វើការសម្រេចចិត្តទុកជាមុនលើការបង្កើតគោលនយោបាយ។ នេះ គឺជាគំរូមួយដ៏ល្អក្នុងការបង្កើនសមត្ថភាពជំនាញ មនុស្សដែលកម្ពុជានឹងត្រូវការដើម្បីដោះស្រាយបញ្ហាគោលនយោបាយសំខាន់នាពេលអនាគត។ តាមរយៈការអភិវឌ្ឍ សមត្ថភាព ស្រាវជ្រាវ និងវិភាគទៅតាមមាត្រារបស់ស្ថាប័ន រាជរដ្ឋាភិបាលនឹងអាចដោះស្រាយមិនត្រឹមតែកំណែទម្រង់ការអប់រំប៉ុណ្ណោះឱ្យមានប្រសិទ្ធភាពប៉ុណ្ណោះទេ តែថែមទាំងដោះស្រាយបញ្ហាគោលនយោបាយលំបាកជាច្រើន ទៀតដែលខ្លួនអាចជួបប្រទះនៅឆ្នាំខាងមុខទៀត។

**តួនាទីរបស់ស្ថាប័ន**

ស្ថាប័នស្រាវជ្រាវ និងផ្តល់ប្រឹក្សា ជាស្ថាប័នឯករាជ្យក្នុងការស្រាវជ្រាវ និងការប្រឹក្សារបស់រដ្ឋាភិបាលអូស្ត្រាលីស្តីពីបញ្ហាសេដ្ឋកិច្ច សង្គម និងបរិស្ថាននានាដែលប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាជនអូស្ត្រាលី។ ជាងនេះទៅទៀត តួនាទីរបស់ស្ថាប័ននេះ គឺជួយរដ្ឋាភិបាលឱ្យធ្វើគោលនយោបាយកាន់តែប្រសើរដោយទទួលបានប្រយោជន៍រយៈពេលវែងដល់សហគមន៍អូស្ត្រាលី។ ស្ថាប័ននេះ ត្រូវបានបង្កើតឡើងក្នុងនាមជាអាជ្ញាធរឯករាជ្យមួយ ដោយច្បាប់ដែលបង្កើតឡើងដោយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ ដើម្បីជំនួសស្ថាប័នឧស្សាហកម្ម ការិយាល័យសេដ្ឋកិច្ច ឧស្សាហកម្ម និងស្ថាប័នផ្តល់ប្រឹក្សាផែនការសេដ្ឋកិច្ច។

**លំហូរលទ្ធផល ៤ សំខាន់ៗ របស់ស្ថាប័ន**

១. ការអង្កេតសាធារណៈ និងការសិក្សាស្រាវជ្រាវដែលស្នើរឡើងដោយរដ្ឋាភិបាល
២. ការត្រួតពិនិត្យ និងការកំណត់ចំណុចដៅការងារ និងសេវាដទៃទៀតដល់អង្គភាពរបស់រដ្ឋាភិបាល
៣. ការតវ៉ាអព្យាក្រឹត្យភាពដែលមានការប្រកួតប្រជែង
៤. ការគាំទ្រឱ្យមានរបាយការណ៍ស្រាវជ្រាវ និងប្រចាំឆ្នាំស្តីពីផលិតភាព ជំនួយឧស្សាហកម្ម និងបទបញ្ជា

- ស្ថាប័ននេះជាស្ថាប័នផ្តល់ការប្រឹក្សា។ ស្ថាប័ននេះ មិនទទួលខុសត្រូវលើកម្មវិធីរបស់រដ្ឋាភិបាល ឬអនុវត្តអំណាចតុលាការទេ។ ការផ្តល់សេវារបស់ស្ថាប័ននេះផ្អែកលើតម្លៃប្រឹក្សា និងព័ត៌មានឯករាជ្យដែលស្ថាប័ននេះផ្តល់ឱ្យរដ្ឋាភិបាល និងផ្អែកលើតួនាទីណែនាំពីដំណើរការសាធារណៈរបស់ខ្លួន។
- ស្ថាប័ន ជាទីភ្នាក់ងាររបស់រដ្ឋាភិបាលអូស្ត្រាលីដែលមានទីតាំងនៅក្នុងរតនាគារ។ ទោះបីជាយ៉ាងណាសកម្មភាពរបស់ស្ថាប័ន មានគ្រប់កម្រិតរបស់រដ្ឋាភិបាល និងមានគ្រប់វិស័យសេដ្ឋកិច្ចក៏ដូចជាបញ្ហាសង្គម និងបរិស្ថានផងដែរ។
- មុខងារសំខាន់របស់ស្ថាប័ននេះ គឺធ្វើការអង្កេតជាសាធារណៈលើគោលនយោបាយសំខាន់ ឬបញ្ហាគ្រប់គ្រងដែលទាក់ទងនឹងការងារសេដ្ឋកិច្ចរបស់រដ្ឋាភិបាល និងសុខមាលភាពសហគមន៍។ លើសពីនេះទៅទៀតស្ថាប័នធ្វើការស្រាវជ្រាវជាច្រើនលើសំណើររបស់រដ្ឋាភិបាល និងដើម្បីជាជំនួយរបាយការណ៍ប្រចាំឆ្នាំការត្រួត ពិនិត្យការងារ និងការទទួលខុសត្រូវផ្សេងទៀត។
- ស្ថាប័នមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ និងត្រួតពិនិត្យបទបញ្ញត្តព្រមទាំងការផ្តល់ប្រឹក្សាលើអព្យាក្រឹត្យភាពក្នុងការប្រកួតប្រជែងនៃសកម្មភាពការងាររបស់រដ្ឋាភិបាល។

**ស្ថាប័នឯករាជ្យ**

ស្ថាប័នប្រតិបត្តិការក្រោមអំណាច ការការពារ និងការណែនាំនៃការអនុវត្តច្បាប់របស់ខ្លួនតែប៉ុណ្ណោះ។ ឯករាជ្យភាពរបស់ស្ថាប័នត្រូវបានធ្វើឡើងជាផ្លូវការក្រោមច្បាប់ស្ថាប័នស្រាវជ្រាវនេះ តាមរយៈប្រធាន អនុប្រធាន និងសមាជិកដែលត្រូវបានតែងតាំងដោយអភិបាលរដ្ឋគ្នានរយៈពេលកំណត់។ ស្ថាប័នមានកញ្ចប់ថវិកាផ្ទាល់ខ្លួន និងបុគ្គលិកអចិន្ត្រៃយ៍ដែលដំណើរការការងារទៅតាមស្ថាប័នរដ្ឋាភិបាល។ នៅពេលដែលរដ្ឋាភិបាលកំណត់កម្មវិធីការងាររបស់ខ្លួនហើយនោះលទ្ធផល និងអនុសាសន៍របស់ស្ថាប័នផ្អែកលើការវិភាគ និងការវិនិច្ឆ័យរបស់ស្ថាប័ន។ ស្ថាប័នរាយការណ៍ជាផ្លូវការតាមរយៈហិរញ្ញិកនៃរដ្ឋសភាអូស្ត្រាលីដែលរបាយការណ៍អង្កេតត្រូវបានយកមកពិភាក្សា។ ទោះបីយ៉ាងណាតម្រូវការជាផ្លូវការលើការលើកកម្ពស់ការយល់ដឹងសាធារណៈនៃបញ្ហាគោលនយោបាយជាមួយនឹងទស្សនៈ លើកកម្ពស់ស្ថានភាពរស់នៅរបស់ប្រជាជនអូស្ត្រាលី មានន័យថារបាយការណ៍របស់ស្ថាប័នក៏មានគោលដៅនៅសហគមន៍ដែរ។

**ដំណើរការរបស់ស្ថាប័នមានតម្លាភាព**

ការប្រឹក្សារបស់ស្ថាប័នជាមួយរដ្ឋាភិបាល និងព័ត៌មានស្តីពីស្ថាប័ននេះទទួលបាន គឺបើកទូលាយដល់សាធារណៈជនក្នុងការរិះគន់។ ដំណើរការរបស់ស្ថាប័នផ្តល់នូវធនធានសាធារណៈយ៉ាងច្រើនតាមរយៈការចូររួមស្តាប់សិក្ខាសាលា និងវេទិកាប្រឹក្សាផ្សេងៗ និងតាមរយៈការចេញផ្សាយរបាយការណ៍ព្រាង និងលទ្ធផលដំបូង។

**ស្ថាប័នអនុម័តទស្សនៈវិសាលភាពសហគមន៍**

ស្ថាប័នមានកាតព្វកិច្ចធ្វើឱ្យទស្សនៈទូលំទូលាយដោយផ្តោតការយកចិត្តទុកដាក់លើសេដ្ឋកិច្ច និងសហគមន៍ជាជាងលើឧស្សាហកម្ម ឬក្រុមជាក់លាក់ក្រោមគោលការណ៍ណែនាំផ្លូវការណ៍របស់ខ្លួន។ វិសាលភាពបរិស្ថាន តំបន់ និងសង្គមនៃការងាររបស់ស្ថាប័នយកមកពិចារណាយ៉ាងហ្មត់ចត់ ផ្តល់ដំណឹងដោយការប្រឹក្សាជាសាធារណៈ និង សមត្ថភាពស្រាវជ្រាវផ្ទាល់របស់ស្ថាប័ននេះ។

*ប្រភព : ស្ថាប័នស្រាវជ្រាវ និងផ្តល់ប្រឹក្សារបស់រដ្ឋាភិបាលអូស្ត្រាលី : ការណែនាំខ្លីនៃស្ថាប័នស្រាវជ្រាវ និងផ្តល់ប្រឹក្សា។*

*ប្រអប់ ក.៤ វចនាសម្ព័ន្ធក្របខ័ណ្ឌការងារមន្ត្រីរាជការក្នុងប្រទេសកម្ពុជា*

| វចនាសម្ព័ន្ធ/ សមាសភាព | មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌការងារទាំងបួន : | | | |
|---|---|---|---|---|
| | ក្របខ័ណ្ឌការងារ ក : អ្នកគ្រប់គ្រង (អ្នកដឹកនាំ អ្នកសម្រេចចិត្ត) ចែកចេញជា ៣ កម្រិតតូច : | ក្របខ័ណ្ឌការងារ ខ : មន្ត្រីរាជការកម្រិត កណ្តាល (ជំនួយការថ្នាក់ដឹកនាំ) ចែកចេញជាបីកម្រិតតូច : | ក្របខ័ណ្ឌការងារ គ : លេខា ឬការីជំនាញ(ប្រតិបត្តិ) ចែកចេញជាបីកម្រិតតូច | ក្របខ័ណ្ឌការងារ ឃ : ភ្នាក់ងាររដ្ឋបាលចែកចេញជាបីកម្រិតតូច |
| មន្ត្រីរាជការស៊ីវិលសញ្ជាតិកម្ពុជា ចាត់ទុកថាជាបណ្តុំមន្ត្រីរាជការ ស៊ីវិលដែលធ្វើការទាំងនៅទីស្នាក់ការ ឬការិយាល័យនៅតាមខេត្ត ដូចដែលមានបង្ហាញក្នុងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។ រដ្ឋលេខាធិការដ្ឋាននៃមន្ត្រីស៊ីវិល (SSCS) គ្រប់គ្រងលើមន្ត្រីស៊ីវិលទាំងអស់ ដោយមិនរាប់បញ្ចូលយោធាកងកម្លាំងនគរបាល និងចៅក្រមសេចក្តីសម្រេច គតិយុត្តិ និងមន្ត្រីរាជការសេចក្តីសម្រេចអនុវត្តច្បាប់ ។ ចំនួនបុគ្គលិកមន្ត្រីរាជការ សរុបមានចំនួន ១៦៦.៣៨១ ក្នុងឆ្នាំ ២០០៣ ដែលក្នុងនោះ ៦៩%ជាបុរស និង ៣១%ជាស្ត្រី (២០០០) ។ បុគ្គលិកក្នុងក្រុមអាយុនីមួយៗ មានដូចតទៅ :<br>• ២០ និងក្រោម :0,៣%<br>• ២១-៣០ : ៣២,៥%<br>• ៣១-៤០ : ២៩,៧%<br>• ៤១-៥០ : ២៧%<br>• ៥១-៦០ : ១១%<br>• ៦១-៧០ : 0,00៣% (២០០០)<br>វចនាសម្ព័ន្ធរដ្ឋបាលសាធារណៈ មានពីរកម្រិត ទីស្នាក់ការកណ្តាល និងការិយាល័យតំបន់ ។ ការិយាល័យដែលចាត់ទុកថា ជាទីស្នាក់ការកណ្តាល មានក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន ដូចជា អាជ្ញាធរ គណៈកម្មការ និងក្រុមប្រឹក្សា ។ល។ ការិយាល័យដែលចាត់ទុកថាជា ការិយាល័យតំបន់ រួមមាន មន្ទីរខេត្ត និងរាជធានី និង ការិយាល័យស្រុក ។ ឯកសណ្ឋានដែលកំណត់ និងរចនាម៉ូត សម្រាប់មន្ត្រីស៊ីវិល ។ ដោយមានករណីលើកលែងពីក្រសួងព្រះបរមរាជវាំង ក្រសួងយុត្តិធម៌ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋលេខាធិការដ្ឋានរដ្ឋបាលសាធារណៈ និង រដ្ឋលេខាធិការ ដ្ឋានអាកាសចរស៊ីវិលក្រសួង នីមួយៗមានមន្ទីរ ខេត្ត និងរាជធានី ដោយមន្ទីរ នីមួយៗមានស្រុកផ្ទាល់ខ្លួន ។ | **កម្រិត ក១ :**<br>ប្រធានផ្នែករដ្ឋបាល (មាន៦ ថ្នាក់ពី ក.១-៦ ដល់ ក១-១)<br>តំណែង :<br>អគ្គលេខាធិការ អគ្គលេខាធិការរង អគ្គនាយក អគ្គធិការដ្ឋាន អភិបាលខេត្ត-ក្រុង | **កម្រិត ខ១ :**<br>ប្រធានមន្ត្រីរាជការ កម្រិតមធ្យម (មាន ៦ថ្នាក់ពី ខ១-៦ ដល់ ខ១-៣)<br>តំណែង :<br>ទីស្នាក់ការកណ្តាល អនុប្រធានមន្ទីរ អភិបាលរងស្រុក | **កម្រិត គ១ :**<br>ប្រធានលេខា (មាន ៦ថ្នាក់ពី គ១-៦ ដល់ គ១-១)<br>តំណែង : អនុប្រធានមន្ទីរស្រុក | **កម្រិត ឃ១ :**<br>ប្រធានភ្នាក់ងាររដ្ឋបាល (មាន ៦ ថ្នាក់ពី ឃ១-៦ ដល់ ឃ១-១)<br>តំណែង : អ្នកជំនាញជាន់ខ្ពស់ |
| | **កម្រិត ក ២ :**<br>ប្រធានផ្នែករដ្ឋបាល (មាន ១០ ថ្នាក់ពី ក២-១០ ដល់ ក២-១)<br>តំណែង :<br>អគ្គនាយករង អគ្គធិការរង ប្រធាននាយកដ្ឋានកណ្តាល អភិបាលរងខេត្ត-ក្រុង និងប្រធានស្រុក អធិការ | **កម្រិត ខ ២:**<br>ប្រធានមន្ត្រីស៊ីវិល ថ្នាក់កណ្តាល (មាន៣០ ថ្នាក់ពី ខ ២-១០ ដល់ ខ ២-១)<br>តំណែង :<br>អនុប្រធានការិយាល័យកណ្តាលមន្ទីរខេត្ត | **កម្រិត គ ២:**<br>នាយកលេខា (មាន ១០ថ្នាក់ពី គ២-១០ ដល់ គ២-១)<br>តំណែង :<br>ក្រឡាបញ្ជីទូទៅ | **កម្រិត ឃ ២:**<br>ប្រធានភ្នាក់ងាររដ្ឋបាល (មាន ១០ថ្នាក់ពី ឃ ២-១០ ដល់ ឃ២-១)<br>តំណែង :<br>អ្នកជំនាញថ្នាក់មធ្យម |
| | **កម្រិត ក ៣ :**<br>អ្នករដ្ឋបាល (មាន ១៤ថ្នាក់ពី ក៣-១៤ ដល់ ក៣-១) តំណែង :<br>អនុប្រធានមន្ទីរកណ្តាលប្រធានមន្ទីរបរិញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតដែលមិនមានមុខតំណែង | **កម្រិត ខ ៣ :**<br>**មន្ត្រីស៊ីវិល កម្រិតកណ្តាល (មាន ១៤ថ្នាក់ពី ខ៣-១៤ ដល់ ខ៣-១)**<br>**តំណែង :**<br>**អនុប្រធានទីស្នាក់ការខេត្ត ទីស្នាក់ការស្រុក** | **កម្រិត គ ៣ :**<br>**លេខា (មាន ១៤ថ្នាក់ពី គ ៣-១៤ ដល់ គ ៣-១)** | **កម្រិត ឃ ៣ :**<br>ភ្នាក់ងាររដ្ឋបាល (មាន១៤ថ្នាក់ពី ឃ ៣-១៤ ដល់ ឃ ៣-១)<br>តំណែង :<br>អ្នកជំនាញថ្នាក់ទាប |

*ប្រភព : បណ្តាញការងាររដ្ឋបាលសាធារណៈរបស់អង្គការសហប្រជាជាតិ- NEW YORK EASTERN REGIONAL ORGANIZATION FOR PUBLIC ADMINISTRATION ប្រព័ន្ធក្របខ័ណ្ឌការងារមន្ត្រីរាជការសាធារណៈនៅតំបន់អាស៊ាន: ទស្សនៈប្រៀបធៀប ។*

*ប្រអប់ ក.៩ លក្ខខណ្ឌក្របខ័ណ្ឌការងារមន្ត្រីរាជការនៅប្រទេសកម្ពុជា*

១. មានលក្ខខណ្ឌមូលដ្ឋានមួយចំនួនសម្រាប់ការងារក្នុងជួររដ្ឋាភិបាលដែលមានជាទូទៅសម្រាប់មុខងារទាំងអស់។

លក្ខខណ្ឌទាំងនេះរួមមាន ៖

ក. ត្រូវតែមានសញ្ជាតិកម្ពុជា

ខ. ត្រូវមានអាយុតិចបំផុត ១៨ឆ្នាំ មិនត្រូវមានអាយុលើសពី២៥ឆ្នាំឡើយ។ ប៉ុន្តែ ក៏មានករណីលើកលែងមួយចំនួនសម្រាប់ ៖

- បេក្ខជនដែលមានសញ្ញាបត្រជាន់ខ្ពស់ពីឧត្តមសិក្សាដែលករណីកំណត់អាយុត្រូវតែ ៖ បេក្ខជនដែលមានការសិក្សារយៈពេលមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំនៅថ្នាក់ឧត្តមសិក្សាដោយមិនទទួលបានវិញ្ញាបនប័ត្រ ហើយក្នុងករណីកំណត់អាយុ២៥ឆ្នាំ នឹងគិតត្រឡប់ទៅរយៈពេលឱ្យស្មើនឹងការសិក្សារបស់គាត់ដោយមិនឱ្យលើស អាយុ ៣០ ឆ្នាំ ឡើយ។
- បេក្ខជនដែលសម្រេចបានសមិទ្ធផលសំខាន់ៗនៅក្នុងការបម្រើជាយោធា ក្នុងករណីដែលដល់អាយុត្រូវគិត ត្រឡប់ទៅរយៈពេលស្មើនឹងការបម្រើការងារជាយោធារបស់ពួកគេ និង
- សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្ត ក្នុងករណីចាំបាច់តាមរយៈអនុក្រិតរាល់ការកំណត់ទាក់ទងនឹង អាយុបេក្ខជនដើម្បីបំពេញតម្រូវការដែលយល់ថាជាអាទិភាព និងផលប្រយោជន៍ជាតិ

គ. មិនត្រូវបានដកហូតសិទ្ធិជាពលរដ្ឋ សិទ្ធិសង្គមស៊ីវិល និងសិទ្ធិនយោបាយ

ឃ. មិនធ្លាប់បានប្រព្រឹត្តបទឧក្រិត ឬករណីនៃការប៉ុនប៉ងប្រព្រឹត្តិបទល្មើស ប្រាសចាកសីលធម៌ កិត្តិយស ឬភាពស្អាតស្អំ

ង. ត្រូវបំពេញឱ្យបាននូវកាយសម្បទារឹងមាំដើម្បីអនុវត្តរាល់មុខងារតម្រូវតាមរយៈគោលការណ៍ណែនាំ និងបទបញ្ជាជាធរមាន

ច. បេក្ខជនដែលមកពីសហគមន៍ជនជាតិភាគតិចមកពីតំបន់ដាច់ស្រយាល ព្រមទាំងស្ត្រីនឹងទទួលបានអត្ថប្រយោជន៍ពីសេវា ឬវិធានចម្បងសម្រាប់ការជ្រើសរើស និង

ឆ. ត្រូវបំពេញតាមលក្ខខណ្ឌសម្បទាកំណត់ដោយអង្គភាពគ្រប់គ្រងជាក់លាក់។

២. លក្ខខណ្ឌតែមួយសម្រាប់មុខតំណែងជាក់លាក់មានដូចជា ៖

ក្របខ័ណ្ឌការងារ ក. តម្រូវឱ្យមានយ៉ាងហោចណាស់សញ្ញាបត្របរិញ្ញាបត្រ

ក្របខ័ណ្ឌការងារ ខ. តម្រូវឱ្យមានយ៉ាងហោចណាស់វិញ្ញាបនបត្រវិជ្ជាជីវៈកម្រិតមធ្យម (សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២)

ក្របខ័ណ្ឌការងារ គ. តម្រូវឱ្យមានយ៉ាងហោចណាស់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ក្របខ័ណ្ឌការងារ ឃ. មិនចាំបាច់មានសញ្ញាបត្រ

តាមរយៈសេចក្តីស្នើច្បាប់របស់ក្រសួងពាក់ព័ន្ធ SSCS សម្របសម្រួល និងបង្កើតផែនការបុគ្គលិកប្រចាំឆ្នាំ តាមរយៈការរក្សានៅចំនួនបុគ្គលិកដើម្បីស្នើរដ្ឋាភិបាលធ្វើសេចក្តីសម្រេច។ បន្ទាប់មកទៀត SSCS ផ្តល់ព័ត៌មានដល់ក្រសួងពាក់ព័ន្ធដើម្បីរៀបចំការប្រឡងប្រកួតប្រជែង។

៣. ខាងក្រោមនេះគឺជាស្តង់ដាក្នុងនីតិវិធីជ្រើសរើសបុគ្គលិក ៖

មុនពេលប្រឡង មានការបង្កើតប្រធានគណៈកម្មការជ្រើសរើសបុគ្គលិកដោយមានវត្តមាន SSCS។ ការប្រឡងសរសេរនឹងប្រព្រឹត្តទៅដោយផ្តោតលើផ្នែកដូចខាងក្រោមនេះ ៖

ក. មុខវិជ្ជាសំខាន់ (ច្បាប់ ព័ត៌មានវិទ្យា ហិរញ្ញវត្ថុ ការគ្រប់គ្រង...)

ខ. វប្បធម៌ទូទៅ

គ. ភាសា (អង់គ្លេស)

*ប្រភព ៖ បណ្តាញការងាររដ្ឋបាលសាធារណៈរបស់អង្គការសហប្រជាជាតិ– NEW YORK EASTERN REGIONAL ORGANIZATION FOR PUBLIC ADMINISTRATION ។ ២០០៤ ប្រព័ន្ធរដ្ឋបាលសាធារណៈនៅតំបន់អាស៊ាន ៖ ទស្សនៈប្រៀបធៀប។*

*ប្រអប់ ក.៦ ការគ្រប់គ្រងភាពជាដៃគូរបស់អាស៊ាន*

វិបត្តិហិរញ្ញវត្ថុពិភពលោកដែលចាប់ផ្តើមនៅឆ្នាំ២០០៧ បានប៉ះពាល់យ៉ាងខ្លាំងដល់ប្រទេសនានា។ ប្រទេសមួយចំនួនអាចទ្រាំទ្រនៅនឹងវិបត្តិនេះ ហើយអាចដោះស្រាយនឹងវិបត្តិនេះបានល្អទៀតផង ប៉ុន្តែប្រទេសមួយចំនួនទៀតនៅតែបន្តទទួលរងឥទ្ធិពលពីវិបត្តិនេះ។ ប្រទេសកម្ពុជាក៏ជាប្រទេសមួយដែលរងវិបត្តិនេះដែរ។ ឆ្លើយតបនៅនឹងហេតុការណ៍នេះ កម្ពុជាត្រូវការមធ្យោបាយដើម្បីជួយកសាងផែនការស្តារសេដ្ឋកិច្ចដែលទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីវិបត្តិនេះ។

មធ្យោបាយមួយដើម្បីឱ្យកម្ពុជាដោះខ្លួនចេញពីវិបត្តិនេះ គឺការបង្កើនកិច្ចសហការយ៉ាងខ្លាំងក្លា និងបង្កើតចំណងមិត្តភាពឱ្យបានជិតស្និត និងកាន់តែខ្លាំងជាមួយប្រទេសសមាជិករបស់អាស៊ាន។ ត្រូវចងចាំថាកម្ពុជាបានធ្វើដំណើរដ៏វែងឆ្ងាយ និងច្រើនឆ្នាំពីសម័យខ្មែរក្រហមដ៏យង់ឃ្នងបន្ទាប់មកស្ថានភាពនយោបាយនិងសេដ្ឋកិច្ចបានចាប់ផ្តើមមានភាពរីកចម្រើន។ ប្រការចាំបាច់បំផុត គឺថាកម្ពុជាត្រូវទទួលបានឱកាស និងគាំទ្រពីប្រទេសជិតខាង និងប្រទេសជាសមាជិកអាស៊ានក្នុងតំបន់។ ការធ្វើសមាហរណកម្មទីផ្សាររបស់សហភាពអឺរ៉ុបដ៏ជោគជ័យនោះ គឺជាមេរៀនប្រាប់យើងទាំងអស់គ្នាដឹងថាការធ្វើសមាហរណកម្ម និងកិច្ចសហប្រត្តិបត្តិការក្នុងតំបន់ជាមួយនឹងប្រទេសអាស៊ានអាចបង្កើននូវផលប្រយោជន៍យ៉ាងច្រើន។

ប្រទេសសមាជិកអាស៊ានអាចទទួលបានផលយ៉ាងច្រើនពីកិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មនេះ។ គុណប្រយោជន៍មួយចំនួនអាចមានដូចជា លំហូរទំនិញសេវាប្រសើរជាងមុនការកើនឡើងការប្រកួតប្រជែង និងការវិនិយោគការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពជាងមុន ការកាត់បន្ថយពន្ធពាណិជ្ជកម្មសម្រាប់ពាណិជ្ជកម្មក្នុងតំបន់ការអភិវឌ្ឍសេដ្ឋកិច្ចដោយសមធម៌ និងការពង្រីកមូលដ្ឋានទីផ្សារ។ ចំពោះឥទ្ធិពលជំនួញវិញលោក Rosabel B. Guerrero បានលើកឡើងថា "នៅពេលដែលសុខមាលភាពសេដ្ឋកិច្ចកើនឡើងដែលពីមុនធនធានយកមកធ្វើជាផលិតកម្មប្រើប្រាស់មានការបែងចែកសាជាថ្មីឡើងវិញឱ្យមានប្រសិទ្ធភាពដោយផ្តោតលើគុណប្រយោជន៍ប្រហាក់ប្រហែលគ្នារបស់ប្រទេស ហើយការបែងចែកសាជាថ្មីនេះនឹងធ្វើឱ្យមានឱកាសកាន់តែប្រសើរជាងមុន"[១]។ ចំណុចជាក់លាក់ដែលត្រូវលើកឡើងគឺថា មានការយល់ឃើញពីទីផ្សារក្នុងតំបន់ថា ជាឱកាសពាណិជ្ជកម្មដោយប្រទេសនានានៅក្រៅតំបន់អាស៊ាន។

ការយល់ឃើញនេះ ក៏មានការទាក់ទងទៅនឹងការកំណត់លើតួនាទីរបស់អាស៊ានចំពោះគោលបំណងនៃអ្នកដែលមានបំណងធ្វើពាណិជ្ជកម្មឱ្យបានត្រឹមឆ្នាំ២០១៥ និងការយកចិត្តទុកដាក់នាពេលថ្មីៗនេះរបស់សមាជិកអាស៊ានស្តីពីការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍជំនាញនៅទូទាំងតំបន់។ នៅខណៈពេលដែលសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ានស្តីពីការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍជំនាញសម្រាប់ឱ្យភាពប្រសើរឡើងនៃសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចឱ្យមាននិរន្តរភាពនៅ ឆ្នាំ២០១០ ថ្នាក់ដឹកនាំបានលើកឡើងពីតម្រូវការក្នុងការ :

- ការពង្រឹងការសហការលើការអប់រំដើម្បីសម្រេចឱ្យមានសហគមន៍យកចិត្តទុកដាក់ និងចែករំលែកនៅអាស៊ានដែលមានការទទួលស្គាល់ពីតួនាទី នៃការអប់រំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងការអភិវឌ្ឍក្របខ័ណ្ឌជំនាញជាតិទៅជាជំហានបន្ថែមឆ្ពោះទៅក្រមខ័ណ្ឌទទួលស្គាល់ជំនាញនៅអាស៊ាន
- ការយល់ដឹងពីសារសំខាន់នៃការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍជំនាញនៅក្នុងការលើកកម្ពស់ផលិតកម្ម និងការបង្កើនភាពប្រសើរឡើងនៃសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចឱ្យមាននិរន្តរភាពនៅក្នុងវិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលថ្មីៗនេះ។
- ការទទួលស្គាល់ថា បញ្ហាប្រឈមក្នុងការអភិវឌ្ឍធនធានមនុស្សគឺមានសារៈសំខាន់ដែលអាស៊ានបានកំពុងតែប្រឈមនឹងការស្តារសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច នឹងមានការពង្រឹងការប្រកួតប្រជែងការងារការលើកកម្ពស់ជំនាញការងារ ការបង្កើតការងារឡើងវិញ និងការបង្កើនផលិផល។

គោលបំណងទាំងនេះឈានទៅរកគោលដៅ : (១) ការលើកកម្ពស់ការសហការបច្ចេកទេស និងសកម្មភាពកសាងសមត្ថភាពនៅអាសាន (២) ការលើកកម្ពស់ការសហការត្រីភាគី និងវិស័យឯកជន-សាធារណៈ (៣) ការលើកកម្ពស់គុណភាព និងជំនាញរបស់និយោជិតនៅក្នុងប្រទេសជាសមាជិកអាស៊ាន និង (៤) ការលើកកម្ពស់ការរៀនសូត្រពេញមួយជីវិត

**ការព្រមព្រៀងចំមួយចំនួនដែលបានផ្លាស់ប្តូរតំបន់ឱ្យកាន់តែខិតទៅជិតទស្សនៈវិស័យសហគមន៍សេដ្ឋកិច្ចអាស៊ាន២០១៥ :**

១. អាស៊ាន បូក ៦ អាចនាំចូល និងនាំចេញស្ទើរគ្រប់ទំនិញទាំងអស់ រីឯពន្ធដែលមានភាគរយលើពី ៩៩% បានកាត់បន្ថយពី 0-៥%សម្រាប់កម្ពុជាដែលមានព្រំប្រទល់ជាប់ប្រទេសឡាវ ភូមា និងវៀតណាម

២. តំបន់ពាណិជ្ជកម្មសេរីអាសាន-ចិន ក៏បានអនុវត្តពេញលេញដែលបានលុបចោលពន្ធយ៉ាងហោចណាស់ ៩០%លើ ពាណិជ្ជកម្មទ្វេភាគីអាស៊ាន-ចិន

៣. ក្រោមតំបន់ពាណិជ្ជកម្មសេរីអាសាន-កូរ៉េ ផលិតផលនៃពាណិជ្ជកម្មទ្វេភាគី ៩០% ត្រូវបានលុបចោល

៤. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ញូវហ្ស៊ីលែន ក៏បានបង្កើតឡើង

៥. ពាណិជ្ជកម្មអាស៊ាន-ឥណ្ឌានៅក្នុងកិច្ចព្រមព្រៀងទំនិញ បានអនុវត្តជាផ្លូវការដែលរៀបចំធ្វើឡើងដើម្បីបង្កើត តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា

**បញ្ហាប្រឈមក្នុងការសម្រេចសមាហរណកម្មសេដ្ឋកិច្ចពេញលេញ :**

១. ទៅតាមរចនាសម្ព័ន្ធមិនបំពានគ្នាក្នុងតំបន់អាស៊ាន ការអនុវត្តកិច្ចព្រព្រៀងពាណិជ្ជកម្មបូកនឹងគម្រោងសមាហរណកម្មមានការលំបាកក្នុងការសហការ ។

២. សមាហរណកម្មមានកំណត់ និងឧបសគ្គក្នុងការនាំទំនេញឆ្លងកាត់បណ្តាប្រទេសជាសមាជិកអាស៊ានធ្វើឱ្យមានការលំបាកក្នុងការកសាងទំនុកចិត្តរបស់អ្នកវិនិយោគទន់ ។

៣. ទីផ្សារអាស៊ាននៅតែមិនទូលាយ និងគ្មានការសហការបើប្រៀបធៀបទៅនឹងទីផ្សារប្រទេសចិន សហភាពអឺរុប និងទីផ្សារផ្សេងទៀត ។

**តម្លៃសេដ្ឋកិច្ចសម្រាប់កម្ពុជាដែលជាប្រទេសសមាជិកក្នុងតំបន់អាស៊ាន ៖**

១. ប្រព័ន្ធសមាហរណកម្មអនុគ្រោះអាស៊ាន ពន្ធពិសេសជាមួយប្រទេសចិន ប្រព័ន្ធអនុគ្រោះទូលំទូលាយជាមួយជប៉ុន និងសាធារណៈរដ្ឋកូរ៉េ ។

២. អាស៊ាន បានអនុវត្តសកម្មរួមជាមួយនឹងប្រទេសរុស្ស៊ីនៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទេសចរណ៍ សហគ្រាសខ្នាតតូច និងមធ្យម និងការអប់រំ ។

៣. អាស៊ាន ស្ថិតនៅចំកណ្ដាលស្ថាបត្យកម្មតំបន់ដែលកំពុងតែកើតមាននៅអាស៊ីបូព៌ា ៖ អាស៊ានបូក៣ និងដំណើរការ កិច្ចប្រជុំកំពូលនៅអាស៊ីបូព៌ា កំពុងតែរកមើលលទ្ធភាពក្នុងការធ្វើសមាហរណកម្មតំបន់ពាណិជ្ជកម្មសេរីរបស់ប្រទេសដែលបានចូលរួមមានដូចជា តំបន់ពាណិជ្ជកម្មសេរីអាស៊ីបូព៌ាសម្រាប់អាស៊ានបូក៣ និងភាពជាដៃគូក្នុងវិស័យសេដ្ឋកិច្ចឱ្យបានទូលំទូលាយសម្រាប់អាស៊ីបូព៌ានៅប្រទេសដែលចូលរួមកិច្ចប្រជុំកំពូលនៅអាស៊ីបូព៌ា ។

៤. ដោយបានលើកឡើងថាពាណិជ្ជកម្ម គឺជាចលករសំខាន់មួយដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ការពង្រីកពាណិជ្ជកម្មក្នុងតំបន់ដែលកើតឡើងពីការប្ដេជ្ញាចិត្តក្នុងការបង្កើតសហគមន៍អាស៊ាននៅត្រឹមឆ្នាំ២០១៥ ផ្ដល់ឱ្យមានឱកាសដ៏សំខាន់សម្រាប់ប្រទេសជាសមាជិកក្នុងការទទួលបានប្រយោជន៍ពីការធ្វើសមាហរណកម្មក្នុងតំបន់ និងការពង្រឹងការរក្សាស្ថានភាពសេដ្ឋកិច្ចឱ្យមានភាពល្អប្រសើរដើម្បីត្រៀមខ្លួនទប់ទល់នឹងវិបត្តខាងក្រៅនាពេលអនាគត (អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០១០) ។

**រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការមួយចំនួនដើម្បីបង្កើនសមាហរណកម្មរបស់ប្រទេសជាមួយនឹងទីផ្សារតំបន់ដោយ មានមានការប្ដេជ្ញាចិត្តដើម្បី ៖**

១. ចូលរួមក្នុងការពិភាក្សា/ចរចារដើម្បីក្លាយជាសមាជិកនៃវេទិកាសហការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីភិច និងបន្តចូលរួមកសាងសហគមន៍ និងបណ្ដាញអាស៊ាននៃអាស៊ីបូព៌ា ។

២. លើកកម្ពស់យ៉ាងសកម្មក្នុងការបង្កើតអាស៊ានបូកចិន អាស៊ានបូកកូរ៉េ អាស៊ានបូកអូស្ត្រាលី-ញូហ្ស៊ីលែន ក៏ដូចជាការបង្កើតមជ្ឈមណ្ឌលអាស៊ានបូកចិន និងអាស៊ានបូកកូរ៉េផងដែរ ។

៣. ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តអនុតំបន់ទន្លេមេគង្គ យុទ្ធសាស្ត្រសហការសេដ្ឋកិច្ចទន្លេមេគង្គ Ayeyawada-Chao Phray ដោយផ្ដោតលើការអភិវឌ្ឍវិនិយោគទន់ឆ្លងដែន ការដឹកជញ្ជូនឆ្លងដែន និងការធ្វើវិនិយោគទន់នៅតំបន់ព្រំដែន ។

៤. ចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍច្រកសេដ្ឋកិច្ចតាមរយៈ វេទិកាច្រកសេដ្ឋកិច្ចនៃអនុតំបន់ទន្លេមេគង្គជាមួយនឹងការចូលរួមនៃវេទិកាអភិបាលខេត្ត និងធានាឱ្យមានច្រកសេដ្ឋកិច្ចអនុតំបន់ទន្លេមេគង្គក្នុងការលើកកម្ពស់ការអភិវឌ្ឍតំបន់ដាច់ស្រយាល ។

| *ប្រអប់ ក.៧ កាលបរិច្ឆេទកំណត់នៃដំណាក់កាលសំខាន់ៗក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់អាស៊ាន* | | |
|---|---|---|
| កាលបរិច្ឆេទ | ព្រឹត្តិការណ៍សំខាន់ៗ | ការពិពណ៌នា |
| ១៩៦៧ | សេចក្តីប្រកាសទីក្រុងបាងកក | អាស៊ានបង្កើតឡើងដោយ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ។ |
| ១៩៧៧ | កិច្ចព្រមព្រៀងស្តីពីការរៀបចំពាណិជ្ជកម្មអាស៊ានដោយអនុគ្រោះ | កិច្ចព្រមព្រៀងដំបូងបំផុតរបស់អាស៊ានក្នុងចំណោមកិច្ចព្រមព្រៀងទាំងឡាយស្តីពីការអនុវត្តកាតព្វកិច្ចច្បាប់។ ប្រទេសសមាជិកបានព្រមព្រៀងអនុវត្តការយកអត្រាពន្ធគយដោយអនុគ្រោះផ្អែកលើទំហំអនុគ្រោះលើអត្រា ប្រទេសដែលទទួលបានការអនុគ្រោះពាណិជ្ជកម្ម ផ្អែកលើទំនិញផលិតផលរបស់គម្រោងឧស្សាហកម្មអាស៊ាន និងវិស័យផ្សេងៗទៀតដែលផ្តល់នូវភាពចំណេញ។ |
| ១៩៨៤ | ប្រទេសប្រ៊ុយណេចូលជាសមាជិកអាស៊ាន | |
| ១៩៨៧ | ការពង្រឹងការរៀបចំពាណិជ្ជកម្មដោយអនុគ្រោះ | ការកែលម្អកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះ ឧទាហរណ៍ ដោយការកាត់បន្ថយទំនិញហាមឃាត់មិនឱ្យនាំចូលនាំចេញ ការបន្តកាត់បន្ថយពន្ធគយ និងការសម្រាលខ្លឹមសារលក្ខខណ្ឌរបស់អាស៊ានក្នុងវិធានដើម។ |
| ១៩៨៧ | កិច្ចព្រមព្រៀងស្តីពីការធានាលើការវិនិយោគ | កិច្ចព្រមព្រៀងស្តីពីការធានាលើការវិនិយោគ ផ្តល់ការការពារដល់ការវិនិយោគដោយផ្ទាល់ពីបរទេសរវាងអាស៊ាន និងប្រទេសជាសមាជិក រួមទាំងការផ្តល់សំណងក្នុងករណី មានការធ្វើអស្សាមិករណ៍ ការធានាដល់សិទ្ធិរបស់ វិនិយោគិនក្នុងការផ្ទេរប្រាក់ចំណេញមកប្រទេសខ្លួនដោយអនុវត្តស្របតាមច្បាប់ស្រុក និងការផ្តល់មជ្ឈត្តវិនិច្ឆ័យរវាងភាគីក្នុងករណីមានជម្លោះ។ |
| ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៣ | ការអនុវត្តតំបន់ពាណិជ្ជកម្មអាស៊ានសេរី | ប្រទេសជាសមាជិកបានព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មអាស៊ានសេរី និងផែនរួមការស្តីពីការយកពន្ធគយដោយអនុគ្រោះប្រកបដោយប្រសិទ្ធភាព នៅពេលដែលប្រភេទផលិតផលចំនួន៩៩ភាគរយ នឹងត្រូវអនុវត្តការយកពន្ធតាមអត្រាពន្ធគយក្នុងតំបន់អាស៊ាន ដែលកាត់បន្ថយពន្ធពី ០ ដល់ ៥ ភាគរយ។ |
| ១៩៩៥ | ប្រទេសវៀតណាមចូលជាសមាជិកអាស៊ាន | |
| ១៩៩៥ | កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា | ដោយផ្អែកលើកិច្ចព្រមព្រៀងរួមស្តីពីសេវាពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងនេះមានគោលបំណងលុប ចោលនូវការកម្រិតលើសេវាពាណិជ្ជកម្ម ពង្រឹង សហប្រតិបត្តិការសេវាក្នុងតំបន់អាស៊ាន និងបង្កើនលទ្ធភាព ទទួលបានសេវាពាណិជ្ជកម្មផ្អែកលើកិច្ចព្រមព្រៀងទូទៅស្តីពីសេវាពាណិជ្ជកម្មបូករួមជាមួយគោលការណ៍។ ការធ្វើការចរចារ ប្រកបដោយភាពជោគជ័យ ដើម្បីបង្កើនសេវាពាណិជ្ជកម្ម។ |

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍សំខាន់ៗ | ការពិពណ៌នា |
|---|---|---|
| ១៩៩៦ | ផែនការសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន | ជាផែនការជំនួសឱ្យកម្មវិធីសហប្រតិបត្តិការនៃគម្រោងឧស្សាហកម្មរបស់អាស៊ាន។ ជាការជំរុញឱ្យមានសកម្មភាពឧស្សាហកម្មរួមរវាងបណ្ដាក្រុមហ៊ុនក្នុងអាស៊ាន។ ផែនការសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន បង្កើតការយកពន្ធ តាមអត្រាពន្ធគយដោយអនុគ្រោះចាប់ពី ០ ដល់ ៥ ភាគរយ។ |
| ១៩៩៧ | ប្រទេសភូមា និងឡាវចូលជាសមាជិកអាស៊ាន | |
| ១៩៩៧ | ទស្សនៈវិស័យអាស៊ានឆ្នាំ២០២០ | ការកំណត់ទស្សនៈវិស័យអាស៊ានសម្រាប់ឆ្នាំ២០២០ រួមទាំងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ និងការប្ដេជ្ញាចិត្តបង្កើតឱ្យមាន "សេដ្ឋកិច្ចអាស៊ានដែលមានស្ថិរភាពមានការរីកចម្រើន និងមានការប្រកួតប្រជែងខ្ពស់ក្នុងតំបន់ដែលអនុញ្ញាតឱ្យមានលំហូរទំនិញ សេវា និងការវិនិយោគ លំហូរមូលធនដោយសេរី ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និងការកាត់បន្ថយភាពក្រីក្រ និង វិសមភាពសេដ្ឋកិច្ចសង្គមកិច្ច"។ |
| ១៩៩៨ | កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីតំបន់វិនិយោគអាស៊ាន | កិច្ចព្រមព្រៀងនេះមានគោលបំណងធានាឱ្យមានលំហូរវិនិយោគ (ក្នុងផ្នែកកម្មន្តសាល ជលផល ព្រៃឈើ ធនធានរ៉ែ កសិកម្ម និងសេវា) ត្រឹមឆ្នាំ២០២០។ ប្រទេសជាសមាជិកបានកំណត់ពេលវេលាលុបចោលនូវខដាក់លក្ខខណ្ឌក្នុងឆ្នាំ២០១៥សម្រាប់វិនិយោគិន និងក្នុងឆ្នាំ២០២០សម្រាប់វិនិយោគិនមិនមែនមកពីបណ្ដាប្រទេសជាសមាជិកអាស៊ាន។ ប្រទេសស្ថាបនិកអាស៊ានទាំង៦ (ប្រទេសស្ថាបនិកអាស៊ាន និងប្រទេសប្រ៊ុយណេ) បានព្រមព្រៀងធ្វើការពន្លឿនដំណើរការលុបចោលខដាក់លក្ខខណ្ឌក្នុងវិស័យកម្មន្តសាលសម្រាប់និយោគិនអាស៊ានត្រឹមឆ្នាំ២០០៣ និងអ្នកវិនិយោគទាំងអស់ត្រឹមឆ្នាំ២០១០។ |
| ១៩៩៨ | ផែនការសកម្មភាពទីក្រុងហាណូយ | ជាផែនការសកម្មភាពដំបូងក្នុងចំណោមផែនការសកម្មភាពជាច្រើនដែលជួយដល់ការអនុវត្តទស្សនៈវិស័យរបស់អាស៊ានឆ្នាំ២០២០។ ផែនការសកម្មភាពនេះបានកំណត់ពីជំហានក្នុងការលើកកម្ពស់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចសម្រាប់រយៈពេល ១៩៩៩ ដល់ ២០០៤។ |
| ឆ្នាំ១៩៩៩ | ប្រទេសកម្ពុជាចូលរួមជាសមាជិកអាស៊ាន | |
| ឆ្នាំ២០០០ | គំនិតផ្ដួចផ្ដើមស្ដីពីការធ្វើសមាហរណកម្មអាស៊ាន | មានគោលដៅដោះស្រាយគម្លាតអភិវឌ្ឍន៍រវាងរដ្ឋជាសមាជិកតាមរយៈគម្រោងហេដ្ឋារចនាសម្ព័ន្ធសិក្សា (ដូចជាការបណ្ដុះបណ្ដាល ការសិក្សាបច្ចេកទេស និងការកសាងសមត្ថភាព) និងគម្រោង ហេរដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការប្រាស្រ័យទាក់ទង ព្រមទាំងមានគោលដៅកៀរគរធនធានពី ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសអភិវឌ្ឍន៍សម្រាប់ជាជំនួយ។ រហូតមកដល់សព្វថ្ងៃនេះ មានគម្រោងប្រហែល ២៥៨ ដែលបានបញ្ចប់សព្វគ្រប់។ |

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍សំខាន់ៗ | ការពិពណ៌នា |
|---|---|---|
| ខែតុលា ឆ្នាំ២០០៣ | សេចក្តីប្រកាសកិច្ចព្រមព្រៀងអាស៊ាន ២ : សហគមន៍អាស៊ាននៅត្រឹមឆ្នាំ ២០២០ (កិច្ចប្រជុំកំពូលអាស៊ានលើទី៩ ឬកិច្ចព្រមព្រៀងកោះបាលី ២) | កិច្ចព្រមព្រៀងនេះបានយល់ព្រមបង្កើតសហគមន៍អាស៊ាននៅត្រឹមឆ្នាំ២០២០ ដែលមានសសរស្តម្ភ ឬសហគមន៍បីដោយផ្អែកលើកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ និងសន្តិសុខ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងសង្គមវប្បធម៌។ សហគមន៍សេដ្ឋកិច្ចអាស៊ាន គឺជាគោលដៅចុងក្រោយបង្អស់របស់ដំណើរការសមាហរណកម្មសេដ្ឋកិច្ច ដែលមានចែងក្នុងចក្ខុវិស័យអាស៊ាន។ មានការកំណត់ពីវិស័យអាទិភាពទាំង ១១ សម្រាប់ពន្លឿនសមាហរណកម្ម។ |
| ខែវិច្ឆិកា ឆ្នាំ២០០៤ | កម្មវិធីសកម្មភាពវៀតទៀង | អ្នកទទួលបានជោគជ័យក្នុងផែនការសកម្មភាពទីក្រុងហាណូយក្នុងការជួយសម្រេចនូវចក្ខុវិស័យអាស៊ាន និងសហគមន៍អាស៊ាន។ ការជួយនេះចាប់ពីឆ្នាំ២០០៤ ដល់ ២០១០។ |
| ខែវិច្ឆិកា ឆ្នាំ២០០៤ | កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសម្រាប់សមាហរណកម្មវិស័យអាទិភាព | រួមមានផែនការសម្រាប់វិស័យអាទិភាពនីមួយៗ ដែលកំណត់វិធានការក្នុងការអនុវត្ត និងពេលវេលាកំណត់សម្រាប់ការអនុវត្តរបស់ខ្លួន។ |
| ខែមករា ឆ្នាំ២០០៧ | សហគមន៍អាស៊ាននៅត្រឹមឆ្នាំ ២០១៥ | ថ្នាក់ដឹងនាំក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១២ បានយល់ព្រមពន្លឿនការបង្កើតសហគមន៍អាស៊ាន កាលបរិច្ឆេទគោលដៅគឺ នៅឆ្នាំ២០១៥។ |
| ខែវិច្ឆិកា ឆ្នាំ២០០៧ | ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន | ថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៣ បានអនុម័តផែនការសេដ្ឋកិច្ចអាស៊ាន ដែលផ្តល់ក្របខ័ណ្ឌសម្រាប់ការសម្រេចបានសហគមន៍សេដ្ឋកិច្ចអាស៊ាននៅត្រឹមឆ្នាំ២០១៥។ |
| ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ | បានអនុវត្តធម្មនុញ្ញអាស៊ាន | បង្កើតក្របខ័ណ្ឌច្បាប់ និងស្ថាប័នសម្រាប់អាស៊ាន |
| ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ | បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន | កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ានបន្ថែមទៅក្នុងការការពារវិនិយោគិនក្រោមកិច្ចព្រមព្រៀងក្រខ័ណ្ឌស្តីពីតំបន់វិនិយោគរបស់អាស៊ានតាមរយៈមធ្យោបាយមួយចំនួនៈ រួមមានបទបញ្ញត្តិការពារ និងសេរីភាវូបនីយកម្មវិនិយោគទូលំទូលាយ រួមទាំងការហាមឃាត់លក្ខខណ្ឌបំពេញការងារ និងរួមមានដំណើរដោះស្រាយជម្លោះរវាងរដ្ឋ និងវិនិយោគិន ព្រមទាំងការពង្រីកអត្ថប្រយោជន៍សម្រាប់វិនិយោគិនបរទេស វិនិយោគិនអាស៊ាន។ ក្របខ័ណ្ឌកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន គឺជាក្របខ័ណ្ឌដែល "មិនទាន់បានសម្រេច" រដ្ឋសមាជិកនីមួយៗ ក៏ចងក្រងខដាក់លក្ខខណ្ឌ ឬត្រូវលុបចេញពីកិច្ចព្រមព្រៀងនេះ។ |

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍សំខាន់ៗ | ការពិពណ៌នា |
|---|---|---|
| ខែមិនា ឆ្នាំ២០០៩ | ផែនទីយុទ្ធសាស្ត្រសម្រាប់សហគមន៍អាស៊ាន ឆ្នាំ២០០៩-២០១៥ | ផែនការនេះ រួមមានផែនការលម្អិតស្តីពីសហគមន៍សេដ្ឋកិច្ច ( អនុម័តឆ្នាំ ២០០៧) ផែនការលម្អិតស្តីពីសន្តិសុខនយោបាយរបស់សហគមន៍ ផែនការលម្អិតស្តីពីសហគមន៍សង្គមវប្បធម៌ និងផែនការការងារស្តីពីគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ។ ផែនការនេះ ជាផែនការជំនួសឱ្យកម្មវិធីសកម្មភាពទីក្រុងវៀងច័ន្ទ ។ |
| ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ | កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ានចូលជាធរមាន | កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន បង្កើតឡើងផ្អែកលើគំនិតផ្តួចផ្តើមទាក់ទងនឹងពាណិជ្ជកម្មទំនិញ ( ឧទាហរណ៍ CEPT-តំបន់ពាណិជ្ជកម្មអាស៊ានសេរី វិធានការមិនយកពន្ធ ពន្ធគយ ច្រកចេញចូលអាស៊ានតែមួយ កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក ។ល ។) ។ គោលដៅនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីសម្រេចឱ្យបានលំហូរទំនិញដោយសេរីដើម្បីបង្កើតទីផ្សារតែមួយ និងផលិតកម្មដែលអាចឈានទៅសម្រេចសហគមន៍សេដ្ឋកិច្ចអាស៊ាននៅត្រឹមឆ្នាំ ២០១៥ ។ |

*ប្រភព : USITC និន្នាការថ្នាក់តំបន់របស់អាស៊ានក្នុងការធ្វើសហមាហរណកម្មសេដ្ឋកិច្ច ការនាំចេញការប្រកួតប្រជែង និងការវិនិយោគនាំផលចំណេញចូលក្នុងប្រទេសសម្រាប់ឧស្សាហកម្មដែលបានជ្រើសរើស ។ ឆ្នាំ២០១០ : ២.២-២.៣ ។*

Cambodia

**United Nations Development Programme**
**No. 53, Pastuer Street**
**P.O. Box 877**
**Phnom Penh**
**Cambodia**

**www.un.org.kh/undp**

AUGUST 2011